


# ទស្សនាវដ្ដី
# វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម



ឆ្នាំទី៣
លេខ១

ចេញផ្សាយប្រចាំឆមាស
ការផ្សាយរបស់វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម

ខែមករា - មិថុនា
ឆ្នាំ២០២៤

# និពន្ធនាយក

*ដោយៈ ឯកឧត្តមបណ្ឌិត* **ផុន កសិកា**

# រៀបចំចងក្រង

*ដោយៈ លោក* **ប៉ាន់ សំណាង**

# រចនាក្រប

*ដោយៈ លោក* **ហ៊ាង សុចិត្រា**

*អាសយដ្ឋាន* : *មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ*
*(ជាប់បរិវេណសាកលវិទ្យាល័យភូមិន្ទភ្នំពេញ មណ្ឌល២)*

*គេហទំព័រ* (Website) : https://ihss.rac.gov.kh

*ហ្វេសប៊ុក*(Facebook) : https://web.facebook.com/
*វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*

# កថាមុខ

*រាជបណ្ឌិត្យសភាកម្ពុជា ជាស្ថាប័នស្រាវជ្រាវវិទ្យាសាស្ត្ររបស់ជាតិ ដែលប្រមូលផ្តុំដោយបញ្ញវន្ត និងអ្នកស្រាវជ្រាវជាន់ខ្ពស់ពីគ្រប់មជ្ឈដ្ឋានក្នុងព្រះរាជាណាចក្រកម្ពុជា ហើយត្រូវបានរាជរដ្ឋាភិបាលចាត់ទុកជាធនាគារខួរក្បាលដ៏សំខាន់របស់ជាតិ។*

*រាជបណ្ឌិត្យសភាកម្ពុជា មានតួនាទីយ៉ាងសំខាន់ក្នុងការសិក្សាស្រាវជ្រាវលើគ្រប់វិស័យទាំងអស់ ដើម្បីផ្តល់ធាតុចូលជូនរាជរដ្ឋាភិបាលសម្រាប់បម្រើដល់កិច្ចការស្តារ និងអភិវឌ្ឍសេដ្ឋកិច្ចសង្គម។ ជាមួយគ្នានេះដែរ វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម គឺជាសេនាធិការមួយរបស់រាជបណ្ឌិត្យសភាកម្ពុជា ដែលមានភារកិច្ចជាច្រើនស្រាវជ្រាវលើវិស័យមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម ក្នុងគោលបំណងរួមចំណែក អភិវឌ្ឍប្រទេសកម្ពុជា អភិវឌ្ឍស្មារតី ចំណេះដឹង ពង្រីកសមត្ថភាពធនធានមនុស្ស ព្រមទាំងបោះពុម្ពផ្សព្វផ្សាយលទ្ធផលនៃការសិក្សាស្រាវជ្រាវរបស់ខ្លួនក្នុងស្មារតីសន្តិភាព អភិវឌ្ឍនភាព ភាពសុខដុមរមនា ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ក៏ដូចជារាជបណ្ឌិត្យសភាកម្ពុជា។*

*ស្របតាមតួនាទីភារកិច្ចរបស់ខ្លួន វិទ្យាស្ថានមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គមបានបង្កើតទស្សនាវដ្តីមួយដែលមានឈ្មោះថា «**ទស្សនាវដ្តីមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម**» ដើម្បីរៀបចំចងក្រង និងបោះពុម្ពផ្សាយលទ្ធផលស្រាវជ្រាវរបស់ថ្នាក់ដឹកនាំ មន្ត្រីវិទ្យាស្ថាន អ្នកស្រាវជ្រាវរបស់រាជបណ្ឌិត្យសភាកម្ពុជា ក៏ដូចជាលទ្ធផលស្រាវជ្រាវបែបវិទ្យាសាស្ត្រពីគ្រប់មជ្ឈដ្ឋានផងដែរ។ **ទស្សនាវដ្តីមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម** ប្រមូលផ្តុំដោយអត្ថបទទាក់ទងទៅនឹងប្រធានបទណាមួយ របកគំហើញថ្មីៗ និងអត្ថបទទស្សនៈរបស់អ្នកនិពន្ធជាដើម ក្នុងគោលបំណងចែករំលែកចំណេះដឹងទៅកាន់មជ្ឈដ្ឋានអ្នកស្រាវជ្រាវ សិស្ស និស្សិត ក៏ដូចជា អ្នកអានទូទៅផងដែរ។*

*យើងខ្ញុំសង្ឃឹម និងជឿជាក់ថា «**ទស្សនាវដ្តីមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម**» នៃវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គមនៃរាជបណ្ឌិត្យសភាកម្ពុជា ពិតជាផ្តល់នូវមូលដ្ឋានឯកសារសម្រាប់សិស្ស និស្សិត អ្នកស្រាវជ្រាវទូទៅ ធ្វើការសិក្សាស្រាវជ្រាវបន្តទៀត។*

*ថ្ងៃព្រហស្បតិ៍ ២កើត ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៧*

*រាជធានីភ្នំពេញ ថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ២០២៤*

**ប្រធានវិទ្យាស្ថាន**

**បណ្ឌិត ផុន កសិកា**

# មាតិកា

*ទំព័រ*


១- ប្រាសាទព្រះធាតុបារាយណ៍ និង រចនាសម្ព័ន្ធបុរាណវត្ថុ នៅជុំវិញតំបន់ប្រាសាទ.................................១

បណ្ឌិត ផុន កសិកា

២-សំណង់ប្រាសាទក្នុងស្រុកកំពង់លែងនៃដែនដីអាណាចក្រចេនឡា.................................................១៧

បណ្ឌិត ផុន កសិកា

៣-ភ្នំបូរី និងទំនាក់ទំនងជាមួយអង្គរបូរី.........................................................................................៤៣

បណ្ឌិត ផុន កសិកា

៤- អេលីត និងទ្រឹស្តីអេលីត, Elite and Theories of Elite..............................................................៥៨

បណ្ឌិត អ៊ុំ ប៉ុម

៥- ប្រវត្តិស្រុករតនមណ្ឌល និងរមណីយដ្ឋានទេសចរណ៍.................................................................៦៥

លោក សួ ប៊ុណ្ណារ៉ាត់

៦-សារៈសំខាន់ក្នុងការចែករំលែកចំណេះដឹង និងបទពិសោធន៍របស់ស្ត្រី...............................................៨៥

លោកស្រីបណ្ឌិត ជា វណ្ណី

៧-ស្វែងយល់ពីជំងឺធ្លាក់ទឹកចិត្តនិងដំណោះស្រាយ.......................................................................៩៣

លោកស្រីបណ្ឌិត ជា វណ្ណី

៨-ស្ត្រីក្នុងភាពជាអ្នកដឹកនាំ.......................................................................................................១០១

បណ្ឌិត ទុយ យូឃីម និងលោកស្រីបណ្ឌិត ជា វណ្ណី

៩-.មែកធាងចម្បងៗនៃទស្សនវិជ្ជា...............................................................................................១២៧

បណ្ឌិត ហែម ឡាច

១០- ទស្សនវិជ្ជាហិណ្ឌូះ ទ្រឹស្តីសំសារៈ និង មោក្ស.......................................................................១៥០

បណ្ឌិត ប៉ាន់ វុត្ថា

១១-ទស្សនៈ និងជំនឿតូតឹមនិយមរបស់ជនជាតិខ្មែរ........................................................................១៥៧

បណ្ឌិត ប៉ាន់ វុត្ថា

១២-ភ្នំពេញ និងបម្លាស់លំនៅ..... .......................................................................................១៧៩

លោក ហៃ សុគន្ធា

១៣-សេដ្ឋកិច្ចវិទ្យានៃការបោះបង់ការសិក្សានៅវិទ្យាល័យ....................................................................១៩៣

បណ្ឌិត សូ សុធីរ

១៤-សេដ្ឋកិច្ចវិទ្យានៃការបោះបង់ការសិក្សានៅមធ្យមសិក្សា...............................................................២០៩

បណ្ឌិត សូ សុធីរ

១៥-ប្រវត្តិឧត្តមសិក្សាកម្ពុជាពីឆ្នាំ១៩៤៦ ដល់ឆ្នាំ១៩៦៧................................................................២២២

បណ្ឌិត សុង ស៊ីណា

១៦-គុណតម្លៃនៃអំណាន..........................................................................................................២៤០

លោក ប៉ាន់ សំណាង

១៧-ផលវិបាកនៃក្មេងទំនើងចំពោះសង្គម...............................................................................២៦១

លោក ប៉ាន់ សំណាង

១៨-វិន័យគ្រួសារ ជាគ្រឹះរឹងមាំជួយកុមារក្លាយជាមនុស្សធំដ៏ជោគជ័យក្នុងសង្គម................................២៧៦

លោក ប៉ាន់ សំណាង

១៩-ទស្សនវិជ្ជាសង្គម..............................................................................................................២៩២

លោក ឈុន ផារ៉េង

២០-ទស្សនៈស្តីពីជីវិតរបស់ព្រះពុទ្ធសមណគោតម.........................................................................៣០៧

លោក ឈុន ផារ៉េង

២១-ការអនុវត្តកិច្ចសន្យាពាណិជ្ជកម្មអន្តរជាតិ............................................................................៣២១

បណ្ឌិត មិន ប្រុសបញ្ញារិទ្ធិ

# ប្រាសាទព្រះធាតុបារាយណ៍ និង រចនាសម្ព័ន្ធបុរាណវត្ថុ នៅជុំវិញតំបន់ប្រាសាទ

*ដោយៈ* **បណ្ឌិត ផុន កសិកា**

*ប្រធានវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*

*រាជបណ្ឌិត្យសភាកម្ពុជា*

Email: kaseka1975@yahoo.com

## សេចក្តីផ្តើម

*ប្រទេសកម្ពុជាគឺជាប្រទេសមួយដែលសម្បូរទៅដោយសម្បត្តិបេតិកភណ្ឌរូបី (កេរដំណែលបន្សល់ពីដូនតាតាំងពីសម័យបុរាណ)។ សម្បត្តិបេតិកភណ្ឌទាំងនោះរួមមានប្រាសាទបុរាណ វិហារពុទ្ធសាសនាបុរាណ ស្ពានបុរាណ ឡបុរាណ ផ្លូវបុរាណ ភូមិដ្ឋានបុរាណ បារាយណ៍ ឡកុលាលភាជន៍ ជាដើម ។ល។*

*ប្រាសាទព្រះធាតុបារាយណ៍គឺជាប្រាសាទបុរាណមួយចាត់ទុកថាជាសម្បត្តិបេតិកភណ្ឌជាតិ ត្រូវបានកសាងនៅក្នុងទឹកដីភូមិស្បាអំពិល ឃុំបារាយណ៍ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។ ទោះបីប្រាសាទនេះមានរូបរាងតូច មិនធំដូចប្រាសាទនៅតំបន់ផ្សេងៗក្នុងប្រទេសកម្ពុជាក្តី ប៉ុន្តែប្រាសាទនេះមានសំណល់គ្រឿងបង្គុំប្រាសាទមួយចំនួនដែលអាចអ្នកស្រាវជ្រាវអាចកំណត់អាយុកាលប្រាសាទ និងកំណត់រចនាបថរបស់ប្រាសាទបាន។*

*ប្រាសាទព្រះធាតុបារាយណ៍ជាប្រាសាទដែលត្រូវបានកែបន្ថែមនៅសម័យក្រោយៗមកទៀត ដោយមានការលាបកំបោរបាយអលើតួប្រាសាទ ព្រមទាំងកសាងសំណង់ទីធ្លានៅមុខប្រាសាទ។ ក្រៅពីនោះ ប្រាសាទនេះមិនត្រូវបានសាងសង់ដាច់តែឯងនោះទេ គឺមានគូទឹក បារាយណ៍ដែលជារចនាសម្ព័ន្ធបុរាណវត្ថុនៃប្រាសាទនេះ។*

*ជាធម្មតា កាលណាមានសំណង់ប្រាសាទគឺមានសគមន៍មនុស្សរស់នៅ។ មនុស្សរស់នៅបានកសាងប្រាសាទសម្រាប់គោរពបូជា។ ដូច្នេះ ភូមិដ្ឋានរបស់មនុស្សរស់*

នៅគឺនៅក្បែរទីងប្រាសាទនេះឯង។ ករណី នៅប្រាសាទព្រះធាតុបាពាយណ៍ មានស្លាក ស្នាមទីទួលជាច្រើនដែលជាតឹកតាងនៃទីទួល មានមនុស្សរស់នៅ។

អត្ថបទនេះនឹងបង្ហាញត្រួសៗអំពី សំណង់ប្រាសាទព្រះធាតុបាពាយណ៍ គ្រឿង បង្គំប្រាសាទ មានផ្តែរ ហោរជាង ជាដើម... សំណង់ជាទីផ្ទានៅមុខប្រាសាទ គូទឹក និង វត្ថុបុរាណវត្ថុមួយចំនួនទៀត។

## ១. ស្ថានភាពភូមិសាស្ត្រក្នុងតំបន់ប្រាសាទព្រះធាតុបាពាយណ៍

ប្រាសាទព្រះធាតុបាពាយណ៍ស្ថិតក្នុង ភូមិស្បាអំពិល ឃុំបាពាយណ៍ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ស្ថិតក្នុងតំបន់អតីតរាជធានី ខ្មែរសម័យកណ្តាល មានឈ្មោះថា«**ស្រីសន្ធរ**»។ ប្រាសាទនេះស្ថិតក្នុងតំបន់ភាគខាងត្បូង និង ខាងកើតទន្លេមេគង្គ នៅចន្លោះទន្លេមេគង្គ និងទន្លេតូច ក្នុងតំបន់ដែលទទួលរងឥទ្ធិពល របបទឹកទន្លេមេគង្គនៅរដូវវស្សា ធ្វើឱ្យតំបន់ នេះលិចទឹក លើកលែងតំបន់ខ្លះជាទួលដែល ត្រូវបានលើកឱ្យខ្ពស់សម្រាប់បង្កើតទីតាំងរស់ នៅ ឬបង្កើតទីសក្ការៈជាដើម (ផែនទីលេខ ១ លេខ២ និងលេខ៣)។



ផែនទីលេខ១៖ផែនទីទីតាំងស្ថានីយ(Google Earth)



ផែនទីលេខ២៖ ផែនទីឃុំបាពាយណ៍ស្ថិតក្នុងស្រុក ស្រីសន្ធរ ខេត្តកំពង់ចាម (ប្រភព៖ ឡេង សត្យា)



ផែនទីលេខ៣៖ ផែនទីឃុំបាពាយណ៍

(ផលិតផែនទីដោយៈ ឡេង សត្យា)

ប្រជាពលរដ្ឋរស់នៅតំបន់ប្រាសាទព្រះធាតុបាពយណ៍ប្រកបមុខរបរចិញ្ចឹមជីវិតជាមូលដ្ឋានដោយធ្វើកសិកម្មក្នុងរដូវវស្សាផង និងរដូវប្រាំងផង។ ប៉ុន្តែការដាំស្រូវនៅរដូវប្រាំងច្រើនជាងក្នុងរដូវវស្សា ព្រោះដីក្នុងតំបន់នេះ ពិសេសក្នុងឃុំបាពយណ៍មានដីជាស្រែប្រាំងច្រើន ព្រោះលិចទឹកនៅរដូវវស្សា។ មុខរបរសំខាន់មួយទៀតក្រៅពីធ្វើកសិកម្ម ពួកគេច្រើនប្រកបអាជីវកម្មដោយការនេសាទត្រីនៅតាមបឹង នៅតាមវង់កុង (ទំនប់មេទឹក) នៅភាគខាងត្បូង និងខាងកើត ក្នុងរដូវប្រាំង។

តាមរយៈលោក គង់ សុមុនី[1] បានឲ្យដឹងថាផ្ទៃដីសរុបរបស់ឃុំបាពយណ៍មាន ៦៤៩២ហិកតា ក្នុងនោះដីស្រែវស្សាមានចំនួន ២៣០០ហិកតា និងស្រែប្រាំងតែ១០៤០ហិកតាប៉ុណ្ណោះ។ ក្នុងនោះដែរ ទំហំផ្ទៃបឹងមានរហូតដល់២៧៨៨ហិកតា និងផ្ទៃដីភូមិចំនួន ៣២៤ហិកតា[2]។ ចំពោះផ្ទៃដីបឹង គឺគិតពីផ្ទៃបឹងដែលស្ថិតក្នុងមេទឹកផ្សេងៗក្នុងតំបន់នេះ។

## ២. តួប្រាសាទ គ្រឿងបង្គុំ និង គ្រឿងលម្អផ្សេងៗ

ប្រាសាទព្រះធាតុបាពយណ៍ជាប្រាសាទសង់លើទីទួល ជាដីលើករាងចតុកោណកែង មានពីរជាន់ថ្នាក់ មានគូទឹកជុំវិញ និងផ្លូវចូលនៅទិសខាងកើត និងខាងលិច (រូបលេខ ១)។



រូបលេខ១ៈ គូទឹកប្រាសាទព្រះធាតុបាពយណ៍

ប្រាសាទព្រះធាតុបាពយណ៍គឺជាប្រាសាទមានប្រាង្គទោល សង់ពីថ្មបាយក្រៀមទទួលរងការបាក់បែក នៅសល់ត្រឹមទ្វារប៉ុណ្ណោះ (រូបលេខ២)។

[1] លោក គង់ សុមុនី គឺជាជំទប់ទី១ ឃុំបាពយណ៍ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។

[2] កិច្ចសម្ភាសន៍ជាមួយលោក គង់ សុមុនី ជំទប់ទី១ ឃុំបាពយណ៍ នៅថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២៣។



រូបលេខ២២៖ តួប្រាសាទព្រះធាតុបារាយណ៍ (រូបថតឆ្នាំ២០១៩)

ដោយសារមានការគោរពបូជាចំពោះប្រាសាទ អ្នកស្រុកបានសង់ដំបូលស័ង្កសីប្រក់ពីលើកំឲ្យទឹកភ្លៀងស្រក់ចូលក្នុងប្រាសាទ ប៉ុន្តែដំបូលនោះមានសភាពចាស់ទ្រុឌទ្រោមខ្លាំង។ លុះដល់ឆ្នាំ២០២០ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ដោយមានជំនួយថវិកាពីគម្រោងដៃគូ មានឈ្មោះថា «គម្រោងស្រាវជ្រាវរាជធានីសម័យកណ្ដាល និងបុរាណដ្ឋានជុំវិញ» ដែលដឹកនាំដោយលោកបណ្ឌិត Martin Polkinghorne[3] ជួយឧបត្ថម្ភថវិកាកសាងដំបូលថ្មីប្រក់ក្បឿង ក្នុងគោលបំណងអភិរក្សប្រាសាទ ទប់ស្កាត់ទឹកភ្លៀងហូរចូលប្រាសាទ ក៏ដូចជាផ្ដល់លក្ខណៈងាយស្រួលដល់ការចូលគោរពបូជារបស់ប្រជាពលរដ្ឋផងដែរ (រូបលេខ២៣)។



រូបលេខ២៣៖ ទិដ្ឋភាពប្រាសាទព្រះធាតុបារាយណ៍ បន្ទាប់ប្រក់ដំបូលថ្មីរួចនៅឆ្នាំ២០២០

តួប្រាសាទសង់ពីថ្មបាយក្រៀមភាគច្រើន និងមានលាយថ្មភក់ខ្លះ។ ថ្មបាយក្រៀមប្រើនៅតួប្រាសាទដែលមានកម្ពស់៤ម៉ែត្រ ចំណែកថ្មភក់ប្រើនៅខឿនផ្នែកខាងក្រោមនៃប្រាសាទ និងសម្រាប់គ្រឿងបង្គុំ ផ្សេងៗមានដូចជា សសរពេជ្រ ផ្ដែរ ហោរជាង ជាដើម។ ប្រាសាទមានរាងការ៉េ បួនជ្រុងស្មើ ដែលជ្រុងនីមួយៗមានប្រវែង៥៨០ស.ម.។ ទ្វារចូលនៅទិសខាងកើតមានកម្ពស់២៥០ស.ម. និងទទឹងប្រវែង១៣០ស.ម.។

[3] លោកបណ្ឌិត Martin Polkinghorne គឺជាអ្នកស្រាវជ្រាវជនជាតិអូស្ត្រាលី ដែលមានបទពិសោធន៍ស្រាវជ្រាវក្នុងប្រទេសកម្ពុជាតាំងពីឆ្នាំ២០១១ រហូតដល់បច្ចុប្បន្ន និងបានចូលរួមបណ្ដុះបណ្ដាលជំនាញដល់និស្សិតក៏ដូចជាមន្ត្រីជំនាញខ្មែរជាច្រើនទៀត។ លោកបណ្ឌិតគឺជាសាស្ត្រាចារ្យបង្រៀននៅសាកលវិទ្យាល័យ Flinders ប្រទេសអូស្ត្រាលី។



រូបលេខ២៖ ប្លង់បាតនៃប្រាសាទព្រះធាតុបារាយណ៍




ប្លង់បាតប្រាសាទព្រះធាតុបារាយណ៍

(ប្រភព៖Lajonquière, Lunet D. ( 1902 ) P. 163 )

ចំពោះទ្វារប្រាសាទ ទ្វារនៅទិសខាងកើតចំហអាចចេញចូលបាន ចំណែកទ្វារនៅខាងលិចក៏ចំហរដែរ ប៉ុន្តែត្រូវគេបិទខ្ទប់ពីឥដ្ឋជាមួយនឹងកំបោរបាយអ (រូបលេខ២)។ តាមរយៈការពិនិត្យ ទៅលើទឹកដៃនៃការបិទខ្ទប់នេះ សកម្មភាពបិទខ្ទប់ទ្វារខាងលិចប្រហែលធ្វើឡើងនៅសម័យក្រោយ។ រីឯទ្វារខាងត្បូង និងខាងជើងគឺជាទ្វារបញ្ឆោត។ តាមឯកសាររបស់លោក Lajonquière នៅឆ្នាំ១៩០២ ប្លង់ប្រាសាទព្រះធាតុបារាយណ៍នៅចំហដូចទ្វារខាងកើត។ ហេតុនេះការយកឥដ្ឋនិងកំបោរបាយអមកបិទខ្ទប់ទ្វារខាងលិចអាចកើតឡើងដំណាលគ្នានឹងសកម្មភាពលាបបូកកំបោរបាយអលើតួប្រាសាទ ក្នុងពេលណាមួយក្រោយឆ្នាំ១៩០២។



រូបលេខ២៖ រូបត្រីទស្សន៍នៃទ្វារខាងលិច

គ្រឿងបង្គុំសំណង់ប្រាសាទធ្វើពីថ្មភក់ មានដូចជា មេទ្វារ ថ្មដណ្តើរ សសរពេជ្រ (រូបលេខ៥និង៦) ផ្តែរ ហោជាង ចម្លាក់នាគនៅតាមចែងនៃប្រាសាទ និងទម្របដិមា ជាដើម។

ចំពោះសសរពេជ្រ នៅក្បាលសសរផ្នែកខាងក្រោម គេឆ្លាក់រូបអប្សរផង និង រូបឥស្សីផង។



រូបលេខ៥៖ ចម្លាក់ទេពអប្សរនៅលើជើងសសរពេជ្រ ជាប់ទ្វារចូលប្រាសាទទិសខាងកើត



រូបលេខ៦៖ ចម្លាក់ឥស្សីនៅលើជើងសសរពេជ្រ ជាប់ទ្វារចូលប្រាសាទទិសខាងកើត

គ្រឿងសំណង់ប្រាសាទមានដូចជាផ្តែរ ហោរជាងត្រូវបានតម្រៀបនៅតាមជើងទីធ្លារាងចតុកោណកែង ដែលសង់ខ្ពស់ជាងខឿនប្រាសាទ និងស្ថិតនៅពីចំពីមុខ។ គេក៏ជឿថាធ្លានេះត្រូវបានកសាងនៅសម័យក្រោយ ប៉ុន្តែមិនទាន់មានការស្រាវជ្រាវបង្ហាញពីពេលវេលានៃការសង់ធ្លានេះឱ្យបានច្បាស់លាស់នៅឡើយទេ។ ទីធ្លាមានបណ្តោយប្រវែង១៩ម៉ែត្រ ទទឹងប្រវែង៧,៧០ម៉ែត្រ និងកម្ពស់ប្រវែង១ម៉ែត្រ។ ទោះយ៉ាងណា សំណង់ទីធ្លារាងចតុកោណកែងសង់នៅពីមុខប្រាសាទ ប្រហែលជាសំណង់ព្រះពុទ្ធសាសនាសង់នៅសម័យកណ្តាល (រូបលេខ៧និង៨)។



រូបលេខ៧៖ រូបប្លង់បាតនៃទីធ្លាពង់ចតុកោណកែង



រូបលេខ៨៖ រូបថតពីលើអាកាសនៃទីធ្លាពង់ចតុកោណកែង

គ្រឿងបង្គុំសំណង់នៅតាមដើងទីធ្លាពង់ចតុកោណកែងមានក្បាច់ចម្លាក់ដែលអាចសម្គាល់បានដូចជា៖ ផ្តែរកូរសមុទ្រទឹកដោះ (រូបលេខ៩) ផ្តែរព្រះគ្រឹស្ណៈទ្រភ្នំ (រូបលេខ១០) ផ្តែររឿងរាមកេរ្តិ៍ ត្រង់ឈុតសុគ្រីពប្រយុទ្ធជាមួយពាលី (រូបលេខ១១) ផ្តែរព្រះវិស្ណុផ្ទំលើនាគ (រូបលេខ១២) ហោជាង៉ធ្លាក់ព្រះភារុណជិះលើសត្វហង្ស (រូបលេខ១៣) ផ្តែរព្រះឥសូររាំ មានទាំងព្រះព្រហ្ម និងព្រះវិស្ណុជាមួយដែរ (រូបលេខ១៤) ទ្វារបាល ព្រមទាំងរូបនាគនៅតាមចែងនៃប្រាសាទ (រូបលេខ១៥)។



រូបលេខ៩៖ ផ្តែរកូរសមុទ្រទឹកដោះ



រូបលេខ១០៖ ផ្តែរព្រះគ្រឹស្ណៈទ្រភ្នំ



រូបលេខ១១៖ ផ្តែររឿងរាមកេរ្តិ៍



*រូបលេខ១២៖ ផ្តែរព្រះវិស្ណុផ្ទុំលើនាគ*



*រូបលេខ១៣៖ ហោជាង់ឆ្លាក់រូបព្រះភារុណជិះលើសត្វហង្ស*



*រូបលេខ១៤៖ ផ្តែរព្រះឥសូររាំ ព្រះព្រហ្ម និងព្រះវិស្ណុ*



*រូបលេខ១៥៖ បដិមាទ្វារបាល នាគ ព្រមទាំងសសរពេជ្រ កំពូលប្រាសាទ និងទម្របដិមា*

ដោយសារមានចម្លាក់នៅលើផ្តែរ ហោជាង់ និងក្បាលសសរពេជ្រ ទើបយើងអាចសិក្សាវិភាគ ដើម្បីកំណត់សម័យកាល និងរចនាបថប្រាសាទនេះបាន។ ក្បាច់សំពត់មានភ្ជីទម្លាក់ចុះក្រោម និងមានក្បាច់កន្ទុយត្រីទម្លាក់ចំពីមុខ ដូចមានឆ្លាក់លើទេពទាំងឡាយនៅលើសសរពេជ្រ ផ្តែរ និងហោជាង់។ លក្ខណៈបែបនេះគឺជាលក្ខណៈនៃ រចនាបថបាពួន។ លក្ខណៈដែលអាចកំណត់បានពីលម្អក្នុងរចនាបថបាពួនបន្ថែមទៀតនោះ គឺក្ងួងសក់និងមកុដ។ ក្រៅពីមកុដ និងក្ងួងសក់ នៅមានគ្រឿងខ្លះទៀត ដូចជា មុក្តាហា (ខ្សែក ឬកងក) វណ្ណទ្រូង ជាលក្ខណៈនៃក្បាច់រចនាក្នុងសម័យរចនាបថបាពួនដែរ។ តាមរយៈក្បាច់លម្អទាំងនេះ ប្រាសាទព្រះធាតុបារាយណ៍ប្រហែលកសាងនៅសតវត្សរ៍ទី១១ ក្នុងរចនាបថបាពួន។ ប៉ុន្តែ ប្រាសាទត្រូវបានគេកែពីប្រាសាទគោរពបូជាព្រហ្មញ្ញសាសនា មកជាទីគោរពពុទ្ធសាសនាវិញ នៅសម័យក្រោយ ក្នុងពេលព្រះពុទ្ធសាសនាថេរវាទគោរពបូជាខ្លាំង។

## ៣. បារាយណ៍

នៅខាងកើតប្រាសាទ គេសង់បារាយណ៍ធំមួយដែលអ្នកស្រុកហៅឈ្មោះថា

«ស្រែបឹង» មានបណ្ដោយប្រវែង៧៥០ម៉ែត្រ (អ័ក្សកើតលិច) និងទទឹង៤៥០ម៉ែត្រ (អ័ក្សជើងត្បូង) (ផែនទីលេខ២)។



ផែនទីលេខ២៖ ផែនទីប្រាសាទព្រះធាតុបារាយណ៍ និងបារាយណ៍ ដែលអ្នកស្រុកហៅថា «ស្រែបឹង»

លោកមេភូមិស្យាអំពិលបានប្រាប់ឱ្យដឹងថា អ្នកស្រុកហៅខ្នងបារាយណ៍ថា «ថ្នល់វង់សេះ» ដោយគេមានជំនឿថា កាលពីបុរាណមានការប្រណាំងសេះលើខ្នល់បារាយណ៍នេះ[4]។

នៅចន្លោះពីប្រាសាទទៅបារាយណ៍ «ស្រែបឹង» មានរចនាសម្ព័ន្ធបុរាណវត្ថុមួយទៀត ដែលអ្នកស្រុកហៅថា «ទន្លេអុំ» ដោយអ្នកស្រុកមានជំនឿថា នៅសម័យបុរាណចាស់ៗតែងតែមកប្រណាំទូកនៅក្នុងទន្លេអុំនេះ[5]។ នេះគឺជាបារាយណ៍តូចមួយ មានបណ្ដោយប្រវែង៣២០ម៉ែត្រ និងទទឹងប្រវែង១០០ម៉ែត្រ។ ទន្លេអុំមាននៅរក្សារូបរាងខ្នងបារាយណ៍ខាងជើង ចំណែកនៅទិសផ្សេងៗទៀត ខ្នងបារាយណ៍ត្រូវបានអ្នកស្រុកឈូសទម្លាយដើម្បីពង្រីកដីធ្វើស្រែ។

នេះបង្ហាញថា ប្រាសាទព្រះធាតុបារាយណ៍មានបារាយណ៍ដែលជារចនាសម្ព័ន្ធរួមផ្សំចំនួន២ ដែលមានលក្ខណៈខុសពីប្រាសាទជាច្រើននៅក្នុងប្រទេសកម្ពុជាដែលមានបារាយណ៍តែ១។ ទោះបីប្រាសាទកសាងក្នុងសតវត្សរ៍ទី១១ ប៉ុន្តែបារាយណ៍ទាំង២មិនដឹងថា សង់នៅសតវត្សរ៍ទីប៉ុន្មានទេ ហើយក៏មិនអាចដឹងថា បារាយណ៍ទាំង២ជីកនៅសម័យដូចគ្នា ឬ ជីកនៅសម័យខុសគ្នា (ផែនទីលេខ៤ និង៥)។

---

[4] សម្ភាសលោក ម៉ៅ ម៉េន មេភូមិស្យាអំពិល ឃុំបារាយណ៍ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម នៅថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២៣។

[5] តាមការប្រាប់ពីសំណាក់លោក លឹម ព្រែក ឆ្មាំប្រាសាទព្រះធាតុបារាយណ៍ រស់នៅក្នុងភូមិស្យាអំពិល ឃុំបារាយណ៍ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម នៅថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២៣។



ផែនទីលេខ៨៖ ផែនទីបាពយណ៍ ដែលអ្នកស្រុកហៅថា «ទន្លេអុំ»



ផែនទីលេខ៩៖ ផែនទីបង្ហាញប្រាសាទ ទន្លេអុំ និងស្រែបឹង

## ៤. ទួលបុរាណ

នៅតំបន់ប្រាសាទព្រះធាតុបាពយណ៍ មិនត្រឹមតែប្រាសាទឯកឯងនោះ នៅមានទួលបុរាណជាច្រើនទៀត ដែលទួលខ្លះយើងអាចសន្និដ្ឋានថាជាប្រភេទទួលគ្រឹះប្រាសាទ ជាទួលមនុស្សរស់នៅ ទួលខ្លះអាចជាប្រភេទឡកុលាលភាជន៍ ឬ ជាទួលផ្សេងៗទៀតដែលយើងមិនអាចដឹងបាន។

មានប្រភេទទួលខ្លះជាទួលមនុស្សរស់នៅ ដែលស្ថិតនៅជុំវិញប្រាសាទ មានដូចជា ទួលកក្តី ទួលតាកឹម ទួលតាមោគ (រូបលេខ ១៦) និងទួលតាគង់ (រូបលេខ១៧), ទួលប៉ាសាន, ទួលអាស៊ុំ, ទួលទន្លេអុំ, ទួលជ្រលឹម, ទួលចន្ទកចាស់, ទួលតាឡី, ទួលវង់សេះ, ទួលសុខស ជាដើម[6]។



រូបលេខ១៦៖ ទួលតាមោគ ថតពីលើអាកាស



រូបលេខ១៧៖ ទួលតាមោគ

[6] កិច្ចសម្ភាសន៍ជាមួយលោក គង់ សុមុនី ជំទប់ទី១ ឃុំបាពណ៌ នៅថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០២៣។

មានទួលខ្លះស្ថិតក្នុងភូមិផ្សេងខុសពី ភូមិនៃទីតាំងប្រាសាទ តែស្ថិតក្នុងឃុំតែមួយ គឺ ភូមិបន្ទាយក៏មានទួលបុរាណមួយចំនួនដែរ ដូចជា ទួលត្បូង ទួលជើង ដែលទួលទាំងពីរ នេះមានស្រះមួយឈ្មោះ ស្រះស្តេច ស្ថិតនៅ ចន្លោះទួលទាំង២[7] (រូបលេខ១៨និង១៩)។



រូបលេខ១៨៖ ទួលជើង ស្ថិតក្នុងភូមិបន្ទាយ



រូបលេខ១៩៖ ទួលជើងនិងទួលត្បូងដែលមានស្រះ ស្តេចនៅចន្លោះ ស្ថិតក្នុងភូមិបន្ទាយ

ក្រៅពីទួលខាងលើនៅមានទួលមួយ ចំនួនទៀតស្ថិតនៅខាងកើតភូមិបន្ទាយ ដូចជា ទួលគុកត្នោត, ទួលអ្នកតាតាណាល, ទួលរកា, ទួលកណ្តាល, ទួលពោធិ៍ស្វាយ និងទួល អ្នកតាចាបពូក (រូបលេខ២០)។



រូបលេខ២០៖ ទួលអ្នកតាចាបពូក

ការពិត នៅមានទួលបុរាណជាច្រើន ទៀតដែលស្ថិតក្នុងឃុំបារាយណ៍ ប៉ុន្តែ ដោយសារការសិក្សាមានកម្រិត យើងមិនអាច បង្ហាញទិន្នន័យទួលបុរាណទាំងអស់ក្នុងឃុំ បានទេ។ ក្នុងករណីមានលទ្ធភាពថវិកា យើង នឹងសិក្សាស្រាវជ្រាវផ្ទៃលើ ដោយធ្វើផែនទី លម្អិតក្នុងតំបន់ឃុំបារាយណ៍នេះ។

## ៥. ទំនប់មេទឹក

[7] សម្ភាសលោក អ៊ាង អឿន គឺជាក្រុមប្រឹក្សាឃុំបារាយណ៍ នៅថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២៣។

នៅមានទំនប់មេទឹកមួយចំនួនទៀត ក្នុងឃុំបាពយណ៍។ អ្នកស្រុកច្រើនហៅទំនប់មេទឹក ឬអ្នកខ្លះក៏ថា ទំនប់វង់កុង ដោយសារទំនប់ប្រភេទនេះរាងកោងដូចចំណិតព្រះចន្ទមិនត្រង់ៗ ដូចទំនប់ផ្សេងៗទេ។

នៅក្នុងឃុំបាពយណ៍ទាំងមូល មានទំនប់មេទឹកដូចជា ទំនប់បឹងកក់មានចម្ងាយរហូតដល់ជាង២គ.ម., ទំនប់មេទឹក, ចន្ទកចាស់, ទំនប់បាយដេរ, ទំនប់បឹងនន់ស, ទំនប់បឹងឫស្សី, ទំនប់បឹងរាំង ទំនប់ថ្មីដែលនៅក្នុងទំនប់នោះមានទួលបុរាណចំនួន២ទៀត គឺ ទួលម្រេញគង្វាល និងទួលវិហារ (រូបលេខ២១ និង២២)។



*រូបលេខ២១៖ ទំនប់មេទឹកបឹងកក់*



*រូបលេខ២២៖ ទំនប់មេទឹកថ្មី*

## ៦. វត្ថុសិល្បៈផ្សេងៗ

នៅតំបន់ប្រាសាទព្រះធាតុបាពយណ៍ មានភស្តុតាងសម័យផ្សេងទៀត ក្រៅពីសម័យអង្គរ (សតវត្សរ៍ទី១១) និងសម័យកណ្ដាល។ តាមការរកឃើញជាបឋមនៃបុរាណវត្ថុ ដូចជា ឧបករណ៍ថ្មរំលីង បង្ហាញថា តំបន់នេះមានការតាំងទីលំនៅពីសម័យបុរេប្រវត្តិ ក្នុងយុគថ្មរំលីង (រូបលេខ២៣)។



*រូបលេខ២៣៖ ឧបករណ៍ថ្មមានអាយុកាលក្នុងយុគថ្មរំលីង*

កស្តុតាងបុរាណវត្ថុមួយចំនួនទៀត ដែលត្រូវបានរកឃើញនៅតំបន់ប្រាសាទព្រះធាតុបាពយណ៌ដែរ គឺបំណែកកុលាលភាជន៍ផុយ និងបំណែកកុណ្ឌី ដែលប្រភេទកុលាលភាជន៍ផុយដែរ មានដូចជាចំពួយកុណ្ឌី ខ្លួន និងបាត (រូបលេខ២៤) មានអាយុកាលក្នុងសម័យមុនអង្គរ (សតវត្សរ៍ទី៥-៦) ដែលអាចបង្ហាញថា អាយុកាលនៃការតាំងទីលំនៅក្នុងតំបន់ក៏ចាប់ពីសម័យមុនអង្គរដែរ។



រូបលេខ២៤៖ បំណែកកុលាលភាជន៍ និងកុណ្ឌី មានអាយុកាលក្នុងសម័យមុនអង្គរ

នៅមានប្រភេទកុលាលភាជន៍ផ្សេងៗទៀត ដូចជា កុលាលភាជន៍មានប្រភពមកពីតំបន់អង្គរភ្នំគូលេន, កុលាលភាជន៍ទ័ពជ័យ, កុលាលភាជន៍បុរីរម្យ, កុលាលភាជន៍ជើងឯក, កុលាលភាជន៍ចិន និងក្បឿងជាច្រើនទៀត។ ទិន្នន័យនេះក៏អាចបង្ហាញថា ទីតាំងប្រាសាទព្រះធាតុបាពយណ៌ក៏អាចជាទីតាំងផលិតកុលាលភាជន៍នៅសម័យកាលណាមួយដែរ (រូបលេខ២៥)។

ក្រៅពីប្រភេទវត្ថុបុរាណខាងលើ នៅមានបំណែកដុំឥដ្ឋជាច្រើនដែលរកឃើញនៅតាមស្ថានីយ។ ឥដ្ឋទាំងនោះអាចជាប្រភេទឥដ្ឋសម្រាប់សង់ប្រាសាទ, ឥដ្ឋសម្រាប់សង់ឡ ឬឥដ្ឋសម្រាប់សង់សំណង់គោរពបូជាផ្សេងៗទៀត នៅតាមសម័យកាលខុសៗគ្នា (រូបលេខ២៦)។



រូបលេខ២៥៖ បំណែកកុលាលភាជន៍ផ្សេងៗ



រូបលេខ២៦៖ បំណែកដុំឥដ្ឋ

មួយវិញទៀត មានបំណែកសសរពេជ្រវាងមូល(រូបលេខ២៧) ព្រមទាំងបំណែកឥដ្ឋជាច្រើនស្ថិតក្នុងប្រាសាទព្រះធាតុបាពយណ៍នេះ។ សសរពេជ្រវាងមូលគឺជាសមាសធាតុមួយនៃសំណង់ប្រាសាទក្នុងសម័យមុនអង្គរ។ ដូច្នេះហើយ ប្រាសាទព្រះធាតុបាពយណ៍ប្រហែលកសាងលើគ្រឹះប្រាសាទឥដ្ឋ សម័យមុនអង្គរ។



រូបលេខ២៧៖ សសរពេជ្រវាងមូលស្ថិតក្នុងប្រាសាទព្រះធាតុបាពយណ៍

## ៦. បញ្ហាប្រឈមនិងការគំរាមកំហែងចំពោះស្ថានីយក្នុងតំបន់ប្រាសាទព្រះធាតុបាពយណ៍

បញ្ហាប្រឈមនានាតែងតែកើតមាននៅតាមស្ថានីយបុរាណក្នុងប្រទេសកម្ពុជា ដូចជាចោរកម្ម ការគាស់កកាយរកវត្ថុបុរាណ ការជីកបំផ្លាញទួលប្រាសាទ ទួលឡ ទួលភូមិដ្ឋានមនុស្សរស់នៅ បាពយណ៍ ជាដើមៗលៗ គួរឲ្យភ័យបារម្ភទៀតនោះ ម៉ាស៊ីនអេស្កា (excavator) គឺជាឧបករណ៍កាយដីលឿនបំផុត ហើយក៏ជាអ្នកបំផ្លាញស្ថានីយបុរាណលឿនបំផុតដែរ។ កាលពីដើម អ្នកស្រុកប្រើចប កាយដីតិចតួចពីជើងទួលប្រាសាទ ដោយចំណាយពេលជាច្រើនឆ្នាំ។ សម្រាប់ម៉ាស៊ីនប្រភេទនេះវិញ គេប្រើពេលតែ១ម៉ោង ទួលប្រាសាទបាត់រូបរាងតែម្តង។

ចំពោះករណីការបាត់បង់ទួលបុរាណក្នុងតំបន់ប្រាសាទព្រះធាតុបាពយណ៍ បណ្តាលមកពីការកាប់ដីពីទួលបុរាណមកចាក់ដីបំពេញនៅក្រោមផ្ទះ ដោយប្រើរទេះសេះដឹក។ សកម្មភាពបែបនេះបានអនុវត្តមកជាយូរមកហើយ ដូច្នេះហើយទួលបុរាណមួយចំនួនធំលែងរក្សាសណ្ឋានដើម ភាគច្រើននៅសល់កម្ពស់ទាបៗ (រូបលេខ២៨)។ ដោយសារ

ស្ថានភាពភូមិសាស្ត្រក្នុងភូមិស្យាអំពិលជាដីទំនាប ទឹកលិចនៅរដូវវស្សា ដូច្នេះហើយទើបប្រជាពលរដ្ឋសម្រេចចិត្តជីកដីពីទួលមកចាក់បំពេញ។



រូបលេខ២៨៖ រទេះសេះដឹកដីដែលជីកពីទីទួលមកចាក់បំពេញក្រោមទីធ្លាផ្ទះ

នៅពេលថ្មីៗនេះ យើងសង្កេតឃើញមានម៉ាស៊ីនកាយដីធំៗជាច្រើនគ្រឿងធ្វើសកម្មភាពកាយដីពីបឹងខាងកើតប្រាសាទ មកចាក់ដីធ្វើផ្លូវ ឬ ចាក់ដីសម្រាប់សង់លំនៅដ្ឋានជាដើម។ ក្នុងករណីប្រជាពលរដ្ឋ ក៏ដូចជាអាជ្ញាធរមូលដ្ឋានមិនបានដឹងថាជាទួលបុរាណ នោះគេនឹងជួលម៉ាស៊ីនកាយដីកាយយកដីពីទួលណាមួយនោះ។ ដូច្នោះ ហានិភ័យនៃការបាត់បង់ទួលបុរាណរឹតតែខ្លាំង ប្រសិនបើមិនមានវិធានការណ៍ទប់ស្កាត់ទេនោះ។

## សន្និដ្ឋាន

ការបង្ហាញខាងលើ បញ្ជាក់ថាប្រាសាទព្រះធាតុបាពយណ៍កសាងក្នុងសតវត្សរ៍ទី១១ ក្នុងរចនាបថបាពួន និងជា ភស្តុតាងបង្ហាញថា មនុស្សរស់ក្នុងនៅតំបន់ប្រាសាទព្រះធាតុបាពយណ៍មករស់នៅនៅសតវត្សរ៍ទី១១។ លើសពីនេះ ការតាំងទីលំនៅរបស់មនុស្សមិនត្រឹមតែនៅសម័យកសាងប្រាសាទនេះទេ មនុស្សមករស់នៅតំបន់នេះតាំងពីយុគថ្មរំលីង បន្តដល់សម័យមុនអង្គរ សម័យអង្គរ សម័យក្រោយអង្គរ និងបច្ចុប្បន្នតែម្តង។

ការរៀបរាប់ខាងលើគឺការសិក្សាស្រាវជ្រាវ និងសន្និដ្ឋានដោយផ្អែកលើវិធីសាស្ត្រនៃការសិក្សាប្រៀបធៀបបុរាណវត្ថុព្រមទាំងរចនាសម្ព័ន្ធផ្សេងៗទៀត ដូចជាបាពយណ៍ ទួលប្រាសាទ ទួលបុរាណទំនប់មេទឹក ទាំងឡាយដែលរកឃើញនៅស្ថានីយដោយមិនបានយកលទ្ធផលទៅវិភាគតាមបែបបុរាណវត្ថុវិទ្យា និងធ្វើការវិភាគវិបែបទ្យាសាស្ត្រទេ។

នៅពេលថ្មីៗនេះ អ្នកស្រាវជ្រាវអន្តរជាតិនៃសាកលវិទ្យាល័យផ្លិនឌ័រ (UNIVERSITY OF FLINDERS) នៃប្រទេសអូស្ត្រាលី ដឹកនាំ

ដោយលោកបណ្ឌិត Martin Polkinghorne និង វិទ្យាស្ថានNARA ប្រទេសជប៉ុន មន្ត្រីជំនាញក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ព្រមទាំងរាជបណ្ឌិត្យសភាកម្ពុជាផង រួមសហការគ្នាសិក្សាស្រាវជ្រាវធ្វើកំណាយបុរាណវត្ថុវិទ្យា ដើម្បីស្វែងរកព័ត៌មាន និង ភស្តុតាងផ្សេងៗ ដើម្បីបង្ហាញពីកាលបរិច្ឆេទប្រាសាទព្រះធាតុបារាយណ៍ តំបន់ជុំវិញ ក៏ដូចជាកាលបរិច្ឆេទនៃការតាំងទីរាជធានីស្រីសន្ធរ តាមបែបបុរាណវត្ថុវិទ្យា និងវិទ្យាសាស្ត្រ។ លទ្ធផលនៃការសិក្សាស្រាវជ្រាវនឹងបង្ហាញជាបន្តបន្ទាប់ក្រោយពេលបេសកកម្មសិក្សាស្រាវជ្រាវបានបញ្ចប់។

**ឯកសារយោង**


១-Lajonquière, Lunet D. (1902). Inventaire Descriftif des Monuments du Cambodge, Tome I, P: 161-167

២-https://thmeythmey25.com/detail/89919 (ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២១)កិច្ចសម្ភាសន៍

៣-លោក គង់ សុមុនី គឺជាជំទប់ទី១ ឃុំបារាយណ៍ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម សម្ភាសនៅថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០២៣។

៤-លោក ម៉ៅ ម៉េន មេភូមិស្បាអំពិល ឃុំបារាយណ៍ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម សម្ភាសនៅថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២៣។

៥-លោក លឹម ព្រែក ឆ្មាំប្រាសាទព្រះធាតុបារាយណ៍ រស់នៅក្នុងភូមិស្បាអំពិល ឃុំបារាយណ៍ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម សម្ភាសនៅថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២៣។

៦-សម្ភាសលោក អ៊ាង អឿន គឺជាក្រុមប្រឹក្សាឃុំបារាយណ៍ នៅថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២៣។

# សំណង់ប្រាសាទក្នុងស្រុកកំពង់លែង នៃដែនដីអាណាចក្រចេនឡា

*ដោយៈ* **បណ្ឌិត ផុន កសិកា**

*ប្រធានវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*

*រាជបណ្ឌិត្យសភាកម្ពុជា*

Email: kaseka1975@yahoo.com

## សេចក្តីផ្តើម

*អាណាចក្រចេនឡាចាត់ទុកជារដ្ឋដំបូងៗមួយក្នុងតំបន់អាស៊ីអាគ្នេយ៍។ អាណាចក្រ ឬ រដ្ឋសំខាន់ៗ និងដំបូងបង្អស់ក្នុងដែនដីអាស៊ីអាគ្នេយ៍មានដូចជារដ្ឋហ្វូណន រដ្ឋចេនឡា និង រដ្ឋអង្គរ (អាណាចក្រអង្គរ ឬ ចក្រភពអង្គរ)*[1]*។*

*កត្តាដែលបណ្តាលឲ្យដែនដីមួយអាចត្រូវបានចាត់ទុកជារដ្ឋបានលុះណាដែនដីនោះ មានរចនាសម្ព័ន្ធគ្រប់គ្រងទឹកដីច្បាស់លាស់ ដែលជាព្រះមហាក្សត្រ ឬអាចនិយាយថា ជាទឹកដីដែលមានស្តេចគ្រប់គ្រង។ នៅមានចំណុចមួយចំនួនទៀតដូចជា មានមូលដ្ឋានប្រមូលទិន្នផល ឧទាហរណ៍ការធ្វើកសិកម្មដែលអាចប្រមូលភោគផលបានច្រើនសម្រាប់ទ្រទ្រង់រដ្ឋ។ កាលណាក្លាយជារដ្ឋបានលុះត្រាមានប្រព័ន្ធអក្សរសម្រាប់សរសេរច្បាស់លាស់។ ការគោរពប្រតិបត្តិសាសនាជាក់លាក់ណាមួយក៏ជាធាតុមួយរបស់រដ្ឋដែរ។*

*បើនិយាយអំពីអាណាចក្រចេនឡា គេរាប់បញ្ចូលតំបន់ដងទន្លេមេគង្គចន្លោះពីភ្នំពេញទៅដល់ជួរភ្នំដងរែក រួមទាំងផ្នែកផ្សេងៗទៀត មានបឹងទន្លេសាបនិងទន្លេមូល*[2]*។ នៅចន្លោះសតវត្សរ៍ទី៧-៨ អាណាចក្រនេះបានលេចចេញជារូបរាងឡើងគ្រប់គ្រងតំបន់ទំនាបទន្លេមេគង្គ ក្នុងគោលបំណងពង្រីងនិងពង្រីកវិស័យកសិកម្មនៅតាមតំបន់នេះ*[3]*។ រាជធានីរបស់អាណាចក្រចេនឡាស្ថិតនៅសម្បូរព្រៃគុក ខេត្តកំពង់ធំ។ ភស្តុតាងដែលបញ្ជាក់អំពីដែនដីនៃអាណាចក្រចេនឡាមានដូចជា សិលាចារឹក សំណង់ប្រាសាទឥដ្ឋដែលសង់*

---

[1] *ហាយហេម*, ២០១៣: ៣៦២

[2] *ហាយហេម*, ២០១៣: ៣០២

[3] *សូមអាន* Stark, 2017: 100

ក្នុងរចនាបថសម្បូរព្រៃគុក ព្រៃក្មេង និង រចនាបថកំពង់ព្រះ ព្រមទាំងបុរាណវត្ថុផ្សេងៗទៀត មានដូចជា កុលាលភាជន៍ជាដើម។

នៅតាមបណ្តាខេត្ត ស្រុក ខណ្ឌ ក្នុងប្រទេសកម្ពុជាតែងតែមានបន្សល់ទុកកស្តុតាងបុរាណវត្ថុនានា មានប្រាសាទ សិលាចារឹក កុលាលភាជន៍ ព្រមទាំងរចនាសម្ព័ន្ធបុរាណវត្ថុផ្សេងៗទៀត ដែលអាចឲ្យយើងសិក្សាកំណត់បានអំពីអត្តសញ្ញាណដែនដី និងអាយុកាល ការតាំងទីលំនៅរបស់មនុស្សនៅសម័យកាលណាមួយបាន។

ស្រុកកំពង់លែង ស្ថិតក្នុងខេត្តកំពង់ឆ្នាំង មានទីតាំងស្ថិតនៅជាប់ដងទន្លេសាប និងមានចម្ងាយ៦៥គីឡូម៉ែត្រខាងត្បូងរាជធានីចេនឡា (សម្បូរព្រៃគុក) ក៏ជាដែនដីស្ថិតក្នុងអាណាចក្រចេនឡាមួយដែរ។

អត្ថបទខ្លីមួយនេះជាអត្ថបទសម្រង់ព័ត៌មាននិងស្រាវជ្រាវដែលបានមកពីការចុះអង្កេតផ្ទាល់ និងសម្ភាសអ្នកពាក់ព័ន្ធរួមមានចាស់ទុំ ព្រឹទ្ធាចារ្យ ឆ្មាំយាមប្រាសាទ និងអាជ្ញាធរមូលដ្ឋាននៅតាមភូមិគោលដៅនៅស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង។ អត្ថបទនេះបង្ហាញអំពីរចនាបថខ្លះៗ អាយុកាល នៃសំណង់ប្រាសាទបុរាណ និងស្ថានីយបុរាណផ្សេងៗ ក្នុងស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង ដែលបង្ហាញអំពីលក្ខណៈអត្តសញ្ញាណនៃដែនដីចេនឡាកាលពីអតីតកាល។




ផែនទីស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង

## ១. ស្ថានភាពទូទៅស្រុកកំពង់លែង

ស្រុកកំពង់លែងគឺជាស្រុក១ក្នុងចំណោមស្រុកទាំង៧ ក្នុងខេត្តកំពង់ឆ្នាំង ស្ថិតនៅជាប់ដងទន្លេសាប ភាគខាងជើង ជាតំបន់លិចទឹកនៅរដូវវស្សាក្នុងតំបន់ដែលស្ថិតនៅជិតដងទន្លេ។ ស្រុកនេះមានព្រំប្រទល់ខាងកើតជាប់នឹងស្រុកបារាយណ៍ ខេត្តកំពង់ធំ ខាងលិចជាប់នឹងស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំង ខាងជើងជាប់នឹងស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ និងខាងត្បូងជាប់នឹងស្រុកជលគិរី និងក្រុងកំពង់ឆ្នាំង[4]។

ស្ថានភាពស្រុកកំពង់លែងនៅរដូវវស្សាគឺមានទឹកលិចនៅតំបន់ជុំវិញ នៅសល់តែតំបន់ភាគកណ្តាល ព្រោះជាតំបន់សម្បូរភ្នំច្រើន។ ក្នុងចំណោមភ្នំទាំងនោះ មានភ្នំនាងកង្វីដែលមានឈ្មោះល្បីល្បាញទាក់ទងនឹងរឿងព្រេង «រិទ្ធិសែននាងកង្វី» និងភ្នំទូកមាស។

នៅឆ្នាំ១៩៣៤ ខេត្តកំពង់ឆ្នាំងមានស្រុកតែ៥ទេ ដូចជា៖ ១/ស្រុករលាប្អៀរ, ២/ស្រុកបរិបូរណ៍, ៣/ស្រុកកំពង់លែង, ៤/ស្រុកកំពង់ត្រឡាច និង ៥/ស្រុកតាំងផ្គោច[5]។ នៅបច្ចុប្បន្ននេះ ស្រុកកំពង់លែងមានឃុំចំនួន៩ដូចជា៖ ឃុំប្រឡោក, ឃុំដារ, ឃុំកំពង់ហៅ ឃុំផ្លូវទូក, ឃុំពោធិ, ឃុំប្រឡាយមាស, ឃុំសំរោង, ឃុំស្វាយរំពារ និងឃុំត្រងិល។ កាលនោះដែរ ស្រុកកំពង់លែងមានទីរាជការនៅកំពង់ហាវ ឃុំដែលត្រូវធ្វើឡើងគឺ៖ ១/ឃុំកំពង់ហាវ, ២/ឃុំត្រងិល, ៣/ឃុំពោធិ, ៤/ឃុំប្រឡាយមាស, ៥/ឃុំផ្លូវទូក, ៦/ឃុំដារ, ៧/ឃុំសំរោងសែន, ៨/ឃុំស្វាយរំពារ, ៩/ឃុំពាមឆ្កោក, ១០/ឃុំប្រឡោក និង ១១/ឃុំព្រៃគគី[6]។ នៅសម័យបច្ចុប្បន្ន ស្រុកកំពង់លែង មានឃុំចំនួន៩ដូចជា៖ ឃុំប្រឡោក, ឃុំដារ, ឃុំកំពង់ហៅ, ឃុំផ្លូវទូក, ឃុំពោធិ, ឃុំប្រឡាយមាស, ឃុំសំរោង, ឃុំស្វាយរំពារ និង ឃុំត្រងិល។ បើធៀបនឹងឆ្នាំ១៩៣៥ ស្រុកកំពង់លែងមានឃុំពាមឆ្កោក និង ឃុំព្រៃគគីដែលកាត់ចូលក្នុងស្រុកជលគិរីវិញ។

ប្រជាពលរដ្ឋក្នុងស្រុកកំពង់លែងមានចំនួន៥៦៦៤៩ នាក់ មានផ្ទៃដីសរុប ៩៩៧៦៧ គីឡូម៉ែត្រក្រឡា ក្នុងនោះផ្ទៃដីព្រៃឈើចំនួន៦៦៥១៦ហិកតា ផ្ទៃដីព្រៃលិចទឹក៦១០០៥ ហិកតា ផ្ទៃដីដាំដុះចំនួន

[4] កម្មវិធីវិនិយោគបីឆ្នាំរំកិល២០២២-២០២៣ ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង, ទំព័រ IV ឆ្នាំ២០២១។

[5] ព្រះរាជប្រកាសលេខ១២ ចុះថ្ងៃទី១៣កើត ខែបុស្ស ឆ្នាំចធស័ក ព.ស. ២៤៧៧ (ថ្ងៃ១៧ ខែមករា ឆ្នាំ ១៩៣៥)

[6] ព្រះរាជប្រកាសលេខ១២ ចុះថ្ងៃទី១៣ កើតខែបុស្ស ឆ្នាំចធស័ក ព.ស. ២៤៧៧ (ថ្ងៃ១៧ ខែមករា ឆ្នាំ ១៩៣៥) ដែលប្រកាសអាវេតេ លោកឡឺរេស៊ីដង់សុប៉េរីយ៉ើរ លេខ១៨៦ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ ១៩៣៥ បញ្ញត្តិឱ្យសំរេចតាម។

១៩២៦៣ ហិកតា ផ្ទៃដីសាងសង់ចំនួន ១២១៨ហិកតា និងផ្ទៃដីផ្សេងៗទៀតចំនួន ១២៧៧០ ហិកតា[7]។ ចម្ងាយពីស្រុកកំពង់លែងមិនឆ្ងាយពីទីរួមខេត្តកំពង់ឆ្នាំងទេ ក៏ប៉ុន្តែពិបាកធ្វើដំណើរ ដោយសារខណ្ឌផ្តាច់ដោយដៃទន្លេសាបចំនួន៣។ នៅរដូវវស្សាមានផ្ទៃទឹកធំល្វឹងល្វើយ ដោយត្រូវធ្វើដំណើរតាមទូក កាណូត ឬ សាឡាង ដើម្បីឆ្លងដៃទន្លេទាំងនោះ (រូបលេខ១)។ ប្រជាពលរដ្ឋនៅស្រុកនេះភាគច្រើនគឺជាកសិករជិត៩០% ដែលប្រកបមុខរបរកសិកម្មធ្វើស្រូវវស្សាផង និង ស្រូវប្រាំងផង។ ស្រូវប្រាំងគេច្រើនធ្វើនៅនាបលិចទឹកនៅរដូវវស្សា។ នៅមានដំណាំរួមផ្សំមួយចំនួនដែលអ្នកស្រុកកំពង់លែងអាចដាំដុះបានដូចជាៈ បន្លែគ្រប់ប្រភេទ ពោត សណ្តែក ល្ពៅ ដំឡូងមី ដំឡូងជ្វា អំពៅ ស្វាយ ស្វាយចន្ទី[8]។ មុខរបរគួរឲ្យចាប់អារម្មណ៍មួយដែលអ្នកស្រុកកំពង់លែងកំពុងអនុវត្តគឺការចិញ្ចឹមសត្វគោ និង ក្របី។ នៅពេលរសៀលថ្ងៃរៀបលិច គេឃើញមានហ្វូងគោ ក្របីដើរពេញផ្លូវ និងអាចម៍គោ អាចម៍ក្របីរនេលរនោគលើដងផ្លូវ ក្នុងបណ្តាឃុំមួយចំនួន។ ក្នុងមួយគ្រួសារៗ មានគោជាច្រើនក្បាល ដែលយ៉ាងហោចណាស់ក៏មាន ២ទៅ៣ក្បាលដែរ។ គ្រួសារខ្លះមានគោផង និង ក្របីផងរហូតដល់២០ក្បាលក៏មាន (រូបលេខ២)។ ចំពោះក្របីវិញ មានក្របីច្រើនប្រភេទ។ បើភូមិណាដែលមានត្រពាំង ទំនប់ទឹក ឬថ្លុកមានទឹកដក់ច្រើន គេចិញ្ចឹមក្របីក៏ច្រើនដែរ ព្រោះក្របីអាចរកចំណីនៅក្នុងទឹកក៏បាន នៅលើគោកក៏បាន។

ជាទូទៅ អ្នកស្រុកកំពង់លែងចិញ្ចឹមគោប្រភេទគោកណ្តុរ (គោសម្ពរ) ច្រើនជាងគោពូជធំៗ។ រីឯតម្លៃគោកណ្តុរក្នុងមួយក្បាលអាចលក់បានពី៧០០ ០០០ រៀល រហូតដល់១ ២០០ ០០០ រៀល។

ចំណែកក្របីវិញ មានពូជក្របីស្រង៉ែ ក្របីសំពៅ និង ក្របីឃ្មៀច។ ក្របីស្រង៉ែមានរូបរាងតូចជាងក្របីសំពៅ ហើយតម្លៃក៏ថោកជាងក្របីសំពៅដែរ។ បើក្របីសំពៅមានតម្លៃជាង៤ ០០០ ០០០ រៀល (ជាងបួនលានរៀល) ក្របីស្រង៉ែមានតម្លៃតែជាង៣ ០០ ០០០ រៀលទេ (ជាងបីលានរៀល)។ ចំពោះក្របីឃ្មៀចវិញ ស្ទើតែផុតពូជទៅហើយ ព្រោះនៅសល់តែ៤ក្បាលគត់ ក្នុងស្រុកកំពង់លែង។

---

[7] កម្មវិធីវិនិយោគបីឆ្នាំរំកិល២០២២-២០២៣ ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង, ទំព័រ២ ឆ្នាំ២០២១។

[8] ឯកសារព័ត៌មានស្តីពី ស្ថានភាពស្រុកកំពង់លែង មន្ទីរផែនការខេត្តកំពង់ឆ្នាំង ២០២១។

នៅមានរបរនេសាទដែលអ្នកស្រុកកំពង់លែងអាចរកស៊ីបន្ថែមគ្រាន់ចិញ្ចឹមជីវិត ជាពិសេសសម្រាប់ប្រជាពលរដ្ឋដែលរស់នៅជាប់តំបន់លិចទឹកនៅរដូវវស្សា។

ប្រជាពលរដ្ឋនៅស្រុកកំពង់លែងក៏នៅមានចំណេះដឹងធ្វើសម្ភារៈ ប្រើប្រាស់ជាប្រពៃណីដូចជាការត្បាញកន្ទេលកក់ជាដើម ដែលជាមុខរបររួមផ្សំបន្ថែមទៀតក្រៅពីការងារធ្វើស្រែ (រូបលេខ២៣)។ នៅមានមុខរបរផ្សេងទៀត ដូចជា៖ លក់ដូរនៅផ្ទះ កម្មករសំណង់ កម្មករកាត់ដេរ សេវាកម្ម ចំណាកស្រុក ជាដើម។



រូបលេខ២១៖ ទិដ្ឋភាពស្រុកកំពង់លែងនៅចំណុចភ្នំនាងកង្ររី នៅរដូវវស្សា





រូបលេខ២២៖ ហ្វូងគោដើរតាមផ្លូវ ពេលចេញពីផ្ទះ ទៅរកស្មៅនៅតាមជើងភ្នំ និងក្របីឃ្វៀច



រូបលេខ២៣៖ កន្ទេលកក់ដែលអ្នកភូមិត្បាញរួចសម្រាប់យកទៅលក់

## ២. សំណង់ប្រាសាទ

### ២. ១. ប្រាសាទប្រុស (សក្ដូ[9])

ប្រាសាទប្រុស ឬ ប្រាសាទសក្ដូ (និយាមការ៖ N. 12°25′ 06.6", E. 104°47′41.3") (រូបលេខ៤) ស្ថិតក្នុងភូមិកង្កែប ឃុំច្រណូក ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង ជាប្រាសាទនៅតំបន់ទំនាប ដោយលើកដីជាទួលខ្ពស់ជាងវាលស្រែប្រហែល៣ម៉ែត្រ[10]។ ប្រាសាទនេះជាប្រាសាទឥដ្ឋ សង់នៅសម័យរចនាបថកំពង់ព្រះ (រូបលេខ៥) ដោយសារមានក្បាច់ចម្លាក់ផ្តែរនៅជាប់នឹងតួប្រាសាទ ជាផ្តែរក្នុងសិល្បៈរចនាបថកំពង់ព្រះ។ ដូច្នេះ ប្រាសាទនេះប្រហែល កសាងនៅក្នុងដើមសតវត្សរ៍ទី៨ ក្នុងសម័យចេនឡា។ ប្រាសាទប្រុសជាប្រាសាទឥដ្ឋដែលមានក្បាច់ចម្លាក់ឆ្លាក់លើតួប្រាសាទតែម្តង សូម្បីផ្តែរ សសរពេជ្រ សសរផ្អោបប្រាសាទអណ្តែតជាដើម(រូបលេខ៦ និង៧)។ ក្បាច់រចនាឆ្លាក់លើទ្វារបញ្ឆោតនៅគ្រប់ទិសគឺទិសខាងត្បូងខាងជើង និងខាងលិច។ ចំណែកនៅទិសខាងកើត គឺជាទ្វារចូលទៅក្នុងប្រាសាទ។ នៅខាងក្នុងប្រាសាទ មានសសរពេជ្រធ្វើពីថ្មភក់ និងបល្ល័ង្កថ្មភក់មួយ។

នៅជុំវិញប្រាសាទ មានគ្រឹះប្រាសាទទួលបុរាណ ភូមិបុរាណ ព្រមទាំងត្រពាំងបុរាណ ដែលបង្ហាញថា នៅជុំវិញប្រាសាទមានការតាំងទីលំនៅជាច្រើន។ ប្រាសាទនេះនៅជិតផ្លូវឆ្ពោះទៅកាន់ខេត្តកំពង់ធំ។

កាលពីប្រាំឆ្នាំមុន ប្រជាជនបាននាំគ្នាសង់ជណ្តើរស៊ីម៉ង់ ដាក់ជាប់នឹងប្រាសាទ ដើម្បីឡើងចូលទៅក្នុងប្រាសាទ គោរពបូជា (រូបលេខ៨)។ នៅឆ្នាំ២០២២ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈជួសជុល និងអភិរក្សប្រាសាទប្រុស ដោយជួសជុលពង្រឹងរចនាសម្ព័ន្ធប្រាសាទ និងដកជណ្តើរ និងកំពូលស៊ីម៉ង់ចេញ (រូបលេខ៩)។

---

[9] អ្នកស្រុកកំពង់លែង ប្រើពាក្យ «សក្ដូ» សំដៅលើអ្វីដែលមិនល្អ មិនស្អាត ជាពាក្យសម្តែងនូវលទ្ធផលអវិជ្ជមាន មិនល្អដូចគេ។ អ្នកស្រុកកំពង់លែងប្រើពាក្យនេះចំពោះប្រាសាទប្រុស (ប្រាសាទសក្ដូ) មូលហេតុមានប្រាសាទមួយទៀតឈ្មោះប្រាសាទព្រះស្រី ស្ថិតភូមិប្រាសាទ ក្នុងឃុំដារ មានទំហំធំជាង ខ្ពស់ជាង និង ស្អាតជាង (សម្ភាសលោក អោក ហៃ ឆ្មាំប្រាសាទប្រចាំការិយាល័យវប្បធម៌ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង នៅថ្ងៃទៅ២០ ខែមីនា ខែតុលា ឆ្នាំ២០២២)។ ចំណែកលោក Aymonier (Aymonier, Etienne. ( 1900 ). Le Cambodge: Le Royaume Actuel, Tome I, P: 358-363.) និង Lajonquière សរសេរឈ្មោះប្រាសាទប្រុសថា «Kalo»។

[10] លោក Lajonquière សរសេរថា « Ce temple s’élève vers l'extrémité septé trional des pentes E. du Phnom Tuk Moas. C`est un sanctuaire en briques. Carré, ouvert à IE. Élevé sur une petite boss de terrain qui domine la plaine d'une hauteur de – à 3 mitres.» (Lajonquière, Lunet D. (1902). Inventaire Descriftif des Monuments du Cambodge, Tome I, P: 200-201).



រូបលេខ២៤៖ ប្រាសាទប្រុស ឬ ប្រាសាទសក្ក





រូបលេខ២៥និង៦៖ ផ្ដែរថ្មភក់ និង ផ្ដែរធ្លាក់ជាប់នឹងជញ្ជាំងប្រាសាទ



រូបលេខ២៨៖ ក្បាច់ចម្លាក់ផ្សេងៗនៅជាប់ជញ្ជាំងប្រាសាទ មានទាំងចម្លាក់លើផ្ដែរ សសរពេជ្រ ប្រាសាទអណ្ដែត



*រូបលេខ២៨៖ កាំជណ្ដើរអ្នកស្រុកសាងសង់ពីស៊ីម៉ង់*



*រូបលេខ២៩៖ ប្រាសាទប្រុស (រូបថតខែសីហា ឆ្នាំ២០២២ បន្ទាប់ពីប្រាសាទត្រូវបានជួលជុលពង្រឹងរួច ដោយក្រសួងវប្បធម៌និងវិចិត្រសិល្បៈ)*

## ២. ២. ប្រាសាទភ្នំពណ្ណរាយ

លោក អោក ហៃ ជាឆ្មាំប្រាសាទប្រចាំស្រុកកំពង់លែង ប្រាប់ឲ្យដឹងថា ឈ្មោះប្រាសាទភ្នំពណ្ណរាយមកពីប្រាសាទនេះធ្លាប់មានបដិមាព្រះវិស្ណុ។ រីឯលោក Etienne Aymonier (ជាអ្នកស្រាវជ្រាវជនជាតិបារាំង) សរសេរថា អ្នកស្រុកខ្លះហៅប្រាសាទ «ពណ្ណរាយ» មកពីពាក្យ «ល្អប្រពៃ, ដែលភ្លឺត្រចះ» ចំណែកអ្នកស្រុកខ្លះហៅ «ប្រាសាទព្រះនរាយណ៍» ដោយសារជាប្រាសាទរបស់ព្រះវិស្ណុ[11]។

ប្រាសាទភ្នំពណ្ណរាយ (និយាមការៈ N. 12∘24′36.3", E. 104∘44′24.5") (រូបលេខ ១០) ស្ថិតក្នុងភូមិឯលិច ឃុំចំណូក ស្រុកកំពង់លែង កសាងនៅលើភ្នំឈ្មោះ ពណ្ណរាយ ដែលនៅជើងភ្នំមានសាលាឆទានដែលបានកសាងឡើងដោយមានការឧបត្ថម្ភថវិកាដោយលោកឧកញ៉ា អ៊ឹង ប៊ុនហ៊ួវ។ ភ្នំពណ្ណរាយមានកម្ពស់៥០ម សន្ធូកលើវាលទំនាបរហូតដល់ទន្លេសាប ហើយស្ថិតនៅចុងខាងជើងជួរភ្នំទូកមាសដែលជាភ្នំធំមួយក្នុងស្រុកកំពង់លែង។

នៅពេលបច្ចុប្បន្ននេះ (ឆ្នាំ២០២២) ជាប្រាសាទមានតួ២ សង់ពីឥដ្ឋ មានថ្មភក់ជាគ្រឿងបង្គុំប្រាសាទ។ ក៏ប៉ុន្តែ នៅឆ្នាំ១៩០០ និង១៩០២ ក្នុងពេលដែលលោក Etienne Aymonier និង លោក Lunet de Lajonquière មកសិក្សាស្រាវជ្រាវចុះបញ្ជីសារពើភណ្ឌប្រាសាទ តួប្រាសាទភ្នំពណ្ណរាយមានចំនួន៣[12]ស្របតាមអក្សជើង-ត្បូង។ ទោះយ៉ាងណាក៏ដោយ លោក Lunet de Lajonquière សរសេរបន្ថែមទៀតថា តួប្រាសាទខាងជើង (បច្ចុប្បន្នលែងឃើញរូបរាងហើយនោះ) ស្ថិតក្នុងភាពបាក់បែក វិចវិលខ្លាំង។ តួប្រាសាទសង់ស្មើ ជាប់ៗគ្នា ដោយចន្លោះពីតួប្រាសាទមួយទៅតួប្រាសាទមួយទៀតប្រវែងតែ៩០សង់ទីម៉ែត្រប៉ុណ្ណោះ។ តួប្រាសាទកណ្ដាលមានទំហំខាងក្នុងធំជាងគេ ប្រវែង ៤,៥ម៉ែត្រ រីឯតួកណ្ដាលពីរទៀតមានទំហំខាងក្នុងប្រវែងតែ៣,៥ម៉ែត្រ។ មានផ្តែរនៅពីមុខប្រាសាទដែលក្បាច់នោះជារចនាបថប្រែរូប (រូបលេខ១១)។ ដូច្នេះ ប្រាសាទប្រហែលក៏សាងនៅក្នុងសតវត្សរ៍ទី១០។ ចំណុចពិសេសមួយគឺ ប្រាសាទនេះបែមុខទៅទិស

[11] Aymonier, p. 359: 1900.

[12] «C`est un groupe de trois sanctuaires, en briques, carrés, alignés N-S., mais exceptionnellement ouverts à |`0 probablement à cause du Tonlè Sap qui est dans cette direction. Les portes sont san-avant-corps.» (Lajonquière, Lunet D. (1902). Inventaire Descriftif des Monuments du Cambodge, Tome I, P: 201-202)

ខាងលិច (២៥៥ ដឺក្រេ) ខុសពីប្រាសាទ ដទៃក្នុងស្រុកកំពង់លែង ហើយក៏ខុសប្លែកពីប្រាសាទជាច្រើនក្នុងប្រទេសកម្ពុជាដែរ។ លោក Lunet de Lajonquière យល់ថា ការបែមុខទៅទិសខាងជើងនៃប្រាសាទភ្នំពណ្ណរាយមកពីហេតុផលបែទៅរកបឹងទន្លេសាប[13]។ ចំណែកលោក Etienne Aymonier ក៏សន្និដ្ឋានដែរថា ដោយសារទេសភាពនៅភាគខាងលិចភ្នំពណ្ណរាយមានសម្រស់ព្រៃឈើ និងទំនាបលិចទឹកជាប់កន្ទុយភ្លែករហូតដល់បឹងទន្លេសាប ទើបគេសង់ប្រាសាទលើភ្នំពណ្ណរាយបែមុខទៅទិសខាងលិច[14]។ ករណីប្រាសាទបែមុខទៅទិសខាងលិចគឺជាបញ្ហាមួយដែលមានការពិភាក្សាគ្នាច្រើនរវាងអ្នកស្រាវជ្រាវប្រវត្តិសិល្បៈទាំងអ្នកស្រាវជ្រាវជាតិនិងអន្តរជាតិ ព្រោះមានប្រាសាទខ្លះក្នុងប្រទេសកម្ពុជាសង់បែមុខទៅទិសខាងលិច ដូចជាប្រាសាទអង្គរវត្តជាដើម។

មានវត្ថុបុរាណមួយចំនួន ត្រូវបានគេរៀបចំទុកដាក់មួយបណ្តុំចំពីមុខប្រាសាទ គឺនៅទិសខាងលិច (រូបលេខ១១២)។ លោក Lunet de Lajonquière ក៏រៀបរាប់ដែរថា នៅមានសំណល់បដិមាទេពមួយ មានដៃ៦ ប៉ុន្តែលោកសង្ស័យថា ជាបដិមាមានដៃ៨ ដូចដែលអ្នកស្រុកប្រាប់ថា នៅប្រាសាទភ្នំពណ្ណរាយមានបដិមាព្រះនារាយណ៍មួយ ប៉ុន្តែត្រូវបាត់បង់ទៅហើយ[15]។

តាមការសិក្សាស្រាវជ្រាវនៅឆ្នាំ ២០២២ ប្រាសាទភ្នំពណ្ណរាយនៅរក្សាកម្ពស់ៈ ចំពោះប្រាង្គខាងជើងមានកម្ពស់៧,១៩ ម៉ែត្រ ចំណែកតួខាងត្បូងមានកម្ពស់៧,៣៥ ម៉ែត្រ (រូបលេខ១៣និង១៤)។

ជារៀងរាល់ឆ្នាំនៅថ្ងៃទី១៥កើត ខែផល្គុន អ្នកស្រុកភូមិឯលិច ឃុំច្រណូក តែងប្រារព្ធធ្វើបុណ្យឡើងនៅលើភ្នំពណ្ណរាយរយៈ៥យប់ ៥ថ្ងៃ ដោយមានការចូលរួមពីប្រជាពលរដ្ឋយ៉ាងច្រើនកុះករផងដែរ ដើម្បីបួងសួងសុំពរជ័យសេចក្តីសុខចម្រើនដល់អ្នកភូមិនៅទីនោះ។ វិធីបុណ្យនេះ អ្នកស្រុកកំពុងលែងហៅថា «បុណ្យកម្សាន្តថ្វាយភ្នំពណ្ណរាយ»[16]។

---

[13] Lajonquière, Lunet D. (1902). Inventaire Descriftif des Monuments du Cambodge, Tome I, P: 201.

[14] Aymonier, p. 1900: 359.

[15] សម្ភាសលោក អោក ហៃ ជាឆ្មាំប្រាសាទប្រចាំនៅស្រុកកំពង់លែង។

[16] សម្ភាសលោកតាអាចារ្យ មិន ហួត អាយុ៧៤ឆ្នាំ គណៈកម្មការវត្តច្រណូក រស់នៅក្នុងភូមិឯលិច ឃុំ ច្រណូក ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង នៅថ្ងៃទី៧ ខែសីហា ឆ្នាំ២០២២។



រូបលេខ១០៖ ប្រាសាទពណ្ណរាយមើលពីមុខប្រាសាទដែលបែមុខទៅទិសខាងលិច



រូបលេខ១១៖ ផ្តែរប្រាសាទពណ្ណរាយ





រូបលេខ១២និង១៣៖ គំនរបំណែកវត្ថុបុរាណដែលគេយកមកតម្រៀបនៅមុខប្រាសាទ និង ប្លង់ប្រាសាទ



*រូបលេខ១៤៖ រូបត្រីទស្សន៍ប្រាសាទពណ្ណរាយ បង្ហាញពីកម្ពស់និងទំហំតួប្រាសាទ*



*ផែនទីភ្នំពណ្ណរាយ ស្ថិតនៅជាប់ផ្លូវពីទីរួមស្រុកមកកាន់ទីរួមឃុំច្រណូក*

## ២. ៣. ប្រាសាទព្រះស្រី[17]

*ប្រាសាទព្រះស្រីស្ថិតក្នុងភូមិប្រាសាទ ឃុំដារ (និយាមការ៖* N. 12°23′57.3", E. 104°48′40.1") (*រូបលេខ១៥, ១៦និង១៧*) *ជាប្រាសាទឥដ្ឋសង់ក្នុងរចនាបថកំពង់ព្រះ។ មានសំណង់វត្តព្រះពុទ្ធសាសនាសង់នៅជាប់ប្រាសាទ នៅជ្រុងឦសាន្ត។ វាជាប្រាសាទនៅរក្សារូបរាងល្អច្រើន មានក្បាច់រចនានៅលើតួប្រាសាទ ដូចគ្នានឹងប្រាសាទ*

[17] *លោក* Aymonier *សរសេរក្នុងអត្ថបទរបស់គាត់នៅឆ្នាំ១៩០០ថា អ្នកស្រុកខ្លះហៅព្រះស្រី ចំណែកអ្នកស្រុកខ្លះហៅថា បាស្រី ព្រោះអីមានបដិមាព្រះនាងលក្ស្មី* (Aymonier, 1900: 360)។

សក្ដៃរ។ ក្បាច់រចនានៅលើជញ្ជាំងប្រាសាទគ្រប់ជ្រុងទាំងអស់ ដោយការដាប់ជាក្បាច់ផ្សេងៗលើឥដ្ឋនៃជញ្ជាំងប្រាសាទតែម្ដង។ នៅគ្រប់ជ្រុងទាំងអស់មានចម្លាក់ក្រឡោតទាបនៃប្រាសាទអណ្ដែត។ លក្ខណៈចម្លាក់នៅរក្សាស្ថានភាពល្អបែបបនេះមិនសូវមាន ឬមានដោយកម្រណាស់សម្រាប់ប្រាសាទទាំងឡាយសង់ពីឥដ្ឋក្នុងប្រទេសកម្ពុជា ជាពិសេសប្រាសាទដែលសង់ក្នុងសម័យមុនអង្គរ។ លោក Lajonquière និង លោក Aymonier បានកត់សម្គាល់ដូចគ្នាថា ប្រាសាទព្រះស្រីនៅរក្សាស្ថានភាពដើមបានល្អជាងប្រាសាទផ្សេងៗក្នុងប្រទេសកម្ពុជា[18]។

ប្រសិនបើយើងចូលទស្សនាប្រាសាទព្រះស្រី យើងនឹងឃើញប្រាសាទហាក់ដូចជាសង់ក្នុងបរិវេណវត្ត «វត្តប្រាសាទ» នៅជាប់នឹងព្រះវិហារ។ នៅខាងលិចប្រាសាទបន្តិច ប្រហែលប្រវែងតែ១០ម៉ែត្រ យើងឃើញមានខ្ទមអ្នកតាសង់ពីស៊ីម៉ង់ចំនួន២ ខ្ទមទី១សង់ផ្ទប់ជិត ដាក់ចម្រឹងដែក ដោយនៅក្នុងនោះមានបដិមាព្រះវិស្ណុមួយ។ ការសង់បែបនេះ ដើម្បីការពារកុំឲ្យចោរលួចយកបដិមានេះចេញពីវត្ត។ ចំណែកខ្ទមអ្នកតាមួយទៀត មានដាក់បុរាណវត្ថុធ្វើពីថ្មភក់ដែលសុទ្ធសឹងជាគ្រឿងបង្គំប្រាសាទ ឬគ្រឿងលម្អប្រាសាទ ដូចជា ផ្ដែរ សសរពេជ្រ និង គ្រោងមេទ្វារនៅជាប់ជារចនាសម្ព័ន្ធមានន័យថាជា លក្ខណៈដើមនៅមេទ្វារនៅឈរបែបនេះ គឺគេគ្រាន់តែសង់ខ្ទមគ្របពីលើ។ នៅក្នុងខ្ទមអ្នកតានេះដែរក៏មានរូបអ្នកតាមួយ ប៉ុន្តែជាសំណង់សម័យថ្មី សង់ពីស៊ីម៉ង់ (រូបលេខ១៨ និង ១៩)។




រូបលេខ១៥និង១៦៖ តួប្រាសាទព្រះស្រី មានវត្តសង់ស្ទើប៉ះប្រាសាទនៅជ្រុងភ្លៀសាន្ត

[18] Aymonier, 1900: 360, និង Lajonquière, 1902: 197



រូបលេខ១៧៖ ប្លង់ប្រាសាទព្រះស្រី

 

រូបលេខ១៨និង១៩៖ ខ្ទមអ្នកតាដែលខ្ទម១ដាក់បដិមាព្រះវិស្ណុ និងខ្ទម១ទៀតដាក់មេទ្វារ

តាមរយៈទិន្នន័យស្រាវជ្រាវរបស់លោក Lajonquière នៅឆ្នាំ១៩០២ ឲ្យដឹងថាប្រាសាទព្រះស្រីមានតួប្រាសាទចំនួន៣ ហើយប្រហែលជាសង់នៅសម័យខុសគ្នា ពីព្រោះប្លង់ប្រាសាទមិនត្រូវគ្នា ហើយស្ថិតក្នុងស្ថានភាពពុកផុយខុសគ្នា។ ប្រាសាទដែលធំជាងគេមានរាងបួនជ្រុង បែមុខទៅទិសខាងកើត និងទ្វារបើកចំហរនៅទិសខាងកើត និងទ្វារបញ្ឆោតនៅទិសបីផ្សេងទៀត។ ទំហំខាងក្រៅ ៩ម៉ែត្រ និង ៦,៣០ម៉ែត្រ, ចំណែកទំហំខាងក្នុងគឺ ៥,២០ម៉ែត្រ និង ៣,៦០ម៉ែត្រ[19]។ ប្រាសាទនេះនៅមានទ្វារ

[19] Lajonquière, 1902: 197-198

ឈើនៅជាប់នឹងប្រាសាទនៅឡើយ។ ចំណែកតួប្រាសាទទី២ ស្ថិតនៅចម្ងាយ៧ម៉ែត្រ ខាងជើងបន្តិចពីប្រាសាទធំ (ប្រាសាទព្រះស្រី) មានរាងការ៉េ។ ប្រាសាទនេះបែមុខទៅទិសខាងលិច ប៉ុន្តែតួប្រាសាទផ្នែកខាងលិចដួលរលំទាំងស្រុង នៅសល់តែផ្នែកខាងកើតដែលមានទ្វារបញ្ឆោត ប៉ុន្តែមិនមានក្បាច់លម្អទេ។ នៅខាងលិច ចម្ងាយ១០ម៉ែត្រពីប្រាសាទទី១ (ប្រាសាទព្រះស្រី) មានតួប្រាសាទមួយទៀត ក៏ប៉ុន្តែដួលរលំទាំងស្រុងហើយ បន្សល់នៅតែគ្រោងមេទ្វារបែមុខទៅទិសខាងលិច មានកម្ពស់១ម៉ែត្រ ដែលលោកគិតថា គឺជាមេទ្វារប្រាសាទដូចប្រាសាទផ្សេងទៀតដែរ[20]។ (រូបលេខ២០)




*រូបលេខ២០៖ រូបភាពទូទៅមើលពីលើអាកាស បង្ហាញពីទីតាំងតួប្រាសាទដែលលោក* Lajonquière *បានរៀបរាប់ក្នុងសៀវភៅ* Inventaire Descriftif des Monuments du Cambodge

[20] *សេចក្តីដែលរៀបរាប់ក្នុងអត្ថបទគឺដកស្រង់ចេញពីអត្ថបទរបស់លោក* Lajonquière (Inventaire Descriftif des Monuments du Cambodge, Tome I) *ឆ្នាំ* 1902 *ក្នុងទំព័រ* 199។

## ២. ៤. ប្រាសាទថ្មបី្ត[21]

ប្រាសាទថ្មបី្ត (និយាមការ៖ N. 12°22′54.4″, E. 104°48′01.0″) (រូបលេខ២១) ស្ថិតក្នុងភូមិជ្រលង ឃុំដារ ស្រុកកំពង់លែង ជាប្រាសាទមានតួ២ សង់លើខឿន ដែលមានក្លោងទ្វារ តែបានបាក់ដួលរលំ។ តួប្រាសាទនៅទិសខាងជើងបាក់បែកទ្រុឌទ្រោមខ្លាំងស្ទើតែរលំនៅជញ្ជាំងខាងលិច (រូបលេខ២២, ២៣និង២៤)។ គេបានយកផ្ដែរមួយពីប្រាសាទនេះទុកក្នុងសារមន្ទីរជាតិភ្នំពេញ (រូបលេខ២២)។ តាមក្បាច់រចនាលើផ្ដែរជាក្បាច់ក្នុងរចនាបថឃ្លាំង។ ដូច្នេះប្រាសាទនេះប្រហែលសង់ក្នុងសតវត្សរ៍ទី១១។



រូបលេខ២១៖ ប្រាសាទថ្មបី្ត





រូបលេខ២២៖ ជញ្ជាំងខាងលិចនៃតួប្រាសាទខាងជើងបាក់រលំនៅសល់ដុំឥដ្ឋពីរបីដុំ



រូបលេខ២៣៖ ប្លង់បាតតួប្រាសាទខាងត្បូង



រូបលេខ២៣៖ ប្លង់បាតតួប្រាសាទខាងជើង

[21] ជាទូទៅការសិក្សាស្រាវជ្រាវចុះបញ្ជីប្រាសាទនៅដើមឆ្នាំ១៩០០ គឺមានលោក Lajonquière (១៩០២) និងលោក Aymonier (១៩០០) នៅទូទាំងប្រទេសកម្ពុជា។ ចំណែកនៅស្រុកកំពង់លែង លោកទាំង២នាក់ក៏បានចុះសិក្សានិងចុះបញ្ជីរៀបរាប់អំពីប្រាសាទមួយចំនួនដូចបានរៀបរាប់ខាងលើរួចមកហើយ។ គួរឲ្យប្លែក និង ចម្លែកដែលប្រាសាទថ្មបី្តមិនមានក្នុងអត្ថបទរបស់លោកទាំង២។ បើប្រាសាទស្ថិតក្នុងព្រៃជ្រៅ ទៅមិនដល់ ក៏មិនថាដែរ ក៏ប៉ុន្តែប្រាសាទថ្មបី្តស្ថិតក្នុងភូមិជ្រលង ឃុំដារ ដែលស្ថិតនៅចម្ងាយប្រមាណ៩០០ម៉ែត្រពីផ្លូវទៅកាន់ទីរួមស្រុកកំពង់លែង។



រូបលេខ២៤៖ ផ្ដែរយកពីប្រាសាទថ្មបុី បច្ចុប្បន្នតាំងនៅសារមន្ទីរជាតិភ្នំពេញ

## ២. ៥. ប្រាសាទតូច

ប្រាសាទតូច ស្ថិតក្នុងភូមិប្រាសាទ ឃុំដារ ស្រុកកំពង់លែង ស្ថិតនៅចម្ងាយ ៣០០ម៉ែត្រ ខាងលិចប្រាសាទព្រះស្រី នៅលើទួលធម្មជាតិទំនងជាចុងភ្នំ។ តួប្រាសាទនៅសល់កម្ពស់១ម៉ែត្រ និង ផ្ដែររចនាសម្បូរព្រៃគុក សិលាចារឹក២ផ្ទាំង ១ផ្ទាំងបែកជា២កំណាត់ សរសេរជាភាសាខ្មែរ[22]។ (រូបលេខ ២៥, ២៦និង២៧)





រូបលេខ២៥និង២៦៖ តួប្រាសាទតូច និង សិលាចារឹក



រូបលេខ២៧៖ ផ្ដែរនៅប្រាសាទតូច ស្ថិតក្នុងរចនាបថសម្បូរព្រៃគុក

[22] Lajonquière, 1902: 199

## ៣. ទួលគ្រឹះប្រាសាទ

*នៅស្រុកកំពង់លែង ក្រៅពីប្រាសាទដែលនៅមានរូបរាងនៅឡើយ នៅមានគ្រឹះប្រាសាទ ឬ ទួលប្រាសាទដែលអាចជាទីគោរពសក្ការៈបូជានៅសម័យណាមួយផងដែរ។*

### ៣. ១. ភ្នំប្រស់ព្រលឹង

*ភ្នំប្រស់ព្រលឹងមានទីតាំងស្ថិតក្នុងភូមិពោធិ៍ ឃុំពោធិ៍ (និយាមការ៖* N. 12°23′18.1" , E. 104°43′47.0")*។ ភ្នំប្រស់ព្រលឹងគឺជាទួលធម្មជាតិតូចមួយ មានថ្មក្រានីត។ នៅលើទួលមានបល្ល័ង្កថ្មភក់មួយដែលគេគោរពបូជា អុចធូបបន់ស្រន់សុំសេចក្ដីសុខ។ នៅក្បែរបល្ល័ង្កមានស្នាមរណ្ដៅជីកតូចមួយ ដែលនៅជុំវិញរណ្ដៅមានបំណែកឥដ្ឋដុតដែលជាប្រភេទឥដ្ឋសំណង់ប្រាសាទ។ បំណែកឥដ្ឋមានសណ្ឋានពុកផុយខ្លាំង ហើយជាបំណែកតូចៗ។ (រូបលេខ២៨, ២៩ និង៣០)*





*រូបលេខ២៨និង២៩៖ បល្ល័ង្កថ្មភក់ និងបំណែកឥដ្ឋប្រាសាទនៅលើទីទួលប្រស់ព្រលឹង*



*រូបលេខ៣០៖ ទិដ្ឋភាពនៃទួលប្រស់ព្រលឹង*

### ៣. ២. ទួលសំរោង

ទួលសំរោងស្ថិតក្នុងភូមិគុយ ឃុំដារ ស្រុកកំពង់លែង ស្ថិតនៅជិតដើងភ្នំដែរ គឺជាទួលប្រាសាទមានទម្រង់ដិមាមានរន្ធចំនួនបី (៣) រន្ធ២ (សងខាង) ស្ថិតនៅផ្ទៃរាបដូចទម្រផ្សេងដែរ ប៉ុន្តែរន្ធ (រន្ធកណ្ដាល) មួយស្ថិតនៅលើទម្រតូចមួយទៀត រាងមូល មានចម្លាក់ក្បាច់ត្របកឈូក។ មើលមួយភ្លែត ទម្រនេះដូចជាផ្តិលដាក់ពីលើទម្រធំ។ ទម្រតូចរាងមូលនេះជាថ្មមួយដុំជាប់គ្នានឹងទម្រធំតែម្តង (រូបលេខ៣១)។ ក្រៅពីនេះ នៅលើទួលមានដុំថ្មបាយក្រៀម និងឥដ្ឋប្រាសាទ។ នៅជុំវិញទួលប្រាសាទ មានបំណែកកុលាលភាជន៍ជាច្រើន។



រូបលេខ៣១៖ បល្ល័ង្កនៅលើទួលសំរោង

### ៣. ៣. ទួលគោកស្រុក

ទួលគោកស្រុកស្ថិតក្នុងភូមិក្នុង ឃុំស្វាយរំពារ ស្ថិតលើទួល មានថ្មបាយក្រៀម មានខ្ទមអ្នកតាស្ថិតនៅក្រោយសាលាបឋមសិក្សា ហើយមានត្រពាំងនៅខាងកើតទួល (រូបលេខ៣២)។



រូបលេខ៣២៖ ទួលគោកស្រុក

## ៣. ៤. ទួលបល្ល័ង្ក

ទួលបល្ល័ង្កស្ថិតក្នុងភូមិតាឡាប់ ភាគខាងកើត ឃុំស្វាយរំពារ មានទម្របដិមាធំមួយ លិង្គបែកជាពីរ និងមានដុំថ្មបាយក្រៀមស្ថិតក្នុងរចនាសម្ព័ន្ធសំណង់ (រូបលេខ៣៣)។



រូបលេខ៣៣៖ ទួលបល្ល័ង្កមានបល្ល័ង្ក និង បំណែកលិង្គ

## ៣. ៥. ភ្នំទេពី

ភ្នំទេពីស្ថិតក្នុងភូមិកំពង់បឹង ឃុំកំពង់ហៅ នៅជិតស្ទឹងជីនិត មានទីតាំងបុរាណចំនួន៤ទីតាំងនៅតាមកំពូលភ្នំនីមួយៗ។

-**ទួលគ្រឹះភ្នំទេពីទី១៖** ជាចំណុចទីតាំងខ្ពស់ជាងគេ មានសំណង់តម្កល់អ្នកតាព្រះនាងទេពី។ នៅទីនោះគឺជាគ្រឹះប្រាសាទ មានដុំឥដ្ឋប្រាសាទជាច្រើន មានផ្តែរក្នុងរចនាបថសម្បូរព្រៃគុក តែបែកជាពីរដុំ។ មានមេទ្វារផ្នែកខាងក្រោមយកមកប្រើជាទម្ររូបសំណាក់ទេពីបច្ចុប្បន្ន និងមេទ្វារមួយទៀតដាក់ពីមុខរូបសំណាកព្រះនាងទេពី។ នៅមានសសរពេជ្រសម័យអង្គរ។





រូបលេខ៣៤និង៣៥៖ ទីតាំងភ្នំទេពី ទីតាំងទី១ និង ផ្តែររចនាបថសម្បូរព្រៃគុក




រូបលេខ៣៦និង៣៧៖ បល្ល័ង្ក និង មេទ្វារត្រូវបានគេយកមកធ្វើជាគ្រឿងផ្សេងៗសម្រាប់សំណង់អ្នកតា



រូបលេខ៣៩៖ សសរពេជ្រ និង ដុំឥដ្ឋប្រាសាទ

## -ទួលគ្រឹះភ្នំទេពីទី២

ជាគ្រឹះប្រាសាទមួយ មានបំណែកឥដ្ឋច្រើនព្រមទាំងស្ថិតក្នុងរចនាសម្ព័ន្ធប្រាសាទ។ គេសង់សំណង់ថ្មី តែត្រូវបានគេវាយចោលវិញ។ ជាសាឡាវត្តលោកយួន (ក្នុងសម័យសង្គមរាស្ត្រនិយម ឬ សម័យលន់នុល) តែត្រូវទម្លាក់គ្រាប់បែកនៅសម័យសង្គ្រាម។ នៅឆ្នាំ១៩៨២ ទាហានរដ្ឋាភិបាលបោះទីតាំងនៅទីនេះដោយដាក់កាំភ្លើងធំនៅទីនេះផង។




រូបលេខ៤០និង៤១៖ បំណែកឥដ្ឋប្រាសាទនៅចំណុចទី២នៃភ្នំទេពី

### -ទួលគ្រឹះភ្នំទេពីទី៣

នៅលើទីតាំងធំដែលមានកុដិព្រះសង្ឃជាច្រើន។ មានសំណង់គ្រឹះប្រាសាទនៅមានកម្ពស់ជាង១ម៉ែត្រ មានឥដ្ឋ និង ថ្មបាយក្រៀមជាច្រើន។ នៅពីលើរចនាសម្ព័ន្ធសំណង់នេះមានៈ សសរពេជ្រ, កំពូលប្រាសាទ, មេទ្វារ, ប្រអប់ជើងបដិមា, ទម្របដិមា, សន្ទឹកសីមា។ នៅខាងជើងរចនាសម្ព័ន្ធសំណង់មានផ្តែររចនាបថសម្បូរព្រៃគុក ប៉ុន្តែសឹករិចរឹលខ្លាំង។




រូបលេខ៤២និង៤៣ៈ គ្រឹះប្រាសាទនិងបំណែកថ្មភក់ នៅចំណុចទីតាំងទី៣ នៃភ្នំទេពី




រូបលេខ៤៣និង៤៥ៈ បំណែកថ្មភក់ នៅចំណុចទីតាំងទី៣ នៃភ្នំទេពី



រូបលេខ៤៦ៈ បំណែកផ្តែររចនាបថសម្បូរព្រៃគុក នៅចំណុចទីតាំងទី៣ នៃភ្នំទេពី

## -ទួលគ្រឹះភ្នំទេពីទី៤

ស្ថិតនៅផ្នែកមួយទៀត ភាគខាងលិចទួលទី៣ ដែលគេសង់សំណង់ថ្មីគ្របពីលើ ហើយយើងអាចឃើញបំណែកឥដ្ឋប្រាសាទខ្លះ និង បំណែកថ្មបាយក្រៀមខ្លះដែរ។





*រូបលេខ៤៧និង៤៨៖ បំណែកឥដ្ឋប្រាសាទ នៅចំណុចទីតាំងទី៤ នៃភ្នំទេពី*




*ផែនទីទីតាំងភ្នំទេពី ស្ថិតនៅជាប់ស្ទឹងជីនិត* (ប្រភព៖ Google Earth)

## សន្និដ្ឋាន

*ការសិក្សាបង្ហាញថា មានប្រាសាទមួយចំនួនត្រូវបានសាងសង់ក្នុងស្រុកកំពង់លែង ដូចជាប្រាសាទសក្ក ឬ ប្រាសាទប្រុស, ប្រាសាទព្រះស្រី, ប្រាសាទតូច, ប្រាសាទក្នុំពណ្ណរាយ និង ប្រាសាទថ្មបុទ្ធិ។ លើសពីនេះនៅមានគ្រឹះប្រាសាទមួយចំនួនដែរ។*

*ប្រាសាទទាំងនោះសាងសង់នៅសម័យកាលខុសៗគ្នាដែរ ឧទាហរណ៍ ប្រាសាទសក្ក (ប្រាសាទប្រុស), ប្រាសាទព្រះស្រី, ប្រាសាទតូច, ទួលគ្រឹះប្រាសាទទេពីនៅកំពូលទី១, ទួលគ្រឹះប្រាសាទទេពីនៅកំពូលទី២ និង ទួលគ្រឹះប្រាសាទទេពីនៅកំពូលទី៤ សាងសង់នៅសម័យមុនអង្គរ ក្នុងរចនាបថសម្បូរព្រៃគុក និងរចនាបថកំពង់ព្រះ ប្រហែលក្នុង សតវត្សរ៍ទី៧ និងទី៨ នៃសម័យកាលចេនឡា។ ចំណែកប្រាសាទពណ្ណរាយ, ប្រាសាទថ្មបុទ្ធិ, តួប្រាសាទដែលបែមុខទៅទិសលិចនៃក្រុមប្រាសាទព្រះស្រី[23] ទួលគ្រឹះប្រាសាទទេពីនៅកំពូលទី៣ និងទួលគ្រឹះប្រាសាទខ្វះទៀតសាងសង់ក្នុងសម័យអង្គរ គឺក្នុងរចនាបថ ប្រែរូប និងរចនាបថឃ្លាំង នៃរាជព្រះបាទសូរ្យវរ្ម័នទី១ ក្នុងសតវត្សរ៍ទី១១។*

*សរុបមក ទឹកដីស្រុកកំពង់លែងគឺជាចំណែកមួយនៃដែនដីនៃអាណាចក្រចេនឡា នាសតវត្សរ៍ទី៧ និងទី៨ ដែលមានសំណង់ប្រាសាទឥដ្ឋកសាងសម្រាប់គោរពបូជាដល់ព្រះឥសូរនៃហិណ្ឌូសាសនា។*

*ទាក់ទងនឹងការតាំងទីលំនៅរបស់មនុស្សនៅស្រុកកំពង់លែង យើងដឹងហើយថា មានស្ថានីយបុរេប្រវត្តិសាស្ត្រដ៏ល្បីល្បាញមួយឈ្មោះ «ស្ថានីយសំរោងសែន» ក៏ស្ថិតក្នុងស្រុកកំពង់លែងនេះដែរ។ អត្ថបទ លោក* Lajonquière *ក៏បាននិយាយអំពីស្ថានីយសំរោងសែននេះដែរ[24] ដែលមនុស្សមកតាំងទីលំនៅប្រកបមុខរបរចិញ្ចឹមជីវិតដោយការធ្វើនេសាទ ព្រោះគេរកឃើញវត្ថុបុរាណ ដូចជា ផ្ទៃសន្ទូច ឧបករណ៍ស្មិតសំរិទ្ធ និងស្រទាប់គំនរលាសយ៉ាងក្រាស់។ ភស្តុតាងនេះបង្ហាញថា មនុស្សមករស់នៅក្នុងស្រុកកំពង់លែងតាំងពីសម័យបុរេប្រវត្តិ ហើយបន្តរស់នៅដល់សម័យហ្វូណន[25] មុននឹងឈានដល់សម័យចេនឡា។ ការតាំងទីលំនៅរបស់មនុស្សនៅក្នុងស្រុកកំពង់លែងមិនបានបញ្ចប់ ឬ រើលំនៅដ្ឋានទៅណាទេ មនុស្សបន្តរស់នៅដល់សម័យអង្គរទៀត ដែលមាន*

---

[23] *លោក* Lajonquière *បានហៅប្រាសាទព្រះស្រីថា «ក្រុមប្រាសាទព្រះស្រី* (groupe de Prah Srei)» *ដោយសារមានជាបណ្តុំប្រាសាទមានតួច្រើន។*

[24] Lajonquière 1902: 196

[25] *ភស្តុតាងកុលាលភាជន៍សម័យហ្វូណន មានដូចជា ប្រភេទកុណ្ឌី ក៏បានរកឃើញ ចំណែកទួលប្រាសាទមួយចំនួនក៏អាចកសាងក្នុងសម័យហ្វូណនដែរ។*

កស្តុតាងសំណង់ប្រាសាទភ្នំពណ្ណរាយ និងប្រាសាទថ្មបម្តី និងគ្រឹះប្រាសាទភ្នំទេពកំពូលទី៣។ សម័យក្រោយមកទៀត មនុស្សក៏មិនបោះបង់ទីតាំងនេះដែរ មនុស្សនៅបន្តរស់នៅរហូតដល់សម័យកណ្តាល[26] និងមកដល់សម័យបច្ចុប្បន្ន ដូចយើងឃើញស្រាប់។

ទីតាំងមួយដែលមានសហគមន៍មនុស្សរស់នៅបាន ហើយអាចបន្តជាហូរហែរហូតមិនដាច់ ចាប់ផ្តើមពីសម័យកាលណាមួយនោះ គឺទីតាំងនោះប្រាកដជាមានសក្តានុពលសេដ្ឋកិច្ចគ្រប់គ្រាន់សម្រាប់ទ្រទ្រង់ការចិញ្ចឹមជីវិតរបស់មនុស្ស។ ជាក់ស្តែង ស្រុកកំពង់លែងដែលជាផ្នែកនៃដែនដីអាណាចក្រចេនឡាមានភូមិសាស្ត្រអំណោយផល (មានដីខ្ពស់ ដីទំនាប ភ្នំ បឹង ព្រៃក) ដល់ការធ្វើកសិកម្មស្រូវ ទាំងស្រូវប្រាំងនិងវស្សា មានមនុស្សបន្តរស់នៅរហូតចាប់តាំងពីសម័យបុរេប្រវត្តិសាស្ត្រ។ កត្តាសំខាន់មួយទៀត ធនធានមច្ឆាទាំងឡាយទឹកសាបដែលមានក្នុងទន្លេសាប ក៏ដូចជាក្នុងដៃទន្លេ បឹង និងព្រៃកដែលមានសត្វមច្ឆាផ្សេងៗ គឺជាអាហារចាំបាច់ខ្វះមិនបានរបស់មនុស្ស តាំងពីសម័យបុរេប្រវត្តិសាស្ត្ររហូតមកដល់បច្ចុប្បន្នផងដែរ។

ដូច្នេះ ការថែរក្សាធនធានធម្មជាតិក្នុងទន្លេសាប បឹង ព្រៃក ពិតជាមានសារសំខាន់ចំពោះប្រជាជនខ្មែរ ដែលរស់រាន្តមានជីវិតតាំងពីសម័យបុរេប្រវត្តិសាស្ត្រ សម័យហ្វូណន សម័យចេនឡា សម័យអង្គរ សម័យក្រោយអង្គរ និង សម័យបច្ចុប្បន្ននេះទៀត ដោយសារមានអាហារទឹកសាបសម្រាប់ទ្រទ្រង់ជីវិត ។

[26] វិហារដែលកសាងក្នុងវត្តប្រាសាទដែលកសាងស្មើជាប់ប្រាសាទព្រះស្រី ត្រូវបានសង់ឡើងមុនឆ្នាំ១៩០០ មុនពេលលោក Etienne Aymonier និងលោក Lunet de Lajonquière មកស្រាវជ្រាវ។ លោក Lunet de Lajonquière សរសេរថា « Ce sanctuaire, à l'entrée duquel est du reste arriolée une pagode moderne, n'est pas abandonné : il contient des porte cires, des chaires de bonzes et autres ustensiles du culte Bouddhique.»។

**ឯកសារយោង**

-*ឆាល ហាយធេម, (២០១៣) វប្បធម៌ដំបូងនៃតំបន់អាស៊ីអាគ្នេយ៍ដីគោក, អង្គការបុរាណវត្ថុវិទ្យាខ្មែរ និង រាជបណ្ឌិត្យសភាកម្ពុជា។*

-Aymonier, Etienne. (1900). Le Cambodge: Le Royaume Actuel, Tome I, P: 258-263.

-Lajonquière, Lunet D. (1902). Inventaire Descriftif des Monuments du Cambodge, Tome I, P: 193-202.

-Stark, Miriam T. (2014). Pre-Angkorian and Angkorian Cambodia in Southeast Asia: From Prehistory to History, edited by Ian Glover and Peter Bellwood.

-*ព្រះរាជប្រកាសលេខ១៤ ចុះថ្ងៃទី១៣កើត ខែបុស្ស ឆ្នាំចធស័ក ព.ស. ២៤៧៧ (ថ្ងៃ១៧ ខែមករា ឆ្នាំ១៩៣៥)*

-*ឯកសារព័ត៌មានស្តីពី ស្ថានភាពស្រុកកំពង់លែង មន្ទីរផែនការខេត្តកំពង់ឆ្នាំង ២០២១។*

-*កម្មវិធីវិនិយោគបីឆ្នាំរំកិល២០២២-២០២៣ ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង, ឆ្នាំ២០២១។*

**បទសម្ភាសន៍**

-*លោកតាអាចារ្យ ម៉ិន ហួត អាយុ៧៤ឆ្នាំ គណៈកម្មការវត្តប្រណ្តូក រស់នៅក្នុងភូមិឯលិច ឃុំប្រណ្តូក ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង នៅថ្ងៃទី៧ ខែសីហា ឆ្នាំ២០២២។*

-*លោក អោក ហៃ ឆ្មាំប្រាសាទនៃការិយាល័យវប្បធម៌ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង នៅថ្ងៃទៅ ២០ ខែមីនា តុលា ឆ្នាំ២០២២។*

# ភ្នំបូរី និងទំនាក់ទំនងជាមួយអង្គរបូរី

Phnom Borei and Its Relationship with Angkor Borei

ដោយៈ បណ្ឌិត **ផុន កសិកា**
ប្រធានវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម
រាជបណ្ឌិត្យសភាកម្ពុជា

## សេចក្តីផ្តើម

អង្គរបូរី គឺជាទីតាំងនៃទីក្រុងមានកំពែងធំ ដែលជារាជធានីសម័យហ្វូណន (សតវត្សទី១ ដល់ទី៦ តាមរយៈបរិច្ឆេទវិទ្យុសកម្មធ្យូងC14 ជាទីកន្លែងមនុស្សរស់ច្រើនសតវត្សរ៍ និងនិងជាទីបញ្ចុះសពរហូតដល់ចុងសហស្សវត្សរ៍ទី១ មុន គ.ស.)។ អង្គរបូរីក៏មានកស្តុតាងមនុស្សរស់នៅរយៈពេលវែង មានសំណង់ស្ថាបត្យកម្មឥដ្ឋ និងថ្មបាយក្រៀមរូបចម្លាក់ សិលាចារិក និងជំនួញពាណិជ្ជកម្ម។ នៅមានប្រាសាទភ្នំដាដ៏ល្បីល្បាញសង់នៅលើភ្នំដា (អាស្រមមហាឬស្សី សតវត្សទី៧ និងប្រាសាទភ្នំដា ក្នុងសតវត្សរ៍ទី១១)។ តំបន់នេះមានសណ្ឋានដីជាវាលទំនាបទាប ដែលទទួលរងការជន់លិចពីភ្លៀងមូសុងប្រចាំឆ្នាំ។ ការសិក្សាស្រាវជ្រាវបុរាណវត្ថុវិទ្យា ដែលចាប់ផ្តើមពីឆ្នាំ១៩៩៥ រហូតមកដល់បច្ចុប្បន្នក៏បានរកឃើញទួលបុរាណ និង ទួលប្រាសាទមានគូទឹកព័ទ្ធជុំវិញ ដែលមានឥដ្ឋសេរ៉ាមិក និងវត្ថុបុរាណផ្សេងៗទៀតទាំងនៅក្នុងស្រុកអង្គរបូរី និងនៅតំបន់វាលទំនាបខេត្តតាកែវ។ ភាគច្រើនជាលក្ខណៈនៃការតាំងទីលំនៅ និងជាប្រាសាទ ឬទីគោរពសក្ការបូជាតូចៗ។

នៅចម្ងាយប្រមាណ៥គីឡូម៉ែត្រ ខាងត្បូងក្រុងអង្គរបូរី មានភ្នំមួយឈ្មោះថា «ភ្នំបូរី» ស្ថិតក្នុងភូមិបូរី ឃុំព្រៃកផ្លោល ស្រុកអង្គរបុរី ខេត្តតាកែវ។ នៅតាមជើងភ្នំបូរី យើងសង្កេតឃើញមានបំណែកកុលាលភាជន៍ ក៏ដូចជាឥដ្ឋដូចគ្នាទៅនឹងឥដ្ឋសង់ប្រាសាទ នៅរាយប៉ាយនៅតាមកន្លែងដែលគេព្យួរដីដាំដំណាំ ជីក ធ្វើផ្លូវ ឬ ជីកស្រះទឹកជាដើម។ ការសិក្សាប្រៀបធៀបអំពីកុលាលភាជន៍ដែលមាននៅភ្នំបូរីទៅនឹងកុលាលភាជន៍រកបានពីកំណាយអង្គរបូរី មានលក្ខណៈស្រដៀងគ្នា និងបង្ហាញថា ពេលវេលានៃការតាំងទីលំនៅនៅភ្នំបូរីក៏អាចប្រហាក់ប្រហែលគ្នានឹងពេលវេលានៃការតាំងទីលំនៅរបស់មនុស្សនៅអង្គរបូរីដែរ។

អត្ថបទនេះនឹងបង្ហាញអំពីលទ្ធផលនៃការសិក្សាស្រាវជ្រាវធ្វើកំណាយនៅភ្នំបូរី កាល

ពីខែតុលា ឆ្នាំ២០០៤ កន្លងទៅ។ ការសិក្សាស្រាវជ្រាវធ្វើកំណាយមានគោលបំណងឈ្វេងយល់អំពីទំនាក់ទំនងរវាងស្ថានីយភ្នំបូរី និងអង្គរបូរី ដែលជាស្ថានីយនៅក្បែរគ្នា។ គោលបំណងផ្សេងទៀតគឺចង់រកអាយុកាលនៃការទីតាំងលំនៅដ្ឋាននៅស្ថានីយភ្នំបូរីនេះដែរ។

ដើម្បីប្រមូលទិន្នន័យយកមកវិភាគបកស្រាយទៅតាមគោលបំណងដូចចែងនៅខាងលើ វិធីសាស្ត្រមួយចំនួនត្រូវបានយកមកប្រើមានដូចជាៈ

**ក. ការធ្វើកំណាយ**

ទីតាំងមួយចំនួនត្រូវបានកត់សម្គាល់ទុក និងធ្វើការប្រមូលវត្ថុសិល្បៈពីស្រទាប់លើស្ថានីយ។ វិធីសាស្ត្រនេះ អាចឱ្យយើងយល់ពីទីតាំងណាមួយដែលមានវត្ថុសិល្បៈច្រើនដើម្បីធ្វើកំណាយទទួលបានលទ្ធផលដូចគ្រោងទុក។

យើងបានជ្រើសរើសទីតាំងកំណាយមួយធ្វើកំណាយសាកល្បងទំហំ១ម$^{២}$ រួចទើបពង្រីករណ្តៅពីរទៀតបន្តពីរណ្តៅសាកល្បងទំហំ ២ម x ២ម។ យើងជីកដល់ជម្រៅ១,៥ម៉ែត្រ នៅគ្រប់រណ្តៅ។ កំណាយធ្វើឡើងរៀងរាល់កម្រិត១០ស.ម. ម្តងៗ (ភាសាបច្ចេកទេសជាភាសាអង់គ្លេសហៅថា SPIT)។ វត្ថុសិល្បៈក៏ត្រូវរែងយកដោយប្រុងប្រយ័ត្ន ពីព្រោះវត្ថុតូចៗនឹងបាត់ ប្រសិនបើមិនរែងនោះទេ។ ដាក់ស្តែង អង្កាំមានទំហំតូចៗ ដែលប្រមូលបានពីការរែងនេះ។ អ្នកជួយធ្វើកំណាយសម្រាប់កំណាយជ្រើសរើសពីអ្នកភូមិ ក្រោមការដឹកនាំរបស់អ្នកជំនាញបុរាណវត្ថុវិទ្យា។

**ខ. ការគូសផែនទី**

ដើម្បីកត់សម្គាល់ទីតាំងជាក់លាក់របស់ស្ថានីយនិងរណ្តៅកំណាយ ក្រុមស្រាវជ្រាវបានធ្វើការបន្ថែមមួយសប្តាហ៍ទៀត ដើម្បីបន្តការងារគូសផែនទី ដោយប្រើឧបករណ៍ GPS កត់ត្រារយៈបណ្តោយ និងរយៈទទឹង និងមានឧបករណ៍ Transit មើលរយៈកំពស់ ទីតាំងក្នុងរណ្តៅ និងជុំវិញរណ្តៅ។



ផែនទីរណ្តៅកំណាយដែលជាលទ្ធផលនៃការគូសប្លង់ និងផែនទី ដោយប្រើម៉ាស៊ីន Transit

ការគូសផែនទីរួមមានៈ (១) គូសផ្លូវពីអង្គរបូរី ទៅភ្នំបូរី (២) គូសផ្លូវព័ទ្ធជុំវិញភ្នំបូរី (៣)

គូសទីតាំងស្ថានីយដែលមើលឃើញនៅជុំវិញភ្នំ៖ មានទីតាំងធំពីរ ហើយទីតាំងទាំងពីរដាច់គ្នាដោយសារថ្មភ្នំមានរហូតដល់ដីទំនាប និង(២) កត់ត្រាចំណុចខ្ពស់បំផុតនៅលើភ្នំដែលជាទីតាំងប្រាសាទឥដ្ឋបុរាណ មានសំណល់មួយចំនួនអាចកត់សម្គាល់ថាជាគ្រឹះប្រាសាទ តែត្រូវបំផ្លាញក្នុងសម័យសង្គ្រាមនិងសម័យប៉ុលពត។



រូបលេខ១៖ បំណែកមេទ្វារប្រាសាទ នៅលើភ្នំបូរី



រូបលេខ២៖ ជុំឥដ្ឋប្រាសាទស្ថិតនៅលើភ្នំបូរី

## គ. វិធីសាស្ត្រវិភាគ

បន្ទាប់ពីធ្វើកំណាយរួច ក្រុមស្រាវជ្រាវយកកុលាលភាជន៍ប្រមូលបានពីរណ្តៅកំណាយមកសម្អាតភាជន៍នៅស្ថានីយ ក្នុងពេលយុទ្ធនាការកំណាយ។ វត្ថុសិល្បៈភាគច្រើនគឺជាកុលាលភាជន៍។

ធ្យូងគឺជាវត្ថុមួយដែលជាប្រភេទសមុច្ច័យដ៏ពិសេសសម្រាប់អ្នកស្រាវជ្រាវបុរាណវត្ថុវិទ្យា ពីព្រោះវានឹងជួយឱ្យយើងរកឃើញអាយុកាលទីតាំងដែលកំពុងស្រាវជ្រាវនេះ។ ជាក់ស្តែងក្រុមកំណាយក៏ប្រមូលបានធ្យូងក្នុងរណ្តៅកំណាយ និងមានសាកលវិទ្យាល័យជាតិសិង្ហបូរីឧបត្ថម្ភថវិកាធ្វើវិភាគអាយុកាលធ្យូង (C14)។

## ១. ភូមិសាស្ត្រ

ភ្នំបូរី មានទីតាំងស្ថិតនៅក្នុងភូមិបូរី ឃុំព្រៃកផ្ទោល ស្រុកអង្គរបុរី ខេត្តតាកែវ មានចម្ងាយប្រហែលជាប្រាំគីឡូម៉ែត្រ ភាគខាងត្បូងអង្គរបូរី នាជ្រុងខាងលិចនៃដងទន្លេមេគង្គ ដែលមានកូអរដោនេភូមិសាស្ត្រ លេខ៖ ១០° ៥៦ ខាងជើង និង ១០៤° ៥៨ ខាងកើត និងរយៈកម្ពស់ជុំវិញអង្គរបូរីផ្លាស់ប្តូរពី ២-១០ម៉ែត្រ ពីកម្ពស់ទឹកសមុទ្រ។ នៅភាគខាងត្បូងក្រុងអង្គរបូរី មានភ្នំ២ គឺ ភ្នំបូរី (១៧០ម ពីកម្ពស់ទឹកសមុទ្រ) និងភ្នំដាដែលមានប្រាសាទសម័យអង្គរ។



រូបលេខ២៣៖ ទិដ្ឋភាពទេសភាពនៅជើងភ្នំបូរី



រូបលេខ២៤៖ អ្នកស្រុកភ្នំបូរីចាប់ត្រីនៅក្នុងប្រឡាយ ជាប់ជើងភ្នំ



រូបលេខ២៥៖ អ្នកស្រុកភ្នំបូរីចាប់ត្រីនៅក្នុងទន្លេភ្នំជាប់ ជើងភ្នំបូរី

## ២. ប្រជាសាស្ត្រ និងសេដ្ឋកិច្ចចិញ្ចឹមជីវិត

យោងទៅលើជំរឿននៃក្រសួងផែនការ ក្នុងឆ្នាំ ១៩៩៨ ប្រជាជនក្នុងខេត្តតាកែវ មាន ចំនួន ៧៩០១៦៨នាក់។ ប្រជាជននៅក្នុងឃុំព្រៃកផ្ទោលមានចំនួន៦១២០ (ស្ថិតិឆ្នាំ ១៩៩៩)។ ប្រជាជននៅក្នុងភូមិភ្នំបូរីមានជីវភាព និងមុខរបរដោយផ្អែកទៅលើការធ្វើកសិកម្ម និងការនេសាទ (ស្រះ ទន្លេ ប្រឡាយ និងរដូវទឹកជំនន់) នៅរដូវប្រាំងប្រជាជនពឹងផ្អែកទៅលើការធ្វើស្រែប្រាំង និងធ្វើស្រូវវស្សានៅលើដីមួយចំនួនតូចៗ ការដាំដំណាំរួមផ្សំនៅក្បែរផ្ទះអាចដាំបានដោយសារមានទឹកយកពីព្រែកជីក និងប្រភពទឹកផ្សេងទៀត។ ការនេសាទ (សន្ទូច, មង, សំណាញ់) មានសារៈសំខាន់បំផុត។ ការចិញ្ចឹមសត្វនៅក្នុងស្រុកមានដូចជា គោ ជ្រូក ទា និងមាន់។ល។ ផលិតផលធ្វើដោយដៃធ្វើឡើងអាស្រ័យទៅតាមតម្រូវការរបស់អ្នកទិញ ប៉ុន្តែទំនិញភាគច្រើនត្រូវបានដឹកជញ្ជូនយកមកពីខេត្តតាកែវ។

ប្រជាជននៅភ្នំបូរីក៏ដូចជាប្រជាជនរស់នៅតាមដងទន្លេមេគង្គអាចធ្វើស្រែប្រាំងនៅរដូវប្រាំង។ ដំណាំស្រូវទទួលផល ចាប់ពី២តោនទៅ៣តោនក្នុងមួយហិចតា។ ភ្នំបូរី គឺជាកន្លែងមួយដែលគេស្គាល់ថាជាកន្លែងដែលអាចប្រកបមុខរបរនេសាទបាន នៅរដូវប្រាំង។ តាមរយៈទីតាំងភូមិសាស្ត្រទីនោះមានប្រឡាយដ៏ធំមួយព័ទ្ធជុំវិញភ្នំបូរី។ ប្រជាជនក្នុងតំបន់ហៅប្រឡាយនេះថា "ទន្លេភ្នំ"។ ប្រឡាយនេះ មានទីតាំងស្ថិតនៅភាគខាងកើតភ្នំ និងខាងចុងស្ថិតនៅភាគ

អាគ្នេយ៍ភ្នំ។ ប្រជាជនក្នុងតំបន់ (ភ្នំបូរី) ពឹងផ្អែកការនេសាទដោយសារប្រឡាយនេះ។ ជាអកុសលដោយសារប្រឡាយនេះត្រូវបានគ្រប់គ្រងដោយម្ចាស់ឡូនេសាទ ឯកជនមួយធ្វើការដាក់កម្រិតមិនឱ្យសមាជិកក្នុងសហគមនេសាទក្នុងទន្លេនេះ។ ប្រជាជនក្នុងតំបន់ពេលខ្លះ ប្រកបមុខរបរនេសាទដោយមិនស្របច្បាប់នៅក្នុងប្រឡាយនេះដែរ។ ទាំងនេះគឺជាហេតុដែលបណ្តាលឱ្យមានទំនាស់រវាងប្រជាជន និងម្ចាស់ឡូនេសាទឯកជន។ នៅរដូវវស្សា ទឹកជំនន់ដែលព័ទ្ធជុំវិញភ្នំ ហើយប្រជាជនភ្នំបូរីមិនសូវមានកិច្ចការងារមមាញឹកជាមួយនឹងការដាំដុះទេ។ ប្រជាជនមួយចំនួនបានកាប់ឆ្ការព្រៃនៅលើភ្នំយកធ្វើអុសដុត និងយកដីសម្រាប់ដាំពោត។



ផែនទីបង្ហាញពីភ្នំបូរី និង អង្គរបូរី



ផែនទីភ្នំបូរី

## ៣. លទ្ធផលនៃការធ្វើកំណាយ

រណ្ដៅកំណាយមានទីតាំងស្ថិតនៅភាគខាងត្បូងឈាងខាងកើត (អាគ្នេយ៍) នៅជម្រាលភ្នំដែលមានលេខកូអរដោនេ (១០ ៥៦ ៨៨ខាងជើង និង ១០៤ ៥៨ ៥១ ខាងកើត)។

- រណ្ដៅសាកល្បង៖ តំបូងក្រុមស្រាវជ្រាវបានបើករណ្ដៅសាកល្បងតូចមួយដែលមានប្រវែង (១មx ១ម) ដើម្បីបញ្ជាក់ថាកន្លែងដែលបានជ្រើសរើសទីតាំងសម្រាប់កំណាយនោះនឹងអាចផ្ដល់នូវព័តមានក្នុងវិស័យបុរាណវត្ថុវិទ្យា ពិសេសសម្រាប់ការធ្វើកំណាយនេះ។



រូបលេខ២៦៖ រណ្ដៅសាកល្បង

- រណ្ដៅធំ៖ ក្រុមស្រាវជ្រាវបានជ្រើសរើសទីតាំងមួយសមរម្យសម្រាប់ជីករណ្ដៅតូចមួយ បូកបញ្ចូលទាំងរណ្ដៅសាកល្បងដែលបានរៀបរាប់ពីខាងលើមុននេះ។ រណ្ដៅកំណាយមានទីតាំងស្ថិតនៅភាគខាងកើតនៃដីម្ចាស់ផ្ទះ និងភាគ ពាយ័ព្យនៃវត្តភ្នំបូរី[1]។ មានវត្ថុសិល្បៈជាច្រើនដែលរកឃើញនៅក្នុងរណ្ដៅតូចមានទម្ងន់លើសពី ១០០០ គីឡូក្រាម។ វត្ថុសិល្បៈ និង វត្ថុធម្មជាតិ (Ecofacts) ដែលរកឃើញនោះច្រើនជាងគេគឺភាជន៍។ តាមរយៈរូបភាពពុះកាត់ក្នុងរណ្ដៅកំណាយបង្ហាញថា ដីមានចំនួន៥ស្រទាប់ ខុសៗគ្នា។



រូបលេខ២៧៖ ស្រទាប់ដីនៃជញ្ជាំងរណ្ដៅកំណាយធំ



គំនូរស្រទាប់ដីបង្ហាញពីស្រទាប់ដីនៅទីតាំងកំណាយ

[1] នៅជើងភ្នំបូរី ជ្រុងខាងលិចភ្នំ មានវត្តមួយឈ្មោះថា «វត្តភ្នំបូរី»។

- រណ្ដៅសាកល្បង៖ ផ្នូរតំបូង រកឃើញនៅស្រទាប់ទី៥ ភាគអាគ្នេយ៍នៃជ្រុងរណ្ដៅ (Unit II) ប្រហែលជា ១៣៥ស.ម ខាងក្រោមស្រទាប់លើ។ រណ្ដៅបានពង្រីកបន្តទៅ ១៤០ស.ម ទៅកើត និង ១២០ស.ម ទៅជើង។ ដីលាយជាមួយដីបច្ចុប្បន្ន ជម្រៅ ៥០ស.ម។ ដីក្នុងជម្រៅនេះមានពណ៌ត្នោតចាស់ ( brownish black)។

គោលបំណងនៃការពង្រីកបន្ថែមរណ្ដៅកំណាយ គឺដើម្បីពង្រីកផ្នូរ និងយកភាជន៍ឡើងដែលបានរកឃើញនៅស្រទាប់ទី៥ ក្នុងរណ្ដៅ២។

បន្ទាប់ពីរណ្ដៅកំណាយពង្រីកដល់ស្រទាប់របស់ផ្នូរ ភាជន៍ពេញរូបរាង និងផ្នូរផ្សេងទៀតបានលេចរូបរាងឡើងកាន់តែច្រើន។ សាកសពទាំងអស់កប់ស្របគ្នា និងជិតៗគ្នា។ សាកសពផ្សេងៗទៀតស្ថិតនៅក្នុងជញ្ជាំងនៃរណ្ដៅកំណាយ។ សរុបគឺមានសាកសព៩កប់ដោយឡែកពីគ្នា ត្រូវបានកត់ត្រាសម្រាប់ស្រាវជ្រាវ។ ការតម្រៀបនៅជិតៗគ្នា និងទិសនៃការកប់សព អាចបញ្ជាក់បានថាជាកន្លែងផ្ទាល់របស់គ្រួសារមួយឬជាដីផ្ទាល់ខ្លួនរបស់គ្រួសារធំមួយ។ ទិសនៃការកប់សព គឺបែរទៅទិសអាគ្នេយ៍។ សពនីមួយៗបានបន្សល់ទុកនូវភាជន៍ និងជើងទម្រ (ជើងពាន)។ វាជារឿងធម្មតា ដែលគេតែងប្រទះឃើញភាជន៍ដែលមានជើងទម្រកប់នៅលើក្បាលរបស់សព និងភាជន៍ផ្សេងទៀតកប់នៅលើ ឬក្បែរដៃ និងខាងក្រោមដៃ។ ភាជន៍កប់នៅខាងលើដៃ និងភាជន៍ដែលកប់នៅខាងក្រោមដៃមានទម្រង់ខុសគ្នា។

សរុបមក ទំនៀមនៃការកប់សពគឺមានភាពស្រដៀងគ្នាទៅនឹងការកប់សព នៅយុគ្គដែក ដែលបានរកឃើញនៅក្នុងប្រទេសកម្ពុជា និងនៅប្រទេសថៃ។ មានអង្កាំពណ៌ទឹកក្រូច ប្រហែលជា ២-៣គ្រាប់បានរកឃើញនៅក្នុងផ្នូរ។ អង្កាំអង្កាម និងអង្កាំគ្រាប់តូចៗមិនបានរកឃើញពីរណ្ដៅសពទេ តែអង្កាំទាំងអស់នោះ គេតែងប្រទះឃើញនៅក្នុងរណ្ដៅជាមួយសាកសពដូចជាស្ថានីយព្រៃក្មេងជាដើម។ វត្ថុធាតុដែលធ្វើពីដែក ក៏មិនបានជួបប្រទះ ក្នុងផ្នូរ លើកលែងកងដៃ ដែលធ្វើអំពីស្ពាន់កប់នៅលើដៃប៉ុណ្ណោះ។

អាស្រ័យដោយមានភាជន៍កប់នៅក្នុងផ្នូរសព យើងអាចដឹងថា ពិធីនៃការកប់សពធ្វើឡើងនៅមុនពេលដែលគេកប់សាកសព។ កិច្ចប្រតិបត្តប្រហែលគ្នាតាមបែបជាតិពន្ធុវិទ្យា ត្រូវបានគេស្រាវជ្រាវកន្លងមក។ នៅពីលើក្បាលសពមានភាជន៍មានជើងពណ៌ត្នោត។ នេះអាចបញ្ជាក់ច្បាស់ថាប្រជាជននៅក្នុងតំបន់ មានទំនៀមប្រារព្ធពីធីបុណ្យសព និងកប់សពដូចទៅនឹងអង្គរបូរី (វត្តគំនូរ) ព្រៃក្មេង និងភូមិស្នាយ ព្រមទាំងដូចទៅនឹងស្ថានីយនៅតាមបណ្ដាប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍។

នេះអាចបង្ហាញពីវិសាលភាពនៃវប្បធម៌។ យ៉ាងណាមិញ វាអាចបង្ហាញអំពីក្រុមជនជាតិដែលមានទំនៀមទម្លាប់ និងសាសនា ។ល។

ទីតាំងភូមិសាស្ត្រអាចឱ្យយើងដឹងថា ក្នុងកំឡុងពេលនោះ ប្រជាជនដែលតាំងទីនៅភ្នំបូរី ឬរស់នៅជិតភ្នំបូរី (ទីតាំងរស់នៅដាច់ៗពីគ្នា ដូចជាភ្នំដា អង្គរបូរីជាដើម) ប្រើស្ថានីយនេះសម្រាប់ប្រារព្ធពិធី។ ទំនៀមទម្លាប់របស់ខ្មែរក្នុងពិធីកប់សព តែងតែស្ថិតនៅឆ្ងាយពីកន្លែងដែលមនុស្សរស់នៅ និងជាតំបន់ដែលមិនលិចទឹក។ ប្រសិនបើទំនៀមកប់សពនេះ ជាកិច្ចពិធីរបស់ខ្មែរពីសម័យបុរាណ ភ្នំបូរីជាទីតាំងមួយសម្រាប់កប់សព។ វត្ថុសិល្បៈដែលស្ថិតនៅស្រទាប់ខាងលើ អាចបប្រាប់ពីសម័យកាលក្រោយផ្នូរ ហើយជាសម័យផ្នូរសពត្រូវបានគេបំភ្លេចចោល។ ឆ្អឹងលលាដ៍ក្បាល រួមមានឆ្អឹងមនុស្សពេញវ័យ កុមារ និងទារក។ ឧទាហរណ៍ គឺមានដូចជា សាកសពមនុស្សពេញវ័យជាប់នឹងកូនឱបផ្កាប់និងដើមទ្រូង។ នេះប្រហែលជាអាចស្លាប់នៅពេលសម្រាលកូនដោយជម្ងឺ ឬរងរបួសស្លាប់ទៅជាមួយគ្រួសារជាច្រើន ប៉ុន្តែដោយសារទំនៀមទម្លាប់គឺគេដាច់ខាតត្រូវកប់ជាមួយគ្នា។

ការយកឆ្អឹងទៅសិក្សាពិនិត្យដើម្បីយល់ដឹងអំពីជម្ងឺ របួស ភេទ អាយុ សុខភាព និងចំណីអាហារ នៅមិនទាន់បានធ្វើនៅឡើយទេ ។ ការវិភាគក្នុងពេលអនាគត នឹងធ្វើឡើងដើម្បីឱ្យមានការយល់ដឹងកាន់តែប្រសើរឡើង។




រូបលេខ៣៨៖ ផ្នូរបុរាណរកឃើញនៅរណ្តៅកំណាយភ្នំបូរី



រូបលេខ៩៖ សាកសពមនុស្សពេញវ័យឱ្យបកូនតូចក្នុងដៃ




រូបលេខ១០៖ រណ្តៅកំណាយបង្ហាញពីសពមួយនៅជាប់នឹងជញ្ជាំង និង ក្អមមួយដែលប្រើដាក់កប់នៅលើក្បាលសព

### ៤. ការវិភាគវត្ថុសិល្បៈ

វត្ថុសិល្បៈ និងវត្ថុធម្មជាតិ (Ecofacts) ត្រូវបានប្រមូលខ្ចប់ទុក និងកត់ត្រាទៅតាមរណ្ដៅ និងកម្រិតជម្រៅនៃកំណាយ (Unit and Spit)។ ការប្រមូលយកវត្ថុសិល្បៈនៅស្រទាប់ខាងលើ គេប្រមូលហើយបែងចែកដាក់ក្នុងថង់ផ្សេងៗគ្នា។ លើសពីនេះទៀត ប្រជាជនរស់នៅភ្នំបូរីជាច្រើនអនុញ្ញាតឱ្យថតវត្ថុសិល្បៈដែលមិនស្គាល់ប្រភព។ ការធ្វើដូចនេះ មានការងាយស្រួលក្នុងការប្រគល់ជូនម្ចាស់ដើមវិញ។ យើងមិនទិញវត្ថុសិល្បៈណាមួយទេ ដែលទង្វើនេះនឹងបង្កើនឱ្យមានការបំផ្លាញស្ថានីយបុរាណវត្ថុវិទ្យាកាន់តែខ្លាំង ដើម្បីស្វែងរកវត្ថុសិល្បៈសម្រាប់លក់ ដោយខុសច្បាប់។

#### -កុលាលភាជន៍

យើងប្រមូលកុលាលភាជន៍ពីស្រទាប់លើ និងពីរណ្ដៅកំណាយសម្រាប់សិក្សាវិភាគ។ កុលាលភាជន៍ ប្រមូលពីរណ្ដៅកំណាយបានប្រមូលទុកយ៉ាងប្រុងប្រយ័ត្នទៅតាមលេខរណ្ដៅ ស្រទាប់ដី និងតាមកម្រិតជម្រៅនីមួយៗ។ កុលាលភាជន៍ប្រមូលបានទាំងអស់មានទម្ងន់ ១១៨៩,០៩គីឡូក្រាម។ នៅជម្រៅពី៧០ស.ម ទៅ ៨០ស.ម នៅរណ្ដៅសាកល្បង រណ្ដៅទី១ និងរណ្ដៅទី២ មានបំណែកកុលាលភាជន៍ក្រាស់ជាងគេ។

កុលាលភាជន៍ភ្នំបូរីចែកជាពីរប្រភេទធំៗ គឺ៖

**១- ភាជន៍ប្រណិតៈ** ជាទូទៅ ភាជន៍ប្រណិតមានរូបរាងតូច ហើយស្ដើង។ ភាជន៍ប្រភេទនេះច្រើនប្រើក្នុងពិធីសាសនាសំខាន់ៗរួមទាំងពិធីបញ្ចុះសពផង។ ភាជន៍ប្រណិតមានដោយកម្រក្នុងរណ្ដៅកំណាយស្រទាប់លើ ក៏ប៉ុន្តែសម្បូរនៅក្នុងរណ្ដៅកប់សព។ វាយនភាព (សាច់ភាជន៍) របស់ភាជន៍ប្រណិតរលោង ហើយប្រហែលមានទំនាក់ទំនងជាមួយភាជន៍ ប្រភេទប្រណិតនៅតំបន់អាស៊ីអាគ្នេយ៍។ ដីឥដ្ឋដែលគេយកមកធ្វើភាជន៍ប្រណិតមាននៅលើភ្នំបូរី។ អ្នកធ្វើភាជន៍ (ស្មូន) សម័យបច្ចុប្បន្ន ដូចជាអ្នកនៅភ្នំដីសូរ ខេត្តតាកែវ ប្រើដីឥដ្ឋយកពីភ្នំដីសូរសម្រាប់ធ្វើភាជន៍ និងក្អមឆ្នាំង។ ដីល្បាប់នៅតាមដីទំនាបជាប់ភ្នំបូរី អាចប្រើសម្រាប់ធ្វើភាជន៍បានដែរ ប៉ុន្តែសាច់ភាជន៍ និងពណ៌ខុសគ្នាពីភាជន៍ដែលគេយកដីឥដ្ឋពីភ្នំ។ ដីល្បាប់ទំនាប សម្បូរទៅដោយសារធាតុសរីរាង្គពណ៌ខ្មៅជាច្រើន។

**២- ភាជន៍ប្រើប្រាស់ប្រចាំថ្ងៃ**

ប្រភេទភាជន៍ទូទៅនៅភ្នំបូរីគឺជាប្រភេទភាជន៍ប្រើប្រាស់ប្រចាំថ្ងៃ។ ភាជន៍ប្រភេទនេះមានច្រើននៅរាយប៉ាយលើដី (ស្រទាប់លើ surface collection)។ ទោះយ៉ាងណាក៏ដោយ ប្រភេទចំពួយកុណ្ឌីមានច្រើននៅស្ថានីយអង្គរបូរី និងភ្នំបូរី រកឃើញនៅលើដីជាច្រើន តែវាជាប្រភេទភាជន៍ប្រើប្រាស់ក្នុងពិធីសាសនា។ ប្រភេទចំពួយកុណ្ឌីរកឃើញនៅគ្រប់ស្ថានីយក្នុងសម័យក្រោយហ្វូណន

និងស្ថានីយក្នុងសម័យក្រោយៗ មកទៀត។ ភាជន៍ប្រើប្រាស់ប្រចាំថ្ងៃ រកឃើញច្រើនជាងគេទាំងក្នុងរណ្ដៅកំណាយ និងលើដី។

គ្មានកស្តុតាងណាមួយបង្ហាញថាភាជន៍ទាំងអស់នោះដុតក្នុងឡឡើយ។ ភាជន៍ដុតក្នុងឡមានកម្ដៅខ្ពស់ និងប្រភេទភាជន៍រឹង (stoneware) មិនមែនជាប្រភេទភាជន៍នៅភ្នំបូរី និងអង្គរបូរីទេ។ ទោះយ៉ាងណាក៏ដោយ កស្តុតាងមួយចំនួនបង្ហាញថា ភាជន៍(earthenware) អង្គរបូរី និងភ្នំបូរីដុតក្នុងសីតុណ្ហភាពខ្ពស់ និងប្រើបច្ចេកទេសផលិតដោយប្រើអន្ទោក (ឈ្នាន់បង្វិល)។ លក្ខណៈមួយនៃភាជន៍ភ្នំបូរី គឺសម្បូរទៅដោយគ្រាប់ខ្សាច់ក្វាត (quartz)។ លក្ខណៈនេះ មិនដឹងថា តើអ្នកធ្វើភាជន៍មានចេតនាបញ្ចូលគ្រាប់ខ្សាច់ក្វាតលាយជាមួយដីឥដ្ឋមុនពេលធ្វើភាជន៍ ឬក៏ដីឥដ្ឋដែលគេយកមកធ្វើភាជន៍មានគ្រាប់ខ្សាច់ក្វាតក្នុងនោះ ហើយគេមិនព្យាយាមយកវាចេញ។ ទោះយ៉ាងនេះក៏ដោយ គ្រាប់ខ្សាច់ក្វាតដែលមានក្នុងដីឥដ្ឋជាលក្ខណៈធម្មជាតិរបស់ដីនៅតំបន់ភ្នំបូរី។ ដីរលោងពណ៌ស (white slip) ជាលក្ខណៈទូទៅមួយរបស់ភាជន៍នៅភ្នំបូរី។ ដីរលោងពណ៌សនេះ គេប្រើវាសម្រាប់លាបលើភាជន៍ទាំងខាងក្នុងនិងខាងក្រៅ។ ជាទូទៅ ដីរលោងពណ៌ស ប្រើសម្រាប់លាបតែផ្នែកខាងក្នុងភាជន៍ប៉ុណ្ណោះ។ ពណ៌ដែលគេចូលចិត្តប្រើសម្រាប់ភាជន៍ភ្នំបូរីគឺ ពណ៌ត្នោត និងពណ៌ស។ ការពេញនិយមនេះ ប្រហែលមកពីចំណង់ចំណូលចិត្តតៗគ្នារៀងមក ឬប្រហែលជាទាក់ទងនឹងបច្ចេកទេសនៃការផលិតកុលាលជន៍។ កម្រាស់នៃភាជន៍ខុសគ្នាពី២ម.ម ទៅ២៥ម.ម។ មានក្បាច់លម្អពីរប្រភេទខុសៗគ្នា។ ក្បាច់លម្អប្រភេទទី១ គឺក្បាច់ប្រថាប់ និងក្បាច់លម្អប្រភេទទី២គឺ ក្បាច់ឆ្លូតៗ។ ភាជន៍ដែលយកចេញពីផ្នូរ ជាភាជន៍ពេញ ទោះជាមានបំណែកបាក់បែកខ្លះៗ ហើយបំណែកបាក់បែកទាំងនោះអាចយកផ្គុំគ្នាចេញជាភាជន៍មានរូបរាងពេញលេញច្បាស់លាស់។

រូបរាងភាជន៍មួយចំនួនអាចកត់សម្គាល់បានដូចជាៈ ចាន ក្រទិន ចានមានជើង ក្អម ចានមានជើងទម្រតូច គម្របផ្ទាំង ទ្រនុល (ក្លឹង) ភាជន៍សម្រាប់ក្មេងលេង និងគ្រាប់លុញៗ។

**៣- ភាជន៍ផ្សេងៗ៖**

អង្កាំ៖ អង្កាំកែវច្រើនប្រមូលបានពីដីដែលយកទៅរែង។

កងដៃដែក និងសំរិទ្ធ៖ កងដៃដែក និងសំរិទ្ធរកឃើញក្នុងរណ្ដៅកំណាយដែរ។

ដែក៖ ដែកក៏ប្រទេះឃើញក្នុងរណ្ដៅកំណាយដែរ។

**-សំណល់សត្វ**

ឆ្អឹងសត្វរកឃើញនៅគ្រប់ស្រទាប់ដី។ បំណែកឆ្អឹងសត្វ ដូចជា សត្វពាហនៈ ឆ្អឹងត្រី និងឆ្អឹងអណ្ដើក នៅរក្សាបំណែកធំ មធ្យម និងតូចៗ ទម្ងន់ឆ្អឹងសរុបគឺ ១០,៧៧០៥គីឡូក្រាម។ បរិមាណ

នៃផ្ទឹងដែលមានតាមស្រទាប់ដីគឺដូចគ្នានឹង បរិមាណភាជន៍ដែរ។

## ៥. លទ្ធផលនៃការវិភាគកាលបរិច្ឆេទ

ការធ្វើវិភាគកាលបរិច្ឆេទធ្យូងធ្វើឡើង ដោយមន្ទីរពិសោធន៍នៅសហរដ្ឋអាម៉េរិកឈ្មោះ BETA Analystic Laboratories (US) និងទទួលបាន ថវិកាឧបត្ថម្ភពីសាកលវិទ្យាល័យជាតិសឹង្ហបូរី (National University of Singapore)។ កាលបរិច្ឆេទ បង្ហាញច្បាស់គឺស្ថិតក្នុងសតវត្សទី១ និងទី២ មុនគ្រិស្តសករាជ។ សម័យកាលរបស់ហ្វូណន គិតចាប់ពីសតវត្សទី១នៃគ្រិស្តសករាជ ប៉ុន្តែ ផ្នូរនិងស្រទាប់វប្បធម៌ដែលជាតឹកតាងនៃការរស់នៅរបស់មនុស្ស នៅអង្គរបូរី មានចាប់តាំងពីចុងសហ្សសវត្សទី១។ កាលបរិច្ឆេទ នៅភ្នំបូរីស្របគ្នានឹងកាលបរិច្ឆេទក្នុងដំណាក់កាលទី២នៃអង្គរបូរី ពោលគឺចាប់ពី សតវត្សទី១មុនគ្រិស្តសករាជ ដល់សតវត្សទី៣ នៃគ្រិស្តសករាជ។ ផ្នូរដែលរកឃើញនៅទីតាំងកំណាយ អាចមានអាយុកាលចាស់ជាងស្រទាប់ទី៣ និងទី៤ (សតវត្សទី១ និងទី២មុនគ្រិស្តសករាជ) ប្រសិនបើគេ មិនជីកដីកប់សពនៅសម័យក្រោយស្រទាប់ដីទាំងពីរ។

| Sample Data | Measured Radiocarbon Age | 13C/12C Ratio | Conventional Radiocarbon Age(*) |
|---|---|---|---|
| Beta – 192618<br>SAMPLE: PB01 (Layer 3)<br>ANALYSIS: AMS-Standard delivery<br>MATERIAL/PRETREATMENT: (charred material): acid/alkali/acid<br>2 SIGMA CALIBRATION: Cal BC 340 to 320 (Cal BP 2290 to 2270) and Cal BC 210 to 40 (Cal BP 2160 to 1990) | 2160+/-40 BP | -27.9 o/oo | 2110+/-40 BP |
| Beta – 192619<br>SAMPLE: PB02 (Layer 4)<br>ANALYSIS: AMS-Standard delivery<br>MATERIAL/PRETREATMENT: (charred material): acid/alkali/acid<br>2 SIGMA CALIBRATION: Cal BC 160 to 50 (Cal BP 2120 to 1900) | 2080+/-40 BP | -27.2 o/oo | 2040+/-40 BP |
| Beta – 192620<br>SAMPLE: PB03 ( Layer 4, Depth: 100-110 cm)<br>ANALYSIS: AMS-Standard delivery<br>MATERIAL/PRETREATMENT: (charred material): acid/alkali/acid<br>2 SIGMA CALIBRATION: Cal BC 350 to 310 (Cal BP 2300 to 2260)<br>and Cal BC 210 to 40 (Cal BP 2160 to 1990) | 2160+/-40 BP | -27.5 o/oo | 2120+/-40 BP |

តារាងវិភាគអាយុកាលធ្យូង (C14) វិភាគនៅ the BETA Analytic Laboratories (US) សហរដ្ឋអាម៉េរិក ឧបត្ថម្ភថវិកាវិភាគដោយសាកលវិទ្យាល័យសឹង្ហបូរី (National University of Singapore)




*រូបលេខ២១១៖ កូនឆ្នាំង និងជើងពានរកឃើញនៅរណ្ដៅផ្នូរ*




*រូបលេខ២១២៖ អង្កាំព័ណទឹកក្រូចរកឃើញជាមួយផ្នូរ*



*រូបលេខ២១៣៖ កងដៃសំរឹទ្ធ*




*រូបលេខ២១៤៖ ទ្រនុល (ក្ងឹង) ជាឧបករណ៍ផលិតក្អម*




*រូបលេខ២១៥៖ គ្រាប់លុញរកឃើញក្នុងរណ្ដៅកំណាយ*

## សន្និដ្ឋាន

*កំណាយនៅភ្នំបូរីបានបន្ថែមការយល់ដឹងពីការរស់នៅលើស្ថានីយ និងរចនាសម្ព័នរស់នៅធំទូលាយនៅក្នុងតំបន់។ ទិន្នន័យបានពីផ្នូរ និងវត្ថុសិល្បៈរកឃើញជាវិភាគទានមួយដើម្បីយល់ដឹងឱ្យគាន់តែទូលំទូលាយពីជីវិតក្នុងអតីតកាលក្នុងតំបន់។*

*មានដំណាក់កាលចំនួនពីរសម័យកាលនៅភ្នំបូរី។ ដំណាក់កាលទី១បង្ហាញនៅស្រទាប់ដីទី៥ គឺស្រទាប់ផ្នូរ ក៏ប៉ុន្តែ កាលបរិច្ឆេទផ្នូរ មិនទាន់ធ្វើវិភាគនៅឡើយ។ ដំណាក់កាលទី២បង្ហាញនៅស្រទាប់ទី៣ និងទី៤ ក្នុងសតវត្សទី១ និងទី២ មុនគ្រិស្តសករាជ។*

*ស្រទាប់ដី និងកម្រាស់យ៉ាងក្រាស់របស់វត្ថុសិល្បៈនៅស្រទាប់នេះបង្ហាញពីការរស់នៅយ៉ាងច្រើននៅក្នុងសម័យកាលនោះ។*

*កុលាលភាជន៍ជាសមាសភាពច្រើនជាងគេបំផុតក្នុងចំណោមវត្ថុសិល្បៈទាំងអស់ មានទម្ងន់ ១១៨៦,០៩គីឡូក្រាម យកចេញពីរណ្តៅកំណាយ និងរណ្តៅពង្រីកមួយទំហំសរុប ៨ម៉ែ។ ដង់ស៊ីតេកុលាលភាជន៍ខ្ពស់បែបនេះអាចបកស្រាយបានថាតំបន់នេះ និងតំបន់ជិតខាងជាកន្លែងផលិតកុលាលភាជន៍ក្នុងកំឡុងសតវត្សទី១ ទី២មុនគ្រិស្តសករាជ។ ការសិក្សាពីប្រភពនឹងជួយឱ្យកំណត់បានថា តើបើកុលាលភាជន៍ផលិតក្នុងតំបន់ឬនាំចូលពីក្រៅ។ វត្តមានទ្រនុល (ក្ងីង) គឺជសម្ភតិកម្មមួយបញ្ជាក់ពីការលទ្ធភាពផលិតកម្មកុលាលភាជន៍ក្នុងតំបន់ភ្នំបូរីនេះដែរ។ ចំណែកឯប្រភពដីឥដ្ឋយកមកធ្វើភាជន៍យកមកពីជម្រាលភ្នំ និងដីទំនាបក្បែរភ្នំ។ ដីព័ណសដែលគេយកប្រើជាដីរលោង (slip) ក៏ប្រទេះឃើញក្នុងរណ្តៅកំណាយ។ បឹងព័ទ្ធជុំវិញភ្នំបូរីឈ្មោះទន្លេភ្នំ ប្រហែលជាប្រភេទបឹងក្រចកសេះ។ បច្ចុប្បន្ននេះ ទន្លេភ្នំមានតួនាទីជាផ្លូវទឹកសម្រាប់ធ្វើគមនាគមន៍ភ្ជាប់ទៅអង្គរបូរី និងព្រែកជីកខ្លះទៀតតាមរយៈព្រែកជីកមួយ។ ទន្លេភ្នំជាជំរកសត្វ រុបសាស្ត្រធម្មជាតិផ្សេងៗ ព្រមទាំងជាប្រភពទឹកប្រើប្រាស់របស់ប្រជាជននៅភ្នំបូរី។*

*ផលិតកម្មកុលាលភាជន៍នៅភ្នំបូរីអាចផលិតសម្រាប់ផ្គត់ផ្គង់ការប្រើប្រាស់នៅក្រុងអង្គរបូរី។ ទោះបី ក្រុងអង្គរបូរីមិនទាន់គេស្គាល់ថាជា រាជធានីនៅសតវត្សទី១ ទី២មុនគ្រិស្តសករាជ អង្គរបូរីនៅតែជាមជ្ឈមណ្ឌលនយោបាយសំខាន់មួយ។ ប្រសិនបើកុលាលភាជន៍ និងវត្ថុសិល្បៈផ្សេងទៀតដែលប្រមូលបាន ផលិតនៅកន្លែងរស់នៅមួយ ដូចជានៅភ្នំបូរី វត្ថុសិល្បៈទាំងនោះងាយស្រួលដឹកជញ្ជូនទៅអង្គរបូរី។ ជាងនេះទៀត ប្រហែលជា ភ្នំបូរីមានអុសដុតភាជន៍ ដែលជាកត្តាមួយចាំបាច់ចំពោះផលិតកម្មកុលាលភាជន៍។ មជ្ឈមណ្ឌលផលិតកុលាលភាជន៍នៅតំបនជិតខាងដូចជានៅភ្នំបូរីអាចទាញយកផលចំណេញបានច្រើនជាង ព្រោះផលិតផលដែលមិនទាន់*

សម្រេច មិនចាំបាច់ដឹកពីកន្លែងដ៏ទៃ។ ផលិតផលសម្រេចចុងក្រោយទើបត្រូវបានដឹកជញ្ជូន ដើម្បីឱ្យបានផលចំណេញច្រើន។

ទំនាក់ទំនងអង្គរបូរីនិងភ្នំបូរីបង្ហាញយ៉ាងច្បាស់តាមរយៈកុលាលភាជន៍មានក្នុងស្រទាប់មនុស្សរស់នៅ និងក្នុងផ្នូរកប់សព។ ភ្នំបូរីប្រហែលជាមជ្ឈមណ្ឌលផលិតកុលាលភាជន៍ ឬជាមជ្ឈមណ្ឌលកសិកម្ម និងនេសាទ។

ភ្នំបូរីទោះជាមានវប្បធម៌ដំបូងៗជាទីចាប់អារម្មណ៍ និងសំណល់ប្រាសាទធ្វើពីឥដ្ឋ ប៉ុន្តែមិនមែនជាទីតាំងលំនៅដ្ឋានក្រុង មានកំពែងព័ទ្ធជុំវិញដូចអង្គរបូរីនោះទេ។ ទោះយ៉ាងណា ក៏តំបន់ទាំងពីរមានទំនាក់ទំនងគ្នា ទាំងនយោបាយ និងសេដ្ឋកិច្ចយ៉ាងរឹងមាំ ដែលតំបន់ភ្នំបូរីជាតំបន់រណបមួយឱ្យក្រុងអង្គរបូរី។

ការសិក្សាស្រាវជ្រាវជាលើកដំបូង ជួយផ្តល់ព័ត៌មានពីកាលបរិច្ឆេទ ការតាំងទីលំនៅ សេដ្ឋកិច្ច ពិធីសាសនា និង វត្ថុសិល្បៈវប្បធម៌នៅភ្នំបូរី និងទំនាក់ទំនងជាមួយអង្គរបូរីចាប់ពីចុងសហស្សវត្សរ៍ទី១មុនគ្រិស្តសករាជរហូតមក។

## ឯកសារយោង


Dobby, E. H. G. (for brackish water limit, p. 302)
1960 *Southeast Asia* (7th ed.). University of London Press, London.

Dobby, E. H. G. (for old/new delta, pp. 190-191)
1961 *Monsoon Asia*. University of London Press, London.

Fox, Jeff and Ledgerwood, Judy
1999 Dry-Season Flood-Recession Rice in the Mekong Delta: Two Thousand Years of Sustainable Agriculture? *The Journal of Archaeology for Asia and the Pacific* 38 (1), pp. 37-50.

Ministry of Planning, National Institute of Statistic
1999 General Census of the Population in Cambodia in 1998.

Stark, Miriam T, P. Bion Griffin, Chuch Pheourn, Judy Ledgerwood, Michael Dega, Carol Mortland, Nacy Dowling, James M. Bayman, Bong Sovath, Tea Van, Chhan Chamroeun, and Kyle Latinis
1999 Result of the 195-1996 Archaeological Field Investigations at Angor Borei, Cambodia. *The Journal of Archaeology for Asia and the Pacific* 38 (1), pp. 7-36.

Stark, Miriam T, P. Bion Griffin, Chuch Pheourn
2000 Report on the 1999 Field Season

Stark, Miriam T
2004 OSL and Radiocarbon Dating of a Pre-Angkorian Canal in the Mekong Delta, Southern Camboia. *The Journal of Archaeological Science 31*.

# អេលីត និងទ្រឹស្តីអេលីត

Elite and Theories of Elite

*ដោយៈ* **បណ្ឌិត អ៊ុំ ម៉ុម**

*ជំនួយការរាជបណ្ឌិត្យសភាកម្ពុជា*

## សេចក្តីផ្តើម

*នៅក្នុងសង្គមបច្ចុប្បន្ន មិនថាឡើយសង្គមនោះស្ថិតក្នុងលំហភូមិសាស្ត្រនៃប្រទេសណាមួយនោះ ទេ ពួកអេលីតត្រូវបានគេទទួលស្គាល់ថាជាអ្នកដែលមានតួនាទី និងការទទួលខុសត្រូវសម្រាប់ធ្វើឱ្យសង្គមមានការអភិវឌ្ឍន៍ និងរីកចម្រើនទៅតាមបំណងប្រាថ្នានៃមនុស្សភាគច្រើន។ ដូច្នេះអ្វីៗ ដែលខ្ញុំនឹងលើក យកមកបង្ហាញជូនខាងក្រោមនេះ អាចជាខ្លឹមសារដែលរួមវិភាគទានចំពោះចំណេះដឹងទាក់ទងទៅនឹងទស្សនាទានអេលីតក៏ដូចជាទ្រឹស្តីអេលីតដែលយើងនឹងសិក្សាស្វែងយល់ទាំងអស់គ្នាតទៅ។ ប៉ុន្តែមុននឹង ស្វែងយល់បានថាតើអេលីតជាអ្វី ទ្រឹស្តីអេលីតមានអ្វីខ្លះ យើងគប្បីសិក្សាស្វែងយល់ពីពេលវេលានៃការចាប់កំណើតរបស់ពាក្យអេលីតនេះជាមុនសិន តើពាក្យនេះត្រូវបានគេប្រើប្រាស់តាំងពីពេលណាមក?*

## ១. ប្រវត្តិនៃការប្រើប្រាស់ពាក្យអេលីត

*ជារួមពាក្យអេលីតត្រូវបានគេលើកយកមកប្រើប្រាស់តាំងពីសង្គមក្រិកបុរាណសម្រាប់សម្គាល់ វណ្ណៈមួយក្នុងចំណោមវណ្ណៈទាំងបីរបស់សង្គមតាំងពីសម័យកាលលោកអ៊ីប៉ូដាមដឺមីឡេ[1] នាសតវត្សទី៥មុនគ្រឹស្តសករាជមកម្ល៉េះ។ តាមទស្សនៈរបស់លោក បុរីនីមួយៗត្រូវមានមនុស្សមួយម៉ឺននាក់រស់នៅ និង មានវណ្ណៈចំនួនបីជាអ្នកគ្រប់គ្រងថែរក្សានោះ គឺពួកជនឈ្មោះថាអេលីតដែលជាវណ្ណៈទីមួយទទួលបន្ទុកថែរក្សាការពារផលប្រយោជន៍រួមរបស់បុរីជាអ្នកបង្កើតនូវបទបញ្ញាសេចក្តីសម្រេចចិត្តនានា និងជាអ្នករៀប ចំការងារសម្រាប់បុរីនោះ។ បន្ទាប់ពីពួកអេលីតគឺពួកទាហានដែលជាវណ្ណៈទីពីរជាអ្នកមានកាយសម្បទាមាំមួនទទួលបន្ទុកការពារបុរី។ ជាចុងក្រោយ*

---

[1] *លោកជាអ្នករៀបចំរចនាសម្ព័ន្ធរបស់បុរីជាសហការីរបស់លោក ប៉េរីឃ្លីស ក្នុងសម័យក្រិកបុរាណ។*

គឺពួកជនឧស្សាហ៍ព្យាយាម (Les Laborieux) ដែលជា វណ្ណៈទីបីទទួលបន្ទុកផលិតទ្រព្យសម្ភារៈសម្រាប់បុរី។

## ២. ន័យរបស់ពាក្យអេលីត

បើគិតទៅលើន័យនៃពាក្យ **អេលីត** វិញនោះ ពាក្យនេះត្រូវបានសិក្សាស្វែងយល់ទៅតាមន័យបី យ៉ាងពោលគឺន័យទូទៅ ន័យ បែបសង្គម-នយោបាយ វិទ្យាសាស្ត្រនយោបាយ និងន័យបែបទ្រឹស្តី ឬហៅម្យ៉ាងទៀតថាអេលីតនិយម (Elitism)។

### ២.១ ន័យទូទៅរបស់អេលីត

(General meaning of Elite)

បើតាមវចនានុក្រមអកស្វតអាត់វ៉ាន់ លើនើរស៍បោះពុម្ពផ្សាយនៅឆ្នាំ២០០៣ បានឱ្យនិយមន័យ អេលីតថាជាក្រុមសង្គមដែលត្រូវបានគេគិតថាជាក្រុមមួយល្អបំផុត ឬសំខាន់បំផុតព្រោះតែឥទ្ធិពល លុយកាក់ ភាពឆ្លាតវៃរបស់គេ។ល។ (Elite is a social group that is thought to be the best or most important because of it, power, money, intelligence etc.[2] ។

ដូច្នេះបើតាមន័យ ខាងលើពួកអេលីត ជាក្រុមសង្គមដែលល្អបំផុត ដោយសារតែពួកគេមាន អំណាច មានលុយកាក់ និងមានភាពឆ្លាតវៃ។

### ២.២ ន័យតាមបែបសង្គម-នយោបាយ វិទ្យាសាស្ត្រនយោបាយ

#### ២.២.១ ន័យតាមបែបសង្គម-នយោបាយ

បើតាមន័យនេះ អេលីតគឺជាមនុស្សដែលកាន់កាប់ទីតាំងខ្ពស់បំផុតក្នុងក្រុមសង្គម ឬក្រុមវិជ្ជាជីវៈ ថែមទាំងក្នុងប្រជាជាតិមួយទៀតផង អាស្រ័យដោយតម្លៃ ដែលពួកគេត្រូវបានទទួលស្គាល់។ (Personnes qui, en raison de leurs valeurs reconnues, occupent une position éminente au sein d´un groupe social ou professionel, voire d´une nation)[3]។

#### ២.២.២ ន័យតាមបែបវិទ្យាសាស្ត្រនយោបាយ

បើតាមន័យនេះ អេលីតត្រូវបានផ្តោតជាសំខាន់ទៅលើក្រុមសង្គមដែលមានអំណាច និងមាន ឥទ្ធិពលទៅលើសេចក្តីសម្រេចចិត្តខាងនយោបាយ។ (... Elite s´intérese plus particulièrementaux

[២] Oxford Advanced learner's Dictionary. New Edition, 2003 p219.

[៣] Olivier Nay, Lexique desience Politique, 3éme Edition. 2014, p192.

groupessociaux qui ont du pouvoir et de l′influence sur les décisions politiques)[4]។ បើគេធ្វើសំយោគន័យទាំងអស់នេះមកវិញ ពួកអេលីតជាក្រុមសង្គមដែលមានអំណាច និងមានឥទ្ធិពល ទៅលើសេចក្ដីសម្រេចចិត្ត ខាងនយោបាយរបស់ប្រទេស ដោយសារតែ អំណាច លុយកាក់ ភាពឆ្លាតវៃ របស់គេ ហើយជាអ្នកដែលកាន់កាប់ទីតាំងខ្ពស់បំផុត ក្នុងក្រុមសង្គម ឬវិជ្ជាជីវៈ អាស្រ័យដោយ តម្លៃដែល សង្គមបានផ្ដល់ឱ្យពួកគេ។

ផ្សារភ្ជាប់ទៅនឹងបញ្ហាអេលីតដដែល បើគេនិយាយទាក់ទងទៅនឹងសង្គមប្រជាធិបតេយ្យវិញរបប សង្គមនេះក៏ផ្ដល់តម្លៃឱ្យពួកអេលីតខ្លាំងក្លាណាស់ដែរ។ ជាក់ស្ដែងគេបានប្រកាន់យកនូវគោលការណ៍ ជាលក្ខខណ្ឌសង្គមមួយដោយផ្អែកលើ ″ភាពស័ក្ដិសម″ (Le mérite) ដែលជាលទ្ធផលបានមកពីការសម្រេច ជោគជ័យរបស់ពួកគេ ក្នុងការរៀនសូត្រ ក៏ដូចជាក្នុងវិជ្ជាជីវៈណាមួយ។ ឧទាហរណ៍នៅប្រទេសបារាំង ដែលជាប្រទេសប្រកាន់យករបបប្រជាធិបតេយ្យបែបសាធារណរដ្ឋនិយមតាំងពីឆ្នាំ១៧៨៩មកបានអនុវត្តយ៉ាងខ្ជាប់ខ្ជួនទៅលើគោលការណ៍″ភាពស័ក្ដិសមជាធំ″ ឬ″ស័ក្ដិសមាធិបតេយ្យ″ (La méritocratie) តាមរយៈការប្រឡងប្រជែងជ្រើសរើសចម្រាញ់យកជនឆ្នើមប្រកបដោយសមត្ថភាព និងទេពកោសល្យកម្រិត ខ្ពស់ពីសាលាគរុវិជ្ជាជាន់ខ្ពស់ សាលាពហុបច្ចេកវិទ្យា ក៏ដូចជាសាលារដ្ឋបាលរបស់ជាតិ (Ecole Nationale d′Administration) ឱ្យចូលទៅបម្រើការងារនៅតាមស្ថាប័ន បច្ចេកវិទ្យា ក៏ដូចជានៅតាមស្ថាប័នសំខាន់ៗ ដទៃទៀត ។ ម្ល៉ោះហើយដោយ ទង្វើជា សកម្មភាព បែបនេះ ពួកអេលីតក៏បានក្លាយបន្តិចម្ដងៗទៅជាក្រុម ដែលកាន់កាប់ផ្ដាច់មុខទៅលើស្ថាប័នសំខាន់ៗរបស់រដ្ឋក៏ដូចជាស្ថាប័នឯកជនរបស់ប្រទេស។ ចំណែកនៅ សង្គមសហរដ្ឋអាម៉េរិកវិញក៏យ៉ាងដូច្នេះដែរ ពួកអេលីតក៏ត្រូវបានគេចាត់ទុកថាជាក្រុមសង្គមដ៏មានឥទ្ធិពល ខ្លាំងក្លាគ្របដណ្ដប់ទៅលើវិស័យនយោបាយរបស់រដ្ឋាភិបាល ក៏ដូចជាវិស័យធុរកិច្ចរបស់ប្រទេស។

ជាបន្តទៅទៀតនេះយើងនឹងនាំគ្នាទៅពិចារណាអំពីន័យអេលីតតាមបែបទ្រឹស្ដីឬអេលីតនិយមវិញ ម្ដង តើមានចំណុចអ្វីដែលគួរឱ្យកត់សម្គាល់ដែរឬទេ?

[៤] Ibid p191

**៣ ន័យអេលីតតាមបែបទ្រឹស្តី ឬអេលីតនិយម** ( Elitism )

គេអាចចែកអេលីតនិយមជាពីរប្រភេទគឺអេលីតនិយមបែបទស្សនាទាន និងអេលីតនិយមបែប វិទ្យាសាស្ត្រសង្គម។

**៣.១ អេលីតនិយមបែបទស្សនាទាន**

តាមន័យបែបទស្សនាទានអេលីតនិយមជាទស្សនៈ ជាគំនិត ឬជំនឿដែលប្រកាន់យកទ្រព្យ សម្បត្តិ វង្វាន់លើកទឹកចិត្ត កិត្តិយសនិងការទទួលខុសត្រូវ ជាកម្មសិទ្ធជាកេតនកណ្ឌអាទិភាពដ៏ស័ក្តិសម និងថ្លៃថ្នូរបំផុតរបស់ក្រុមមួយ[៥]។

បើតាមទស្សនៈខាងលើនេះ គេអាចចែកអេលីតនិយមជាប្រាំប្រភេទ៖

**៣.១.១ អេលីតនិយមបែបសាធារណរដ្ឋ** ( Elitisme républicain )

ជាទ្រឹស្តីអេលីតដែលឱ្យតម្លៃជាអាទិភាពទៅលើគុណសម្បត្តិបុគ្គល។

**៣.១.២ អេលីតនិយមបែបអភិជនាធិបតេយ្យ** ( Elitisme aristocratique )

ជាអេលីតនិយមផ្អែកលើកម្មសិទ្ធសង្គម និងគ្រួសារ។

**៣.១.៣ អេលីតនិយមបែបកិត្យានុភាព** ( Elitisme de prestige )

ជាទ្រឹស្តីដែលផ្អែកលើការប្រឡងប្រជែងជ្រើសរើសសម្រិតសម្រាំងក្រុមអេលីតដ៏ម៉ត់ចត់បំផុត។

**៣.១.៤ អេលីតនិយមបែបដាកវីននិយម** ( Elitisme Darwinien )

ជាអេលីតនិយមដែលលើកទឹកចិត្តឱ្យលុបបំបាត់ចោលក្រុមខ្សោយជាជាងការពារក្រុមនោះ[៦]។

**៣.២. អេលីតនិយមបែបវិទ្យាសាស្ត្រសង្គម**

ជាប្រភេទទីពីរនៃអេលីតនិយមបន្ទាប់ពីអេលីតនិយមបែបទស្សនាទាន។ អេលីតនិយមជាចរន្ត ទ្រឹស្តីដែលត្រូវបានបង្កើតដោយលោក ប៉ារ៉ីតូ (V. Pareto) លោក មីសែល (R.Michels) និងលោក ម៉ូស្កា (G. Mosca)។ លោកទាំងបីរូបសុទ្ធតែបានឯកភាពគ្នាលើទស្សនៈដែលចាត់ទុកថាការកាន់កាប់ អំណាចរដ្ឋដោយក្រុមភាគតិចដែលមានវិជ្ជាជីវៈគឺជាការចៀសមិនផុត។ ប៉ុន្តែក្នុងចំណោមលោកទាំងបី លោក មីសែល បានបញ្ចេញទស្សនៈជាការកត់សម្គាល់បន្ថែមទៅលើច្បាប់មិនល្អមួយ (Loi d’airain) របស់ក្រុមអប្បជនាធិបតេយ្យ។ លោកបានវាយតម្លៃយ៉ាងដូច្នេះថាគ្រប់

---

[៥] Olivier Nay, Lexique de science Politique, 3ème Edition. 2014 p191

[៦] សូមមើលពាក្យ ដាកវីននិយមសង្គម សៀវភៅដដែល ទំព័រ១៣៣, ១៩២

គណបក្សនយោបាយទាំងអស់រួម ទាំងគណបក្សកម្មករផងនោះសុទ្ធតែបានដណ្ដើមកាន់កាប់តែម្នាក់ឯង នូវតួនាទីដឹកនាំតាមបែបអេលីតនិយម ពោលគឺរាល់អំណាចដឹកនាំខាងនយោបាយ និងសេដ្ឋកិច្ចរបស់បក្សសុទ្ធតែធ្លាក់ទៅលើក្រុមអេលីត ជាអ្នកដឹកនាំទាំងអស់។

## ៤. ការត្រិះរិះពិចារណាទាក់ទងទៅនឹងអេលីតនិយម

មានការត្រិះរិះពិចារណាជាសំខាន់បីទាក់ទងទៅនឹងអេលីតនិយម។

### ៤.១. អេលីតនិយម និងអប្បជនាធិបតេយ្យ

យើងបានដឹងរួចមកហើយអំពីអ្វីទៅដែលហៅថាអេលីតនិយម។ បន្តទៅទៀតនេះយើងនឹងសិក្សា បន្ថែមទៀតថាតើអេលីតនិយម មានទំនាក់ទំនងបែបណាជាមួយអប្បជនាធិបតេយ្យ? ដំបូងឡើយយើង គប្បីយល់ថាតើអ្វីទៅជាអប្បជនាធិបតេយ្យ?

តាមទស្សនៈរបស់ប្លាតុងអប្បជនាធិបតេយ្យជារបបនយោបាយ ឬរបបគ្រប់គ្រងសង្គមមួយបែប ដែលដឹកនាំរដ្ឋដោយជនមួយក្រុមប្រកបដោយមហិច្ឆតា និងការលោភលន់។ បញ្ជាក់បន្ថែមទៅលើទស្សនៈ នេះអារីស្តូតបានលើកឡើងថាអប្បជនាធិបតេយ្យជារបបគ្រប់គ្រងដឹកនាំដោយមនុស្សមួយក្រុម ដែលគិតគូរ តែអំពីផលប្រយោជន៍របស់ក្រុមខ្លួនប៉ុណ្ណោះ។ បើគេរំលឹកឡើងវិញពីអេលីតនិយមតាមន័យវិទ្យាសាស្ត្រសង្គមរបស់ប៉ារីតូ មីសែលនិងម៉ូស្កា អេលីតនិយមគឺជាទ្រឹស្ដីកត់សម្គាល់ពីការកាន់កាប់អំណាចរដ្ឋដោយ ក្រុមអេលីតដែលមានវិជ្ជាជីវៈ។ ដូច្នេះបើក្រុមភាគតិចដែលមានវិជ្ជាជីវៈយកសមត្ថភាពខាងវិជ្ជាជីវៈទៅ ដឹកនាំសង្គមតាមក្រុមអប្បជនាធិបតេយ្យនោះ អេលីតនិយមនឹងក្លាយទៅជាអេលីតនិយមបែបអប្បជនា ធិបតេយ្យ ហើយទ្រឹស្ដីស្ដីពី កិច្ចសន្យាសង្គមរបស់លោក ថូម៉ាសហូបស៍ ដែលបានបង្កើតក្រោយមកទៀត នឹងក្លាយទៅជាទ្រឹស្ដីដែលគ្មានន័យអ្វីសោះឡើយសម្រាប់ការដឹកនាំនិងគ្រប់គ្រងសង្គម[7]។

[7] ទ្រឹស្ដីនេះហៅកិច្ចសន្យាសង្គមថាជាការបង្កើតសភាពនយោបាយឬសភាពជាពលរដ្ឋដែលមានរូបភាពសំខាន់ពីរ ១ កិច្ច សន្យាមានលក្ខណៈជាហាហគមន៍ ២ កិច្ចសន្យាស្ថិតនៅក្រោមបង្គាប់ពោលគឺបុគ្គលទាំងឡាយបានលះបង់ទៅឱ្យបុគ្គលម្នាក់ ឬបុគ្គលភាគច្រើនក្នុងចំណោមបុគ្គលទាំងឡាយរបស់ខ្លួនដោយប្ដូរយកមកវិញនូវការធានាសន្តិសុខផ្ទាល់។ (សូមមើល អ៊ុំ ប៉ុម ប្រវត្តិគំនិតនយោបាយបច្ចឹមប្រទេស គ្រឹះស្ថានបោះពុម្ពផ្សាយអង្គរ ឆ្នាំ២០០៨ ទំព័រ១០១)។

### ៤.២. អេលីតនិយម និងអភិជនាធិបតេយ្យ

តាមទស្សនៈរបស់អារីស្តូតដដែល អភិជនាធិបតេយ្យជាទ្រឹស្តីដែលកំណត់ពីរបបនយោបាយ ឬ របបគ្រប់គ្រងមួយបែបទៀតដែលដឹកនាំដោយមនុស្សមួយក្រុមដែលគិតគូរពីផលប្រយោជន៍របស់បុរី។ បើអភិជនាធិបតេយ្យមានន័យយ៉ាងនេះ អេលីតនិយមនិងអភិជនាធិបតេយ្យអាចមានទំនាក់ទំនងស្របទិសដៅគ្នា ហើយអាចបន្តស្ថិតស្ថេរដោយសុខដុមជាមួយគ្នាបាន។ ដូច្នេះទ្រឹស្តីនៃកិច្ចសន្យាសង្គមរបស់ថូម៉ាសហូបស៍ និងក្លាយទៅជាគុណធម៌ប្រតិបត្តិប្រកបដោយការទទួលខុសត្រូវ និងមានលក្ខណៈជាកាតព្វកិច្ចរបស់អ្នកដឹកនាំ និងគ្រប់គ្រងសង្គមជាក្រុមអេលីត ហើយចរន្តគំនិតរបស់ប៉ារីតូ មីសែល និងម៉ូស្កានៅតែមានភាព សមស្រប និងត្រឹមត្រូវដដែល។

### ៤.៣. អេលីតនិយម និងប្រជាធិបតេយ្យ

លក្ខណៈសំខាន់របស់ប្រជាធិបតេយ្យគឺការចូលរួមរបស់ប្រជាពលរដ្ឋ។ បើសិនជាពួកអេលីតនិយម ទទួលក្តោបក្តាប់ដោយខ្វះគុណធម៌នូវអំណាចផ្តាច់មុខខាងសមត្ថភាព និងវិជ្ជាជីវៈ ក្នុងដំណើរដឹកនាំ និង គ្រប់គ្រងសង្គម ហើយបដិសេធចោលនូវអំណាចចូលរួមក្នុងកិច្ចការសង្គមពីសំណាក់ប្រជាពលរដ្ឋដែល តំណាងឱ្យមនុស្សភាគច្រើនលើសលុបរបស់សង្គម ពួកអេលីតនិយមបែបនេះនឹងដើរឃ្លាតចាកកាន់តែឆ្ងាយពីប្រជាធិបតេយ្យហើយអ្វីដែលកើតឡើងនៅពីក្រោយនោះគឺ វិបត្តិសង្គមផ្តើមចេញពីទំនាស់ផល ប្រយោជន៍រវាងភាគច្រើន និងភាគតិចហើយកាន់តែគ្រោះថ្នាក់ជាងនេះទៅទៀតនោះគឺបដិវត្តន៍សង្គមអាច នឹងប្រព្រឹត្តឡើងដោយចៀសមិនផុត។

. អេលីត-អេលីតនិយម+អប្បជនាធិបតេយ្យ= គ្រោះថ្នាក់សម្រាប់សង្គម (ទំនាស់ផលប្រយោជន៍)

. អេលីត-អេលីតនិយម+អភិជនាធិបតេយ្យ= សង្គមប្រព្រឹត្តទៅល្អគ្មានគ្រោះថ្នាក់

. អេលីត-អេលីតនិយម+ប្រជាធិបតេយ្យ(គ្មានការចូលរួម)= ប្រជាធិបតេយ្យមិនអាចបដិសន្ធិបាន

. អេលីត-អេលីតនិយម+ប្រជាធិបតេយ្យ(មានការចូលរួម)= ប្រជាធិបតេយ្យអាចកើតឡើងបាន និង ស្ថិតស្ថេរទៅបាន។

## សេចក្តីសន្និដ្ឋាន

*សរុបសេចក្តីមក ទ្រឹស្តីរបស់ពួកអេលីតប្រកាន់ទ្រឹស្តីអេលីតនិយមអាចមានពីរ: ទី១ អេលីតនិយម បែបអប្បជនាធិបតេយ្យ។ ទី២ អេលីតបែបប្រជាធិបតេយ្យ ប៉ុន្តែបដិសេធចោលការចូលរួមរបស់ប្រជាពលរដ្ឋ។ ការក្តោបក្តាប់អំណាចខាងនយោបាយ និងសេដ្ឋកិច្ចរបស់ប្រទេស ដោយក្រុមភាគតិច ដែលជាក្រុមអេលីត គឺជាដំណើរប្រព្រឹត្តទៅរបស់សង្គមដោយចៀសមិនផុត។ ប៉ុន្តែទោះបីជាយ៉ាងណាក្តី ក៏ក្រុមអេលីតដែល ប្រកាន់តាមទ្រឹស្តីអេលីតនិយម គប្បីយកសមត្ថភាពខាងវិជ្ជាជីវៈរបស់ខ្លួនទៅបំរើចំពោះផលប្រយោជន៍រួមរបស់មនុស្សភាគច្រើននៅក្នុងសង្គម ដោយធ្វើយ៉ាងណាផ្សារភ្ជាប់ខ្លួនទៅនឹងវប្បធម៌ "ចូលរួមគិត ចូលរួមធ្វើ និងចូលរួមទទួលខុសត្រូវ" របស់ប្រជាជនភាគច្រើននោះទើបក្រុមអេលីតមានឈ្មោះថាជាអ្នករក្សាបាននូវតម្លៃពិតរបស់ខ្លួន ដែលសង្គមទទួលស្គាល់ ហើយជាអ្នកដែលបានរួមចំណែកកសាងសង្គមជាតិមួយប្រកប ដោយលក្ខណៈប្រជាធិបតេយ្យពេញបរិបូណ៌។*

## ឯកសារពិគ្រោះ


១- *វចនានុក្រម* Oxford advance leaner´s Dictionary, New Edition, 2003.

២- Olivier Nay Lexique de Science Politique. 3ème Edition, 2014.

៣- *អ៊ុំ ប៊ុម ប្រវត្តិគំនិតនយោបាយបស្ចឹមប្រទេស គ្រឹះស្ថានបោះពុម្ពផ្សាយអង្គរ ឆ្នាំ២០០៨។*

# ប្រវត្តិស្រុករតនមណ្ឌល និងរមណីយដ្ឋានទេសចរណ៍

*ដោយៈ* **លោក សួ ប៊ុណ្ណារ៉ាត់**

*ប្រធាននាយកដ្ឋានប្រវត្តិវិទ្យានិងវិទ្យាសាស្ត្រនយោបាយ*

*នៃវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម, រាជបណ្ឌិត្យសភាកម្ពុជា*

## ១. សេចក្តីផ្តើម

*ខេត្តបាត់ដំបង ជាខេត្តចំណាស់មួយ ដែលស្ថិតនៅភាគពាយ័ព្យនៃប្រទេសកម្ពុជា ធ្លាប់មានប្រវត្តិរឿងរ៉ាវបែបប្រវត្តិសាស្ត្រ ស្មុគស្មាញជាមួយប្រទេសជិតខាង។ តាមសន្ធិសញ្ញាបារាំង-សៀម ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩០៧ តម្រូវឱ្យសៀមត្រូវប្រគល់ឱ្យកម្ពុជាវិញ នូវទឹកដីដែលខ្លួនធ្លាប់កាន់កាប់និងគ្រងនោះគឺ បាត់ដំបង សៀមរាបអង្គរ និងសិរីសោភ័ណ។*

*តាំងពីដើមរៀងមកខេត្តនេះត្រូវបានគេចាត់ទុកជាខេត្តស៊ីវិល័យ និងជាជម្រុកស្រូវយ៉ាងធំនៅព្រះរាជាណាចក្រកម្ពុជា ហើយក៏ជាខេត្តដែលមានធនធានវប្បធម៌ប្រវត្តិសាស្ត្រ ធនធានធម្មជាតិ និងធនធានកែច្នៃជាច្រើនផងដែរ។ ធនធានទាំងនោះជាសក្តានុពលមួយយ៉ាងសំខាន់ សម្រាប់បម្រើឱ្យវិស័យទេសចរណ៍។ បច្ចុប្បន្នធនធានសក្តានុពលទាំងអស់នៅក្នុងខេត្ត បាននឹងកំពុងទាក់ទាញភ្ញៀវទេសចរជាតិ និងអន្តរជាតិមកទស្សនាជារៀងរាល់ថ្ងៃ។ តួយ៉ាងដូចជារមណីយដ្ឋានក្នុងខេត្តនិងតាមស្រុកនានាផងដែរ។ ដោយឡែកស្រុករតនមណ្ឌលជាស្រុកដែលធ្លាប់ស្ថិតក្នុងសមរភូមិក្តៅនៃសង្គ្រាមស៊ីវិល។ បន្ទាប់ពីបានបញ្ចប់សង្គ្រាមស៊ីវិលនៅឆ្នាំ១៩៩៨ ខេត្តក៏ដូចជាស្រុកបានប្រែមុខមាត់ថ្មី រីកចម្រើនគួរកត់សម្គាល់ ថែមទាំងមានរមណីយដ្ឋានទេសចរណ៍ជាច្រើនកន្លែង ដែលកំពុងក្លាយជាកន្លែងទាក់ទាញភ្ញៀវទេសចរជាតិនិងអន្តរជាតិឱ្យមកទស្សនាកាន់តែច្រើនឡើងៗ។ សមិទ្ធផលដ៏សំខាន់នេះ ជាកេរមរតកពីធម្មជាតិនិងពីអតីតកាលដែលបុព្វបុរសខ្មែរបានបន្សល់ទុកឱ្យ ដូចជារមណីយបុរេប្រវត្តិសាស្ត្រភ្នំទាកទ្រាំងជាដើម។ ផ្អែកលើសច្ចធម៌ប្រវត្តិសាស្ត្រ ខេត្តបាត់ដំបង គឺជាខេត្តដែលមានសំណង់ប្រាសាទដូចខេត្តនានាក្នុងប្រទេសកម្ពុជាដែរ។ ជាខេត្តមានវប្បធម៌ផ្សេងៗជាច្រើនចម្រុះដូចជា សិល្បៈ ទំនៀមទម្លាប់ ប្រពៃណី សាសនា ថែមទាំងមានសក្តានុពលសេដ្ឋកិច្ច ខ្លាំងៗ។ ដោយសារតែកេរមរតកដ៏ច្រើនបែបនេះទើបធ្វើឱ្យខេត្តមានមោទនភាពនូវសមិទ្ធផលទាំងនោះ ហើយសក្តានុពលទាំងនោះទៀតសោតបានដើរតួយ៉ាងសំខាន់សម្រាប់ទាក់ទាញភ្ញៀវទេសចរ ជាហេតុធ្វើឱ្យវិស័យទេសចរណ៍កាន់តែមានមានភាពទាក់ទាញនិងការរីកចម្រើន។ សព្វថ្ងៃ រាល់សក្តានុពលទាំងអស់នៅក្នុងស្រុករតនមណ្ឌល ត្រូវបានគេយកមកប្រើប្រាស់ក្នុងវិស័យទេសចរណ៍ ហើយសម្រាប់អនាគតនឹងផ្តល់ផលប្រយោជន៍ដល់សហគមន៍ថែមទៀត។*

## ២. ប្រវត្តិស្រុករតនមណ្ឌល

ជាស្រុកមួយស្ថិតក្នុងចំណោមស្រុកទាំង ១៣នៅខេត្តបាត់ដំបង ស្រុកនេះពីមុន (សម័យសង្គមរាស្ត្រនិយម) គេហៅថាស្រុកវល្លិរសង្គម ក្រោយមក (សម័យសាធារណរដ្ឋខ្មែរ) គេប្តូរ មកហៅ រតនមណ្ឌលវិញរហូតមកដល់បច្ចុបបន្ន។ បច្ចុប្បន្ន ស្រុករតនមណ្ឌលមានភូមិមួយឈ្មោះដូចជាចម្លែក គឺ ភូមិជាមន្រ្តី ដែលស្ថិតនៅក្នុងឃុំត្រែង តាមការសាកសួរចាស់ៗក្នុងភូមិបានដំណាលថា ពីមុនមកភូមិនេះជាភូមិដែលមានមន្រ្តីធំៗជាច្រើនរស់នៅ។

ទីប្រជុំជនរដ្ឋបាលស្រុករតនមណ្ឌលត្រូវបានបង្កើតឡើងតាមព្រះរាជក្រមលេខ១៩១ ប.វ. ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ១៩៦៤ ដែលកាលនោះមាន៦ឃុំ ឃុំប៉ៃលិន ឃុំសំឡូត ឃុំក្រញូង ឃុំជីសាង ឃុំស្រែអន្ទាក់ និង ឃុំកំរៀង[1]។ ជំនាន់នោះទឹកដីប៉ៃលិនជាទឹកដីស្ថិតនៅក្នុងខេត្តបាត់ដំបង ទើបក្រោយមកនៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ ២០០៨ ព្រះបាទសម្តេចព្រះបេមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់បានឡាយព្រះហស្ថលេខា លើព្រះរាជក្រឹត្យមួយ ដើម្បីផ្លាស់ប្តូរក្រុងមួយចំនួនឱ្យទៅជាខេត្តតួយ៉ាងដូចជា ក្រុងកែប ក្រុងប៉ៃលិន និង ក្រុងព្រះសីហនុ ឱ្យទៅជាខេត្ត ព្រមទាំងកែតម្រូវព្រំប្រទល់ខេត្តផ្សេងៗទៀតផងដែរ។

តាមប្រវត្តិសាស្រ្តតាំងពីសម័យអាណាព្យាបាលបារាំង(១៨៦៣-១៩៥៣) រហូតដល់សម័យសង្គមរាស្រ្ត និយម និងសម័យសាធារណរដ្ឋខ្មែរ ប៉ៃលិនជាស្រុកមួយចំណុះខេត្តបាត់ដំបង យ៉ាងណាមិញដូចក្នុងប្រលោមលោករឿងកុលាបប៉ៃលិន របស់អ្នកនិពន្ធ ញ៉ុក ថែម និពន្ធនៅឆ្នាំ១៩៣៦ បាននិយាយទាក់ទងទឹកដីប៉ៃលិន ថាជាទឹកដីស្ថិតនៅក្នុងទឹកដីខេត្តបាត់ដំបង ហើយទីតាំងដែលលោកហ្លួងរតនសម្បត្តិខូចរថយន្ត គឺស្ថិតនៅក្នុងទឹកដីនៃស្រុករតនមណ្ឌលតែម្តង ដែលបច្ចុប្បន្នចំណុចនៃទីតាំងនេះស្ថិតត្រង់ព្រំប្រទល់ស្រុករតនមណ្ឌលជាមួយខេត្តប៉ៃលិន។ ចំណែកឯតំបន់រដ្ឋបាលអណ្តើកហែប ទីតាំងរដ្ឋបាលរបស់អាជ្ញាធរដែនដីដែលត្រូវបានបង្កើតឡើងតាមព្រះរាជក្រមចុះថ្ងៃទី១ ខែធ្នូ ឆ្នាំ១៩៦៥[2] ស្ថិតនៅក្នុងខេត្តបាត់ដំបង។ នៅមុនសមាហរណកម្មតំបន់ប៉ៃលិននៅឆ្នាំ១៩៩៦ ស្រុករតនមណ្ឌល គឺជាតំបន់ក្តៅនៃសមរភូមិប្រយុទ្ធរវាងកងទ័ពរបស់រដ្ឋាភិបាលនិងទ័ពឧទ្ទាមក្រៅច្បាប់ខ្មែរក្រហម។ ម្យ៉ាងវិញទៀត បន្ទាប់ពីបានបញ្ចប់សង្រ្គាមស៊ីវិលក្នុងស្រុកដែលបានអូសបន្លាយជាងពីរទសវត្សរ៍ (ឆ្នាំ ១៩៧០រហូតដល់ឆ្នាំ១៩៩៨) បានធ្វើឱ្យប្រទេសស្ថិតក្នុងភាពហ្វឹកវរ បន្សល់ទុកនូវគ្រាប់មីនក្នុងដីយ៉ាងច្រើនសន្ធឹកសន្ធាប់ ប្រជាពលរដ្ឋមួយចំនួន

[1] ព្រះរាជក្រមលេខ១៩១ ប .វ.ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ ១៩៦៤

[2] ព្រះរាជក្រមចុះថ្ងៃទី១ ខែធ្នូ ឆ្នាំ១៩៦៥

មានពិការភាព។ បន្ទាប់មករាជរដ្ឋាភិបាលបានខិតខំប្រឹងប្រែងស្តារខឿនសេដ្ឋកិច្ចជាតិឡើងវិញរហូតទទួលបាននូវភាពរីកចម្រើនគួរជាទីមោទនៈ។ នយោបាយឈ្នះឈ្នះរបស់រាជរដ្ឋាភិបាលឆ្នាំ១៩៩៨ បានឈានទៅរកការបញ្ចប់សង្គ្រាមស៊ីវិលក្នុងស្រុក ដោយបើករាំងននសន្តិភាពលែងមានខ្មែរស ខ្មែរក្រហមគឺខ្មែរតែមួយឈាមជ័រពូជខ្មែរអង្គរទាំងអស់គ្នា។ រាជរដ្ឋាភិបាលបានកែប្រែដីចម្ការមីនទៅជាដីសម្រាប់ប្រកបមុខរបរកសិកម្ម ប្តូរពីការឮសូរសំឡេងគ្រាប់មីនផ្ទុះ គ្រាប់កាំភ្លើងប្រែមកជាសំឡេងដូរ្យតន្ត្រី និងសំឡេងសូត្រធម៌វិញ។

### ៣- ស្ថានភាពភូមិសាស្ត្រ

ខេត្តបាត់ដំបង ជាខេត្តដែលមានសក្តានុពលសេដ្ឋកិច្ចខ្លាំងពិសេសវិស័យកសិកម្ម បច្ចុប្បន្នខេត្តមានស្រុកចំនួន១៣ ឃុំចំនួន៩២ សង្កាត់ចំនួន១០ ភូមិចំនួន៨០៩ មានប្រជាពលរដ្ឋសរុបចំនួន១.២៦៨.១៩០នាក់ ស្ត្រីចំនួន៦៣៩.៦៨០នាក់និង២៦៣.៤៣៥គ្រួសារ[3]។ ដង់ស៊ីតេប្រជាជនមាន១០៤.៩២នាក់ក្នុងមួយគីឡូម៉ែត្រការ៉េ ហើយកម្លាំងពលកម្មជាសក្តានុពលចាប់ពីអាយុ១៨ឆ្នាំដល់អាយុ៣៥ឆ្នាំមានចំនួន៥៦ភាគរយ ចំនួនប្រជាពលរដ្ឋប្រកបមុខរបរកសិកម្មមាន៧២.២០ភាគរយ។ ខេត្តមានក្រុងមួយគឺក្រុងបាត់ដំបង មានស្រុក១៣ និង១០២ឃុំសង្កាត់ មានផ្ទៃដី១១៧០២ គ.ម$^{២}$៖

១.ក្រុងបាត់ដំបងមានសង្កាត់ទួលតាឯក • ព្រែកព្រះស្តេច • រតនៈ • ចម្ការសំរោង • ស្លាកែត • ក្តុលដូនទាវ•អូរម៉ាល់•វត្តគរ•អូរចារ•ស្វាយប៉ោ

២.ស្រុកបាណន់ មាន៨ឃុំ៖ កន្ទឺ ១ • កន្ទឺ ២ • បាយដំរាំ • ឈើទាល • ចែងមានជ័យ • ភ្នំសំពៅ • ស្នឹង • តាគ្រាម

៣.ស្រុកថ្មគោលមាន១០ឃុំ៖ តាពូង • តាម៉ឺន • អូរតាគី • ជ្រៃ • អន្លង់រុន • ជ្រោយស្តៅ • បឹងព្រីង • គោកឃ្មុំ • បន្សាយត្រែង • រូងជ្រៃ

៤.ស្រុកបវេលមាន៨ឃុំ៖ បវេល • ខ្នាចរមាស • ល្វា • ព្រៃខ្ពស់ • អំពិលប្រាំដើម • ក្តុលតាហែន • បឹងប្រាំ • ឃ្លាំងមាស

៥.ស្រុកឯកភ្នំមាន៧ឃុំ៖ ព្រែកនរិន្ទ • សំរោងក្នុង • ព្រែកខ្ពប • ព្រែកហ្លួង • ពាមឯក • ព្រៃចាស់ • កោះជីវាំង

៦.ស្រុកមោងឫស្សីមាន៩ឃុំ៖ មោង • គារ • ព្រៃស្វាយ • ឫស្សីក្រាំង • ជ្រៃ • តាលាស់ • កកោះ • ព្រៃតូច • របស់មង្គល

៧.ស្រុករុក្ខគិរីមាន៥ឃុំ៖ ព្រែកជីក • ព្រៃត្រឡាច • មុខរាហ៍ • ស្តុកប្រវឹក • បាសាក់

៨.ស្រុករតនមណ្ឌលមាន៥ឃុំ៖ ស្តៅ • អណ្តើកហែប • ផ្លូវមាស • ត្រែង • រស្មីសង្ហារ

៩.ស្រុកសង្កែមាន១០ឃុំ៖ អន្លង់វិល • នរា • តាប៉ុន • រកា • កំពង់ព្រះ • កំពង់ព្រៀង • រាំងកេសី • អូរដំបង១ • អូរដំបង២ • វត្តតាមិម

១០.ស្រុកសំឡូតមាន៧ឃុំ៖ ស៊ុង • មានជ័យ • សំឡូត•កំពង់ល្ពៅ •អូរសំរិល•តាតោក•តាសាញ

១១.ស្រុកសំពៅលូនមាន៦ឃុំ៖ អង្គរបាន • សិរីមានជ័យ•សន្តិភាព•តាស្តា •សំពៅលូន•ជ្រៃសីមា

១២.ស្រុកភ្នំព្រឹកមាន៦ឃុំ៖ ភ្នំព្រឹក • បារាំងធ្លាក់ • អូររំដួល • ពេជ្រចិន្តា • ចក្រី • បួរ

១៣.ស្រុកកំរៀងមាន៦ឃុំ ៖ កំរៀង • អូរដា • បឹងរាំង • ត្រាង • តាសែន • តាគ្រី

១៤.ស្រុកគាស់ក្រឡមាន៦ឃុំ ៖ធ្នាល់មាន់ •ដូនបា • ហប់ • គាស់ក្រឡ • ព្រះផុស • ធិបតី

ដោយឡែកស្រុករតនមណ្ឌល ជាស្រុកមួយក្នុងចំណោមស្រុកទាំង១៣នៅក្នុងខេត្តបាត់ដំបង មានចំងាយ៣៥គីឡូម៉ែត្រពីទីប្រជុំជនខេត្តបាត់ដំបង គឺត្រូវធ្វើដំណើរតាមផ្លូវជាតិលេខ៥៧ថ្មីឬផ្លូវជាតិលេខ១០ចាស់ ជាផ្លូវឆ្ពោះទៅខេត្តប៉ៃលិន។ ស្រុករតនមណ្ឌលមានទីតាំងស្ថិតនៅប៉ែកខាងនិរតីនៃខេត្តបាត់ដំបង មានព្រំប្រទល់៖

-ខាងជើងជាប់នឹងស្រុកបាណន់ និងស្រុកបវេល

-ខាងត្បូងជាប់នឹងស្រុកសំឡូត

-ខាងលិចជាប់នឹងខេត្តប៉ៃលិន

-ខាងកើតជាប់នឹងស្រុកបាណន់

ស្រុកមានផ្ទៃដីសរុប ៧៩.២០០ហិកតា ដីចែកចេញជាបីប្រភេទ គឺដីក្រហម ដីខ្មៅ និងដីល្បាយខ្សាច់។

មានប្រជាជនសរុប ១២,៤២៤ គ្រួសារ មនុស្សរាយ ៤៥,៥៩០នាក់ ស្រី ២២,៧០៣នាក់ អាយុ ១៨ ឆ្នាំឡើង។

៣០,៩៤៧នាក់ ។




ផែនទីរដ្ឋបាលស្រុករតនមណ្ឌល(ប្រភពរដ្ឋបាលស្រុក)

ស្រុករតនមណ្ឌលមានឃុំចំនួន៥ ភូមិចំនួន៣៨ និងមានក្រុមចំនួន៥៥៨ក្រុម[4]។

| ល.រ | លេខកូដឃុំ | ឈ្មោះឃុំជាអក្សរខ្មែរ | ឈ្មោះឃុំជាអក្សរខ្មែរ | ចំនួនភូមិ |
|---|---|---|---|---|
| ១ | ០២០៧០១ | ឃុំស្តៅ | Sdau Commune | ៨ |
| ២ | ០២០៧០២ | ឃុំអណ្តើកហែប | Andaeuk Haeb Commune | ៧ |
| ៣ | ០២០៧០៣ | ឃុំផ្លូវមាស | Phlov Meas Commune | ៧ |
| ៤ | ០២០៧០៤ | ឃុំត្រែង | Traeng Commune | ៨ |
| ៥ | ០២០៧០៥ | ឃុំរស្មីសង្ហារ | Reaksmei Songha Commune | ៨ |

ស្ថិតិភូមិ និង ឃុំរបស់ស្រុករតនមណ្ឌល

| ឃុំស្តៅ | ឃុំអណ្តើកហែប | ឃុំផ្លូវមាស | ឃុំត្រែង | ឃុំរស្មីសង្ហារ |
|---|---|---|---|---|
| -ភូមិ ស្តៅ | -ភូមិអណ្តើកហែប | -ភូមិដីប៉ាង | -ភូមិគីឡូ៣៨ | -ភូមិរស្មីសង្ហារ |
| -ភូមិគោកជរ | -ភូមិកណ្តាលស្ទឹង | -ភូមិផ្លូវមាស | -ភូមិគីឡូ | -ភូមិនាងលេម |
| -ភូមិបរិបូណ៌ | -ភូមិសេរីវន្ត | -ភូមិទឹកសាប | -ភូមិជាមន្ត្រី | -ភូមិពេជ្រចង្វា |
| -ភូមិដូនមាយ | -ភូមិថ្មព្រួស | -ភូមិអូរត្រែង | -ភូមិភ្នាវ | -ភូមិអូរដៃខ្លា |
| -ភូមិចម្ការល្មុត | -ភូមិព្រៃអំពរ | -ភូមិសេកសក | -ភូមិដីសាង | -ភូមិបាដាកដើង |
| -ភូមិបាណន់ | -ភូមិស្វាយជួរ | -ភូមិថ្មដារ | -ភូមិស្វាយស | -ភូមិបាដាកត្បូង |
| -ភូមិដង្កត់ | -ភូមិថ្វាក | -ភូមិអូរល្មូន | -ភូមិតាគ្រក់ | -ភូមិអូរឃ្មុំ |
| -ភូមិបឹងអំពិល | | | -ភូមិប្អូរុន | -ភូមិអណ្តើក១១ |

## ៣. ១-សណ្ឋានដីស្រុករតនមណ្ឌល

សណ្ឋានដីនៅស្រុករតនមណ្ឌលគឺមានសណ្ឋានជាតំបន់ខ្ពង់រាបផងនិងតំបន់ទំនាបផង គេអាចប្រកបរបរដាំដំណាំសិកម្មនិងនិងដំណាំឧស្សាហកម្មបាន។ នៅក្នុងសម័យសង្គមរាស្ត្រ និយមភូមិសាស្ត្រនៃតំបន់អណ្តើកហែប សណ្ឋានដីមានលក្ខណៈអំណោយផលខ្លាំងទៅលើដំណាំកប្បាសបន្ទាប់មកគឺអំពៅ។ បច្ចុប្បន្នប្រជាជនចំនួន ៨២,៤% ប្រកបរបរកសិកម្មជាចម្បង និងប្រជាជន ១៧,៦% ប្រកបមុខរបរក្រៅពីកសិកម្ម[5]។ ដោយសារសម្បូរទៅដោយតំបន់ខ្ពង់រាប យើងសង្កេតឃើញថាស្រុករតនមណ្ឌលមានភ្នំជាច្រើនដូចជាៈ ភ្នំបាណន់ ភ្នំដូនមាយ ភ្នំ

[4] អធិការដ្ឋាននគរបាលស្រុករតនមណ្ឌល ស្ថិតិសរុបប្រជាជនបច្ចុប្បន្ន គិតចាប់ពីខែឧសភា ដល់ខែមិថុនា ឆ្នាំ២០២៣

[5] រដ្ឋបាលស្រុករតនមណ្ឌល

ភ្នាស ភ្នំវាយចាប ភ្នំទាកទ្រាំង ភ្នំដីប៉ាង ភ្នំវែង ភ្នំនាងលេម ភ្នំនាងពួន ភ្នំននោង ភ្នំវាលរាប(ជួរភ្នំ) ភ្នំសភ្នំប្រាញ់ ភ្នំឆ្មាមភ្នំស្ទឹក ភ្នំផ្កាយព្រឹកជាដើម។

### ៣. ២-អាកាសធាតុ

ខេត្តបាត់ដំបង ក៏ដូចជាខេត្តដ៏ទៃមួយចំនួននៅប្រទេសកម្ពុជាទាំងមូលដែរ ដោយប្រទេសកម្ពុជាទទួលឥទ្ធិពលនៃខ្យល់មូសុង ធ្វើឱ្យប្រទេសនាំឱ្យមានរដូវពីរច្បាស់លាស់គឺរដូវប្រាំង (ពីខែវិច្ឆិកាដល់ខែមេសា) និងរដូវវស្សា (ពីខែឧសភាដល់ខែតុលា) មានលក្ខណៈអំណោយផលដល់ដំណាំកសិកម្ម រុក្ខជាតិ និងភ្ញៀវទេសចរ។ អាកាសធាតុក្តៅបំផុតនៅរដូវប្រាំងមានរហូតដល់ ៣៩ អង្សាសេ ត្រជាក់បំផុតដល់ ២០អង្សាសេ ហើយអាកាសធាតុមានការប្រែប្រួលទៅតាមរដូវកាលនីមួយៗ កម្ពស់ទឹកភ្លៀងជាមធ្យម ១១៨១.៤ មីលីម៉ែត្រក្នុងមួយឆ្នាំ[6]។ ជារួមអាកាសធាតុនៅនៅបាត់ដំបងក៏ដូចក្នុងព្រះរាជាណាចក្រកម្ពុជាទាំងមូលដែរ គឺមានការប្រែប្រួលទៅតាមតំបន់នីមួយៗ ហើយពុំដែលជួបប្រទះនូវរដូវរងាខ្លាំង ឬក្តៅខ្លាំងទេ។ រដូវទាំងពីរនេះធ្វើឱ្យប្រជាពលរដ្ឋគេចាំច្បាស់ ដើម្បីជាជំនួយក្នុងរបរកសិកម្មរបស់គេ។ នៅរដូវប្រាំងព្រះរាជាណាចក្រកម្ពុជាមានភ្ញៀវទេសចរបរទេស ធ្វើដំណើរមកទស្សនាច្រើន ព្រោះស្របពេលរដូវវិស្សមកាលនៅស្រុកគេផង។ កត្តាលក្ខណៈអាកាសធាតុល្អប្រសើរនេះ ធ្វើឱ្យព្រះរាជាណាចក្រកម្ពុជាពុំសូវជួបប្រទះគ្រោះរាំងស្ងួត និងទឹកជំនន់ផ្ទួនៗជាប់គ្នា និងពុំដែលជួបប្រទះនូវខ្យល់ព្យុះ និងការធ្លាក់ទឹកកកឡើយ។ រដូវប្រាំងនៅប្រទេសកម្ពុជាចែកជាពីរគឺ ៖ រដូវក្តៅ និងរដូវរងារ។ ពួកអឺរ៉ុបអាម៉េរិក ពួកគេសប្បាយរីករាយនឹងមកលេងប្រទេសកម្ពុជា ដោយសារតែមានអាកាសធាតុល្អបំផុតសម្រាប់គេ គឺមានសីតុណ្ហភាពមធ្យម ២៤ អង្សាសេ ទឹកសន្សើមធ្លាក់នៅខែមីនា និងមេសា[7]។ ភ្លៀងធ្លាក់ដំបូងនៅចុងខែមេសា ដំណាំស្រូវ និងដំណាំផ្សេងៗទៀតគេចាប់ផ្តើមដាំ។

### ៣. ៣-វិស័យសុខាភិបាល

សុខាភិបាលនៅស្រុករតនមណ្ឌលធានាបាននូវសុខមាលភាព និងសុខភាពដល់ប្រជាពលរដ្ឋគ្រប់រូប និងមានកម្មវិធីចាក់ថ្នាំបង្ការជំងឺដល់កូនចៅប្រជាពលរដ្ឋ និងចាក់ថ្នាំបង្ការជំងឺដល់សត្វពាហនៈរបស់ប្រជាពលរដ្ឋ។ ស្រុករតនមណ្ឌលមានមណ្ឌលសុខភាព៤គឺស្ថិតនៅឃុំស្តៅ ឃុំរស្មីសង្ហា ឃុំត្រែងនិងឃុំផ្លូវមាស។ មណ្ឌលសុខភាពទាំងនោះ បានបង្កលក្ខណៈងាយស្រួលដល់ប្រជាជនក្នុងសហគមន៍ និង

[6] សក្តានុពលនិងឱកាសវិនិយោគរបស់រដ្ឋបាលខេត្តបាត់ដំបង ឆ្នាំ២០១៨ -ដ-ឯ-ម- ទំព័រ៦

ភ្ញៀវទេសចរ។ មានកន្លែងលក់ឱសថឯកជន ចំនួន១៧កន្លែង[8]។

សកម្មភាពសុខាភិបាលនៅស្រុករតនមណ្ឌល គឺមន្ត្រីសុខាភិបាលបានចុះតាមភូមិដ្ឋានរបស់ប្រជាពលរដ្ឋ ណែនាំពីអនាម័យ ទឹកស្អាត ការពារជំងឺឆ្លង បំបាត់ជំរកមូស និងសកម្មភាពណែនាំអំពីសេវាពន្យាកំណើត និងណែនាំអំពីជំងឺឆ្លងនានាដល់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន។



### ៣. ៤-គមនាគមន៍

ប្រព័ន្ធគមនាគមន៍ជាសរសៃឈាមយ៉ាងសំខាន់ សម្រាប់បម្រើឱ្យវិស័យសេដ្ឋកិច្ច ដូច្នេះយើងសង្កេតឃើញថាចាប់តាំងពីខេត្តទៅដល់ទីប្រជុំជននានារបស់ ស្រុក ឃុំ ភូមិគឺមានស្ពានបេតុងធ្ងន់កាត់អូរជាច្រើន ថ្នល់ក្រាលកៅស៊ូស្អាតល្អ សឹងទៅដល់គ្រប់រមណីយដ្ឋាននានានៅក្នុងស្រុកទាំងមូល។ ភាពល្អប្រសើរទាំងនេះគឺបង្កភាពងាយស្រួលដល់ប្រជាពលរដ្ឋក្នុងការធ្វើដំណើរ ដឹកជញ្ជូនផលិតផល និងថែមទាំងបង្កភាពងាយស្រួលដល់ភ្ញៀវទេសចរគ្រប់ប្រភេទ។ ហេដ្ឋារចនាសម្ព័ន្ធនិងបរិស្ថានដ៏ស្រស់ត្រកាលតាមដងផ្លូវកាន់រមណីយដ្ឋាននានាបាន

ធ្វើឱ្យមានការទាក់ទាញ គយគន់ពីសំណាក់ភ្ញៀវទេសចរ។



ហេដ្ឋារចនាសម្ព័ន្ធក្នុងស្រុក

### ៣. ៥-វិស័យសាសនា

ព្រះពុទ្ធសាសនាបានចាក់គ្រឹះយ៉ាងមាំក្នុងចិត្តគំនិតខ្មែរ សង្គមខ្មែរ ទំនោរខ្មែរតាំងពីយូរអង្វែងណាស់មកហើយ ថែមទាំងបានរួមចំណែកខ្លាំងក្លាក្នុងការអភិវឌ្ឍសង្គមខ្មែរ លើគ្រប់វិស័យតាំងពីអតីតកាលរហូតមកដល់បច្ចុប្បន្ន។ ដោយសារតែព្រះពុទ្ធសាសនា មានគុណូបការៈបែបនេះហើយ ទើបរាជរដ្ឋាភិបាលបានចាត់ទុកព្រះពុទ្ធសាសនាជាសាសនារដ្ឋ ហើយដើម្បីការពារចំពោះព្រះពុទ្ធសាសនាកុំឱ្យមានជនឱកាសនិយមធ្វៀតយកព្រះពុទ្ធសាសនាធ្វើជាឧបករណ៍ បំរើផលប្រយោជន៍ផ្ទាល់ខ្លួន។

[8] ស្រុករតនមណ្ឌល កម្មវិធីវិនិយោគ៣ឆ្នាំរំកិល ២០២៣-២០២៥

ពលរដ្ឋខ្មែរតាមរយៈតំណាងរបស់ខ្លួនដោយបានចងក្រងបញ្ចូលក្នុងច្បាប់ រដ្ឋធម្មនុញ្ញ ត្រង់ជំពូក៣ "អំពីសិទ្ធិ និងករណីកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ"មាត្រា៤៣ ចែងថា" ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ "។ ស្រុករតនមណ្ឌលមានវត្តចំនួន២៤ ព្រះសង្ឃចំនួន១៤០អង្គ ភិក្ខុចំនួន៦៤អង្គ សាមណេរចំនួន៧៦អង្គ ដូនជីចំនួន៤៨នាក់ តាជីចំនួន៥នាក់។ អាចារ្យចំនួន៤៩នាក់ គណៈកម្មការវត្តចំនួន៧៩នាក់។ បន្ទាប់ពីព្រះពុទ្ធសាសនា ក៏មានប្រជាជនមួយចំនួនទៀតក៏ងាកមកជំនឿលើសាសនាគ្រិស្តផងដែរ។ ស្រុករតនមណ្ឌលមានវិហារឥស្លាមចំនួន៤ ស្នាក់ការសាសនាគ្រិស្តចំនួន១១[9]។



វត្តត្រែង

## ៣.៦-វិស័យសិក្សាធិការ

វិស័យសិក្សាធិការមាន តួនាទីសំខាន់ណាស់ក្នុងការបណ្តុះធនធានមនុស្ស ដើម្បីកុំឱ្យកូនចៅប្រជាពលរដ្ឋជួបប្រទះនូវអនក្ខរភាព។ ក្នុងវិស័យសិក្សាធិការនេះ ស្រុករតនមណ្ឌលមានតាំងពីកម្រិតមតេយ្យរសិក្សាហូតដល់វិទ្យាល័យ។ ដូច្នេះ យើងឃើញថាសាលារៀននៅស្រុករតនមណ្ឌល គឺមានសឹងគ្រប់ ភូមិ ឃុំ របស់ស្រុក។ ឯទីតាំងការិយាល័យអប់រំយុវជននិងកីឡាស្រុក គឺស្ថិតនៅទីប្រជុំជនឃុំស្តៅ។ តារាងស្ថិតិសិស្សនិងថ្នាក់រៀននៅស្រុករតនមណ្ឌល[10]។

តារាងស្ថិតិសិស្សនិងថ្នាក់រៀនក្នុងឃុំស្តៅ

| ល.រ | ឈ្មោះសាលារៀន | ចំនួនសិស្សមត្តេយ្យ | | | ចំនួនសិស្សបឋម. មធ្យម | | |
|---|---|---|---|---|---|---|---|
| | | សរុប | ស្រី | ថ្នាក់ | សរុប | ស្រី | ថ្នាក់ |
| ១ | សាលាបឋមសិក្សា អ៊ិនស៊ីដារ៉េ | | | | ៦៤៩ | ៣១២ | ១៥ |
| ២ | សាលាបឋមសិក្សា បឹងអំពិល | ៨៩ | ៥១ | ៣ | ៣៦៧ | ១៧១ | ១២ |

[9] មន្ទីរធម្មការនិងសាសនាខេត្តបាត់ដំបង តារាងស្ថិតិ វត្ត ព្រះសង្ឃ អាចារ្យ គណៈកម្មការ តាជី យាយជី ព.ស ២៥៦៦ គ.ស ២០២២

[10] ការិយាល័យអប់រំ យុវជននិងកីឡាស្រុករតនមណ្ឌល ស្ថិតិសិស្សនិងថ្នាក់រៀនក្នុងស្រុករតនមណ្ឌលសម្រាប់ឆ្នាំសិក្សា២០២១-២០២២

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៣ | សាលាបឋមសិក្សា ស្រែអណ្ដូង | ៥៦ | ៣១ | ២ | ១៨៣ | ៩៦ | ៦ |
| ៤ | សាលាបឋមសិក្សា គោកជ័រ | | | | ១១៩ | ៥៧ | ៦ |
| ៥ | សាលាបឋមសិក្សា ដង្កត់ | | | | ៩៨ | ៤៥ | ៦ |
| ៦ | សាលាបឋមសិក្សាបឹងខ្ទឹង(ឧបសម្ព័ន្ធដង្កត់) | | | | ១៣ | ៣ | ១ |
| ៧ | សាលាបឋមសិក្សា បរិបូរណ៍ | ១៥ | ៦ | ១ | ១០៩ | ៥២ | ៦ |
| ៨ | សាលាបឋមសិក្សា ដូនមាយ | | | | ៩៤ | ៤៧ | ៥ |
| ៩ | សាលាមត្តេយ្យសិក្សា អ៊ិនស៊ីដារ៉េ | ១៧៦ | ៩៥ | ៤ | | | |
| ១០ | វិទ្យាល័យ ស្តៅសន្តិភាព | | | | ១០២៦ | ៥៧៤ | ២៤ |
| ១១ | អនុវិទ្យាល័យ រតនមណ្ឌល | | | | ២៨៨ | ១៥៥ | ៧ |

តារាងស្ថិតិសិស្សនិងថ្នាក់រៀនក្នុងឃុំអណ្ដើកហែប

| ល.រ | ឈ្មោះសាលារៀន | ចំនួនសិស្សមត្តេយ្យ | | | ចំនួនសិស្សបឋម. មធ្យម | | |
|---|---|---|---|---|---|---|---|
| | | សរុប | ស្រី | ថ្នាក់ | សរុប | ស្រី | ថ្នាក់ |
| ១ | សាលាបឋមសិក្សាព្រៃអំពរ | ១៩ | ១១ | ១ | ២៣០ | ១២៦ | ៦ |
| ២ | សាលាបឋមសិក្សាកណ្ដាលស្ទឹង | | | | ១៥៧ | ៨០ | ៦ |
| ៣ | សាលាបឋមសិក្សាថ្មកង់ (ឧបសម្ព័ន្ធកណ្ដាលស្ទឹង) | | | | ៣៧ | ១៣ | ៣ |
| ៤ | សាលាបឋមសិក្សាត្រដក់ពង (ឧបសម្ព័ន្ធកណ្ដាលស្ទឹង) | | | | ៦៦ | ២៨ | ៤ |
| ៥ | សាលាបឋមសិក្សាស៊ិនតុ | ៥១ | ២៨ | ២ | ២៦៧ | ១៣៧ | ៧ |
| ៦ | សាលាបឋមសិក្សាថ្វាក | | | | ៦៥ | ២៤ | ៦ |
| ៧ | សាលាបឋមសិក្សាកណ្ដាល (ឧបសម្ព័ន្ធថ្វាក) | | | | ៦១ | ៣០ | ៦ |
| ៨ | អនុវិទ្យាល័យស្រែអំពរ | | | | ២៩៩ | ១៨៣ | ៤ |

តារាងស្ថិតិសិស្សនិងថ្នាក់រៀនក្នុងឃុំផ្លូវមាស

| ល.រ | ឈ្មោះសាលារៀន | ចំនួនសិស្សមត្តេយ្យ | | | ចំនួនសិស្សបឋម. មធ្យម | | |
|---|---|---|---|---|---|---|---|
| | | សរុប | ស្រី | ថ្នាក់ | សរុប | ស្រី | ថ្នាក់ |
| ១ | សាលាបឋមសិក្សាSCCFA(ឧបសម្ព័ន្ធផ្លូវមាស) | | | | ៣៥៧ | ១៨៣ | ១០ |
| ២ | សាលាបឋមសិក្សា បឹងខ្មុម | ២០ | ៨ | ១ | ៣២៧ | ១៥៧ | ១០ |
| ៣ | សាលាបឋមសិក្សា សេកសក | | | | ១០១ | ៤៤ | ៦ |
| ៤ | សាលាបឋមសិក្សាអូរតាសូ(ឧបសម្ព័ន្ធសេកសក) | | | | ៧២ | ២៧ | ៤ |
| ៥ | សាលាបឋមសិក្សា អូរដា | | | | ១៤៣ | ៧៦ | ៦ |
| ៦ | សាលាបឋមសិក្សា អូរល្ហួន(ឧបសម្ព័ន្ធអូរដា) | | | | ១៤៨ | ៦៩ | ៦ |
| ៧ | អនុវិទ្យាល័យ ផ្លូវមាស | | | | ២៤៤ | ១២០ | ៤ |

តារាងស្ថិតិសិស្សនិងថ្នាក់រៀនក្នុងឃុំត្រែង

| ល.រ | ឈ្មោះសាលារៀន | ចំនួនសិស្សមត្តេយ្យ | | | ចំនួនសិស្សបឋម. មធ្យម | | |
|---|---|---|---|---|---|---|---|
| | | សរុប | ស្រី | ថ្នាក់ | សរុប | ស្រី | ថ្នាក់ |
| ១ | សាលាបឋមសិក្សា មាសពិទូគីឡូ៣៨ | ៣២ | ១២ | ១ | ២៧៤ | ១៣៩ | ៨ |
| ២ | សាលាបឋមសិក្សា អូរតាកុ(ឧបសម្ព័ន្ធពិទូគីឡូ៣៨) | | | | ៣២ | ១៦ | ៣ |
| ៣ | សាលាបឋមសិក្សា ត្រែង | ២៥ | ៨ | ១ | ២៩៥ | ១៣៣ | ៩ |
| ៤ | សាលាបឋមសិក្សា សុវត្ថិភាព កុម៉ាតស៊ុ | | | | ៦៨ | ៣១ | ៦ |
| ៥ | សាលាបឋមសិក្សា ជំនាប់ផេះកុម៉ាតស៊ុ | | | | ១០១ | ៦២ | ៦ |
| ៦ | សាលាបឋមសិក្សា បឹងប្រវឹក | | | | ៨៨ | ៣៦ | ៦ |
| ៧ | សាលាបឋមសិក្សា ប៊ូរុន | | | | ១០០ | ៥៥ | ៥ |
| ៨ | សាលាបឋមសិក្សា ស្រែស្តៅ | | | | ៩៥ | ៤០ | ៦ |
| ៩ | សាលាបឋមសិក្សា ជីសាង | | | | ៣០៤ | ១៥២ | ៨ |
| ១០ | សាលាបឋមសិក្សា ភ្នាវ | ៣៥ | ? | ១ | ៤៤២ | ? | ១១ |
| ១១ | សាលាបឋមសិក្សា រកាគីង | | | | ១៩៥ | ៨៣ | ៦ |
| ១២ | សាលាបឋមសិក្សា ស្វាយស | ២៦ | ១៣ | ១ | ១៥៥ | ៨៤ | ៦ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១៣ | សាលាបឋមសិក្សា តាគ្រក់ | ៤៤ | ២០ | ១ | ២៧៧ | ១៣២ | ៨ |
| ១៤ | សាលាបឋមសិក្សាភ្នំវែងកុម៉ាតស៊ុ(ឧបសម្ព័ន្ធតាគ្រក់) | | | | ១៧ | ៨ | ១ |
| ១៥ | សាលាបឋមសិក្សា ស្រែត្នោត កុម៉ាតស៊ុ | | | | ១៨ | ៨ | ២ |
| ១៦ | វិទ្យាល័យ ហ៊ុន សែន ត្រែង | | | | ៩១០ | ៥២៤ | ១៨ |

តារាងស្ថិតិសិស្សនិងថ្នាក់រៀនក្នុងឃុំរស្មីសង្ហារ

| ល.រ | ឈ្មោះសាលារៀន | ចំនួនសិស្សមត្តេយ្យ | | | ចំនួនសិស្សបឋម. មធ្យម | | |
|---|---|---|---|---|---|---|---|
| | | សរុប | ស្រី | ថ្នាក់ | សរុប | ស្រី | ថ្នាក់ |
| ១ | សាលាបឋមសិក្សា រស្មីសង្ហារ | ២៥ | ១៥ | ១ | ២៩៧ | ១៣៧ | ៨ |
| ២ | សាលាបឋមសិក្សា ស្រង់សែនជ័យ | | | | ១០១ | ៥៩ | ៦ |
| ៣ | សាលាបឋមសិក្សា គិរីជុំ(ឧបសម្ព័ន្ធស្រង់សែនជ័យ) | | | | ៥០ | ២៥ | ៥ |
| ៤ | សាលាបឋមសិក្សា នាងលេម | ១៣ | ៩ | ១ | ៨៧ | ៤៩ | ៦ |
| ៥ | សាលាបឋមសិក្សា អណ្ដើក១១ | | | | ៦៥ | ២៣ | ៦ |
| ៦ | សាលាបឋមសិក្សា បាដាក | ៥៤ | ៣១ | ១ | ៦១៥ | ២៥៨ | ១៦ |
| ៧ | សាលាបឋមសិក្សាដីថ្មី(ឧបសម្ព័ន្ធបាដាក) | | | | ៨០ | ៣៤ | ៥ |
| ៨ | សាលាបឋមសិក្សា ស្វាខ្មៅ(ឧបសម្ព័ន្ធបាដាក) | | | | ៧៤ | ៣៤ | ៦ |
| ៩ | សាលាបឋមសិក្សា ពេជ្រចង្វា | | | | ១៣៦ | ៦៥ | ៦ |
| ១០ | សាលាបឋមសិក្សាទឹកធ្លាក់(ឧបសម្ព័ន្ធពេជ្រចង្វា) | | | | ២០ | ៦ | ២ |
| ១១ | សាលាបឋមសិក្សា នាងពួន | | | | ១៧២ | ៨៤ | ៦ |
| ១២ | សាលាបឋមសិក្សាបឹងមាន់ទោ(ឧបសម្ព័ន្ធនាងពួន) | | | | ២៥ | ៩ | ២ |
| ១៣ | សាលាបឋមសិក្សា អូរឃ្មុំ | | | | ១១៤ | ៥៦ | ៦ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១៤ | សាលាបឋមសិក្សា អូរដែខ្វា(ឧបសម្ព័ន្ធអូរឃ្មុំ) | | | | ១០ | ២ | ១ |
| ១៥ | អនុវិទ្យាល័យ មេត្តាករុណា | | | | ៣៥៥ | ១៨៨ | ៥ |

រហូតមកដល់ឆ្នាំ២០២៣ស្រុករតនមណ្ឌលមានសាលារៀនចំនួន៦៧ ថ្នាក់រៀន២០៩ ចំនួនសិស្សសរុប ១១៧៦៩នាក់ ស្រី៥៨៨២នាក់ ចំនួនគ្រូសរុប៦៩២នាក់និងអ្នកគ្រូចំនួន៣៦៦នាក់[11]។



វិទ្យាល័យ ស្តៅសន្តិភាព

### ៤-ផ្នែកកសិកម្មនិងឧស្សាហកម្ម

កសិកម្មជាមុខរបរមួយដែលប្រជាពលរដ្ឋកម្ពុជាប្រកបមុខរបរនេះតាំងពីបុរាណមកម៉្លេះ ហើយកសិកម្មនៅសម័យនោះភាគច្រើនជាកសិកម្មបែបយថាផល។ តាមប្រសាសន៍លោក ជីវតាក្វាន់ (អ្នកការទូតចិន) ខ្មែរនៅសម័យនោះ (សម័យអង្គរ) អាចធ្វើស្រែបាន ៣ ឬ ២ដង ក្នុងមួយឆ្នាំ។ ទាំងនេះសឱ្យយើងឃើញថា កសិកម្មកម្ពុជានៅសម័យមុន មានការរីកចំរើនយ៉ាងខ្លាំង ហើយការរីកចំរើននោះ ដោយសារភាពសម្បូរនៃប្រព័ន្ធធារាសាស្ត្រខ្វាត់ខ្វែង និងដីសំបូរជីជាតិ។ លោក Henri Stierlin អ្នកឯកទេសជាតិស្វីសម្នាក់បានគន់គូរឃើញថា នៅលើផ្ទៃដី ១០០០គីឡូម៉ែត្រការ៉េ នៅតំបន់អង្គរគេអាចផលិតស្រូវបានក្នុងមួយឆ្នាំប្រហែល ១៥០ ០០០តោន ដែលអាចចិញ្ចឹមប្រជាពលរដ្ឋបានដល់ទៅ ៨០ ០០០នាក់ សល់២០ភាគរយសម្រាប់នាំចេញទៅលក់នៅក្រៅប្រទេស។ វិស័យកសិកម្មនៅប្រទេសកម្ពុជាត្រូវបានប្រជាពលរដ្ឋ និងរាជរដ្ឋាភិបាលយកចិត្តទុកដាក់យ៉ាងខ្លាំង ដោយចាត់ទុកវិស័យកសិកម្មជាវស័យអាទិភាពទីមួយនៅ

[11] មន្ទីរអប់រំ យុវជននិងខេត្តបាត់ដំបង ស្ថិតិវិស័យអប់រំខេត្តបាត់ដំបងឆ្នាំសិក្សា២០២២-២០២៣

ក្នុងគោលនយោបាយអភិវឌ្ឍន៍ជាតិ។ ដំណាំកសិកម្មនៅប្រទេសកម្ពុជា គឺផ្ដោតសំខាន់ជាងគេទៅលើដំណាំស្រូវ និងដំណាំឧស្សាហកម្ម (សណ្ដែកដី សណ្ដែកសៀង អំពៅ ល្ង ថ្នាំជក់ ក្រូច ក្រចៅ ព្រាល)។ វិស័យឧស្សាហកម្មនៅស្រុករតនមណ្ឌល ហាក់បីដូចមានការរីកចម្រើនគួរកត់សម្គាល់ក្នុងក្របខ័ណ្ឌខេត្ត ស្រុកមានឡសម្ងួត និង សៃឡូទិញពោត និងដំឡូងមី មានចំនួន ១៩កន្លែង និងក្រុមហ៊ុនចំនួន ០៤ អាចស្រូបយកកំលាំងពលកម្មបាន ១៣០០ នាក់គឺ[12] ។ ស្រុកមានក្រុមហ៊ុនវិនិយោគដូចជា៖

-ក្រុមហ៊ុនបាត់ដំបង ខនស៍ ស៊ីមេន ខមភេនី លីមីធីត ផលិតស៊ីម៉ង់ត៍ ស្ថិតនៅឃុំស្ដៅ

-ក្រុមហ៊ុនហួណានអឹរកាង ផលិតម្សៅដំឡូងមី ស្ថិតនៅឃុំត្រែង

-ក្រុមហ៊ុនវ៉ាំងកាងបាយអូខេមីខល ផលិតអាល់កុល ម្សៅមី សូដ្យូមនីត្រាត ស្ថិតនៅឃុំត្រែង

-ក្រុមហ៊ុនអឹរកាងបាយអូរស្តេច ផលិតសំបកគ្រាប់ថ្នាំពីម្សៅដំឡូងមី និង ម្សៅដំឡូងមី អេតាណុល ស្ថិតនៅឃុំត្រែង

-ស្ថានីយ៍ផលិតទឹកស្អាតមានចំនួន ០២កន្លែង គឺស្ថានីយ៍ផលិតទឹកស្អាតពពុះពេជ្រចិន្តា ស្ថិតនៅឃុំស្ដៅ និងស្ថានីយ៍ផលិតទឹកស្អាត ១០១ ស្ថិតនៅឃុំអណ្ដើកហែប។



ក្រុមហ៊ុនផលិតសំបកឱសថដែលធ្វើអំពីដំឡូងមី

[12] ស្រុករតនមណ្ឌល កម្មវិធីវិនិយោគ៣ឆ្នាំរំកិល ២០២៣-២០២៥

**៥-សេវាកម្មទេសចរណ៍**

*នយោបាយ ឈ្នះ ឈ្នះ របស់រាជរដ្ឋាភិបាលបាន ធ្វើឱ្យវិស័យទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជា បានប្រែមុខមាត់ថ្មីពោលគឺបាន ធ្វើឱ្យវិស័យសេដ្ឋកិច្ចនៃព្រះរាជាណាចក្រកម្ពុជារីកលូតលាស់យ៉ាងលឿន។*

*ទេសចរណ៍ គឺជាវិស័យមួយដែលមានសក្តានុពលល្អបំផុត ក្នុងការរួមចំណែកជំរុញឱ្យសេដ្ឋកិច្ចជាតិមានភាពរីកចម្រើន និងផ្តល់ការងារផ្ទាល់ដល់ប្រជាពលរដ្ឋ។ ដូច្នេះហើយទើបគេចាត់ទុកវិស័យទេសចរណ៍ជាវិស័យអាទិភាពមួយ ដែលដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍវិស័យសេដ្ឋកិច្ច។ កន្លងមកជំងឺឆ្លងជាសាកលកូវីដ១៩ការបិតខ្ទប់ប្រទេសបានធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងដល់វិស័យទេសចរណ៍ទូទាំងសាកលលោក ហើយបន្ទាប់ពីការបើកប្រទេសឡើងវិញគឺភ្ញៀវទេសចរចាប់ផ្តើម ធ្វើដំណើរកម្សាន្តឡើងវិញតួយ៉ាងដូចព្រះរាជាណាចក្រកម្ពុជា មានភ្ញៀវទេសចរជាតិនិងអន្តរជាតិមកទស្សនាតាមរមណីយដ្ឋាននានា ដូចជាតំបន់អង្គរជាដើម។ ក្នុងឆ្នាំ២០២២ប្រទេសកម្ពុជាបានទទួលភ្ញៀវទេចរអន្តរជាតិចំនួន ២.២៧៦ ៦២៦ នាក់ បើប្រៀបធៀបឆ្នាំ២០២១ មានភ្ញៀវចំនួន ១៩៦ ៤៩៥ នាក់ និងឆ្នាំ២០២០ មានភ្ញៀវចំនួន ១.៣០៦ ១៤៣ នាក់[13]។*

*ខេត្តបាត់ដំបង ជាខេត្តដែលមានសក្តានុពលទេសចរណ៍ជាច្រើនមានដូចជា ធនធានវប្បធម៌ប្រវត្តិសាស្ត្រ(ប្រាសាទបុរាណ សំណង់អគារបានបន្សល់ក្នុងសម័យអាណាព្យាបាលបារាំង) ធនធានធម្មជាតិ និងធនធានកែច្នៃ ដែលសព្វថ្ងៃធនធានសក្តានុពលទាំងនោះបាននិងកំពុងទាក់ទាញភ្ញៀវទេសចរជាតិ និងអន្តរជាតិមកទស្សនាពីគ្រប់ទិសទី។*

*ដោយផ្អែកលើសក្តានុពលប្រវត្តិសាស្ត្រធម្មជាតិនិងធម្មជាតិកែច្នៃ បានធ្វើឱ្យរាល់រមណីយដ្ឋានទាំងឡាយនៅស្រុករតនមណ្ឌលបានក្លាយជាគោលដៅទេសចរណ៍មួយយ៉ាងសំខាន់ ក្នុងការទាក់ទាញភ្ញៀវទេសចរឱ្យមកទស្សនា ហើយថែមទាំងលើកមុខមាត់ខេត្តក៏ដូចជាព្រះរាជាណាចក្រកម្ពុជាផងដែរ។ ផលិតផលទេសចរណ៍ទាំងនេះអាចនាំមកនូវការងារ និងចំណូលឱ្យបានដល់ប្រជាពលរដ្ឋតំបន់ជនបទដាច់ស្រយាលថែមទៀតផង។ សព្វថ្ងៃរមណីយដ្ឋាននានានៅក្នុងស្រុករតនមណ្ឌល ជាផលិតផលទេសចរណ៍ស្នូលកំពុងមានការចាប់អារម្មណ៍យ៉ាងខ្លាំង ក្នុងការទាក់ទាញភ្ញៀវទេសចរជាតិនិងអន្តរជាតិមកទស្សនាកម្សាន្ត។ រាល់រមណីយដ្ឋានទាំងអស់មានសេវាសម្រាប់បម្រើឱ្យវិស័យទេសចរណ៍ ដូចជាតូបលក់ម្ហូបអាហារ ភេសជ្ជៈ រួមផ្សំទេសភាពធម្មជាតិដ៏ស្រស់ត្រកាលនៅតាមទីរមណីយដ្ឋាន។ នៅរាល់*

[13] Ministry of Tourism *Tourism Statistics Report December 2023*

ថ្ងៃឈប់សម្រាកនិងថ្ងៃបុណ្យចូលឆ្នាំខ្មែរ ប្រពៃណីជាតិ ពល់រមណីយដ្ឋាននានារបស់ស្រុក មានប្រជាពលរដ្ឋទៅទស្សនាយ៉ាងច្រើនសន្ធឹកសន្ធាប់។ ចំណែកនៅតាមវត្តអារាមនានានៅក្នុងស្រុកពិសេសនៅថ្ងៃបុណ្យចូលឆ្នាំខ្មែរ ប្រពៃណីជាតិ គណៈកម្មការអាចារ្យវត្តបានបង្កើតកម្មវិធីលេងល្បែងប្រជាប្រិយជាច្រើនមុខ ដើម្បីឱ្យកម្មវិធីកាន់តែអធិកអធម។



សេវាកម្មម្ហូបអាហារនៅភូមិភ្នាវ

## ៦. រមណីយដ្ឋានទេសចរណ៍

ស្រុករតនមណ្ឌល មានរមណីយដ្ឋានទេសចរណ៍សម្រាប់ទាក់ទាញភ្ញៀវទេសចរពីរប្រភេទគឺ រមណីយដ្ឋានទេសចរណ៍ប្រវត្តិសាស្ត្រ និងរមណីយដ្ឋានទេសចរណ៍ធម្មជាតិកែច្នៃ។ ឈ្មោះរមណីយដ្ឋានទេសចរណ៍នានានៅស្រុករតនមណ្ឌល[14]៖

### ៦.១. រមណីយដ្ឋានប្រវត្តិសាស្ត្រ

-រមណីយដ្ឋានល្អាងភ្នំទាកទ្រាំង (ល្អាងស្ពាន)

ជារមណីយដ្ឋានបុរេប្រវត្តិសាស្ត្រ ស្ថិតនៅភូមិគីឡូ៣៨ ឃុំត្រែង ស្រុករតនមណ្ឌល ខេត្តបាត់ដំបង និងមានចម្ងាយ៤០គីឡូម៉ែត្រពីទីប្រជុំជនខេត្ត គ្រប់គ្រងដោយរដ្ឋ។ ល្អាងភ្នំទាកទ្រាំងជាស្ថានីយបុរេប្រវត្តិខ្មែរពីសម័យមុន ជាកូនភ្នំតូចមួយដែលមានបណ្តោយប្រវែង០.៩ គីឡូម៉ែត្រ ទទឹង០.៣ឡូម៉ែត្រនិងមានកម្ពស់ប្រហែល៩០ម៉ែត្រខ្ពស់ជាងបរិវេណដីទំនាបជុំវិញ។ ជាភ្នំថ្មកំបោរកកើតឡើងប្រហែល៣០០លានឆ្នាំគឺនៅចុងស័កទី២ សម័យពែរមីយៀង។ ការដែលគេហៅល្អាងភ្នំនេះថាល្អាងស្ពានគឺដោយសារនៅក្នុងល្អាងមានថ្មមានទម្រង់ដូចស្ពាន ស្ថិតនៅ

[14]មន្ទីរទេសចរណ៍ខេត្តបាត់ដំបង *រមណីយដ្ឋានទេសចរណ៍ សហគមន៍ទេសចរណ៍និងគោលដៅទេសចរណ៍ក្នុងខេត្តបាត់ដំបង* ឆ្នាំ២០២៣

ផ្នែកខាងជើងនៃមាត់ច្រកចូលនៃល្អាង។ ល្អាងនេះចាប់ផ្ដើមស្រាវជ្រាវដោយលោក រ៉ូឡង់ ម៉ូរ៉េ (Roland Mourer) ក្នុងទសវត្សរ៍ឆ្នាំ១៩៦០ តាមការប្រាវជ្រាវស្ថានីយល្អាងស្ពានមានមនុស្សមកតាំងទីលំនៅជាបន្តបន្ទាប់ប្រហែលចាប់តាំងពី ៧០០០ឆ្នាំមុនគ.ស.មកម្ល៉េះ[15]។

សក្ដានុពលទាក់ទាញនៅតំបន់នេះមានដូចជា៖

-ស្ថានីយបុរេប្រវត្តិសាស្ត្រ

-ទេសភាពធម្មជាតិព្រៃភ្នំ

-ទេសភាពចម្ការដំណាំប្រជាពលរដ្ឋជុំវិញភ្នំ

-ជាទីកន្លែងថតរូប

## ៦.២. រមណីយដ្ឋានធម្មជាតិ

**-រមណីយដ្ឋានស្ទឹងថ្វាក**

ជារមណីយដ្ឋានធម្មជាតិកែច្នៃ ស្ថិតនៅភូមិអណ្ដើកហែប ឃុំអណ្ដើកហែប ស្រុករតនមណ្ឌល ខេត្តបាត់ដំបង និងមាន

ចម្ងាយ៤៣គីឡូម៉ែត្រពីទីប្រជុំជនមខេត្តគ្រប់គ្រងដោយឯកជន។

សក្ដានុពលទាក់ទាញនៅតំបន់នេះមានដូចជា៖

-ជាទីកន្លែងលេងទឹក

-ជាទីកន្លែងថតរូប

**-រមណីយដ្ឋានពពុះពេជ្រចិន្ដា**

ស្ថិតនៅភូមិជាមន្ត្រី ឃុំត្រែង ស្រុករតនមណ្ឌល ខេត្តបាត់ដំបង និងមានចម្ងាយ៤៥,៣៦ គីឡូម៉ែត្រពីទីប្រជុំជនខេត្ត គ្រប់គ្រងដោយឯកជន។

សក្ដានុពលទាក់ទាញនៅតំបន់នេះមានដូចជា៖

-ទឹកធ្លាក់ធម្មជាតិ

-ជាទីកន្លែងលេងទឹក

-ជាទីកន្លែងថតរូប

-មើលទេសភាព

**-រមណីយដ្ឋានចម្ការទំពាំងបាយជូ**

ស្ថិតនៅភូមិជាមន្ត្រី ឃុំត្រែង ស្រុករតនមណ្ឌល ខេត្តបាត់ដំបង និងមានចម្ងាយ៤៤គីឡូម៉ែត្រពីទីប្រជុំជនខេត្តគ្រប់គ្រងដោយឯកជន។

សក្ដានុពលទាក់ទាញនៅតំបន់នេះមានដូចជា៖

-ចម្ការទំពាំងបាយជូរ

-សួនផ្កា

-ជាទីកន្លែងថតរូប

-ផលិតផលទំពាំងបាយជូ

**-រមណីយដ្ឋានចម្ការមៀន**

ស្ថិតនៅភូមិជាមន្ត្រី ភូមិក្ដាវ ឃុំត្រែង ស្រុករតនមណ្ឌល ខេត្តបាត់ដំបង និងមានចម្ងាយ៦១ គីឡូម៉ែត្រពីទីប្រជុំជនខេត្ត គ្រប់គ្រងដោយឯកជន ជាប្រភេទរមណីយដ្ឋានធម្មជាតិកែច្នៃ មានដាំដើមមៀនដែលជាប្រភេទដំណាំក្នុងផ្ទៃឈើក្នុងស្រុក។

សក្ដានុពលទាក់ទាញនៅតំបន់នេះមានដូចជា៖

-ទឹកធ្លាក់ធម្មជាតិ ទេសភាពដងស្ទឹង

-ជាទីកន្លែងលេងទឹក

[15] ហេង សុផាឌី បុរាណវិទ្យា ទំព័រទី១៤

-ជាទីកន្លែងថតរូប

-មើលទេសភាព

**-រមណីយដ្ឋានគិរីយង់**

ស្ថិតនៅភូមិគីឡូ៣៨ ឃុំត្រែង ស្រុករតនមណ្ឌល ខេត្តបាត់ដំបង និងមានចម្ងាយ៤០គីឡូម៉ែត្រពីទីប្រជុំជនខេត្ត។

សក្តានុពលដ៏ទាក់ទាញនៅតំបន់នេះមានដូចជាៈ

-ជាទីកន្លែងថតរូប

-ជាតំបន់ធម្មជាតិ

-ជាព្រៃភ្នំ

-ល្អាងភ្នំ

**-រមណីយដ្ឋានចម្ការម៉ែខ្ញុំ**

ស្ថិតនៅភូមិស្វាយស ឃុំត្រែង ស្រុករតនមណ្ឌល ខេត្តបាត់ដំបង និងមានចម្ងាយ៥៥គីឡូម៉ែត្រពីទីប្រជុំជនខេត្ត គ្រប់គ្រងដោយឯកជន។

សក្តានុពលទាក់ទាញនៅតំបន់នេះមានដូចជាៈ

-ជាទីកន្លែងថតរូប

-ទេសភាពអូរធម្មជាតិ

-កន្លែងលេងទឹក

-ចម្ការផ្លែឈើចម្រុះ

**-រមណីយដ្ឋានចង្ហូររីម**

ស្ថិតនៅភូមិជាមន្ត្រី ឃុំត្រែង ស្រុករតនមណ្ឌល ខេត្តបាត់ដំបង គ្រប់គ្រងដោយឯកជន។

សក្តានុពលទាក់ទាញនៅតំបន់នេះមានដូចជាៈ

-ជាទីកន្លែងថតរូប

-ទេសភាពអូរធម្មជាតិ

-កន្លែងលេងទឹក

**-រមណីយដ្ឋានទំនប់ពហុបំណង (សេកសក)**

ជារមណីយដ្ឋានធម្មជាតិកែច្នៃ ស្ថិតនៅភូមិផ្លូវមាស ឃុំផ្លូវមាស ស្រុករតនមណ្ឌល ខេត្តបាត់ដំបង និងមានចម្ងាយ៤៥គីឡូម៉ែត្រពីទីប្រជុំជនខេត្តគ្រប់គ្រងដោយរដ្ឋ។

សក្តានុពលទាក់ទាញនៅតំបន់នេះមានដូចជាៈ

-ទេសភាពលើទំនប់

-តំបន់នេសាទ

-ជាទីកន្លែងថតរូប

-ទេសភាពវាលស្មៅ

ទំនប់ពហុបំណង ជាគម្រោងអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រដ៏ធំ តភ្ជាប់ពីភ្នំមួយទៅភ្នំមួយ (ភ្នំដីប៉ាង ទៅភ្នំកូប)ស្តុកទឹកបាន ចំនួន ២៨៦ លានម៉ែត្រគូប។ ទឹកស្តុកទុកនេះ នឹងត្រូវបង្ហៀរចុះតាមដងស្ទឹងសង្កែ រួចបន្តចែកចាយតាមប្រឡាយមេ ប្រឡាយរង ទៅស្រោចស្រពលើផ្ទៃដីស្រូវវស្សា ចំនួន ៤៧.០០០ ហិកតា និងស្រូវប្រាំងចំនួន ១២.០០០ ហិកតា ក្នុងស្រុករតនមណ្ឌល ស្រុកបាណន់ ស្រុកសង្កែ និងស្រុកមោងឫស្សី។ ទំនប់នេះក៏អាចផ្តល់ថាមពលវារីអគ្គិសនី ចំនួន ១៣,១០ មេហ្គាវ៉ាត់ និងទាំងកាត់បន្ថយទឹកជំនន់ និងផ្តល់ទឹកសម្រាប់ការប្រើប្រាស់ ដល់ក្រុងបាត់ដំបង ផងដែរ[16]។ ចាប់តាំងពីទំនប់ពហុ

[16] ស្រុករតនមណ្ឌល កម្មវិធីវិនិយោគ៣ឆ្នាំរំកិល ២០២៣-២០២៥

បំណងចាប់បើកសម្ពោធដាក់ឱ្យដំណើរការ ធ្វើឱ្យរមណីយដ្ឋានសេកសកលែងដំណើរការ ដោយសារការស្តុកទឹកនៃទំនប់ពហុបំណងមានជាទឹកមានទំហំធំធេងលុបលើរមណីយដ្ឋាននេះ។ សព្វថ្ងៃភ្ញៀវទេសចរងាកមកទស្សនាកម្សាន្តនៅទំនប់ពហុបំណងវិញ។





ទំនប់ពហុបំណង(សេកសក)

**-រមណីយដ្ឋានល្អាងភ្នំបាដាក**

ស្ថិតនៅភូមិបាដាកលើ ឃុំរស្មីសង្ហា ស្រុករតនមណ្ឌល ខេត្តបាត់ដំបង និងមានចម្ងាយ៥៣ គីឡូម៉ែត្រពីទីប្រជុំជនខេត្ត គ្រប់គ្រងដោយរដ្ឋ។

សក្តានុពលទាក់ទាញនៅតំបន់នេះមានដូចជា៖

-ល្អាងភ្នំ

-ជាទីកន្លែងសក្ការៈបូជា

-ជាទីកន្លែងថតរូប

-មើលទេសភាព

**-រមណីយដ្ឋានថ្មតម្រួតក្រោម**

ស្ថិតនៅភូមិអូររំចេកក្រោម ឃុំរស្មីសង្ហា ស្រុករតនមណ្ឌល ខេត្តបាត់ដំបង និងមានចម្ងាយ ៧០,៨៥

គីឡូម៉ែត្រពីទីប្រជុំជនខេត្ត។

សក្តានុពលទាក់ទាញនៅតំបន់នេះមានដូចជា៖

-ទឹកធ្លាក់ធម្មជាតិ

-ជាទីកន្លែងលេងទឹក

-ជាទីកន្លែងថតរូប

-មើលទេសភាព

**-រមណីយដ្ឋានល្អាងភ្នំនាងលេម វត្តអរិយផល**

ស្ថិតនៅភូមិនាងលេម ឃុំរស្មីសង្ហា ស្រុករតនមណ្ឌល ខេត្តបាត់ដំបង និងមានចម្ងាយ៤៧ គីឡូម៉ែត្រពីទី

ប្រជុំជនខេត្តគ្រប់គ្រងដោយរដ្ឋ។

សក្តានុពលទាក់ទាញនៅតំបន់នេះមានដូចជា៖

-ល្អាងភ្នំធម្មជាតិ

-ជាទីកន្លែងថតរូប

-មើលទេសភាពព្រៃភ្នំ

**-រមណីយដ្ឋានចម្ការទុរ៉េនអូរតេង**

ស្ថិតក្នុងភូមិអូរល្មូន ឃុំផ្លូវមាស ស្រុករតនមណ្ឌល ខេត្តបាត់ដំបង ចំងាយ៦៩គីឡូម៉ែត្រពីទីប្រជុំជនខេត្ត(តាមផ្លូវរមណីយដ្ឋានជ្រលងបព្វតា)ជារមណីយដ្ឋានធម្មជាតិកែច្នៃ មានកន្លែងលេងទឹកថ្លាយង់ អមដោយផ្ទាំងថ្មក្រាលបាតស្ទឹង មានកន្លែងអង្គុយលម្ហែអមដងស្ទឹង និងកន្លែងថតរូបស្អាតៗគ្រប់គ្រងដោយឯកជន។ បន្ថែមពីនេះ មានចម្ការផ្លែឈើចម្រុះដូចជា ទុរ៉េន សាវម៉ាវ តាង៉ែន (មៀនប៉ៃលិន) កៅស៊ូ ជាដើម។



រមណីយដ្ឋានចម្ការទុរេនអូរតេង

-**រមណីយដ្ឋានភ្នំចំបាំង**

ស្ថិតក្នុងភូមិអូរល្ហុន ឃុំផ្លូវមាស ស្រុករតនមណ្ឌល ខេត្តបាត់ដំបង ចំងាយ៦០គីឡូម៉ែត្រពីទីប្រជុំជនខេត្ត ជារមណីយដ្ឋានធម្មជាតិកែច្នៃមានកន្លែងកម្សាន្តដូចជាទឹកធ្លាក់ វត្តអារាម កន្លែងលេងទឹកនិងកន្លែងថតរូបស្អាតៗ ជារមណីយដ្ឋានគ្រប់គ្រងដោយសហគមន៍។

-**រមណីយដ្ឋានអូរទទា**

ជារមណីយដ្ឋានធម្មជាតិកែច្នៃស្ថិតនៅភូមិសេរីវ័ន្ត ឃុំអណ្តើកហែប ស្រុករតនមណ្ឌល ខេត្តបាត់ដំបង និងមានចម្ងាយ៤៥គីឡូម៉ែត្រពីទីប្រជុំជនខេត្ត គ្រប់គ្រងដោយឯកជន។

សក្តានុពលទាក់ទាញនៅតំបន់នេះមានដូចជាៈ

-ជាទីកន្លែងលេងទឹក

-ជាទីកន្លែងថតរូប

-មើលទេសភាពចម្ការមៀននិងសួនផ្កា



## សេចក្តីសន្និដ្ឋាន

រតនមណ្ឌលជាស្រុកមួយ នៅក្នុងខេត្តបាត់ដំបងដែលមានសក្តានុពល មុនសមាហរណកម្ម ស្រុករតនមណ្ឌលជាតំបន់សមរភូមិក្តៅរវាងទ័ពរដ្ឋាភិបាលនិងទ័ពឧទ្ទាមក្រៅច្បាប់ខ្មែរក្រហម ជាទឹកដីដែលសម្បូរទៅដោយគ្រាប់មីននៅក្នុងដី។ បន្ទាប់មានការយកចិត្តទុកដាក់របស់អង្គការស៊ីម៉ាក់ បានរុករកដកយកគ្រាប់មីនពីក្នុងដី បច្ចុប្បន្នទឹកដីនៃភូមិសាស្ត្រស្រុកបានក្លាយជាដីលំនៅឋានរបស់ប្រជាពលរដ្ឋ និងជាដីសម្រាប់កសិកម្មរបស់ប្រជាពលរដ្ឋ។ នៅក្នុងរបបសង្គមរាស្ត្រនិយមទឹកដីនៃភូមិសាស្ត្រស្រុករតនមណ្ឌល ជាដីអំណោយផលមានដីជាតិ សម្រាប់ដំណាំឧស្សាហកម្មដូចជាកប្បាសនិងអំពៅជាដើម។ បន្ទាប់ពីសង្គ្រាមស៊ីវិលក្នុងស្រុកបានបញ្ចប់ពោលគឺនយោបាយឈ្នះ ឈ្នះ ធ្វើឱ្យហេដ្ឋារចនាសម្ព័ន្ធក្នុងខេត្តក៏ដូចជាស្រុកមានភាពល្អប្រសើរ។ តាមរយៈនៃការធ្វើកំណាយរបស់អ្នកបុរាណវត្ថុវិទ្យា នៅស្ថានីយល្អាងស្ពាន (ទាកទ្រាំង) បានបញ្ជាក់ឱ្យយើងកាន់តែច្បាស់ថាទឹកដី ខេត្តបាត់ដំបងពិតជាទឹកដីចំណាស់

*ដែលមនុស្សដូនតាយើងមករស់នៅតាំងពីមុន គ្រឹស្តសករាជមកម្លេះ។ បច្ចុប្បន្នទីតាំងនៃស្ថានីយបុរេប្រវត្តិសាស្រ្តនេះ បានក្លាយជារមណីយដ្ឋានទេសចរណ៍ ពិសេសសម្រាប់ទេសចរណ៍ដែលសិក្សាស្វែងយល់អំពីបុរាណវត្ថុវិទ្យា។ បន្ទាប់ពីរមណីយដ្ឋានបុរេប្រវត្តិសាស្រ្តនេះ ស្រុកមានរមណីយដ្ឋានទេសចរណ៍កម្សាន្តច្រើនកន្លែងទៀតសម្រាប់បំពេញតម្រូវការរបស់ភ្ញៀវទេសចរ។*


**គន្ថនិទ្ទេស**

*១.ព្រះរាជក្រមលេខ១៩១ ប.រ. ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ១៩៦៤*

*២.ព្រះរាជក្រមចុះថ្ងៃទី១ ខែធ្នូ ឆ្នាំ១៩៦៥*

*៣.អធិការដ្ឋាននគរបាលស្រុករតនមណ្ឌល ស្ថិតិសរុបប្រជាជនបច្ចុប្បន្ន គិតចាប់ពីខែឧសភា ដល់ខែមិថុនា ឆ្នាំ២០២៣*

*៤.រដ្ឋបាលស្រុករតនមណ្ឌល*

*៥.សក្តានុពលនិងឱកាសវិនិយោគរបស់រដ្ឋបាលខេត្តបាត់ដំបង ឆ្នាំ២០១៨*

*៦.មន្ទីរធម្មការនិងសាសនាខេត្តបាត់ដំបង តារាងស្ថិតិ វត្ត ព្រះសង្ឃ អាចារ្យ គណៈកម្មការ តាជី យាយជី ព.ស ២៥៦៦ គ.ស ២០២២*

*៧.ការិយាល័យអប់រំ យុវជននិងកីឡាស្រុករតនមណ្ឌល ស្ថិតិសិស្សនិងថ្នាក់រៀនក្នុងស្រុករតនមណ្ឌលសម្រាប់ឆ្នាំសិក្សា២០២១-២០២២*

*៨.មន្ទីរអប់រំ យុវជននិងខេត្តបាត់ដំបង ស្ថិតិវិស័យអប់រំខេត្តបាត់ដំបងឆ្នាំសិក្សា២០២២-២០២៣*

៩.Ministry of Tourism Tourism Statistics Report December 2023

*១០.មន្ទីរទេសចរណ៍ខេត្តបាត់ដំបង រមណីយដ្ឋានទេសចរណ៍ សហគមន៍ទេសចរណ៍និងគោលដៅទេសចរណ៍ក្នុងខេត្តបាត់ដំបង ឆ្នាំ២០២៣*

# សារៈសំខាន់ក្នុងការចែករំលែកចំណេះដឹង និងបទពិសោធន៍របស់ស្ត្រី

*ដោយៈ លោកស្រីបណ្ឌិត* **ជា វណ្ណី**
*ប្រធាននាយកដ្ឋានធម្មសាស្ត្រ ចរិយាសាស្ត្រ និង យេនឌ័រ*
*នៃវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*
*នៃរាជបណ្ឌិត្យសភាកម្ពុជា*

*នាពេលបច្ចុប្បន្ននេះ ស្ត្រីបានដើរតួនាទីសំខាន់ក្នុងការជួយអភិវឌ្ឍន៍សង្គមជាតិ មិនថានៅក្នុងគ្រួសារ សហគមន៍ ឬស្ថាប័ន សហគ្រាសនោះឡើយ ហើយក៏មានមានស្ត្រីជាច្រើនរូបដែលមានភាពក្លាហានក្នុងការចែករំលែកចំណេះដឹងនិងបទពិសោធន៍របស់ខ្លួន ដែលយើងអាចសង្កេតឃើញតាមរយៈសកម្មភាពនានាជាច្រើនរបស់ស្ត្រីទាំងក្នុងវិស័យរដ្ឋ ទាំងក្នុងវិស័យឯកជន។ ដូច្នេះមុននឹងលើកឡើងនូវទឡ្ហីករណ៍ នៃស្ត្រីជាច្រើនរូបដែលមានភាពក្លាហានក្នុងការចែករំលែកចំណេះដឹងនិងបទពិសោធន៍របស់ខ្លួន យើងគួរយល់នូវពាក្យគន្លឹះមួយចំនួនដូចជា* ***សារៈសំខាន់ ការចែករំលែក ចំណេះដឹង និងបទពិសោធន៍*** *ជាមុនសិន។*

*. តាមវចនានុក្រមសម្តេចព្រះសង្ឃរាជ* ***ជួន ណាត*** *ពាក្យ «**សារ** និង **សារៈ**» មានន័យថា ខ្លឹម សេចក្តីខ្ជាប់ខ្ជួន មាំមួន រឹងប៉ឹង កម្លាំង អំណាច ក្លាហាន ផលប្រយោជន៍ អង់អាច សេចក្តីពិត តម្លៃ ទ្រព្យ សម្បត្តិ របស់សុទ្ធ។ល។ ដូច្នេះ សារៈសំខាន់ គឺមានន័យថា មានប្រយោជន៍ និងមានតម្លៃ។*

*. ពាក្យ* ***ការចែករំលែក*** *ជាការឱ្យនូវអ្វីដែលយើងមាន យើងចេះ និងយើងធ្លាប់ធ្វើទៅកាន់អ្នកដទៃ ដោយចេតនានិងអចេតនា ហើយការឱ្យនេះ គឺធ្វើឡើងដោយចិត្តចង់ជួយ ចង់ឱ្យអ្នកដទៃបានល្អប្រសើរ។*

*យើងអាចចែករំលែកបានតាមរូបភាពច្រើនយ៉ាង ដូចជា ការចែករំលែកបទពិសោធន៍ក្នុងជីវិត ការចែកជាចំណេះដឹងឬគំនិតយល់ឃើញនានា ដែលក្នុងនោះមានការបង្ហាញជាសកម្មភាពផ្ទាល់ ជារូបភាព ឬពាក្យពេជន៍ល្អៗជាដើម។ សូម្បីតែការឱ្យស្នាមញញឹម ឬការអរគុណ ក៏យើងអាចរាប់បញ្ចូលជាការចែករំលែកផងដែរ។ ជាទូទៅមនុស្សមានហេតុផលផ្សេងៗពីគ្នាក្នុងការចែករំលែកនេះ។ មូលហេតុសំខាន់នៃការចែករំលែក គឺចង់ជួយអ្នកដទៃជាមួយនឹងអ្វីដែលយើងគិតថាមានគុណតម្លៃនឹងជួយ និងចង់រក្សា ក៏ដូចជាបង្កើនទំនាក់ទំនងសង្គម «**បុគ្គលគ្រប់រូបគ្មាននរណាម្នាក់ក្លាយជាអ្នកក្រ ដោយសារការចែករំលែកចំណេះដឹងនិង***

***បទពិសោធន៍នោះទេ កាន់តែចែក គឺកាន់តែមាន កាន់តែចែកគឺកាន់តែបាន***»។ ការចែករំលែកនឹងធ្វើឱ្យយើងធំជាងនិងខ្លាំងជាងអ្វីដែលយើងមាន យើងកាន់តែចែករំលែកច្រើនប៉ុនណា យើងនឹងកាន់តែទទួលនិងចេះបានច្រើនប៉ុននោះ។

***តើយើងនឹងទទួលបានអ្វីត្រឡប់មកវិញ នៅពេលយើងចែករំលែក?***

ជាបទពិសោធន៍នៃការចែករំលែករបស់នាងខ្ញុំកន្លងមក គឺទទួលបាននូវការអរគុណ ទទួលបាននូវការសរសើរ ទទួលបាននូវការពេញចិត្ត និងនៅពេលខ្លះក៏យើងទទួលបាននូវការរិះគន់ ផងដែរ។ ជាទូទៅ នាងខ្ញុំតែងតែ***សាទរទទួលពាក្យរិះគន់ និងអបអរនូវពាក្យកោតសរសើរ*** ដ្បិតនាងខ្ញុំយល់ថា ពាក្យរិះគន់ជាពាក្យដែលចង្អុលបង្ហាញយើងនូវចំណុចខ្វះខាតឬខុសឆ្គង ហើយដែលអាចឱ្យយើងដឹងនិងបំពេញឬក៏កែតម្រូវនូវចំណុចខ្វះខាតឬកំហុសឆ្គងទាំងនោះ ដែលនាំខ្លួនយើងទៅរកភាពល្អពេញលេញ ភាពត្រូវ និងភាពជោគជ័យបន្ថែមទៀត។ ប៉ុន្តែក៏មានមនុស្សមួយចំនួន មិនហ៊ានចែករំលែកចំណេះដឹងនោះដែរ ដែលប្រការនេះមិនមែនដោយសារតែភាពកំណាញ់នោះទេ គឺដោយសារតែខ្លាចពេលចែករំលែកទៅហើយ បែរជាទទួលបាននូវការរិះគន់ នូវការចំអកមើលងាយទៅវិញ ឬក៏ត្រូវគេចោទថាអួត ឬបានតែមាត់ជាដើម។ អ្នករិះគន់ (ដើម្បីស្ថាបនាក្លែងក្លាយ) ជាអ្នករាំងការចែករំលែកចំណេះដឹង។ អ្នករាំងការចែករំលែកចំណេះដឹង គឺជាអ្នកមិនជួយសង្គមជាតិ។ នាពេលបច្ចុប្បន្ន សង្គមខ្មែរត្រូវការអ្នកចែករំលែកចំណេះដឹងច្រើនជាងអ្នករិះគន់ តែយើងក៏មិនត្រូវចែករំលែករឿងមិនល្អទៅកាន់អ្នកដទៃដែរ ដ្បិតវានឹងបង្កគ្រោះថ្នាក់ដល់សង្គម ហើយអ្នកដទៃអាចនឹងធ្វើរឿងនោះមកលើខ្លួនយើងវិញ។ យើងត្រូវពួតដៃគ្នាចែករំលែកចំណេះដឹងនិងបទពិសោធន៍តាមគ្រប់ទម្រង់រូបភាព តាមដែលអាចធ្វើទៅបាន»។ ការចែករំលែក គឺជាប្រភពនាំមនុស្សទៅរកសុខសន្តិភាព ភាពរីកចម្រើនសម្បូរសប្បាយ និងភាតរភាព។ បើគ្មានការចែករំលែកទេ ជីវិតច្បាស់ជាគ្មានន័យខ្លឹមសារអ្វីទាំងអស់។

. ពាក្យ **ចំណេះដឹង** (Knowledge) មានន័យថា សេចក្ដីចេះ ដំណើរចេះ ការចេះដឹងដែលមនុស្សមាន តាមរយៈការសិក្សានៅសាលាក៏ដូចជាតាមរយៈការស្រាវជ្រាវ ពោលគឺជាទំហំទិន្នន័យដែលមានក្នុងខួរក្បាលរបស់មនុស្សដែលទទួលបានពីប្រភពផ្សេងៗដូចជា ការសិក្សា ការស្រាវជ្រាវ និងអ្វីៗដែលជីវិតមនុស្សបានឆ្លងកាត់។ ចំណេះដឹងកើតឡើងពីអ្វីដែលមនុស្សធ្លាប់បានសិក្សាឈ្វេងយល់ និងចងចាំរួចមកហើយ។ ចំណេះដឹងមានច្រើនប្រភេទណាស់ ដូចជាច្បាប់ នយោបាយ សេដ្ឋកិច្ច និងវិស្វកម្ម ជាដើម។ បុគ្គលណាសិក្សាពីអ្វី បុគ្គលនោះច្បាស់ជាមានចំណេះដឹងនិងជំនាញខាងមុខវិទ្យាដែលខ្លួនសិក្សា ដែលចំណេះដឹងទាំងនោះមានទាំងជំនាញ (ដែលវាងវៃ ដែលចេះស្ទាត់ប្រាកដ ហើយជាការងារចេះតគ្នាៗ) មានទាំងទេពកោសល្យ (ភាពប៉ិនប្រសប់ ភាពប្លែកពីគេ ដែលកើតចេញពីការច្នៃប្រឌិតខ្លួនឯង)។ សូមចែកឱ្យដាច់រវាង ***ចំណេះដឹង*** និង ***បញ្ញា***។ ***បញ្ញា*** ឬ***ប្រាជ្ញា***

(Intelligence) គឺជាសមត្ថភាពនៃការចងចាំ និងជាសមត្ថភាពនៃកាយល់។ បើបុគ្គលព្យាយាមសញ្ជឹងគិតពិចារណា ស្វែងរកចម្លើយពីបញ្ហាអ្វីមួយដែលបុគ្គលនោះមិនធ្លាប់យល់ មិនធ្លាប់ឆ្លងកាត់ពីមុន ពេលនោះអ្នកកំពុងតែប្រើសមត្ថភាពខាងបញ្ញា ដើម្បីយល់។ បញ្ញា កើតឡើងពេលបុគ្គលព្យាយាមយល់ និងចងចាំនូវអ្វីដែលអ្នកមិនទាន់យល់ និងអ្វីដែលអ្នកមិនធ្លាប់ចងចាំពីមុនមក។ បញ្ញានិងចំណេះដឹងជាសភាវ២ ដែលមានលក្ខណៈផ្សេងគ្នា តែមានដំណើរអាស្រ័យគ្នាទៅវិញទៅមក។ បញ្ញាមិនមែនជាចំណេះដឹងតែបញ្ញាជាមាគ៌ាអភិវឌ្ឍចំណេះដឹង។ ចំណេះដឹងមិនមែនជាបញ្ញា តែចំណេះដឹងជាមាគ៌ាបង្កើនបញ្ញា។

. ពាក្យ ***បទពិសោធន៍*** គឺជាការជួបប្រទះការឆ្លងកាត់ ពោលគឺជាសកម្មភាពឬទង្វើដែលបុគ្គលម្នាក់ៗធ្លាប់ធ្វើនូវការងារណាមួយ។

ដូច្នេះសារៈសំខាន់ក្នុងការចែករំលែកចំណេះដឹងនិងបទពិសោធន៍នេះ មានន័យប្រយោជន៍ឬតម្លៃដែលយើងទទួលបានពីការផ្ដល់ឱ្យនូវចំណេះដឹងនិងបទពិសោធន៍ដែលបុគ្គលម្នាក់ៗមានជូនដល់អ្នកមិនមាន ឬអ្នកខ្វះខាត ហើយតាមការសង្កេតរបស់នាងខ្ញុំ មានស្ត្រីជាច្រើនដែលមានភាពក្លាហានក្នុងការចែករំលែកចំណេះដឹងនិងបទពិសោធន៍ផងដែរ ដូចជា៖

. សម្ដេចព្រះវររាជមាតាជាតិខ្មែរ សម្ដេច **មុនីនាថសីហនុ** សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុនរ៉ានី ហ៊ុនសែន** និងលោកជំទាវ បណ្ឌិត **ពេជ្រ ចន្ទមុនី ម៉ាណែត** គឺលោកតែងតែចែករំលែកនូវចំណេះដឹង និងបទពិសោធន៍ជីវិតដែលលោកមានដល់ប្រជារាស្ត្រក៏ដូចជាកូនខ្មែរជំនាន់ក្រោយជារៀយៗ។

. លោកជំទាវ **អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីកិច្ចការនារី បានចែករំលែកចំណេះដឹងស្ដីពីស្ត្រីថា នៅឆ្នាំ២០២២ មន្ត្រីរាជការស្ត្រីមានចំនួន ៦៨២២ នាក់ ដែលបានទទួលការពង្រឹងសមត្ថភាពលើចំណេះដឹង និងជំនាញផ្សេងៗ ទាំងនៅក្នុងប្រទេសនិងក្រៅប្រទេស។ លោកជំទាវបានបញ្ជាក់ថា៖ «ក្នុងវិស័យសេដ្ឋកិច្ចនៅកម្ពុជា ស្ត្រីបានក្លាយជាកម្លាំងចលករ ដែលបានរួមចំណែកជំរុញកំណើនសេដ្ឋកិច្ចជាតិនិងការអភិវឌ្ឍសង្គម ដែលមានកម្លាំងពលកម្មស្ត្រីប្រមាណ៨៤ភាគរយ ហើយក្នុងនោះស្ត្រីប្រមាណ៦១ភាគរយជាម្ចាស់អាជីវកម្ម ឬអ្នកធ្វើធុរកិច្ច ជាអត្រាខ្ពស់ក្នុងតំបន់»។[១]

. នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២២ នៅបីទីតាំងផ្សេងគ្នា នៅខេត្តបាត់ដំបង ស្ទឹងត្រែង និងរតនៈគីរី តំណាងជាស្ត្រីមេដឹកនាំសហគមន៍នេសាទមកពីតំបន់នានាទូទាំងប្រទេសកម្ពុជារួមមាន មេគង្គ ទន្លេបី តំបន់ឆ្នេរ និងទន្លេសាប បានមកជួបជុំគ្នានៅក្នុងសិក្ខាសាលាពិគ្រោះយោបល់ស្ដីពី "លទ្ធភាពបង្កើតបណ្ដាញស្ត្រីអ្នកដឹកនាំសហគមន៍នេសាទ" ដែលរៀបចំដោយអង្គការអុកស្វាម និងដៃគូ រួមមាន៖ អង្គការសម្ព័ន្ធភាព

[១] តួនាទីស្ត្រីក្នុងការរួមចំណែកអភិវឌ្ឍសង្គម មានចំនួនកាន់តែច្រើនដែលស្ត្រីជាច្រើនក្លាយជាម្ចាស់ក្រុមហ៊ុននៅកម្ពុជា၊ ភ្នំពេញ ប៉ុស្តិ៍ (postkhmer.com)

ដើម្បីអភិរក្សធនធានជលផល (FACT) អង្គការភូមិខ្ញុំ (MVI) អង្គការអភិវឌ្ឍន៍ជនបទភូមិភាគឦសាន្ត (NRD) អង្គការបណ្ដាញការពារទន្លេសេសាន ស្រែពក សេកុង(3SPN) និងអង្គការសមាគមថែរក្សាបរិស្ថាន និងវប្បធម៌ (CEPA) ដែលតាមរយៈសិក្ខាសាលាពិគ្រោះយោបល់នេះ តំណាងគណៈកម្មការសហគមន៍នេសាទ ជាពិសេសតំណាងស្ត្រី មកពីគ្រប់តំបន់ បានចែករំលែកអំពីបទពិសោធន៍ កត្តាប្រឈមរបស់ពួកគេក្នុងកិច្ចការពារធនធានជលផល ដើម្បីជានាទូវនិរន្តភាពនៃជីវភាពរស់នៅរបស់ពួកគេ និងពិគ្រោះយោបល់អំពីភាពចាំបាច់ លទ្ធភាព និងដំណើរការដើម្បីឈានទៅបង្កើតបណ្ដាញភាពជាអ្នកដឹកនាំស្ត្រីក្នុងវិស័យជលផល។[២]

. នៅថ្ងៃទី២៦-២៧ ខែកញ្ញា ឆ្នាំ២០២៣ លោកជំទាវ **នួន នារតី** ប្រធាន គ.ក.ស.ក ខេត្តកណ្ដាល អភិបាលស្រុកកណ្ដាលស្ទឹង ក្រុមប្រឹក្សាឃុំ និងជំនួយការឃុំជាស្ត្រី ព្រមទាំងមានការសម្របសម្រួល និងជាគ្រូបង្គោលផ្ទាល់ដោយក្រុមការងារជាស្ត្រីនៃមន្ទីរអភិវឌ្ឍន៍ជនបទខេត្តកណ្ដាល ក្នុងឱកាសការបើកវគ្គបណ្ដុះបណ្ដាលស្ដីពី "ការលើកកម្ពស់ភាពជាអ្នកដឹកនាំស្ត្រីឆ្នើម ក្នុងវិស័យទឹកស្អាត និងអនាម័យប្រកបដោយបរិយាបន្ន" ដែលមានសមាសភាពចូលរួមចំនួន២៨នាក់ /ស្រី២៦នាក់។ ក្នុងស្មារតីនៃវគ្គបណ្ដុះបណ្ដាលនេះបានរំពឹងទុកខ្ពស់ថា អ្នកចូលរួមស្ត្រីនឹងអាចបណ្ដុះបណ្ដាលបន្តដល់សហគមន៍ ក្នុងភាពជាអ្នកដឹកនាំស្ត្រីឆ្នើមក្នុងវិស័យទឹកស្អាត និង អនាម័យ ក៏ដូចជាមានសមត្ថភាព និងភាពអង់អាចក្នុងការចូលរួមផ្ដល់មតិ ព្រមទាំងចូលរួមធ្វើសេចក្ដីសម្រេចចិត្តនានា បង្កើនភាពក្លាហានចូលរួមផ្លាស់ប្ដូរជាវិជ្ជមាននៃឥរិយាបទរបស់ស្ត្រី និងបុរស។[៣]

. ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៩ ក្រុមហ៊ុន Linda Keo Premium Brand Trading Co,.LTD ដែលជាក្រុមហ៊ុនឈានមុខមួយផ្នែកសេវាកម្មតាមអនឡាញ បានរៀបចំសិក្ខាសាលាមួយស្ដីអំពី «សិល្បៈក្នុងការនិយាយ ឆ្ពោះទៅកាន់ភាពជោគជ័យកម្រិតកំពូល» ជូនដល់សមាជិកក្រុមរបស់ខ្លួន ក្នុងគោលបំណងចែករំលែកបទពិសោធន៍ជូនជាមួយនឹងវិស័យរកស៊ីតាមអនឡាញ។[៤]

. ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៧ លោកជំទាវបណ្ឌិតសភាចារ្យ **ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ បានអញ្ជើញជាវាគ្មិនកិត្តិយស ធ្វើបាឋកថាចែករំលែកចំណេះដឹងនិងបទពិសោធន៍ លើប្រធានបទស្ដីពី "ការអភិរក្សនិងការអភិវឌ្ឍវប្បធម៌ជាតិនិងលក្ខណៈសម្គាល់អត្តសញ្ញាណជាតិខ្មែរ" ដល់គ្រូនគរបាលជាតិ មន្ត្រីនគរបាល និងនិស្សិត សិក្ខាកាម សិស្សនគរបាល នៃបណ្ឌិត្យសភានគរបាលកម្ពុជា

[២] https://cambodia.oxfam.org/

[៣] វគ្គបណ្ដុះបណ្ដាលស្ដីពី ការលើកកម្ពស់ភាពជាអ្នកដឹកនាំស្ត្រីឆ្នើម ក្នុងវិស័យទឹកស្អាត និងអនាម័យប្រកបដោយបរិយាបន្ន ក្រោមអធិបតីភាព គាំទ្រដោយអង្គការ WaterAid – ក្រសួងអភិវឌ្ឍន៍ជនបទ (mrd.gov.kh)

[៤] https://m.freshnewsasia.com/

សរុបចំនួន៩១៥នាក់ បានចូលរួមស្តាប់។[៥]

. ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៦ ស្ត្រីចែករំលែកដល់ស្ត្រីក្នុងការលុបបំបាត់អំពើហិង្សាលើស្ត្រី ពោលគឺវាកាន់តែមានប្រសិទ្ធភាព។ បើទោះបីជាស្ត្រីភាគច្រើនមិនមានភាពក្លាហានក្នុងការចែករំលែកចំណេះដឹងដើម្បីទប់ស្កាត់អំពើហិង្សាក៏ដោយ ក៏ការចែករំលែករបស់ស្ត្រីទៅកាន់ស្ត្រីដូចគ្នានៅតែមានប្រសិទ្ធខ្ពស់ជាងការចែករំលែកដោយបុរស។ លោកស្រី **សៀ សុផា** ជាក្រុមប្រឹក្សាឃុំទទួលបន្ទុកកិច្ចការស្ត្រីនៅក្នុងឃុំស្នឹង បានមានប្រសាសន៍ថា កន្លងមកលោកស្រីធ្លាប់បានធ្វើការផ្សព្វផ្សាយដោយផ្ទាល់ទៅកាន់ស្ត្រីនៅក្នុងមូលដ្ឋាន ដើម្បីឱ្យពួកគាត់បានយល់ពីច្បាប់ ទម្រង់នៃការប្រព្រឹត្តអំពើហិង្សា និងប្រាប់គាត់ពីអ្នកដែលអាចជួយគាត់បាន នៅពេលកើតមានអំពើហិង្សា។[៦]

. Learning Platform អនុញ្ញាតឱ្យអ្នករៀនសូត្រ និងចែករំលែកចំណេះដឹងគ្នាទៅវិញទៅមក។ Learning Platform មានគោលបំណងក្លាយជាវិបផតថលចែករំលែកចំណេះដឹងមួយកន្លែងដោយឥតគិតថ្លៃ ប្រមូលផ្តុំការអនុវត្តល្អបំផុតនិងការរៀនសូត្រនានានៃសមាជិកចង្កោមនៃគម្រោងគាំទ្រអង្គការសង្គមស៊ីវិល (CSS)។

ដូច្នេះតាមរយៈវគ្គមានស្ត្រីក្នុងការងារសង្គមមានចំនួនកាន់តែច្រើនឡើង និងមានតួនាទីដ៏សំខាន់ក្នុងការចូលរួមចំណែកកសាងនិងអភិវឌ្ឍសង្គម ជាពិសេសការជំរុញកំណើនសេដ្ឋកិច្ចកម្ពុជានោះ ឃើញថាមានស្ត្រីជាច្រើនបានក្លាយជាម្ចាស់ក្រុមហ៊ុន សហគ្រាសនៅកម្ពុជា គឺសុទ្ធតែមានភាពក្លាហានក្នុងការចេញមុខចែករំលែកចំណេះដឹង និងបទពិសោធន៍របស់ខ្លួន។

**. តើនិន្នាការបែបនេះ កើតឡើងដោយសារស្ត្រីខ្លួនឯង ឬក៏មានកត្តាជំរុញពីមជ្ឈដ្ឋានណាខ្លះដែរ?**

និន្នាការបែបនេះ គឺកើតឡើងដោយស្ត្រីខ្លួនឯងផង និងក៏មានកត្តាជំរុញពីមជ្ឈដ្ឋាននានាដូចជា ក្រុមគ្រួសារ (ស្វាមី ឪពុកម្តាយ កូនក្មួយ ឬក៏ញាតិមិត្តផ្សេងៗ) សហគមន៍ ស្ថាប័ន និងសង្គមជាតិផងដែរ ជាពិសេសគឺមជ្ឈដ្ឋានអ្នកទទួល។ ប្រសិនបើស្ត្រីមានសមត្ថភាពក្នុងការចែករំលែកចំណេះដឹងនិងបទពិសោធន៍ តែគ្រួសារ ជាពិសេសស្វាមីមិនផ្តល់ឱកាស ឬក៏មិនបង្កលក្ខណៈឱ្យក៏ស្ត្រីមិនអាចទៅចែករំលែកចំណេះដឹងនិងបទពិសោធន៍ដែលខ្លួនមានបានដែរ។ យ៉ាងណាមិញបុរសក៏ដូចគ្នា នៅចំពោះមុខភាពជោគជ័យរបស់បុរស គឺដាច់ខាតត្រូវតែមានការចូលរួមពីស្ត្រីនិងក្រុមគ្រួសារផងដែរ។

---

[៥] លោកជំទាវ បណ្ឌិត ភឿង សកុណា រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ អញ្ជើញជាវាគ្មិនកិត្តិយស ធ្វើបាឋកថាចែករំលែកចំណេះដឹង និងបទពិសោធន៍ ជូនដល់គ្រូនគរបាលជាតិ មន្ត្រីនគរបាល និងនិស្សិត សិក្ខាកាម សិស្សនគរបាល – បណ្ឌិត្យសភានគរបាលកម្ពុជា (pac.edu.kh)

[៦] https://www.pdibattambang.info

***. តើសិល្បៈនៃការចែករំលែកចំណេះដឹង និងបទពិសោធន៍របស់ស្ត្រីនៅក្នុងកម្មវិធីនានា មានលក្ខណៈទាក់ទាញបែបណាដែរ?***

*បើនិយាយពីសិល្បៈនៃការចែករំឡែក គឺសំដៅដល់វិធីសាស្ត្រក្នុងចែករំលែកដែលលេចចេញពីបទពិសោធ និងទ្រឹស្តីនៃការចែករំលែកចំណេះដឹង និងបទពិសោធន៍របស់ស្ត្រីក្នុងកម្មវិធីនានា ហើយនាងខ្ញុំយល់ថា ពិតជាមានលក្ខណៈទាក់ទាញ ល្អ និងពូកែ ដ្បិតថា ជាទូទៅស្ត្រីជាបុគ្គលមានលក្ខណៈសិល្បៈច្រើនជាងបុរសតាំងពីកំណើតមកម្ល៉េះ មិនថាសិល្បៈក្នុងការនិយាយ និងសិល្បៈក្នុងការតុបតែង ឬការរៀបចំទុកដាក់នោះទេ។ បើយើងសង្កេតជាទូទៅនៅក្នុងគ្រួសារនីមួយៗ បើមានវត្តមានស្ត្រីនៅក្នុងគ្រួសារ នោះគ្រួសារនោះនឹងមានរបៀបរៀបចំនិងការតុបតែងបានល្អជំគួរទាក់ទាញជាងគ្រួសារដែលមិនមានវត្តមានស្ត្រី។*

***. នៅពេលមានស្ត្រីជាច្រើន ក្លាហានហ៊ានចេញមុខចែករំលែកចំណេះដឹង និងបទពិសោធន៍ ថាតើនឹងផ្តល់កម្លាំងចិត្តបែបណាដែរទៅដល់ស្ត្រីដទៃទៀត? ហើយវាមានសារៈសំខាន់បែបណាដែរ?***

*នៅពេលមានស្ត្រីជាច្រើន មានភាពក្លាហានហ៊ានចេញមុខចែករំលែកចំណេះដឹង និងបទពិសោធន៍ គឺនឹងផ្តល់ជាកម្លាំងចិត្តច្រើនទៅដល់ស្ត្រីដទៃទៀតជាពិសេសបុរសៗតែម្តង ដែលធ្វើឱ្យបុរសនឹងយល់ថា ស្ត្រីជាភាពទន់ខ្សោយមែន តែស្ត្រីអាចធ្វើបាន ចុះទំម្រាំខ្លួនជាបុរសដែលមានភាពខ្លាំង ហេតុអ្វីខ្លួនមិនអាចធ្វើបាន ហើយម្យ៉ាងទៀតវានឹងក្លាយទៅជាគំរូនៃស្ត្រីមួយចំនួនដែលមានចំណេះដឹងនិងបទពិសោធន៍ តែខ្វះភាពក្លាហានមិនហានចេញមុខចែករំលែកផងដែរ ហើយក៏ជាជំនួយផ្លូវចិត្តនិងផ្លូវស្មារតីដល់ស្ត្រីដែលទន់ខ្សោយនិងខ្វះសមត្ថភាពឱ្យរឹងមាំ ឱ្យមានសមត្ថភាពតាមរយៈការចែករំលែកនៃស្ត្រីក្លាហាន ហ៊ានចេញមុខនោះ ដូច្នេះវាពិតជាមានសារៈសំខាន់ណាស់។ ការចូលរួមចែករំលែកដោយផ្ទាល់របស់ស្ត្រី ជាពិសេសចំណេះដឹង បទពិសោធន៍ដែលទាក់ទងនឹងអំពើហិង្សាតែម្តង គឺរិតតែមានសារៈសំខាន់ខ្លាំងថែមទៀត ដ្បិតមានតែស្ត្រីដូចគ្នាទេដែលជាអ្នកយល់ពីបញ្ហារបស់ស្ត្រីបានល្អជាងបុរស។ បច្ចុប្បន្ននៅក្នុងប្រទេសកម្ពុជា យើងមានស្ត្រីចំនួនច្រើនគួរសម ដែលធ្លាប់ទទួលរងអំពើហិង្សាពីដៃគូរបស់ពួកគេ។ ដូច្នេះ បន្ថែមពីការចូលរួមពីសំណាក់ស្ត្រីខ្លួនឯងផ្ទាល់ យើងគ្រប់គ្នាគួរបន្តខិតខំគាំទ្រ ធ្វើយ៉ាងណា ដើម្បីជានាឱ្យបានថាអំពើហិង្សាលើស្ត្រីនៅកម្ពុជាមានការថយចុះជាលំដាប់។*

***. ក្រៅពីស្ត្រីគ្នាឯង តើការចែករំលែកចំណេះដឹងនិងបទពិសោធន៍នេះ ទទួលបានការចាប់អារម្មណ៍បុរសៗដែរឬទេ?***

*ក្រៅពីស្ត្រីគ្នាឯង ការចែករំលែកចំណេះដឹងនិងបទពិសោធន៍នេះ គឺពិតជាអាចទទួលបានការចាប់អារម្មណ៍ពីមនុស្សទូទៅ ជាពិសេសបុរសៗតែម្តង លើកលែងតែបុរសមួយចំនួនតូចដែលមានចិត្តចង្អៀត ខ្លាចស្ត្រីខ្លាំងជាងខ្លួនប៉ុណ្ណោះ។ ជាធម្មតានៃកត្តាធម្មជាតិ បុរសតែង*

តែចូលចិត្តស្រ្តី ដូច្នេះនៅពេលមានស្រ្តីធ្វើការចែករំលែកចំណេះដឹងនិងបទពិសោធន៍នោះ នោះបុរសនឹងមានការចាប់អារម្មណ៍ ជាង ជាពិសេសការចែករំលែកត្រូវនឹងជំនាញនិងចំណង់ចំណូលចិត្តរបស់បុរស។

**. តើស្រ្តីផ្សេងទៀត គួរតែហ៊ានបេញមុខចែករំលែកចំណេះដឹង និងបទពិសោធន៍ បន្ថែមទៀតដែរឬទេ?**

ការចែករំលែកចំណេះដឹងនិងបទពិសោធន៍គឺមានសារៈសំខាន់ ដូច្នេះស្រ្តីផ្សេងទៀត គួរតែហ៊ានបេញមុខចែករំលែកចំណេះដឹងនិងបទពិសោធន៍បន្ថែមទៀត ដ្បិតថាការចែករំលែកចំណេះដឹងនិងបទពិសោធន៍នេះនឹងជួយដល់បុគ្គលទូទៅដែលនៅខ្វះចំណេះដឹងនិងមិនទាន់មានបទពិសោធន៍ក្នុងការងារអ្វីមួយ ហើយវានឹងក្លាយទៅជាគំរូសម្រាប់ស្រ្តីជំនាន់ក្រោយក៏ដូចជាមនុស្សខ្មែរទូទៅ។ ចំណេះដឹងនិងបទពិសោធន៍ទាំងនោះ មិនថាជោគជ័យ ឬបរាជ័យ វានឹងមិនបាត់បង់ឬសាបរលាបទេ ដរាបណាយើងចេះចែករំលែក តែបើយើងមិនចែករំលែក នោះចំណេះដឹងទាំងនោះនឹងមិនទូលំទូលាយ ហើយបើជាបទពិសោធបរាជ័យ នោះវានឹងជាន់ដានបរាជ័យ តែបើជោគជ័យ នោះការចែករំលែកវានឹងរឹតតែជោគជ័យបន្ថែមទៀត។

ដូច្នេះជាសរុបសេចក្តី ការចែករំលែកចំណេះដឹងនិងបទពិសោធន៍របស់មនុស្សទូទៅគឺពិតជាមានសារៈសំខាន់ក្នុងការចូលរួមចំណែកជួយអភិវឌ្ឍធនធានមនុស្ស ក៏ដូចជាសង្គមជាតិឱ្យមានការឱ្យមានរីកចម្រើនទៅមុខប្រកបដោយចីរភាព។ នាពេលបច្ចុប្បន្ន សង្គមខ្មែរត្រូវការអ្នកចែករំលែកចំណេះដឹងច្រើនជាងអ្នករិះគន់ តែយើងក៏មិនត្រូវចែករំលែករឿងមិនល្អទៅកាន់អ្នកដទៃនោះដែរ ដ្បិតវានឹងបង្កគ្រោះថ្នាក់ដល់មនុស្សនិងសង្គមជាតិ ហើយអ្នកដទៃអាចនឹងធ្វើរឿងនោះមកលើខ្លួនយើងវិញ។ យើងត្រូវពួតដៃគ្នាចែករំលែកចំណេះដឹងនិងបទពិសោធន៍តាមគ្រប់ទម្រង់រូបភាព តាមដែលអាចធ្វើទៅបានដោយបើកបេះដូងឱ្យទូលាយ គិតសុទិដ្ឋិ កុំគិតទុទិដ្ឋិ។ ការចែករំលែក គឺជាប្រភពនាំមនុស្សទៅរកសុខសន្តិភាព ភាពរីកចម្រើនសម្បូរសប្បាយនិងភាតរភាព។ បើគ្មានការចែករំលែក មិនថាចំណេះដឹង មិនថាបទពិសោធន៍ ឬទ្រព្យសម្បត្តិនោះទេ នោះជីវិតច្បាស់ជាគ្មានន័យខ្វះខឹមសារអ្វីទាំងអស់ ដ្បិតយើងកើតមកទទេ ហើយស្លាប់ទៅវិញក៏ទទេ ដូច្នេះយើងគួរតែយកវប្បធម៌ចែករំលែកជាគោលក្នុងការជួយលើកតម្កើងជួយស្ថាបនាធនធានមនុស្ស និងសង្គមជាតិឱ្យកាន់តែខ្លាំងក្លា និងកាន់តែរុងរឿង។ បើក្នុងករណីស្រ្តីដែលមានចំណេះដឹង និងបទពិសោធន៍ល្អ តែមិនមានភាពក្លាហានក្នុងការចែករំលែក យើងគួរតែជួយជ្រោមជ្រែងលើកកម្ពស់ ផ្តល់ឱកាស ផ្តល់កម្លាំងចិត្ត ក៏ដូចជាជួយបណ្តុះនូវភាពក្លាហានតាមរយៈការបង្ហាត់បង្ហាញ និងជំរុញណែនាំដល់ស្រ្តីទាំងនោះឱ្យហ៊ានចែករំលែកយ៉ាងស្មើមុខស្មើមាត់ដូចស្រ្តីក្លាហានមួយចំនួន និងក៏ដូចជាបុរសៗផងដែរ។

សង្គមជាតិនឹងមានធនធានមនុស្សរិតតែល្អប្រសើរឡើង ដរាបណាសង្គមជាតិយើងសម្បូរទៅដោយការចែករំលែកនូវចំណេះដឹងនិងបទពិសោធន៍ល្អៗពីមនុស្សជាតិដូចគ្នា ជាពិសេសពីស្ត្រីៗ ដ្បិតស្ត្រីៗតែងតែមានសិល្បៈខ្ពស់ក្នុងការចែករំលែក៕

**គន្ថនិទ្ទេស**


១. សម្តេចព្រះសង្ឃរាជ **ជួន ណាត** វចនានុក្រមខ្មែរ

២. តួនាទីស្ត្រីក្នុងការរួមចំណែកអភិវឌ្ឍសង្គម មានចំនួនកាន់តែច្រើន ដែលស្ត្រីជាច្រើនក្លាយជាម្ចាស់ក្រុមហ៊ុននៅកម្ពុជា ၊ភ្នំពេញ ប៉ុស្តិ៍ (postkhmer.com)

៣. វគ្គបណ្តុះបណ្តាលស្តីពី ការលើកកម្ពស់ភាពជាអ្នកដឹកនាំស្ត្រីថ្មើម ក្នុងវិស័យទឹកស្អាត និងអនាម័យប្រកបដោយបរិយាបន្ន ក្រោមអធិបតីភាព គាំទ្រដោយអង្គការ WaterAid – ក្រសួងអភិវឌ្ឍន៍ជនបទ (mrd.gov.kh)

៤. លោកជំទាវបណ្ឌិត ភឿង សកុណា រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ អញ្ជើញជាវាគ្មិនកិត្តិយស ធ្វើបាឋកថាចែករំលែកចំណេះដឹង និងបទពិសោធន៍ ជូនដល់គ្រូនគរបាលជាតិ មន្ត្រីនគរបាល និងនិស្សិត សិក្ខាកាម សិស្សនគរបាល – បណ្ឌិតសភានគរបាលកម្ពុជា (pac.edu.kh)

៥. https://cambodia.oxfam.org/

៦. https://m.freshnewsasia.com/

៧. https://www.pdibattambang.info

# ស្វែងយល់ពីជំងឺធ្លាក់ទឹកចិត្តនិងដំណោះស្រាយ

*ដោយៈ លោកស្រីបណ្ឌិត* **ជា ចណ្ណី**
*ប្រធាននាយកដ្ឋានធម្មសាស្ត្រ ចរិយាសាស្ត្រ និង យេនឌ័រ*
*នៃវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*
*នៃរាជបណ្ឌិត្យសភាកម្ពុជា*

## សេចក្តីផ្តើម

*មនុស្សគ្រប់គ្នា តែងធ្លាប់មានអារម្មណ៍អស់សង្ឃឹម ស្រងូតស្រងាត់ ឬធ្លាក់ទឹកចិត្តក្នុងជីវិតរបស់ខ្លួន ប៉ុន្តែសភាពទាំងនេះនឹងប្រសើរមកវិញដោយខ្លួនឯង។ ទាំងនេះគឺជាប្រតិកម្មផ្លូវចិត្តធម្មតារបស់យើង នៅពេលដែលមានការបាត់បង់វត្ថុឬមនុស្សជាទីស្រឡាញ់ណាមួយ។ ផ្ទុយទៅវិញ ជំងឺធ្លាក់ទឹកចិត្ត ជាជំងឺផ្លូវចិត្តនិងខួរក្បាល និងអាចនិយាយបានថា ជាជំងឺដែលផ្តោតតែលើភាពអវិជ្ជមានពីអតីតកាល (រស់ក្នុងអតីតកាល)។ រោគសញ្ញាវាមានរយៈពេលលើសពី២អាទិត្យនិងប៉ះពាល់ដល់អារម្មណ៍ ការគិត អាកប្បកិរិយា ការងារនិងជីវិតរស់នៅប្រចាំថ្ងៃរបស់យើង។*

*ជំងឺធ្លាក់ទឹកចិត្ត គឺជាជំងឺអារម្មណ៍ដែលមនុស្សជាច្រើនទទួលរងពីចំណុចណាមួយនៅក្នុងជីវិតរបស់ពួកគេ។ វាចាំបាច់ក្នុងការរកឱ្យឃើញកាលៈទេសៈដែលបណ្តាលឱ្យមានអារម្មណ៍ធ្លាក់ទឹកចិត្តនេះ។ ដោយដឹងពីមូលហេតុ វាអាចចាប់ផ្តើមការព្យាបាលឬអនុវត្តតាមការណែនាំខាងផ្លូវចិត្តជាបន្តបន្ទាប់ដើម្បីចេញពីស្ថានភាពមិនល្អ។មានពេលខ្លះ ការចំណាយពេលច្រើនម៉ោងក្នុងបរិយាកាសការងារ ដូច្នេះអ្វីៗដែលកើតឡើងក្នុងបរិបទនោះអាចជះឥទ្ធិពលដល់របៀបដែលយើងឱ្យតម្លៃខ្លួនឯង ហើយដែលអាចបណ្តាលឱ្យធ្លាក់ទឹកចិត្តក្នុងករណីធ្ងន់ធ្ងរ។*

## ១. តើជំងឺធ្លាក់ទឹកចិត្តនេះគួរឱ្យព្រួយបារម្ភដែរឬទេ?

*ជំងឺធ្លាក់ទឹកចិត្តគឺជាការធ្លាក់ចុះនៃអារម្មណ៍ដែលនាំឱ្យមនុស្សមានភាពក្រៀមក្រំ បាត់បង់ភាពសប្បាយរីករាយ និងបាត់ចំណាប់អារម្មណ៍ទៅលើអ្វីជុំវិញខ្លួន។ បុព្វហេតុនៃការកើតមានការធ្លាក់ទឹកចិត្ត គឺនៅពេលមនុស្សប្រឈមមុខនូវការបាត់បង់អ្វីមួយដូចជា បាត់បង់ការងារឬការសិក្សា បាត់បង់ទ្រព្យសម្បត្តិ ទទួលបរាជ័យក្នុងជីវិត និងមានបញ្ហាអ្វីមួយជាដើម។* ***ដូច្នេះជំងឺនេះគឺជាជំងឺគួរឱ្យព្រួយបារម្ភ ដ្បិតសុខភាពផ្លូវចិត្តដើរតួនាទីសំខាន់ក្នុងសុខុមាលភាពទាំងមូលរបស់មនុស្ស។*** *គោរចងចាំថា នៅពេលដែលសុខភាពផ្លូវចិត្តត្រូវបានសម្របសម្រួល វាអាចមានឥទ្ធិពលយ៉ាងខ្លាំងទៅលើជីវិតរបស់បុគ្គល ដ្បិតសុខភាពផ្លូវចិត្តល្អវាលើកកម្ពស់*

អារម្មណ៍វិជ្ជមាន សុភមង្គល ភាពរីករាយ និងការស្កប់ស្កល់ ដែលបង្កើនការពេញចិត្តក្នុងជីវិត មានទំនាក់ទំនងល្អ មានសុខភាពល្អ និងមានភាពពេញចិត្តជាមួយក្រុមគ្រួសារមិត្តភ័ក្តិនិងដៃគូ។ បុគ្គលដែលមានសុខភាពផ្លូវចិត្តល្អ គឺអាចទប់ទល់នឹងភាពលំបាក ភាពតានតឹង និងបញ្ហាប្រឈមក្នុងជីវិត ហើយស្ថានភាពផ្លូវចិត្តវិជ្ជមានត្រូវបានផ្សារភ្ជាប់ជាមួយនឹងការគោរពខ្លួនឯងមានទំនុកចិត្ត។ ប៉ុន្តែបើសុខភាពផ្លូវចិត្តមិនល្អ អាចធ្វើឱ្យអារម្មណ៍មិនល្អ អារម្មណ៍សោកសៅ អស់សង្ឃឹម ផ្លូវចិត្តមិនរឹងមាំ ឬការរំញោចអារម្មណ៍មិនមានចំណង់ការងារ លែងចូលរួមក្នុងសហគមន៍ លែងស្ម័គ្រចិត្ត និងលែងរួមចំណែកជាវិជ្ជមានក្នុងសង្គម។

សរុបមកសុខភាពផ្លូវចិត្តល្អ គឺជាមូលដ្ឋានគ្រឹះមួយសម្រាប់ជីវិត ព្រោះថាវាជួយពង្រឹងផ្នែកផ្សេងៗនៃសុខុមាលភាព ចាប់ពីផ្នែកអារម្មណ៍ និងផ្លូវចិត្ត រហូតដល់សុខុមាលភាពផ្លូវកាយ និងសង្គម។ វាមានសារៈសំខាន់ណាស់ក្នុងការកំណត់អាទិភាព និងថែទាំសុខភាពផ្លូវចិត្តរបស់អ្នកតាមរយៈការថែទាំខ្លួនឯង ស្វែងរកការគាំទ្រនៅពេលចាំបាច់ និងរក្សានូវទស្សនៈវិជ្ជមានលើជីវិត។

## . តើជំងឺប្រភេទនេះមានរោគសញ្ញាដែរឬទេ បើមានយើងសម្គាល់បែបណាដែរ?

ជំងឺធ្លាក់ទឹកចិត្ត គឺជាជំងឺដែលមានប្រភពដើមនៅកន្លែងការងារ ប៉ុន្តែអាចបង្ហាញពីផលប៉ះពាល់របស់វាលើសពីបរិបទនោះ ដែលមានរោគសញ្ញាដូចតទៅ៖

. ភាពសោកសៅនិងស្មារតីស្ពឹកស្រពន់

. ការថប់បារម្ភដោយគ្មានមូលហេតុជាក់លាក់

. ការកាត់បន្ថយការងារ

. អស់កម្លាំងចេរ អារម្មណ៍នៃការត្រូវការឬត្រូវបាន

. ការផ្លាស់ប្តូរទម្ងន់

. ភាពធាប់ខឹងនិងសំឡេងខាងក្រៅនៅក្នុងបរិយាកាសការងារ

. ការផ្តោតអារម្មណ៍ទាបនិងដំណើរការមិនល្អ

. បង្កើនពេលវេលាដែលត្រូវការដើម្បីអនុវត្តមុខងារប្រចាំថ្ងៃ

. បង្កើនកំហុសនិងការឃ្លាំមើលក្នុងការងាររបស់អ្នក

. ការឈប់សម្រាកម្តងម្កាលក្នុងករណីមានជំងឺនេះ សហសេវិកនិងថ្នាក់ដឹកនាំផ្ទាល់របស់បុគ្គលដែលរងផលប៉ះពាល់អាចជាជំនួយដ៏អស្ចារ្យក្នុងការធ្វើរោគវិនិច្ឆ័យបញ្ហា។

## ២. តើអ្វីជាមូលហេតុទូទៅបំផុតនៃការធ្លាក់ទឹកចិត្ត?

. ធ្លាប់មានបទពិសោធន៍ឈឺចាប់ឬស្ត្រេស

. បរិយាកាសការងារដែលនិយោជិកមិនអាចគ្រប់គ្រងស្ថានការណ៍បាន

. ការខកចិត្តជាប្រចាំនៅពេលមិនទទួលបានលទ្ធផលដែលចង់បាន

. ជាពិសេសភាពតានតឹងនិងទាមទារលក្ខខណ្ឌការងារ

. បញ្ហាទំនាក់ទំនងនិងជម្លោះជាមួយមិត្តរួមការងារឬថ្នាក់លើ

. ការទទួលខុសត្រូវហួសហេតុនិងមិនសមនឹងប្រាក់ខែ

. កង្វះការកោតសរសើរនិងការទទួលស្គាល់ការងារដែលបានអនុវត្តដោយនិយោជិក។

## ៣. ជំងឺធ្លាក់ទឹកចិត្តនេះ កើតឡើងដោយកត្តាអ្វី?

ជំងឺធ្លាក់ទឹកចិត្តនេះកើតឡើងដោយកត្តាជាច្រើនដូចជា៖

**. កត្តាខ្លួនឯង៖** មិនចេះគ្រប់គ្រងអារម្មណ៍ខ្លួនឯង មិនឱ្យតម្លៃខ្លួន ធាប់តូចចិត្ត មានគំនិតទុទិដ្ឋិ មិនធ្វើម្ចាស់ចិត្តលើខ្លួនឯង (មិនគួរពេលមានដៃគូស្នេហា ទុកដៃគូស្នេហាជាម្ចាស់ចិត្តរបស់ខ្លួននោះទេ គឺយើងជាម្ចាស់ចិត្តលើខ្លួនយើង) ។

**. កត្តាគ្រួសារ៖** គ្រួសារបែកបាក់ (មិនចុះសម្រុង ឈ្លោះទាស់ទែង ច្រណែន ប្រចណ្ឌ) គ្រួសារដែលខ្វះភាពកក់ក្ដៅមិនបំពេញគ្នាទៅវិញទៅមក(គិតតែពីការងារនិងការរកចំណូលដោយមិនបានគិតពីការផ្ដល់ភាពកក់ក្ដៅសម្រាប់សមាជិកគ្រួសារ) គ្រួសារដែលមិនចេះប្រមាណ (ប្រៀបធៀបតែគ្រួសារដែលល្អនិងមានជាង តែមិនប្រៀបធៀបនឹងគ្រួសារដែលមិនល្អនិងខ្វះខាតជាងគ្រួសារខ្លួន) គ្រួសារមិនទម្លាប់បង្រៀនសមាជិកគ្រួសារឱ្យមានភាពរង់ចាំ (សមាជិកគ្រួសារចង់បានអ្វី គឺផ្ដល់ឱ្យភ្លាមៗ លុះពេលណាមិនមានលទ្ធភាពផ្ដល់ឱ្យ នាំឱ្យសមាជិកធ្លាក់ទឹកចិត្តដោយពេលខ្លះក៏គិតខ្លី)។

**. កត្តាការងារ ឬការសិក្សា៖** បរិយាកាសការងារមិនល្អ មិនផ្ដល់ឱកាស បក្សពួកនិយម អយុត្តិធម៌ មិនតម្លាភាព គេងប្រវញ្ចមិនមានការលើកទឹកចិត្ត មានតែការប្រកួតប្រជែងកាច់កុងដណ្ដើមតួនាទីក្នុងការងារ ជាដើម ដែលជាបុព្វហេតុធ្វើឱ្យមានការធ្លាក់ទឹកចិត្ត។ ចូរចងចាំថា ការធ្វើការងារមិនចាំបាច់ទាល់តែមានឋានៈតួនាទីធំ ជាអ្នកដឹកនាំឬជាផ្នែកគ្រប់គ្រង ទើបជាភាពជោគជ័យនៃការធ្វើការងារនោះទេ យើងតោងគិតថា ការងារក្នុងស្ថាបនមួយឬកន្លែងការងារមួយដែលទទួលបានជោគជ័យ គឺសុទ្ធតែមានចំណែកនៃការចូលរួមការងាររបស់យើង។ បើក្នុងករណីធ្វើអាជីវកម្មវិញ បើបរាជ័យឬដួល គឺត្រូវក្រោកឈរ ហើយស្វែងរកផ្លូវបន្តដំណើរទៅមុខ ចាត់ទុកផ្លូវបរាជ័យជាពទពិសោធន៍។ យ៉ាងណាមិញ ចំពោះការសិក្សាក៏ដូចគ្នា បើបរាជ័យក្នុងការសិក្សា មិនអាចយកឈ្នះអ្នកដៃគូដែលជាអ្នករៀនជាមួយបាន យើងតោងខិតខំព្យាយាមជាបន្តទៀត។ ការបង្កើនការយល់ដឹងក្នុងចំណោមអ្នកធ្វើការងារអំពីបញ្ហានៅកន្លែងធ្វើការ បញ្ហាក្នុងអាជីវកម្ម និងបញ្ហាក្នុងការសិក្សាជាដើមនោះជាវិធីការពារខ្លួន និងជាគំនិតដ៏ល្អមួយដែលអាចជួយការពារករណីអស់សង្ឃឹមពីការកើតឡើង។ យ៉ាងហោចណាស់ថ្នាក់ដឹកនាំរៀនស្វែងយល់ពីស្ថានភាពគ្រោះថ្នាក់និងរាយការណ៍នៅពេលមានអ្វីមួយមិនត្រឹមត្រូវ ដ្បិតព័ត៌មានគឺជា

អំណាច ហើយការដែលអាចកំណត់ស្ថានភាពគ្រោះថ្នាក់ក្នុងចំណោមក្រុមការងារ គឺជាវិធីមួយក្នុងចំណោមវិធីជាក់ស្តែងបំផុតដើម្បីកាត់បន្ថយផលប៉ះពាល់ដែលបញ្ហានេះអាចបណ្តាលមកលើសមាជិកមួយចំនួន។

. **កត្តាសង្គម៖** សង្គមមិនគោរពច្បាប់និងបក្សពួកនិយម សង្គមពុករលួយ សង្គមអយុត្តិធម៌ សង្គមដែលមានអំពើឃាតកម្ម ធក់ប្លន់ សង្គមដែលមិនឱ្យតម្លៃលើអ្នកចេះដឹងពិតប្រាកដ ហើយផ្តល់ឱកាសដល់ជនមិនមានចំណេះ តែពូកែអែបអប សង្គមពោរពេញដោយការសម្តែងសង្គមបែងចែកវណ្ណៈដែលមានគំលាតខ្លាំងលើផ្នែកសេដ្ឋកិច្ចនិងជីវភាពរស់នៅ ក៏ជាកត្តាចម្បងមួយដែលនាំឱ្យសមាជិកដែលជាកោសិការនៃសង្គមមានការធ្លាក់ទឹកចិត្ត។

. **កត្តាពិភពលោក៖** ពិភពលោកមិនមានសន្តិភាព បង្កតែសង្គ្រាម(បច្ចុប្បន្ននេះ មានសង្គ្រាមរវាងរុស្សីនិងអ៊ុយក្រែន សង្គ្រាមរវាងអ៊ីស្រាអែលនិងប៉ាឡេស្ទីន) បង្កើនភាពរីកវរ និងការប្រកួតប្រជែងនៃប្រទេសដែលជាមហាអំណាចធំៗ នឹងធ្វើឱ្យសមាជិកនៃសង្គមនីមួយៗក្នុងពិភពលោករស់ក្នុងភាពអស់សង្ឃឹម។

## ៤. ដើម្បីកុំឱ្យជំងឺធ្លាក់ទឹកចិត្តនេះ ធ្លាក់ចូលក្នុងសភាពធ្ងន់ធ្ងរ តើគួរធ្វើបែបណាដែរ?

ពេញចិត្តនូវអ្វីដែលយើងមាន កុំផ្តោតការសង្ឃឹមច្រើនលើសលុបថាខ្លួននឹងជោគជ័យពិតប្រាកដលើការងារដែលយើងចាប់ផ្តើមធ្វើឬកំពុងតែធ្វើ កុំគិតថាកំហុសដែលយើងបានធ្វើមិនអាចកែប្រែបាន(ការស្គាល់កំហុសនិងចេះកែកំហុសទើបជាបុគ្គលជោគជ័យពិតប្រាកដ)។

ប្រសិនបើអ្នករកឃើញថាខ្លួនអ្នកឬមិត្តរួមការងារម្នាក់នៅក្នុងការិយាល័យរបស់អ្នកមានរោគសញ្ញាទាំងនេះវាដល់ពេលត្រូវចាត់វិធានការ ហើយចាប់ផ្តើមការព្យាបាលផ្លូវចិត្តដែលនឹងផ្អែកលើចំណុចផ្សេងៗគ្នា៖

***ទៅរកការព្យាបាល៖*** អ្នកជំនាញសុខភាពផ្លូវចិត្តប្រើបច្ចេកទេសយុទ្ធសាស្ត្រនិងសកម្មភាពផ្សេងៗគ្នាដែលអនុវត្តតាមរបៀបត្រឹមត្រូវអាចកាត់បន្ថយរោគសញ្ញាដែលបណ្តាលមកពីជំងឺធ្លាក់ទឹកចិត្ត។ ការព្យាបាលដែលត្រូវធ្វើតាម ត្រូវតែសម្របខ្លួនទៅនឹងមនុស្សម្នាក់ៗ និងបញ្ហារបស់បុគ្គលម្នាក់ៗ។ បរិបទការងារនីមួយៗមានលក្ខណៈប្លែក ហើយបុព្វហេតុនិងរោគសញ្ញានានានឹងកំណត់ថាតើស្ថានការណ៍គួរត្រូវឈានដល់កម្រិតណា ហើយឧបករណ៍ព្យាបាលណាដែលទទួលបានជោគជ័យបំផុត។ ប្រសិនបើអ្នកកំពុងទទួលរងនូវការធ្លាក់ទឹកចិត្តនៅកន្លែងធ្វើការឬអ្នករកឃើញថាមានមិត្តរួមការងារម្នាក់ដែលអាចនឹងមានគ្រោះថ្នាក់ វាពិតជាមានប្រយោជន៍ណាស់ក្នុងការជួបអ្នកជំនាញសុខភាពផ្លូវចិត្តដែលអាចព្យាបាលមូលហេតុនិងរោគសញ្ញានៃជំងឺនេះ។ វិជ្ជាជីវៈនីមួយៗនឹងសិក្សាករណីនេះឱ្យស៊ីជម្រៅ ហើយធ្វើការសម្រេចចិត្តអំពីវិធីព្យាបាលនិងឧបករណ៍ល្អបំផុតដែលអាចប្រើបាន។ ការរកឱ្យឃើញយ៉ាងត្រឹមត្រូវនូវមូល

ហេតុនៃជំងឺធ្លាក់ទឹកចិត្តក្នុងអាជីពនឹងជួយអ្នកព្យាបាលឱ្យយល់ពីស្ថានភាពកាន់តែប្រសើរ។

ក្រៅពីការទៅរកអ្នកជំនាញព្យាបាល យើងគោងត្រូវដឹងពីគន្លឹះទូទៅនិងដំណោះស្រាយមួយចំនួនទៀតដែលអាចជួយយើងក្នុងករណីដែលយើងទទួលរងពីការធ្លាក់ទឹកចិត្ត៖

. **បើកបេះដូងឱ្យទូលាយ និងបញ្ចេញស្នាមញញឹម៖** ពេញចិត្តនូវអ្វីដែលយើងមាន *កុំជាប់ជំពាក់ចិត្តក្នុងរបស់ដែលយើងមាន ហើយកុំស្រេកឃ្លានក្នុងរបស់ដែលយើងអត់* ពោលគឺរៀនទទួលយក។ ចំណែកការបញ្ចេញស្នាមញញឹម វាជារឿងមួយដែលយើងអាចធ្វើបានគ្រប់ទីកន្លែង និងគ្រប់ពេលដែលអ្នកចង់បាន។ លោកវេជ្ជបណ្ឌិត **ម៉ាកខេយ** និយាយថា *ការញញឹមគឺជាវិធីងាយស្រួលក្នុងការផ្លាស់ប្តូរអារម្មណ៍របស់អ្នក និងអារម្មណ៍របស់អ្នកដែលនៅជុំវិញអ្នកផង ដែរ។*

. ***កុំផ្តោតការសង្ឃឹមច្រើនលើសលុបពេក៖*** ការសង្ឃឹមថាខ្លួននឹងអាចធ្វើបាននូវអ្វីដែលខ្លួនចង់ធ្វើ គឺពិតជានឹងជោគជ័យពិតប្រាកដលើការងារដែលយើងចាប់ផ្តើមធ្វើ ឬកំពុងតែធ្វើនោះ វាធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់ផ្លូវចិត្តនៅពេលកិច្ចការនោះមិនសម្រេច ឬបរាជ័យ។

. **កុំគិតថារាល់បញ្ហាដែលកើតមានឡើងមិនមានផ្លូវដោះស្រាយ និងជាកំហុសធ្ងន់មិនអាចលើកលែងបាន៖** រាល់បញ្ហាសុទ្ធតែដំណោះស្រាយ គ្រាន់តែពេលខ្លះវាត្រូវការពេលវេលាដើម្បីដោះស្រាយ និងកុំគិតថារាល់កំហុសធ្ងន់ដែលយើងបានធ្វើមិនអាចកែប្រែឬលើកលែងបាន ដ្បិតការស្គាល់កំហុសនិងចេះកែកំហុសទើបជាបុគ្គលជោគជ័យពិតប្រាកដ។

. ***ហ៊ាននិយាយអំពីវា៖*** ត្រូវគិតថា ជំងឺធ្លាក់ទឹកចិត្ត មិនមែនជាជំងឺចម្លែកនោះទេ។ មនុស្សយើងជាច្រើនតែងទទួលរងពីការធ្លាក់ទឹកចិត្តមិនថានៅកន្លែងធ្វើការ មិនថានៅក្នុងអាជីពរបស់ពួកគេ មិនថានៅក្នុងការសិក្សា ក៏មិនថានៅក្នុងគ្រួសារ។ ដូច្នេះ ចូរយើងនិយាយអំពីវា និងចេះចែករំលែកអារម្មណ៍របស់យើងជាមួយមិត្តរួមការងាររបស់យើង មិត្តភក្តិយើង និងសមាជិកនៃគ្រួសារយើង នោះយើងនឹងបានកាត់បន្ថយបន្ទុកផ្លូវចិត្ត។ គ្រាន់តែជាសកម្មភាពនៃការពិនិត្យនិងនិយាយជាមួយនរណាម្នាក់អំពីអារម្មណ៍របស់យើង និងអ្វីដែលកំពុងកើតឡើងនៅក្នុងកន្លែងរបស់យើង វានឹងធ្វើឱ្យអ្នកមានអារម្មណ៍ធូរស្រាលនិងដឹងពីអ្វីដែលកំពុងកើតឡើង។ មនុស្សដែលគាំទ្រយើង នឹងអាចផ្តល់យោបល់ដល់យើងលើស្ថានភាពទាំងនោះ និងជួយណែនាំយើង ដែលអាចឱ្យយើងដោះស្រាយកង្វល់ឬជម្លោះដែលទាក់ទងនឹងយើង។ ដូចគ្នានេះផងដែរ ប្រសិនបើមិត្តរួមការងាររបស់យើងមានចំណេះដឹងអំពីស្ថានភាពរបស់យើង នោះពួកគេទំនងជាយល់ចិត្តយើង ហើយព្យាយាមរកដំណោះស្រាយជួយយើង។

. ***ផ្ទេរក្តីកង្វល់របស់យើងទៅថ្នាក់លើរបស់យើង ឬអ្នកនៅជុំវិញយើង៖*** ប្រសិនបើយើងសម្រេចចិត្តបោះជំហាននេះ វាជាការសំខាន់ណាស់ដែលយើងអាចព្យាបាលជំងឺនេះដោយការប្រុងប្រយ័ត្ននិងការសម្ងាត់។ ក្នុងករណីភាគ

ច្រើន ថ្នាក់លើឬអ្នកនៅជុំវិញយើងអាចយល់អំពីកង្វល់របស់យើងដែលរងផលប៉ះពាល់ និងជួយចាត់វិធានការសមស្របដើម្បីកាត់បន្ថយស្ថានភាព (ជាពិសេសប្រសិនបើមានបន្ទុកការងារលើស ឬបញ្ហាទំនាក់ទំនងខ្វះ)។ ក្នុងករណីណាក៏ដោយ ប្រសិនបើយើងជាមនុស្សដែលទទួលរងពីជំងឺធ្លាក់ទឹកចិត្តក្នុងការងារ សូមចងចាំថាត្រូវប្រាស្រ័យទាក់ទងឱ្យបានត្រឹមត្រូវ និងដោយការប្រុងប្រយ័ត្នទាំងអស់ដែលអាចធ្វើទៅបានក្នុងសំឡេងនៃភាពស្និទ្ធស្នាលជាអតិបរមា ទៅតាមកាលៈទេសៈ នោះថ្នាក់លើឬអ្នកនៅជុំវិញយើងនឹងឃើញថាយើងមានស្មារតីស្ពាបនា គឺប្រសើរជាងយល់ថាយើងជាមនុស្សម្នាក់ដែលធ្វើឱ្យក្រុមមានអស្ថិរភាពឬយើងមិនបំពេញ កាតព្វកិច្ច។ ពេលខ្លះថ្នាក់លើយើង និងអ្នកនៅជុំវិញយើងអាចផ្តល់ឱ្យយើងបន្ថែមពីការលើកទឹកចិត្ត ដោយផ្តល់នូវថ្ងៃឈប់សម្រាកមួយចំនួន ដើម្បីចំណាយពេលឱ្យអារម្មណ៍ រីករាយវិលមក រកផ្លូវចិត្តប្រក្រតីឡើងវិញ។

**. ជ្រើសរើសកិច្ចការមួយក្នុងមួយថ្ងៃ៖** បន្ទាប់ពីភ្ញាក់ពីគេងសូមទុកពេលពីរបីនាទីដើម្បីគិតអំពីអ្វីដែលល្អដែលយើងអាចធ្វើបាននៅថ្ងៃនេះ។ ចាប់ផ្តើមថ្ងៃថ្មីមិនមែនតាមរយៈការរុករកបណ្តាញសង្គមនោះទេ ប៉ុន្តែដោយផ្លូវចិត្តដោយបញ្ចប់កិច្ចសន្យាការងារមួយចំនួនឱ្យរួចរាល់ដ្បិតថាការងារទាំងនោះអាចបន្ធូរផ្លូវចិត្តរបស់យើងបាន។

**. ញុំាអាហារដែលមានតុល្យភាពល្អ៖** ចាប់ផ្តើមពេលព្រឹករបស់អ្នកជាមួយនឹងការបញ្ចូលជីវជាតិសម្រាប់ទ្រទ្រង់រាងកាយដូចជា កាបូអ៊ីដ្រាតនិងប្រូតេអ៊ីនមួយចំនួនដែលជួយកាត់បន្ថយភាពស្មុគស្មាញ ដើម្បីឱ្យយើងផ្តោតនិងមានថាមពលរហូតដល់ពេលបាយថ្ងៃត្រង់ ក៏ជាកត្តាជួយដល់បញ្ហាផ្លូវចិត្តឱ្យស្រស់ស្រាយ បានផ្សារភ្ជាប់ទៅនឹងអារម្មណ៍និងសកម្មភាពកាន់តែប្រសើរឡើង។ ដូចគ្នានេះផងដែរពេលខ្លះអ្នកជំនាញបានទទួចថា កាហ្វេមួយពែងក្នុងមួយថ្ងៃមិនត្រឹមតែធ្វើអោយអារម្មណ៍ ប្រសើរឡើង ប៉ុណ្ណោះទេ ថែមទាំងជួយដល់សកម្មភាពផ្លូវចិត្តទៀតផង។

**. ទទួលបានខ្យល់អាកាសបរិសុទ្ធ និងស្តាប់សំឡេងនៃធម្មជាតិ៖** ការស្រូបយកខ្យល់អាកាសនិងបរិយាកាសបៃតង ក៏អាចមានប្រសិទ្ធភាពជាងការនៅតែផ្ទះឬនៅកន្លែងធ្វើការ។ ការដើរយៈពេលខ្លីនៅកន្លែងមានខ្យល់អាកាសបរិសុទ្ធ គឺជាការលើកស្ទួយក៏ដូចជាការធ្វើ លំហាត់ប្រាណបេះដូងឱ្យល្អប្រសើរផងដែរ។ ការសិក្សាមួយចំនួនបានបង្ហាញថា ការធ្វើលំហាត់ប្រាណនៅក្បែរទឹក ឬនៅកន្លែងមានខ្យល់អាកាសបរិសុទ្ធ បានបង្កើនប្រសិទ្ធភាពនៃការហាត់ប្រាណផងដែរ ដូច្នេះចូរយើងព្យាយាមចំណាយពេលច្រើននៅខាងក្រៅ។ ម្យ៉ាងវិញទៀត ការស្តាប់សំឡេងធម្មជាតិ សំឡេងទឹកហូរ សំឡេងសត្វយំ ក៏ជួយយើងឱ្យមានអារម្មណ៍ល្អ និងជួយឱ្យបានជាសះស្បើយលឿនជាងមុនពីស្ថានភាពស្ត្រេសផងដែរ។

**. ផ្តោតលើអារម្មណ៍ល្អ៖** ភ្លាមៗបន្ទាប់ពីភ្ញាក់ពីគេងលោក Robin McKay បណ្ឌិតផ្នែកចិត្ត

វិទ្យាដែលមានមូលដ្ឋាននៅរដ្ឋអារីហ្សូណាបានណែនាំឱ្យដកដង្ហើមវែងៗ៥ដង ហើយធ្វើចិត្តធ្វើឱ្យមានអារម្មណ៍ល្អពេញមួយថ្ងៃ។ រ៉ូប៊ីននិយាយថា " ស្រមៃថាសូម្បីតែពេលអ្នកជួបការខកចិត្តនិងការភ្ញាក់ផ្អើលដែលមិនសប្បាយចិត្តក៏ដោយអ្នកត្រូវដកដង្ហើមនិងប្រតិកម្មដោយការយល់ដឹងហើយកុំរង្វេងផ្លូវ។ នៅពេលថ្ងៃក្នុងស្ថានភាពស្ត្រេសណាមួយសូមដកដង្ហើមវែងៗ៥ដងហើយរៀបចំខ្លួនដោយមនសិការដើម្បីអារម្មណ៍ល្អ។ ការស្រាវជ្រាវថ្មីមួយបានរកឃើញថា អ្នកដែលផឹកកេសជ្ជៈទឹកដោះគោ កាការ ផឹកសូកូឡា ឬកាហ្វេក្តៅ នៅពេលព្រឹកនឹងមានអារម្មណ៍ល្អ និងមានការប្រុងប្រយ័ត្នខ្ពស់ទោះបីជាពួកគេកំពុងធ្វើការលើបញ្ហាគិតច្រើនឬលំបាក។ ប្រូតេអ៊ីននិងកាបូអ៊ីដ្រាតនៅក្នុងទឹកដោះគោ កាការ ផឹកសូកូឡា ឬកាហ្វេក្តៅ នឹងជួយរក្សាជាតិស្ករក្នុងឈាមរបស់អ្នកឱ្យមានស្ថេរភាពរហូតដល់ម៉ោងអាហារថ្ងៃត្រង់ដើម្បីធ្វើឱ្យអារម្មណ៍របស់អ្នកស្រស់ស្រាយ។ អ្នកស្រាវជ្រាវបានរកឃើញថា ក្លិនរបស់ជីអង្កាមជួយបង្កើនអារម្មណ៍ និងការផ្តោតអារម្មណ៍និងប្រយុទ្ធប្រឆាំងនឹងភាពអស់កម្លាំងនិងសូម្បីតែម្ទេសម្ទេសក៏អាចបង្កើនអារម្មណ៍និងការប្រុងស្មារតីរបស់យើងដែរ។

. **ចំណាយពេលបន្តិចដើម្បីឱ្យតម្លៃខ្លួនឯង**៖ ផ្តល់តម្លៃឱ្យខ្លួនឯងឱ្យបានច្រើន កុំរង់ចាំការផ្តល់តម្លៃពីអ្នកដទៃ។ រស់នៅជាខ្លួនយើង មិនមែនរស់នៅដើម្បីផ្គាប់ភ្នែកនិងផ្គាប់ចិត្តអ្នកដទៃ។ ពេលខ្វះ យើងមិនចាំបាច់លោតចេញពីគ្រែពីវិនាទីដំបូងនៃសំឡេងរោទិ៍ទេ។ ផ្ទុយទៅវិញយើងអាចបញ្ចៀសវាឱ្យលឿនជាងមុន៥នាទី ដើម្បីមានពេលវេលាគ្រប់គ្រាន់ក្នុងការក្រោកតាមសម្រួល ដោយដកដង្ហើមវែងៗ និងឱ្យបានល្អ។ មុនពេលយើងចាប់ផ្តើមការប្រណាំងដើម្បីការងាររាប់រយនិងកិច្ចការផ្ទះ សូមជ្រើសរើសថ្ងៃល្អកំណត់ថ្ងៃឈប់សម្រាកដែលបានគ្រោងទុក ឬគ្រាន់តែក្រឡេកមើលទៅក្រៅបង្អួច នោះនឹងនាំយើងទៅរកភាពស្ងប់ស្ងាត់និងសន្តិភាពផ្លូវចិត្ត។

. **ព្យាករណ៍ពីអវិជ្ជមាន**៖ បើយើងចេះព្យាករណ៍ពីភាពអវិជ្ជមានទុក មានន័យថាយើងបានត្រៀមចិត្តទុកជាមុន ដូច្នេះវានឹងជួយយើងមិនឱ្យរងសំពាធខ្លាំង។ បើគិតអំពីព្រឹត្តិការណ៍វិជ្ជមានពេកនៅក្នុងជីវិតរបស់យើង និងរបៀបដែលយើងទទួលបានការងារនោះ តើវានឹងក្លាយទៅជាយ៉ាងណា ប្រសិនបើព្រឹត្តិការណ៍នោះមិនបានកើតឡើង  ខណៈពេលដែលទទួលបានផលអវិជ្ជមាន។

. **ការគេង**៖ ការគេងក៏អាចជាផលល្អ និងអាចជាផលអាក្រក់សម្រាប់ជំងឺធ្លាក់ទឹកចិត្តផងដែរ។ ផលល្អនោះគឺការគេងលក់ស្រួលមិនយល់សុបិន្តអ្វីនៅពេលយប់ អាចបន្ធូរបន្ថយរោគសញ្ញានៃជំងឺធ្លាក់ទឹកចិត្ត។ ផ្ទុយទៅវិញបើសិនជាមានបញ្ហាដំណេកវាអាចជះឥទ្ធិពលដល់ជំងឺធ្លាក់ទឹកចិត្តទៅវិញ។ វាជាចំណេះដឹងទូទៅហើយដែលថាជំងឺធ្លាក់ទឹកចិត្តអាចប៉ះពាល់ដល់ដំណេករបស់យើង ប៉ុន្តែមិនសូវជាមានអ្នកដឹងទេថា ដំណេកអាចធ្វើអោយមានជំងឺធ្លាក់ទឹកចិត្តនិងភាពធ្ងន់ធ្ងរនៃជំងឺធ្លាក់ទឹកចិត្តផងដែរ។ រហូតដល់ទៅ ៩០% នៃអ្នកជំងឺធ្លាក់ទឹកចិត្តមានការ

ត្អូញត្អែរអំពីគុណភាពនៃដំណេករបស់ពួកគេ ហើយការជាប់ទាក់ទងគ្នារវាងបញ្ហាទាំងពីរនេះ ច្រើនតែមានលក្ខណៈទ្វេទិសដែរ មានន័យថាជារឿយៗនៅពេលដំណេកអាចប៉ះពាល់ដល់ការធ្លាក់ទឹកចិត្ត ហើយការធ្លាក់ទឹកចិត្តក៏អាចប៉ះពាល់ដល់គុណភាពនៃដំណេកផងដែរ។

## សេចក្តីសន្និដ្ឋាន

ដូច្នេះសរុបសេចក្តីមក យើងគួរតែមានបម្រុងប្រយ័ត្នខ្ពស់ កុំបណ្តោយខ្លួនឱ្យធ្លាក់ទៅក្នុងជំងឺធ្លាក់ចិត្ត។ តែបើយើងមានឬដឹងថាទទួលបាននូវជំងឺធ្លាក់ទឹកចិត្តនេះហើយ គោងព្យាបាលជំងឺធ្លាក់ទឹកចិត្តឱ្យបានទាន់ពេលវេលា ដ្បិត***សុខភាពផ្លូវចិត្តដើរតួនាទីសំខាន់ក្នុងសុខមាលភាពទាំងមូលរបស់មនុស្ស សុខភាពផ្លូវចិត្តគឺជាមូលដ្ឋានគ្រឹះសម្រាប់ជីវិត***។ បុគ្គលដែលមានជំងឺបាក់ទឹកចិត្តមាននិន្នាការបង្ហាញពីភាពអកម្មខ្ពស់នៅកម្រិតសំខាន់ដោយមានអារម្មណ៍ថា ខ្លួនមិនសូវមានការគ្រប់គ្រងលើជីវិតរបស់ខ្លួន ហើយជារឿយៗមានអារម្មណ៍អស់សង្ឃឹម ដែលពេលខ្លះឈានទៅរកភាពឯកោ និងការសម្លាប់ខ្លួន។ អ្នកដែលទទួលរងពីជំងឺធ្លាក់ទឹកចិត្តបង្ហាញពីផលប៉ះពាល់អវិជ្ជមានកម្រិតខ្ពស់រួមជាមួយផលប៉ះពាល់វិជ្ជមានទាប ហើយជាទូទៅមានកម្រិតទាបនៃការធ្វើឱ្យសកម្មទាំងផ្លូវចិត្តនិងរាងកាយ។ បើក្នុងករណីដឹងថាខ្លួនមានជំងឺធ្លាក់ទឹកចិត្តហើយ យើងត្រូវស្វែងរកការព្យាបាលតាមអ្នកជំនាញវិជ្ជាជីវៈដែលមានបច្ចេកទេស វិធីសាស្ត្រ និងយន្តការផ្សេងៗគ្នានៃការប្រឆាំងនឹងជំងឺធ្លាក់ទឹកចិត្ត ដើម្បីជួយធ្វើឱ្យស្ថានភាពរបស់ខ្លួនឈានទៅរកភាពកាន់តែប្រសើរឡើង។ ជាពិសេសត្រូវធ្វើចិត្តជាកណ្តាល កុំពេក ពោលគឺត្រូវរៀនទទួលយក ***កុំជាប់ជំពាក់ចិត្តក្នុងរបស់ដែលខ្លួនមានពេក និងកុំស្រេកឃ្លាននឹងរបស់ដែលខ្លួនគ្មានខ្លាំងពេក***។

# ស្ត្រីក្នុងភាពជាអ្នកដឹកនាំ

ដោយៈ លោកបណ្ឌិត **ទុយ យូឃីម**
អនុប្រធាននាយកដ្ឋានប្រវត្តិវិទ្យានិងវិទ្យាសាស្ត្រនយោបាយ
និង លោកស្រីបណ្ឌិត **ជា វណ្ណី**
ប្រធាននាយកដ្ឋានធម្មសាស្ត្រ ចរិយាសាស្ត្រ និង យេនឌ័រ
នៃវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គមនៃរាជបណ្ឌិត្យសភាកម្ពុជា

## សេចក្តីផ្តើម

បើកាលណាយើងនិយាយអំពី ***ស្ត្រីក្នុងភាពជាអ្នកដឹកកនាំ*** យើងមិនអាចបំភ្លេចបានទេនូវព្រះរាជនីយ៍ខ្មែរយើងកាលពីអតីតកាល មានដូចជា ព្រះនាង ***លីវយី*** (សោមម៉ា ឬនាងនាគ) ព្រះនាង***ជ័យទេវី***(សម័យចេនឡា) ព្រះមហាក្សត្រិយានី ***អង្គម៉ី***(សម័យឧដុង្គ) ព្រះមហាក្សត្រិយានី ***ស៊ីសុវត្ថិ កុសុមៈនារ័ត្នសេរីវឌ្ឍនា*** (សម័យសង្គមរាស្ត្រនិយម) និងស្ត្រីមួយចំនួនទៀតដែលបានចូលរួមបង្កើតស្នាដៃដ៏ថ្លៃថ្លាសម្រាប់វប្បធម៌ដ៏រុងរឿងនាសម័យអង្គរ ដែលមានដូចជា ***ព្រះនាងឥន្ទ្រទេវី***ជាដើម។

ទោះបីជាស្ត្រីមានកម្លាំងកាយទន់ខ្សោយជាងបុរស តែកម្លាំងគំនិតបញ្ញា ភាពប៉ិនប្រសប់ ភាពអត់ធ្មត់ ភាពឆ្លាតវៃ និងភាពឧស្សាហ៍ព្យាយាម មិនចាញ់បុរសឡើយ។

ប្រទេសកម្ពុជាបច្ចុប្បន្នប្រកាន់យករបបប្រជាធិបតេយ្យ ហើយកម្ពុជាក៏ជាសមាជិកនៃអង្គការសហប្រជាជាតិដែរ ដូច្នេះព្រះរាជាណាចក្រកម្ពុជាបានអះអាងទទួលស្គាល់ និងគោរពសិទ្ធិជាមូលដ្ឋានរបស់មនុស្សទាំងអស់នៅក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងអនុសញ្ញានានាដែលទាក់ទងនឹងសិទ្ធិមនុស្ស សិទ្ធិស្ត្រី សិទ្ធិកុមារ និងសំណុំនៃសិទ្ធិជាមូលដ្ឋាន ដែលត្រូវបានកំណត់ដោយរដ្ឋធម្មនុញ្ញ។ នៅក្នុងជំពូកទី៣ នៃរដ្ឋធម្មនុញ្ញានៃព្រះរាជាណាចក្រកម្ពុជាដែលចែងអំពីសិទ្ធិនិងករណីយកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ ដែលយើងអាចរកឃើញសិទ្ធិជាច្រើនរបស់ប្រជាពលរដ្ឋខ្មែរ ហើយសិទ្ធិដែលជាអាទិភាពក្នុងការចូលរួមអភិវឌ្ឍសង្គមរបស់ស្ត្រីមានតួយ៉ាងដូចជាៈ សិទ្ធិស្មើភាពគ្នាចំពោះមុខច្បាប់និងសេរីភាពពីការរើសអើង សិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គម

កិច្ច និងវប្បធម៌របស់ប្រទេសជាតិ សិទ្ធិទទួលបានសមភាពរវាងបុរសនិងស្ត្រី និងហាមឃាត់ការរើសអើងគ្រប់ប្រភេទប្រឆាំងនឹងស្ត្រីភេទជាដើម។

ស្ត្រីត្រូវបានចាត់ទុកនិងជឿថា គឺជាកម្លាំងចលករដ៏សំខាន់ក្នុងកិច្ចការអភិវឌ្ឍសេដ្ឋកិច្ច វប្បធម៌ និងសង្គម។ ដូច្នេះយើងត្រូវបង្កលក្ខណៈ ជំរុញ រកមធ្យោបាយ ដើម្បីឱ្យស្ត្រីមានការអប់រំខ្ពស់ ក្លាយជាធនធានមនុស្សដ៏សំខាន់ ក្នុងការចូលរួមដឹកនាំនិងអភិវឌ្ឍប្រទេសជាតិឱ្យបានជឿនលឿន។

ដើម្បីឱ្យស្ត្រីមានភាពជាអ្នកដឹកនាំនិងជាមនុស្សដែលមានប្រយោជន៍សម្រាប់សង្គម ស្ត្រីត្រូវយល់ពីតម្លៃរបស់ខ្លួនក្នុងការស្វះស្វែងកសាងជីវភាព ប្រកបដោយសមត្ថភាព មានភាពក្លាហាន កិត្តិយស ថ្លៃថ្នូរ ដោយមានការទទួលខុសត្រូវចំពោះខ្លួនឯង គ្រួសារ សហគមន៍ ប្រទេសជាតិត្រូវធ្វើយ៉ាងដើម្បីជួយបន្ថែមអភិវឌ្ឍន៍ថាមពលស្ត្រីឱ្យក្លាយទៅជាស្ត្រីមានការទទួលខុសត្រូវចំពោះខ្លួនឯងនិងសង្គមជាតិរបស់ខ្លួន។

មុននឹងយើងធ្វើការសិក្សាស្រាវជ្រាវអំពីស្ត្រីក្នុងភាពជាអ្នកដឹកនាំ យើងគួរស្វែងយល់នូវពាក្យគន្លឹះមួយចំនួនដូចជា ស្ត្រី និងភាពជាអ្នកដឹកជាមុនសិន។

## ១. និយមន័យនិងទស្សនៈស្ដីពី ស្រី/ស្ត្រី

### ១.១- ន័យនៃពាក្យ ស្រី/ស្ត្រី

តាមវចនានុក្រមខ្មែរ ពាក្យ ***ស្រី/ស្ត្រី*** ជាពាក្យប្រើជាសាធារណៈ ពាក្យនេះឃ្លាតមកពីពាក្យសំស្ក្រឹតថា ***ស្ត្រី គឺជាមនុស្សជាតិដែលមានភេទទីទៃពីបុរស(ប្រុស) ឬខ្មើយ។***

ធម្មជាតិបង្កើតមនុស្សប្រុស-ស្រីជាគូនឹងគ្នា រួចកសាងគ្រួសារមានកូនប្រុស កូនស្រី ចៅប្រុស ចៅស្រី ចៅទួត ចៅលួត តៗគ្នា។ មនុស្សប្រុស មនុស្សស្រី សុទ្ធតែមានតួនាទីសំខាន់ក្នុងសង្គម។ មនុស្សស្រីមានរាងកាយទន់ខ្សោយជាងបុរសដែលជាលក្ខណៈនៃធម្មជាតិបង្កើតមក ដែលតម្រូវឱ្យស្ត្រីមានមុខងារក្នុងការផ្តល់កំណើតនិងចិញ្ចឹមបីបាច់មើលថែកូន។ ភាពជាមាតា គឺជាធម្មជាតិ ដូច្នេះវាជាកាតព្វកិច្ចរបស់មនុស្សស្រី។ ស្ត្រីមានលក្ខណៈទន់ភ្លន់និងទន់ខ្សោយផ្នែករូបរាងកាយ ងាយរងការឈឺចាប់ផ្លូវចិត្ត មានមនោសញ្ចេតនាងាយប្រេះស្រាំ។ លក្ខណៈសម្បត្តិដ៏ល្អប្រពៃរបស់ស្ត្រីមានភាពអស្ចារ្យ មានឥទ្ធិពល និងជាពន្លឺដ៏ធំធេងនៃការបង្កើតមនុស្ស ដែលមានកំណើតនៅលើផែនដី។ ស្ត្រីក៏ចែករំលែកនិងធ្វើការមួយចំនួនទៅតាមសមត្ថភាពជាលក្ខណៈធម្មជាតិរបស់ស្ត្រី។ ភេទទាំងពីរ គឺជាជីវិតរស់នៅប្រចាំថ្ងៃ រាល់ការងារគ្រប់យ៉ាងត្រូវដើរទន្ទឹមគ្នា បុរសនិងស្ត្រីនៅជាមួយគ្នា ទើប

ពិភពលោកយើងនេះមានការរីកចម្រើនដូចសព្វថ្ងៃ។

## ១.២- ទស្សនៈនានាទាក់ទងនឹង ស្រីឬស្ត្រី[1]

ពីជាតិសាសន៍មួយទៅជាតិសាសន៍មួយ ពីសង្គមមួយទៅសង្គមមួយ ការឱ្យតម្លៃចំពោះស្រីមានភាពខុសប្លែកគ្នា។ តាំងពីបុរាណកាលមក ជាពិសេសក្រោយពេលដែលសង្គមបង្កើតឱ្យមានការងារកសិកម្ម ដែលជាការងារពឹងផ្អែកខ្លាំងទៅលើកម្លាំងពលំជាធំក្នុងដំណាក់ដំបូងមុនពេលមានបដិវត្តឧស្សាហកម្ម។ ក្នុងដំណាក់កាលនោះ មនុស្សភាគច្រើនយល់ថា ស្ត្រីជាអ្នកបង្កើត និងថែទាំកូន ធ្វើការងារផ្ទះសម្បែង ជាសមាជិកដែលគ្មានបានការនៅក្នុងសង្គម ឬស្ត្រីគ្រាន់តែរៀបចំខ្លួនដើម្បីបំពេញចំណង់របស់បុរសជាស្វាមីជាដើម។

ប៉ុន្តែស្ត្រីត្រូវដឹងថា ឆាកជីវិតរបស់ខ្លួនមិនត្រូវរស់គ្រាន់តែកំដរបុរសនោះទេ។ ទោះបីជាស្ត្រីមានភាពហត់នឿយ ល្ងិតល្ងៃក្នុងការបំពេញអារម្មណ៍បុរសក៏ដោយក្តី ក៏ស្ត្រីនៅតែខិតខំញញឹម ប្រកាន់ខ្ជាប់នូវគុណធម៌និងមានស្មារតី ឆន្ទៈមុះមុតក្នុងការគ្រប់គ្រងគ្រួសារ និងមិនចាំពឹងផ្អែកតែលើស្វាមីដូចមុនទៀតហើយ គឺស្ត្រីបានប្រែក្លាយខ្លួនឱ្យទៅជាមិត្តស្និតស្នាលអាចពិភាក្សាគ្នាស្មើភាពគ្នាជាមួយនិងស្វាមី។ នៅពេលបើស្ត្រីមានគុណសម្បត្តិទាំងអស់នេះ ស្ត្រីមិនបាច់លាក់ចិត្តស្រឡាញ់របស់ខ្លួន និងធ្វើពើកែទឹកមុខ ដើម្បីបំពេញតែចំណង់ចិត្តប្តីទៀតនោះទេ។

***ប្លាតុង*** លោកបានគាំទ្រសមភាពទូលំទូលាយរវាងស្ត្រីនិងបុរស ព្រោះគាត់បានមើលឃើញភាពខុសគ្នារវាងបុរសនិងស្ត្រីដែលមានការកិច្ចផ្សេងៗក្នុងសង្គម ដូចជាស្ត្រីជាអ្នកបង្កើតនិងថែទាំកូន ធ្វើការងារផ្ទះសម្បែង រីឯបុរសបំពេញភារកិច្ចការងារសាធារណៈ។ ***ប្លាតុង*** បានវាយតម្លៃនឹងការងារសិទ្ធិស្ត្រីមុនគេបង្អស់ផ្អែកលើយេនឌ័រ ប្រឆាំងទៅនឹងប្រពៃណីនៅក្នុងសម័យរបស់គាត់កន្លងទៅ។ ***ប្លាតុង*** បានជជែកតវ៉ាទាមទារឱ្យមានឱកាសអប់រំស្មើភាពគ្នាសម្រាប់កុមារនិងកុមារី ឱ្យមានឱកាសបំពេញការងារក្នុងសង្គម ការងារសាធារណៈមានសិទ្ធិធ្វើនយោបាយទាំងអស់គ្នា។ ***ប្លាតុង***

---

[1] សូមមើល តាន់ ផល្លី និក្ខេបបទថ្នាក់បណ្ឌិតទស្សនវិជ្ជា "***តម្លៃស្ត្រីខ្មែរសម័យសកលភាវូបនីយកម្ម***" ទំព័រ ១០-១៤។

មិនគាំទ្រការបែងចែកការងារពលកម្មដោយផ្អែកលើជីវសាស្ត្រ និងឋានានុក្រមនៅក្នុងទស្សនៈរបស់លោកស្ដីពីមនុស្ស។ ទស្សនៈ**ប្លាតុង** បានផ្ដល់ឱ្យបុរសនឹងស្ត្រីមានឋានៈស្មើគ្នានៅក្នុងសង្គម ហើយកំពុងព្យាយាមបំបាត់គំនាបប្រពៃណីរបស់ស្ត្រី។ **ប្លាតុង** មានការបារម្ភពីស្ត្រី ព្រោះខ្លាចមិនអាចគ្រប់គ្រងបានក្នុងការអភិវឌ្ឍកុមារី យុវវ័យ។ ទស្សនៈ**ប្លាតុង**ការអប់រំដ៏ល្អឥតខ្ចោះ គឺជាការអនុវត្តនូវការយល់ដឹង ការគណនាលេលកដ៏ល្អក្នុងការពង្រឹងរាងកាយនិងបង្កើតចិត្តគំនិត ធ្វើឱ្យមនុស្សអាចទទួលបានជីវិតរស់នៅប្រកបដោយគុណធម៌ និងយកចំណេះដឹងនេះទៅផ្សព្វផ្សាយបន្តបានដោយខ្លួនឯង។

លោក **ហ្សង់ហ្សាក់រូសូ** (Jean-Jacques Rousseau ១៧១២-១៧៧៨) បានសន្និដ្ឋានតាមអារម្មណ៍ដ៏ស្មោះត្រង់ថា ស្ត្រីត្រូវបានបង្ខាំងទុកមិនឱ្យស្គាល់ពិភពលោកពិតប្រាកដ ដោយសារគេធ្វើការបង្ហាត់បង្រៀនដុសខាត់ពួកគាត់ខុសក្បួនមិនត្រឹមត្រូវ មិនមែនតាមការព្យាយាមក្នុងការទទួលបានលក្ខណៈសម្បត្តិល្អៗដូចបុរស។ ស្ត្រីត្រូវបានបង្រៀនឱ្យយកចិត្តមនុស្សប្រុស ស្ថិតនៅក្រោមអំណាចមនុស្សប្រុស។ យ៉ាងណាក្ដី ការគោរពបូជាដូចស្ដេចដូចពួកគាត់ទទួលបាន បានបំពុលពួកគាត់ឱ្យវង្វេងរហូតដល់ឫកពាពួកគាត់ នៅពេលនោះត្រូវបានផ្លាស់ប្ដូរនិងបានបង្កើតនូវក្បួនច្បាប់ដែលមិនអាចទទួលបាន នឹងធ្វើឱ្យពួកគាត់អាប់ឱនដែលជាបណ្ដាសារមួយ។ បើពួកគាត់ចង់ទទួលបានការពេញចិត្តក្នុងជីវិតរស់នៅសុខសាន្តមួយ ដែលគាត់អាចទទួលបានពីសេចក្ដីស្រឡាញ់សាមញ្ញរបស់មនុស្សលោក។ នៅយុគសម័យនេះ ត្រូវរង់ចាំហេតុផលមកបំភ្លឺរហូតដល់ស្ដេច និងក្រុមអភិជនដែលស្រឡាញ់កិត្តិយសខ្លាំងរហូតដល់មានសភាពដូចក្មេង។

ប្រធានបទរបស់លោក **ហ្សង់ហ្សាក់រូសូ** រហូតដល់លោក **គ្រិចគូរី** (Dr. Gregory) បានចូលរួមធ្វើឱ្យលក្ខណៈស្ត្រីមានភាពក្លែងក្លាយខុសពីធម្មជាតិនិងមានភាពទន់ខ្សោយ ហើយជាមួយគ្នានោះ ក៏ជាសមាជិកដែលគ្មានបានការនៅក្នុងសង្គមផងដែរ។ ទោះបីជាបុរសមិនបានទទួលចិត្តគំនិតល្អប្រសើរក្រៃលែងក៏ដោយ នៅពេលពេញវ័យ ចិត្តគំនិតនឹងមានភាពសមរម្យ ដែលធ្វើឱ្យបុរសជាស្វាមីនិងប្រពន្ធមានភាពរួមរូបតែមួយ គឺនារីជាប្រពន្ធគួរតែពឹងផ្អែកទាំងស្រុងលើការយល់ដឹងរបស់ស្វាមី ហើយវល្លិ៍ឈើដ៏ស្រស់ស្អាតនេះនឹងតោងជាប់ទៅនឹងដើមឈើខ្ទឹមដ៏ធំមួយដែល

ចិញ្ចឹមវាដោយភាពស្រស់ស្អាត និងលេចធ្លោឡើងស្មើភាពគ្នា។

ស្ត្រីត្រូវបានគេចាត់ទុកជាមនុស្សមានសីលធម៌(ប្រកាន់ខ្ជាប់នូវសីលធម៌) ឬមនុស្សដ៏ទន់ខ្សោយ ដែលពួកគេត្រូវតែនៅក្រោមអំណាចនៃសភាវគតិមនុស្សប្រុស។ នាងត្រូវបានគ្រប់គ្រង ឬបញ្ឆោដោយភាពភ័យខ្លាចដើម្បីទៅហ្វឹកហាត់ល្បិចកលដ៏វ័យឆ្លាតពីកំណើត ធ្វើឫកម្ចិកម៉្ញក់ តាមរយៈកែវភ្នែកដើម្បីឱ្យក្លាយជាមនុស្សមានមន្តស្នេហ៍ ជាអ្នកកំដរដំផ្អែមល្ហែមរបស់មនុស្សប្រុស។

បញ្ហាដែលជាមូលហេតុមួយចំនួនទៀត ចូលរួមក្នុងការធ្វើឱ្យស្ត្រីក្លាយជាទាសករនោះគឺ ដោយពួកគេបានរារាំងការយល់ដឹងរបស់ស្ត្រី។ ស្ត្រីកម្របានចូលរៀនសូត្រឱ្យចេះច្បាស់ដូចបុរស ស្ត្រីទទួលបានតែការអប់រំគ្មានរបៀបត្រឹមត្រូវ ក៏ដូចជាការមើលងាយនូវការយល់ដឹងក្នុងជីវិត ដែលបានបង្កបញ្ហាអសីលធម៌ជាច្រើនដែលតែងតែកើតឡើងជាប្រចាំ។ ដោយសារមានចំណេះដឹងតិចតួច ធ្វើឱ្យស្ត្រីមានស្មារតីពុំសូវរឹងមាំក្នុងការទទួលយកបញ្ហានានា និងមិនមានភាពច្បាស់លាស់។ ម្យ៉ាងតាមរយៈភាពមិនឯករាជ្យនឹងការងារក្នុងផ្ទះរបស់ពួកគេមានកាន់តែច្រើន ការបង្កើនការយល់ដឹងមានលក្ខណៈទាប ការរៀនសូត្រតាមរយៈធ្នៀតឱកាសរៀន ការរៀនសូត្រមិនសំខាន់សម្រាប់ពួកគេ មូលហេតុខាងលើនេះពុំបានបន្តខិតខំចាប់យកជំនាញណាដោយសេចក្ដីក្លាហាន ដើម្បីបង្កើននូវប្រាជ្ញាស្មារតីប្រកបដោយសភាវគតិខ្លួនទេ។

***រូសូ*** គិតថា *ភាពខុសគ្នាដែលខ្ញុំយល់មិនច្បាស់ កើតឡើងពីប្រយោជន៍ដ៏មានឥទ្ធិពលនៃសេរីភាពដែលអាចឱ្យអ្នកជំនាន់មុនយល់កាន់តែច្បាស់ពីជីវិត។ ដំបូងអត្តចរិតពួកគេទទួលបានមុនគេ បន្ទាប់មកការយល់ដឹងពីសីលធម៌ ហើយពួកគេទទួលបានមេរៀនជីវិត មុនពួកគេចេះពិចារណា ធ្វើការដោះបញ្ចាំងពីបញ្ហាក្នុងជីវិត ពីអ្នកស្គាល់គ្នា ដែលមានគម្រោងជីវិតដ៏ល្អមួយពីកំណើត។*

ជាមួយគ្នានោះ លោក ***ម៉ូស៊ីស***(Moses) គិតថា *ស្ត្រីកើតមកដើម្បីតែបុរស មនុស្សស្រីរស់នៅដើម្បីបម្រើសេចក្ដីស្រឡាញ់ ឬតណ្ហារបស់បុរស។* ការសន្និដ្ឋាននេះថា មនុស្សប្រុសតាំងពីបុរាណកាលដ៏យូរលង់ក៏គិតថា វាជារឿងពិតក្នុងការគ្រប់គ្រង ត្រួតត្រាអំណាច ប្រើកម្លាំងលើស្ត្រី ដើម្បីភាពសប្បាយរីករាយរបស់មនុស្សប្រុស។ ព្រហ្មលិខិតហាក់ដូចជាកំណត់ឱ្យមនុស្សប្រុសទទួលបានគុណធម៌ច្រើនជាងខ្ពស់ជាងរួចទៅហើយ។ យ៉ាងណាតាមការប៉ាន់ស្មាន មានមនុស្សតិចណាស់ដែលបាន

ប្រើប្រាស់នូវទស្សនៈប្រាកដប្រជាទាំងឡាយលើប្រធានបទនេះ។ ការសន្និដ្ឋាននេះ ត្រូវតែបានអនុញ្ញាតឱ្យពិភពលោកបានដឹងឮថា មនុស្សប្រុសតាំងពីសម័យបុរាណកាលដ៏យូរលង់គិតថា វាជារឿងត្រឹមត្រូវក្នុងការប្រើកម្លាំងជាអំណាចរបស់គេ ធ្វើឱ្យស្ត្រីស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួន ដើម្បីតែភាពសប្បាយរីករាយរបស់មនុស្សប្រុសប៉ុណ្ណោះ។

លោក *ម៉ូស៊ីស* បានយល់ថា តាំងពីការបង្កើតឱ្យមានរូបរាងកាយមនុស្សលោកមក ព្រហ្មលិខិតហាក់ដូចជាបានកំណត់ឱ្យមនុស្សប្រុស ទទួលបាននូវគុណធម៌ច្រើនជាងខ្ពង់ខ្ពស់ជាងមនុស្សស្រីរួចទៅហើយ។ មានទស្សនៈមួយលើកឡើងថា សុភាពបុរសដែលមានភាពអត់ធ្មត់មិនសូវប្រើប្រាស់អំណាច ក៏អាស្រ័យលើការឆ្លាតវៃរបស់ស្ត្រីដែលចេះសម្របខ្លួនមិនប្រឆាំងនឹងបុរស ដែលបង្កើតនូវមនោសញ្ចេតនារបស់ស្ត្រីនិងបុរសទៅកាន់មាគ៌ាជីវិត និងអារម្មណ៍ដ៏ល្អរបស់មនុស្ស។

លោក *ហ្គ្រេហ្គរី ប៊ី សាដល័រ* (Dr. Gregory B. Sadler) បានផ្តល់យោបល់ឱ្យមនុស្សស្រីចេះ បណ្តុះនូវសេចក្តីស្រឡាញ់តាមរយៈការស្លៀកពាក់ ការតុបតែងខ្លួនឱ្យបានស្អាត ការនិយាយដោយភាពញញឹមផ្អែមល្ហែម ដើម្បីជានាពីក្តីស្រឡាញ់របស់បុរសជាប្តីកុំឱ្យរាករេ ប៉ុន្តែចរិតទាំងអស់នេះគ្រាន់តែជាអត្ថន័យជំនួសនូវមិត្តភាពតែប៉ុណ្ណោះ។

ធម្មជាតិបានផ្តល់ឱ្យនារីនូវរូបរាងកាយដែលទន់ខ្សោយជាងបុរស តែដើម្បីសេចក្តីស្រឡាញ់របស់នាងក្នុងនាមជាប្រពន្ធដែលហ្វឹកហាត់ចិត្តគំនិតនិងរាងកាយ។

ស្ត្រីត្រូវដឹងថា ឆាកជីវិតរបស់គេ មិនត្រូវរស់គ្រាន់តែកំដរបុរស ហើយទោះបីជាហត់នឿយ ល្ហិតល្ហៃ ខិតខំញញឹមបំពេញអារម្មណ៍បុរសនោះទេ ស្ត្រីត្រូវប្រកាន់នូវគុណធម៌និងមានស្មារតី ឆន្ទៈមោះមុតក្នុងការគ្រប់គ្រងគ្រួសារនិងលែងចាំពឹងផ្អែកលើប្តី ផ្ទុយទៅវិញក្លាយជាមិត្តស្និតស្នាលអាចពិភាក្សាគ្នា។ បើស្ត្រីមានគុណសម្បត្តិទាំងអស់នេះ នាងនឹងមិនលាក់ចិត្តស្រឡាញ់របស់ខ្លួននិងធ្វើពើកែទឹកមុខ ដើម្បីបំពេញតែចំណង់ចិត្តប្តី។ ប្រវត្តិពីអតីតកាលក៏បានបញ្ជាក់ថា ស្ត្រីដែលធ្វើខុសពីចរិតលក្ខណៈខ្លួនមិនមែនជាស្ត្រីមានភាពស្រស់ស្អាតឬក៏ទន់ភ្លន់នោះទេ ដែលនេះជាចំណុចមូលដ្ឋាននៃគុណធម៌មនុស្សជាតិនេះ គួរតែបណ្តុះបណ្តាលដោយមានក្បួនច្បាប់តឹងរឹង ដោយសារការគោរពមនុស្សស្រីមានភាពហ្មត់ចត់បំផុត វាជាមេរៀនដ៏សំខាន់មួយគួរឱ្យចាប់អារម្មណ៍។

***ហ្ក្រហ្វរី*** បានគិតដល់ស្ត្រី ស្ត្រីត្រូវចេះលាក់ទំហំក្ដីស្រឡាញ់របស់ខ្លួនចំពោះប្ដី ពោលគឺបិទបាំងអារម្មណ៍របស់ខ្លួនដែលជារឿងមិនសមហេតុផល។ ស្នេហាគឺមិនឋិតថេរនោះទេ ហើយបើមិនចង់ឱ្យប្រែប្រួល គឺពិបាកស្វែងរកឱសថមកព្យាបាលណាស់។ បើទោះជារកឃើញក៏គ្មានតម្លៃដែរ មានតែផ្ដល់ភាពវិនាសដល់មនុស្សជាតិ។ មានតែមិត្តភាពទេដែលមានតម្លៃលើសអ្វីៗទាំងអស់ ហើយក៏ធ្លាប់មានកវីនិពន្ធ ដ៏ពូកែម្នាក់លើកឡើងថា "***សេចក្ដីស្នេហាស្មោះពិត គឺកម្រមាន ចំណែកឯមិត្តភាពពិតគឺសឹងតែគ្មានដែរ***"។

មនុស្សជាតិជាច្រើនបានឆ្លងកាត់អារម្មណ៍ស្នេហា ហើយជួនកាលអារម្មណ៍នោះ ក៏ពុះកញ្ជ្រោលធ្វើឱ្យមនុស្សឈ្លក់វង្វេងស្មារតី ប៉ុន្តែពេលគេឆ្លងកាត់ជីវិតអាពាហ៍ពិពាហ៍ កម្ដៅស្នេហាក៏សាបរលាបទៅវិញ។ អារម្មណ៍នេះនឹងសោះកក្រោះចំពោះអ្នកដែលមិនចាត់ទុកទំនាក់ទំនងស្នេហាជាមិត្តភាព ជាការគោរពគ្នាទៅវិញទៅមក ពោលគឺ ស្រឡាញ់តាមតែអារម្មណ៍រំដើបរំជួល។ មិត្តភាពពិតណាស់មានសារៈសំខាន់ជាងស្នេហា ប្រសិនបើស្ត្រីភាគច្រើនមានចិត្តចង់បានប្ដីគ្រាន់ជាទីបង្អែក ពេលគេបានរួមរស់នៅជាមួយបុរសនោះ មានន័យថា ពួកគេបានសម្រេចគោលដៅ ការសម្រេចនេះគ្មានន័យឡើយ ព្រោះស្ត្រីទាំងនោះរស់នៅចាំតែបំពេញចំណង់របស់ប្ដី។ វានឹងក្លាយជារឿងផ្សេង បើស្ត្រីនោះបណ្ដុះគំនិតពិចារណាជាមុនលើបុគ្គលិកលក្ខណៈរបស់ប្ដីដែលនាងរៀបការជាមួយ។ បើទោះបីជានាងបានទទួលប្ដីមានលក្ខណៈសម្បត្តិខ្វះខាត នាងនៅតែអាចរស់នៅជាមួយគ្នាដោយគ្មានភាពរកាំរកូស ពោលគឺ ស្ត្រីនោះមិនផ្លាស់ប្ដូរចិត្តគំនិត ស្របតែទៅតាមប្ដី ប៉ុន្តែរៀនអត់ធ្មត់រស់នៅជាមួយគ្នា។ បុគ្គលិកលក្ខណៈខ្វះខាតរបស់ប្ដី អាចជាបទពិសោធន៍ មេរៀន ប៉ុន្តែដាច់ខាតមិនមែនជាឧបសគ្គរារាំងការបណ្ដុះគុណធម៌របស់ស្ត្រីទេ។ ស្ត្រីដែលចិញ្ចឹមចិត្តចង់បានស្នេហាដ៏ផ្អែមល្ហែម តែងតែស្រមៃពីជីវិតរបស់គេរស់នៅយ៉ាងរីករាយជាមួយប្ដី ដែលនឹងផ្ដល់ការថ្នាក់ថ្នមជារៀងរាល់ថ្ងៃ។ ស្ត្រីខ្លះក៏សុខចិត្តនៅលីវ និងរង់ចាំប្ដីមានគុណសម្បត្តិល្អ នេះជាការពិតចំពោះស្ត្រីដែលមានគំនិតច្រើន និងអាចចិញ្ចឹមជីវិតដោយភាពថ្លៃថ្នូរ បើទោះជាគេមិនយកប្ដី។

ចំណែកឯ ***ដាឡៃ ឡាម៉ា*** (DALAI LAMA) យល់ថា វាជារឿងពិតដែលមនុស្សប្រុសនិងស្រីមានភាពផ្សេងគ្នាខាងរាងកាយ និងធ្វើឱ្យកម្រិតអារម្មណ៍មានភាពផ្សេងពីគ្នា

ផងដែរ។ តែបើតាមមូលដ្ឋាននៃវិធីការគិត អារម្មណ៍ និងទស្សនៈផ្សេងៗ ចរិតលក្ខណៈផ្សេងៗគឺមានដូចគ្នា។ បុរសធ្វើការបានធូន់ល្អជាងស្ត្រី ចំណែកស្ត្រីធ្វើការមានប្រសិទ្ធភាពច្រើនជាងបុរសជាមួយការងារដែលប្រើការគិត ភាពស្រស់ស្រាយ និងរហ័សរហួន។ បុរសនិងស្ត្រីច្រើនតែប្រហាក់ប្រហែលគ្នា បើយើងគិតឱ្យបានល្អិតល្អន់។

បើមិនមានភាពខុសគ្នាជាមូលដ្ឋានរវាងបុរសនិងស្ត្រីទេ វានឹងធ្វើឱ្យអ្នកទាំងពីរមានសិទ្ធិស្មើគ្នា។ ដូច្នេះ ការបែងចែកណាក៏ដោយ គឺជារឿងដែលមិនយុត្តិធម៌ទេ។ រឿងអ្វីដែលបុរសចង់បាននិងអាចធ្វើបាន ស្ត្រីក៏ចង់បាននិងអាចធ្វើបានដូចគ្នាដែរ។ ពេលណាដែលសិទ្ធិរបស់ពួកគេត្រូវបានជាន់ឈ្លី ស្ត្រីគួរតែទាមទារសិទ្ធិ ហើយបុរសគួរតែជួយគាំទ្រដល់ការទាមទារនេះ។ ខ្ញុំផ្ទាល់បានមកតស៊ូនៅឥណ្ឌាជាង២០ឆ្នាំហើយ ដើម្បីឱ្យស្ត្រីបានទទួលការសិក្សាអប់រំ និងមានការងារធ្វើឱ្យស្មើជាមួយនឹងបុរសនៅគ្រប់ជាន់ថ្នាក់នៅក្នុងសង្គមទីបេ។

តាមគោលការណ៍របស់ព្រះពុទ្ធសាសនា បុរសនិងស្ត្រីមិនមានភាពខុសគ្នា សូម្បីតែបន្តិចឡើយ ដែលយើងតែងតែនាំគ្នាហៅថាជាគុណសម្បត្តិរបស់ពុទ្ធសាសនិកជនឬក៏ជាសក្តានុពលនៃការត្រាស់ដឹង។ ហេតុនេះ ទើបពួកគេមានសិទ្ធិស្មើគ្នាដោយពិតប្រាកដ។

តាមប្រពៃណីខ្លះ បុរសនិងស្ត្រីត្រូវញែកចេញពីគ្នា ដែលទាំងអស់នេះធ្វើទៅតាមហេតុផលរបស់សង្គមនិងវប្បធម៌។ **ណាការ៍ជូណា** បានសរសេរក្នុងសៀវភៅ **ផ្កាដ៏មានតម្លៃ** អំពី "គុណវិបត្តិនៅក្នុងរាងកាយរបស់ស្ត្រី" តែគាត់មិនមានចេតនាក្នុងការបង្ហាញឱ្យឃើញថា ស្ត្រីមានឋានៈទាបជាងបុរសឡើយ តែដោយសារអ្នកបួសភាគច្រើនជាមនុស្សប្រុសដែលគោលបំណងរបស់គាត់ ក្នុងការនាំយករឿងគុណវិបត្តិរបស់ស្ត្រីមកសរសេរ ក៏ព្រោះដើម្បីជួយបុរសទាំងនោះ ឱ្យយកឈ្នះកម្លាំងប្រាថ្នាដែលមានចំពោះកាយស្ត្រីឱ្យបាន ចំណែកឯយាយជីទាំងឡាយ ក៏គួរពិចារណារាងកាយរបស់បុរសបានដូចគ្នាដែរ។

កិច្ចការជាប្រចាំខ្ពស់បំផុតរបស់ព្រះពុទ្ធសាសនិកាយមហាយាន មិនត្រឹមតែហាមមិនឱ្យមានការបែងចែកគ្នារវាងបុរសនិងស្ត្រីប៉ុណ្ណោះទេ ថែមទាំងសង្កត់ធ្ងន់ទៀតថា ស្ត្រីភេទ ជាភេទដែលមានតួនាទីសំខាន់ផងដែរ ហើយការជិះជាន់ស្ត្រីភេទចាត់ទុកថា ជាការល្មើសនឹងពាក្យសច្ចាប្រណិធាន។[២]

## ២- ភាពជាអ្នកដឹកនាំ

ភាពជាអ្នកដឹកនាំ គឺសំដៅទៅលើបុគ្គល

[២] ថេរដីការបស់សម្តេចដាឡៃឡាម៉ា **អំពីស្ត្រីនិងបុរសវ័យ** បកប្រែដោយលោក គីម ចាន់ណា ទំ ៣៨-៤០។

ដែលមានឥទ្ធិពលក្នុងការគ្រប់គ្រងកិច្ចការ ព្រមទាំងការបង្កើតយុទ្ធសាស្ត្រ ដើម្បីឱ្យអ្នកក្រោមបង្គាប់អនុវត្តតាមប្រកបដោយប្រសិទ្ធផលនិងប្រសិទ្ធភាពនៃការងារ ឬថា ជាសមត្ថភាពរបស់បុគ្គល(អ្នកដឹកនាំ អ្នកគ្រប់គ្រង ឬយើងម្នាក់) ក្នុងការអន្ទងមនុស្សឱ្យជឿ គាំទ្រ និងដើរតាម ដើម្បីធ្វើការផ្លាស់ប្តូរនិងសម្រេចបានគោលដៅ។

ភាពជាអ្នកដឹកនាំ គឺជាការយល់ពីរបៀបនៃការគ្រប់គ្រងមនុស្ស និងអាចទំនាក់ទំនងជាមួយនឹងមនុស្សបានគ្រប់ប្រភេទគ្រប់ជាតិសាសន៍ គ្រប់វប្បធម៌ដែលមានលក្ខណៈខុសគ្នា។

## ២.១- សារៈសំខាន់ នៃភាពជាអ្នកដឹកនាំ

- អាចបង្កើតបាននូវចក្ខុវិស័យដ៏ច្បាស់លាស់មួយ ដែលស្ថាបន ឬក្រុមហ៊ុនអាចសម្រេចបាន ដោយអាចផ្តល់នូវផែនទីបង្ហាញ និងរៀបចំធនធានបានគ្រប់គ្រាន់ ដើម្បីសម្រេចបាននូវគោលដៅ។

- ចេះផ្សារភ្ជាប់ទស្សនវិស័យបេសកកម្មរបស់ស្ថាបន ឬក្រុមហ៊ុនដល់ក្រុមការងារ ដោយអាចឱ្យក្រុមការងារស្គាល់ច្បាស់ពីតួនាទី ទំនួលខុសត្រូវ និងចេះប្រើជំនាញបទពិសោធន៍ផ្ទាល់ខ្លួនដ៏មានប្រសិទ្ធភាពបំផុត ដើម្បីបំពេញកិច្ចការងាររបស់ពួកគេឱ្យឆាប់បានសម្រេចនូវគោលដៅជាក់ស្តែងរបស់ខ្លួន និងរបស់ក្រុមហ៊ុន។

- សម្រេចចិត្តដ៏ត្រឹមត្រូវ ដោយចេះថ្លឹងថ្លែងពីចំណុចខ្លាំង ចំណុចខ្សោយរបស់ក្រុមហ៊ុន និងយល់គ្រប់កាលៈទេសៈដែលកើតឡើងនៅចំពោះមុខ។

- អាចជំរុញឱ្យក្រុមការងារស្គាល់ច្បាស់ពីគោលបំណងរបស់ក្រុមហ៊ុននិងផ្តល់នូវហេតុផលដ៏មានអានុភាពដល់ក្រុមការងារ ដើម្បីបន្តយកចិត្តទុកដាក់ចំពោះកាតព្វកិច្ចរបស់ពួកគេ។

- ជួយធ្វើឱ្យក្រុមការងារមានភាពរីកចម្រើន ព្រមទាំងចេះលើកទឹកចិត្តឱ្យអ្នកក្រោមបង្គាប់ដោយផ្តល់អនុសាសន៍ល្អៗដើម្បីកែប្រែកំហុស ក៏ដូចជាបង្កើនភាពខ្លាំងផ្ទាល់ខ្លួន ដើម្បីធ្វើឱ្យដំណើរការការងារ និងផ្តល់រង្វាន់បន្ថែម ចំពោះក្រុមការងារណាដែលមានការច្នៃប្រឌិត មានលទ្ធផលការងារល្អ និងមានភាពស្មោះត្រង់។

- អាចធ្វើកិច្ចការងារជាមួយមនុស្សបានគ្រប់ប្រភេទយ៉ាងមានប្រសិទ្ធភាពខ្ពស់។

## ២.២- លក្ខណៈសម្បត្តិដើម្បីក្លាយជាអ្នកដឹកនាំ

មនុស្សគ្រប់រូប សុទ្ធតែអាចក្លាយជាអ្នកដឹកនាំបាន ប៉ុន្តែដើម្បីក្លាយជាអ្នកដឹកនាំដ៏ល្អ

និងមនុស្សគ្រប់គ្នាគោរពឱ្យតម្លៃ ហើយដើរតាមដោយអស់ពីចិត្ត គឺជារឿងពិបាកបំផុត ដូច្នេះប្រសិនបើអ្នកមានគោលបំណងចង់ក្លាយជាអ្នកដឹកនាំ ចូរឈ្វេងយល់ពីលក្ខណៈសម្បត្តិខាងក្រោមជាមុនសិន[៣]៖

- **បើកចិត្តទូលាយ**៖ ជាមនុស្សចេះយល់ពីសុខទុក្ខរបស់អ្នកជុំវិញ ចេះស្តាប់អ្នកជុំវិញ និងរៀនសូត្រពីមនុស្សជុំវិញ ដោយគ្មានចិត្តចង្អៀត មិនអាត្មានិយម មិនតាំងខ្លួនជាទឹកពេញកែវឡើយ និងចេះជួយអ្នកដទៃ។

- **បន្តរៀនសូត្រពេញមួយជីវិត**៖ ទោះបីជាបច្ចុប្បន្នបានបញ្ចប់ថ្នាក់បរិញ្ញាប័ត្រ ឬមានវ័យណា កាលៈទេសៈណានោះទេ តែងតែរៀនសូត្រជានិច្ច ដើម្បីយកមកធ្វើជាក្បួន ជាបទពិសោធន៍ ជាមេរៀន ក្នុងការធ្វើឱ្យមានភាពប្រសើរឡើងនៅក្នុងជីវិតរស់នៅ ការងារកាន់តែមានប្រសិទ្ធផល និងដឹកនាំអាជីវកម្មកាន់តែរីកចម្រើន។

- **ជាគ្រូបង្វឹកដ៏ល្អ**៖ អ្នកដឹកនាំខ្លាំង ត្រូវតែមានជំនាញគ្រូបង្វឹក ដើម្បីយកជំនាញនេះមកបណ្តុះបណ្តាលក្រុមការងារឱ្យបំពេញកិច្ចការងារកាន់តែមានប្រសិទ្ធភាព និងមានលទ្ធផលខ្ពស់។

- **មានទស្សនវិស័យ និងបេសកកម្មវែងឆ្ងាយ**៖ ជាអ្នកដឹកនាំ ត្រូវតែជាគំរូដល់អ្នកដទៃ ជាពិសេសមានទិសដៅច្បាស់លាស់ ដូចជាការមានទស្សនវិស័យ និងបេសកកម្មវែងឆ្ងាយ ហើយមានផែនការជាក់ លាក់។ ធ្វើបែបនេះ ទើបអ្នកផ្សេងមានភាពជឿជាក់ និងទំនុកចិត្តខ្ពស់លើការដឹកនាំ។

- **គិតប្រយោជន៍រួម**៖ ក្នុងនាមជាអ្នកដឹកនាំ មិនមែនជាមនុស្សដែលគិតតែប្រយោជន៍ផ្ទាល់ខ្លួន ដោយមិនខ្វល់ខ្វាយពីអ្នកជុំវិញឡើយ។ ដូច្នេះដើម្បីអាចក្លាយជាអ្នកដឹកនាំបាន ចូរហ្វឹកហាត់ខ្លួនឯងឱ្យមានផ្នត់គំនិតចេះគិតពីប្រយោជន៍រួម ដោយហ៊ានលះបង់ប្រយោជន៍ផ្ទាល់ខ្លួន ដើម្បីសម្រេចបាននូវគោលដៅធំៗ។

- **មានសុចរិតភាព**៖ ជាមនុស្សដែលមិនចូលចិត្តបានតែនិយាយឡើយ ដោយចូលចិត្តបែប ហ៊ាននិយាយ ហ៊ានធ្វើសកម្មភាព និងហ៊ានទទួលខុសត្រូវ។

- **សេពគប់មនុស្សត្រូវ**៖ អ្នកដឹកនាំខ្លាំងតែងតែចេះជ្រើសរើសមនុស្សដែលមានគុណភាព មនុស្សដែលមានគំនិតច្នៃប្រឌិត មានគំនិតវិជ្ជមាន ចង់រីកចម្រើន និងជាមនុស្សខ្លាំង

[៣] https://kumnit.com/tag/ភាពជាអ្នកដឹកនាំ

ឬមនុស្សដែលមានទស្សនវិស័យ បេសកកម្ម ស្រដៀង ឬដូចគ្នា។

**- ជំនាញដោះស្រាយបញ្ហា៖** ជាមនុស្សដែលចូលចិត្តផ្តោតលើដំណោះស្រាយ និងភាពអាចទៅរួច ជាជាងគិតតែពីបញ្ហាតែគ្មានដំណោះស្រាយ។ លើសពីនេះ ជាមនុស្សដែលចេះស្វែងរកជំនួយ នៅពេលមានបញ្ហាប្រឈមណាដែលពិបាកនឹងដោះស្រាយ ហើយត្រូវការជំនួយបន្ថែមពីអ្នកមានជំនាញ ឬអ្នកមានបទពិសោធន៍។

**- ឆន្ទៈខ្ពស់៖** ជាបុគ្គលដែលមានឆន្ទៈខ្ពស់ក្នុងការធ្វើអ្វីមួយ ដោយមិនគ្រាន់តែមានគោលដៅ មានក្តីស្រឡាញ់ តែគ្មានឆន្ទៈមោះមុតក្នុងការធ្វើសកម្មភាពដើម្បីសម្រេចឡើយ។

## ២.៣- ការខារស្ទួលរបស់របស់អ្នកដឹកនាំ

- វាស់មើលគុណសម្បត្តិ
- ចក្ខុវិស័យ (បង្កើត ចែករំលែក)
- ការបណ្តុះទស្សនៈនិងទស្សនវិជ្ជា។

## ២.៤- ភាពខុសគ្នារវាងអ្នកដឹកនាំនិងអ្នកគ្រប់គ្រង

| | **អ្នកគ្រប់គ្រង** | **អ្នកដឹកនាំ** |
|---|---|---|
| ចំណាត់ការ | ធ្វើផែនការ ចាត់ចែងថវិកា<br>ចាត់ចែងការងារ ប្រើមនុស្ស | បង្កើតចក្ខុវិស័យ យុទ្ធសាស្ត្រ<br>រើសមនុស្សមកប្រើឱ្យត្រូវ |
| តម្រែតម្រង់ | តម្រង់ទិស<br>ត្រួតពិនិត្យ<br>ពន្យាតនូវកម្រិតគម្លាត | បង្កើតវប្បធម៌ចែករំលែក<br>ជួយអ្នកដទៃឱ្យរីកចម្រើន<br>បន្ថយនូវកម្រិតគម្លាត |
| ទំនាក់ទំនង | ផ្តោតលើគោលដៅ<br>ផ្អែកលើអំណាចនៃតួនាទី<br>ដើរតួជាចៅហ្វាយនាយ | បំផុសលើកទឹកចិត្តមនុស្ស<br>ផ្អែកលើអំណាចផ្ទាល់ខ្លួន<br>ដើរតួជាគ្រូបង្វឹក អ្នកសម្រប |
| បុគ្គលិកលក្ខណៈ | គម្លាតអារម្មណ៍<br>គំនិតជាអ្នកជំនាញ<br>ធ្វើតាមច្បាប់ទម្លាប់<br>យល់ដឹងបញ្ហាក្នុងអង្គភាព | ភាពជាប់អារម្មណ៍គ្នា(បេះដូង)<br>បើកចិត្ត(ដឹងចិត្ត)<br>ដឹងពីខ្លួនឯង(លក្ខណៈសម្បត្តិ) |
| លទ្ធផល | រក្សាស្ថេរភាព | បង្កើតនូវការផ្លាស់ប្តូរ |

| | | |
|---|---|---|
| | បង្កើតវប្បធម៌<br>ភាពស័ក្តិសិទ្ធ | វប្បធម៌សុច្ចរិតភាព<br>វប្បធម៌នវានុវត្ត |

## ២.៥- ប្រភេទនៃភាពជាអ្នកដឹកនាំឆ្នើម

អ្នកដឹកនាំឆ្នើម គឺជាអ្នកដើរតាមដ៏ល្អបំផុត ដែលមានភាពលេចធ្លោសូម្បីតែនៅក្នុងបន្ទប់មួយ ដែលពោរពេញទៅដោយបុគ្គលដែលមានជំនាញ មានបទពិសោធន៍ និងជោគជ័យក៏ដោយ។ អ្នកអាចប្រាប់បានភ្លាមៗថា ពួកគេគ្រាន់តែគិត ធ្វើសកម្មភាព និងដឹកនាំខុសពីមនុស្សភាគច្រើនផ្សេងទៀតប៉ុណ្ណោះ។ បុគ្គលដ៏កម្រទាំងនោះ មិនមែនក្លាយជាអ្នកដឹកនាំឆ្នើម ក្នុងរយៈពេលមួយយប់នោះទេ តែអ្នកខ្លះក៏មានទេពកោសល្យ ភាពជាអ្នកដឹកនាំពីកំណើត។ តាមរយៈការ បណ្តុះបណ្តាល បទពិសោធន៍និងបន្ថែមដោយការពិនិត្យមើលផ្លូវចិត្តខ្លួនឯងនោះ ពួកគេបានរៀនអំពីវិធីធ្វើការសម្រេចចិត្តយ៉ាងរហ័សជាមួយការជំរុញទឹកចិត្ត និងបំផុសគំនិត។ ពួកគេរៀនធ្វើការជាមួយមនុស្ស ដែលមានបុគ្គលិកលក្ខណៈ ខុសៗគ្នាជាច្រើន។ ប្រភេទនៃភាពជាអ្នកដឹកនាំឆ្នើម រួមមាន៖

- ***តម្លើងតំណែងពីមួយកម្រិតទៅមួយកម្រិត៖*** អ្នកគ្រប់គ្រង គឺជាបុគ្គលិកថ្នាក់ក្រោម ដែលបានអភិវឌ្ឍន៍ខ្លួន នឹងសន្សំបទពិសោធន៍រយៈពេលជាយូរ រហូតបានទទួលការទុកចិត្តតម្លើងតំណែងដើម្បីគ្រប់គ្រងក្រុមការងារ។ បន្ទាប់មកទើបធ្វើការសម្រេចចិត្តទៅនឹងសកម្មភាព រួមជាមួយការធ្វើការផងនោះ។ នៅពេលដែលបុគ្គលិកដែលធ្វើបេសកម្មរបស់ខ្លួនបានល្អនៅក្នុងរយៈពេលយូរអង្វែង ប្រាកដណាស់ស្ថិតនៅក្នុងការគិតគូររបស់មេដឹកនាំក្នុងការសម្រេចចិត្តថាឱ្យឡើងតំណែងឬយ៉ាងណាទៅតាមសកម្មភាពធ្វើការរបស់បុគ្គលិកនីមួយៗ។

- ***ទំនាក់ទំនង៖*** អាជីវកម្មពោរពេញទៅដោយពាក្យអ្វី? អ្វីខ្លះដែលត្រូវប្រតិបត្តិ? អ្វីខ្លះដែលត្រូវអនុវត្ត? ហើយអ្វីខ្លះទៀតដែលត្រូវនិយាយ? ពេលខ្លះសូម្បីតែអារម្មណ៍ តើយើងត្រូវមានអារម្មណ៍ដឹងអំពីអ្វីខ្លះ? អ្វីដែលតែងតែខ្វះខាតនោះគឺហេតុផល។ ហេតុនេះហើយបានជាគម្រោង ដំណើរការ និងកិច្ចការជាច្រើនបរាជ័យ។ អ្នកគ្រប់គ្រងត្រូវបញ្ជាក់ ធ្វើការពន្យល់ មកស្តាប់ពីទំនាក់ទំនងដែលមានប្រសិទ្ធភាពបំផុត គឺស្តាប់ច្រើនជាងនិយាយ ព្រោះថា ការនិយាយមានឥទ្ធិពលខ្លាំងក្នុងការទំនាក់ទំនងរវាងមេ និងបុគ្គលិក ហើយ

*បុគ្គលិក និងបុគ្គលិកជាពិសេសអ្នកនៅជុំវិញខ្លួនតែម្តង។*

- ***ការដាក់តាំងមុខតំណែង៖*** *ដោយសារបុគ្គលិកបំពេញការងារបានល្អលើសពីការរំពឹងទុករបស់មេដឹកនាំ ដោយមានភាពជាម្ចាស់ការលើទំនួលខុសត្រូវខ្លួនឯង និងទទួលខុសត្រូវចំពោះការងារបានល្អឥតខ្ចោះ នោះមានន័យថា ការងារដែលអ្នកកំពុងតែបំពេញបេសកម្មក្នុងកន្លែងធ្វើការ គឺការគោរព និងការឱ្យតម្លៃ។ បំពេញការងារដោយគិតថា ស្ថាបន ឬក្រុមហ៊ុន គឺជាស្ថាបន ឬក្រុមហ៊ុនរបស់ខ្លួនឯង ដែលបំពេញការងារជាមួយនឹងសកម្មភាពការងារទៅដោយភាពរលូន ដែលមេដឹកនាំបានឃើញនិងវាស់វែងពីសកម្មភាពរបស់បុគ្គលិកផ្ទើម។ បន្ទាប់មកទើបមានការសម្រេចចិត្តពីមេដឹកនាំ(ម្ចាស់ក្រុមហ៊ុន)បានចាត់តាំងដាក់លើមុខដំណែងថ្មីដែលត្រូវនឹងការវាស់វែងពីកម្រិតសកម្មភាពរបស់បុគ្គលផ្ទើម។*

- ***បណ្តុះអ្នកបន្តវេន*** *៖ មេដឹកនាំផ្ទើម គឺជាបុគ្គលដែលមានសមត្ថភាពអាចដឹកនាំអ្នកដទៃឱ្យដើរតាមសកម្មភាពដែលខ្លួនកំពុងតែធ្វើ ឱ្យមានលទ្ធភាពលើការងារលើសពីការរំពឹងទុករបស់មេដឹកនាំដើម្បីឱ្យបុគ្គលផ្ទើមហើយបានបង្រៀនទៅដល់បុគ្គលដទៃឱ្យមានការគិត ជាមួយនឹងសកម្មភាពឱ្យកាន់តែខ្លាំងដូចជាការបង្ហាត់បង្រៀនបុគ្គលិកក្នុងស្ថាប័ន ឬនៅទៅណាក៏ដោយដោយដើម្បីមានការអភិវឌ្ឍក្នុងស្ថាប័ននិងសង្គមជាតិទាំងមូលបាន។*

- ***ដឹកនាំកំពូល៖*** *ជំនាញភាពជាអ្នកដឹកនាំរបស់និយោជក មិនថាអ្នកជាអ្នកគ្រប់គ្រងការិយាល័យ ឬអ្នកដឹកនាំគម្រោងនោះទេ។ ចំពោះអ្នកដឹកនាំដែលល្អ គឺតម្រូវឱ្យមានជំនាញទន់មួយចំនួន ដើម្បីជួយពួកគេឱ្យមានទំនាក់ទំនងវិជ្ជមានជាមួយបុគ្គលិក ឬសមាជិកក្រុម។ និយោជកស្វែងរកជំនាញទាំងនេះនៅក្នុងបេក្ខជនដែលពួកគេដួលសម្រាប់តួនាទីជាអ្នកដឹកនាំ។ ក្នុងនោះផងដែលវាកើតឡើងពីគុណធម៌ដែលមានគុណសម្បត្តិ មានសេចក្តីថ្លៃថ្នូរ បានបង្កើតនូវស្នាដៃ កេរ្តិ៍ឈ្មោះក្នុងស្ថាប័ន ឬក្រុមហ៊ុននោះ។*

## ៣- ស្ត្រីក្នុងភាពជាអ្នកដឹកនាំនៅកម្ពុជា

*កាលពីបុរាណកាលយើងតែងឮនូវពាក្យមួយឃ្លាថា «ស្ត្រីបង្វិលចង្ក្រានមិនជុំ»។ ពាក្យនេះបានដក់ជាប់នៅក្នុងក្រឡីបេះដូងស្ត្រីខ្មែរស្ទើរតែលុបមិនជ្រះ ហើយវាក៏ជាឥទ្ធិពលមួយនៅក្នុងការបង្អាក់ដំណើរការអភិវឌ្ឍសមត្ថភាពរបស់ស្ត្រីផងដែរ ដូចជាការកំណត់គោលដៅជីវិតថា ស្ត្រីគួរតែជាមេផ្ទះ ហើយពុំចាំបាច់រៀនច្រើនពេកជាដើម។ នេះគឺជាមូលហេតុដែលនាំឱ្យមានវិសមភាពយេនឌ័រ និង*

ការកើតមាននូវអំពើហិង្សាជាអាទិ៍ ព្រោះដោយសារតែមានចំណេះដឹងទាប បូករួមជាមួយច្បាប់ទូន្មានមួយចំនួនដូចជា «កុំនាំភ្លើងក្នុងចេញក្រៅ កុំនាំភ្លើងក្រៅចូលក្នុង» ជាដើម ដែលវាជាហេតុមួយនៅក្នុងន័យថា ស្ត្រីមិនគួរយករឿងក្នុងគ្រួសារទៅប្រាប់អ្នកដទៃដើម្បីសុំជំនួយនោះទេ ទោះបីស្ថិតក្នុងរឿងហេតុប្រភេទណាក៏ដោយ។ ក៏ប៉ុន្តែផ្នត់គំនិតទាំងនេះ ត្រូវបានលុបបំបាត់ស្ទើរតែអស់ទៅហើយ ព្រោះតែស្ត្រីខ្មែរបច្ចុប្បន្នខិតខំខ្នាតខ្មីស្វែងរកចំណេះដឹង អភិវឌ្ឍខ្លួនជាបន្តបន្ទាប់ ហ៊ានសម្រេចក្តីបំណងផ្ទាល់ខ្លួន ក្លាហានក្នុងការចាប់យកក្តីស្រមៃរបស់ខ្លួន។

នៅក្នុងសង្គមកម្ពុជាយើងបច្ចុប្បន្ន ស្ត្រីមិនមែនត្រឹមតែជាស្ត្រីមេផ្ទះមួយមុខតែប៉ុណ្ណោះទេ ថែមទាំងជាបុគ្គលស្វែងរកប្រាក់ចំណូលផ្គត់ផ្គង់គ្រួសារ ជាអ្នកបណ្តុះបណ្តាល និងជាអ្នកចូលរួមការអភិវឌ្ឍសង្គមជាតិថែមទៀតផង។

ស្ត្រីប្រៀបបាននឹងសរសៃឈាមសង្គម ឆ្អឹងខ្នងសេដ្ឋកិច្ច ដែលមិនអាចខ្វះបាន ជាម្តាយ ជាវិចិត្រករនៃមនុស្ស ជាមាតាដៃ១០០ សម្រាប់ពិភពលោកទាំងមូល។

### ៣.១- ការលើកកម្ពស់ស្ត្រីក្នុងនាទីជាអ្នកដឹកនាំ

ចាប់តាំងពីក្រោយថ្ងៃរំដោះថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ រហូតដល់ពេលបច្ចុប្បន្ន រាជរដ្ឋាភិបាលកម្ពុជាតែងបានយកចិត្តទុកដាក់ជានិច្ចក្នុងការលើកកម្ពស់ស្ត្រី រហូតបង្កើតបានជាពាក្យស្លោកថា «ស្ត្រីជាឆ្អឹងខ្នងសេដ្ឋកិច្ចជាតិ»។

ការលើកកម្ពស់ មានសមភាពយេនឌ័រ គឺជាប្រធានបទដ៏មានអត្ថន័យ ដែលជាការបង្ហាញឱ្យឃើញពីការដើរតួនាទីយ៉ាងសំខាន់របស់សុខសន្តិភាពនៅក្នុងសង្គមជាតិ ជាពិសេសសុខសន្តិភាពដែលកម្ពុជារកបានយ៉ាងលំបាកក្នុងរយៈពេលកន្លងមកនេះ ជាបុព្វលក្ខខណ្ឌមិនអាចប្រកែកបានឡើយ ក្នុងការរួមចំណែកជួយដល់ការលើកកម្ពស់សិទ្ធិសេរីភាពរបស់ស្ត្រី និងជួយឱ្យស្ត្រីមានតម្លៃកាន់តែខ្ពស់ឡើងនៅក្នុងសង្គម។ គ្រប់ក្រសួង ស្ថាប័ន ពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល វិស័យឯកជន និងជនរួមជាតិទាំងអស់ អនុវត្តនូវចំណុចសំខាន់ៗដូចជា ត្រូវរួមគ្នាយកចិត្តទុកដាក់តាមរយៈការផ្តល់អាទិភាព ចំពោះការបង្កើនចំនួនស្ត្រីដែលមានតួនាទីជាថ្នាក់ដឹកនាំនៅតាមវិស័យផ្សេងៗ និងគ្រប់កម្រិត។

ជាពិសេសក្រសួងអប់រំ យុវជន និងកីឡា ត្រូវធ្វើការណែនាំដល់គ្រប់ក្រសួងស្ថាប័នទាំងអស់ឱ្យអនុវត្តវិន័យ ផ្តល់ឱកាសដល់

ក្មេងស្រីនៅគ្រប់កម្រិត ជាពិសេសឪពុកម្ដាយត្រូវអប់រំកូនចៅឱ្យមានសីលធម៌ល្អនៅក្នុងសង្គម។ ត្រូវបន្តការវិនិយោគលើការសិក្សារបស់ក្មេងស្រីនៅគ្រប់កម្រិតសិក្សា ជាពិសេសក្នុងជំនាញវិទ្យាសាស្ត្រ បច្ចេកវិទ្យា ដើម្បីធ្វើឱ្យដើរទាន់សម័យបច្ចេកវិទ្យាជឿនលឿននៃសង្គមជាតិ។

រីឯក្រសួងវប្បធម៌ ក្រសួងព័ត៌មាន និងបណ្ដាញផ្សព្វផ្សាយទាំងអស់ត្រូវបន្តពង្រឹង និងលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរយើងតាមរយៈការបង្កើតកម្មវិធីអប់រំ ដែលបង្ហាញអំពីអត្តសញ្ញាណស្ត្រីខ្មែរ ជាពិសេសតាមរយៈការស្លៀកពាក់ប្រកបដោយភាពថ្លៃថ្នូរ និងមានលក្ខណៈជាស្ត្រីខ្មែរ។

ការលើកកម្ពស់សិទ្ធិ និងសេចក្ដីថ្លៃថ្នូរ ក៏ដូចជាគុណតម្លៃសម្រាប់ស្ត្រីមិនអាចមានប្រសិទ្ធភាពត្រឹមតែការថ្លែងសារតាមមាត់ប៉ុណ្ណោះទេ ហើយក៏មិនអាស្រ័យតែលើការវិនិច្ឆ័យរបស់សង្គមក្នុងការដាក់គំនាប ឬបន្ទុះបង្អាប់បន្ថែមលើស្ត្រីដែលជាជនរងគ្រោះពីការរំលោភបំពាននោះដែរ ប៉ុន្តែទាមទារនូវការគោរព និងគាំពារជាក់ស្ដែង ដោយធានាថា សិទ្ធិពលរដ្ឋ សិទ្ធិស្ត្រីគ្រប់រូប អាចចូលរួមដោយសកម្មក្នុងជីវភាពសង្គម វប្បធម៌ សេដ្ឋកិច្ច និងនយោបាយ។ បើយោងទៅតាមរបាយការណ៍វាយតម្លៃរបស់វេទិកាសេដ្ឋកិច្ចពិភពលោកបានឱ្យដឹងថា ស្ត្រីកម្ពុជាជាប់លេខ២៥ នៅក្នុងចំណោម១៥៣ប្រទេស ដែលជាតួលេខបង្ហាញពីការចូលរួមរបស់ស្ត្រីនៅក្នុងសេដ្ឋកិច្ចកម្ពុជា។[4]

ដើម្បីក្លាយជាអ្នកដឹកនាំបាន ជាបឋមស្ត្រីត្រូវមានឆន្ទៈចង់ដោះស្រាយបញ្ហា ហើយចាប់យកឱកាសដែលមាន ដើម្បីឈានដើងចូលក្នុងភាពជាអ្នកដឹកនាំ។

ដើម្បីបង្កើនចំនួនស្ត្រីក្នុងភាពជាអ្នកដឹកនាំ ក្រសួងកិច្ចការនារី បានផ្ដួចផ្ដើមកម្មវិធីអភិវឌ្ឍភាពជាអ្នកដឹកនាំរបស់យុវជន ដើម្បីសមភាពយេនឌ័រ រយៈពេល២ឆ្នាំ នៅឆ្នាំ ២០១៩ និងឆ្នាំ២០២១ បានដាក់ឱ្យដំណើរការនៅថ្នាក់ជាតិដោយយុវជនចំនួន ៣៦នាក់ ក្នុងនោះស្រីមានចំនួន២៦នាក់ ដែលមកពីក្រសួង-ស្ថាប័ន និងសាកលវិទ្យាល័យនានា តាមរយៈកម្មវិធីបណ្ដុះបណ្ដាលជាស៊េរីរយៈពេល ១៥ ថ្ងៃ និងកម្មវិធីហ្វឹកហាត់អនុវត្តកម្មវិធី និង

---

៤ មណ្ឌលព័ត៌មានស្ត្រីកម្ពុជា **តើស្ត្រីចូលរួមអ្វីខ្លះសម្រាប់សង្គមជាតិ?** ថ្ងៃអង្គារ ទី១០ ខែមីនា ឆ្នាំ ២០២០។

គម្រោងសាកល្បងស្តីពី ភាពជាអ្នកដឹកនាំ និង សមភាពយេនឌ័រនៅតាមសហគមន៍ និង ស្ថាប័ននានា។

ក្នុងសន្និសីទសារព័ត៌មានស្តីពី សមិទ្ធផលសម្រេចបានរយៈពេល៥ឆ្នាំកន្លងមក របស់ក្រសួងកិច្ចការនារី លោកស្រីកិត្តិបណ្ឌិត **អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី បានឱ្យដឹងថា ស្ត្រីវ័យក្មេងនៅថ្នាក់ក្រោមជាតិចំនួន ៣២៥ នាក់ ក្នុងខេត្តគោលដៅ ចំនួន៤ ទទួលបានការពង្រឹងសមត្ថភាព និងអភិវឌ្ឍភាពជាអ្នកដឹកនាំនៅក្នុងវិស័យទឹកស្អាត និង អនាម័យ តាមរយៈការអនុវត្តកម្មវិធីក្នុងកិច្ចសហការជាមួយដៃគូពាក់ព័ន្ធ នៅក្នុងឆ្នាំ២០២០។ ក្រសួងបានដឹកនាំការសម្របសម្រួលជាមួយ ក្រសួង-ស្ថាប័ន សង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ និងដៃគូពាក់ព័ន្ធ តាមរយៈក្រុមការងារបច្ចេកទេសស្តីពី ស្ត្រីក្នុងភាពជាអ្នកដឹកនាំ និង អភិបាលកិច្ច ដោយអនុវត្តកម្មវិធីស្វែងរកគាំទ្រមតិ និងយុទ្ធនាការលើកកម្ពស់តួនាទីស្ត្រីក្នុងភាពជាអ្នកដឹកនាំនៅថ្នាក់ជាតិ និងក្រោមជាតិ។ ក្រសួងកិច្ចការនារី បានរៀបចំចងក្រងស្ថិតិយេនឌ័រ អំពីស្ត្រី និងបុរសនៅកម្ពុជា ដែលផ្អែកលើលទ្ធផលនៃការជំរឿនអង្កេតថ្នាក់ជាតិ និងទិន្នន័យប្រចាំឆ្នាំរបស់ក្រសួងមុខងារសាធារណៈ និងក្រសួង-ស្ថាប័នពាក់ព័ន្ធ ដែលជាឧបករណ៍សម្រាប់ការពិនិត្យតាមដានស្ថានភាពយេនឌ័រ និងស្ត្រីក្នុងភាពជាអ្នកដឹកនាំនៅគ្រប់កម្រិត និងប្រើប្រាស់សម្រាប់ការស្វែងរកការគាំទ្រ និងដាក់ចេញវិធានការគោលនយោបាយ និងកម្មវិធីឆ្លើយតប។

ក្រសួងកិច្ចការនារី បានសហការជាមួយក្រសួងមុខងារសាធារណៈ តាមរយៈការចុះអនុវត្តអនុស្សរណៈនៃការយោគយល់គ្នា ចាប់ពីឆ្នាំ២០១៩ ដើម្បីតាមដានការអនុវត្តសេចក្តីណែនាំដល់គ្រប់ក្រសួង-ស្ថាប័ន ក្នុងការជ្រើសរើសមន្ត្រីរាជការថ្មីដែលកំណត់ឱ្យមានស្ត្រីពី២០ ទៅ៥០ភាគរយ។

ជាមួយគ្នានោះ ក្រសួងបានសហការជាមួយសាលាភូមិន្ទរដ្ឋបាល ក្នុងការអនុវត្តកម្មវិធីអភិវឌ្ឍន៍ភាពជាអ្នកដឹកនាំរបស់ស្ត្រីនៅតាមក្រសួង-ស្ថាប័ន ជាអគ្គនាយករង អគ្គនាយក អនុរដ្ឋលេខាធិការ និងរដ្ឋលេខាធិការ ចំនួន ១៦៤រូប។ ក្រសួងបានសហការជាមួយសាលាជាតិរដ្ឋបាលមូលដ្ឋាន បានអភិវឌ្ឍសមត្ថភាពស្ត្រីជា អភិបាល-អភិបាលរងក្រុង-ស្រុក-ខណ្ឌ ចំនួន៦១រូប។ ក្រសួងបានអភិវឌ្ឍសមត្ថភាពក្នុងភាពជាអ្នកដឹកនាំដល់ស្ត្រីជាថ្នាក់ដឹកនាំនៅថ្នាក់ក្រសួង និងក្នុងរចនាសម្ព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិ ចំនួន១.២៨៧នាក់។ ក្រសួងបានសហការជាមួយក្រសួងមុខងារសាធារណៈ

ក្រសួងបរិស្ថាន និងក្រសួងការពារជាតិ ក្នុងការអនុវត្តកម្មវិធីភាពជាអ្នកដឹកនាំដល់ស្ត្រីជាមន្ត្រីរាជការនៅក្នុងក្រសួង-ស្ថាប័នរបស់ខ្លួន។

ជាក់ស្តែង មន្ត្រីរាជការជាស្ត្រី បានកើនឡើងដល់៤១% (២០១៨) ដល់៤២% (២០២១) និងនៅក្នុងមុខតំណែងគ្រប់គ្រង កើនឡើងពី ២៤,៣៣% (២០១៨) ដល់២៦% (២០២១)។ ស្ត្រីជាមេឃុំ-ចៅសង្កាត់ បានកើនឡើងពី ៧.៨៩% (២០១៨) ដល់ ១០.៤៧% (២០២២) និងស្ត្រីជាសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ បានកើនឡើងពី ១៣.៩៣% (២០១៨) ដល់ ២២% (២០២២)"។[5]

## ៣.២- ស្ត្រីក្នុងតួនាទីធ្វើសេចក្តីសម្រេច

គោលដៅទីប្រាំ ដែលលើកឡើងអំពីការសម្រេចបានសមភាពយេនឌ័រ និងផ្តល់អំណាចទៅស្រី និងក្មេងស្រីគ្រប់រូបរបស់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) បានទទួលស្គាល់ពីសារៈសំខាន់នៃការចូលរួមរបស់ស្ត្រីនៅក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្ត។[6] ការលើកកម្ពស់ស្ថានភាពស្ត្រីនៅក្នុងសង្គម ក៏ដូចជាបង្កើនតំណាងស្ត្រីនៅក្នុងវិស័យនយោបាយ នឹងជួយពង្រឹងសមត្ថភាពស្ត្រីដើម្បីបន្តតួនាទីភាពជាអ្នកដឹកនាំនៅក្នុងកម្រិតគ្រប់គ្រង បច្ចេកទេស និងនយោបាយ។

រដ្ឋាភិបាលដែលប្រកបដោយប្រជាធិបតេយ្យ និងមានលក្ខណៈជាតំណាងពិតប្រាកដ មិនអាចបង្កើតឡើងដោយគ្មានការចូលរួមពីពីស្ត្រីនៅក្នុងដំណើរនយោបាយបានឡើយ។ ស្ត្រីត្រូវបានមើលឃើញថា មានតួនាទីពិសេសនិងសំខាន់នៅក្នុងនយោបាយ តាមរយៈការបញ្ចេញមតិយោបល់ និងគំនិតដោះស្រាយបញ្ហាដែលកើតមានឡើង។ នៅប៉ុន្មានទសវត្សចុងក្រោយនេះ មានការកើនឡើងនូវទទួលស្គាល់ពីសារៈសំខាន់នៃការចូលរួមរបស់ស្ត្រីនៅក្នុងគ្រប់វិស័យនៅក្នុងសង្គម។ របាយការណ៍ប្រៀបធៀបមួយរបស់អង្គការសហប្រជាជាតិស្តីពីគណៈកម្មការសេដ្ឋកិច្ច និងសង្គមសម្រាប់តំបន់អាស៊ី និងប៉ាស៊ីហ្វិច (UNESCAP) បានបង្ហាញថា ស្ត្រី៖

---

៥ កម្ពុជាថ្មីប្រចាំថ្ងៃ ***ស្ត្រីក្នុងភាពជាអ្នកដឹកនាំ និងអភិបាលកិច្ច មានកំណើន ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ*** ថ្ងៃសុក្រ ទី២៣ ខែកញ្ញា ឆ្នាំ២០២២។

៦ MINISTRY OF WOMEN'S AFFAIRS 2014b. Neary Rattanak IV: ***Five years Strategic Plan for Gender Equality and Women's Empowerment Phnom Penh Ministry of Women's Affairs***

- មានសមត្ថភាពដោះស្រាយបញ្ហាសង្គម សុខមាលភាពរបស់សហគមន៍ និងបញ្ចូលចំណុចទាំងនោះ ទៅក្នុងការសម្រេចចិត្ត

- លើកកម្ពស់គោលនយោបាយ និងសកម្មភាពដែលជួយដល់សហគមន៍

- ជួយឱ្យមានការចូលរួមពីសំណាក់អ្នកពាក់ព័ន្ធកាន់តែច្រើន

- លើកឡើងពីសារៈសំខាន់ និងការអនុវត្តការប្រាស្រ័យទាក់ទងល្អជាមួយសហគមន៍

- មានវិធីសាស្ត្រផ្សេងៗចូលរួមជាមួយការងាររបស់អជ្ញាធរមូលដ្ឋាន

- បង្កើតវិធីសាស្ត្រធ្វើការងារជាមួយក្រុមការងារ

- កំណត់អាទិភាពផ្សេងៗគ្នា

- មានជំនាញសម្របសម្រួល កំណត់គោលដៅច្បាស់លាស់ ធ្វើការងារបានច្រើនប្រភេទ និងចេញលទ្ធផលជាក់ស្តែង

- មានការលះបង់ ទទួលខុសត្រូវ និងអនុវត្តន៍ថានេះអ្វីដែលបានផ្សព្វផ្សាយ និងមានស្មារតីល្អក្នុងការងារ

- ជំរុញ និងលើកកម្ពស់ស្ត្រីផ្សេងៗទៀតឱ្យចូលរួមមានក្នុងការអភិវឌ្ឍ។

វិសមភាពយេនឌ័រនៅតែជាបញ្ហាសំខាន់នៅប្រទេសកម្ពុជា ទោះបីជាមានការអភិវឌ្ឍយ៉ាងឆាប់រហ័ស ផ្នែក សេដ្ឋកិច្ច សង្គម និងនយោបាយ នៅក្នុងប្រទេសយ៉ាងណាក៏ដោយ។ ខណៈពេលដែលមានការរីកចម្រើនគួរឱ្យកត់សម្គាល់ក្នុងការកាត់បន្ថយគម្លាតយេនឌ័រនៅក្នុងវិស័យជាច្រើន ប៉ុន្តែស្ថិតិនៅតែបង្ហាញថា ការចូលរួមរបស់ស្ត្រីនៅក្នុងវិស័យជាច្រើននៅតែមានកំណត់។ ឧទាហរណ៍ សមាមាត្រស្ត្រីជាប់ឆ្នោតជាសមាជិកសភាមានការថយចុះបន្តិចពី២១,១០% នៅឆ្នាំ២០០៨ ២០,៣២% នៅឆ្នាំ២០១៣ ហើយនៅឆ្នាំ ២០២១ មានការកើនឡើងដល់ ២០.៨០%។ ខណៈពេលដែលភាគរយរបស់ស្ត្រីជាសមាជិកព្រឹទ្ធសភានៅថេរពីឆ្នាំ១៩៩៩រហូតដល់ឆ្នាំ២០១២ គឺមានជំនួន ១៨,៧៥% ហើយដល់ឆ្នាំ២០២១ មានការថយចុះមកនៅត្រឹម ១៦.១៣%។

នេះបញ្ជាក់យ៉ាងច្បាស់ថា ទោះបីជារដ្ឋាភិបាលកម្ពុជាបានធ្វើឱ្យមានការរីកចម្រើនគួរឱ្យកត់សម្គាល់ ទៅលើការលើកកម្ពស់សមភាពយេនឌ័រ និងជំរុញស្ត្រីនៅក្នុងការសេចក្តីសម្រេច និងនយោបាយយ៉ាងណាក៏ដោយ ក៏ការរីកចម្រើននៅតែមានភាពយឺតយ៉ាវដដែល។

ជាងនេះទៅទៀត ក្នុងចំណោម ឧបនាយករដ្ឋមន្ត្រី១០រូប មានស្ត្រីតែមួយរូបប៉ុណ្ណោះ ហើយមានស្ត្រីជារដ្ឋមន្ត្រី ៣រូប

(១០.៣៤%)។ ចំនួនស្ត្រីនៅក្នុងតួនាទីធ្វើសេចក្តីសម្រេច គឺមានតិចតួចនៅឡើយ ក្នុងចំណោមរដ្ឋមន្ត្រីចំនួន២៩រូបក្នុងជួររដ្ឋាភិបាល មានតែបីរូបប៉ុណ្ណោះដែលកាន់កាប់ដោយស្ត្រី។

ចំនួនស្ត្រីជាថ្នាក់ដឹកនាំមានការកើនឡើងតាមរយៈការលើកទឹកចិត្ត និងតែងតាំងស្ត្រីជាអ្នកដឹកនាំនៅគ្រប់ក្រសួង-ស្ថានទាំងអស់។ សមាមាត្រស្ត្រីដែលបានតែងតាំងជារដ្ឋលេខធិការមានការកើតឡើងពី៨,០៨% (ស្ត្រី១៦រូបក្នុងចំណោម១៩៨រូប) ទៅ២០,៥៤% (ស្ត្រី៣៨រូប ក្នុងចំណោម១៨៩រូប) រវាងឆ្នាំ២០០៨ និងឆ្នាំ២០១៣ហើយនៅឆ្នាំ២០១៨ ស្ត្រីជារដ្ឋលេខាធិការមានចំនួន ៣៦នាក់ ស្មើនឹង១៥,៧៨%។ សមាមាត្រស្ត្រីដែលបានតែងតាំងជាអនុរដ្ឋលេខធិការត្រូវបានកើនឡើងពី១៦% (ស្រី៣៣រូប ក្នុងចំណោម ២០៥ រូប) ទៅ១៧,៦០% (ស្ត្រី៤៨រូប ក្នុងចំណោម ២៧៣រូប) រវាងឆ្នាំ២០០៨ និងឆ្នាំ២០១៣ និងកើនឡើងដល់ ៥៦រូបនៅឆ្នាំ២០១៨។ ចំនួននេះយើងឃើញថាស្ត្រីដែលជាអនុរដ្ឋលេខាធិការមានចំនួនកើនឡើង ប៉ុន្តែបើគិតពីសមាមាត្រយើងឃើញថា មានចំនួនថយចុះទៅវិញ គឺមានត្រឹមតែ១៤,៣២%។

សម្រាប់ថ្នាក់ក្រោមជាតិ សមាមាត្រស្ត្រីជាថ្នាក់ដឹកនាំខេត្តនៅមានកម្រិតតិចតួចនៅឡើយ គឺមានតែពីររូបប៉ុណ្ណោះ រហូតដល់ពេលបច្ចុប្បន្ននេះ។ ទោះបីជាយ៉ាងណាក៏ដោយ ការរីកចម្រើនមួយត្រូវបានធ្វើឡើងនៅថ្នាក់អភិបាលរង គឺមាន១៧% (ស្ត្រី ២៥រូប ក្នុងចំណោម១៥០រូប) នៅថ្នាក់រាជធានីខេត្ត ដែលត្រូវបានតែងតាំងជាស្ត្រី។ ស្ត្រីដែលកាន់តួនាទីជាអភិបាលស្រុក-ខណ្ឌ មានចំនួន៧រូប ក្នុងចំណោម ១៩៧រូប និងស្ត្រីជាអភិបាលរងស្រុក-ខណ្ឌ មានចំនួន១៩៤រូប។

ខាងក្រោមនេះជាចំនួនស្ត្រីដែលមានតួនាទីក្នុងការធ្វើសេចក្តីសម្រេច[7]៖

- ក្រុមប្រឹក្សាធម្មនុញ្ញស្រី២នាក់
- ស្ត្រីជាសមាជិកព្រឹទ្ធសភា១០នាក់ (១៦.១៣%)
- ស្ត្រីជាសមាជិករដ្ឋសភា២៦នាក់ (២០.៨០%)
- ស្ត្រីជារដ្ឋមន្ត្រី ៣នាក់(១០.៣៤%)
- ស្ត្រីជារដ្ឋលេខាធិការ៣៦នាក់ (១៥,៧៨%)
- ស្ត្រីជាអនុរដ្ឋលេខាធិការ៥៦នាក់ (១៤,៣២%)
- ស្ត្រីជាអភិបាលខេត្ត២នាក់

[7] តាន់ ផល្លី ជ.ឯ.ម ទំព័រ៧៣។

- ស្ត្រីជាអភិបាលរងខេត្ត រាជធានី ២៥នាក់

- ស្ត្រីជាអភិបាលស្រុក ក្រុង៧នាក់

- ស្ត្រីជាអភិបាលរងស្រុក ក្រុង១៩៤នាក់

- ស្ត្រីជាប្រធានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ៥នាក់

- ស្ត្រីជាសមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ៦១៧នាក់

- ស្ត្រីជាមេឃុំ ចៅសង្កាត់១៣០នាក់ (៧.៨៩%)

- ស្ត្រីជាជំទប់ទី១ ២៧២នាក់ (១៦.៣១%)

- ស្ត្រីជាជំទប់ទី២ ២៨៥នាក់ (១៧.៣១%)

- ស្ត្រីជាសមាជិកក្រុមប្រឹក្សាឃុំ១,៦១១ នាក់ (១៤%)

- ស្ត្រីជាចៅក្រម៤៦នាក់ (១៥.២៨% ២០១៩)

- ស្ត្រីជាព្រះរាជអាជ្ញា២៥នាក់ (១៣.៥១%)

- ស្ត្រីជាក្រឡាបញ្ជី១៨៩នាក់ (២២.៧%)

- ស្ត្រីជាមន្ត្រីរាជការ៤១% (២០២០)

- ស្ត្រីជាមន្ត្រីរាជការដែលមានមុខតំណែងចាប់ពី ថ្នាក់ការិយាល័យតាមស្រុកដល់ថ្នាក់អគ្គនាយក២៦% (២០២០)។

## ៤- ស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈមភាពជាអ្នកដឹកនាំរបស់ស្ត្រី

បើទោះបីជាមានវឌ្ឍនភាពខ្លះៗរបស់ស្ត្រីក្នុងតួនាទីជាអ្នកដឹកនាំក្នុងរយៈពេលកន្លងមក ហើយស្ត្រី ត្រូវបានចាត់ទុកនិងជឿថា គឺជាកម្លាំងចលករដ៏សំខាន់ក្នុងកិច្ចការអភិវឌ្ឍសេដ្ឋកិច្ច វប្បធម៌ និងសង្គមក្តី ក៏ស្ត្រីនៅតែមានតំណាងតិចតួចនៅក្នុងវិស័យសាធារណៈ ជាពិសេសក្នុងតួនាទីដឹកនាំទាំងនៅថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ។

កត្តា វប្បធម៌ សង្គម និងសេដ្ឋកិច្ច ជាកត្តាសំខាន់ដែលបានរួមចំណែកក្នុងការធ្វើឱ្យមានស្ត្រីជាតំណាងតិចតួចនៅក្នុងវិស័យសាធារណៈ។ តួយ៉ាង កង្វះស្ត្រីនៅក្នុងតួនាទីដឹកនាំមានការទាក់ទងនឹងផ្នត់គំនិត និងឥរិយាបថបុរេនិច្ឆ័យចំពោះសមត្ថភាពរបស់ស្ត្រី ក៏ដូចជាតួនាទីរបស់ស្ត្រីដែលមនុស្សទូទៅតែងតែរំពឹងទុក ហើយកត្តាទាំងនេះ គឺជាឧបសគ្គធំបំផុតដែលរារាំងស្ត្រីក្នុងការក្លាយជាអ្នកដឹកនាំ។ ស្របគ្នានេះដែរ ការរើសអើងទៅលើអាយុ ឧបសគ្គលក្ខណៈស្ថាប័ន និងឧបសគ្គផ្នែកហិរញ្ញវត្ថុ ត្រូវបានរកឃើញថាគឺ

ជាឧបសគ្គសំខាន់ៗដែលរារាំងស្ត្រីក្នុងការក្លាយជាអ្នកដឹកនាំ។

ផ្នត់គំនិត និងការធ្វើបុរេនិច្ឆ័យទៅលើសមត្ថភាពរបស់ស្ត្រីនៅតែចាក់ជ្រៅក្នុងចំណោមប្រជាពលរដ្ឋទូទៅមួយចំនួន ជាមួយគ្នានោះដែរ ស្ត្រីខ្លួនឯងក៏បានចង់ខ្លួនឯងមិនឱ្យក្លាយជាអ្នកដឹកនាំផងដែរ។ នៅប្រទេសកម្ពុជាយើងបច្ចុប្បន្ន មានឧបសគ្គចម្បងចំនួន៧ ដែលរារាំងស្ត្រីក្នុងការឈានទៅរកតួនាទីជាអ្នកដឹកនាំ រួមមានៈ បន្ទុកគ្រួសារ កង្វះការលើកទឹកចិត្ត/ការគាំទ្រ ឥទ្ធិពលរបស់បុរសលើសលប់ក្នុងវិស័យសាធារណៈ ការអប់រំ/សមត្ថភាព/ទំនុកចិត្តរបស់ស្ត្រីនៅទាប ការរើសអើងដោយបុរស និងស្ត្រីដទៃទៀត ផ្នត់គំនិតដែលរឹតត្បិតសេរីភាពរបស់ស្ត្រី និងឧបសគ្គផ្នែកសុខភាព(ត្រូវបានគេយល់ថាមានភាពទន់ខ្សោយ និងការមានគភ៌)។

ឧបសគ្គចម្បងទាំងនេះដែលមានការទាក់ទងគ្នា បានដាក់កម្រិតលើឱកាសសម្រាប់ស្ត្រីដើម្បីឈានទៅកាន់តួនាទីដឹកនាំ ដូចជាៈ ការបន្ទុចបង្អាក់ពីឪពុកម្តាយ ការរើសអើងទៅលើភេទ ឱកាសសម្រាប់ស្ត្រីដើម្បីក្លាយជាអ្នកដឹកនាំនៅមានកម្រិត ការធ្វើចំណាកស្រុកដើម្បីការងារ សេរីភាពក្នុងការបញ្ចេញមតិនៅមានកម្រិតបក្ខពួកនិយម និងកង្វះជំនាញទន់។

ដរាបណាផ្នត់គំនិត និងការធ្វើបុរេនិច្ឆ័យចំពោះស្ត្រី និងយុវជននៅតែមាន ពួកគេអាចនៅតែមើលឃើញថាវាជាការពិបាកដើម្បីបំពេញតួនាទីសំខាន់ៗនៅក្នុងសង្គមជាតិ។ ស្ត្រីគួរតែត្រូវបានផ្តល់ឱកាសគ្រប់គ្រាន់ និងបរិយាកាសអំណោយផល ដើម្បីឱ្យពួកគេអាចអភិវឌ្ឍខ្លួនឯង និងបង្ហាញខ្លួនឱ្យមនុស្សទូទៅបានស្គាល់ បញ្ចេញនូវសក្តានុពលរបស់ពួកគេ និងដើរតួនាទីយ៉ាងសកម្មនៅក្នុងតួនាទីធ្វើសេចក្តីសម្រេចចិត្ត។

ថ្វីបើស្ត្រីដ៏ច្រើន និងមានសក្តានុពលក៏ដោយ ពួកគេនៅតែមានបរិមាណតិចតួចណាស់នៅក្នុងតួនាទីដឹកនាំ ជាពិសេសក្នុងវិស័យសាធារណៈ។ ដូច្នេះយើងខ្ញុំសូមអំពាវនាវដល់គ្រប់ភាគីពាក់ព័ន្ធទាំងអស់ឱ្យខិតខំបន្ថែមទៀតដើម្បីលើកកម្ពស់ និងពង្រឹងសិទ្ធិអំណាចស្ត្រីឱ្យចូលរួមក្នុងតួនាទីដឹកនាំ។ សំខាន់ជាងនេះទៅទៀត វាមានភាពចាំបាច់នៃកិច្ចខិតខំប្រឹងប្រែងរួមគ្នាក្នុងការបង្កើតបរិយាកាសអំណោយផលដល់ស្ត្រីដើម្បីចូលរួមប្រកបដោយប្រសិទ្ធភាពនៅក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តដោយគ្មានការភ័យខ្លាចការវិនិច្ឆ័យ ការរើសអើង និងការបំភិតបំភ័យ។ ការគាំទ្រសមស្របគួរតែផ្តល់ជូនផងដែរដល់ស្ត្រី ដើម្បីបង្កើត និងធានានូវបរិយាកាស

អំណោយផល សម្រាប់ការចូលរួម និងការដើរតួនាទីកាន់តែសំខាន់របស់ស្ត្រី ក្នុងជីវភាពសង្គម សេដ្ឋកិច្ច និងនយោបាយ។

## សេចក្តីសន្និដ្ឋាន

តាមរយៈនៃការរៀបរាប់ពីខាងលើ បង្ហាញឱ្យយើងឃើញថា ពីដំណាក់កាលមួយឆ្លងទៅដំណាក់កាលមួយទៀត ទោះបីជាយើងមានការខិតខំបែបណាក៏ដោយ ក៏លទ្ធផលដែលទទួលបានមកនោះ គឺហាក់នៅមានកម្រិតនៅឡើយ។ ការផ្តល់សិទ្ធិអំណាចដល់ស្ត្រី គឺនៅវែងឆ្ងាយទៀត ដែលស្ត្រីខ្មែរកំពុងដើរលើផ្លូវឆ្ពោះទៅរកទិសដៅដែលធ្វើឱ្យបុរសទទួលស្គាល់កាន់តែច្បាស់ នូវភាពចាំបាច់របស់ស្ត្រីក្នុងការរួមចំណែកអភិវឌ្ឍសង្គម សេដ្ឋកិច្ច ជាពិសេសវិស័យនយោបាយ។

ដំណើរឆ្ពោះទៅមុខរបស់ស្ត្រីខ្មែរបច្ចុប្បន្ន មានការតស៊ូ ព្យាយាម អត់ធ្មត់ ចូលរួមការងារយ៉ាងសកម្ម ក្នុងការលើកកម្ពស់សមភាពយេនឌ័រ ទប់ស្កាត់ និងកាត់បន្ថយអំពើហឹង្សាលើស្ត្រី ផ្តល់ភាពក្លាហាន បង្កឱកាស និងលើកទឹកចិត្តខ្លួនឯង បង្ហាញសមត្ថភាព និងសក្តានុភាពរបស់ខ្លួន ក្នុងការចូលរួមចំណែកអភិវឌ្ឍសង្គម និងប្រទេសជាតិប្រកបដោយសមត្ថភាពនិងភាពជឿជាក់។

ការអភិវឌ្ឍប្រទេសក្នុងពេលបច្ចុប្បន្ន បានរំលេចឱ្យឃើញនូវការលូតលាស់យ៉ាងសកម្មក្នុងការអនុវត្តគោលនយោបាយសមភាពយេនឌ័រ ដែលជាអាទិភាពរបស់រាជរដ្ឋាភិបាល បានកែប្រែស្ថានភាពនិងជីវភាពរស់នៅរបស់ស្ត្រី មានការរីកចម្រើនល្អប្រសើរជាលំដាប់ ។

យន្តការនៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ក្រសួងកិច្ចការនារី ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បានខិតខំបំពេញការងារ និងភារកិច្ចរបស់ខ្លួនសម្រេចបានលទ្ធផលគួរជាទីមោទនៈ តាមរយៈការអនុវត្តច្បាប់ គោលនយោបាយទៅតាមផែនការការរំពឹងទុក ប្រកបដោយការទទួលខុសត្រូវខ្ពស់។

សម័យបច្ចុប្បន្ន ក្នុងគ្រួសារដែលមានជីវភាពរស់នៅខ្ពស់មធ្យម បានបញ្ជូនកូនស្រីប្រុសទៅសាលារៀនបានគ្រប់ៗគ្នា និងមួយចំនួនបានទទួលការសិក្សាខ្ពស់ដល់អនុបណ្ឌិត បណ្ឌិត តាមសកលវិទ្យាល័យល្បីៗនានា មានក្នុងប្រទេស និងក្រៅប្រទេស មានដូចជា អាម៉េរិកកាំង បារាំង អូស្ត្រាលី ជប៉ុន អង់គ្លេស ដែលក្នុងនោះស្ត្រីបានសិក្សា និងកំពុងបន្តការសិក្សាជាន់ខ្ពស់មានតួលេខកាន់តែច្រើនជាងមុន។ និស្សិតនារី អាចទទួលបានឱកាស និងសិទ្ធិពេញលេញស្មើគ្នាជាមួយបុរសក្នុងការ

ទទួលយកចំណេះដឹង និងការចូលរួមអភិវឌ្ឍប្រទេសជាតិ។

ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាល ដែលមានចក្ខុវិស័យ និងយុទ្ធសាស្ត្រផ្តោតយ៉ាងជាក់លាក់ទៅលើការលើកកម្ពស់សមភាពយេនឌ័រ និងការអភិវឌ្ឍស្ថាប័ន កំពុងអនុវត្តដើម្បីប្រជាជនកម្ពុជា ជាពិសេសស្ត្រី និងយុវវ័យ បានរួមចំណែកអភិវឌ្ឍប្រទេសឱ្យឈានឆ្ពោះទៅរកភាពចម្រើនរុងរឿង មានជាអាទិ៍ ការធ្វើឱ្យប្រសើរឡើងនូវកំណើនសេដ្ឋកិច្ច ការរក្សានូវសន្តិភាព ស្ថិរភាពនយោបាយ និងសន្តិសុខសង្គម ព្រមទាំងការលើកកម្ពស់សិទ្ធិ សេចក្តីថ្លៃថ្នូរ និងសីលធម៌ផងដែរ។ ទន្ទឹមនឹងនេះ ដំណើរការនៃគណៈកម្មាធិការជាតិលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ និងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី មានការរីកចម្រើនគួរឱ្យកត់សម្គាល់ ក៏ជាចំណែកមួយដ៏សំខាន់ក្នុងការលើកកម្ពស់ស្ថានភាព តម្លៃស្ត្រី រួមទាំងសីលធម៌សង្គម វប្បធម៌ និងប្រពៃណីដ៏ល្អផូរផង់របស់កម្ពុជា។

សម័យសកលភាវូបនីយកម្មទាំងក្នុងជួររាជរដ្ឋាភិបាល និងវិស័យឯកជន បច្ចុប្បន្ននេះស្ត្រីភាគច្រើនបានទទួលជោគជ័យក្នុងជីវិតដ៏ប្រសើរដោយការខំប្រឹងប្រែងអស់ទាំងកម្លាំងកាយ កម្លាំងចិត្ត ខិតខំព្យាយាម តស៊ូ អំណត់អត់ធន់ដើម្បីរួមចំណែកអភិវឌ្ឍប្រទេសជាតិឱ្យរីកចម្រើនរុងរឿងប្រកបដោយសក្តានុពល និងវឌ្ឍនភាព៕

## ឯកសារពិគ្រោះ

- ក្រសួងកិច្ចការនារី *ព្រឹត្តិបត្រនារីរតនៈ* ចេញផ្សាយប្រចាំខែមីនា ឆ្នាំ២០១០ ភ្នំពេញ។
- ក្រុមអ្នកស្រាវជ្រាវកម្មវិធីបណ្តាញការងារ *យេនឌ័រ និងអាកប្បកិរិយាចំពោះស្នេហា* មណ្ឌលព័ត៌មានស្ត្រីកម្ពុជា ចេញផ្សាយពីខែមេសា-មិថុនា ឆ្នាំ២០០០។
- គង់ សុខហេង *សិក្សាកាព្យឱវាទច្បាប់ស្រីរបស់បណ្ឌិត ម៉ឹន ម៉ៃ និងព្រះបាទអង្គឌួង* ភ្នំពេញ ឆ្នាំ២០០៩។
- ឃី សុវណ្ណរតនា *ឋានៈស្ត្រីក្នុងព្រះពុទ្ធសាសនា* ទស្សនាវដ្តីកម្ពុជសុរិយា លេខ២និងលេខ៤ វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ ឆ្នាំ២០០៤។
- ឃុន សាថាល់ *មុខងារ និងតួនាទីស្ត្រីនៅសម័យបុរាណ* សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្របុរាណវិទ្យាជំនាន់ទី១១, ភ្នំពេញ (២០០៤)។
- ង៉ួន ញ៉ិល *ព្រលឹងមាតាធិបតេយ្យក្នុងសង្គមខ្មែរ* បោះពុម្ពដោយក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ភ្នំពេញ ឆ្នាំ២០០០។
- ជា វណ្ណី *ការប្រៀបធៀបបច្ចុប្បន្នភាពស្ត្រីជាមួយនឹងស្ត្រីក្នុងរឿងព្រេងខ្មែរ* សមាជស្រាវជ្រាវសង្គមវប្បធម៌អំពីកម្ពុជា លើកទី៨ ភ្នំពេញ ឆ្នាំ២០០៧។
- ដួង សាយរុន *តួនាទីស្ត្រីខ្មែរ និងសិទ្ធិមនុស្ស* ការផ្សាយរបស់សមាគមអាដហុក ភ្នំពេញ ឆ្នាំ១៩៩៧។
- តាន់ ផល្លី និក្ខេបបទថ្នាក់បណ្ឌិតទស្សនវិជ្ជា *"តម្លៃស្ត្រីខ្មែរសម័យសកលភាវូបនីយកម្ម"* រាជបណ្ឌិត្យសភាកម្ពុជា ២០២២។
- ទ្រូឌី ចេកុប្បិន *មហាឧបាសិកា សីលធម៌ និងអំពើជាកុសលរបស់ស្ត្រីនៅប្រទេសកម្ពុជានាសម័យកណ្តាល* ទស្សនាវដ្តីសិក្សាចក្រ លេខ៨-៩ ឆ្នាំ២០០៦-២០០៧។
- ជា សុកម៉េង *តួនាទីស្ត្រីខ្មែរតាមរយៈប្រវត្តិសាស្ត្រ និងអក្សរសិល្ប៍* ទស្សនាវដ្តីសង្គមសាស្ត្រ-មនុស្សសាស្ត្រ ឆ្នាំទី៣៤ លេខ៤៧-៤៨ ភ្នំពេញ ឆ្នាំ២០០៤។
- នាយកដ្ឋានផែនការនិងស្ថិតិនៃក្រសួងកិច្ចការនារី *ខិត្តប័ណ្ណស្ថិតិយេនឌ័រសំខាន់ៗក្នុងប្រទេសកម្ពុជា* ភ្នំពេញ ចេញផ្សាយខែមីនា ឆ្នាំ២០០៩។
- នួន សុធិមន្ត *លក្ខណសម្បត្តិមេដឹកនាំ* បណ្ណាគារអង្គរធំ ភ្នំពេញ ឆ្នាំ២០០៨។
- ប៊ុញ សឿន *តម្លៃអប់រំស្ត្រីខ្មែរតាមរយៈសុភាសិតច្បាប់ស្រីរបស់អ្នកឧកញ៉ាសុត្តន្តប្រីជាឥន្ទ* សារណា

បញ្ចប់ថ្នាក់បរិញ្ញាបត្រអក្សរសាស្ត្រខ្មែរ ភ្នំពេញ ឆ្នាំ២០០៧។
- ប៊ុត សាវង្ស ***ស្ត្រីក្នុងព្រះពុទ្ធសាសនា*** រោងពុម្ព អ៊ឹម សាវ័ន្ត ភ្នំពេញ ឆ្នាំ២០០៨។
- ព្រួច គុម ***លក្ខណ៍របស់បុរសស្ត្រី*** ទស្សនាវដ្តីកម្ពុជសុរិយា លេខ៣ វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ ឆ្នាំ១៩៩៩។
- មៀច ប៉ុណ្ណ ***ក្រមុំចូលម្លប់*** បោះពុម្ពដោយបណ្ណាគារអង្គរ ភ្នំពេញ ឆ្នាំ២០០៧។
- ម៉ៅ តាន់ណារី ***វីរភាពរបស់ស្ត្រីខ្មែរនៅក្នុងអក្សរសិល្ប៍*** ទស្សនាវដ្តីសំឡេងស្ត្រីខ្មែរ លេខ៣៨-៤០ ការផ្សាយរបស់មជ្ឈមណ្ឌលសំឡេងស្ត្រីខ្មែរ ភ្នំពេញ ឆ្នាំ១៩៩៨។
- លឹម លីម៉ា ***ស្ត្រីខ្មែរ និងការកសាងជាតិតាមរយៈសីលធម៌ព្រះពុទ្ធសាសនា*** សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រទស្សនៈវិជ្ជាជំនាន់ទី១៧ ភ្នំពេញ ឆ្នាំ២០០០។
- ស ចរិយា ***សម្បត្តិនារី*** បោះពុម្ពឡើងវិញ ភ្នំពេញ ឆ្នាំ២០០៤។
- ស៊ីរិ សារីណា ***ស្ត្រី និងព្រះពុទ្ធសាសនានៅក្នុងសង្គមខ្មែរ*** សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្របុរាណវិទ្យា ជំនាន់ទី១១ ភ្នំពេញ ឆ្នាំ២០០៤។
- សុង ស៊ីវ ***សុជីវធម៌ប្រចាំសង្គមគ្រួសារ*** បោះពុម្ពឡើងវិញដោយ គិន ប៊ុនថន ភ្នំពេញ ឆ្នាំ១៩៩៩។
- សុត្តន្តប្រីជា ឥន្ទ ***សុភាសិតច្បាប់ស្រី*** បោះពុម្ពលើកទី៣ វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ ឆ្នាំ១៩៥៩។
- ហ៊ុល ថុនហាក់ ***ឥទ្ធិពលកំណាព្យលើការអប់រំផ្នែកយេនឌ័រក្នុងអតីត និងបច្ចុប្បន្ន*** សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រអក្សរសាស្ត្រខ្មែរជំនាន់ទី២៣ ភ្នំពេញ ឆ្នាំ២០០៦។
- ហេម៉ា ហ្គូណាទីលេក ***ព្រះពុទ្ធសាសនា សិទ្ធិស្ត្រី និងសិទ្ធិមនុស្ស*** ផ្សាយដោយសមាគមដូនជី និងឧបាសិកាកម្ពុជរដ្ឋ ឆ្នាំ១៩៩៦។
- ហៀប អានកន្និដ្ឋា ***ការរំសារស្ត្រី*** សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រវិចិត្រកម្មជំនាន់ទី១៤ ភ្នំពេញ ឆ្នាំ ២០០៦។
- អង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា ***សៀវភៅមេរៀនចំណេះដឹងយេនឌ័រ*** បោះពុម្ពលើកទី២ ភ្នំពេញ ឆ្នាំ២០០៣។
- អង្គ ឌួង ***ច្បាប់ស្រី*** ចេញផ្សាយដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ ឆ្នាំ១៩៦២។
- អាំង ជូលាន " ***ស្រី*** " កម្រងអត្ថបទក្នុងបណ្ដាញពត៌មានវប្បធម៌ខ្មែរ, លេខ២៤, ភ្នំពេញ ឆ្នាំ២០០៨-

២០០៩។
- ឱម ខែម " ***ស្វាមីថប្រការនិងភរិយាពប្រភេទ*** " ទស្សនាវដ្ដីកម្ពុជសុរិយា លេខ៤ វិទ្យាស្ថាន ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ ឆ្នាំ១៩៩៤។
- ឱម ខែម " ***អំពីស្ត្រីភាព*** " ទស្សនាវដ្ដីកម្ពុជសុរិយា លេខ៣ វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ ឆ្នាំ២០០០។

# មែកធាងចម្បងៗនៃទស្សនវិជ្ជា

ដោយៈ បណ្ឌិត **ហែម ឡាច**
ប្រធានស្តីទីនាយកដ្ឋាននីតិសាស្ត្រ
វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសង្គមនៃរាជបណ្ឌិត្យសភាកម្ពុជា

## ១-ពុទ្ធិវិជ្ជា

ពុទ្ធិវិទ្យា (Epistemology) គេហៅម្យ៉ាងទៀតថា ទ្រឹស្តីពុទ្ធិគឺជាវិស័យសំខាន់បំផុតមួយក្នុងចំណោមវិស័យសំខាន់នានារបស់ទស្សនវិជ្ជា។ ការអភិវឌ្ឍនវិស័យសិក្សាក្នុងផ្នែកនេះចាប់ផ្តើមឡើងនៅសម័យបុរាណជាមួយ ប្លាតុង(Platon)នៅពេលទស្សនវិទូទាំងឡាយចោទបញ្ហាទាក់ទងទៅនឹងអ្វីដែលយើងដឹង។ មានសំណួរជាច្រើនស្តីពីពុទ្ធិនេះ។ សំណួរទាំងនេះភាគច្រើនទាក់ទងជាមួយប្រភពកំណើតពុទ្ធិ ធម្មជាតិរបស់វានិងសុពលភាពចំពោះអ្វីដែលយើងយល់ដឹង។ សំណួរទាំងនេះមានដូចជា តើយើងស្គាល់អ្វីមួយបានយ៉ាងដូចម្តេច? តើអ្វីដែលយើងស្គាល់គេហៅថាអ្វី? តើយើង ម្នាក់ៗអាចប្រាកដក្នុងខ្លួនបានយ៉ាងដូចម្តេចចំពោះអ្វីដែលយើងស្គាល់ថាត្រឹមត្រូវឬយកជាការបាន។

ប្រវត្តិសាស្ត្រលាតត្រដាងថាមាន ទស្សនៈយោបល់ និងជំនឿជាច្រើនដែលនៅក្នុងសម័យកាលមួយឬក្នុងសម័យកាលផ្សេងទៀត ត្រូវបានគេចាត់ទុកថាពិត ប៉ុន្តែប្រែក្លាយជាមិនពិត។ មានសម័យកាលមួយនៅក្នុងដំណើរចម្រើននៃអរិយធម៌ ពេលមនុស្សជឿជាក់ថា ផែនដីសំប៉ែត ឬថាបិសាចធ្វើឱ្យឈឺ ហើយមនុស្សមិនមានសមត្ថភាពបណ្តេញពីរាងកាយតាមរយៈការសូត្រធម៌ ឬមន្តអាគមទេ ហើយក្នុងការយល់សប្តិ ព្រលឹងរបស់យើងបានទស្សនាកន្លែងនានា ដែលយើងមិនដែលមានឱកាសបានមើលឃើញ។ ទាំងអស់នេះ ជាឧទាហរណ៍ទាំងឡាយស្តីពីជំនឿ ដែលយើងធ្លាប់ជឿថាពិតប៉ុន្តែបច្ចុប្បន្ន ត្រូវបដិសេធដោយមនុស្សស្ទើរតែទាំងអស់ដែលរកឃើញវាថាគ្មានមូលដ្ឋានទាល់តែសោះ។

មនុស្សមានវិចារណញ្ញាណនិងបញ្ញាពិតប្រាកដ គឺជាអ្នកដែលមិនពេញចិត្តនឹងជំនឿសាមញ្ញនិងទស្សនៈទាំងឡាយដែលគេបានទទួលពីសង្គមឬពីជំនាន់មុន។ ការផ្អែកលើជំនឿនិងទស្សនៈសាមញ្ញគឺប្រឈមនឹងការធ្វើសេចក្តីសម្រេចចិត្តនិងការផ្លាស់ប្តូរខុសឆ្គង។ គេធ្វើសេចក្តីសម្រេចចិត្ត ប៉ុន្តែមានការភ័យខ្លាចថាគេអាចមានការខុសឆ្គង។

*ដូច្នេះ យើងគួរតែសិក្សាស្វែងយល់ឱ្យបានច្បាស់លាស់ កុំស្រពិចស្រពិលអំពីអ្វីដែលយើងដឹង*[1]*។*

### ក-ឧបសគ្គរាំងការសម្រេចបានពុទ្ធិ

*មាគ៌ាឆ្ពោះទៅកាន់ពុទ្ធិមិនរលូនទេ។ មានឧបសគ្គជាច្រើនដែលត្រូវជម្នះ ពុះពារមុនអ្នកស្រាវជ្រាវរកសច្ចភាពណាមួយឈានដល់គោលដៅរបស់ខ្លួន។ ឧបសគ្គដែលរៀបរាប់ខាងក្រោមអាចធ្វើឱ្យទស្សនវិទូវង្វេងឬទទួលឥទ្ធិពលតាមរយៈការយល់ដឹងនិងទស្សនៈរបស់គេឃ្លាតចេញពីភាពដើម។*

#### ក.១-បុរេនិច្ឆ័យ

*បុរេនិច្ឆ័យ គឺជាទស្សនៈអមិត្តឬ ទស្សនៈមិនសមស្របដែលបង្កើតឡើងគ្មានមូលដ្ឋានត្រឹមត្រូវ ឬជាទស្សនៈមានមុនពុទ្ធិពេញលេញស្តីពីបញ្ហាដែលទទួលបាន។ មនុស្សម្នាក់មានបុរេនិច្ឆ័យមានការចោទប្រកាន់ខាងអារម្មណ៍ ហើយគិតនិងពិចារណាយោងតាមផលប្រយោជន៍របស់ខ្លួន មោទនភាពនិងសេចក្តីរីករាយ។ ទាក់ទង នឹងការផ្លាស់ប្តូរទស្សនៈរបស់ខ្លួនគេត្រៀមហេតុផលឬទឡ្ហីករណ៍ជាស្រេច ដើម្បីការពារពីអ្វីដែលគេជឿជាក់ ទោះជាទស្សនៈឬយោបល់នោះមិនស៊ីជម្រៅក៏ដោយ។ គេមិនងាយជឿលើកស្តុតាងបង្ហាញបែបវិទ្យាសាស្ត្រនៃទស្សនៈមិនត្រឹមត្រូវដែលឥរិយាបទរបស់គេផ្អែកលើនោះឡើយ។ ដូច្នេះជាការងាយទេថាមនុស្សមានបុរេនិច្ឆ័យមិនទំនងជាទាញយកការសន្និដ្ឋានបរានុម័តនិងត្រឹមត្រូវនិងមិនលម្អៀងនោះទេ។*

#### ក.២-ភាពងាយទទួលឥទ្ធិពលពីការឃោសនា

*ការឃោសនាមានគោលបំណងបញ្ចុះបញ្ចូលយ៉ាងទូលំទូលាយ ដោយចេតនានិងមានលក្ខណៈជាប្រព័ន្ធមានន័យថា សំដៅជះឥទ្ធិពលលើឬត្រួតត្រាទស្សនៈអនុវត្តបាន ឆ្លងតាមវិទ្យុ ទូរទស្សន៍ ការផ្សព្វផ្សាយ និងភាពយន្ត។ ដើម្បីឱ្យមានប្រសិទ្ធភាពអ្នកឃោសនាប្រើប្រាស់មធ្យោបាយមួយចំនួនដូចជា៖*

-***ភាពច្រំដែល*** *គឺនៅទីណាដែលគំនិតមួយបានបង្ហាញដដែលៗរហូត គំនិតនោះជ្រួតជ្រាបជាក់ស្តែងក្នុងញាណរបស់យើងដោយកម្លាំងជំរុញស្ថិតស្ថេរ។*

-***ការប្រើប្រាស់ភាសាមួលបង្កាច់ឬបន្តុះបង្អាប់*** *គឺនៅទីណាដែលគំនិតមួយត្រូវបានសង្ខេបមកជាពាក្យមួយដែលនាំមកនូវន័យពិសេស។*

-***ការអះអាងទាក់ទាញមិនគ្រប់គ្រាន់*** *គឺនៅទីណាដែលពាក្យសម្តីមានន័យមិន*

---

[1]Mariano Artigas, Introduction to Philosophy,1984, Sinag Publishers, Inc, Manila.

ច្បាស់លាស់ មានចេតនាប្រើប្រាស់ដើម្បីបង្កើតជាអារម្មណ៍ជាជាងឆ្លើយតបតាមវិចារណញ្ញាណ។

-***កសុតាង*** គឺនៅទីណាដែលមនុស្សគួរឱ្យគោរពបានសន្មតស្គាល់អ្វីដែលល្អបានធ្វើការយល់ព្រមឬក៏មិនរកការឃោសនានិងគាំទ្រគោលបំណងនៃការឃោសនានោះ។

-***មនុស្សមានជីវភាពសាមញ្ញ*** គឺនៅទីណាដែលការឃោសនាទាក់ទងដល់"មនុស្សសាមញ្ញ"ដែលក្នុងវប្បធម៌ខ្លះត្រូវបានគេគោរពចូលចិត្ត។

-***ការរៀបចំជើងព្រួលជាមុន*** គឺនៅកន្លែងណាដែលព័ត៌មានខ្លះត្រូវបានជ្រើសរើសដោយយកចិត្តទុកដាក់ដោយគាំទ្របញ្ហាតែមួយជ្រុងត្រូវបានផ្សព្វផ្សាយដោយចាប់បង្ខំតាមដែលអាច។

-***ទំនោរពេញនិយម*** គឺនៅទីណាដែលមនុស្សភាគច្រើនសន្មតថាត្រឹមត្រូវជានិច្ចហេតុនេះគេគួរតែចូលរួមឬគាំទ្រ។

**ក.៣-ការប្រើប្រាស់អ្នកឯកទេសដោយខ្វះគតិ**

*ការប្រើប្រាស់អ្នកឯកទេសដោយគ្មានការត្រួតពិនិត្យ រិះគន់អំពីអ្វីដែលវាតំណាងឱ្យឬជំរុញគឺគ្មានលក្ខណៈវិទ្យាសាស្ត្រទេ ដូច្នេះវាមិនមែនជាវិធីបែបទស្សនវិជ្ជាឡើយ ក្នុងការសម្រេចឬទទួលបានពុទ្ធិ។ ក្នុងការទទួលស្គាល់អ្នកឯកទេសដោយគ្មានការរិះគន់គេហៅថាឯកទេសនិយម ដែលគេជឿថាពុទ្ធិជានាបានឬមានតម្លៃតាមរយៈអ្នកឯកទេស។ មនុស្សម្នាក់ទទួលស្គាល់អ្នកឯកទេសដោយគ្មានការរិះគន់ គេឈប់មានការខិតខំឯករាជ្យដើម្បីស្វែងរកអ្វីពិតឬមិនពិតទៀតហើយ។*

**ក.៤-កម្លាំងជំរុញនិងទម្លាប់**

*ពេលខ្លះយើងត្រូវបានជំរុញឱ្យមានប្រតិកម្មឆាប់រហ័សចំពោះរំញោចខាងក្រៅដោយគ្មានគំនិតញាណ។ យើងក៏មានបំណងធ្វើអំពើចេញផុតពីទម្លាប់មានន័យថាជាវិធីធម្មតាដែលយើងធ្វើជាពិសេសក្នុងស្ថានភាពដែលធ្លាប់ស្គាល់។ខណៈដែលទម្លាប់មានប្រយោជន៍ក្នុងការយកចិត្តទុកដាក់ភាពដោយឡែកប្រចាំថ្ងៃរបស់ជីវិតវាមិនបានជួយនិងជូនកាលរាំងយើងប្រឈមមុខជាមួយស្ថានភាពថ្មីនិងមិនធ្លាប់ស្គាល់។*

**ក.៥-កំហុសឆ្គងក្នុងការពិចារណា**

*កំហុសឆ្គងមួយគឺការអះអាង បោកបញ្ឆោតមួយ ពីព្រោះថាវាហាក់ដូចជាមានលក្ខណៈជាការសន្និដ្ឋានឬមានតម្លៃប៉ុន្តែជាការពិតវាមិនមានលក្ខណៈសន្និដ្ឋានឬខុសឆ្គងទេ។ មានកំហុសឆ្គងមួយចំនួនដែលជួនកាលគេប្រមូលផ្តុំជាពីរប្រភេទគឺ៖*

*-កំហុសផ្លូវការឬកំហុសខាងភាសាដែលផ្អែកលើរចនាសម្ព័ន្ធឬការអះអាងមិនប្រែប្រួលដូចជាកំហុសទាក់ទងនឹងការសម្តែងជាពាក្យសំដីឬរំលោភលើភាសា។*

ប្រភេទកំហុសគ្គងនេះគឺពេលដែលគេអះអាងថា ភេមសត្វក្នីហើយក្នីមានប្រភពពីព្រះអាទិត្យ ដូច្នេះភេមសត្វមានប្រភពពីព្រះអាទិត្យ។

-កំហុសខាងឯកសារ ដែលជាកំហុសផ្អែកលើខ្លឹមសារនៃការអះអាងដូចជាកំហុសឬកស្តុតាងខ្វះខាតឬការប្រើប្រាស់មនោសញ្ចេតនាជំនួសតក្កវិជ្ជា។ ការធ្វើឱ្យមានភាពជាទូទៅផ្អែកលើកស្តុតាងគ្រប់គ្រាន់ គឺជាឧទាហរណ៍នៃប្រភេទកំហុសនេះ។

**ខ-ប្រភពពុទ្ធិ**

មានប្រភពផ្សេងៗដែលមនុស្សអាចទាញយកពុទ្ធិ។ ប្រភពទាំងនេះមានភាពមិនគ្រប់គ្រាន់ទេប៉ុន្តែមនុស្សបន្តប្រើប្រាស់វាដើម្បីមូលហេតុនេះឬមូលហេតុនោះ។ ទោះបីជាវាមានភាពមិនគ្រប់គ្រាន់ក៏ដោយវាមានតម្លៃនិងមានអ្វីមួយរួមវិភាគទានដល់ការស្វែងរកសច្ចភាពរបស់មនុស្ស។ ភាពខ្វះខាតដោយឡែកៗរបស់ពុទ្ធិអាចរួមតូចពេលគេប្រើប្រាស់វាបំពេញបន្ថែមឱ្យគ្នា។

**ខ.១-ទំនៀមទម្លាប់និងប្រពៃណី**

សូម្បីតែនៅក្នុងសម័យកាលរីកចម្រើននៃវិទ្យាសាស្ត្រនិងបច្ចេកទេសក៏ដោយ ក៏នៅមានមនុស្សជាច្រើនដែលផ្អែកលើទំនៀមទម្លាប់និងប្រពៃណីសម្រាប់ជំនឿឬពុទ្ធិរបស់គេ។ ទំនៀមទម្លាប់គេក៏បានស្គាល់ថាជាទំនៀមទម្លាប់សង្គមតាមប្រពៃណីសំដៅលើវិធីជាទូទៅឬទម្លាប់ជាតួយ៉ាងនិងគំរូខាងអាកប្បកិរិយាដែលគេព្រមនឹងប្រព្រឹត្តច្រំដែលដោយក្រុមមនុស្សឬសហគមន៍មួយ។ជាវិធីបែបប្រពៃណីសាកល្បងនិងដោយងាយស្រួលដែលជះឥទ្ធិពលលើយើងតាមរយៈក្រុមរបស់យើងចាប់តាំងពីយើងកើតមក។ ម្យ៉ាងទៀតប្រពៃណីជាទំនៀមទម្លាប់ដែលរក្សាជាច្រើនជំនាន់ដូច្នេះវាមានឫសគល់ជ្រាលជ្រៅនិងជះឥទ្ធិពលលើគំនិតនិងវិធីរបស់មនុស្ស។ ទំនៀមទម្លាប់និងប្រពៃណីត្រូវបានទទួលបន្តពីជំនាន់មួយទៅជំនាន់មួយដោយការគ្រាប់តាមនិងបង្ហាត់បង្រៀន។ វាមានបំណងគ្រប់គ្រងបុគ្គលឱ្យមានសណ្តាប់ធ្នាប់ព្រោះមានការដាក់ទណ្ឌកម្មសង្គមដូចជាការមិនយល់ព្រម ការចំអកឬការអៀនខ្មាសចំពោះអ្នកមិនអនុលោមតាមទំនៀមទម្លាប់និងប្រពៃណី។

ទន្ទឹមនឹងទំនៀមទម្លាប់និងប្រពៃណីផ្តល់ឱ្យសម្រាប់តម្រូវការមួយចំនួនសម្រាប់មនុស្សវាមានលក្ខណៈពិសេសមួយចំនួនដែលគួរតែព្រមានយើងមិនឱ្យផ្អែកលើវាប្រសិនបើមិនដាក់វាជាដំបូងឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យរិះគន់ដោយយកចិត្តទុកដាក់ទេនោះ[2]។

**ខ.២-អ្នកឯកទេស**

[2] Mariano Artigas, Introduction to Philosophy,Ibid.

ភស្តុតាងតាមរយៈបុគ្គលដែលគេចាត់ទុកជាអ្នកឯកទេសក្នុងវិស័យឯកជនរបស់ខ្លួននិងហេតុការណ៍ផ្តើមពីវិស័យពិសេសនៃវិទ្យាសាស្ត្រនានាជាប្រភពច្រើនបំផុតនៃប្រទេសរបស់យើង។ យើងមានអ្វីមួយពីអតីតកាលរបស់យើងពីអ្នកប្រវត្តិសាស្ត្រយើងដឹងពីអាកាសធាតុប្រចាំថ្ងៃពីពួកឧត្តុនិយម ដឹងពីទំនាក់នាក់ទំនងរវាងការផ្តល់និងតម្រូវការពីរអ្នកសេដ្ឋកិច្ចនិងផលប៉ះពាល់នៃកំណើនប្រជាជនលើបរិស្ថាននិងសុខមាលភាពសង្គម ពីអ្នកបរិស្ថាន និងពីអ្នកវិទ្យាសាស្ត្រសង្គមនានា។ នៅពេលដែលអ្នកឯកទេសផ្តល់ឱ្យយើងនូវពុទ្ធិដោយយើងមិនបានត្រួតពិនិត្យនូវស្នាដៃដោយហេតុដែលពួកគេទទួលបាននៅក្នុងដំណើរយើងប្រែជាចំណុចរបស់ពួកគេ។ អ្វីដែលជាការប្រុយប្រថាននឹងមានគ្រោះថ្នាក់ និងការផ្អែកលើអ្នកឯកទេសដោយគ្មានការឆ្លុះបញ្ចាំងពីសច្ចភាពឬកំហុសឆ្គងនៃការសន្និដ្ឋានរបស់ពួកគេដែលយើងទទួលស្គាល់និងប្រើប្រាស់រួចមកហើយ។ គ្រោះថ្នាក់លើការផ្អែកលើអ្នកឯកទេសទាំងស្រុងបានបង្ហាញនូវការពិភាក្សាពីមុនរួចមកហើយ។ វាមានអត្ថប្រយោជន៍ចំពោះយើងដែលត្រូវចងចាំវា។

## ខ.៣-ឥន្ទ្រិយពុទ្ធិ

មានអ្នកដែលមិនចង់មានបញ្ហា និងបទពិសោធន៍តឹងតែង និងពិចារណាដើម្បីក្តាប់បានពុទ្ធិ ឡើយ។ ពួកគេជ្រើសរើសមាគ៌ាឆាប់រហ័ស និងងាយស្រួលឆ្ងងតាមអំណាចប្រត្យក្សារម្មណ៍ឬការពិនិត្យសង្កេតដោយប្រើប្រាស់ភ្នែក សំឡេង ក្លិន ការប៉ះពាល់ និងរសជាតិ។ អ្វីដែលឥន្ទ្រីយ៍ទទួលបានពីបរិស្ថានផ្តល់មូលដ្ឋាន ក្នុងការបង្កើតគំនិតអំពីវត្ថុមួយចំនួនឬទំនាក់ទំនងយល់ដឹង។ ជាសរុបអ្វីដែលយើងដឹងត្រូវផ្តល់ដោយឥន្ទ្រីយ៍របស់យើង។ ទស្សនៈនេះដែលសង្កត់ធ្ងន់លើអំណាចរបស់ឥន្ទ្រីយ៍ ក្នុងការផ្តល់ពុទ្ធិដែលគេហៅថាពិសោធន៍និយម។

## ខ.៤-វិចារណញ្ញាណ

ផ្ទុយពីពិសោធន៍និយមវិចារណញ្ញាណនិយម គឺជាទស្សនៈដែលថាពុទ្ធិទទួលបានឆ្លងតាមការពិចារណាជាជាងឆ្លងតាមបទពិសោធន៍ឥន្ទ្រីយ៍។ ពួកវិចារណញ្ញាណនិយមអះអាងថា គំនិតមានអំណាចស្គាល់សច្ចភាពដោយខ្លួនវាពោល គឺដោយប្រើប្រាស់វិធីពិចារណាមួយចំនួន។ វិធីរបស់ពួកវិចារណញ្ញាណនិយម អាចធ្វើឱ្យមនុស្សស្គាប់បានពុទ្ធិខ្ពស់ ជាពុទ្ធិដែលស្ថិតក្នុង កាលៈទេសៈណាមួយមិនអាចខុសឆ្គងពួកគេអះអាងខ្លាំងក្លាថា បទពិសោធន៍ឥន្ទ្រីយ៍ទោះបីជាយ៉ាងណាក្តី មិនអាចផ្តល់ឱ្យមនុស្សនូវពុទ្ធិមានតម្លៃដាច់ខាតទេ។ មនុស្សត្រូវតែវិលទៅរកសតិបញ្ញារបស់ខ្លួនដើម្បីសម្រេចបានពុទ្ធិ។ មានទម្រង់វិចារណញ្ញាណនិយមសំខាន់ៗ ២ ។ ទម្រង់

វិចារណញ្ញាណនិយមមិនសូវហួសហេតុ បង្រៀនថាគំនិតអាចយល់ដឹងច្បាស់នូវសច្ចភាពនានារបស់ចក្រវាលដែលឥន្ទ្រិយ៍តែងតែឯងរបស់យើង មិនអាចផ្តល់ឱ្យយើងបានឡើយ។ ប៉ុន្តែវាទទួលស្គាល់ការរួមចំណែករបស់ឥន្ទ្រិយ៍ដូចជាគំហើញសំឡេងក្លិន ការប៉ះពាល់និងរសជាតិក្នុងការទទួលបានពុទ្ធិ។ ឥន្ទ្រិយ៍យារម្មណ៍និងបទពិសោធន៍របស់យើងត្រូវរៀបចំឡើងដោយគំនិតរបស់យើងទូទៅជាប្រព័ន្ធមួយមានន័យមុនវាប្រែក្លាយជាពុទ្ធិ ដែលស្ថិតក្នុងទម្រង់បញ្ញត្តិគោលការណ៍ និងច្បាប់។

ទម្រង់វិចារណញ្ញាណនិយមហួសហេតុ មិនចាត់ទុកការរួមវិភាគទាន របស់បទពិសោធន៍ឥន្ទ្រិយ៍ ក្នុងការទទួលបានពុទ្ធិទេ។ វាអាងថាមនុស្សអាចឈានទៅដល់ពុទ្ធិដែលមិនអាចសង្ស័យបានដោយគ្មានជំនួយពីបទពិសោធន៍ឥន្ទ្រិយ៍។ ទម្រង់វិចារណញ្ញាណនិយមហួស ហេតុនេះអាចជំរុញយើងខ្លះដែលឱ្យជំនួសវិចារអនុមានញែករបស់យើងដោយការពិនិត្យសង្កេតពិសោធន៍។ ទង្វើដូច្នេះយើងអាចឈានទៅទទួលស្គាល់ប្រព័ន្ធខ្លះ ដែលមានភាពរឹងមាំខាងឡូស៊ិក ប៉ុន្តែទាក់ទងតិចតួចទៅនឹងពិភពលោកដែលយើងរស់នៅ។

**ខ.៥-អព្ភន្តរញ្ញាណ**

ប្រភពពុទ្ធិមួយ ដែលអាចគឺអព្ភន្តរញ្ញាណ ដែលមានន័យខុសគ្នា ចំពោះមនុស្សផ្សេងគ្នា។ មនុស្សខ្លះទាក់ទងជាមួយអារម្មណ៍ខុសគ្នា ចំពោះមនុស្សផ្សេងគ្នា។ មនុស្សខ្លះទាក់ទងជាមួយអារម្មណ៍ ដែលយល់ឆាប់រហ័សនិងធ្វើឱ្យគេជាក់ច្បាស់អំពីអ្វីមួយ។ អ្នកខ្លះទៀតចិត្តទុកវាជាគំនិតសកម្មដែលអាចធ្វើអោយមនុស្សម្នាក់យល់ដឹងហួសពីអ្វី ដែលឡូស៊ិកផ្តល់ឱ្យ។ លោក Carl Jung ជាពេទ្យវិកលចរិតល្បីល្បាញនិងត្រចះត្រចង់កំណត់នៃអព្ភន្តរញ្ញាណថា "ការគិតដែលបានធ្វើលើកម្រិតអញ្ញាណ" ឯលោក Henri Bergson ជាទស្សនវិទូបារាំងគួរឱ្យកត់សម្គាល់ យល់ថាអព្ភន្តរញ្ញាណថាជាដំណើរសកម្មរបស់គំនិត ដែលជ្រួតជ្រាបព្រំដែនស្មារតិករបស់ឡូហ្សិក។

ពុទ្ធិដែលបានផ្តើមពីអព្ភន្តរញ្ញាណ មិនមែនជាផលិតផលនៃការពិចារណារបស់ញាណហើយក៏មិនមែនជាប្រត្យក្សារម្មណ៍ឥន្ទ្រិយ៍ដោយផ្ទាល់នោះដែរ។ មនុស្សម្នាក់អាចភ្ញាក់នៅកណ្តាលអធ្រាត្រជាមួយដំណោះស្រាយបញ្ហារបស់ខ្លួន ដែលបានធ្វើឱ្យគេស្ទើរស្ទាក់ជាច្រើនខែ។

**គ-ធម្មជាតិនៃពុទ្ធិ**

ក្នុងចំណោមទ្រឹស្តីមួយចំនួនអំពីធម្មជាតិនៃពុទ្ធិ មានទ្រឹស្តីពីរដែលលេចធ្លោ។ ទ្រឹស្តីទាំងពីរនេះមានទ្រឹស្តីអត្តនោម័តនិងទ្រឹស្តីបរានុម័ត។

**គ.១-ទ្រឹស្តីអត្តនោម័ត**

អត្តនោម័តនិយមគឺជាទ្រឹស្តីមួយដែលអះអាងថាពុទ្ធិរបស់យើងអំពីវត្ថុគុណភាពរបស់វា និងទំនាក់ទំនង ដែលមានរវាងវត្ថុ និងអ្នកយល់ដឹងរបស់វាមានលក្ខណៈជាបង្គួរធៀបនិងគំនិតធៀបនឹងស្ថានភាពសរីរាង្គរបស់យើងដូចជាកាលៈទេសៈព័ទ្ធជុំវិញវត្ថុនោះ។ ព្រោះតែសភាពគំនិតនិងស្ថានភាពសរីរាង្គឥន្ទ្រីយ៍របស់យើងដូចជា គំហើញក្លិន សំឡេង ការប៉ះពាល់ និងរសជាតិខុសគ្នាម៉្លោះហើយទស្សនៈរបស់យើងអំពីវត្ថុ និងមានការខុសគ្នាពីមនុស្សម្នាក់ទៅមនុស្ស ម្នាក់។ ជាការពិតមនុស្សមានម្នាក់ទទួលរងជំងឺគ្រុនក្តៅ និងមានប្រត្យក្សារម្មណ៍ ខុសគ្នារវាងរូបរាង និងពណ៌របស់វត្ថុជាក់ស្តែងមួយធៀបនឹងមនុស្សម្នាក់ស្ថិតក្នុងសភាពធម្មតា។ កត្តាផ្សេងទៀតស្ថិតនៅខាងក្រៅមនុស្សដូចជាពន្លឺនិងចម្ងាយក៏ជះឥទ្ធិពលលើ ប្រត្យក្សារម្មណ៍ ផ្ទាល់នៃវត្ថុ។

សម្រាយបំភ្លឺវត្ថុដដែល និងមានការយល់ខុសគ្នាពីមនុស្សម្នាក់ក្រោមពន្លឺព្រះអាទិត្យចែងចាំងនិងពីមនុស្សម្នាក់ទៀតដែលស្ថិតនៅក្នុងបន្ទប់ងងឹត។ ហើយកើតឡើងដូចគ្នានេះដែរប្រសិនបើមនុស្សម្នាក់មើលឃើញវត្ថុមួយចម្ងាយមួយម៉ែត្រ តែមនុស្សម្នាក់ទៀតមើលឃើញវត្ថុដដែលនោះចម្ងាយមួយពាន់ម៉ែត្រ។

ទ្រឹស្តីពុទ្ធិអត្តនោម័តិនេះ ចាប់ផ្តើមពីសម័យសូក្រាត ពេលពួកសូហ្វីស ជាទស្សនវិទូចែងចាំង និងទស្សនវិទូដំបូងគេ ដែលឱ្យតម្លៃការអប់រំ ដោយបង្រៀនថា មនុស្សគឺជារង្វាស់នៃអ្វីទាំងអស់។ Protagoras ជាពួកសូហ្វីសដ៏ល្បីល្បាញ បំផុតអះអាងថាពុទ្ធិមានលក្ខណៈជាបង្គួរពោលគឺវាគ្រាន់តែជាប្រភពនៃយោបល់ប៉ុណ្ណោះ។ ជាអាទិ៍យោបល់ដោយឡែករបស់មនុស្សម្នាក់ម្នាក់គឺពិតដោយមិនគិតថាវាស្រប ឬមិនស្របជាមួយយោបល់របស់អ្នកដទៃឡើយ។ អ្វីដែលពិតចំពោះអ្នកពិតចំពោះអ្នកហើយអ្វីពិតចំពោះខ្ញុំគឺពិតចំពោះខ្ញុំ។ ប្រសិនបើដូច្នេះមែន ហេតុនេះតថភាពត្រូវបង្កើតដោយមនុស្សព្រោះបទពិសោធន៍ឥន្ទ្រីយ៍របស់គេ គឺជាការឆ្លុះបញ្ចាំងដោយផ្ទាល់នៃពិភពលោកខាងក្រៅ។ ដូច្នេះតថភាពមិនមែនមួយទេប៉ុន្តែច្រើនស្មើនឹងចំនួនមនុស្សដែលយល់ដឹងនិងឆ្លុះបញ្ចាំងពីពិភពខាងក្រៅ។

ការរិះគន់ មួយប្រឆាំងនិងអត្តនោមតិនិយមគឺថាសរីរាង្គឥន្ទ្រីយ៍យ៍របស់យើងដែលផ្តល់ទិន្នន័យដើមសម្រាប់គំនិតរបស់យើងដើម្បីវិភាគនិងបកស្រាយមិនល្អឥតខ្ចោះទេ។ន័យរបស់វាធ្វើឱ្យយើងអន់ឬបោកបញ្ឆោតយើង។ ក្រៅពីនេះ ប្រត្យក្សារម្មណ៍ឥន្ទ្រីយ៍ របស់យើងមិនអាច ជ្រៀតចូលផ្នែកខាងក្នុងរបស់វត្ថុបានឡើយ។ដូច្នេះពុទ្ធិរបស់យើងមានលក្ខណៈសើសើនឹងមិនពេញលេញដូច្នេះហើយគ្មាននរណាអាចអះអាង

ថាមានពុទ្ធិដាច់ខាតទេព្រោះអ្វីដែលគេដឹងមានលក្ខណៈបង្គួរតឹកម្រិតដោយបទពិសោធន៍របស់ខ្លួន។

**គ.២-ទ្រឹស្តីបរានុម័ត**

ផ្ទុយនឹងទ្រឹស្តីអត្តនោម័តពីធម្មជាតិនៃពុទ្ធិគឺទ្រឹស្តីបរានុម័តនិយម។ ទ្រឹស្តីនេះអះអាងថាមានពិភពលោកមួយនៅខាងក្រៅខ្លួនយើង ដែលអត្ថិភាពពោលគឺស្ថិតនៅខាងក្រៅឯណោះដោយមិនគិតពីនរណាម្នាក់គិតពីវា ឬយល់ដឹងពីវាឬអត់ទេ។ វាមានគុណភាពផ្ទាល់ខ្លួនវាជាគុណភាពដែលមិនកំណត់ដោយមុខងាររបស់សរីរាង្គឥន្ទ្រីយ៍ទេ ហើយក៏មិនមែនជាស្ថានភាពគំនិត និងសមត្ថភាពវិភាគរបស់អ្នកយល់ដឹងដែរ។ ប្រការនេះជឿជាក់ដោយពួកតថនិយមកញ្ចោត ដែលអះអាងថាមានវត្ថុរូបខាងក្រៅឬហួសពីខ្លួនយើងដែលឆ្លងតាមគុណភាពទីមួយរបស់វាធ្វើឱ្យគេស្គាល់តាមរយៈអ្នកយល់ដឹង។ ទ្រឹស្តីចម្លងរបស់លោក John Locke ឬ"តថនិយមតំណាង" មានការ សន្មត់ដូចគ្នា។ លោកអះអាងថា៖

មានពិភពពិត និងពិភពខាងក្រៅដែលរួមមានគុណភាពរូបធាតុចលនា ដែលទស្សនៈរបស់យើងអំពីគុណភាពរូបធាតុគ្រាន់តែតំណាងឱ្យគុណភាពទាំងនេះ ហើយជាការពិតគ្រាន់តែតំណាងឱ្យគុណភាពទីមួយនេះ ដូចជាចលនា និងរូបភាពឯគុណភាពទី២ ដូចជាពណ៌និង សំឡេងឥទ្ធិភាពនៅតែក្នុងគំនិតប្រភពបរានុម័តរបស់វាជាទម្រង់រូបធាតុចលនាមួយចំនួន។

កត្តាតាំងពីរអាចលើកឡើងគាំទ្រទ្រឹស្តីបរានុម័តនិយមនៃធម្មជាតិរបស់ពុទ្ធិ។ ទី១ បទពិសោធន៍ឥន្ទ្រិយរបស់យើង ក៏ដូចជាការឆ្លុះបញ្ចាំងរបស់យើងសម្គាល់ដោយការយល់ដឹងរបស់យើងអំពីអ្វីមួយនៅខាងក្រៅយើង ឬហួសពីយើង។ ជួនកាលយើងយល់ថាយើងមានការយល់ដឹង។ អ្វីមួយនៅខាងក្រៅខ្លួនយើង មិនចំណុះលើគំនិតរបស់យើងដើម្បីអធិភាពឡើយ។ ទី២ អន្តរកម្មហេតុផលប្រព្រឹត្តទៅមិនមែនតែនៅក្នុងខ្លួនយើងទេ ប៉ុន្តែថែមទាំងហួសពីបទពិសោធន៍របស់យើងទៀតផង។បទពិសោធន៍របស់យើងក៏ត្រូវតែមានមូលហេតុដូចជាការឈឺចាប់ពេលប៉ះទង្គិចនឹងថ្មជាដើម។

**ឃ-ពួកនៃពុទ្ធិ**

ពុទ្ធិសំដៅយកចំណេះដឹងទូទៅរបស់មនុស្ស ទោះក្នុងខ្លួនយើងក្តី ខ្លួនអ្នកដទៃក្តី ឬនៅលើធម្មជាតិក្រៅខ្លួនយើងក្ដី។ ប៉ុន្តែ ពុទ្ធិពុំមែនត្រឹមតែជាចំណេះដឹងស្រពេចស្រពិលឬមានប្រព័ន្ធច្បាស់លាស់ដែលមនុស្សបង្កើតប៉ុណ្ណោះទេ តែពុទ្ធិជារបៀបដែលញុំាងឱ្យចំណេះទាំងនោះកើតឡើងថែទៀតផង។ ពួកនៃពុទ្ធិចែកជាបីគឺ ពុទ្ធិសាមញ្ញ ពុទ្ធិស្បង់ និងពុទ្ធិទស្សនវិជ្ជា។

**ឃ.១-ពុទ្ធិសាមញ្ញ**

គឺជាពុទ្ធិធម្មតាដែលអ្នកផង មានគ្រប់ៗគ្នា។គឺពុទ្ធិដែលកើតពីការដែលឮតៗគ្នាស្រពេចស្រពិល មិនច្បាស់លាស់ ឬដែលកើតពីគំហើញវត្ថុនានាដោយផ្ទាល់ ឬពីកិច្ចសន្ទនាជាមួយអ្នកដទៃ ពីព័ត៌មានកាសែត កុន ល្ខោន វិទ្យុៗល។ ចំណេះដឹងដោយការផ្សាយទាំងនេះ យើងឆាប់ជឿ ឆាប់ទទួលយកណាស់ ព្រោះវាឆ្លើយតបទៅនឹងសេចក្តីត្រូវការក្នុងការរស់នៅរបស់ យើង។ ជួនកាលយើងជឿដោយមិនបាច់គិតផងក៏សឹងមាន ហើយពុទ្ធិដែលចេញពីជំនឿនេះ តែងតែមានខុសឬច្រលំឬក៏ល្មៀង ញ យៗណាស់។ ពុទ្ធិសាមញ្ញមានលក្ខណៈដូចតទៅនេះ : គ្មានលំដាប់ គ្មានទំនាក់ទនងជិតស្និទ្ធ និងគ្មានការត្រួតពិនិត្យម៉ត់ចត់។ ពុទ្ធិសាមញ្ញច្រើនច្រលំ "ភាគច្រើន" និង " ទូទៅ"។ ឧទាហរណ៍ ថ្មលិចក្នុងទឹក ផ្សែងហុយឡើងលើ ឈើឆេះ...។ គេឥតបានគិតដល់ទេថា ថ្មខ្លះឥតលិចក្នុងទឹក ផ្សែងខ្លះឥតហុយឡើងលើ ឬក៏ឈើខ្លះមិនឆេះ ថ្វីត្បិតតែមានភាគតិចក៏ដោយ។

ប៉ុន្តែ ថ្វីបើមានលក្ខណៈបែបនេះ មនុស្សយើងតែងតែត្រូវការពុទ្ធិសាមញ្ញជាចាំបាច់ក្នុងការរស់នៅ។ ដូចជាដើម្បីទិញបាយបរិភោគ អ្នកជាក់ស៊ីក្លូ ត្រូវតែដឹងជាចាំបាច់នូវកន្លែងលក់បាយនិងម្ហូបអាហារ ព្រមទាំងពេលវេលាបើកលក់ ដោយមិនបាច់ពិចារណាវែកញែករកហេតុផលតាមរបៀបស្យង់ឬតាមបែបទស្សនវិជ្ជាទេ ប្រសិនបើគេមិនចង់អត់បាយបរិភោគ។

**ឃ.២-ពុទ្ធិស្យង់**

ពុទ្ធិនេះមានលក្ខណៈដូចតទៅៈ

-ភាពជាក់លាក់ ឧទាហរណ៍ៈ ខ្លួនខ្ញុំមានកំដៅ៤០ អង្សា។

-ភាពទូទៅ មិនរើសទីកន្លែងឬពេល

-ឈរជានិច្ចលើវិចារណញ្ញាណ ហើយថែមទាំងមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធក្នុងប្រព័ន្ធមួយៗទៀតផង។

ពុទ្ធិស្យង់កើតពីការត្រិះរិះពិចារណាយ៉ាងល្អិតល្អន់នៃបញ្ហាហើយត្រួតពិនិត្យយ៉ាងម៉ត់ចត់វិចារសង់របៀបគណិតវិទ្យាឬដោយពិសោធន៍បញ្ជាក់សម្មតិកម្មនៃស្យង់ពិសោធផង។ ពុទ្ធិបែបនេះល្បងគាស់កកាយយកទំនាក់ទំនងអរូបីដែលកប់នៅក្នុងបាតុភូតមកជំនួសស្រមោលតថភាពដែលគ្រាន់តែបន្ទំឬបញ្ឆោតឥន្ទ្រិយរបស់យើងប៉ុណ្ណោះ។ ជំនួសការប្រើប្រាស់សាំញ៉ាំមិនច្បាស់លាស់ ស្យង់ត្រូវការជាចាំបាច់នូវភាពជាក់លាក់ដោយប្រើចំនួន ទោះក្នុងរង្វាស់ក្តីក្នុងទំនាក់ទំនងស្ថិតិក្តីឬក្នុងច្បាប់ពីជគណិតក្តី។

**ឃ.៣-ពុទ្ធិទស្សនវិជ្ជា**

ពុទ្ធិទស្សនវិជ្ជាមានភាពទូទៅជ្រៅល្អិតល្អន់ជាងពុទ្ធិសាមញ្ញឬស្យង់ ព្រោះពុទ្ធិនេះកើតពីការត្រិះរិះពិចារណាលើគ្រប់

បញ្ហាលើបញ្ហាធម្មតាក៏ដូចជាលើបញ្ហាស្បង់ដែរ។ ដោយពិតទៅ ទស្សនវិជ្ជាគឺជាការពិចារណារិះគន់លើជីវិត លើភាវៈទាំងឡាយ និងលើពិភពលោក[3]។

**ខ-តេស្តនៃសច្ចភាព**

នៅក្នុងការពិភាក្សាមុននេះគេបានគូសបញ្ជាក់ថា មានជំនឿជាច្រើនដែលគេជាថាពិតក្រោយមកគេបង្ហាញថាមិនពិត។ នេះមិនគ្រាន់តែជាជំនឿសាមញ្ញប្រចាំថ្ងៃនោះទេ ប៉ុន្តែថែមទាំងជាជំនឿរបស់អ្នកវិទ្យាសាស្ត្រ និងទស្សនវិទូដែលគេស្គាល់ថាមានលក្ខណៈជាប្រព័ន្ធ និងរិះគន់ក្នុងវិធីឈានដល់សច្ចភាពរបស់ខ្លួន។ ចំពោះអ្នកវិទ្យាសាស្ត្រ ទស្សនវិទូ និងបុគ្គលគិតពិចារណាផ្សេងទៀត សច្ចភាពមានសារៈសំខាន់ បំផុត។ យើងត្រូវយល់ច្បាស់ពីអ្វីដែលយើងដឹងពីព្រោះអំពើនិងវិធីពិនិត្យបញ្ហារបស់យើងជះឥទ្ធិពលមកលើយើងដោយពុទ្ធិ។

ទស្សនវិទូ និងអ្នកផ្សេងទៀតបានប្រើប្រាស់តេស្តសច្ចភាពជាច្រើន ក្នុងការកំណត់សច្ចភាពនៃអ្វីដែលពួកគេដឹង។ មិនមែនតេស្តទាំងអស់គ្រប់គ្រាន់នោះទេ ក្នុងការបែងចែកសច្ចភាពពីកំហុស ប៉ុន្តែភាពគ្រប់គ្រាន់ជានិច្ចកាលមិនធានាថា ជាតេស្តសច្ចភាពដែលមានការទទួលស្គាល់ទូលំទូលាយ ទោះបីជាភាពមិនគ្រប់គ្រាន់ខ្លះមានលក្ខណៈជាបន្ទូរក៏ដោយ។ ការយល់ដឹងតម្លៃជាបន្ទូររបស់តេស្តនីមួយៗនឹងជួយយើងក្នុងការជ្រើសរើសអំពីតេស្តអ្វីខ្លះ ដែលយើងជឿជាក់និងប្រើប្រាស់ក្នុងការវិនិច្ឆ័យសច្ចភាពឬកំហុសនៃជំនឿរបស់យើង។

មានតេស្តជាច្រើនដែលត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយដោយសាធារណជនហើយដែលត្រូវបានគេលើកយកមកបង្ហាញ។ តេស្តទាំងអស់នេះរួមមាន ប្រត្យក្សារម្មណ៍ ឥន្ទ្រិយារម្មណ៍ សភាវគតិ អព្ភន្តរញាណ ទំនៀមទម្លាប់ប្រពៃណី ភាគច្រើន ការយល់ព្រមទូទៅ អ្នកឯកទេស ភាពសមស្រប ប្រតិបត្តិនិយម ភាពមិនផ្លាស់ប្តូរនិងទំនាក់ទំនង។

**ច-សារៈសំខាន់នៃការសិក្សាពុទ្ធិវិជ្ជា**

**ច.១-ទស្សនៈជាយុទ្ធសាស្ត្រ**

ពុទ្ធិវិជ្ជាមានសារៈសំខាន់ណាស់ ពីព្រោះវាសិក្សាអំពីធម្មជាតិ គោលបំណង និងការបង្ហាញភាពត្រឹមត្រូវនៃពុទ្ធិ។ ពុទ្ធិមានសារៈសំខាន់ជាយុទ្ធសាស្ត្រមួយគឺការនិយាយទាក់ទងនឹងរបៀបដែលយើងអាចគ្រប់គ្រងអំណាច(សមត្ថភាព)ដែលមានដើម្បីសម្រេចបានគោលដៅមួយជាក់លាក់។ ដូចលោក Francis Bacon (១៥៦១-១៦២៦) បាននិយាយថាពុទ្ធិ គឺជាអំណាច ពុទ្ធិមាន

[3] វិទ្យាស្ថានជាតិខេមរយានកម្ម៖ *ទស្សនវិជ្ជា ថ្នាក់បញ្ចប់* ភ្នំពេញ ១៩៧៤

អំណាចឬកម្លាំងផ្លាស់ប្តូរវត្ថុទាំងឡាយ។ សព្វថ្ងៃយើងរស់នៅក្នុងសកលពិភពមួយដែលត្រួតត្រាដោយអំណាចពុទ្ធិលើមូលដ្ឋាននៃបច្ចេកវិទ្យា។ បញ្ហាជាមូលដ្ឋាននៃពុទ្ធិទាក់ទងជាមួយនឹងសារៈសំខាន់ជាយុទ្ធសាស្ត្រគឺបញ្ហាទំនាក់ទំនងរវាងអំណាចក្នុងទម្រង់ជាច្រើននិងពុទ្ធិនៃអ្នកដែលមានអំណាចទាំងខាងនយោបាយសេដ្ឋកិច្ច និងវប្បធម៌។ អ្នកមានអំណាចបានក្លាយជាអ្នកកំណត់ថាពុទ្ធិមួយណាមានសារៈសំខាន់ ពុទ្ធិមួយណាមិនសំខាន់ ពុទ្ធិមួយណាត្រូវបានគេចាត់ទុកថាពិត ពុទ្ធិមួយណាមិនពិត។

**ច.២-ទស្សនៈវប្បធម៌**

សារៈសំខាន់ទី២នៃការសិក្សាពុទ្ធិជ្ញាគឺដោយសារតែអត្ថន័យវប្បធម៌។ ពុទ្ធិគឺជាផ្នែកមួយនៃវប្បធម៌។ ពិតណាស់វប្បធម៌មានសមាសធាតុផ្សេងៗក្រៅពីពុទ្ធិដូចជាប្រព័ន្ធអង្គការសង្គមរបស់វា សិល្បៈ ប្រព័ន្ធភាសានិងនិមិត្តរូបរបស់វា ប្រព័ន្ធសាសនា។ល។ ប៉ុន្តែនៅក្នុងសមាសធាតុផ្សេងទាំងនោះពុទ្ធិមានមុខងារមួយយ៉ាងសំខាន់។ ដោយសារតែពុទ្ធិរបស់ខ្លួនមនុស្សជាតិមានលទ្ធភាពបណ្តុះបណ្តាល និងប្រើប្រាស់បរិស្ថាន ធម្មជាតិ និងសង្គមរបស់ខ្លួន។ មនុស្សអាចយល់ដឹងបញ្ហាសំខាន់ៗ ចេះវិភាគនិងបកស្រាយបទពិសោធន៍របស់ខ្លួននិងចេះវិនិច្ឆ័យព្រឹត្តិការណ៍ដែលកំពុងប្រព្រឹត្តទៅ ហើយទីបំផុតចេះធ្វើសេចក្តីសម្រេចចិត្តបានត្រឹមត្រូវ។ ដោយសារពុទ្ធិរបស់ខ្លួន មនុស្សជាតិប្រែក្លាយធម្មជាតិឱ្យទៅជាវប្បធម៌។ គេអាចនិយាយថា ពុទ្ធិជាគោលការណ៍ណែនាំនិងផ្លាស់ប្តូរវប្បធម៌។ ការបដិវត្តន៍ពុទ្ធិបាននាំមកនិងបន្តនាំមកនូវចលនាសកម្មនិងអភិវឌ្ឍវប្បធម៌។

**ច.៣-ទស្សនៈអប់រំ**

មូលហេតុទី៣អំពីសារៈសំខាន់នៃការសិក្សាពុទ្ធិវិជ្ជា គឺដោយសារតែអត្ថន័យរបស់វាការអប់រំ ជាការប៉ុនប៉ងយល់ដឹងមួយដើម្បីជួយនិស្សិតអភិវឌ្ឍទស្សនៈអំពីជីវិតរបស់គេ អភិវឌ្ឍឥរិយាបថចំពោះជីវិតនិងជំនាញចាំបាច់ដើម្បីជីវិតរស់នៅដែលទាមទារការយល់ដឹងច្បាស់លាស់ ជាប្រចាំនូវទាំងឡាយទាក់ទងនឹងដំណើរនៃការបង្រៀននិងការរៀនក្នុងប្រព័ន្ធអប់រំទាំងមូលទាក់ទងនឹងការផ្ទេរពុទ្ធិ ជំនាញ និងតម្លៃការផ្ទេរពុទ្ធិ ពីគ្រូដល់សិស្ស និងការស្វែងរកពុទ្ធិរបស់និស្សិត ជាធាតុដ៏សំខាន់ក្នុងការអប់រំ។ សារៈសំខាន់នៃពុទ្ធិចំពោះការអប់រំ ក៏ត្រូវបានអះអាងដោយប្រការដែលថា ពុទ្ធិគឺជាកត្តាយុទ្ធសាស្ត្រមួយនឹងកំណត់ចំពោះការអភិវឌ្ឍនិងអរិយធម៌របស់មនុស្ស។

ការអប់រំជាការខិតខំដោយភ្ញាក់រលឹកមួយដើម្បីជួយនិស្សិតឱ្យអភិវឌ្ឍភាពប៉ិនប្រសប់និងសក្តានុពលរបស់គេពីព្រោះមនុស្សជាតិមិនកម្រិតត្រឹមការអភិវឌ្ឍសមត្ថភាពបញ្ញារបស់ខ្លួននោះទេ។ ការអប់រំ

ក៏គួរតែអភិវឌ្ឍស្មារតី សីលធម៌ អារម្មណ៍ និងអភិវឌ្ឍភាពរីកចម្រើនរបស់សង្គម។ ប៉ុន្តែក្នុងគ្រប់ទិដ្ឋភាពទាំងអស់ ពុទ្ធិមានតួនាទីសំខាន់ជាងនេះទៅទៀត។ ពុទ្ធិក្នុងករណីនេះមិនគ្រាន់តែពុទ្ធិអំពីពិភពខាងក្រៅប៉ុណ្ណោះទេប៉ុន្តែថែមទាំងជាពុទ្ធិអំពីខ្លួនឯងក្នុងឋានៈជាមនុស្សជាតិ។

## ២-អស្តិរូបវិជ្ជា

ចក្រវាលបានជុំរុញឱ្យមនុស្សចង់ដឹងអំពីប្រភពរបស់វា។ មនុស្សបានព្យាយាមជាបន្តបន្ទាប់ក្នុងការស្វែងរកការពន្យល់ពីចក្រវាល ជាការពន្យល់មួយដែលអាចចាត់ទុកថាមានកម្រិតខ្ពស់ និងសកលឬគ្របដណ្តប់ទាំងអស់។ ក្នុងការខិតខំនេះនិកាយគំនិតផ្សេងៗកើតឡើងទូទាំងដំណើរប្រវត្តិសាស្ត្រហើយនិកាយនីមួយៗធ្វើការពន្យល់តាមគំនិតផ្ទាល់ខ្លួនរបស់គេ។ និកាយខ្លះ ស្វែងរកគ្រឹះដ៏សំខាន់បំផុតនៃតថភាពជាមួយធាតុពិសេសមួយនៅក្នុងតថភាពនោះ។ និកាយខ្លះទៀត អះអាងថា មានអត្ថិភាពតែមួយគត់នៃចក្រវាល ឯអ្នកគិតមួយចំនួនទៀតចាត់ទុកថា ចក្រវាលមានប្រភពពីរឬច្រើនជាងនេះ។

បញ្ហាទាំងនេះមានឥទ្ធិពលជ្រាលជ្រៅលើអត្ថិភាពរបស់មនុស្ស។ វាពិតជាធ្វើឱ្យមនុស្សមានការខុសគ្នាចំពោះមនុស្សដែលដែលជឿថា អ្វីៗដែលកើតចេញពីរូបធាតុនឹងវិលទៅរករូបធាតុវិញឬជឿថា មនុស្សត្រូវបានបង្កើតឡើងដោយអាទិទេព។ ជាដំបូង ការសិក្សាបញ្ហាទាំងនេះបង្កើតជាអង្គពុទ្ធិតែមួយគត់ដែលមិនអាចបែកចែកបានគេហៅថា ទស្សនវិជ្ជាគតិបណ្ឌិតឬវិទ្យាសាស្ត្រ។ ប៉ុន្តែក្រោយមក ការសិក្សាវិស័យតថភាពខុសគ្នានាំមកនូវវិទ្យាសាស្ត្រពិសេសឬដោយឡែកដែលក្លាយជាខុសគ្នាពីអ្វីដែលគេហៅថា ទស្សនវិជ្ជា ហើយវានិយាយពីបញ្ហាតថភាពមូលដ្ឋានកាន់តែច្រើន។ ចំណែកឯទស្សនវិជ្ជាវិញ ក្នុងឋានៈជាអង្គពុទ្ធិ ទស្សនវិជ្ជារីកចម្រើន មានលេចឡើងមែកធាងទស្សនវិជ្ជាដែលនិយាយពីវត្ថុសិក្សាជាក់លាក់ដូចជា ធម្មជាតិ មនុស្ស និងសីលធម៌។ យើងរកឃើញក្នុងចំណោមមែកធាងទាំងនេះនូវស្នូលពុទ្ធិទស្សនវិជ្ជាមួយដែលជះឥទ្ធិពលលើមែកធាងផ្សេងទៀតព្រោះវាស្វែករករចនាសម្ព័ន្ធចក្រវាលដល់ទីបំផុតដែលចាំបាច់នាំដល់ការសិក្សាអំពីមូលហេតុដំបូងនិងសំខាន់បំផុរបស់វា។វិទ្យាសាស្ត្រនេះគេហៅថាអស្តិរូបវិជ្ជា (Metaphysics)។

### ក-បញ្ញត្តិអស្តិរូបវិជ្ជា

អស្តិរូបវិជ្ជា ជាមុខវិជ្ជាដែលសិក្សារកមូលហេតុខ្ពស់បំផុតនិងជាគោលការណ៍ទីមួយនិងសកលបំផុតនៃតថភាព។ ឥឡូវនេះ

ចូរយើងពិភាក្សាលំអិតនូវផ្នែកទាំងឡាយនៃនិយមន័យដំបូងនេះ[4]។

### ក.១-មូលហេតុខ្ពស់បំផុតឬមូលហេតុដើម(Ultimate cause)

ខុសពីមូលហេតុជិតឬចំពោះមុខ (proximate cause)ដែលបង្កើតជារបៀបមួយដោយផ្ទាល់នូវលទ្ធផលជាក់លាក់មួយចំនួន។ ឧទាហរណ៍៖ ការកើនឡើងនៃសម្ពាធបរិយាកាស គឺជាមូលហេតុនៃអាកាសធាតុល្អ។ បេះដូងជាសរីរាង្គដែលញុំាងឱ្យមានចរាចរឈាម។ ការសិក្សាមូលហេតុទាំងនេះទាក់ទងទៅនឹងវិស័យវិទ្យាសាស្ត្រដោយឡែកៗ។ មូលហាតុចុងក្រោយ(គេស្គាល់ផងដែរថា ជាមូលហេតខ្ពស់បំផុត)ហើយវាលាតសន្ធឹងឥទ្ធិពលរបស់វារហូតដល់លទ្ធផលទាំងអស់នៅក្នុងវិស័យជាក់ស្តែង មួយ ប្រៀបដូចទង្វើអ្នកដឹកនាំនយោបាយម្នាក់ទាក់ទងនឹងប្រទេសជាតិរបស់ខ្លួនឬចំណង់បានសុកមង្គលរបស់មនុស្សទាក់ទងនឹងសកម្មភាពរបស់ខ្លួនគេទាំងស្រុង។ អស្តិរូបវិជ្ជាពិចារណាមូលហេតុខ្ពស់ដាច់ខាតបំផុតនៃចក្រវាល។ វាខិតខំជុំរុញឱ្យស្វែងរកមូលហេតុនោះ និងស្គាល់កាន់តែច្រើនពី ធម្មជាតិរបស់វានិងសកម្មភាព។ ដោយសារតែអាទិទេពជាមូលហេតុចុងក្រោយឬខ្ពស់បំផុតនៃភាវៈទាំងអស់ ដូច្នេះហើយអាទិទេពជាកម្មវត្ថុសំខាន់នៃអស្តិរូបវិជ្ជា។

### ក.២-អស្តិរូបវិជ្ជាក៏សិក្សាផងដែរនូវគោលការណ៍ទីមួយនិងសកលបំផុតនៃ តថភាព

ក្រៅពីមូលហេតុទាំងឡាយដែលជះឥទ្ធិពលរបស់វាលើលទ្ធផលរបស់វាពីខាងក្រៅ ក៏នៅមានកត្តាខាងក្នុងជាលទ្ធផលខ្លួនវាដែលបង្កើតវា និងជះឥទ្ធិពលលើបែបបទឬរបៀបនៃភាវៈនិងអំពើរបស់វាផងដែរ។ ទាំងអស់នេះជាធម្មតាគេហៅថា គោលការណ៍(principle)។ អាតូម ជាគោលការណ៍ជាក់លាក់នៃម៉ូលេគុលដែលកំណត់ធម្មជាតិនិងលក្ខណៈរបស់វានៅក្នុងភាវរស់ កោសិកាធ្វើអំពើដូចជាគោលការណ៍នៃសរីរាង្គរស់(organism)។ ប៉ុន្តែ អស្តិរូបវិជ្ជា ស្វែងរកគោលការណ៍ទី១និងសកលបំផុត ពោលគឺគោលការណ៍ទាំងអស់នោះជាសំខាន់បង្កើតវត្ថុឬភាវៈទាំងអស់។ ដូច្នេះ ទស្សនវិទូជាញឹកញាប់ ចាត់ទុកទិដ្ឋភាពដោយឡែកមួយចំនួនរបស់តថភាពថាមានលក្ខណៈមូលដ្ឋានបំផុតនិងជាអាទិ៍ចាត់ទុកជាប្រភពនៃអ្វីៗផ្សេង(ឧទាហរណ៍ ការផ្លាស់ប្តូរឬប្រែក្លាយ បរិមាណ សារជាតិ ឬឱកាស)។ ពេលណាក៏ដោយដែលនរណាម្នាក់ចាត់ទុកអ្វីមួយថាជាគោលការណ៍ខាងក្នុងទី១នៃអ្វីៗទាំងអស់

---

[4] ខ្មៅ សារនេះ ***អស្តិរូបវិជ្ជា*** បកប្រែ ឆ្នាំ២០១៥

នោះ គឺគេនិយាយក្នុងកម្រិតអស្តិរូបវិជ្ជារួចស្រេចទៅហើយ។ ក្នុងកម្រិតនេះ អស្តិរូបវិជ្ជារួមមានអ្វីៗពិតនៅក្នុងវិស័យសិក្សារបស់វា ពីព្រោះវាស្វែងរកមូលហេតុដើមឬចុងក្រោយ និងគោលការណ៍មូលដ្ឋាន នៃតថភាព ផ្ទុយទៅវិញ វិទ្យាសាស្ត្រដោយឡែកៗសិក្សាតែទៅលើវិស័យមានដែនកំណត់មួយរបស់ពិភពលោក។

ឧទាហរណ៍អំពីការសិក្សារបស់វិទ្យាសាស្ត្រ៖ មានដូចជា រចនាសម្ព័ន្ធអាតូម ប្រព័ន្ធរំលាយអាហាររបស់សត្វ ជំងឺរុក្ខជាតិ។ វិទ្យាសាស្ត្រទាំងនេះអភិវឌ្ឍក្នុងវិស័យរបស់វាដោយសារតែអង្គពុទ្ធិអចិន្ត្រៃយ៍ធ្វើជាគ្រឹះរបស់វា និងជានិច្ចកាលសន្មតឬចាត់ទុកថាពិតនៅគ្រប់ការស្រាវជ្រាវ។ ឧទាហរណ៍ គំនិតអំពីជីវិតរុក្ខជាតិ ជីវិតជាទូទៅ រាងកាយ រូបធាតុ បរិមាណ។ល។ អ្នកវិទ្យាសាស្ត្រ ជាធម្មតាមិនធ្វើការសិក្សាបន្ថែមទាក់ទងនឹងកត្តាទាំងអស់នេះទេ ប៉ុន្តែប្រសិនបើពួកគេសួរ "ជីវិតជាអ្វី" "បរិមាណជាអ្វី" នោះពួកគេសន្មត ថាជាបញ្ហាទស្សនវិជ្ជា រួចទៅហើយ។ មានបញ្ហាជាក់ស្តែងសំខាន់ជាងបញ្ហាដែលបាននិយាយពីមុនទៅទៀត ហើយបញ្ហាជាក់ស្តែងនេះសន្មតជាមុនដោយខ្លួនវា៖ "តើវាមានន័យដូចម្តេច?" "តើអ្វីជាហេតុផលភាព (causality)" "តើអ្វីជាអត្ថន័យចក្រវាល" "អ្វីជាសច្ចភាព?" "អ្វីជាកុសល?" បញ្ហាទាំងអស់នេះទាក់ទងជិតស្និទ្ធទៅនឹងវិស័យ អស្តិរូបវិជ្ជា។

**ខ-អស្តិរូបវិជ្ជា ជាវិទ្យាសាស្ត្រភាវៈក្នុងឋានៈជាភាវៈ** ( Metaphysics as the Science of Being as Being )

គ្រប់វិទ្យាសាស្ត្រមានកម្មវត្ថុសិក្សាផ្ទាល់ខ្លួនរបស់វា ជាវិស័យតថភាពមួយដែលវាបរិយាយដល់។ឧទាហរណ៍ វិទ្យាសាស្ត្រពិចារណាពិភពនៃការរស់គណិតវិទ្យាសិក្សាលើវិស័យបរិមាណនៃការៈ និងភូមិវិទ្យារូបនិយាយពីផ្ទៃក្រឡានៃផែនដី។ កម្មវត្ថុ នៃការសិក្សារបស់វិទ្យាសាស្ត្រជាក់លាក់មួយពណ៌នាឬកំណត់នៃវិទ្យាសាស្ត្រនោះ វាផ្តល់សហទំនាក់ទំនងខាងក្នុងចំពោះខ្លឹមសាររបស់វា និងបែងចែកការខុសគ្នារបស់វា ទៅនឹងវិទ្យាសាស្ត្រផ្សេងទៀត។

ការខុសគ្នាជាធម្មតាធ្វើឡើងរវាង កម្មវត្ថុរូបធាតុ(material object)និងកម្មវត្ថុទម្រង់ (Formal Object)របស់វិទ្យាសាស្ត្រមួយ វិស័យទី១ ជាកម្មវត្ថុរូបធាតុ គេក៏ហៅផងដែរថាជា "ខ្លឹមសារនៃការសិក្សា" ឬប្រធាន(Subject matter) នៃវិទ្យាសាស្ត្រមួយ ព្រោះវាជាការប្រមូលសរុបនៃអ្វីដែលសិក្សា ឯវិស័យទី២ ជាកម្មវត្ថុទម្រង់ ដែលវិទ្យាសាស្ត្រនីមួយផ្តោតលើ។ ដូច្នេះ កម្មវត្ថុរូបធាតុរបស់ជីវវិទ្យារួមមានការរស់ទាំងអស់ ប៉ុន្តែកម្មវត្ថុទម្រង់របស់វា កម្រិតកម្មវត្ថុសិក្សាពីព្រោះវិទ្យាសាស្ត្រនេះបន្តការសិក្សារបស់វាផ្តើមពីទស្សនៈអំពី

ជីវិត។ ដូចគ្នានេះកម្មវត្ថុរូបធាតុរបស់វេជ្ជសាស្ត្រ គឺរាងកាយរបស់មនុស្ស ប៉ុន្តែកម្មវត្ថុទម្រង់របស់វា គឺរាងកាយរបស់មនុស្សត្រឹមកម្រិតវាផ្អែកលើ ជាឬឈឺ។

### ខ.១-អស្តិរូបវិជ្ជាសិក្សាភាវៈនៅក្នុងឋានៈជាភាវៈ លក្ខណៈ និងមូលហេតុរបស់វា

( Metaphysics Studies being as being, its properties and its causes )

វិទ្យាសាស្ត្រដោយឡែកៗមានកម្មវត្ថុសិក្សាលើវិស័យជាក់លាក់មួយចំនួននៃតថភាព។ ប៉ុន្តែ មានវិទ្យាសាស្ត្រមួយទៀតដែលសិក្សាតថភាពទាំងមូល ដោយផ្តោតការយកចិត្តទុកដាក់លើវិស័យរួមបំផុតនៃអ្វីៗ៖ អ្វីៗនោះ "មានអត្ថិភាព" គឺវាមាន "ពិត" ។ វិស័យរួមនេះសន្មតដោយទម្រង់ពុទ្ធិដោយឡែកណាមួយផ្សេងទៀត។ ដូច្នេះ ពេលរុក្ខវិទូ(botanist)ម្នាក់សិក្សានិងបែកចំណែកថ្នាក់ប្រភេទរុក្ខជាតិ គេដឹងថា វាជា "ភាវៈ" គំនិតអំពីភាវៈនៅពីមុខ ឬមានមុនគំនិតអំពីប្រភេទរុក្ខជាតិណាមួយ។ ចូរយើងពិចារណាផ្នែកទាំងឡាយនៃអំណះអំណាងដែលបានលើកឡើងខាងលើ។

**ភាវៈ(Being)** ជាសព្ទអស្តិរូបវិជ្ជា មានន័យស្មើនឹងអ្វីដែលគេហៅថា "វត្ថុ"(thing) ក្នុងភាសាធម្មតា។ ភាវៈមានន័យថា"អ្វីដែលមានអត្ថិភាព"ឬអ្វីដែលផ្តល់នូវអំពើនៃភាវៈ។ ដើមឈើមួយជាភាវៈមួយ បក្សីមួយជាភាវៈមួយ មនុស្សម្នាក់ជាភាវៈមួយ ឬពេជ្រមួយគ្រាប់ជាភាវៈមួយ ប៉ុន្តែចំណែកឯពាក្យ"បក្សី" មានន័យថា ធម្មជាតិដោយឡែកមួយ ឬរបៀបរបស់ភាវៈ ភាវៈបង្ហាញហេតុការណ៍ថា បក្សីមានអត្ថិភាព។ មនុស្សក្នុងកម្រិតជាអ្នកស្តាប់(មានន័យថា គេអនុវត្តអំពើនៃការស្តាប់) គេហៅថា អ្នកស្តាប់ និងក្នុងកម្រិតគេជាអ្នកសិក្សាគេហៅថា និស្សិត ហើយបើមនុស្សម្នាក់ក្នុងកម្រិតគេមានអំពើនៃភាវៈគេហៅថាជា"ភាវៈ"មួយ។

**ក្នុងឋានៈជាភាវៈ(As being)**

សន្ត ថូម៉ាស អាឃ្វីណាស(St. Thomas Aquinas) នៅក្នុងការអធិប្បាយរបស់លោកស្តីពីអស្តិរូបវិជ្ជា របស់ អារីស្តូត បាននិយាយថា "វិទ្យាសាស្ត្រផ្សេងទៀតដែលនិយាយពីភាវៈដោយឡែកពិតណាស់ពិចារណាពីភាវៈ ព្រោះកម្មវត្ថុសិក្សាទាំងអស់របស់វិទ្យាសាស្ត្រ គឺភាវៈ។ ប៉ុន្តែវាមិនពិចារណាភាវៈក្នុងឋានៈជាភាវៈទេ តែវាពិចារណាប្រភេទភាវៈដោយឡែកមួយចំនួន ឧទាហរណ៍ វាពិចារណាពីចំនួនឬបន្ទាត់ឬភ្លើង។ល។ ដូច្នេះ គេនិយាយថាកម្មវត្ថុរូបធាតុនៃអស្តិរូបវិជ្ជា គឺតថភាពក្នុងភាពទាំងមូលរបស់វា ព្រោះតែវត្ថុទាំងអស់ ទោះជាមានធម្មជាតិដូចម្តេចក៏ដោយ ក៏ជាភាវៈដែរ។ ម្យ៉ាងទៀត កម្មវត្ថុទម្រង់របស់វា ជាភាវៈក្នុងឋានៈជាភាវៈ ឬភាវៈក្នុងខ្លួនរបស់វា។ គោលការណ៍ពិតគឺថា កម្មវត្ថុរូបធាតុនៃអស្តិរូបវិជ្ជារួមមានតថភាពទាំងអស់មិនមានន័យ

ថា អស្តិរូបវិជ្ជាជាការបូកសរុបវិទ្យាសាស្ត្រដោយឡែកខុសៗគ្នានោះទេ។ វាមិនមែនជាការសំយោគវិទ្យាសាស្ត្រដោយឡែកទាំងអស់ ដូចដែលទស្សនវិទូវិជ្ជមាននិយមអះអាងនោះទេ។ អស្តិរូបវិជ្ជាជាវិទ្យាសាស្ត្រដោយឡែកមួយព្រោះវាសិក្សាវិស័យដោយឡែករបស់តថភាពពិសេសចំពោះខ្លួនវា និងសន្មតតាមរយៈវិទ្យាសាស្ត្រផ្សេងទៀត វាជាភាវៈនៃវត្ថុទាំងឡាយ។

### លក្ខណៈនិងមូលហេតុរបស់ភាវៈ

(The Properties and causes of being)

នៅក្នុងការដោះស្រាយកម្មវត្ថុនៃការសិក្សារបស់វា គ្រប់វិទ្យាសាស្ត្រត្រូវសិក្សាលក្ខណៈពិសេសរបស់វា និងអ្វីៗដែលទាក់ទងនឹងវា ទោះជាក្នុងករណីណាក៏ដោយ។ ដូចជារូបវិទ្យាសិក្សាលទ្ធផលនៃ លក្ខណៈរូបវិទ្យារបស់រាងកាយដូចជា ម៉ាសឬថាមពលរបស់វា អស្តិរូបវិជ្ជាសិក្សាលក្ខណៈនៃភាវៈក្នុងកម្រិតជាភាវៈ។ វាក៏ជាភារកិច្ចនៃអស្តិរូបវិជ្ជាដែលរកឃើញវិស័យភាវៈក្នុងខ្លួនវា(ឧទាហរណ៍"សច្ចភាព") ក៏ដូចជាវិស័យទាំងអស់នោះដែលមិនមែនជាភាវៈក្នុងឋានៈជាភាវៈ (ដូចជា "រូបធាតុ" ឬធម្មជាតិរាងកាយ)។

ជាងនេះទៅទៀត វិទ្យាសាស្ត្រខ្លះសិក្សាប្រភេទជាក់លាក់មួយនៃវត្ថុនិងមូលហេតុផ្ទាល់របស់វា ពីព្រោះពុទ្ធិមិនពេញលេញសោះឡើយ ប្រសិនបើវាមិនក្តាប់បានល្អនូវមូលហេតុ។ ដូច្នេះ អស្តិរូបវិជ្ជាត្រូវសិក្សាមូលហេតុនៃភាវៈទាំងអស់ត្រឹមកម្រិតវាជាភាវៈ។ នេះជាផ្នែកសំខាន់មួយក្នុងចំណោមផ្នែកសំខាន់ទាំងឡាយរបស់វា នៃការសិក្សានៅក្នុងកម្មវត្ថុសិក្សាពិតរបស់វា។ ដូចជា វេជ្ជសាស្ត្រស្វែងរកមូលហេតុនៃសុខភាពរាងកាយ(ឧទាហរណ៍ ចំណីអាហារ អាកាសធាតុ អនាម័យ) អស្តិរូបវិជ្ជានាំយើងទៅដល់មូលហេតុនៃអំពើរបស់ភាវៈរបស់វត្ថុទាំងអស់ គឺអាទិទេពជាអ្នកបង្កើត។

ខណៈដែលយើងរីកចម្រើនក្នុងការយល់ដឹងបញ្ហាអស្តិរូបវិជ្ជានានា យើងនឹងឃើញកាន់តែច្បាស់ថា លក្ខណៈពិសេសមូលដ្ឋានបំផុតនៃពិភពពិតផ្អែកលើសច្ចភាពមូលដ្ឋានដែលវត្ថុទាំងអស់មានអត្ថិភាព វាជាភាវៈ។ អំពើនៃភាវៈគឺជាលក្ខណៈមូលដ្ឋានបំផុតនៃវត្ថុទាំងអស់ ព្រោះសុក្រឹតភាពឬលក្ខណៈពិសេសរបស់វាណាមួយមុនអ្វីផ្សេងទៀតត្រូវតែមានអត្ថិភាព។ នេះជាលក្ខខណ្ឌដំបូងដែលអ្វីផ្សេងផ្អែកលើ។ ព្រោះតែអស្តិរូបវិជ្ជាជាវិទ្យាសាស្ត្រស្វែងរកកត្តាសំខាន់បំផុតនៃតថភាព វាត្រូវតែផ្តោតជាចាំបាច់លើអំពើនៃភាវៈក្នុងឋានៈជាកម្មវត្ថុសិក្សាមូលដ្ឋានរបស់វា។

និកាយគំនិតទស្សនវិជ្ជាខ្លះបានជ្រើសរើសវិស័យតថភាពផ្សេងទៀត ជាកម្មវត្ថុនៃអស្តិរូបវិជ្ជា។ ឧទាហរណ៍ "ជំនឿលើកម្លាំងត្រួតពិនិត្យជីវិត" (vitalism) មានជីវិតសម្រាប់

ធ្វើជាកម្មវត្ថុរបស់វា "អត្ថិភាពនិយម" (Existentialism) មានអត្ថិភាពរបស់មនុស្ស "មនោនិយម" (Idealism) មានគំនិតរបស់មនុស្ស "ប្រវត្តិសាស្ត្រនិយម" (Historicism) មានវឌ្ឍនភាពខាងប្រវត្តិសាស្ត្រ។ ខាន្ត (Kant) ក្ដាប់បានលក្ខខណ្ឌនៃពុទ្ធិវិទ្យាសាស្ត្រយ៉ាងណែន ការរិះគន់ជាកម្មវត្ថុនៃទស្សនវិជ្ជារបស់លោក។ ទោះជាយ៉ាងនេះក៏ដោយទស្សនវិទូទាំងអស់ មិនទទួលបានជោគជ័យឡើយប្រសិនបើពួកគេមិនសិក្សាអំពីពីភាវៈ។ អ្វីដែលពួកគេបានធ្វើគឺបង្រួមភាវៈទៅជាកម្មវត្ថុដោយឡែក និងមានដែនកំណត់។

## ១.២-ប្រភពប្រវត្តិសាស្ត្រនៃ វិទ្យាសាស្ត្រភាវៈ(Historical origin of the Science of being)

ចាប់តាំងពីសម័យកាលទស្សនវិទូដំបូងបង្អស់មកម្ល៉េះ វិទ្យាសាស្ត្រភាវៈត្រូវបានគេយល់ថា ជាពុទ្ធិសកលមួយដែលកម្មវត្ថុរបស់វាគឺរកឃើញធាតុដំដូងនៃតថភាព។ ប៉ុន្តែធាតុនេះទាក់ទងជាមួយធាតុរូបធាតុខ្លះដែលមិនប្រែប្រួល ដូចជា ភ្លើង ខ្យល់ ឬទឹក រហូតមកដល់ប៉ាមេនីត (Parmenides) និយាយជាដំបូងអំពីភាវៈថា ជាវិស័យមូលដ្ឋាននៃតថភាព។ លោកបាននិយាយថា "ភាវៈគឺមានអត្ថិភាព និងអភាវៈគឺមិនមានអត្ថិភាព វាជាវិធីបញ្ចុះបញ្ចូល ពីព្រោះវានាំទៅរកសច្ចភាព។ ដោយមិនទាក់ទងសោះជាមួយលទ្ធិរបស់ Parmenides ទស្សនវិទូជាបន្តបន្ទាប់មកទៀត ផ្ដោតសំខាន់ទៅលើបញ្ហាផ្សេងទៀតរបស់ទស្សនវិជ្ជា។ ប៉ុន្តែពេលអារីស្តូតលេចមុខឡើង ភាវៈទទួលបាននូវបឋមភាព ឬភាពចម្បងគេក្នុងឋានៈជាកម្មវត្ថុនៃវិទ្យាសាស្ត្រ អស្តិរូបវិជ្ជា។

## ១.៣-ឈ្មោះផ្ដល់ដល់អស្តិរូបវិជ្ជា (Name given to Metaphysics)

ឈ្មោះផ្ដល់ឱ្យអស្តិរូបវិជ្ជាខុសៗគ្នាដោយសង្កត់ធ្ងន់លើវិស័យខុសគ្នានៃវិទ្យាសាស្ត្រដដែលនេះ។ លោកអារីស្តូតហៅថាទស្សនវិជ្ជាទី១(First Philosophy)ព្រោះវាសិក្សាមូលហេតុទី១និងគោលការណ៍នៃតថភាព។ ឈ្មោះនេះបង្ហាញសមស្របនូវទីតាំងស្នូលរបស់អស្តិរូបវិជ្ជាក្នុងទស្សនវិជ្ជា ហើយវាបែងចែកការខុសគ្នាផងដែររវាងអស្តិរូបវិជ្ជាជាមួយមែកធាងពុទ្ធិផ្សេងទៀតដែលលោកអារីស្តូតហៅថា ទស្សនវិជ្ជាទី២។ អស្តិរូបវិជ្ជាគឺ"ទី១" មិនមែនដោយសារតែបឋមភាពខាងកាលប្បវត្តិរបស់វាទេ។ វាទី១ព្រោះវាមានបឋមភាពឬសារសំខាន់បំផុតនៅក្នុងទស្សនវិជ្ជាទាំងមូល ហើយវាទាក់ទងនឹងវិទ្យាសាស្ត្រផ្សេងទៀត។

ឈ្មោះ"អស្តិរូបវិជ្ជា" ដែលមានន័យត្រង់ថា"ហួសពីរូបវិទ្យា"(beyond physics) ត្រូវបានបង្កើតឡើងដោយលោក អង់ដ្រូនីគុស អូហ្វ រ៉ូដ ( Adronicus of Rhodes) សំដៅហៅ "ទស្សនវិជ្ជាទី១"របស់លោក អារីស្តូតបន្ទាប់ពីសៀវភៅរបស់លោកស្ដីពីរូបវិទ្យា។

ឈ្មោះនេះបង្ហាញស្របនឹងធម្មជាតិនៃវិទ្យាសាស្ត្រនេះ ដែលវាពិចារណាហួសពីវិស័យតថភាពរូបធាតុដែលសិក្សាដោយរូបវិទ្យា។

នៅសតវត្សរ៍ទី១៧ លោក គ្រីស្សៀន វ៉ុល(Cristian Wolff) ហៅអស្តិរូបវិជ្ជាថា ភាវវិទ្យា (ontology) ជាសព្ទមកពីភាសាក្រិក ដែលមានន័យថា "ការសិក្សាពីភាវៈ"។ ទស្សនវិទូវិចារណញ្ញាណនិយមចូលចិត្តប្រើប្រាស់សព្ទ "ភាវវិទ្យា" បង្ហាញកម្មវត្ថុសិក្សាដូចគ្នានឹងអស្តិរូបវិជ្ជាផងដែរ។

## គ-អស្តិរូបវិជ្ជានិងពុទ្ធិរបស់មនុស្ស ( Metaphysics and Human knowledge )

### គ.១-អស្តិរូបវិជ្ជានិងពុទ្ធិឯកឯង (Metaphysics and spontaneous Knowledge)

មនុស្សទាំងអស់មានពុទ្ធិរួមអំពី តថភាពដែលក្តាប់បានតាមរយៈពន្លឺនៃវិចារណញ្ញាណធម្មជាតិ។ ពួកគេដឹងនូវន័យដែលពួកគេនិយាយអំពី "ភាវៈ" "សច្ចភាព" ឬ "កុសល"។ ពួកគេមានពុទ្ធិមួយចំនួនអំពីធម្មជាតិមនុស្សនិងការខុសគ្នារវាងតថភាព" សារធាតុ" និងតថភាព"ចៃដន្យ"។ ជាងនេះទៅទៀត ពួកគេអាចដឹងថាអាទិទេព ជាមូលហេតុទី១របស់ចក្រវាលដែលជាអ្នកស្ថិតស្ថេរជានិច្ច និងណែនាំភាវៈទាំងអស់ទៅរកគោលដៅរបស់ខ្លួន។ ពុទ្ធិប្រភេទនេះយើងនិយាយថាមានលក្ខណៈឯកឯង (សយម្ភូត) (Spontaneous) ទាក់ទងជាមួយបញ្ហាឬប្រធានបទដដែលដែលបានសិក្សាដោយអស្តិរូបវិជ្ជា។ ការណ៍នេះមិនគួរភ្ញាក់ផ្អើលទេ ព្រោះមនុស្សមានទំនោរធម្មជាតិមួយ គឺចង់ស្គាល់ពិភពលោក ទីតាំងរបស់គេក្នុងពិភពលោក ប្រភពរបស់ចក្រវាល និងបញ្ហាដែលមានទំនាក់ទំនងផ្សេងគ្នា។ ដំណើរជីវិតរបស់មនុស្សភាគច្រើនផ្អែកលើពុទ្ធិ ដែលគេមានក្នុងចំណោមបញ្ហាទាំងនេះ។ ដូច្នេះគេអាចយល់ថាពុទ្ធិនេះ ត្រូវបានគេហៅថា អស្តិរូបវិជ្ជាឯកឯង ឬអស្តិរូបវិជ្ជាធម្មជាតិនៃបញ្ញារបស់មនុស្ស។ ទោះជាយ៉ាងណាក៏ដោយ ហេតុការណ៍នេះមិនខ្វះបាននូវតម្រូវការ អស្តិរូបវិជ្ជាមួយដែលបានអភិវឌ្ឍជាវិទ្យាសាស្ត្រ ព្រោះតែហេតុផលផ្សេងៗ ពោលគឺ ព្រោះតែពុទ្ធិឯកឯងជាញឹកញាយមិនពេញលេញឬមិនជាក់លាក់ ព្រោះតែវាមិនរឹងមាំឬមិនគ្រប់គ្រាន់ក្នុងវិស័យជាក់លាក់មួយចំនួន និងចុងក្រោយ ព្រោះវាស្ថិតក្រោមឥទ្ធិពលនៃមនោគមវិជ្ជាដែលរីកសាយក្នុងមជ្ឈដ្ឋានវប្បធម៌ខ្លះ ឬមានការទទួលស្គាល់ពី ប្រជាជនភាគច្រើន។

ក្រៅពីនេះ គេគួរចងចាំថា ជំនឿរឹងមាំលើសីលធម៌របស់មនុស្សគ្រប់រូបមានឥទ្ធិពលជាកំណត់លើពុទ្ធិរបស់គេអំពីបញ្ហាអស្តិរូបវិជ្ជា។ បទពិសោធន៍បង្ហាញថាខណៈដែលបុគ្គលបាត់បង់ភាពត្រឹមត្រូវខាងសីលធម៌ ពួកគេក៏បាត់បង់ភាពជឿជាក់ខាងបញ្ញា

ជាមូលដ្ឋាន តាមរយៈនោះពួកគេធ្លាក់ចូលទៅកាន់ឥរិយាបថសង្ស័យចំពោះសច្ចភាព។ ដូច្នេះនាំឱ្យពួកគេសង្ស័យពុទ្ធិអំពីព្រះថាតើព្រះមានអត្ថិភាពពិតដែរឬទេ និងនាំដល់បង្គរនិយម(Relativism)ទាក់ទងនឹងតម្រូវការច្បាប់សីលធម៌។ ទីបំផុតមនុស្សត្រូវបានលើកកម្ពស់ថាជាស្នូលនៃចក្រវាលទាំងមូល។ នេះជាហេតុផលនៅពីក្រោយអត្ថិភាពនៃប្រពន្ធ័ទស្សនវិជ្ជាមួយចំនួនដែលប្រឆាំងទាំងស្រុងទៅនឹងសច្ចភាព ដូចជាលទ្ធិម៉ាក្សនិយម លទ្ធិសង្ស័យពីអត្ថិភាពរបស់ព្រះ ( Agnosticism) និងលទ្ធិមនោនិយម (Idealism)។ ទាំងអស់នេះ ជារចនាសម្ព័ន្ធទ្រឹស្តីដែលបានកសាងឡើងស្របជាមួយឥរិយាបថខុសឆ្គងជាមូលដ្ឋានមួយចំនួនចំពោះជីវិតមនុស្ស។ ក្នុងឋានៈជាវិទ្យាសាស្ត្រអស្តិរូបវិជ្ជាជះឥទ្ធិពលកម្រិតណានោះគឺតាមរយៈជីវភាពសីលធម៌របស់ទស្សនវិទូដែលពាក់ព័ន្ធក្នុងវា។ ឥទ្ធិពលនេះកាន់តែច្បាស់ឡើងក្នុងចំណុចសំខាន់ៗទាំងឡាយដែលបញ្ហាបច្ចេកទេសនិងបញ្ហាពិសេសផ្អែកលើ។

### គ.២-តួនាទីណែនាំរបស់អស្តិរូបវិជ្ជាចំពោះវិទ្យាសាស្ត្រផ្សេងទៀត

(The guiding Role of Metaphysics in Relation to other Sciences)

អស្តិរូបវិជ្ជានិយាយពីបញ្ហាមូលដ្ឋានបំផុតនៃពុទ្ធិរបស់មនុស្ស ចំណែកកម្មវត្ថុសិក្សារបស់វាគ្របតថភាពទាំងមូល។ ជាធម្មតាវិទ្យាសាស្ត្រដោយឡែកៗ មានកម្មវត្ថុសិក្សាសិក្សាខ្លួនតូចចង្អៀតដោយផ្តោតតែលើវិស័យមួយនៃភាវៈ។ កម្មវត្ថុនៃការសិក្សារបស់វិទ្យាសាស្ត្រដោយឡែកៗ ជាប្រភេទដោយឡែកមួយរបស់ភាវៈ។ តាមគោលការណ៍អស្តិរូបវិជ្ជា លក្ខណៈនៃភាវៈនិងគំនិតមូលដ្ឋានផ្សេងទៀតអំពីតថភាពត្រូវតែឆ្លុះបញ្ចាំងតាមរបៀបណាមួយផងដែរក្នុងវិស័យជាក់លាក់នៃការស្រាវជ្រាវវិទ្យាសាស្ត្រដោយឡែកៗ។ គោលការណ៍ទាំងនេះសន្មតតាមរយៈវិទ្យាសាស្ត្រដោយឡែក និងទោះបីមិនអង្កេតច្បាស់លាស់តាមរយៈវាក្តី ក៏វិទ្យាសាស្ត្រទាំងនេះប្រើប្រាស់អស្តិរូបវិជ្ជាពេលណាចាំបាច់។ឧទាហរណ៍ ពេលរូបវិទូធ្វើការពិសោធអំពីឌីណាមិចនៃរាងកាយ នៅក្នុងសកម្មភាព គីមីសរីរៈ ពួកគេប្រើប្រាស់គោលការណ៍ហេតុផលភាព(causality) ជាមួយអត្តន័យរបស់វា។ ដូចគ្នានេះ ពេលជីវវិទូសិក្សាមុខងាររបស់សរីរាង្គរស់មួយ វាតែងតែប្រើប្រាស់គោលការណ៍ខ្ពស់បំផុត(finality)។ ប៉ុន្តែជួនកាលការអភិវឌ្ឍវិទ្យាសាស្ត្រដោយឡែក អាចណែនាំដោយប្រព័ន្ធទស្សនវិជ្ជាជាក់លាក់មួយជាជាងដោយពុទ្ធិឯកឯងនៃអត្តន័យបែបអស្តិរូបវិជ្ជា។ នេះជាករណីវិទ្យាសាស្ត្រដោយឡែក ដូចជាប្រវត្តិសាស្ត្រឬសេនេទិច(Genetics)ដែលបានអភិវឌ្ឍតាមទស្សនៈម៉ាក្សនិយម។

នៅក្នុងការខិតខំរបស់ខ្លួន ដើម្បីឈានដល់ការយល់ដឹងពេញលេញនូវកម្មវត្ថុសិក្សារបស់ខ្លួន ពួកវិទ្យាសាស្ត្រពិសោធន៍ជាញឹកញយបានវិលទៅរកសំណួរបែបទស្សនវិជ្ជា។ ដូច្នេះមិនគួរភ្ញាក់ផ្អើលទេដែលរូបវិទូសហសម័យបានសរសេរបទនិពន្ធ(Essay)ស្តីពីប្រធានបទអស្តិរូបវិជ្ជា។ ចំណង់បានរបស់វិទ្យាសាស្ត្រដោយឡែកៗ(វិទ្យាសាស្ត្រជាក់ស្តែង)នូវឯករាជ្យភាពដាច់ខាតពីពុទ្ធិអស្តិរូបវិជ្ជាណាមួយ មិនដែលសម្រេចទាំងស្រុងឡើយ។

ដូច្នេះគេអាចមើលឃើញថា អស្តិរូបវិជ្ជាមានតួនាទីណែនាំវិទ្យាសាស្ត្រដោយឡែកៗព្រោះវាជាកំពូលនៃពុទ្ធិរបស់មនុស្សនៅក្នុងលំដាប់ធម្មជាតិ។ តួនាទីនេះហៅឱ្យត្រឹមត្រូវទៅថា ការវិនិច្ឆ័យត្រឹមត្រូវនិងសមហេតុផល(Sapiential) ព្រោះគតិបណ្ឌិតមានតួនាទីត្រឹមត្រូវក្នុងការណែនាំពុទ្ធិ និងសកម្មភាពរបស់មនុស្សទាក់ទងនឹងគោលការណ៍ទីមួយ និងគោលបំណងចុងក្រោយរបស់មនុស្ស។

## ឃ-តើអស្តិរូបវិជ្ជាទាក់ទងនឹងជំនឿសាសនា និងទេវវិទ្យា ដូចម្តេច?

( How Metaphysics Is Related to Faith and theory )

មានពុទ្ធិមួយដែលទាក់ទងនឹងលំដាប់អធិធម្មជាតិដែលខ្ពស់ជាង និងហួសពីពុទ្ធិឯកឯង និងពុទ្ធិវិទ្យាសាស្ត្រ។ ពុទ្ធិខ្ពស់នេះកើតចេញពីប្រកាសន៍(Revelation)ផ្ទាល់របស់ព្រះ។ វាជាប្រភេទពុទ្ធិមួយខ្ពស់ ព្រោះវាធ្វើឱ្យសុក្រឹតឬពេញលេញនូវពុទ្ធិរបស់មនុស្សទាំងអស់ ណែនាំវាឆ្ពោះទៅរកគោលបំណងអធិធម្មជាតិចុងក្រោយរបស់មនុស្ស[៥]។

### ឃ១-ជំនឿសាសនាជួយទស្សនវិជ្ជា

**(Faith helps philosophy)**

សច្ចភាពបែបអស្តិរូបវិជ្ជាមួយចំនួនទោះបីជាធម្មជាតិអាចដឹងតាមរយៈមនុស្សក៏ដោយ ក៏ជាប្រកាសន៍(Revelation)ដោយអាទិទេព។ ក្រៅពីបង្ហាញភាពអាថ៌កំបាំងបែបអធិធម្មជាតិចំពោះមនុស្ស ប្រកាសន៍របស់ព្រះក៏បានធ្វើឱ្យមនុស្សដឹងពីសច្ចភាពខ្ពស់បំផុតរបស់ពិភពលោករបស់មនុស្ស និងរបស់អាទិទេពផ្ទាល់ ជាសច្ចភាពដែលបង្កើតជាផ្នែកមួយនៃកម្មវត្ថុសិក្សារបស់អស្តិរូបវិជ្ជា។ ដោយសារតែអំពើបាបពីកំណើតមនុស្សពិបាកទទួលបានពុទ្ធិសច្ចភាពទាំងនេះដែលចាំបាច់សម្រាប់ជីវភាពសីលធម៌ណាស់ ជាមួយភាពជាក់ច្បាស់រឹងមាំ និងគ្មានសញ្ញាខុសឆ្គងមួយឡើយ។ ដោយមូលហេតុនេះ អាទិទេពប្រកាសន៍សច្ចភាពចំពោះមនុស្សដូចជាបង្កើតភាវៈទាំងអស់ពីមិនទទេ( ex nihilo) បុព្វទេព( divine providence) ស្មារតី និងអមតភាពនៃព្រលឹង

[៥] ខ្មៅ សារនេះ ***អស្តិរូបវិជ្ជា*** ជ.ឯ.ម.

របស់មនុស្ស អត្ថិភាព និងធម្មជាតិនៃអាទិទេពពិតមួយ ច្បាប់សីលធម៌ និងគោលដៅចុងក្រោយរបស់មនុស្ស និងជាងនេះទៀតឈ្មោះផ្ទាល់របស់អាទិទេពជាអំពើគង់វង្សរបស់ភាវៈ "ខ្ញុំមានអត្ថិភាព"។

ជាមួយជំនួយនៃប្រកាសន៍ អស្តិរូបវិជ្ជាទទួលសន្ទុះពិសេស មិនសមស្របក្នុងប្រវត្តិសាស្ត្រនៃគំនិតមនុស្ស។ អ្នកកាន់សាសនាគ្រិស្ត ដំបូងភ្ញាក់ផ្អើលនឹងហេតុការណ៍ថា សូម្បីតែក្មេងម្នាក់ដែលបានរៀនពីសច្ចភាពតិចតួចពីជំនឿសាសនាក៏អាចផ្តល់ចម្លើយកាន់តែជ្រៅ និងច្បាស់ចំពោះសំណួរធំបំផុតដែលប្រឈមមុខនឹងញាណសតិរបស់មនុស្សជាងទស្សនវិទូក្រិកខ្លួនឯង។ ចម្ងល់របស់ញាណសតិទាក់ទងនឹងអំពើបាប សេចក្តីទុក្ខរបស់មនុស្ស ការស្លាប់ សេរីភាព អត្ថន័យជីវិត និងកុសលរបស់ពិភពលោកបានផ្តល់នូវចម្លើយពេញលេញនិងទាំងស្រុងតាមរយៈជំនឿលើគ្រិស្តសាសនា។

ដោយសារតែកិច្ចការអនុវត្តដោយលោកឪពុកនិងបណ្ឌិតសាសនា វឌ្ឍនភាពមិនគ្រប់គ្រាន់តែកើតឡើងនៅក្នុងទេវវិទ្យាគ្រិស្តសាសនាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងការយល់ដឹងបែបទស្សនវិជ្ជា ពីសច្ចភាពធម្មជាតិដែលបានប្រកាសន៍។ ការអភិវឌ្ឍនេះជាយថាហេតុ ត្រូវបានគេហៅថាជា ទស្សនវិជ្ជាគ្រិស្តសាសនា។

ពិតណាស់សច្ចភាពធម្មជាតិសិក្សាដោយអស្តិរូបវិជ្ជា ត្រូវបានលាតត្រដាងថាអស្តិរូបវិជ្ជាចាំបាច់ជាវិទ្យាសាស្ត្រមួយ។ ផ្ទុយទៅវិញ វាត្រូវតែលើកកម្ពស់អស្តិរូបវិជ្ជា ជាពុទ្ធិសច្ចភាពកាន់តែជ្រៅព្រោះអាទិទេពលាតត្រដាងវាជាក់ច្បាស់ ដើម្បីឱ្យមនុស្សអាចរុករកវាថែមទៀតឆ្លងតាមញាណសតិរបស់គេនិងទទួលការបណ្តុះបញ្ញាឆ្លងតាមវា។

### ឃ.២-ទស្សនវិជ្ជាបម្រើឱ្យជំនឿសាសនា (Philosophy at the Service of the Faith)

ខណៈដែលវិចារណញ្ញាណបម្រើឱ្យជំនឿសាសនា អស្តិរូបវិជ្ជាជាឧបករណ៍វិទ្យាសាស្ត្ររបស់ទេវវិទ្យា។ ខណៈដែលអស្តិរូបវិជ្ជារីកចម្រើនពេញលេញ ឆ្លងតាមការណែនាំដែលផ្តល់ដោយជំនឿសាសនា វាក្លាយជាឧបករណ៍ដ៏មានតម្លៃសម្រាប់ការយល់ដឹងកាន់តែប្រសើរឡើងពីអាថ៌កំបាំងអធិធម្មជាតិដែលបង្កើតជាកម្មវត្ថុនៃ វិទ្យាសាស្ត្រទេវវិទ្យា។

**• ពុទ្ធិនៃលំដាប់អធិធម្មជាតិសន្មតពុទ្ធិនៃលំដាប់ធម្មជាតិ**

នេះជាលទ្ធផលនៃការអនុគ្រោះមិនជំនួសធម្មជាតិទេ ប៉ុន្តែលើកកម្ពស់វា។ ឧទាហរណ៍ ការសិក្សាពីការអនុគ្រោះ (Grace)ខ្លួនវា និងពីការផ្តល់គុណធម៌ តម្រូវឱ្យយល់ដឹងថា ព្រលឹងរបស់មនុស្សមាន

លក្ខណៈស្មារតី និងវាមានសេរីភាពជាមូលដ្ឋាន និងតម្រង់ឆ្ពោះទៅព្រះដែលជាគោលដៅចុងក្រោយឬខ្ពស់បំផុតរបស់មនុស្ស។ នៅក្នុងការបកស្រាយពីអាទិទេព (Christology) និយាយថា យេស៊ូគ្រិស្តជា "មនុស្សពិត" ទាមទារការយល់ដឹងត្រឹមត្រូវពីធម្មជាតិមនុស្ស។ ប្រសិនបើគេយល់អំពើបាបតាមបែបទេវវិទ្យា នោះគេត្រូវយល់ដឹងអំពីអំណាចឬសតិរបស់មនុស្ស ជាពិសេសឆន្ទៈនិងតណ្ហា និងមានពុទ្ធិគ្រប់គ្រាន់អំពីធម្មជាតិនៃកុសលនិងអំពើបាប។ ទីបំផុត ដើម្បីសិក្សាត្រីទេព (Trinity) និងអវតា (incarnation) ពុទ្ធិអំពីគំនិតនៃធម្មជាតិនិងមនុស្ស គឺមិនអាចខ្វះបាន។

**•ប្រសិនបើទេវវិទ្យាមិនចាត់ទុកជាពុទ្ធិអស្តិរូបវិជ្ជាទេ នោះវាមិនឈានដល់ឋានៈជាវិទ្យាសាស្ត្រមួយ និងភ្ញាត់ទៅក្នុងកំហុស និងភាពមិនច្បាស់លាស់**

ពុទ្ធិមានលក្ខណៈវិទ្យាសាស្ត្រពេលខ្លឹមសាររបស់វាមានលំដាប់ មានគ្រឹះហេតុផល និងបង្ហាញជាក់ច្បាស់ដែលវាបង្កើតជាប្រព័ន្ធសហទំនាក់ទំនងមួយ។ ចាប់តាំងពីទេវវិទ្យាត្រូវបានប្រើប្រាស់ពុទ្ធិធម្មជាតិទាក់ទងនឹងតថភាព វាប្រែក្លាយជាវិទ្យាសាស្ត្រមួយពេលពុទ្ធិនោះត្រូវបានធ្វើឱ្យសំបូរបែបជាមុនតាមរយៈវិទ្យាសាស្ត្រជាឧបករណ៍ គឺអស្តិរូបវិជ្ជា។ អស្តិរូបវិជ្ជាផ្តល់ភាពច្បាស់លាស់ដាច់ខាតចំពោះអត្ថន័យនៃសព្ទធ្ងន់តាមពុទ្ធិ ឯកឯង។ ជាងនេះទៅទៀត ការបកស្រាយកំហុសនៃសិទ្ធាន្ត (dogma)ក្នុងដំណើរប្រវត្តិសាស្ត្រ ចាប់បង្ខំឱ្យទេវវិទ្យាស្វែងរកភាពជាក់ច្បាស់ខាងនិរុត្តិសាស្ត្រនិងបញ្ញត្តិផ្តើមពីទស្សនៈអស្តិរូបវិជ្ជា។ ដូច្នេះ អ្វីដែលសម្រេចបានធ្ងន់តាមការខិតខំនេះ មិនអាចបោះបង់ចោលបានឡើយ ប្រសិនបើមិនប្រថុយនឹងការធ្លាក់ចូលសាជាថ្មីទៅក្នុងកំហុសដដែល។ ឧទាហរណ៍ សព្ទទាំងឡាយដូចជា "លទ្ធិប្រែក្លាយជារាងកាយនិងឈាមរបស់ព្រះគ្រិស្តតាមរយៈនំប៉័ងនិងស្រា (Tran substantiation) "ការឯកភាពបុគ្គល" (Hypostatic union) និង "រូបជាតុនិងទម្រង់របស់ពិធី" មិនអាចជំនួសបានទាំងស្រុង ព្រោះវាបង្ហាញច្បាស់នូវន័យពិតនៃជំនឿសាសនា ម្ល៉ោះហើយការរើកចេញពីជំនឿសាសនាត្រូវជៀសវាង។

ក្រៅពីនេះ អស្តិរូបវិជ្ជា គឺចាំបាច់ដើម្បីយល់ដឹងវិញ្ញត្តិ (Expression) របស់សិទ្ធាន្ត (dogma) ដែលស្នើឡើងដោយការបង្រៀនរបស់អាជ្ញាធរគ្រិស្តសាសនា។ ទីបំផុត យើងក៏ត្រូវរំលឹកថា គោលជំនឿប្រើប្រាស់សព្ទជាក់លាក់ជាច្រើនដែលយល់ដឹងកាន់តែល្អឡើងធ្ងន់តាមការជួយនៃ វិទ្យាសាស្ត្រអស្តិរូបវិជ្ជាដែលមានលក្ខណៈជាឧបករណ៍។

## គន្ថនិទ្ទេស


១-ខ្មៅ សាវនៈ ***អស្តិរូបវិជ្ជា*** បកប្រែ ឆ្នាំ២០១៥

២-ជួន ណាត៖ ***វចនានុក្រមខ្មែរ*** ភ្នំពេញ ការផ្សាយរបស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ គ.ស. ១៩៦៧

៣-វិទ្យាស្ថានជាតិខេមរយានកម្ម៖ ***ទស្សនវិជ្ជា ថ្នាក់បញ្ចប់*** ភ្នំពេញ ១៩៧៤

៤-Mariano Artigas, Introduction to Philosophy, 1984, Sinag Publishers, Inc, Manila.

៥-Venancio B. Ardales, Introduction Text to Philosophy,1987, New York.

# ទស្សនវិជ្ជាហិណ្ឌូ៖ ទ្រឹស្តីសំសារៈនិងមោក្ស

*ដោយ៖* **បណ្ឌិត ប៉ាន់ ឧត្តា**

*ប្រធានស្តីទីនាយកដ្ឋានទស្សនវិជ្ជានិងសង្គមវិជ្ជា*
*នៃវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*

## ១- ទ្រឹស្តីនៃការចាប់កំណើតជាថ្មី

*ខ្លឹមសារសំខាន់ៗជាមូលដ្ឋានក្នុងទស្សនវិជ្ជាហិណ្ឌូ បង្ហាញពីគំនិតស្តីអំពីវដ្តគ្មានទីបញ្ចប់នៃការកើតនិងការស្លាប់។ វដ្តគ្មានទីបញ្ចប់នៃការកើត និងការស្លាប់ គេហៅថា សំសារៈ* (samsara) *ឬ វាលវដ្តសង្សារ។ វាលវដ្តសង្សារ មានការផ្សារភ្ជាប់ជាមួយនឹងគំនិតទស្សនវិជ្ជាស្តីពី កម្ម* (karma) *ឬ អំពើ។ វាជា កម្ម ឬ អំពើ របស់យើងដែលកំណត់ថា តើយើងនឹងកើតឡើងវិញជាមនុស្ស ឬ ជាសត្វ (ដូចជាសត្វក្អែ ឆ្មា ថ្លៃន បង្គួយ ជីងចក់ ...) ពោលគឺ ពីក្នុងចំណោមរាប់លាននៃលទ្ធភាពគួរឱ្យសង្វេគ !*

***កម្ម*** (karma) *ត្រូវបានគេចាត់ទុកថា ជាបញ្ញត្តិគន្លឹះក្នុងទស្សនវិជ្ជាហិណ្ឌូ។ ទស្សនវិជ្ជាហិណ្ឌូទាំងមូលវិលជុំវិញបញ្ហានៃកម្ម។ ពាក្យដែលហៅថា កម្ម ជាផ្លូវនៃការគិតបើកចំហទាំងពីរ គឺទាំងបញ្ហាសីលធម៌ និងទាំងបញ្ហាអស្តិរូបវិជ្ជាឬបរមត្ថវិជ្ជាក្នុងទស្សនវិជ្ជា។ នេះគឺដោយសារពាក្យ កម្ម ទាក់ទងយ៉ាងជិតស្និទ្ធទៅនឹងជំនឿស្តីពីការចាប់កំណើតជាថ្មី ការកើតឡើងវិញ ហើយនិងគំនិតស្តីពី ហេតុ-ផល សីលធម៌។ អ្វីៗទាំងអស់ ធ្វើដំណើរទៅរកល្អដោយសារភាពល្អ ហើយទៅរកអាក្រក់ដោយសារភាពអាក្រក់។ រាល់សេចក្តីទុក្ខវេទនា និងអសុក្រឹតភាពទាំងអស់ក្នុងលោក គឺជាលទ្ធផលនៃអំពើរបស់បុគ្គលម្នាក់ៗ។ ប៉ុន្តែ អ្វីដែលល្អ និងអាក្រក់នឹងត្រូវបានកំណត់មួយផ្នែក ដោយសារទីតាំងវណ្ណៈពិតរបស់មនុស្សម្នាក់ៗ។ ដូច្នេះ ទស្សនវិជ្ជាហិណ្ឌូ អាចត្រូវបានគេនិយាយថា ជាទស្សនវិជ្ជាមួយធ្វើឱ្យប្រព័ន្ធវណ្ណៈត្រឹមត្រូវតាមច្បាប់៖ មនុស្ស សក្តិសមនឹងទទួលនូវវណ្ណៈបច្ចុប្បន្នរបស់គេ ពីព្រោះ ឋានៈវណ្ណៈរបស់មនុស្សម្នាក់ៗ គឺជាវិបាកនៃអំពើពីមុនៗរបស់មនុស្សនោះ។ បញ្ញត្តិស្តីពី កម្ម បានរកឃើញនូវវិញ្ញត្តិរបស់វានៅក្នុងភាសិតនានា ដូចជា មនុស្សម្នាក់ៗជាអ្នកកសាងនូវអនាគតរបស់គេ ឬគេបានធ្វើគ្រែរបស់គេ ហើយឥឡូវនេះ គេត្រូវតែដេកនៅលើគ្រែនោះ។*

*នៅក្នុងទស្សនវិជ្ជាហិណ្ឌូ អំពើប្រកបដោយសីលធម៌ ចងភ្ជាប់ជាមួយនឹងវដ្តនៃការរស់-ការស្លាប់-ការរស់-ការស្លាប់...។ អំពើ និង តណ្ហា គឺជាបញ្ហាសំខាន់។ ទ្រឹស្តីស្តីអំពីការចាប់កំណើតឡើងវិញ និយាយថា ទម្រង់នៃអត្តិភាពរបស់យើងនៅជាតិក្រោយ គឺជា*

ការទុះបញ្ចាំងនៃអំពើ និងតណ្ហា របស់យើង ក្នុងជាតិនេះ។ គំនិតស្តីពីការចាប់កំណើតឡើងវិញ និងប្រព័ន្ធវណ្ណៈ បង្កើតបានជាអង្គឯកភាព ដែលមានទំនាក់ទំនងគ្នាមួយដ៏រលូនក្នុងទស្សនវិជ្ជាហិណ្ឌូ។ នៅក្នុងរចនាសម្ព័ន្ធនេះ សីលធម៌ និងប្រព័ន្ធសង្គម គាំទ្រគ្នាទៅវិញទៅមក។

## ២-ទ្រឹស្តីនៃការរំដោះកម្ម

***តើយើងអាចរំដោះចេញពីចំណង់ និងការត្រួតពិនិត្យពីលើ កម្ម ដូចម្តេច?***

*នៅក្នុងទស្សនវិជ្ជាហិណ្ឌូ វដ្តនៃជីវិត និងការស្លាប់ គឺជាអ្វីដែលគេត្រូវតែគេចចេញឱ្យផុតពីវា ពោលគឺ ស្វែងរកការរំដោះឱ្យផុតពីវដ្តមិនចេះចប់នៃការកើត និងការស្លាប់ ដែលគេហៅថា មោក្ស*(moksha)។

*ខ្លឹមសារក្នុងទស្សនវិជ្ជាហិណ្ឌូ បានសន្មតថា អត្ម័ន(ព្រលឹងមនុស្សម្នាក់ៗ) ជាសារធាតុបិតថេរ ហើយ អាត្ម័ន មានទំនាក់ទំនងនឹងព្រហ្ម័ន(ព្រលឹងសាកល)។ បញ្ញត្តិព្រហ្ម័ន ៖ មានន័យថា អ្វីៗដែលជាមូលដ្ឋាន*(The Absolute) *ឬ ការរាប់បញ្ចូលទាំងអស់*(The all-Encompassing) *ឬ ភាពជាអាទិទេព* (The Divine)។

*មោក្ស* (moksha) *គឺជាការផ្តាច់អាត្ម័នចេញពីវាលវដ្តសង្សារ ឬបញ្ចប់ការវិលកើត-ស្លាប់-កើត-ស្លាប់ ជម្រះអស់នូវកម៌ និងចាកចេញពីចំណង់គ្រប់ប្រការដែលកើតឡើងដោយសារការផ្សំសំខតធាតុ រួចចាក នូវអបាយមុខ ការឈឺចាប់សព្វយ៉ាង និងអវិជ្ជា។ កាលណាគេសម្រេចបាននូវមោក្ស ពេលនោះ អាត្ម័ន នឹងវិលទៅជួបនឹងព្រហ្ម័នវិញ។*

*ទស្សនវិជ្ជាអប់រំក្នុងសាសនាហិណ្ឌូ បានអប់រំមនុស្សនៅលើផែនដីនេះ គឺធ្វើយ៉ាងណាដើម្បីឱ្យ ជីវិតរបស់ខ្លួនកាន់តែមានភាពសុក្រឹត និងកាន់តែក្លាយជាមនុស្សពិតប្រាកដ។*

*នៅក្នុងទស្សនវិជ្ជាហិណ្ឌូចាត់ទុក ភ្លើងជានិមិត្តរូបនៃចំណេះដឹង។ ចំណង់របស់យើងត្រូវតែត្រូវបានប្រើប្រាស់ក្នុងភ្លើងនៃចំណេះដឹង ដែលអាចកើតមានឡើងឆ្លងតាមរយៈយោគៈ* (yoga)។ *ពួកគេមានជំនឿថា សច្ចភាព មិនមែនចេញមកពីខាងក្រៅនោះ ទេ ពោលគឺ មិនមែនចេញមកពីក្នុងអត្ថបទទេ វានៅខាងក្នុងខ្លួនអ្នក។ អ្នកត្រូវតែខិតខំរៀនសូត្រដើម្បីស្វែងរកដោយខ្លួនអ្នកផ្ទាល់។ គេអាចរៀនអំពីជំនឿខាងអធិម្មជាតិនិយម ក៏ប៉ុន្តែ នោះវាមិនដូចគ្នាទៅនឹងការមើលធ្លុះស៊ីជម្រៅបែបអធិធម្មជាតិទេ។ ការមើលធ្លុះស៊ីជម្រៅនេះ អាចធ្វើឱ្យសម្រេចបានដោយខ្លួនឯង និងឆ្លងតាមការខិតខំផ្ទាល់ខ្លួនតែប៉ុណ្ណោះ។*

*អ្នកទាំងឡាយណាដែលប្រើប្រាស់ភ្លើងដឹកនាំការរំដោះខ្លួនគេឱ្យរួចផុតពី កម្ម អាចសម្រេចបាននូវការសង្គ្រោះចុងក្រោយ*

(មោក្ស-moksha)។ ការប្រើប្រាស់ភ្លើង ដឹកនាំការរំដោះខ្លួនពី កម្ម គឺមានទាំងពីរ ទាំងធ្វើនូវអ្វីៗដែលល្អ និងទាំងប៉ងប្រាថ្នានូវអ្វីដែលល្អ នឹងក្លាយទៅជាសត្វលោកដ៏ល្អ ឬនឹងឡើងទៅក្នុងវណ្ណៈដែលខ្ពស់ជាង។ ភ្លើងជួយយើងឱ្យមើលធ្លុះស៊ីជម្រៅបានយ៉ាងត្រឹមត្រូវ និងផ្តល់នូវមូលដ្ឋានសម្រាប់ធ្វើអំពើនៅក្រៅព្រំដែននៃចំណង់។ ការរំដោះឱ្យមានសេរីភាព ត្រូវមានការត្រួតពិនិត្យទៅលើអំពើរបស់គេ។ កាលណាគំនិតទាំងអស់របស់មនុស្សម្នាក់ គ្មានទាំងហេតុជំរុញ គ្មានទាំងចំណង់ គ្មានទាំងលោភលន់ ពោលគឺការងាររបស់គេកើតចេញពីភ្លើងនៃគតិបណ្ឌិតខាងក្នុង នោះគេហៅគាត់ថា ជាបណ្ឌិតដែលបានរៀនចេះដឹង[1]។ ប៉ុន្តែ នៅខណៈពេលជាមួយគ្នានោះដែរ ការរំដោះឱ្យមានសេរីភាព មានទំនាក់ទំនងជាមួយនឹងអំពើ អហិង្សា(Ahimsa) និង ខន្តី។

សាសនាហិណ្ឌូ រកឃើញថា ការធ្វើឱ្យសក្តានុពលរបស់មនុស្សក្លាយជា អំពើ គឺបិតនៅក្រោមការធ្វើ យោគៈ។ យោគៈ គឺជាវិធីដែលរៀបចំឡើងដើម្បីដឹកនាំទៅកាន់គោលបំណងចុងក្រោយ គឺទៅជួបអាទិទេព។ មានយោគៈ(មគ្គៈ)៤ ទៅកាន់គោលបំណងតែមួយ។ ប៉ុន្តែ សម្រាប់ពួកគេ វាគ្រាន់ តែជាយុទ្ធវិធីដែលមានលក្ខណៈផ្សេងៗគ្នាក្នុងការធ្វើដំណើរទៅរកការរំដោះតែប៉ុណ្ណោះ។ គ្រប់យោគៈ ទាំង៤ ចាប់ផ្តើមជាមួយសីលធម៌ជាមូលដ្ឋាន។ គោលបំណងនៃការបំពេញយោគៈ គឺ រំលេចនូវ អត្តបរិសុទ្ធ ហេតុនេះ ស្រទាប់ខាងក្រៅដែលបិទបាំង អត្តៈបរិសុទ្ធ ត្រូវតែដកចេញ នោះគឺ អត្តទត្តនិយម និង ឆន្ទៈមិនត្រឹមត្រូវ លោភៈ ទោសៈ អវិជ្ជា ត្រូវបានដកចេញ។ ហេតុនេះ គ្រប់ យោគៈ ទាំងអស់ចាប់ផ្តើមជាមួយការបំផ្លាញទម្លាប់មិនល្អ ទទួលយកទម្លាប់ល្អ មិនលួច គ្មានការឈឺចាប់ មានជំនឿ ស្វ័យគ្រប់គ្រង ភាពស្អាតស្អំ មានវិន័យ មានចំណង់ទៅដល់គោលដៅ[2]។

## ៣-មគ្គដឹកនាំអាត្ម័នទៅជួបព្រហ្ម័ន

### *ក- មគ្គៈទៅកាន់អាទិទេពតាមរយៈបញ្ញាយោគៈ*

បញ្ញាយោគៈ គឺជាយោគៈដ៏ចម្បងក្នុងចំណោមយោគៈទាំង៤ ដែលដឹកនាំទៅកាន់អាទិទេព តាមរយៈពុទ្ធិ និងការវិភាគប្រកបដោយបញ្ញា។ ពុទ្ធិនេះ មិនទាក់ទងទៅនឹងពិភពជាក់ស្តែងទេ វាជាវិចារណញាណសុទ្ធសាធ។ តាមរយៈការវិភាគប្រកបដោយបញ្ញា ទើបយើងទទួលបាននូវពុទ្ធិពិត។ យោគៈនេះ មិនត្រឹមតែតម្រូវឱ្យមានការគិតប្រកបដោយភាពច្បាស់លាស់ប៉ុណ្ណោះទេ តែថែមទាំងឱ្យចេះផ្តាច់ខ្លួនពីពិភពខាងក្រៅនេះ

---

[១] ភគវត្គដគត: (Bhagavad-Gita), Book IV, §19, ទំព័រ ២៦៨។

[២] Huston Smith : ***The Illustrated World's Religion***, A Guide to Our Wisdom Tradition,
Harper San Francisco, New York, 1994, p. 26-39.

ថែមទៀតផង។ ហ៊ូស្តុន ស្មីត (Huston Smith) ពិពណ៌នាពុទ្ធិនេះថា ជាអំណាចដើម្បីញែកអត្តៈខាងក្រៅ និងរំលេចនូវអត្តៈបរិសុទ្ធខាងក្នុងអាត្ម័ន។ តាមរយៈការវិភាគប្រកបដោយបញ្ញា ឬវិចារណញាណ៖ វាញែកអត្តៈក្នុងខ្លួនមនុស្សម្នាក់ៗចេញពីអត្តខាងក្រៅខ្លួន ហើយក្នុងពេលតែមួយ ជំរុញឱ្យអត្តៈក្នុងខ្លួននេះទៅកាន់កម្រិតដ៏ជ្រៅតាមរយៈពុទ្ធិ ដែលភាវៈអាត្ម័ន និង ភាវៈព្រហ្ម័ន មានលក្ខណៈដូចគ្នាតែមួយ(ម្នាក់ៗក្លាយជាអ្វីមួយ ដែលក្នុងបេះដូងរបស់គេចង់ទៅជា...) ជាចុងក្រោយ ភាវៈសតិ ធ្លុះបញ្ចាំង ភាវៈពិត នឹងមានការត្រាស់ដឹង។ ហេតុនេះ នៅក្នុង បញ្ញាយោគៈ គ្រប់អវិជ្ជាទាំងអស់ត្រូវបានជំនះ ហើយចុងបញ្ចប់តែមួយគត់ដែលអាចកើតឡើង គឺការជួបគ្នារវាង អាត្ម័ន និង ព្រហ្ម័ន។

### ខ- មគ្គៈទៅកាន់អាទិទេពតាមរយៈករុណាឬភក្តីយោគៈ

ដោយសារមនុស្សមានទាំងវិចារណញ្ញាណ និងមនោសញ្ចេតនា ហើយពេញមួយជីវិតមនុស្ស មនោសញ្ចេតនាមានតួនាទីយ៉ាងសំខាន់ ហេតុនេះ មនុស្សត្រូវចាប់ផ្តើមជាមួយមនោសញ្ចេតនា។ លក្ខណៈដ៏សំខាន់នៃមនោសញ្ចេតនារបស់មនុស្សដែលមានពីធម្មជាតិគឺ ករុណា ឬ សេចក្តីស្រឡាញ់។ ការប្រតិបត្តិ ករុណា នេះនៅក្នុងជីវិត គេហៅថា ភក្តីយោគៈ។ សាសនាហិណ្ឌូអប់រំយើងឱ្យជឿថា យើងអាចទៅជួបព្រះអាទិទេពតាមរយៈការប្រកាន់យកករុណា។ ករុណា គឺអាចភ្ជាប់ប្រធានវិស័យភាព(មនុស្ស) ទៅនឹងវត្ថុវិស័យភាព(ព្រះ) ក្នុងន័យថា វាគឺជាលក្ខខណ្ឌគ្រប់គ្រាន់ និងចាំបាច់សម្រាប់ធ្វើ ឱ្យអ្វីដែលអ្នកមានករុណាចង់ស្វែងរក អាចសម្រេចទៅបាន។ គោលបំណងចុងក្រោយតែមួយគត់ ដែលអ្នកមានករុណាស្វែងរក គឺប្រភេទមួយនៃការរំដោះ នោះគឺទៅជួបព្រះអាទិទេព។

### គ-មគ្គៈទៅកាន់អាទិទេពតាមរយៈការធ្វើសកម្មភាពក្នុងចិត្តឬកម៌យោគៈ

សកម្មភាព នៅទីនេះ មិនត្រូវបានយល់ក្នុងន័យធម្មតារបស់វាទេ។ ក្នុងន័យធម្មតា គ្រប់សកម្មភាពទាំងអស់ជាអំពើដែលស្តែងចេញតាមរយៈកាយវិការដែលជាវេទយិតភាព។ កម៌យោគៈ ជាសកម្មភាពគ្មានអំពើ (Actionless action) ជាសកម្មភាពដែលធ្វើនៅក្នុងអព្ភន្តរញាណ ឬវិចារណញាណ៖ មិនធ្វើអ្វីៗទាំងអស់ ប៉ុន្តែអ្វីៗបានធ្វើរួចពាល់ហើយ។ កម៌យោគៈ ជាសកម្មភាពលុបបំបាត់អត្តទត្ត តណ្ហាគ្មានព្រំដែន លោភៈ ទោសៈ។ ក្នុងសៀវភៅ Batagavad Gita លោក ហ៊ើរម៉ាន់(A.L. Herman)បានដកស្រង់អត្ថន័យអប់រំមួយមកសរសេរថា៖ សូមឱ្យការបារម្ភរបស់អ្នកផ្តោតលើសកម្មភាពតែមួយគត់ ហើយកុំផ្តោតជាមួយផលនៃ

សកម្មភាពនោះ។ កុំឱ្យផលនៃសកម្មភាពរបស់អ្នក ចេញពីកម្លាំងជំរុញរបស់អ្នក ហើយក៏មិនត្រូវមិនធ្វើសកម្មភាពដែរ ។ ឃ្លានេះមានអត្ថន័យអប់រំថា ចូរយើងដកចំណង់ចេញពីលទ្ធផលនៃសកម្មភាពរបស់យើង នៅពេលនោះ ទ្រឹស្តីកម្ម មិនអាចប្រព្រឹត្តទៅសាចុះសាឡើងបានទេ ហេតុនេះ សកម្មភាពរបស់យើងមិនអាចដឹកនាំទៅកាន់ការចាប់កំណើតថ្មីឡើងវិញទេ។ សកម្មភាពបែបនេះ ដឹកនាំការរំដោះ នឹងនាំ អាត្ម័ន ឱ្យទៅជួបព្រហ្ម័ន(អាទិទេព)វិញ។

### ឃ- មគ្គៈទៅកាន់អាទិទេពតាមរយៈការហ្វឹកហ្វឺនរូបកាយ-ចិត្ត

គោលបំណងនៃ យោគៈ គឺស្វែងរកឱ្យឃើញភាវៈខ្លួនវា ហេតុនេះ អាត្ម័ន របស់មនុស្សម្នាក់ៗនឹងបានជួប ព្រហ្ម័ន។ ក្នុងការបំពេញយោគៈនេះ គេសង្កេតឃើញមាន៨ ជំហានដែលត្រូវធ្វើ៖

- ជំហានទី១ ទាក់ទងទៅនឹងសីលធម៌ជាមូលដ្ឋាន។ វាត្រូវចាប់ផ្តើមពីបុរេលក្ខខណ្ឌខាងសីលធម៌ ដែលត្រូវឱ្យកាយនិងចិត្តមានភាពស្រុះស្រួលក្នុងខ្លួន។

- ជំហានទី២ ទាក់ទងទៅនឹងសីលធម៌ជាមូលដ្ឋាន។ វាត្រូវចាប់ផ្តើមពីបុរេលក្ខខណ្ឌខាងសីលធម៌ ដែលត្រូវឱ្យកាយនិងចិត្តមានភាពស្រុះស្រួលជាមួយបរិស្ថានដែលកាយនិងចិត្តតាំងនៅ។

- ជំហានទី៣ គឺការធ្វើយោគៈរូបកាយ គោលបំណងរបស់វាគឺ ស្វែងរកជំហមួយ ដែលពេលនោះការប្រតិបត្តិខាងការសញ្ជឹងគិត មិនបានរំខានដោយរូបកាយ។

- ជំហានទី៤ គឺការគ្រប់គ្រងដង្ហើម ការប្រតិបត្តិនេះ មានលក្ខណៈសំខាន់បំផុត ពីព្រោះដង្ហើមជះឥទ្ធិពល យ៉ាងខ្លាំងទៅលើគំនិត និងការរំដើបរំជួលខាងផ្លូវចិត្តរបស់មនុស្ស។

- ជំហានទី៥ គឺការសញ្ជឹងគិត ការដកវិញ្ញាណទាំងអស់ចេញពីអង្គវិញ្ញាណ។

- ជំហានទី៦ ទោះបីជាអ្នកធ្វើយោគៈ ផ្តោតអារម្មណ៍លើសតិបានមូលក៏ដោយ ប៉ុន្តែអ្វីៗមិនទាន់បញ្ចប់ទេ សតិពេលនេះ គឺជាកញ្ចក់ឆ្លុះបញ្ចាំងពីតថភាព ហេតុនេះ សតិត្រូវសម្រេចថា យល់ព្រម ឬបដិសេធទំនាក់ទំនងជាមួយអង្គវិញ្ញាណទាំងអស់។

- ជំហានទី៧ គឺជាដំណាក់កាលភ្ជាប់សតិ និង វត្ថុវិស័យភាព ដោយមិនឆ្លងកាត់អង្គវិញ្ញាណ។

- ជំហានទី៨ គឺ សមាធិ ដែលពេលនេះពហុភាព និងពិភពដែលបង្ហាញនៅមុខយើង លែងមានសុពលភាពទៀតហើយ វាជាដំណាក់កាលដែល សតិ ធ្វើការពិចារណាឆ្លុះបញ្ចាំង រិះគន់ ប្រឌិតញាណ នៅ ...ក្នុងវត្ថុវិស័យភាព។ ពេលនេះតថភាពនៃសារធាតុ សារជាតិ រចនាសម្ព័ន្ធ ដំណើរ

ប្រព្រឹត្តទៅ និងអាចកំបាំងនៃវត្ថុវិស័យ... ភាពត្រូវបានត្រាស់ដឹង[3]ៗ

សាសនាហិណ្ឌូអប់រំចំពោះមនុស្សទាំងអស់ឱ្យជឿថា ម្នាក់ៗអាចចាប់យកមគ្គៈឬយោគៈ ណាមួយដែលសមស្របសម្រាប់ខ្លួន ដើម្បីដឹកនាំខ្លួនទៅរកសេចក្តីសុខក៏បាន ព្រោះ យោគៈទាំងអស់ គឺដឹកនាំទៅកាន់ការរំដោះ(គោលបំណងចុងក្រោយ)ដូចៗគ្នា។ លោក ហ៊ឺមាន់(A.L. Herman) អះអាងថា ភក្តិយោគៈ គេបង្កើតឡើងសម្រាប់បម្រើវណ្ណៈទាបពីរផ្សេងទៀតផងដែរគឺ សូទ្រៈ និងវៃស្យៈ ជាពិសេស ចំពោះ ស្ត្រី ពីព្រោះ ស្ត្រីគេមិនឱ្យតម្លៃទេកន្លងមក។ គាត់ស្រង់ពី Bhagavad Gita ៖ អារហ្ជុណា(Arjuna) អ្នកត្រូវមើលឃើញថា អ្នកដែលបូជាចំពោះយើង គឺមិនដែលស្លាប់នោះទេ ចំពោះអ្នកដែលគោរព និងមានភក្តីចំពោះយើង ទោះបីជាគេកើតចេញពីផ្ទៃរបស់អ្នកសាងបាបក៏ដោយ ទោះបីគេជាស្ត្រីក៏ដោយ ជាវណ្ណៈវៃស្យៈ ឬជាវណ្ណៈសូទ្រៈ ពួកគេនឹងទៅកាន់គោលបំណងដ៏ខ្ពស់។ ប៉ុន្តែទោះបីជាយ៉ាងនេះក៏ដោយ យោគៈទាំង៤ មិនអាចផ្តាច់ចេញពីគ្នាទាំងស្រុងនោះទេ ដោយហេតុថា វាគ្មានបុគ្គលណាម្នាក់ មានតែការធ្ងុះបញ្ចាំងមនោសញ្ចេតនា សកម្មភាពឬការពិសោធន៍ខាងរូបកាយ-ចិត្តទាំងស្រុងនោះទេ ហើយស្ថានភាពនៃដំណាក់កាលជីវិតផ្សេងគ្នា ទាមទារឱ្យមានការស្វែងរកយោគៈផ្សេងគ្នាដែរ។ បុគ្គលជាច្រើនយល់ឃើញថា យោគៈ មួយជាក់លាក់ក៏អាចជួយពួកគេឱ្យទៅកាន់ការរំដោះ ហេតុនេះ បុគ្គលនោះគួរតែបន្តទៀតគ្មានបញ្ហាអ្វីទេ។ ប៉ុន្តែសាសនាហិណ្ឌូជំរុញឱ្យមនុស្សសាកល្បងយោគៈទាំង៤ ហើយបញ្ចូលគ្នាក្នុងរបៀបមួយដែលពួកគេគិតថាមានប្រសិទ្ធភាពបំផុត[4]ៗ

មគ្គទៅកាន់មោក្សៈនេះ និងដឹកនាំមនុស្សសម្រេចបានទូវវត្ថុ៤យ៉ាងគឺ ៖

១- ភាពរីករាយ សេចក្តីសុខ សុភមង្គល

២-ជោគជ័យនៅលើផែនដី (អាចមានទម្រង់ជាទ្រព្យសម្បត្តិ កិត្តិយ និងអំណាច)

៣- កាតព្វកិច្ចចំពោះសហគមន៍ និងចុងក្រោយគឺ

៤- ការរំដោះ[5]ៗ

---

៣ Huston Smith : **The Illustrated World's Religion**, p. 34.

៤ Huston Smith : ***The Illustrated World's Religion***, p. 38.

៥ Huston Smith : ***The Illustrated World's Religion***, A Guide to Our Wisdom Tradition, Harper San Francisco, New York, 1994, p. 18-22.

## ឯកសារពិគ្រោះ

1-Huston Smith : ***The Illustrated World’s Religion***, A Guide to Our Wisdom Tradition, Harper San Francisco, New York,.

2-ភគវទ្គីតា: ( Bhagavad-Gita ), Book IV.

3-A.L. Herman : ***A Brief Introduction to Hinduism***,.

# ទស្សនៈ និងជំនឿតូតឹមនិយមរបស់ជនជាតិខ្មែរ

## (ទស្សនៈ និងជំនឿលើសត្វ)

*ដោយ៖* **បណ្ឌិត ប៉ាន់ ឧត្ដា**
*ប្រធានស្ដីទីនាយកដ្ឋានទស្សនវិជ្ជានិងសង្គមវិជ្ជា*
*នៃវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*
*រាជបណ្ឌិត្យសភាកម្ពុជា*

**សេចក្ដីផ្ដើម**

*ជំនឿតូតឹម គឺជាជំនឿលើសត្វ និងជំនឿលើដើមឈើ តែក្នុងអត្ថបទនេះខ្ញុំលើកយកតែជំនឿលើសត្វមកបង្ហាញតែប៉ុណ្ណោះ។ ការគោរពសត្វពុំមានន័យថា គោរពសត្វក្នុងឋានៈជាសត្វនោះទេ តែជានិម្មិតរូបក្នុងក្របខណ្ឌទស្សនៈនិងជំនឿ។*

*គេចែកសត្វជា៖ សត្វអច្ឆរិយ ដែលមានប្រវត្តិក្នុងទេវកថាឬគម្ពីរសាសនា សត្វដែលអ្នកស្រុកបានផ្សាំងឬចិញ្ចឹមសម្រាប់យកសាច់បរិភោគ និងសត្វព្រៃ។ សត្វទាំង៣ប្រភេទនេះ ត្រូវបានគេគូរជាគំនូរឬឆ្លាក់សម្រាប់តុបតែង លំអ និងជានិម្មិតរូបគោរពសក្ការៈ។ វត្តមានគំនូរ និងចម្លាក់សត្វ សរបញ្ជាក់ថា ខ្មែរបុរាណផ្សារភ្ជាប់ខ្លួនជាមួយបរិស្ថានដែលស្ថិតនៅជុំវិញខ្លួន ដែលជានិមិត្តរូបនៃថាមពលធម្មជាតិ និងជាឫសកែវនៃជីវិត។ បរិស្ថាន មនុស្ស សត្វ រុក្ខជាតិ មានអន្តរទំនាក់ទំនងគ្នា និងទ្រទ្រង់ស្ថេរភាពបរិស្ថាន។ ទន្ទឹមនឹងនេះដែរ រូបសត្វទាំងអស់នោះក៏ឆ្លុះបញ្ចាំងឱ្យយើងឃើញនូវជំនឿសាសនារបស់ជនជាតិខ្មែរនាសម័យបុរាណដែរ។ ខ្មែរមានជំនឿលើសត្វ ជាដើមសន្តតិវង្ស ជាព្រះអាទិទេព ជាអវតាររបស់អាទិទេព ជាអ្នកនាំសាររវាងមនុស្សនិងអាទិទេព ជាយានជំនិះរបស់ព្រះអាទិទេព ជាភាវៈមានអំណាចស័ក្ដសិទ្ធិដែលគួរឬត្រូវគោរពបូជា ជាភាវៈនាំមកនូវប្រផ្នូលល្អឬអាក្រក់...។ សត្វទាំងនោះមានជាអាទិ៖ នាគ ក្រពើ អណ្ដើក ត្រី គោ ក្របី តោ ខ្លា ដំរី គ្រុឌ ហង្ស លលកខ្មោច ខ្ទែងស្រាក។ល។*

*ក្នុងទស្សនៈខ្មែរយើងចាត់ទុក ត្រី កង្កែប ហ៊ីង គីង្គក់ នាគ ...ជាសត្វតំណាង ភ្លៀង និងទឹក។ ចាបឬបក្សី តំណាង ខ្យល់ ឬ អាកាស។ សត្វជើងបួនដូចជា គោ ក្របី តំណាង ដី។ ដូច្នេះក្នុងទស្សនៈខ្មែរ សត្វ តំណាងនូវឥទ្ធិពលនៃធម្មជាតិ ដែលជាប្រភពនៃជីវិត និងទ្រទ្រង់ជីវិត។ ក្នុងជំនឿតូតឹមនេះទៀតសោត គឺគេជឿលើសត្វទាំងមូល ឬគ្រាន់តែជាភាគណាមួយនៅលើខ្លួនសត្វ ដូចជា ស្នែង ក្លុក ចង្កូម ខ្នាយ*

ចៃ ឬសម្រែកយំ ឬលក្ខណៈភិនភេទរបស់សត្វជាដើម។

ក្នុងព្រហ្មញ្ញសាសនា និង ពុទ្ធសាសនា ក៏មានជំនឿទាក់ទងនឹងសត្វដូចគ្នានឹងគំនិតខ្មែរដើម ហេតុនេះ នៅពេលសាសនាទាំងពីរនាំចូលពីឥណ្ឌាមកដល់កម្ពុជា មានលំនាំនៃជំនឿប្រហាក់ប្រហែលគ្នា ខ្មែរក៏ទទួលយកមកស្របញ្ចូលគ្នាទៅជាគំនិតទស្សនវិជ្ជាខ្មែរ ហើយមានអត្ថិភាពតាំងពីបុរាណកាលរហូតមកដល់សព្វថ្ងៃនេះ។ ក្នុងព្រហ្មញ្ញសាសនា គេចាត់ទុកសត្វ ជាអវតារបស់អាទិទេពជាយានជំនិះរបស់អាទិទេព។ ក្នុងពុទ្ធសាសនា ក៏បានផ្សារភ្ជាប់ប្រវត្តិព្រះពុទ្ធទាំង៥អង្គ មានរូបតំណាងព្រះពុទ្ធអង្គនីមួយៗក្រោមរូបភាពជាសត្វ ជាអវតា និងជាយានជំនិះរបស់ព្រះពុទ្ធផងដែរ។

## ១. ទស្សនៈ និងជំនឿរបស់ខ្មែរអំពីសត្វ

### ១. ១. នាគ

ការគោរពសត្វនាគ ពុំមានន័យថាគោរពសត្វនាគក្នុងឋានៈជាសត្វនោះទេ តែជានិមិត្តរូបនៃសត្វនេះតំណាងទៅវិញ។ ខ្មែរមានជំនឿទៅលើសត្វនាគ ដោយគេយល់ថា បុព្វបុរសរបស់ខ្លួនមានអំបូរមកពីនាងនាគ។ ទស្សនៈ និងជំនឿលើសត្វជាដើមសន្តតិវង្សនេះស្របជាមួយទ្រឹស្តីវិទ្យាសាស្ត្ររបស់ដីវិទូដាកវីន (Darwin) ដែលបានពន្យល់បកស្រាយថា ៖ នៅក្នុងចក្រវាឡ ចលនានៃលោកធាតុទឹក ដី ភ្លើង ខ្យល់ ក្នុងលក្ខខណ្ឌណាមួយនោះកកើតបានជាសត្វ និងរុក្ខជាតិថ្នាក់ទាប។ បន្ទាប់ការរស់នៅ និងការចិញ្ចឹមជីវិតតាមការប្រែប្រួលអាកាសធាតុ និងបាតុភូតធម្មជាតិ ពពួកសត្វតូចៗបានវិវត្តមកជាត្រីរស់នៅក្នុងទឹក។ ត្រីបានវិវត្តទៅជាពួកល្មូនអាចរស់នៅក្នុងទឹកក៏បាន រស់នៅលើគោកក៏បាន។ ដោយសារការស្វែងរកចំណីនៅទីឆ្ងាយ និងខ្ពស់ៗ ពពួកល្មូនបានវិវត្តដុះដៃ ដុះជើង រួញកន្ទុយ ចាប់ឈរជើង២ ហើយយកដៃបេះយកអាហារស៊ី។ មានល្មូនមួយក្រុមវិវត្តន៍មកជាស្វាអង់ត្រូប៉ូម័រ ហើយចុងក្រោយបានវិវត្តន៍មកជាមនុស្ស។

តាមរឿងព្រេង ព្រះថោង នាងនាគៈ នាគទាក់ទងនឹងកំណើតនៃព្រះរាជវង្សានុវង្សខ្មែរដំបូងបង្អស់។ នាគ ជានិម្មិតរូបនៃបុព្វការីជនខ្មែរ ពីព្រោះប្រជាជនខ្មែរតែងតែជឿជាក់ថាខ្លួនពិតជាបានជាប់តំណពូជព្រះញាតិវង្សព្រះនាងសោមា (ស្រីទេពអប្សរមេរា) និងព្រះញាតិវង្សសូរ្យវង្ស(ឥសីកម្ពុស្វយម្ភុវ:)។អាពាហ៍ពិពាហ៍រវាង សន្តតិវង្សព្រះអាទិត្យតំណាងស្តេចគ្រុឌ(ព្រះថោង) និងសន្តតិវង្សព្រះច័ន្ទតំណាងស្តេចនាគ (នាងនាគ)។ ក្នុងសិល្បៈខ្មែរ ដែលឆ្លាក់នាគ និងគ្រុឌនៅជាមួយគ្នា តំណាងបដិសំយោគរវាងធាតុញី-ឈ្មោលស្រី-ប្រុសទឹក-ដី ក្តៅ-ត្រជាក់។

ក្នុងទស្សនៈខ្មែរ សត្វនាគ ជាសត្វអច្ឆរិយៈ តំណាងព្រលឹងរបស់បុព្វបុរសខ្មែរដែលជាអ្នកបីបាច់ថែរក្សាការពារទឹកដីនៃនគរគោកធ្លក។ ជនជាតិខ្មែរចាត់ទុកស្តេចកុដុង្គនាគ គឺជាអ្នកដែលបានបង្កើតទឹកដី ដោយបានផឹកទឹកសមុទ្រឱ្យរីងស្ងួត ជាហេតុបណ្តាលឱ្យដីដុះលេចចេញកើតជានគរខ្មែរតរៀងមក (ក្នុងទស្សនៈខ្មែរ ឥន្ទធ្នូចម្រុះពណ៌ តំណាង ស្តេចនាគ ដែលចេញពីរន្ធក្រោមដី នឹងលូនឡើងទៅលើមេឃដើម្បីផឹកទឹក)។

រឿងព្រះថោងនាងនាគ បានបន្សល់ទុកនូវទស្សនវិជ្ជាជាច្រើន ហើយត្រូវបានអនុវត្តនៅក្នុងទំនៀមទម្លាប់ ប្រពៃណី នៅក្នុងពិធីរៀបអាពាហ៍ពិពាហ៍ គឺមានតាំងពីការស្លៀកពាក់ (ក្រឡាហូលឬខៀនដែលស្ត្រីខ្មែរស្លៀកលំអពងកាយជាតំណាងស្រកានាគ) របៀបរៀបចំពិធីហែគ្រឿងបណ្ណាការ (ឈរតកន្ទុយគ្នាពងជាសត្វនាគ) បទចម្រៀងនិងបទភ្លេងការ ការសែនព្រេនចងដៃឱ្យពរ បាចផ្កាស្លា គោងស្បែកូនក្រមុំ សូត្រមន្តចម្រើនព្រះបរិត បួងសួងបន់ស្រន់ អញ្ជើញអស់ឥន្ទព្រហ្ម ទេពតា អារុក្ខរក្សអ្នកតា ចាស់ទុំ យមរាជ ខ្មោចព្រាយបិសាចទាំងប៉ុន្មានសុទ្ធតែរំលឹកឈ្មោះព្រះថោង នាងនាគជាហូរហែ។ ក្នុងទស្សនៈខ្មែរ ព្រះថោងនាងនាគ បានក្លាយទៅជានិម្មិតរូបនៃការបង្កើតក្រុមគ្រួសារ កូនចៅ បន្តវង្សត្រកូល។

ក្រៅពីទស្សនៈចាត់ទុកនាគជាបុព្វបុរស ខ្មែរក៏បានចាត់ទុកសត្វនាគ ជានិម្មិតរូបដ៏សំខាន់ក្នុងជំនឿសាសនាផងដែរ។ សត្វនាគ ត្រូវបានខ្មែរចាត់ទុកថា ជាអាទិទេពមួយយ៉ាងសំខាន់បំផុតនាសម័យបុរេប្រវត្តិសាស្ត្រ ដោយហេតុថា សត្វនេះជានិម្មិតរូបនៃធាតុទឹក ដែលជាមូលដ្ឋាននៃជីវិតឬជាជង្គ្រើមនៃជីវិត។ គេចាត់ទុកសត្វនេះ ជាស្ពានសម្រាប់ភ្ជាប់ឋានមនុស្សលោក ទៅនឹងឋានទេវលោក។ នាគ តំណាងនូវអានុភាព អំណាច ថាមពល ឥទ្ធិពល ឫទ្ធានុភាព ភាពអង់អាចភាពថ្លៃថ្នូរ ការការពារជាតិ តំណាងទឹក (ផ្នែកកសិកម្ម) អ្នកមើលថែរក្សាផែនដី តំណាងភាពត្រជាក់ត្រជុំ រុងរឿងភាពចុំចើ្លង។ នាគជានិម្មិតរូបនៃការបង្កបង្កើនផលកសិកម្ម ពីព្រោះផលកសិកម្ម សុទ្ធតែកើតចេញពីទឹក និងដី។ នាគជាសត្វពស់ដែលចាស់សក មានជីវិតអមតៈ ហើយអាចរស់នៅក្នុងទឹកក៏បាន អាចរស់នៅលើគោកក៏បាន។ រួមសេចក្តីមក ក្នុងផ្នត់គំនិតខ្មែរ សត្វនាគ ជានិម្មិតរូបនៃធាតុទឹកនិងដីផ្សំគ្នា។

ជំនឿលើសត្វនាគរបស់ខ្មែរក៏មានទំនាក់ទំនងនិងព្រហ្មញ្ញសាសនា និងពុទ្ធសាសនាផងដែរ។ សត្វនាគ ត្រូវគេយកទៅឆ្លាក់បំពាក់លើបង្កាន់ដៃ ខ្លោងទ្វារ ក្បាច់ព្រំដំបូល... នៅស្ទើរគ្រប់សំណង់សាសនា កន្លែងសក្ការៈបូជា និងទីរមនីយដ្ឋាន ដែលដើរតួជាឆ្មាំមរតក ជាឆ្មាំការពារភូមិគ្រឹះ និងទ្រព្យក្នុងភូមិគ្រឹះ ក្រៅពីនេះ នាគត្រូវបានគេឆ្លាក់នៅលើរបស់របរប្រើប្រាស់ផ្សេងៗ ដូចជា រទេះគោនង្គ័ល (សម្រាប់ច្រត់ព្រះនង្គ័ល) ក្បាលទូក

ឈើច្រត់ ផ្តិល កៅអី ជាដើម។ ជាទូទៅ នៅក្នុងក្បាច់រចនារបស់ខ្មែរ រូបនាគដែលត្រូវយកទៅបំពាក់នោះ គេឃើញក្បាល សុទ្ធតែមានចំនួនសេស មានជាអាទិដូចជា ក្បាល៣ ក្បាល៥ ក្បាល៧ ក្បាល៩។ ចំនួនក្បាលនាគសេសតំណាងជីវិតរស់នៅ គឺភាពអមតៈ (ទស្សនៈខ្មែរយល់ថា លេខគត់គូរតំណាងសេចក្តីស្លាប់)[1]។

ក្នុងព្រហ្មញ្ញសាសនា នាគ ជាអសនៈរបស់ព្រះវិស្ណុ (ព្រះវិស្ណុផ្ទុំលើនាគអនន្ត ក្បាល៧)។ ធ្លុះបញ្ចាំងពីអត្ថន័យក្នុងរឿងកូរសមុទ្ទទឹកដោះ (ល្បែងប្រជាប្រិយ ទាញព្រ័ត្រ មានខ្សែពួរ ជានិម្មិតរូបនៃសត្វនាគ) យើងរកឃើញថាអត្ថន័យនាគ ជាវត្ថុពិសោធន៍កម្លាំងរវាងសភាវៈល្អ និងសភាវៈអាក្រក់ ហើយវាក៏ជាការបង្រួបបង្រួមរវាងសភាវៈល្អ និងសភាវៈអាក្រក់ឱ្យរួបរួមគ្នាធ្វើការដើម្បីសម្រេចបំណងណាមួយដែរ។ នាគ ជាជំនិះរបស់ឆ្មាំទិសបស្ចិម (ព្រះកិរុណជិះនាគ)។ ព្រះកិរុណ ជាទេវៈនៃទឹកភ្លៀង។ នាគ ជាសត្វតំណាងឱ្យទឹក (ទឹកភ្លៀង) ផងដែរ។ នៅសម័យ បុរាណគ្រប់ប្រាសាទតែងមានចម្លាក់រូបនាគ ឬសត្វមករជាលំអជានិច្ច ដែលតំណាងនយោបាយទឹក ឬប្រព័ន្ធធារាសាស្ត្រក្នុងវិស័យ កសិកម្ម។

ពិនិត្យតាមផ្ទាំងគំនូរនៅតាមវត្តអារាម យើងឃើញថា សត្វនាគ មានទំនាក់ទំនងជាមួយព្រះពុទ្ធសាសនា តាំងពីយូរលង់ណាស់មកហើយ។ ប្រជាជនខ្មែរ មានជំនឿ និងគោរពនាគ ដោយយល់ថា ជាតួអង្គពោធិសត្វ និងជាខ្សែគោត្ត (ខ្សែវង្សត្រកូលពីបុព្វជាតិរបស់ព្រះពុទ្ធព្រះកោនាគមនោ ដែលបានត្រាស់ដឹងរួចហើយ) នៅក្នុងពុទ្ធសាសនា។ នាគ គឺជាអ្នកបម្រើរបស់ព្រះពុទ្ធ នៅជាតិក្រោយៗរបស់ព្រះអង្គ។ មានរូបគំនូរ និងរូបចម្លាក់ព្រះពុទ្ធសមាធិនៅក្រោមក្បាលនាគ ដែលមានន័យថា នាគជាអ្នកការពារថែរក្សាព្រះពុទ្ធ។ គម្ពីរព្រះពុទ្ធសាសនាបានសរសេរថាៈ កាលពីព្រះពុទ្ធទ្រង់កំពុងធ្វើសមាធិក្រោមដើមឈើដ៏ធំមួយនៅក្នុងព្រៃ ពេលនោះមានសត្វនាគក្មេងមួយមកសុំបួសជាព្រះសង្ឃ ប៉ុន្តែ ព្រះអង្គបដិសេធព្រោះនាគជាសត្វតិរច្ឆានមិនអាចបួសដូចមនុស្សបានទេ។ ទោះបីនាគមិនបានបួសក្តី ក៏ស្ម័គ្រចិត្តធ្វើជាអ្នកការពារព្រះអង្គ ដោយសង្ឃឹមថា នឹងបានសិក្សាស្វែងយល់ពីព្រះពុទ្ធសាសនា។ មានរឿងមួយទៀត តំណាលថា កាលព្រះអង្គធ្វើសមាធិអស់រយៈពេល៧ថ្ងៃ ក៏មានហេតុការណ៍ដ៏ចម្លែកកើតឡើង គឺមានខ្យល់ព្យុះទឹកភ្លៀងយ៉ាងខ្លាំងមកលើព្រះពុទ្ធអង្គ ស្រាប់តែពេលនោះដែរក៏ស្តេចនាគក្បាល៧មានឈ្មោះថាមុជ្ជលិន្ទបានផុសចេញមកពីស្រះទឹកមកជួយការពារដល់ព្រះពុទ្ធអង្គ។

[1] សាកលវិទ្យាល័យបញ្ញាជាតិៈ ខេមរៈសិក្សា ភ្នំពេញ ឆ្នាំ ២០១០ ទំព័រ៥១។

ពុទ្ធសាសនា ទាក់ទងនឹងពីធីបំបួសនាគ។ មានរឿងដំណាលថា កាលពីព្រេងនាយ មានសត្វនាគមួយតំណែងខ្លួនជាមនុស្ស ហើយចូលទៅសុំបួសយកនិស្ស័យក្នុងសំណាក់ព្រះពុទ្ធសាសនា។ថ្ងៃមួយ លោកគ្រូប្រើលោកនេនឱ្យទៅហៅ គាត់ជួនពេលនោះសង្ឃដែលជាសត្វនាគនោះ កំពុងដេកលង់លក់ពុំដឹងខ្លួនដោយកាយក្លាយខ្លួនជាសត្វនាគពេនទ្រេលពេញក្នុងបន្ទប់។ ដំណឹងនោះ ក៏ជ្រាបដ ' ព្រះបរមសាស្ដា ព្រះពុទ្ធព្រះអង្គក៏បង្គាប់ឱ្យលោកនាគនោះលាចាក សិក្ខាបទទៅវិញ ដោយហេតុថាច្បាប់ព្រះពុទ្ធសាសនា ហាមមិនឱ្យសត្វចូលបួសទេ។ ប៉ុន្តែ ដោយទ្រង់មេត្តាដល់នាគដែលមានសេចក្ដីជ្រះថ្លានឹងសាសនាព្រះអង្គ ទ្រង់ក៏សន្យានឹងនាគថា ចាប់ពីថ្ងៃនេះតទៅ តថាគតសន្មតឱ្យនាមអ្នកសុំផ្នួសទាំងអស់ថា នាគ ដើម្បីជាទីរំលឹកដល់អ្នក។ ហេតុនេះហើយបានជា មាន ឈ្មោះថា បំបួសនាគដរាបរៀងមក រហូតដល់សព្វថ្ងៃនេះ។

ក្រៅពីនោះទៀត ខ្មែរបានយកសត្វនាគដាក់ជាឈ្មោះឆ្នាំមួយ (ឆ្នាំរោង) ក្នុងចំណោមឆ្នាំទាំង១២នៃចន្ទគតិ។ ទាក់ទងនឹងឆ្នាំរោង (នាគ) នេះ មានធាតុមាស ពង្សទេវតាប្រុស ដែលមានន័យទស្សនវិជ្ជា ទាក់ទងនឹងវាសនា និងជោគជតារាសី របស់មនុស្សដែលកើតក្នុងឆ្នាំរោងឬនាគផងដែរ។

## ១.២. អណ្ដើក

អណ្ដើក ជាសត្វដែលខ្មែរមានជំនឿ ទាំងក្នុងជីវចលនិយម ទាំងក្នុងព្រហ្មញ្ញសាសនា ទាំងក្នុងពុទ្ធសាសនា តាំងពីសម័យបុរាណរហូតដល់បច្ចុប្បន្ន។

ប្រជាជនខ្មែរមានជំនឿ និងគោរព អណ្ដើកកូម៌ ជាតួអង្គអវតាទី២របស់ព្រះនរាយណ៍នៅក្នុងព្រហ្មញ្ញសាសនា ដែលបានធ្វើជាទម្រភ្នំមន្ទរក្នុងការកូរសមុទ្ទទឹកដោះ ដើម្បីបានទឹកអម្រឹតមកផឹកឱ្យមានជីវិតគង់វង្សអមតៈ។

ក្នុងពុទ្ធសាសនា ប្រជាជនខ្មែរមានជំនឿ និងគោរព អណ្ដើក ជាតួអង្គពោធិ សត្វខ្សែវង្សត្រកូលពីបុព្វជាតិរបស់ព្រះពុទ្ធព្រះនាម កស្សបោ ដែលបានត្រាស់ដឹងរួចហើយ។

អណ្ដើកជាសត្វមួយដែលអាចរស់ក្នុងទឹកផង និងលើគោកផង។ អណ្ដើកតំណាងធាតុទឹក និងដី ដែលជាប្រភពឱ្យមានជីវិត។ ក្នុងគម្ពីរ Satapatha-Brahmana បានចារឹកថា អណ្ដើក ជាតួអង្គមួយបានបង្កើតគ្រប់ធម្មជាតិទាំងអស់[2]។ សត្វអណ្ដើកក៏ត្រូវបានប្រជាជនខ្មែរចាត់ទុកថា ជាសត្វមួយនាំមកនូវ ភោគផល។ គេមានទម្លាប់យកស្នូកអណ្ដើកទុកក្នុងជង្រុក ឬចិញ្ចឹមអណ្ដើកក្នុង ជង្រុកដែលគេផ្ទុកធញ្ញជាតិ ស្រូវ ល្ង ពោត ។ល។

រូបភាពអណ្ដើក ក៏ត្រូវបានគេយកទៅគូរនៅលើយ័ន្តសម្រាប់ដាក់ព្យួរនៅសរសរកន្ទោងផ្ទះ

[2] K, Bhattacharyya : ***Les Religions dans L'Ancien Cambodge***, EFFEO, Paris, 1949, Vol.49.

ដែលប្រជាជនខ្មែរមានជំនឿថា អណ្ដើក ទ្រទ្រង់គ្រឹះផ្ទះឱ្យរឹងមាំ និងជួយឱ្យក្រុមគ្រួសារ មានភាពត្រជាក់ត្រជុំ។

តាមរយៈការធ្វើកំណាយបុរាណវិទ្យានៅ តំបន់អង្គរ (នៅប្រាសាទគោកតាសៀន ស្ថិត នៅភូមិប្រឡាយ ឃុំវត្តឃ្នា ស្រុកពួក) ដោយ សាលាបារាំងចុងបូព៌ា នាឆ្នាំ១៩៩៧ គេបាន ជួបប្រទះសន្ទឹកមាស មានឆ្លាក់ជា រូបដំរី រូប នាគ និង រូបអណ្ដើក ដែលគេយកទៅបញ្ចុះ នៅក្រោមគ្រឹះប្រាសាទ[3]។ ជំនឿលើការកប់ រូប ដំរី រូបនាគ និង រូបអណ្ដើក ក្នុងគ្រឹះប្រាសាទ នេះ ជានិម្មិតរូបនៃភាពរឹងមាំលើតុល្យភាពទឹក និងដី។ ការធ្វើកំណាយនៅលានប្រជល់ដំរី ក៏ គេបានប្រទះ ឃើញរូបអណ្ដើកចំនួន៦ ធ្វើអំពី សំណនៅក្រោមគ្រឹះហើយត្រូវបានគេតំរៀប ជា ជួរកែងនឹងសសរគ្រឹះ[4]។ ជាការសន្និដ្ឋាន រូប អណ្ដើកធ្វើអំពីសំណនេះ ប្រហែល ជានិម្មិត រូបនៃអវតាព្រះនារាយណ៍តំណែងខ្លួនជា អណ្ដើកធំមួយ ដើម្បីទ្រភ្នំមន្ទរកុំឱ្យលិច ទៅ ក្នុងសមុទ្រក្នុងខណៈពេលកូរសមុទ្រទឹកដោះ យកទឹកអម្រឹត ទើបធ្វើឱ្យប្រព័ន្ធគំនិតខ្មែរនៅ សម័យនោះ មានជំនឿលើការបញ្ចុះរូប អណ្ដើកទៅក្រោមបាតប្រាសាទ ដើម្បីជួយ ទ្រទ្រង់គ្រឹះប្រាសាទឱ្យឈររឹងមាំនិងគង់វង្ស យូរអង្វែង និងឱ្យទៅជាកន្លែងសក្ដិសិទ្ធ ហើយ វាពិតជាមានអត្ថន័យដូចគ្នានឹងការបញ្ចុះ សីមានៅតាមព្រះវិហារព្រះពុទ្ធសាសនាសព្វ ថ្ងៃនេះដែរ។ ហេតុនេះ ក្នុងទស្សនៈខ្មែរយើង ចាត់ទុកថា សត្វអណ្ដើក អាចទ្រទ្រង់ផែនដី ឬ ទេវដ្ឋានឱ្យមានលំនឹង និងរឹងមាំយូរអង្វែង។

រូបរាងអណ្ដើកហាក់ដូចជាតំណាងមេឃ (ស្នូកខ្នងលើ) និងដី (ស្នូកពោះ) ពោលគឺជា ប្រវាឡ[5]។

ក្នុងផ្នត់គំនិតខ្មែរយល់ថា អណ្ដើកជាសត្វ ស្លូតត្រង់ និងផ្ដល់នូវភាពត្រជាក់ត្រជុំដ ' គ្រួសាររបស់គេ ហើយប្រហែលជាស្ថិតក្នុង ន័យនេះហើយ បានជាគេ ប្រទះឃើញមាន ស្នូកអណ្ដើកកប់ជាមួយសាកសពនៅក្នុងផ្នូរ សម័យបុរាណ (កំណាយបុរាណវិទ្យានៅអង្គរ បុរី និងនៅស្ពានទីយកប់សពគោកភ្នំដំរីប្រទេស ថៃ)[6]។

ប្រជាជនខ្មែរបានយកស្នូកអណ្ដើកមក ឆ្លាក់ជាគ្រឿងអលង្ការ ឬយកមាស ឬប្រាក់មក ឆ្លាក់ជារូបអណ្ដើកធ្វើជាគ្រឿងអលង្ការពាក់ ដូចជា បន្ដោងខ្សែក ឬ ចិញ្ចៀន ដោយគេមាន ជំនឿថា អណ្ដើកជាសត្វមានអាយុវែង ហើយ នឹងធ្វើឱ្យគេមានអាយុវែងដូចអណ្ដើកដែរ ហើយលើសពីនេះទៅទៀត គេមានជំនឿ ថា

---

[3] Cristope Pottier : ***Perspective de la mission archaeologique France-Khmere sure láménagement du Territior Angkor*** ឆ្នាំ២០០១ ឧទ័យលេខ២ ទំព័រទី១២៩។

[4] ព្រឹត្តបត្រទំនាក់ទំនងការស្រាវជ្រាវនៅកម្ពុជាលេខ១ ខែមិថុនា ១៩៩៧ ចេញផ្សាយដោយសាលា បារាំងចុងបូព៌ា ទំព័រ៣២។

[5] Fujiwara : ***Khmer Ceramics from the Kumaratan Collection***, Singapore Oxford University Press, 1990, p.597.

[6] Charles Higham and Rachanie Thosarat : ***Prehistorics Thailand***, 1998, p.55.

អាចរក្សាការពារខ្លួនឱ្យបានសុខ និងអាចឱ្យគេភ្ជាប់ខ្លួនជាមួយអាទិទេពបាន ព្រោះសត្វអណ្តើក ជាអវតារបស់ព្រះនារាយណ៍[7]។

ខ្មែរមានជំនឿលើសត្វអណ្តើករហូតដល់ធ្វើជាខ្ទមអ្នកតាអណ្តើក (ខ្ទមអ្នកតាអណ្តើកនៅព្រែកក្តាម) និងមានការចូលរូបបង់បត់ (បង់បត់អណ្តើកមាស[8] បង់បត់ព្រះអង្គកស្សបោ[9])។

ក្នុងជំនឿនេះទៀតសោត ប្រជាជនខ្មែរនៅតំបន់ខ្លះ បានយកទ្រូងអណ្តើក ទៅពាក់នឹងកកូនក្មេងដែលមានជំងឺកើតអណ្តើក (ដុំសាច់ដុះក្នុងពោះ) ដើម្បី ឱ្យធាប់ជាសះស្បើយ។ គេយកស្នូកអណ្តើកទៅធ្វើជាឱសថព្យាបាលជំងឺជាច្រើនមុខ។ ពេលក្មេងក្តៅខ្លួន មានគ្រូនសន្និ អ្នកស្រុកយកស្នូកអណ្តើកមួយចំណិតតូចទៅដុសនឹងថ្ម ហើយស្រង់ទឹកនោះឱ្យក្មេងផឹកនេះជាថ្នាំស័ក្តិសិទ្ធិ។ គេដឹងថា សត្វអណ្តើកមានថាមពលអាថ៌កំបាំង កាលបើបានផឹកកម្ទេចឆ្អឹង ឬស្នូករបស់វាហើយ គឺអាចជាសះស្បើយពីជំងឺភ្លាមៗពុំខាន។

ក្រៅពីនេះ នៅមានជំនឿថា ដើម្បីឱ្យរួចផុតពីឧបទ្រពចង្រៃ រំដោះគ្រោះកម្មឱ្យអស់ពីខ្លួនដើម្បីបានសេចក្តីសុខ និងដើម្បីបានបុណ្យកុសលទៅអនាគតជាតិ គឺកាលែងអណ្តើក ហើយទំនៀមទំលាប់នេះនៅមានបន្តរហូតមកដល់សព្វថ្ងៃ។ ខ្មែរមានជំនឿលើសត្វអណ្តើកជាសត្វជួយរំដោះគ្រោះកម្មរបស់គេ ហេតុនេះ ហើយបានជាខ្មែរនិយមការលែងអណ្តើកនៅទីណាមានទឹក និងចំណីអាហារគ្រប់គ្រាន់ កាលណាគេមានបញ្ហាអ្វីមួយទាក់ទងនឹងការលាបំណាន់ ការរំដោះគ្រោះរំដោះកម្ម ជាដើម។ អណ្តើកមានច្រើនប្រភេទ៖ អណ្តើកក្អែក អណ្តើកបិទមុខឬក្បិតមុខ អណ្តើកព្រេច និង អណ្តើកសង្កល់។ ក្នុងចំណោមអណ្តើកទាំងនេះ គេនិយមលែងអណ្តើកព្រេច។ ជំនឿលើការលែងអណ្តើកខ្មែរនិយមចូលចិត្តលែងនៅថ្ងៃសីលចំថ្ងៃខែដាច់ ព្រោះគេមានជំនឿថា ថ្ងៃខែដាច់ ជានិមិត្តរូបនៃការដាច់កម្ម ដាច់ពៀរ ដាច់គ្រោះអស់ពីក្នុងខ្លួនគេ។ ពេលលែងអណ្តើកជួនកាលអ្នកលែងបានយកអណ្តើកទៅប្រគេនព្រះសង្ឃឱ្យប្រសិទ្ធី ជួនកាលមានថ្វាយភ្លេងពិណពាទ្យ មានការចារឹកអក្សរលើស្នូក និងមានលាបប្រេងម្សៅ ហើយ ពេលដាក់អណ្តើកទៅក្នុងទឹក គេស្រែកថា៖ អញលែងឯងឱ្យមានសេរីភាព ហើយ សូមឯងជួយចម្លងគ្រោះកម្មអញផងចាប់ពីពេលនេះតទៅ។ អណ្តើកដែលមានចារឹកអក្សរលើស្នូក ទោះបើវាចេញពីស្រះទៅក្នុងភូមិអ្នកស្រុកចាប់បានក៏គេមិនហ៊ានចាប់យកទៅលក់ឬបរិភោគទេ

[7] Louis Malleret : ***L'Archeaology  du delta du Mekong***, Paris, 1962, Vol.43, Tome III, p.57.

[8] *អ្នកចូលរូប(រូបស្នង)ឈ្មោះ ថុល អាយុ៥៤ឆ្នាំ នៅភូមិស្ពានថ្មី ឃុំរការកោង៣ ស្រុកមុខកំពូល ខេត្តកណ្តាល។*

[9] *អ្នកចូលរូប(រូបស្នង)ឈ្មោះ តោ សេង អាយុ៧៩ឆ្នាំ នៅភូមិព្រែកដីក ឃុំកោះចិនស្រុកពញាឮ  ខេត្តកណ្តាល។*

ព្រោះគេខ្លាចមាន បណ្តាសាកម្មពៀរ ហើយគេយកវាទៅលែងវិញ គេមានអារម្មណ៍ថាបានសេចក្តីសុខ ព្រោះបានអណ្តើកនាំលាភមកដល់គេ។ ជំនឿនេះ ធ្វើឱ្យប្រជាជនខ្មែរមួយចំនួនធំមិនបរិភោគសត្វ អណ្តើកទេ ព្រោះខ្លាចបាប និងខ្លាចមានកម្មពៀរ។

ជំនឿចំពោះសត្វអណ្តើក ត្រូវបានយកទៅប្រើក្នុងវណ្តាប់ថង់រងអាពាហ៍ពិពាហ៍ ដែលមានន័យថា ជាសត្វរស់នៅក្នុងទឹក តំណាងភាពត្រជាក់ត្រជុំដល់គូស្វាមីភរិយាថ្មី។ អាចារ្យពេលាមួយចំនួនបានពោលថា រូបអណ្តើកតំណាងព្រះកស្សបចុះមកប្រទានពរជ័យដើម្បីឱ្យកូនប្រុសកូនស្រីរៀបការ ហើយមានសុភមង្គលល្អក្នុងជីវិត។

## ១.៣. ក្រពើ

ក្រពើជាពពួកលូនមានជើង ដែលវិវត្តពីពពួកលូនគ្មានជើង ដូចជា ពស់ នាគ...មកជាលូនមានជើង។

ក្នុងផ្នែកអក្សរសិល្ប៍ មានរឿងព្រេងជាច្រើនដែលតំណាលរៀបរាប់និទានអំពី ក្រពើ ជាកញ្ចក់ឆ្លុះបញ្ចាំងតថភាពទស្សនវិជ្ជាក្នុងសង្គមខ្មែរ។ ក្រពើជាសត្វ អាច រស់នៅលើគោកផង និងក្នុងទឹកផង។ ទំនៀមទម្លាប់ដោតទង់ក្រពើនៅពេលមាន មនុស្សស្លាប់ ជាតំណាងព្រលឹងរបស់ខ្មែរ។ ទង់ក្រពើ ជានិមិត្តរូបតំណាង ព្រះថោង ហើយគេចាត់ទុកព្រះថោង ជាជីតារបស់ខ្មែរ ជាព្រលឹងនៃជាតិខ្មែរ ដែលខ្មែរតែងតែរំលឹក គោរពបូជាប្រណិប័តន៍។ ក្នុងទស្សនៈខ្មែរយើង រូបតំណាងនាងគង្ហីងឬនាងធរណី និងក្រពើនោះ គឺគ្មាននរណាក្រៅពី ព្រះថោង និងនាងនាគ ឬមេបានិយម ឬជានិមិត្តរូបនៃអន្តរទំនាក់ទំនងទឹកនិងដីឡើយ។ ផ្តើមចេញពីអត្ថន័យទស្សនវិជ្ជានេះ ទើបគេសង្កេតឃើញមានរូបចម្លាក់អំពីក្រពើ នៅតាមព្រះវិហារ នៅតាមប្រាង្គប្រាសាទនានា លើសពីនេះទៅទៀត សណ្ឋានរូបក្រពើ ក៏ត្រូវបានគេយកមកឆ្លាក់ធ្វើជាឧបករណ៍ប្រើប្រាស់។

ប៉ុន្តែ រូបភាពក្រពើត្រូវខ្មែរជំនាន់ថ្មីយល់ច្រឡំថា ជាតំណាងរូបភាពអាក្រក់ តំណាងមនុស្សអកត្តញ្ញូ ដែលរមិលមិនស្គាល់គុណគេ។ គេតែងនិយមនិយាយ ជាប់មាត់ថា៖ អាក្រពើវង្វេងបឹង[10]។ បើយើងវិភាគពីអត្ថន័យទស្សនវិជ្ជា នោះទើបយើងយល់ឃើញថា ចាស់បុរាណលោកតែងស្តីបន្ទោសចំពោះជនអកត្តញ្ញូ មិច្ឆាទិដ្ឋិនិរគុណ ថាជា ក្រពើវង្វេងបឹង ពោលគឺ បុព្វបុរសខ្មែរចង់ចង្អុលបញ្ជាក់ និងស្តីបន្ទោសទៅលើខ្មែរដែលភ្លេចដើមកំណើតជាតិខ្លួនជាខ្មែរ ភ្លេចស្រុកកំណើត ភ្លេចពណ៌សម្បុរ ភ្លេចមុខមាត់ខ្លួនជាខ្មែរ ភ្លេច

[10] រស់ ចន្ទ្រាបុត្រ៖ ប្រវត្តិសាស្ត្រខ្មែរ ភាគទី១(ភាគរឿងនិទាន និង តាមសិលាចារឹក) បោះពុម្ពនៅ ពេងពុម្ព L'Harmattan ធីយេស៍ ប្រទេសបារាំង ឆ្នាំ១៩៩៧ ទំព័រ៣៦-៣៧។

ភាសា ក្លេចអត្តសញ្ញាណជាតិ ជាខ្មែរ ក្លេចវប្បធម៌ខ្លួនជាខ្មែរ ប្រែក្រឡាស់លះបង់ចោនូវច្បាប់ទម្លាប់ និងទំនឹមទំនៀមពីបុរាណរបស់ខ្លួន ហើយយកវប្បធម៌អរិយធម៌បរទេសជាត្រីមុខ លើកតម្កើងបរទេសជាធំនិងសំខាន់ជាង បរទេសនិយម បន្ទាបបន្ថោកខ្លួនឯងដែលជាមូលហេតុនៃការប្រាសចាកសេចក្តីសុខក្សេមក្សាន្តនៅក្នុងដែនអាណាចក្ររបស់ខ្លួន មិនខុសពីក្រពើវង្វេងបឹងទេ។ ដោយសារតែការវង្វេងបឹងនេះហើយ ដែលធ្វើឱ្យអរិយធម៌អង្គរដ៏រុងរឿងធ្លាក់ចុះអាប់រស្មីរហូតមកដល់សព្វថ្ងៃនេះ។

**១.៤. គោ**

គោ ជាសត្វពាហនៈផ្តល់អត្ថប្រយោជន៍យ៉ាងច្រើនដល់ការរស់នៅរបស់ប្រជាជនខ្មែរ ដូចជា សម្រាប់ទឹមអូសនង្គ័ល រនាស់ រទេះ បង្កបង្កើនផលកសិកម្ម និង ដឹកភោគផលកសិកម្ម។

ពាក្យ គោ មានន័យថា ឋានសួគ៌ រស្មី ព្រះអាទិត្យ ព្រះចន្ទ ទឹក ផែនដី មាតា និងមានអត្ថន័យផ្សេងៗទៀត ដូចជា កាំរន្ទះ ខ្សែផ្ទេកបន្ទោរ ប្រស្រីភ្នែក សំដី ទិស សរ (ព្រួញ) ពេជ្រ អារម្មណ៍ រោមតាមរាងកាយ ជាដើម។

គោ ក្នុងទស្សនៈខ្មែរស្របជាមួយព្រហ្មញ្ញសាសនាផង និងស្របជាមួយព្រះពុទ្ធសាសនាផង។ ក្នុងពុទ្ធសាសនា សត្វគោ តំណាងប្រាជ្ញាបារមីខ្ពង់ខ្ពស់ លះសោតបត្តិមគ្គ។ ព្រះពុទ្ធមាននាម គោតម ដែលមកពីពាក្យ គោ និង តម។

គោ មានន័យថា ព្រះអាទិត្យ។ តម មានន័យថា ប្រសើរ។ ព្រះសក្យមុនីសម្មាសម្ពុទ្ធព្រះអង្គជា គោតមគោត្ត (គោត្ត មានន័យថា វង្ស ត្រកូល ឬ សៃ) ដែលមានន័យថា ពូជវង្សនៃព្រះអាទិត្យដ៏ប្រសើរ។ ក្នុងមជ្ឈិមប្រទេសក្នុងសម័យបុរាណ ពាក្យ គោតម ជានាមឬគោរមងាររបស់អ្នកប្រាជ្ញឬអ្នកមានវង្សត្រកូល ប្រសើរខ្ពង់ខ្ពស់ (វង្សព្រះរាម ក្នុងរឿងរាមកេរ្តិ៍។ នៅឥណ្ឌានៅមានប្រើនាមនេះរហូតមកដល់បច្ចុប្បន្ន។ ប្រជាជនខ្មែរមានជំនឿ និងគោរព គោ ដោយយល់ថា ជាតួអង្គពោធិសត្វនិងជាខ្សែគោត្ត (ខ្សែវង្សត្រកូលពីបុព្វជាតិរបស់ព្រះពុទ្ធ ព្រះនាម គោតមោ ដែលបានត្រាស់ដឹងរួចហើយ) នៅក្នុងពុទ្ធសាសនា។ ជំនឿលើ សត្វគោនេះ ធ្វើឱ្យប្រជាជនខ្មែរមួយចំនួនធំមិនបរិភោគសាច់គោទេ ព្រោះខ្លាចបាប និងខ្លាចមានកម្មពៀរ។

គោ មានអត្ថន័យស្មើ មាតា ការគោរពគោ គឺមានន័យថា ប្រកាន់ទស្សនៈ មាតាធិបតេយ្យ។

ក្រៅពីនោះទៀត ខ្មែរបានយកសត្វគោដាក់ជាឈ្មោះឆ្នាំមួយ (ឆ្នាំឆ្លូវ) ក្នុងចំណោមឆ្នាំទាំង១២នៃចន្ទគតិ។ ទាក់ទងនឹងឆ្នាំគោនេះ មានជាតុដី ពង្សមនុស្សប្រុស ដែលមានន័យទស្សនវិជ្ជាទាក់ទងនឹងវាសនា និងជោគជតារាសីរបស់មនុស្សដែលកើតក្នុងឆ្នាំឆ្លូវឬឆ្នាំគោផងដែរ។ លើសពីនេះទៅទៀត គោ ជានិមិត្តរូបនៃទឹក និងដី ផងដែរ។

**១.៥. តោ** *(រាជសីហ៍)* **និង ខ្លា**

*បុព្វបុរសខ្មែរបានចាត់ទុក តោ និង ខ្លា គឺជាសត្វព្រៃមានភាពកាចសាហាវ មានកម្លាំងខ្លាំងក្លា មាំមួន និងមានភាពអង់អាចក្លាហាន។ តោ ជាស្តេចសត្វលើ គោក ជាសត្វតំណាងដី។ សត្វទាំង២ គឺជានិមិត្តិសញ្ញានៃឥទ្ធិពល ឬអំណាចដ៏ពិសិដ្ឋមានមកពីធម្មជាតិ គួរឱ្យកោតខ្លាច លាយឡំទៅដោយការគោរពសក្ការៈផងដែរ។ ក្នុងទស្សនៈខ្មែរ ចាត់ទុក តោ និង ខ្លា ជាឆ្មាំ ជានិមិត្តរូបនៃអំណាចបណ្តេញឧបទ្រពចង្រៃ។ គេតែងដាក់ចម្លាក់តោឬខ្លានៅមុខផ្ទះមានផ្លូវបុកចំនៅខ្លោងទ្វារប្រាសាទ វត្ត ដោយគេមានជំនឿថា ទីកន្លែងណាដែលមានសត្វតោនៅ មិនដែលមានអ្វីមួយហ៊ានចូលទៅក្បែរ បង្កជាឧបសគ្គនិងយាយីឡើយ ហេតុនេះទើបនៅតាមប្រាសាទបុរាណ ដែលជាទីសក្ការៈ ឬតម្កល់វត្ថុមានតម្លៃ គេតែងដាក់សត្វតោឬខ្លាឱ្យនៅយាមជាទ្វារបាល។ គេឆ្លាក់រូបតោឬខ្លា ឬយកចង្កូមរបស់វាមកស្រោបធ្វើជាបន្តោងខ្សែកពាក់ ដោយគេជឿជាក់ថា បន្តោងរូបសត្វព្រៃបែបនេះ គឺជានិមិត្តរូបដើម្បីការពារខ្លួនកុំឱ្យមានឧបទ្រពចង្រៃផ្សេងៗ ដូចជា ខ្មោច ព្រាយ បិសាច មកយាយី។ ម៉្យាងវិញទៀត ក្នុងគំនិតរបស់មនុស្សខ្មែរបុរាណយល់ថា បើនរណាម្នាក់មានសាក់ជាសញ្ញារូបសត្វខ្លានៅលើខ្លួនប្រាណរបស់គេ គឺមនុស្សនោះ មានឥទ្ធិពលប្រៀបដូចជាសត្វខ្លាមិនខាន ហើយក៏អាចជួយឱ្យអ្នកមានចិត្តស្រាល ឬទន់ខ្សោយប្រែក្លាយទៅជាមនុស្សមានចិត្តអង់អាច ក្លាហានស្វាហាប់ឡើងវិញបានដែរ។*

*ក្នុងពុទ្ធសាសនា តោ ជាជំនិះរបស់ព្រះពោធិសត្វមញ្ជុស្រីដែលជាពោធិសត្វ តំណាងយុត្តិធម៌ និងតុលាការ។*

*ខ្មែរបានយកសត្វខ្លាដាក់ជាឈ្មោះឆ្នាំមួយ (ឆ្នាំខាល) ក្នុងចំណោមឆ្នាំទាំង១២នៃចន្ទគតិ។ ទាក់ទងនឹងឆ្នាំខាលនេះមានជាតុឈើ ពង្សយក្ខិណី ដែលមានន័យទស្សនវិជ្ជាទាក់ទងនឹងវាសនា និងជោគជតារាសីរបស់មនុស្សដែលកើតក្នុងឆ្នាំខាលឬខ្លាផងដែរ។ ក្រៅពីនោះទៀត គេឱ្យមនុស្សឆ្នាំខ្លា គូររូបខ្លាលើថ្ពាល់អ្នកកើតជំងឺក្រឡទែន ដើម្បីបំបាត់ការឈឺចាប់និងព្យាបាលផងដែរ។*

*ដូចនេះ ក្នុងទស្សនៈខ្មែរ តោ និង ខ្លា ជាសត្វតំណាងឬនិមិត្តរូបនៃភាពអង់អាចក្លាហាន និងអំណាចយុត្តិធម៌ ជាឆ្មាំមរតក និងជាសត្វតំណាងដី។*

**១.៦. ទន្សាយ**

*ក្រោយពីបែកបាក់ក្រុងអង្គរ ប្រជាជនខ្មែរបានបោះបង់ចោលព្រហ្មញ្ញសាសនា ហើយ ងាកបែរមកគោរពព្រះពុទ្ធសាសនាវិញ។ នៅក្នុងគម្ពីរព្រះពុទ្ធសាសនា (ត្រៃបិតក) មានភាគមួយបានចែងអំពី ទន្សាយពោធិសត្វ គឺព្រះពុទ្ធធ្លាប់យោង យកកំណើតជាទន្សាយ ហើយបានបូជាសាច់ខ្លួនជាទាន ធ្វើឱ្យព្រះឥន្ទ*

ផ្ដិតរូបទន្សាយពោធិសត្វជាប់ទៅនឹងឋានព្រះចន្ទ។ ពិធីបុណ្យសំពះព្រះខែ ប្រារព្ធឡើងដើម្បីរំលឹកកាលព្រះពោធិសត្វយោនយកកំណើតទៅកើតជាសត្វទន្សាយ។ នៅថ្ងៃពេញបូរណ៌មីនាវេលារាត្រីព្រះចន្ទរះពេញវង់មានពន្លឺល្អត្រកាលទ្រង់ក្រឡេកមើលព្រះចន្ទ ហើយមានសេចក្ដីជ្រះថ្លា ដោយនឹកគិតថា បើនរណាត្រូវការសាច់របស់អាត្មាអញជាអាហារ អាត្មាអញនឹងបានបំពេញទានក្នុងពេលឥឡូវនេះ។ គ្រាន់តែនឹកគិតភ្លាមក៏រំជួលដល់ព្រះទ័យព្រះឥន្ទ ដឹងថាទន្សាយព្រះពោធិសត្វ មានសេចក្ដីជ្រះថ្លាចង់បំពេញទាន។ ព្រះឥន្ទក៏មកក្លែងខ្លួនធ្វើជាព្រាហ្មណ៍ចាស់ម្នាក់មកកាន់សំណាក់ទន្សាយពោធិសត្វ ហើយពោលថា៖ ជីវិតខ្ញុំនឹងក្ស័យក្នុងថ្ងៃនេះមិនខានឡើយ ធ្វើម្ដេចនឹងបានអាហារបរិភោគ។ ទន្សាយប្រាប់ថា៖ ខ្ញុំ មានតែសាច់ និងឈាមរបស់ខ្ញុំសម្រាប់ឱ្យជាទាន បើអ្នកត្រូវការ ចូររកអុសមកបង្កាត់ភ្លើងឱ្យឆេះទៅចុះ ខ្ញុំនឹងលោតចូលក្នុងភ្លើងកំពុងឆេះនោះភ្លាម ហើយអ្នកនឹងបានអាហារបរិភោគ។ ព្រាហ្មណ៍ចាស់តបថា៖ ខ្ញុំអរគុណអ្នកណាស់ ហើយក៏រកអុសមកបង្កាត់ភ្លើង។ ទន្សាយក៏រលាស់ខ្លួនយ៉ាងស្អាតលោតចូលទៅក្នុងភ្លើង ស្រាប់តែភ្លើងនោះរលត់អស់ សូម្បីតែរោមមួយសរសៃក៏ពុំឆេះផង។ ព្រះឥន្ទ ស្ញើចសរសើរហេតុដ៏អស្ចារ្យនេះ ហើយក៏ហោះទៅយកម្នាងសិលាមួយដុំមកគូសវាសក្លាប់រូបទន្សាយក្នុងវង់ព្រះចន្ទ។ ហេតុនេះហើយ បានជាមានរូបទន្សាយនៅក្នុងវង្វង់ព្រះចន្ទ។ អ្នកកាន់ព្រះពុទ្ធសាសនា ក៏នាំគ្នាគោរព ហើយនេះជាចំណែកមួយដែលធ្វើឱ្យប្រជាជនខ្មែរកាន់សាសនាព្រះពុទ្ធ និយមគោរព និងលើកតម្កើង តួអង្គទន្សាយ។ ឯចំណែកពិធីបុណ្យទាន គេឃើញ ពិធីមួយដែលប្រជាជនខ្មែរនិយមយ៉ាងខ្លាំងហើយឃើញប្រារព្ធធ្វើនៅគ្រប់ផ្ទះសម្បែង គ្រប់ភូមិស្រុកនៅទូទាំងប្រទេសនោះ គឺពិធីបុណ្យសំពះព្រះខែ (គេតែងប្រារព្ធធ្វើឡើងនៅថ្ងៃ១៥កើត ខែកត្តិក ជារៀងរាល់ឆ្នាំ នៅពេលរាត្រី) ដែលជាពិធីមួយជាប់ទាក់ទងយ៉ាងខ្លាំងទៅនឹងសត្វទន្សាយដែលគេចាត់ទុកថា រូបខ្មៅនៅលើព្រះចន្ទ គឺជាតួអង្គទន្សាយព្រះពោធិសត្វ។

ក្រោយបែកបាក់អង្គរ ប្រជាជនខ្មែរហាក់បីដូចជា បាត់ព្រលឹង ខ្លាចបាក់ស្បាត ហើយការរស់នៅក្នុងសង្គមទៀតសោត គេតែងតែឃើញនូវការជិះជាន់កេងប្រវ័ញ្ច បំបាត់សិទ្ធិសេរីភាព ឆក់ប្លន់ កាប់សម្លាប់ ពីសំណាក់អ្នកធំ អ្នកមានអំណាច អ្នកមានទ្រព្យសម្បត្តិ ជនទុច្ចរិត មកលើអ្នកតូចតាចទន់ខ្សោយ(ជាធម្មតា ត្រីធំតែងស៊ីត្រីតូច ព្រោះនេះជាច្បាប់ធម្មជាតិមួយយ៉ាងជាក់លាក់)។ ការរស់នៅក្នុងស្ថានភាពបែបនេះ អជ្ញាធរ និងច្បាប់ ហាក់មិនអាចរកយុត្តិធម៌ជូនដល់អ្នកទន់ខ្សោយ ទើបកវីនិពន្ធខ្មែរបានបញ្ជ្រាបគំនិតអប់រំ និងទិតៀនសង្គម ហើយតែងតែជ្រើសយកតួអង្គសុភាទន្សាយ មកធ្វើជានិមិត្តរូបអ្នកការពារ អ្នកមាន

មេត្តាករុណា ជួយសង្គ្រោះអ្នកទន់ខ្សោយ កម្សត់ទុគ៌ត ជាចៅក្រមជួយរកយុត្តិធម៌ ជាអ្នកប្រឆាំង ចំពោះអ្នកមានអំណាចឃោរឃៅ ហើយជិះជាន់សង្កត់សង្កិនអ្នកទន់ខ្សោយ[១១]។ ក្នុងទស្សនៈរបស់អ្នកនិពន្ធអក្សរសិល្ប៍ខ្មែរ បានចាត់ទុក ទន្សាយ ជាតួអង្គមានចំណេះដឹង មានបញ្ញា មានប្រាជ្ញា មានវិចារណញ្ញាណ ដែលរស់នៅក្នុងសង្គម ក្នុងក្រឡាជីវិតមួយ នៅចន្លោះ អ្នកមានទ្រព្យធន អ្នកមានអំណាច អ្នកស្លូតត្រង់ និងអ្នកល្ងង់ខ្លៅ។ ដូច្នេះហើយ បានជាអ្នកសិក្សាវិភាគតួអង្គសុភាទន្សាយបានសន្និដ្ឋានថា រឿងសុភាទន្សាយ ជារឿងបង្កប់នូវ ទស្សនវិជ្ជាមនុស្សនិយម និង ជាទស្សនវិជ្ជាតថនិយម សុទ្ធសាធ គឺរស់នៅជាមនុស្សសាមញ្ញ ធម្មតាក្នុងជីវិត ពោលគឺ ចោទតែបញ្ហាជីវិតនិយមសុទ្ធសាធ រស់ជាមនុស្សដោយពុំដេករង់ចាំអន្តរាគមន៍ពីពពួកទេវៈមិនជឿជោគជាំទៅលើប្រព័ន្ធឬទ្រឹស្តីគំនិតផ្សេងៗ ដែល ពុំស្របនិងទ្រឹស្តីប្រាកដនិយមទេ។ ដូច្នេះអ្នកសិក្សាស្រាវជ្រាវយល់ថា រឿងសុភាទន្សាយពុំមានជាប់ទាក់ទងទៅនឹងទស្សនៈកម្មផលអ្វីឡើយ។ នេះជាគតិបណ្ឌិត មនុស្សនិយមសុទ្ធសាធ មិនមានជាប់ពាក់ព័ន្ធឥទ្ធិពលសាសនា[១២]។

ក្រៅពីនោះទៀត ខ្មែរបានយកសត្វទន្សាយដាក់ជាឈ្មោះឆ្នាំមួយ(ឆ្នាំថោះ) ក្នុងចំណោមឆ្នាំទាំង១២នៃឆ្នាំចន្ទគតិ។ ទន្សាយមានធាតុឈើ ពង្សមនុស្សស្រី ដែលមានន័យទស្សនវិជ្ជាទាក់ទងនឹងវាសនា និងជោគជតាពសីរបស់មនុស្សដែល កើតក្នុងឆ្នាំថោះឬទន្សាយផងដែរ។ ហើយគេតែងតែចាត់ទុកថា មនុស្សកើតឆ្នាំ ទន្សាយ ជាអ្នកមានប្រាជ្ញាវាក់ទាក់ ចេះជួយយកអាសាគេ ជាមនុស្សមានឧត្តមគតិ ចេះគិតគូរវាក់ជ្រៅ ចូលចិត្តភាពវាក់ទាក់ ចងមិត្តភាព ហើយមានសេចក្តីស្នេហាស្មោះត្រង់ មិនចេះលោភលន់ គឺរស់នៅសាមញ្ញប្រកបដោយសេចក្តីថ្លៃថ្នូរនៅក្នុងសង្គម។ ដោយការស្រឡាញ់ គោរពខ្លាំង គេក៏ឃើញមានឧបករណ៍ប្រើប្រាស់ផ្សេងៗទៀត ត្រូវបានគេផលិតឡើងជារូបទន្សាយ ឬគូរឬឆ្លាក់ជារូបទន្សាយដូចជាសម្លៀកបំពាក់ កាបូបកាតាប ស្បែកជើង ប្រដាប់ប្រដាក្មេងលេង សម្ភារៈសិក្សា ប្រដាប់សន្សំលុយ ជាដើម។

## ១.៧. ហង្ស

ខ្មែរមានជំនឿក្នុងទេវកថាលើសត្វ ហង្ស (សុវណ្ណហង្ស) ថាជា ស្តេចបក្សី ហើរខ្ពស់ និងហើរបានឆ្ងាយ និងជាសត្វរកចំណីអាហារស៊ីត្រង់កន្លែងមានបរិស្ថាន ធម្មជាតិល្អ ស្អាត និង

[១១] ពុទ្ធសាសនបណ្ឌិត្យ ប្រជុំរឿងព្រេងខ្មែរភាគ២ រោងពុម្ពក្រសួងអប់រំ បោះពុម្ពឆ្នាំ២០០៣ សូមអានរឿង សុភាទន្សាយ រឿងទន្សាយនិងអ្នកបរទេស រឿងទន្សាយជាប់គូទនិងគល់ត្រាច រឿងបុរសដណ្តឹងប្រពន្ធ ។ល។

[១២] ពុទ្ធសាសនបណ្ឌិត្យ ប្រជុំរឿងព្រេងខ្មែរភាគ ២ រោងពុម្ពក្រសួងអប់រំ បោះពុម្ពឆ្នាំ២០០១ ទំព័រ៥៨.។

ត្រជាក់។ ក្នុងគម្ពីរលោកនីតិ បានចែងថា៖ **ឋី រមតិបុ ខុរមតិធំ ហឹរមតិបំ ហំរមតិបោ** ដែលមានន័យថា ស្ត្រីត្រេកអរចំពោះបុរសកិត្តុមានសីលស្រស់ត្រេកអរចំពោះធម៌ ក្របីត្រេកអរចំពោះភក់ជាបវរ សត្វហង្សនិករត្រេកអរចំពោះព្រះឈូក នេះមានន័យថា ហង្សតំណាងតម្លៃពោរពេញដោយ សោភណភាព ភាពស្មោះត្រង់ ភាពត្រជាក់ត្រជុំ ដែលជាទីប្រាថ្នាចង់បានរបស់ មនុស្សផងទាំងពួង។

ក្នុងវិស័យអប់រំ ទស្សនៈរបស់ខ្មែរយកពាក្យ ហង្ស មកប្រើភ្ជាប់ជាមួយពាក្យ គតិ បានជាពាក្យ ហង្សគតិ ដែលមានន័យថា មានចំណេះដឹងប្រពៃ ខ្ពង់ខ្ពស់លើសគេ។

ក្នុងវិស័យសេដ្ឋកិច្ច ទស្សនៈរបស់ខ្មែរយកហង្ស (សុវណ្ណហង្ស) តំណាងស្ថិរភាពផ្នែកហិរញ្ញវត្ថុ។ ការហើរខ្ពស់ និងហើរបានឆ្ងាយ តំណាងការអភិវឌ្ឍជឿនលឿន ខ្ពង់ខ្ពស់ឡើងជានិរន្ត និងវែងឆ្ងាយទៅអនាគត ដោយសម្របទៅតាមបរិស្ថានពិភពលោកយើងដែលកំពុងផ្លាស់ប្តូរ និងការអនុវត្តទៅតាមច្បាប់ជាតិ និងច្បាប់អន្តរជាតិយ៉ាងពេញលេញដើម្បីទទួលការអភិវឌ្ឍសេដ្ឋកិច្ច និងសុខុមាលភាពសង្គម។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ វិទ្យាស្ថានឯកទេសសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រូបសញ្ញារបស់ធនាគារអេស៊ីលេដាពីមុន... សុទ្ធតែបានដាក់រូបសត្វហង្ស ជាសញ្ញាសំគាល់ឬជាឡូហ្គោ (LOGO) របស់ខ្លួន គឺសុទ្ធតែបានឆ្លុះបញ្ចាំងនូវអត្ថន័យដូចដែលបានបង្ហាញនេះ។

លើសពីនេះទៅទៀត គេបានបកស្រាយថា អក្ខរក្រមសរសេរពាក្យ ហង្ស ចាប់ផ្តើមដោយអក្សរ ហ (Logogram) ស៊ីគ្នាជាមួយពាក្យហិរញ្ញវត្ថុ ដែលចាប់ផ្តើមដោយអក្សរ ហ (Logogram) ហើយ ហិរញ្ញវត្ថុ មានន័យថា ជាដុំមាស ឬ ជាដុំប្រាក់ ពោលគឺ តំណាងទ្រព្យសម្បត្តិ លុយកាក់ក្នុងគ្រួសារ ក្នុងសង្គម។

ក្នុងវិស័យសាសនា ហង្ស ជាយានជំនិះរបស់ព្រះព្រហ្ម។ ការហែសពព្រះមហាក្សត្រលើរថហង្ស គឺមានន័យថា ព្រះមហាក្សត្រតំណាងដោយព្រហ្មទេព ហើយក្រោយពេលសោយទិវង្គត ព្រះមហាក្សត្រនិងយាងទៅគង់នៅឋានព្រហ្ម ជាមួយព្រះព្រហ្ម។

### ១.៨. គ្រុឌ

គ្រុឌ ជាស្តេចបក្សី ជាសត្វអច្ឆរិយ មានកម្លាំងខ្លាំង តំណាងអានុភាព និងអំណាចលើអាកាស។ គ្រុឌ ជាជំនិះរបស់ព្រះវិស្ណុ។ ជំនឿលើសត្វនេះ មានប្រភពចេញពីឥណ្ឌា ហើយបានហូរចូលក្នុងទឹកដីខ្មែរ នៅសម័យអាណាចក្រហ្វូណន តាមរយៈព្រហ្មញ្ញសាសនា។ ក្នុងស្ថាបត្យកម្ម គេឆ្លាក់រូបមនុស្សគ្រុឌ (ខ្លួនជាមនុស្ស ក្បាលជាគ្រុឌ មានស្លាប) ដោយមានពាក់មុដ និងគ្រឿងអលង្ការ ហើយត្រូវបាន គេយកមកធ្វើជាទម្រដំបូលព្រះវិហារ ឬសំណង់ស្ថាបត្យកម្មនានាជាលំអផង ជានិមិត្តរូបនៃ

ភាពរឹងមាំ និងបំពាក់តេជបារមីលើលំហអាកាសផងដែរ។ នៅក្នុងជំនឿសាសនា បានបញ្ជាក់តាមគម្ពីរវេទ ថា សត្វដ៏មានឥទ្ធិពលនេះ វាអាចជួយ ថែរក្សានៅទីកន្លែងដ៏ពិសិដ្ឋនេះ មិនឱ្យមានកម្លាំងអាក្រក់ឬឧបទ្រពចង្រៃផ្សេងៗ មកបៀតបៀនបានឡើយ។

ក្នុងទស្សនៈខ្មែរ ចម្លាក់គ្រុឌដែលមានឥរិយាបថសម្តែងឫទ្ធិអំណាចរបស់ខ្លួន គឺជានិមិត្តកម្មនៃការបង្ហាញអំពីអំណាចដ៏ខ្លាំងពូកែរបស់ព្រះមហាក្សត្រខ្មែរ។ មានន័យថា គ្រុឌ តំណាងព្រះមហាក្សត្រដែលមានតេជបារមី ហើយក៏ក្នុងន័យតម្កើងជ័យជេស្ដារបស់ព្រះរាជាត្រូវចេញទៅធ្វើសឹកសង្គ្រាម ឱ្យបានជោគជ័យជាស្ថាពរផងដែរ។ ជាឧទាហរណ៍ សត្វគ្រុឌនៅប្រាសាទព្រះខ័ន ក្នុងឥរិយាបថសម្តែងឫទ្ធី ដែលមានជើងម្ខាងកំពុងជាន់ក្បាលសត្វពស់ ដៃម្ខាងកាន់កន្ទុយពស នេះជាតំណាងមហិទ្ធិរិទ្ធដ៏ធំធេងរបស់ព្រះមហាក្សត្រខ្មែរនៅក្នុងជំនាន់និមួយៗ។

### ១.៩. ដំរី

សង្គមខ្មែរនាសម័យបុរេអង្គរ និងអង្គរ តាមកំណត់ហេតុចិន គួបផ្សំនឹងសិលាចារឹក បានបង្ហាញថា សត្វដំរីបានបំពេញតួនាទីយ៉ាងសំខាន់ក្នុងកងទ័ព ក៏ដូចជាវិស័យជំនឿសាសនា ទំនៀមទម្លាប់ ហើយដំរីត្រូវបានចាត់ទុកជារតនសម្បត្តិសម្រាប់ស្តេចចក្រវាឡផងដែរ ដោយហេតុថា សត្វនេះអាចការពារព្រះរាជនគរអោយរួចផុតពីមហន្តរាយ ក្នុងឋានៈសត្វសិរីមង្គល ប្រចាំព្រះរាជនគរ។ ក្នុងទស្សនៈខ្មែរ គេផ្សងដំរីរកអ្នកមានបុណ្យ ដោយលែងដំរីឱ្យដើត្រាច់ចរ បើដំរីលុតជង្គង់ចុះនៅចំពោះមុខបុគ្គលណាម្នាក់ គឺបុគ្គលនោះជាអ្នកមានបុណ្យ ដែលអាចជ្រើសមកធ្វើជាស្តេច ឬមន្ត្រីរាជការ។ នៅក្នុងវិស័យជំនឿសាសនា ពោលគឺ នៅក្នុងពុទ្ធប្រវត្តិ ដំរីត្រូវបានចាត់ទុកជាប្រភពកំណើតអ្នកមានបុណ្យមកចាប់កំណើតផងដែរ។ ព្រះមាតារបស់ព្រះពុទ្ធ ព្រះនាងសិរិមហាមាយា សុបិន្តឃើញដំរីចូល ក្នុងឧទររបស់ព្រះនាង ព្រាហ្មណ៍ប្រចាំរាជវាំងបានទស្សន៍ទាយថា ព្រះនាងនឹងមានអ្នកមានបុណ្យមកចាប់កំណើត គឺទៅថ្ងៃខាងមុខ បើព្រះរាជបុត្រគ្រងរាជ នឹងក្លាយជាស្តេចចក្រពត្តិ តែបើសាងផ្នួសនឹងបានត្រាស់ដឹងជាព្រះពុទ្ធ។ តាំងពីបុរមបុរាណរៀងដរាបមក ខ្មែរយើងតែងតែចាត់ទុកដំរីជាសត្វតំណាងឱ្យទឹក ជាសត្វតំណាងនូវរិទ្ធអំណាច កម្លាំង ភាពរឹងមាំ ជាសត្វត្រដាក់ត្រដុំ ជាសត្វនាំមកនូវសុភមង្គល និងភាពសំបូររុងរឿង។ ជំនឿនេះបានចាក់ឫសយ៉ាងជ្រៅទៅក្នុងអារម្មណ៍ខ្មែរ រហូតដល់នាំគ្នាជឿតៗមកថា បើកាលណាយល់សប្តិឃើញដំរី នោះ ច្បាស់ជាមានភ្ញៀវជាមិនខាន។ អ្នកខ្លះជឿថា ដំរីនាំមកនូវជោគវាសនា ល្អ ធ្វើអ្វីៗតែងតែកើតចំរើនផល កាក់កបជានិច្ច។ ដូច្នេះហើយ បានជាស្រីៗនៅស្រុកស្រែខ្លះដែលចង់ចិញ្ចឹមសត្វ ឬធ្វើកសិកម្ម ឬប្រកបរបររកស៊ីឱ្យ

បានផលចំរើន គេតែងទៅនិយាយអង្វរហ្មដំរីឱ្យជួយគេឱ្យបានស្ទាបបបូរមាត់ក្រោមរបស់ដំរី។ ប្រជាជនខ្មែរ ពិសេសគ្រួសារអ្នកមាន ច្រើនតែយកភ្លុកដំរីទាំងគូរមកដាក់តាំងលើតុកិត្តិយស ឬលើខ្នងទូ ទុកជាគ្រឿងលម្អផ្ទះផង និងទុកជាទ្រព្យត្រជាក់ នៅក្នុងផ្ទះផង និងនិមិត្តរូបនៃឆ្មាំការពារទ្រព្យសម្បត្តិក្នុងផ្ទះផងដែរ។ ចំពោះ ក្មេងអារ៉ុះ គេយកវាទៅដាក់ពីក្រោមពោះដំរី ឬឱ្យដំរីដើរកន្ទង ឬដាក់ពីក្រោមមាត់ ដំរី ឱ្យដំរីយកប្រមោយវាស្ទាបក្បាលក្មេងនោះ ឬក៏ឱ្យដំរីព្រួសទឹកដាក់ខ្លួនប្រាណ ក្មេងនោះ ក្នុងក្តីសង្ឃឹមថា ធ្វើយ៉ាងនេះ ក្មេងនឹងបានជាសះស្បើយពីជំងឺពុំរ៉ៃរបស់វា ហើយវានឹងមានសុខភាពល្អ មានកម្លាំងពលំ មានប្រាជ្ញាស្មារតីល្អឡើងវិញ។

## ២. ទស្សនៈ និងជំនឿរបស់ខ្មែរអំពីខ្នាយតាន់ ភ្លុក ស្នែង ចង្កូម ចែ ...

ប្រជាជនខ្មែរមានជំនឿថា ខ្នាយតាន់របស់ជ្រូកព្រៃ គឺជាវត្ថុស័ក្តិសិទ្ធិដែលនាំមកនូវសន្តិសុខ សុវត្ថិភាព សិរីមង្គល និងសេចក្តីសុខចម្រុងចម្រើន។ ខ្មែរមានជំនឿថា ខ្នាយតាន់ដែលដុះនៅលើថ្វាសជ្រូកព្រៃ មានបារមីមានមហិទ្ធិរិទ្ធ ឬមានព្រលឹងស័ក្តិសិទ្ធិប្រថាប់នៅក្នុងនោះ ហើយបារមីនេះឯង ដែលពិបាកនឹងមាននរណាមួយអាចសម្លាប់វាដោយងាយៗឡើយ។ ហេតុដូច្នេះហើយ ទើបប្រជាជនខ្មែរជឿថា អ្នកដែលរើសបានខ្នាយតាន់ជ្រូកព្រៃយកមកប្រសិទ្ធីមន្តអាគមបន្ថែម ហើយទុកដាក់តាមខ្លួនជាប្រចាំ ឬស្រោបមាស ប្រាក់ ថ្នាទីន ធ្វើជាបន្តោងពាក់ លើខ្លួន គឺគេនឹងមានបារមីមានមហិទ្ធិរិទ្ធ ឬព្រលឹងស័ក្តិសិទ្ធិតាមថែរក្សាគាំពារ និងនាំឱ្យគេមានសេចក្តីសុខ សិរីសួស្តីជានិច្ចកាល។ អ្នកមានខ្នាយតាន់ជ្រូកព្រៃគេតែងតែមានត្រណមមួយចំនួនឱ្យបានខ្ជាប់ខ្ជួន គួបផ្សំនិងមន្តអាគមបន្ថែម ទៀតផងនោះបារមីនៃខ្នាយតាន់នេះនិងនៅរក្សាការពារ មិនឱ្យសត្រូវជិត ឆ្ងាយ ណាមកបៀតបៀន ឬយកឈ្នះលើខ្លួនគេបានឡើយ។

ភ្លុក ស្នែង ចង្កូម ចែ ជាអាវុធការពារខ្លួនដែលនៅជាប់នឹងសត្វ។ ក្នុងទស្សនៈ ខ្មែរមានជំនឿថា វត្ថុទាំងនេះមានព្រលឹងឬបារមីដែលប្រថាប់នៅថែរក្សា នឹងជួយ ការពារសត្វនោះនៅពេលមានសត្រូវមកបៀតបៀនវា។ ភ្លុក ស្នែង ចង្កូម ចែ តំណាង នូវអច្ឆរិយភាពតំណាងថាមពលពិសិដ្ឋនៃធម្មជាតិ ជាវត្ថុស័ក្តិសិទ្ធិ។ គេយក ភ្លុក ស្នែង ចង្កូម ចែ មកធ្វើជាគ្រឿងអលង្ការដូចជា ចិញ្ចៀន បន្តោងខ្សែកកងដៃ ពាក់ ការពារខ្លួន បាំងខ្នង រងមុខ សភាវៈអាក្រក់មិនឱ្យមកបៀតបៀនដល់រាងកាយ កុំឱ្យចង្រៃឧបទ្រព មកយាយី ឬការពារគ្រាប់រំសេវខណៈធ្វើសឹកសង្គ្រាម។ ភ្លុក ស្នែង ចង្កូម ចែ របស់សត្វព្រៃទាំងអស់នោះ ក៏ត្រូវបានគេយកមកធ្វើជាគ្រឿងតាំងក្នុងផ្ទះ ដោយគេយល់ថា ជាគ្រឿងនាំមកនូវសិរីមង្គល ភាពត្រជាក់ត្រជុំ សេចក្តី សុខចម្រើន ជាឆ្មាំការពារផ្ទះសម្បែង និងទ្រព្យសម្បត្តិក្នុងគេហដ្ឋានថែម

ទៀតផង។ លើសពីនេះទៅទៀត គេកប់ ក្អក ស្នែង ចង្កូម ចែ ជាមួយមនុស្សស្លាប់ ក្នុងនិម្មិត កម្មមួយដែលតំណាងសត្វដ៏មានមហិទ្ធិ រិទ្ធទៅ បម្រើ និងការពារព្រលឹងសាកសព។

### ៣. ទស្សនៈ និងជំនឿរបស់ខ្មែរនៅលើសម្រែកយំ សកម្មភាព និងបុគ្គលិក លក្ខណៈរបស់សត្វ

សត្វមានសត្តភាពសភាវគតិពិសេស លើសមនុស្ស ដោយអាចស្តាប់ឮសំឡេងតិច បំផុត មើលឃើញក្នុងទីងងឹត ដឹងពីបំរែ បម្រួលសីតុណ្ហភាព ដូចជា មៀម ឆ្កែ ឆ្មា... អាចមើលឃើញក្នុងទីងងឹត ហ៊ីង គីង្គក់ ស្រមោច អាចដឹងមេឃជិត ភ្លៀង។ ប្រជាជន ខ្មែរបានធ្វើការកត់សម្គាល់ សត្វមួយចំនួន ស្រែកយំ បន្ទាប់មកមានហេតុ ការណ៍អ្វីមួយ កើតឡើង។ ភាពទៀងទាត់ និងភាពជាក់លាក់ នៃហេតុការណ៍ កើតឡើងតាមសម្រែក សកម្មភាព និងបុគ្គលិកលក្ខណៈរបស់សត្វ ក៏ ក្លាយទៅជាជំនឿ ជាការគោរពបូជាតរៀងមក ដូចជា៖

#### ៣.១. សម្រែកខ្លែងស្រាក មៀម លលកខ្មោច

ខ្មែរធ្លាប់ជឿថា ខ្លែងស្រាក មៀម លលក ខ្មោច ជាអ្នកបំរើ ឬជាអ្នកនាំសាររបស់ខ្មោច ព្រាយ   បិសាច។ សម្រែក សត្វទាំងនេះនៅ ពេលយប់ ច្រើនតែធ្វើឱ្យមនុស្សម្នាក្មេងចាស់ ភ័យខ្លាច ញ័ររន្ធត់។ គេធ្លាប់ចំណាំថា បើកាល ណាខ្លែងស្រាកទំយំនៅលើដំបូលផ្ទះណា ឬក៏ ទំនៅលើ មែកឈើជិតផ្ទះណា មនុស្សក្នុងផ្ទះ នោះនឹងឈឺធ្ងន់ ឬស្លាប់ផង ក៏សឹងមាន។

#### ៣. ២. សំឡេងសត្វឪឡយំ

ចាស់ៗធ្លាប់និយាយថា មានសត្វឪឡពីរ ប្រភេទគឺ ឪឡគោ និង ឪឡស្វឹក។ ឪឡស្វឹក ជា ធម្មតាមានមាឌតូច ឯសម្រែករបស់វាក៏ពុំ បណ្តាលឱ្យមានគ្រោះមហន្តរាយអ្វីដែរ។ តែ ចំពោះឪឡគោវិញ មានមាឌធំជាង ត្នោត ឬកេងកង ហើយវាយំឮសូរ (ម៉! ម៉!...) ដូច សំឡេងគោយំអញ្ចឹង។ ប្រជាជនខ្មែរតែងមាន ជំនឿថា បើសត្វឪឡគោនេះយំបែរមុខឆ្ពោះ ទៅទិសណា ឬក្នុងភូមិណា វាជាប្រផ្នូលថា ទិសនោះ ឬស្រុកភូមិនោះ ច្បាស់ជាជួបគ្រោះ វិបត្តិភ័យ អន្តរាយ ដូចជា ជំងឺអំបល់ ស្លាប់រង្គះរង្គាល ដូចយ៉ាងជំងឺអុតធំ ជំងឺអាសន្នរោគ ទុរ្ភិក្សអត់ឃ្លាន ជាដើម។

#### ៣. ៣. ឈ្លូសចូលភូមិ

តាមជំនឿរបស់ប្រជាជនខ្មែរ ប្រសិនបើសត្វ ឈ្លូស រត់ចូលមកក្នុងភូមិ ទោះរត់កាត់ទទឹង ភូមិ ឬបណ្តោយភូមិក្តី ទោះរត់ធ្លងផុតរួចខ្លួន ក្តី ទោះត្រូវអ្នកស្រុកវាយសម្លាប់បានក្តី ចាស់ បុរាណតែងតែទស្សន៍ទាយប្រផ្នូលនេះថា ស្រុកភូមិនោះនឹងកើតមានវិបត្តិ ចលាចល ភ័យកិត ឬមានហេតុឧបទ្រពចង្រៃបែបណា មួយកើតឡើងជាមិនខាន ដូចជា ឈ្លោះទាស់ទែង បែកបាក់សាមគ្គីគ្នា មានកិតភ័យ ត្រូវ ឃ្លាតចាកចោលស្រុកភូមិ ឬមានកើតហេតុ ចង្រៃផ្សេងៗទៀត។ ជាទូទៅ គេត្រូវសម្តែងរបាំ

គ្រូតដើម្បីបោសឧបទ្រពចង្រៃនេះ និងនិមន្ត ព្រះសង្ឃ សូត្រមន្តរំដោះគ្រោះ បណ្ដេញ ឧបទ្រព។

**៣. ៤. ព្រួត និង ឃ្មុំ ចូលផ្ទះ**

ប្រជាជនខ្មែរតែងមានជំនឿថា បើឃ្មុំចូលផ្ទះ និង នាំមកនូវលាភសក្ការៈដល់ម្ចាស់ផ្ទះ តែកុំ ប៉ះពាល់វា។ ចំពោះព្រួតវិញ បើវាហើរ ចូល ផ្ទះណា ហើយមានទិចមនុស្ស សត្វក្នុងផ្ទះ នោះ តាមទំនាយចាស់ៗពីបុរាណថា នឹងមាន ឧបទ្រពចង្រៃ វិនាសទ្រព្យសម្បត្តិក្នុងផ្ទះនោះ ជាប្រាកដ មានកូន ចៅក្នុងផ្ទះឈឺ ឬងាប់គោ ក្របីជាដើម។

**៣. ៥. ក្រៀលយំ**

ប្រជាជនខ្មែរមានជំនឿតៗគ្នាមកថា កាល ណាគេឃើញសត្វក្រៀលមួយគូឬច្រើន ហើរ យ៉ាងខ្ពស់ជារង្វង់មូល ហើយយំបន្ទឺស្នូរយ៉ាង ក្រលួចនោះគេនាំគ្នាសន្មតថា នៅក្នុងស្រុកភូមិ នាតំបន់នោះ និងមានគ្រមុំកំម្លោះពង្រត់គ្នា។

**៣. ៦. សសេះយំ**

ប្រជាជនខ្មែរតែងចំណាំ និងមានជំនឿតៗ គ្នាមកថា ជនណាដែលនៅជិតកន្ទេងវាយំ ញាប់ រន្ទើននោះ ជាប្រផ្នូលល្អ ទំនាយទាយថា នឹង មានលាភអ្វីម្យ៉ាងមិនខាន។

**៣. ៧. ក្អែកបូល**

តាមជំនឿតៗគ្នាមក កាលណាគេឮក្អែកបូល គេតែជឿថា បងប្អូនគ្រួសារដែលឃ្លាតទៅ ឆ្ងាយនោះ នឹងវិលត្រឡប់មកវិញ ឬនឹងមាន ភ្ញៀវមកលេង។

**៣. ៨. កុកទំលើដំបូលផ្ទះ**

ចាស់បុរាណតែងតែកត់សម្គាល់ថា កាល ណាកុកទំលើដំបូលផ្ទះ គឺមានទំនាយថានឹង មានចង្រៃឧបទ្រពខ្លាំងណាស់។ គេតែងចង ក្រងជាពាក្យទំនៀមថា "...ចង្រៃដូចកុកទំផ្ទះ ដូចរន្ទះបាញ់ភូមិ..." បានន័យថា អព្វតហេតុ ទាំងពីរយ៉ាងនេះ ចង្រៃដូចគ្នា។ ដូច្នេះ កាល ណាមានហេតុភេទបែបនេះកើតឡើង ប្រជា ជនខ្មែរ ដែលមានជំនឿបែបនេះ តែងតែនិមន្ត ព្រះសង្ឃមក ចំរើនព្រះបរិត្តបណ្ដេញឧបទ្រព ចង្រៃ ឬក៏អញ្ជើញគ្រូមន្តអាគមមកបង្កក់ ប្រោះព្រំ កំចាត់នូវឧបទ្ទវហេតុនេះ ដើម្បីឱ្យ ម្ចាស់ផ្ទះរស់នៅក្នុងសុភមង្គលឡើងវិញ។

**៣. ៩. ពស់ថ្លាន់ចូលផ្ទះ**

ប្រជាជនខ្មែរតែងមានជំនឿថា បើកាលណា ពស់ថ្លាន់វារចូលមកនៅក្នុងផ្ទះឬនៅក្រោមផ្ទះ នោះ ជាប្រផ្នូលនាំមកមកនូវក្ដីសុខសប្បាយ និងលាភសំណាងដល់ម្ចាស់ផ្ទះ។ កាលណា ឃើញវាចូលមក គេត្រូវចាប់វាថ្នមៗ ហើយ បបោសអង្អែលលាបប្រេង លាបម្សៅ រួចដុត ធូប ហើយនិយាយថា" ឯង ចូលមកផ្ទះយើង នេះ សូមឯងនាំយកមកនូវលាភជ័យ សេចក្ដី សុខ សេចក្ដីចំរើន សុភមង្គលដល់យើង យើង លែងឯងឱ្យមានសេរីភាព ចូរឯងទៅរស់នៅ ក្នុងព្រៃ ឱ្យបានសេចក្ដីសុខចុះ"។

**៣. ១០. អំពិលអំពែកចូលផ្ទះ**

ចាស់បុរាណតែងមានជំនឿថា វានាំ យកលាភ សក្ការៈមកឱ្យម្ចាស់ផ្ទះនោះ។ កាល

បើឃើញអំពិលអំពែកហើរចូលផ្ទះ គេហាមកូនហាមចៅមិនឱ្យចាប់វាលេងឡើយ ព្រោះគេជឿថា បើកាលណាវាងាប់ដោយក្មេងចាប់ដៃធ្ងន់ពេកនោះ នឹងនាំឱ្យមានគ្រោះមហន្តរាយវិញ។ គេបង្គាប់កូនចៅឱ្យនិយាយថា "អំពិលអំពែកអើយកុំទៅផ្ទះគេ គេចាប់គេចងមកផ្ទះបង បងឱ្យកងពាក់ បាក់មួយទៅ បងឱ្យមួយទៀត ..."។

### ៣. ១១. តុកកែយំ

ចាស់ៗធ្លាប់ប្រាប់តៗគ្នាមកថា បើតុកកែណាយំតិចជាង ៧ ម៉ាត់ នោះពុំល្អឡើយ ព្រោះវាបកស្រាយនូវឋាមពលខ្សោយ (រាសីដាក់ វាសនាតិច) ដែលចាស់ៗប្រាប់ឱ្យដេញវាចេញពីផ្ទះ។ បើតុកកែណាដែលយំចាប់ពីប្រាំពីរម៉ាត់ រហូតទៅដល់១៥ឬ១៨ម៉ាត់នោះលោកទាយថា ល្អពន់ពេកណាស់ គួរលៃថែរក្សា វាឱ្យនៅជាប្រចាំនៅក្នុងផ្ទះ ព្រោះតាមរយៈចំនួនម៉ាត់ដែលវាយំបានច្រើនយ៉ាងនេះ វាជាការបកស្រាយនូវឋាមពលខ្លាំងក្លា (រាសីខ្ពស់ ជោគជតាល្អវិសេស)។

### ៣. ១២. អំពីព្រាបចូល ឬ ព្រាបចេញ

ចាស់ៗធ្លាប់មានជំនឿថា បើកាលណា គេឃើញសត្វព្រាបហើរទាំងហ្វូងមកអាស្រ័យនៅលើផ្ទះណា នោះជាសញ្ញាប្រាប់ឱ្យដឹងថា គ្រួសារនោះនឹងមានជោគជតារាសីល្អ គួរថែរក្សាការពារឱ្យវារស់នៅជារៀងរហូតតទៅ វាពិតជាបានល្អ ត្រជាក់ត្រជុំមិនខាន។ ផ្ទុយទៅវិញ បើកំពុងតែរស់នៅលើផ្ទះណាមួយសុខៗស្រាប់តែនាំគ្នាហើរចេញពីផ្ទះលែងនៅតទៅទៀត នោះជាសញ្ញាប្រាប់ឱ្យដឹងថា រាសីម្ចាស់ផ្ទះនឹងធ្លាក់ចុះ និងមានហេតុភេទមិនល្អ តទៅថ្ងៃមុខៗ

### ៣. ១៣. វត្តមានសត្វចាបដូនតា

សត្វនេះ មានវត្តមានតាមកាល ពោលគឺមិន មែនរស់នៅជាអចិន្ត្រៃយ៍ដូចអស់សត្វបក្សាបក្សីផ្សេងឯទៀតឡើយ។ ខ្មែរយើងធ្លាប់ជឿតៗគ្នាតាំងពីរយូរមកហើយថា សត្វចាបដូនតានេះ ជាតំណាងព្រលឹង ដូនតាខ្មែរទាំងអស់ មានទីស្នាក់អាស្រ័យនៅជាអចិន្ត្រៃយ៍នៅឯព្រៃហេមពាន្តឯ ណោះ។ តែកាលណាចូលដល់ជិតពាក់កណ្ដាលខែភទ្របទហើយនោះ សត្វចាប ដូនតាបានធ្វើដំណើរពីព្រៃហេមពាន្តមកដល់ប្រទេសខ្មែរ។ ត្រង់នេះស្រប នឹងជំនឿខ្មែរថា នៅវស្សាន រដូវ ពេលដែលមេឃមានពពកខ្មៅមីដេរដាស មានភ្លៀងធ្លាក់ជោគជាំ ទាំងយប់ថ្ងៃឥតស្រាក មានផ្គរលាន់ឮសូរគគ្រឹមឮដ៏អាកាសនោះ ស្ដេចយមបាលបានបើកលែងព្រលឹងខ្មោចដូនតាដែលមានទោសជាប់នៅឯស្ថាននរកនោះ ឱ្យមករកកូនចៅដើម្បីបានទទួលអាហារភោជនា ដែលកូនចៅតែងនាំគ្នាទៅធ្វើបុណ្យបញ្ជូនកុសលនៅតាមវត្តអារាមនានា។ តាមចំណាំ សត្វចាបដូនតាមកកាន់ស្រុកខ្មែរយើងក្នុងកាលវេលាមួយទៀង ទាត់ ណាស់ គឺ ចូល ដល់ ជិត ពាក់កណ្ដាលខែភទ្របទមកដល់ លុះចប់រដូវភ្ជុំបិណ្ឌហើយ ក៏ស្រាប់តែទៅបាត់អស់។

ចាស់ៗធ្លាប់និទានថា លុះផុតរដូវភ្ជុំបិណ្ឌ ហើយ សត្វចាបដូនតាដែលជាតំណាងព្រលឹងដូនតា បានលាយើងជាកូនចៅវិលត្រឡប់ទៅលំនៅឋានឯព្រៃ ហោមពាន្តវិញៗ លុះដល់ខែភទ្របទ រដូវភ្ជុំបិណ្ឌឆ្នាំក្រោយ ទើបមកម្តងទៀត។

**៣. ១៤. ឆ្មាចូលផ្ទះ**

បុព្វបុរសខ្មែរតែងតែមានជំនឿតៗគ្នាមកថា កាលណាឆ្មាចូលមកនៅក្នុងផ្ទះយើងនោះ ចាត់ទុកជាប្រផ្នូលល្អណាស់។ គេសន្មតថា ប្រហែល ជាអានុភាពជាអាថ៌កំបាំងអ្វីបណ្តាលចិត្តឱ្យសត្វនេះចូលមកនៅក្នុងផ្ទះយើង ក្នុងន័យនាំយកទ្រព្យសម្បត្តិ លាភជ័យល្អមកឱ្យយើង។ អាចគិតថា ប្រហែលជាផ្ទះនោះជាទីត្រជាក់ ត្រជុំសុខក្សេមក្សាន្តហើយបានជាសត្វនេះសុំមកជ្រកកោននៅជាមួយ ដើម្បីសុំសេចក្តីសុខ។ ចាស់ៗធ្លាប់ពោលថា ឆ្មាវាបន់ឱ្យតែម្ចាស់ មាន នឹងបានដេកពួក។

**៣. ១៥. ឆ្កែលូ**

បើនៅពេលយប់ស្ងាត់ គេឮឆ្កែលូយ៉ាងវែងបន្លឺសូរគ្រលួចបែបលន្ទង់លន្ទោច សូរគួរឱ្យព្រឺក្បាល គឺចាស់ៗតែងតំណាលថា ឆ្កែឃើញខ្មោច ព្រាយ បិសាច ដើរ គេមិនត្រូវធ្វើដំណើរចេញក្រៅទេ ខ្លាចក្រែងប៉ះពារដល់ ខ្មោច ព្រាយ បិសាច នាំមកនូវទុក្ខបុកម្នេញ (ផ្លូវងងឹតដើរចម្រាញ់ កាប់ក្តារ) និងជាប្រផ្នូលមិនល្អសំរាប់ស្រុកភូមិទៅថ្ងៃមុខ។ ចាស់តែងតែជឿថា ស្រុកទេស នឹងមានចម្បាំងរាំងជល់ ទុរ្ភិក្សអត់ឃ្លាន ឬមានជំងឺរាតត្បាត។

**៣. ១៦. គោក្រយៅក្រឡាច់**

គេមើលដឹងលក្ខណៈល្អ ឬអាក្រក់របស់គោដោយ សារក្រយៅរបស់វា។ ក្រយៅដែលអាក្រក់នោះគឺ ក្រយៅក្រឡាច់ ក្រយៅឈ្វេកក្រោល ក្រយៅរំកាយខ្វាត់ ក្រយៅដាក់លាញៗល។ ប្រជាជនខ្មែរមានជំនឿថា គោណាដែលមានក្រយៅមានកិនភាគដូចពោលមកនេះ គេចាត់ទុកជាសត្វចង្រៃ គេរិះរកគ្រប់វិធីដើម្បីលក់ ឬដូរចេញឱ្យផុតពីផ្ទះ។ បើកាលណានៅតែរឹងរូសប្រើប្រាស់ ឬចិញ្ចឹមគោប្រភេទនេះ គេជឿថា នឹងមានហេតុអន្តរាយវិនាសទ្រព្យសម្បត្តិ ឬមនុស្សក្នុងគ្រួសារឈឺថ្កាត់ ស្លាប់ព្រាត់ប្រាសក៏សឹងមាន។ អំពីលក្ខណៈចង្រៃបែបនេះ ខ្មែរយើងធ្លាប់មានពាក្យស្លោកពោលថាៈ អំពិលឯត្បូង អណ្តូងឯលិច គោក្រយៅក្រឡាច់ ប្រពន្ធដោះញ កុំយកខ្ជួនបៀត។ មានន័យថា បើមានដើមអំពិល នៅពីខាងត្បូងផ្ទះ បើមានអណ្តូងនៅខាងលិចផ្ទះ បើមានគោក្រយៅក្រឡាច់ បើមានប្រពន្ធដោះញ នោះបុរាណាចារ្យលោកចំណាំថាចង្រៃពន់ពេកណាស់។

**៣. ១៧. ហ្វូងត្រដេវទិច**

ចាស់ៗខ្មែរធ្លាប់និយាយជាពាក្យទំនឹមទំនៀមថាៈ ដេកយកជើងទ្រមេឃ ដូចសត្វត្រដេវរិច។ មានន័យថា ជាមនុស្សប្រយ័ត្នប្រយែង មានការភ័យបារម្ភច្រើន។ តែចំពោះ

ចាស់បុរាណគាត់ធ្លាប់ចំណាំតៗគ្នាមកថា បើនៅពេលយប់ស្ងាត់ មានសត្វត្រដេវរ៉ិចចាល់ទាំងហ្វូង ហើយយំទ្រហឹងអឹងអាប់ នោះច្បាស់ជាមានពពួកចោរហោរយមកលួចប្លន់នៅភូមិណាមួយក្នុងតំបន់នោះ ហើយ គេត្រូវនាំគ្នាប្រុងប្រយ័ត្នឡើង។

## ៣. ១៨. សត្វជើងបី

តាមធម្មតា សត្វចតុប្បាទ ដូចជា គោ ក្របី សេះ ដំរី ជ្រូក ឆ្កែ ឆ្មា ជាដើម តែងតែមានជើងបួនជាដរាប។ ប្រជាជនខ្មែរកំណត់ថា សត្វចតុប្បាទជើង៣ មិនមែនវាមានជើងតែ៣ទេ។ តើគេសំគាល់ត្រង់លក្ខណៈបែបណា ដែលសត្វចតុប្បាទមានជើង៤ ថា ជាជើង៣ទៅវិញ? គេសំគាល់ថា សត្វជើង៣ ចំពោះតែសត្វដែលជើងទាំងបួនរបស់វាមានសម្បុរមិនដូចគ្នា។ ឧទាហរណ៍ ជើង បីសម្បុរខ្មៅ ជើងមួយសម្បុរស ឬផ្ទុយមកវិញ ជើងបីសម្បុរស ជើងមួយសម្បុរ ខ្មៅ នេះគេចាត់ថា សត្វនោះមានជើងបីហើយ។ បើសត្វដែលគេចិញ្ចឹមណាដែលមានលក្ខណៈដូចពោលខាងលើនេះ គេមិនចិញ្ចឹមទេ គេចាត់ទុកថា ជាសត្វចង្រៃនាំមកនូវទុក្ខទោស ឧបទ្រព អពមង្គលដល់ម្ចាស់ជាមិនខាន។ គេត្រូវ យកវាទៅលែងនៅវត្ត ហើយនិមន្តព្រះសង្ឃសូត្រមន្តរំដោះគ្រោះ។

## ៣. ១៩. កូនក្របីឃ្លៀច

តាមពូជរបស់វា ក្របីមានពីរពណ៌គឺសម្បុរខ្មៅ និង សម្បុរឃ្លៀច (ពណ៌សព្រឿងៗ)។ ចំពោះអ្នកដែលចិញ្ចឹមក្របីខ្មៅទាំងហ្វូងៗឱ្យដេករួមគ្នានៅក្នុងក្រោលតែមួយនោះ បើកាលណាមានមេក្របីខ្មៅណាមួយកើត កូនមកជាក្របីឃ្លៀច នោះគេជឿថា ជាបុព្វនិមិត្តប្រាប់ឱ្យដឹងអំពីការស្លាប់រង្គាល នៃហ្វូងក្របីឃ្លៀច ឬហ្វូងក្របីខ្មៅដោយសារជំងឺអំបល់[13]។

## សេចក្ដីសន្និដ្ឋាន

សរុបសេចក្ដីមក ជំនឿលើសត្វ ជំនឿលើខ្លាយតាន់ ក្អុក ស្នែង ចង្កូម និងជំនឿ ើ ី សម្រែកសត្វយំ ជំនឿលើសកម្មភាពនិងសភាពបុគ្គលិកលក្ខណៈរបស់សត្វ … ជាជំនឿតូតឹមនិយម របស់បុព្វបុរសខ្មែរតាំងពីបុរេប្រវត្តិសាស្ត្រមកម្ល៉េះ។ ជំនឿនេះ ជាមែកធាងនៃខឿនវប្បធម៌ និងអារ្យធម៌របស់ជនជាតិខ្មែរ ដែលឆ្លុះបញ្ចាំងឱ្យឃើញពីគំនិតទស្សនវិជ្ជាដំបូងក្នុងការតស៊ូដើម្បីរស់រានមានជីវិត គេឧប្បត្តិកនូវជំនឿនេះឡើងដើម្បីលើកទឹកចិត្តគេឱ្យមានភាព ក្លាហានក្នុងការតស៊ូទប់ទល់នឹងធម្មជាតិ និងសត្រូវមកបៀតបៀន និងជាការលួងលោមចិត្តថា ខ្លួនមានកម្លាំងអមនុស្ស និងកម្លាំងអធិធម្មជាតិជួយគេគ្រប់ខណៈក្នុងជីវិត។ លុះព្រហ្មញ្ញ សាសនា និង

13 http://km.wikipedia.org/w/index.php?title=ឥទ្ធិពលរបស់សត្វមកលើជីវភាពមនុស្សខ្មែរ & oldid =159379

ពុទ្ធសាសនាលាតសន្ធឹងឥទ្ធិពលមកដល់សុវណ្ណភូមិ ហើយក្នុងទ្រឹស្តីសាសនាទាំង២ មានការគោរពជឿលើ សត្វ ជាអវតារបស់ព្រះ ជាយានជំនិះរបស់ព្រះ ជាអ្នកនាំសាររបស់ព្រះ … ស៊ីគ្នាជាមួយទស្សនៈរបស់ខ្មែរ ខ្មែរក៏ទទួយក ហើយស្វំលាយចូលគ្នាទៅជារបស់ខ្មែរ។ ជំនឿតូតឹមនេះ ជាអស្ថិរូបវិជ្ជា (បរមត្ថវិជ្ជា) លាតត្រដាងនូវទ្រឹស្តីពុទ្ធិដំបូងរបស់មនុស្សខ្មែរ ហើយត្រូវបានអនុវត្តក្នុងសោភណវិជ្ជា និងសីលវិជ្ជា ទោះបីជាគ្មានតក្កភាពទាំងស្រុង តែការយល់ដឹងនិងការបកស្រាយនេះមានឥទ្ធិពលធំធេងមកលើជីវភាពរស់នៅ ទឹកចិត្ត អារម្មណ៍ និងក្លាយជាផ្នត់គំនិតរបស់ប្រជាជនខ្មែរតាំងពីបុរេប្រវត្តិសាស្ត្ររហូតដល់បច្ចុប្បន្ន។ ទន្ទឹមនឹងនេះដែរ យើងក៏បានរកឃើញថា៖ អន្តរទំនាក់ទំនងរវាងសត្វ នឹងមនុស្សខ្មែរ ផ្សារភ្ជាប់គ្នាយ៉ាងស្អិតរមួតនៅគ្រប់កាល និងលំហ។ ក្នុងផ្នែកចម្លាក់ ជួនកាល គេបានឆ្លាក់ខ្លួនជាមនុស្ស ក្បាលជាសត្វ ជួនកាលខ្លួនជាសត្វក្បាលជា  មនុស្ស។ ប្រជាជនខ្មែរបានផ្សារភ្ជាប់សត្វទៅនឹងពេលវេលា និងទីកន្លែង។ ថ្ងៃ ខែ ឆ្នាំ សុទ្ធតែតំណាងដោយសត្វ មាននាមសត្វ។ នៅក្នុងផ្នែកភាសាវិទ្យា ស្រៈ និងព្យញ្ជនៈ ការដាក់ឈ្មោះ មនុស្ស ក៏តាងដោយសត្វ និងនាមសត្វដែរ[14]។ ដូចនេះ យើងឃើញថា ជំនឿលើសត្វនេះ ជាឫសគល់ទស្សនវិជ្ជាខ្មែរមួយ ដែលដក់ជាប់ក្នុងចិត្តគំនិតខ្មែរតាំងពីបុរាណកាលរហូតមកដល់ បច្ចុប្បន្ន។

[14] លី សុវីរៈ៖ ក្បួនឱ្យឈ្មោះកូនក្នុងសង្គមខ្មែរ ភ្នំពេញ រោងពុម្ព ម៉េងហាវ បោះពុម្ពលើកទី៣ ឆ្នាំ២០១០ ទំព័រ ១-៣៥។

**ឯកសារពិគ្រោះ**


១-សាកលវិទ្យាល័យបញ្ញាជាតិ៖ ខេមរៈសិក្សា ភ្នំពេញ ឆ្នាំ២០១០ ទំព័រ ៥១។

២-ព្រឹត្តបត្រទំនាក់ទំនងការស្រាវជ្រាវនៅកម្ពុជាលេខ១ ខែមិថុនា ១៩៩៧ ចេញផ្សាយដោយសាលាបារាំងចុងបូព៌ា ទំព័រ៣២។

៣-រស់ ចន្ទ្រាបុត្រ៖ ប្រវត្តិសាស្ត្រខ្មែរ ភាគទី១(ភាគរឿងនិទាន និង តាមសិលាចារឹក) បោះពុម្ពនៅរោងពុម្ព L'Harmattan ធីយេស៍ ប្រទេសបារាំង ឆ្នាំ១៩៩៧ ទំព័រ៣៦-៣៧។

៤-ពុទ្ធសាសនបណ្ឌិត្យ ប្រជុំរឿងព្រេងខ្មែរភាគ២ រោងពុម្ពក្រសួងអប់រំ បោះពុម្ពឆ្នាំ២០០៣ សូមអានរឿង សុភាទន្សាយ រឿងទន្សាយនិងអ្នកបរទេស រឿងទន្សាយជាប់គូទនិងគល់ត្រាច រឿងបុរសដណ្ដឹងប្រពន្ធ ។ល។

៥-ពុទ្ធសាសនបណ្ឌិត្យ ប្រជុំរឿងព្រេងខ្មែរភាគ ២ រោងពុម្ពក្រសួងអប់រំ បោះពុម្ពឆ្នាំ២០០១ ទំព័រ ៥៨.។

៦-លី សុវីរៈ៖ ក្បួនឱ្យឈ្មោះកូនក្នុងសង្គមខ្មែរ ភ្នំពេញ រោងពុម្ព ម៉េងហាវ បោះពុម្ពលើកទី៣ ឆ្នាំ ២០១០ ទំព័រ ១-៣៥។

៧-អ្នកចូលរូប(រូបស្នង)ឈ្មោះ ថុល អាយុ៥៤ឆ្នាំ នៅភូមិស្ពានថ្មី ឃុំរការកោង៣ ស្រុកមុខកំពូល ខេត្តកណ្ដាល។

៨-អ្នកចូលរូប(រូបស្នង)ឈ្មោះ តោ សេង អាយុ៧៩ឆ្នាំ នៅភូមិព្រែកជីក ឃុំកោះចិនស្រុកពញាឮ ខេត្តកណ្ដាល។

៩-Fujiwara : ***Khmer Ceramics from the Kumaratan Collection***, Singapore Oxford University Press, 1990, p.597.

១០-Charles Higham and Rachanie Thosarat : ***Prehistorics Thailand***, 1998, p.55.

១១- Louis Malleret : ***L'Archeaology du delta du Mekong***, Paris, 1962, Vol.43, Tome III, p.57.

១២-K, Bhattacharyya : ***Les Religions dans L'Ancien Cambodge***, EFFEO, Paris, 1949, Vol.49.

១៣-Cristope Pottier : ***Perspective de la mission archaeologique France-Khmere sure láménagement du Territior Angkor*** ឆ្នាំ២០០១ ឧទ័យលេខ២ ទំព័រទី១២៩។

# ភ្នំពេញនិងបម្លាស់លំនៅ

## Phnom Penh and Migration

ដោយៈ **លោក ហៃ សុគន្ធា**

មន្ត្រីស្រាវជ្រាវនាយកដ្ឋានភូមិវិទ្យានិងនគរូបនីយកម្ម

នៃវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម

Email: haysokunthea@yahoo.com

## សេចក្តីផ្តើម

ភ្នំពេញ (Phnom Penh) គឺជារាជធានីរបស់ព្រះរាជាណាចក្រកម្ពុជា ដែលមានដង់ស៊ីតេប្រជាជនរស់នៅច្រើនជាងគេ រហូតដល់៣៣១៦នាក់[1] ក្នុងមួយគីឡូម៉ែត្រការ៉េ និងជាទីក្រុងធំលំដាប់ទី១ ដែលមានប្រជាជនរស់នៅច្រើនជាងគេផងដែរ។ ភ្នំពេញ ជាមជ្ឈមណ្ឌលពាណិជ្ជកម្ម ដែលប្រមូលផ្តុំទៅដោយ សំណង់អគារលំនៅដ្ឋាន សាលារៀន មន្ទីរពេទ្យ វត្តអារាម ទីផ្សារដោះដូរមុខទំនិញ លើមុខជំនួញជួញដូរផ្សេងៗ ទាំងក្នុងស្រុក និងក្រៅស្រុក រួមបញ្ចូលទាំងសេដ្ឋកិច្ចទីផ្សារ សង្គមកិច្ច និង នយោបាយ ពោលគឺជាទីកន្លែងរស់នៅប្រកបដោយភាពសម្បូរបែបៗ តាមប្រវត្តិសាស្ត្រ រាជធានីភ្នំពេញ ត្រូវបានសាងសង់លើកដំបូង នៅក្នុងឆ្នាំ១៤៣៤ នៃរជ្ជកាលព្រះបាទស្រីសុរិយោព័រ (ពញាយ៉ាត) នៅពេលដែលទ្រង់បានចាកចោលរាជធានីអង្គរ ប៉ុន្តែមិនបានឋិតថេររហូតដល់បច្ចុប្បន្ននេះទេ។ ដំណាក់កាលទីពីរ គឺសាងសង់នៅក្នុងឆ្នាំ១៨៦៥ នៃរជ្ជកាលព្រះបាទនរោត្តម ហើយបានក្លាយទៅជារាជធានីជាក់លាក់មួយ បន្តរហូតដល់បច្ចុប្បន្ននេះ។ លំនៅដ្ឋានជាច្រើនរបស់ប្រជាជននាពេលនោះ គឺធ្វើអំពីឫស្សីប្រក់ដំបូលស្លឹក ហើយមានមុខរបរជាអ្នកជំនួញ នេសាទ និងធ្វើស្រែចម្ការចម្រុះទៅដោយជាតិសាសន៍ ជាច្រើន ដូចជា ខ្មែរ ចិន យួន ជ្វា ជាដើម។ គោលនយោបាយថ្មី របស់ព្រះបាទនរោត្តមនាពេលនោះ គឺការពង្រីកទីក្រុងដោយបានស្ថាបនាអគារថ្មីៗជំនួសឱ្យផ្ទះឫស្សីប្រក់ស្លឹក ជាពិសេស ផ្ទះនៅតាមតំបន់ជួរមាត់ទន្លេ។ ក្រោមការគ្រប់គ្រងរបស់អាណានិគម

---

[1] ក្រសួងផែនការ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនទូទៅនៃប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩

បារាំង ហេដ្ឋារចនាសម្ព័ន្ធជាច្រើននៅក្នុងរាជធានីភ្នំពេញ ត្រូវបានរៀបចំដោយវិស្វករបារាំង ពោលគឺចម្លងតាមគម្រូស្ថាបត្យកម្មនៅក្នុងទីក្រុងប៉ារីស។ រចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាល រាជធានីភ្នំពេញនាពេលនោះ គឺបែងចែកជាបីសង្កាត់ ដែលមានទីតាំងស្ថិតនៅបន្តគ្នា តាមបណ្តោយមាត់ទន្លេ ពីជើងទៅត្បូង ហើយសម្គាល់ដោយក្រុមជាតិសាសន៍ផ្សេងៗគ្នារស់នៅ។ នៅខាងជើងក្បែរវត្តភ្នំ គឺជាសង្កាត់បារាំង ដែលមានពួកអឺរ៉ុបរស់នៅ មានព្រំប្រទល់ជាប់នឹងព្រែកជីកមួយ។ បន្តភ្ជាប់មកខាងត្បូងមុំផ្សារកណ្តាល គឺជាសង្កាត់ចិន ដែលមានជនជាតិចិនរស់នៅជុំវិញផ្សារ មានព្រំប្រទល់ជាប់នឹងព្រែកពាមផុង ហើយខាងត្បូងជាប់នឹងវាលព្រះមេរុ។ រីឯសង្កាត់ខ្មែរវិញ គឺមានទីតាំងស្ថិតនៅមុំព្រះបរមរាជវាំង និងលាតសន្ធឹងចុះទៅផ្នែកខាងត្បូង។ រជ្ជកាល ព្រះបាទស៊ីសុវត្ថិ បានបន្តរៀបចំហេដ្ឋារចនាសម្ព័ន្ធ រាជធានីភ្នំពេញកាន់តែមានភាពទំនើបថែមទៀត ដោយមានការស្ថាបនាអគារសាធារណៈជាច្រើន និងបានពង្រីកសង្កាត់នីមួយៗឱ្យកាន់តែធំបន្ថែមទៀត។ ក្រោយទទួលបានឯករាជ្យ ពីបារាំង ថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ រាជធានីភ្នំពេញ បានពង្រីកខ្លួនយ៉ាងឆាប់រហ័ស ពោលគឺ មានបម្លាស់លំនៅរបស់ប្រជាជន ពីគ្រប់តំបន់នានាទូទាំងប្រទេស។ ផ្ទុយទៅវិញ ក្រោយរដ្ឋប្រហារ ថ្ងៃទី១៨ មីនា ១៩៧០ បានធ្វើឱ្យដំណើរអភិវឌ្ឍន៍ក្នុងវិស័យរៀបចំក្រុង ត្រូវបានគាំងស្ទះ រហូតដល់ប្រជាជន ត្រូវបានជម្លៀសដោយបង្ខំចេញពីរាជធានីភ្នំពេញ ហើយហេដ្ឋារចនាសម្ព័ន្ធ និងសេវាសាធារណៈជាច្រើនទៀត ត្រូវបានទុកចោលទាំងស្រុង ពោលគឺរាជធានីភ្នំពេញនាពេលនោះ គឺជាទីក្រុងខ្មោច។

បម្លាស់លំនៅ គឺជាកត្តាមូលដ្ឋានមួយនៃកំហាយនិងកំណើនប្រជាជន តាមតំបន់នីមួយៗនៃពិភពលោក ពោលគឺពីតំបន់អសន្តិសុខទៅតំបន់ដែលមានសុវត្ថិភាព ពីប្រទេសកំពុងអភិវឌ្ឍទៅប្រទេសអភិវឌ្ឍ ជាដើម។ បម្លាស់លំនៅអន្តរជាតិ (ឆ្លងមហាសមុទ្រ ឆ្លងទ្វីប ឆ្លងប្រទេស) គឺជាបម្លាស់លំនៅមួយ ដែលបណ្តាលឱ្យមានរបាយ និងសមាមាត្រពូជសាសន៍ផ្សេងៗគ្នា គួរឱ្យកត់សម្គាល់ ដូចជា បម្លាស់លំនៅរបស់ជនជាតិស្បែកខ្មៅក្នុងសតវត្សទី១៦ និង ១៧ ពីទ្វីបអាហ្វ្រិកទៅកាន់ទ្វីបអាម៉េរិក (សហរដ្ឋអាម៉េរិក) បម្លាស់លំនៅពីទ្វីបអឺរ៉ុបទៅកាន់ទ្វីបអាម៉េរិក ក្នុងសតវត្សទី១៧ និងពីទ្វីបអាហ្វ្រិកទៅទ្វីបអឺរ៉ុប ក្នុងសតវត្សទី២០ និង២១ ជាដើម។

ប្រទេសកម្ពុជា ក៏បានឆ្លងកាត់ព្រឹត្តិការណ៍បម្លាស់លំនៅក្នុងប្រទេស ជាករណីដោយឡែករបស់ខ្លួនដែរ ព្រមទាំងត្រូវបានគេរាប់បញ្ចូលទៅក្នុងបណ្តាប្រទេសនៅក្នុងអាស៊ីអាគ្នេយ៍ ដែលមានបម្លាស់លំនៅអន្តរជាតិ ដោយឆ្លងកាត់ដំណាក់កាលប្រវត្តិសាស្ត្រជាច្រើន ទៅកាន់ទ្វីប ឬ

ប្រទេសគោលដៅផ្សេងៗ ដូចជាប្រទេសបារាំង សហរដ្ឋអាម៉េរិក អូស្ត្រាលី ជាដើម។

បម្លាស់លំនៅ គឺសំដៅលើដំណើរផ្លាស់ទីរបស់មនុស្ស សត្វ ឬរុក្ខជាតិ ជាបណ្ដោះអាសន្ន ឬស្ថាពរ ពីតំបន់មួយទៅកាន់តំបន់ផ្សេង[2]។ នៅក្នុងខ្លឹមសារនៃអត្ថបទស្រាវជ្រាវនេះ គឺផ្ដោតជាសំខាន់អំពីបម្លាស់លំនៅរបស់មនុស្ស ពោលគឺការផ្លាស់ទីលំនៅរបស់ប្រជាជនកម្ពុជានៅក្នុងរាជធានីភ្នំពេញ ដោយឆ្លងកាត់ព្រឹត្តិការណ៍ប្រវត្តិសាស្ត្ររបស់ប្រទេស ជាពិសេសគឺព្រឹត្តិការណ៍នៃសង្គ្រាមស៊ីវិលផ្ទៃក្នុងកម្ពុជា។

នៅក្នុងអត្ថបទស្រាវជ្រាវនេះ មានគោលបំណងផ្ដោតជាសំខាន់ទៅលើចលនាបម្លាស់លំនៅប្រជាជននៅក្នុងរាជធានីភ្នំពេញ ដោយឆ្លងកាត់ព្រឹត្តិការណ៍សង្គមនានា ដែលកម្ពុជាបានឆ្លងកាត់ និងផលវិបាកដោយសារបម្លាស់លំនៅញឹកញាប់របស់ប្រជាជនកម្ពុជា។ បើទោះបីបច្ចុប្បន្នកម្ពុជា បានទទួលនូវសុខសន្តិភាពជំពេញលេញក្រោមនយោបាយឈ្នះឈ្នះក៏ដោយ ក៏មូលដ្ឋានបម្លាស់លំនៅរបស់ប្រជាជនខ្មែរមួយចំនួនមិនបានសម្រាលបន្ទុកកម្រិតជីវភាពរស់នៅប្រចាំថ្ងៃរបស់ខ្លួនដែរ។

## ១- ព្រឹត្តិការណ៍សង្គមនិងបម្លាស់លំនៅ

ការផ្លាស់ប្ដូរទីលំនៅរបស់មនុស្ស តែងតែផ្សារភ្ជាប់ទៅនឹងមូលហេតុផ្សេងៗ ដូចជាព្រឹត្តិការណ៍សង្គមនានា មូលហេតុសេដ្ឋកិច្ច និងមូលហេតុផ្សេងៗទៀត។ ជាក់ស្ដែង នៅក្នុងព្រះរាជាណាចក្រកម្ពុជា មូលហេតុចម្បងមួយនៃការផ្លាស់ប្ដូរទីលំនៅរបស់ប្រជាជនកម្ពុជា ឆ្លងកាត់ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រសង្គម គឺសង្គ្រាម។ ក្រោយទទួលបានឯករាជ្យពីអាណានិគមបារាំង និងក្រោមឥទ្ធិពលសង្គ្រាមត្រជាក់ កម្ពុជាបានឆ្លងកាត់ព្រឹត្តិការណ៍សំខាន់ៗ ដូចជា៖

- សង្គមរាស្ត្រនិយម
- សាធារណរដ្ឋខ្មែរ
- កម្ពុជាប្រជាធិបតេយ្យ
- សាធារណរដ្ឋប្រជាមានិតកម្ពុជា
- រដ្ឋកម្ពុជា
- ព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្ន

### ១.១- សង្គមរាស្ត្រនិយមនិងបម្លាស់លំនៅ

ក្រោយទទួលបានឯករាជ្យ ថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ កម្ពុជាទទួលបានសិទ្ធពេញលេញក្នុងដឹកនាំប្រទេស ពោលគឺគ្មានការត្រួតត្រាអំពីបរទេសលើបូរណភាពទឹកដីទៀតទេ។ បក្សប្រជាជនបដិវត្តន៍ខ្មែរ ដែលបង្កើតឡើងនៅឆ្នាំ១៩៥១ ដើម្បីធ្វើការតស៊ូប្រឆាំងអាណានិគមបារាំង ត្រូវ

[2] ក្រុមប្រឹក្សាជាតិភាសាខ្មែរ សទ្ទានុក្រម ភូមិវិទ្យា និង ប្រវត្តិវិទ្យា ទំព័រ ៣០

បានផ្លាស់ប្តូរមេដឹកនាំជាបន្តបន្ទាប់ រហូតដល់ឈ្មោះ សាឡុត ស ។ ក្រុមដឹកនាំចលនានេះ យល់ថា ប្រជាជនក្រីក្រនៅកម្ពុជា ត្រូវបានពួកសក្តិភូមិ និងពួកមូលធននិយមជិះជាន់សង្កត់សង្កិនច្រើនទសវត្សមកហើយ។ ឆ្នាំ១៩៦៦ ក្រុមនេះ បានរៀបចំការតស៊ូប្រដាប់ដោយអាវុធទ្រង់ទ្រាយធំ ដើម្បីរំលំរបបសក្តិភូមិ។ ឆ្នាំ១៩៦៧ ពួកនេះ សម្រេចចាប់ផ្តើម សង្គ្រាមស៊ីវិលប្រឆាំងនឹងរាជរដ្ឋាភិបាលដែលមានសម្តេច នរោត្តម សីហនុ ជាព្រះប្រមុខរដ្ឋ ដែលកំពុងស្ថិតក្នុងស្ថានភាពមានវិបត្តិសេដ្ឋកិច្ចនិងសង្គមផង។ និន្នាការមួយរបស់សម្តេចព្រះ នរោត្តម សីហនុ គឺព្រះអង្គមានទំនាក់ទំនងយ៉ាងកក់ក្តៅជាមួយប្រទេសវៀតណាមខាងជើង (ប្រទេសកុម្មុយនីស្ត)។ ស្ថានភាពនយោបាយកម្ពុជានាពេលនោះ កំពុងទទួលរងឥទ្ធិពលភូមិសាស្ត្រនយោបាយតំបន់ ដែលប្រទាញប្រទង់រវាងមហាអំណាចលោកសេរី និងមហាអំណាចកុម្មុយនីស្ត ជាពិសេសតំបន់នៅតាមបណ្តោយព្រំដែនគោករវាងកម្ពុជា និងវៀតណាម បានក្លាយតំបន់សង្គ្រាម ដោយប្រើប្រាស់ជាទីជម្រកសម្រាប់ការលាក់ខ្លួន ការដឹកជញ្ជូនគ្រាប់រំសេវ និងស្បៀងរបស់ភាគីជម្លោះ។ ការទម្លាក់គ្រាប់បែករបស់កងទ័ពអាម៉េរិក លើកងទ័ពវៀតណាមខាងត្បូងដែលបានចូលដីខ្មែរ ហើយក៏ជាមូលហេតុចុងក្រោយដែលនាំឱ្យដល់កាផ្តាច់ចំណងការទូតរវាងកម្ពុជា និងសហរដ្ឋអាមេរិកក្នុង ឆ្នាំ១៩៦៥ ដោយសម្តេចព្រះនរោត្តមសីហនុ។ ជម្លោះនៅតាមតំបន់ព្រំដែនកម្ពុជាវៀតណាមបានធ្វើឱ្យមានបម្លាស់លំនៅចេញពីតំបន់ទាំងនោះ មកតំបន់ដែលមានសុវត្ថិភាព។ ក្នុងនោះ រាជធានីភ្នំពេញ គឺជាតំបន់មួយដែលមានការផ្លាស់ទីចូលមករស់នៅរបស់ប្រជាជនរាប់ទាំងតំបន់ជនបទទូទាំងប្រទេសផ្សេងទៀតផង។ ទោះបីជាមានបម្លាស់លំនៅច្រើនរបស់ប្រជាជនមកក្នុងទីក្រុងភ្នំពេញសម័យនោះក៏ដោយ ក៏ស្ថិតិពិតប្រាកដ នៃចំនួនប្រជាជនមិនមានកំណត់ត្រាជាក់លាក់ណាមួយបានបង្ហាញឡើយ។

## ១.២ សាធារណរដ្ឋខ្មែរនិងបម្លាស់លំនៅ

ឧត្តមសេនីយ៍ លន់ នល់ ជានាយករដ្ឋមន្ត្រីមួយរូបរបស់សម្តេចព្រះនរោត្តម សីហនុ នាសម័យសង្គមរាស្ត្រនិយម បានឈ្វេងយល់ថា សភាពការណ៍កម្ពុជា ត្រូវតែផ្លាស់ប្តូរចេញពីការគ្រប់គ្រងរបស់សម្តេចព្រះនរោត្តម សីហនុ ដោយមូលហេតុ២យ៉ាង៖ ទី១ គឺការទប់ស្កាត់ការឡើងកាន់អំណាចដោយបដិវត្តន៍របស់ពួកកុម្មុយនីស្ត និងទី២ ការទប់ស្កាត់ការរុលចូលរបស់កងទ័ពវៀតកុង នៃរណសិរ្សជាតិរំដោះវៀតណាមខាងត្បូង ដែលគាំទ្រដោយប្រទេសវៀតណាមខាងជើង ចូលក្នុងទឹកដីកម្ពុជា។ លោក លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ក្នុងឱកាសដែលព្រះអង្គកំពុងបំពេញបេសកកម្មនៅក្រៅប្រទេស។ សង្គ្រាមស៊ីវិលរវាងពួកកុម្មុយនីស្តខ្មែរក្រហម ដឹកនាំដោយឈ្មោះ ប៉ុល ពត (សាឡុត ស) ក្រោម

ការអំពាវនាវអំពីសម្ដេច ព្រះនរោត្តម សីហនុ និងរបបដែលដឹកនាំដោយ ឧត្តមសេនីយ៍ លន់ នល់ មានការគាំទ្រពីសហរដ្ឋអាមេរិក ត្រូវបានបើកចំហ ហើយរីករាលដាលពីមួយថ្ងៃទៅមួយថ្ងៃរហូតដល់ពេញប្រទេស ដែលបង្កឱ្យមានបម្លាស់លំនៅបន្តបន្ទាប់នៅកម្ពុជា។ ក្រោយរដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ប្រទេសកម្ពុជាបានប្ដូរឈ្មោះពីព្រះរាជាណាចក្រកម្ពុជា មកជាសាធារណរដ្ឋខ្មែរ ប៉ុន្តែរបបនេះមិនបានធ្វើឱ្យប្រទេសកម្ពុជា មានសុខសន្តិភាពពេញលេញទូទាំងប្រទេសកម្ពុជានោះទេ។ ប្រទេសដែលធ្លាប់មានសុខសន្តិភាព បានប្រែក្លាយទៅជាសមរភូមិប្រយុទ្ធនៅតាមតំនានាទូទាំងប្រទេស។ របបនេះបានធ្លាក់ចូលក្នុងវិបត្តិសង្គមធ្ងន់ធ្ងរ ពោលគឺមានការកេណទ័ព ចាប់ទាហ៊ាន ដើម្បីចេញច្បាំង។ ស្របតាមការអំពាវនាវរបស់អ្នកនយោបាយ បានធ្វើឱ្យប្រទេសមានការជ្រួល ច្របល់ មានភាពវឹកវរ ហើយបង្កើតឱ្យមានក្រុមចលនាតស៊ូនៅទូទាំងប្រទេស។ មូលហេតុទាំងនេះ គឺជាមូលដ្ឋាននៃកត្តាអសន្តិសុខរបស់ប្រទេសកម្ពុជានាពេលនោះ។ ការប្រយុទ្ធដោយកងទ័ពថ្មើរជើង និងការទម្លាក់គ្រាប់បែករបស់ភាគីជម្លោះបានបណ្ដាលឱ្យកើតមានហានិភ័យ ដល់ប្រជាជន សូម្បីតែកសិផល ផលិតកម្ម លំនៅដ្ឋាននានា និងអាយុជីវិតក៏ត្រូវបានបំផ្លាញដែរ។ ពីមួយថ្ងៃទៅមួយថ្ងៃស្ថានការណ៍ក្នុងប្រទេសចេះតែធ្ងន់ធ្ងរ និងដុនដាបទៅៗ រីឯការប្រយុទ្ធនៅតាមតំបន់នានាកាន់តែមានសភាពខ្លាំងឡើងៗ ដែលជាមូលហេតុចម្បងនៃការធ្វើបម្លាស់ទីចេញពីតំបន់អសន្តិសុខទាំងនោះ។ ការទម្លាក់គ្រាប់បែក ការបាញ់ផ្លោង ការបាញ់រះ ការបាញ់ផ្ដក់រវាងភាគីជម្លោះកម្ពុជា បានធ្វើអោយប្រជាជននាំគ្នាភៀសខ្លួនមកការរស់នៅតាមទីរួមខេត្តនានា ជាពិសេស ទីក្រុងភ្នំពេញ។ កំឡុង៥ឆ្នាំនៃរបបនេះ ទីក្រុងភ្នំពេញ ហាក់បីដូចជាបន្ទាយមួយដែលត្រូវឡោមព័ទ្ធដោយគូរជម្លោះ។ ប្រជាជនកម្ពុជា ដែលធ្លាប់ទទួលបានសុខសន្តិភាព លែងមានពេលប្រកបការងារចិញ្ចឹមជីវិតគឺមិនដូចពេលមុនទៀតឡើយ ពោលគឺប្រជាជនចាប់ផ្ដើមធ្វើបម្លាស់ទីទៅរកតំបន់ណាដែលមិនប្រឈមនឹងការប្រយុទ្ធគ្នា។ ពេលនេះស្ថានភាពបម្លាស់លំនៅរបស់ប្រជាជនទូទាំងប្រទេសកំពុងច្របូកច្របល់ ប្រជាជនមួយចំនួនមិនមានគោលដៅពិតប្រាកដ។ ទីក្រុងភ្នំពេញ នាពេលនោះ គឺជាទីកន្លែងដែលមានសុវត្ថិភាពជាងគេ បើប្រៀបធៀបទៅនឹងតំបន់នានា ទូទាំងប្រទេស។ ភ្នំពេញ ដែលធ្លាប់តែជាទីក្រុងឆើតឆាយ និងជោគជ័យ នៅអាស៊ីអាគ្នេយ៍ បានប្រែក្លាយទៅជាទីប្រជុំជន ដែលមានកំណើនប្រជាជនហួសប្រមាណ ព្រោះប្រជាជនប្រមាណ១/៣ (ជាងពីរលាននាក់) បានធ្វើបម្លាស់លំនៅចូលមកទីក្រុងភ្នំពេញ រាប់ទាំងមន្ត្រីរាជការរបស់រដ្ឋការ លោក លន់ នល់ ដែលមិនចូលជាមួយពួកខ្មែរក្រហម ត្រូវភៀសខ្លួនមកភ្នំពេញ ហើយរដ្ឋការគ្រប់លំដាប់ថ្នាក់នៃខេត្តនីមួយៗ ក៏ត្រូវប្រមូលផ្ដុំរៀងៗ មកតាំងនៅក្រុងភ្នំពេញដែរ។ ទីក្រុងភ្នំពេញ នាពេលនោះ បានជួបបញ្ហាជាច្រើន ដូចជា ការខ្វះ

ស្បៀង បញ្ហាទំនិញឡើងថ្លៃ គ្មានទីជម្រកគ្រប់គ្រាន់ សង់ទីជម្រកតាមចិញ្ចើមផ្លូវ បង្កើតភាពអាណាធិបតេយ្យ ជាដើម។

## ១.៣- កម្ពុជាប្រជាធិបតេយ្យ និងបម្លាស់លំនៅ

តំបន់បង្អែកជាច្រើន(តំបន់រំដោះ) របស់ចលនាតស៊ូខ្មែរប្រឆាំងនឹងរបបថ្មី បានពង្រីកមូលដ្ឋានកាន់តែធំឡើងៗ។ នៅដើមឆ្នាំ១៩៧៣ ទឹកដីប្រមាណ៨៥% នៃប្រទេសកម្ពុជា ត្រូវបានកាន់កាប់ដោយកម្លាំងតស៊ូខ្មែរក្រហម ហើយកងទ័ពសេនាប្រមុខ លន់ នល់ កាន់តែបង្ហាញភាពទន់ខ្សោយនិងដកថយជាបន្តបន្ទាប់។ ដំណើរបាត់បង់នៃការកាន់កាប់ទឹកដី រួមទាំងប្រជាជនដោយរបបលោក លន់ នល់ មានច្រើនដំណាក់កាលបន្តបន្ទាប់ រហូតឈានទៅដល់ការបាត់បង់ការកាន់កាប់ប្រទេសទាំងស្រុងនាថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ ជ័យជំនះរបស់កងទ័ព ខ្មែរក្រហមដឹកនាំដោយ ប៉ុល ពត ដោយវាយយកបានរដ្ឋធានីភ្នំពេញ ដែលគ្រប់គ្រងដោយរបបសាធារណរដ្ឋ លោក លន់ លន់ និងគាំទ្រដោយសហរដ្ឋអាម៉េរិក បន្ទាប់ពីការតស៊ូស្វិតស្វាញដោយអាវុធរហូតដល់ឆ្នាំ១៩៧៥។ គេប៉ាន់ស្មានថា ប្រជាជនកម្ពុជាប្រមាណពាក់កណ្ដាលត្រូវបានគេជម្លៀសដោយបង្ខំទៅជនបទ ក្នុងនោះប្រជាជនប្រមាណជាង២លាននាក់ ចេញពីរាជធានីភ្នំពេញ និងប្រមាណជាង១លាននាក់ ចេញពីតំបន់ទីប្រជុំជននានាទូទាំងប្រទេស។ ជាក់ស្ដែង នៅថ្ងៃជ័យជំនះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ប្រជាពលរដ្ឋនៅក្នុងរាជធានីភ្នំពេញ បានចេញមកតាមដងផ្លូវនានា ដើម្បីអបអរសាទរកងទ័ពរំដោះ ក្នុងទឹកមុខរីករាយ ប៉ុន្តែប្រមាណជាមួយម៉ោងបន្ទាប់មក ក៏កើតមាននូវសកម្មភាពស្រែកបញ្ជាដោយកងទ័ពដែលមានឯកសណ្ឋានឈុតខ្មៅ ដៃកាន់កាំភ្លើងឱ្យប្រជាពលរដ្ឋដែលកំពុងឈរត្រៀបត្រានៅតាមដងផ្លូវនោះ ចាកចេញពីទីក្រុង ដោយមិនចាំបាច់យកសម្ភារអ្វីទៅតាមខ្លួនឡើយ។ ព្រឹត្តិការណ៍នេះបានធ្វើឱ្យប្រជាពលរដ្ឋ ដែលកំពុងរស់នៅក្នុងរាជធានីភ្នំពេញ ហាក់វិលវល់គំនិត ដោយមិនដឹងគោលដៅច្បាស់លាស់របស់ខ្លួនថាទៅទីណា។ ជម្រើសភាគច្រើននៃការចាកចេញរបស់ប្រជាពលរដ្ឋ គឺការវិលត្រឡប់ទៅស្រុកកំណើតវិញ ជាពិសេសគ្រួសារដែលទើបនឹងធ្វើបម្លាស់លំនៅសម័យសាធារណរដ្ឋខ្មែរ ប៉ុន្តែគ្រួសារមួយចំនួនធំ ដែលគ្មានស្រុកកំណើត ពោលគឺគ្មានគោលដៅច្បាស់លាស់ ត្រូវបានក្រុមអាវខ្មៅដែលហៅខ្លួនឯងថា "អង្គការ" ជម្លៀសទៅនៅតាមតំបន់ផ្សេងៗ ជាពិសេស សម្រាប់កម្លាំងពលកម្មបម្រើឱ្យវិស័យកសិកម្ម។

## ១.៤- សាធារណរដ្ឋប្រជាមានិតកម្ពុជានិងរដ្ឋកម្ពុជា និងបម្លាស់លំនៅ

ជ័យជំនះថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ គឺជាថ្ងៃដែលរបបបីឆ្នាំប្រាំបីខែ និងម្ភៃថ្ងៃ បរាជ័យ

បើទោះជារបបនេះមិនដួលរំលំទាំងស្រុងក៏ដោយ។ រាជធានីភ្នំពេញ ត្រូវបានសង្គ្រោះ និងគ្រប់គ្រងដោយចលនាតស៊ូរំដោះប្រទេស ដែលមានវរជនស្នេហាជាតិខ្មែរជាច្រើន បានប្រមូលរួបរួមគ្នានិងក្រោកឡើងធ្វើការតស៊ូប្រឆាំងនឹងការជិះជាន់ ការបំបិទសិទ្ធិ ការរស់ជាទាសករដូចគុកឥតជញ្ជាំង នៃរបបខ្មៅងងឹតនេះ។ រណសិរ្ស ដែលមានឈ្មោះថា "រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា" ត្រូវបានប្រសូត្រឡើងនៅថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៧៨ នៅក្នុងស្រុកស្នួល ខេត្តក្រចេះ ក្រោមគោលដៅតែមួយ គឺការរួបរួមគ្នា ដើម្បីតស៊ូវាយរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត។ របបថ្មីឈ្មោះ "សាធារណរដ្ឋប្រជាមានិតកម្ពុជា" ត្រូវបានបង្កើតឡើង ក្រោមការដឹកនាំរបស់ "បក្សប្រជាជនបដិវត្តកម្ពុជា"។ បម្លាស់ទីត្រឡប់វិញរបស់ប្រជាជនចូលរដ្ឋធានីភ្នំពេញ ពីតាមតំបន់ជនបទ ហាក់មិនមានព្រឹត្តិការណ៍ដូចពេលបម្លាស់លំនៅចេញ កាលពីជាងបីឆ្នាំមុនទេ ពោលគឺមនុស្សមួយចំនួនធំ គឺជាក្រុមមនុស្សថ្មី ដែលពីមុនមិនមែនជាមនុស្ស ដែលរស់នៅទីក្រុងភ្នំពេញ។ ដោយឡែកប្រជាជនដែលអ្នកធ្លាប់រស់នៅទីក្រុងភ្នំពេញ តាំងពីសម័យសង្គមរាស្ត្រនិយម មួយចំនួនបានស្លាប់ក្នុងរបបខ្មៅងងឹត និងមួយចំនួនទៀតមិនហ៊ានត្រឡប់វិញ។ នៅក្នុងឆ្នាំ១៩៨៣-១៩៨៩ ការធ្វើបម្លាស់លំនៅបានថយចុះ ព្រោះពិបាកធ្វើដំណើរ ដោយសារត្រូវសុំលិខិតអនុញ្ញាតក្នុងការធ្វើដំណើរពីតំបន់មួយទៅតំបន់មួយក្នុងប្រទេស និងតម្រូវឱ្យមានហេតុផលច្បាស់លាស់។ ពន្លឺនៃដំណើរការឆ្ពោះទៅរកការបញ្ចប់សង្គ្រាមស៊ីវិលនៅប្រទេសកម្ពុជា ដោយមានការចចារពីគ្រប់ភាគីជម្លោះ ក្រោមការសម្របសម្រួលពីអន្តរជាតិ។ ឆ្នាំ១៩៨៩-១៩៩៣ បម្លាស់លំនៅចូលក្នុងប្រទេសរបស់ប្រជាជន (មាតុភូមិនិវត្តន៍) ពីតំបន់តាមព្រំដែនកម្ពុជាថៃ ទៅកាន់តំបន់នានាទូទាំងប្រទេស។ ដោយឡែក រាជធានីភ្នំពេញ គឺជាតំបន់មួយ ដែលទទួលក្រុមមនុស្សច្រើនជាងតំបន់ផ្សេងទៀតទូទាំងប្រទេស រាប់បញ្ចូលទាំងមន្ត្រីគណបក្សនយោបាយនានា មកពីបរទេស ដើម្បីចូលរួមធ្វើការបោះឆ្នោតតាមបែបប្រជាធិបតេយ្យនៅកម្ពុជាផងដែរ។

## ១.៥- ព្រះរាជាណាចក្រកម្ពុជានិងបម្លាស់លំនៅ

របបសេដ្ឋកិច្ចទីផ្សារសេរីត្រូវបានកម្ពុជាប្រកាន់យក ចាប់ពីក្រោយការបោះឆ្នោតសកលឆ្នាំ១៩៩៣ លើកដំបូង បន្ទាប់ពីមានកិច្ចព្រមព្រៀងទីក្រុងប៉ារីស ២៣ តុលា ១៩៩១ ស្តីពីបញ្ហាកម្ពុជា។ របបសេដ្ឋកិច្ចនេះ បានបើកឱ្យមានការវិនិយោគជាច្រើន ពិសេសវិនិយោគពីក្រៅប្រទេសលើវិស័យកាត់ដេរសម្លៀកបំពាក់និងស្បែកជើង។ កម្លាំងពលកម្មក្នុងប្រទេសបានរាប់រងដំណើរការផលិតកម្មទាំងនេះ ដើម្បីនាំទៅលក់នៅទីផ្សារអន្តរជាតិ ពិសេសនៅសហរដ្ឋអាម៉េរិក និងសហគមន៍អឺរ៉ុប។ បើទោះបីជាមិនសូវមានភាពចុះសម្រុងគ្នារវាងគណបក្សកាន់

អំណាចធំៗពីរ ក៏ដោយ ក៏ការបើកសិទ្ធិសេរីភាពពេញលេញ ក្នុងការធ្វើដំណើរនិងបម្លាស់ទីលំនៅ បានធូរស្រាលជាងរបបមុនៗ ជាពិសេសការផ្លាស់ទីទៅកាន់តំបន់ដែលងាយទទួលបានផលប្រយោជន៍ផ្នែកសេដ្ឋកិច្ច។ គ្រប់ដំណាក់កាលនៃចលនាបម្លាស់លំនៅទាំងអស់ (លើកលែងការជម្លៀសក្នុងឆ្នាំ១៩៧៥) គឺមានចលនាដ៏សំខាន់មួយនៃបម្លាស់លំនៅ គឺចំណោលស្រុកស្រែមកកាន់ទីក្រុងឬទីប្រជុំជន ដែលបណ្ដាលមកពីបញ្ហាសេដ្ឋកិច្ច និងបញ្ហាអសន្តិសុខនៅតាមតំបន់នោះ។ ក្រៅពីនេះ ក៏មានចលនាបម្លាស់លំនៅតាមរដូវ ដូចជា ក្រោយរដូវច្រូតកាត់ប្រមូលផល កសិករ តែងនាំគ្នាមករកការងារធ្វើ ដើម្បីបានចំណូលបន្ថែមនៅតាមទីប្រជុំជន ជាពិសេសរាជធានីភ្នំពេញតែម្ដង។

តាមទិន្នន័យជំរឿន បានបង្ហាញថា ចំនួនប្រជាជនដែលបានតាំងទីលំនៅក្នុងទីក្រុងភ្នំពេញក្រោយថ្ងៃ៧ មករា ១៩៧៩ មានដូចតទៅ[3]៖

- ឆ្នាំ១៩៨០ ចំនួន ២៣៨ ២៨៧ នាក់
- ឆ្នាំ១៩៩០ ចំនួន ៦១៥ ០០០ នាក់
- ឆ្នាំ១៩៩៥ ចំនួន ៨៣៥ ៨៨៥ នាក់
- ឆ្នាំ១៩៩៨ ចំនួន ៩៩៩ ៨០៤ នាក់
- ឆ្នាំ២០០៨ ចំនួន ១ ៥០១ ៧២៥ នាក់
- ឆ្នាំ២០១៩ ចំនួន ២ ១២៩ ៣៧១ នាក់

## ២- ផលវិបាកនៃបម្លាស់លំនៅ

ព្រឹត្តិការណ៍នៃសង្គ្រាមស៊ីវិលជាច្រើនដំណាក់កាល បានធ្វើឱ្យកម្ពុជាមានតំបន់ប្រទាញប្រទង់គ្នាកាន់កាប់រាប់បញ្ចូលទាំងចំនួនប្រជាជនផងដែរ ពោលគឺរវាងកម្លាំងតស៊ូនានា ដូចជាកម្លាំងចលនាតស៊ូរបស់ជនខ្មែរនិងអាណានិគមបារាំង ក្រុមចលនាតស៊ូរបស់បក្សកុំម្មុយនីស្តខ្មែរ និងរបបសក្តិភូមិ ក្រុមចលនារំដោះជាតិនិងកម្លាំងរបស់របបសាធារណរដ្ឋខ្មែរ ក្រុមចលនាតស៊ូនៃរណសិរ្សសង្គ្រោះជាតិកម្ពុជានិងខ្មែរក្រហម ក្រុមចលនានៃរដ្ឋាភិបាលចម្រុះត្រីភាគី និងរដ្ឋាភិបាលទីក្រុងភ្នំពេញ និងចុងក្រោយក្រុមខ្មែរក្រហមដែលនៅសេសសល់តាមព្រំដែនខ្មែរថៃជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា។ ការបែងចែកកាន់កាប់ទឹកដី និងប្រជាជនកម្ពុជាដែលមានប្រមាណ ៧ លាននាក់ (ប៉ាន់ស្មាននៅឆ្នាំ១៩៧០) បានស្ថិតក្រោមការគ្រប់គ្រងពីរដែលចែកជាដំណាក់កាលរវាងតំបន់រំដោះរបស់ពួកខ្មែរក្រហមកុម្មុយនីស្តនិងរបបសាធារណរដ្ឋខ្មែរ។ កត្តាចម្បងនៃភាពខុសគ្នារវាងការគ្រប់គ្រងនៃក្រុមទាំងពីរ គឺរបបនយោបាយដឹកនាំ ដែលអាចឱ្យប្រជាជនស្គាល់ភ្នាម ពិសេសការជួបដំបូងនូវលទ្ធិកុម្មុយនីស្តខ្មែរក្រហម ដែលអាចកត់សម្គាល់បានខ្លះៗ ដូចខាងក្រោម៖

- របបសាធារណរដ្ឋខ្មែរ(របបសេរី) គឺបើកទូលាយសេរីខាងនយោបាយ ការរស់

[3] ទិន្នន័យសាលាក្រុងភ្នំពេញ និងវិទ្យាស្ថានជាតិស្ថិតិ

នៅជាឯកជនតាមគ្រួសារ សេរីភាពពលរដ្ឋត្រូវបានបើកទូលាយ កម្មសិទ្ធិត្រូវបានធានា ជាដើម។

- របបខ្មែរក្រហម (របបកុម្មុយនីស្ត) គឺមានការគ្រប់គ្រងតឹងតែង (បញ្ញា វិន័យ...) ការរស់នៅជាសមូហភាពគ្មានទីផ្សារ គ្រប់ការទាក់ទងត្រូវកាត់ផ្ដាច់ការដើរហើរត្រូវបានហាមឃាត់ ការនិយាយស្ដីត្រូវប្រើពាក្យបដិវត្តន៍ សម្លៀកបំពាក់ត្រូវប្រើពណ៌ខ្មៅ ជាដើម។

បម្លាស់លំនៅរបស់ប្រជាជន មានកំណើនច្រើនសន្ធឹក នៅក្នុងរបបសាធារណរដ្ឋខ្មែរ ពោលគឺចំនួនប្រជាជនប្រមាណ ៧លាននាក់ បានប្រែប្រួលចំនួនជាបន្តបន្ទាប់ ដោយការគ្រប់គ្រងរបស់ខ្មែរក្រហម រហូតដល់ដំណាក់កាលចុងក្រោយ។ នៅឆ្នាំ១៩៧៣ ប្រជាជនប្រមាណជា ៣លាននាក់ប៉ុណ្ណោះ ដែលត្រូវបានគ្រប់គ្រងដោយរបបសាធារណរដ្ឋខ្មែរ ហើយប្រមូលផ្ដុំនៅតាមទីក្រុង និងទីប្រជុំជនខេត្តនានា ពិសេសនៅក្នុងទីក្រុងភ្នំពេញ ដែលមួយភាគធំ គឺជាជនភៀសសឹក ដោយសារសង្គ្រាម និងដោយសារការភៀសខ្លួនពីការគ្រប់គ្រងរបស់ពួកខ្មែរក្រហម។

## ៣- ចំណោលជនបទ

ចំណោលជនបទ គឺជាបម្លាស់លំនៅមួយប្រភេទ ដែលមនុស្សធ្វើការផ្លាស់ទីលំនៅពីតំបន់ជនបទនានា មកទីប្រជុំជនជនដោយកត្តាសេដ្ឋកិច្ច។ ដោយឡែក បម្លាស់លំនៅ ចន្លោះឆ្នាំ ១៩៧០-១៩៧៩ គឺជា "បម្លាស់លំនៅក្ដៅ" ដោយសារភ្លើងសង្គ្រាមនិងការជម្លៀសដោយបង្ខំ និងបម្លាស់លំនៅចាប់ពីឆ្នាំ១៩៧៩ (មិនរាប់អំពីការវិលត្រឡប់មកភូមិកំណើតវិញក្រោយការដួលរំលំនៃរបបខ្មៅងងឹត) ដែលជា "បម្លាស់លំនៅត្រជាក់" ពោលគឺជាចំណោលជនបទទៅរកការងារនៅតាមទីក្រុង ជាពិសេសការងាររោងចក្រ។ បម្លាស់លំនៅបែបនេះ អាចនិយាយថា "បម្លាស់លំនៅអភិវឌ្ឍន៍" ដោយទទួលបានប្រយោជន៍សម្រាប់គ្រួសារផ្ទាល់ និងសម្រាប់សេដ្ឋកិច្ចជាតិផងដែរ។ បម្លាស់លំនៅ អភិវឌ្ឍន៍ បានរង់ចាំពេលវេលាអស់ប្រមាណជាបីទៅបួនឆ្នាំ ក្រោយការបោះឆ្នោតឆ្នាំ១៩៩៣ ដែលកម្ពុជាប្រកាន់យករបបសេដ្ឋកិច្ចទីផ្សារសេរី ។ ដោយឡែក នៅទសវត្សរ៍ឆ្នាំ១៩៦០ សតវត្សទី២០ កម្ពុជា មានរោងចក្រតម្បាញ(កំពង់ចាម) រោងចក្រស៊ីម៉ង់ត៍(កំពត) រោងចក្រក្រដាស(បាត់ដំបង) រោងចក្រកែវ(ភ្នំពេញ) រោងចក្រស្ករ-ស (កំពង់ស្ពឺ) រោងចក្រដំឡើងត្រាក់ទ័រ (កំពង់សោម) រោងចក្រចម្រាញ់ប្រេងកាត (កំពង់សោម) ជាដើម។ ផ្ទុយទៅវិញ នាបច្ចុប្បន្ននេះ រោងចក្រភាគច្រើន ជារោងចក្រកាត់ដេរសម្លៀកបំពាក់ និងផលិតស្បែកជើងសម្រាប់នាំចេញ ហើយភាគច្រើនប្រមូលផ្ដុំនៅតាមទីក្រុង ជាពិសេសរាជធានីភ្នំពេញ ដែលជាកត្តាទាក់ទាញ ធ្វើឱ្យមានចំណោលជនបទ។ រោងចក្រនា

អតីតកាល មិនមានបញ្ហាចំណោលជនបទទេ ដោយសារទីតាំងរោងចក្រនៅតាមខេត្តផ្សេងៗ ហើយផលិតកម្មមានកម្រិតមធ្យម ដែលអាចទ្រទ្រង់ដោយកម្លាំងពលកម្មមូលដ្ឋានជុំវិញបាន។ ចំណោលជនបទ គឺជាបម្លាស់លំនៅក្នុងប្រទេសរបស់ប្រជាជនដែលចេញពីជនបទ ស្រែចម្ការ ទៅកាន់ទីក្រុងឬតំបន់ឧស្សាហកម្ម ក្នុងគោលបំណងប្រកបការងារ តាមរូបភាពផ្សេងៗ។

## ៤- ចំណោលជនបទនិងបម្លាស់លំនៅ

ចំណោលជនបទនៅកម្ពុជា ក៏បានបង្ហាញនូវចំណុចវិជ្ជមានមួយចំនួន នៅក្នុងសង្គមផងដែរ ដូចជា ប្រជាជននៅជនបទ បានផ្លាស់ប្តូរទស្សនៈរបស់ខ្លួនពីការពឹងផ្អែក លើការប្រកបការងារស្រែចម្ការដោយពឹងធម្មជាតិ ទៅបន្ថែមមុខរបរផ្សេងៗលើសពីស្រែចម្ការរបស់ខ្លួន។ និន្នាការនេះ បង្កើតបានជាទម្រង់គ្រួសារថ្មីនៅជនបទ គឺទម្រង់ដែលទ្រទ្រង់ជីវភាពដោយប្រភពស្រែចម្ការផង (ប្រភពចាស់) និងប្រភពប្រាក់ឈ្នួលប្រចាំខែផង (ប្រភពថ្មី) តាមរូបភាពផ្សេងៗនៃសកលភាវូបនីយកម្ម។ ម្យ៉ាងទៀត ចំណោលជនបទ ក៏បានរួមចំណែកផងដែរ ក្នុងការដោះស្រាយបញ្ហាខ្វះដីធ្លីធ្វើស្រែចម្ការ ដូចជា កសិករមួយចំនួនមានដីស្រែចម្ការតិចតួច មិនអាចចិញ្ចឹមគ្រួសារបាន(សមាជិកច្រើន) ឬកង្វះទឹកសម្រាប់ធ្វើកសិកម្មជាដើម ពោលគឺ បញ្ហាកង្វះដីធ្លីលែងជាកត្តាស្ទាប់រស់របស់កសិករទៀតហើយ។

នាសម័យអភិវឌ្ឍន៍សេដ្ឋកិច្ចទីផ្សារសេរី ពិសេសសម័យរីកចម្រើនរបស់រោងចក្រកាត់ដេរសម្លៀកបំពាក់ និងស្បែកជើង គឺមានឥទ្ធិពលជាខ្លាំងដល់ "បម្លាស់លំនៅ" យ៉ាងពិតប្រាកដ ពោលគឺមនុស្សពេញកម្លាំងពលកម្ម ភាគច្រើនបានធ្វើចំណោលជនបទទៅទីប្រជុំជន និងមួយចំនួនទៀតបានធ្វើចំណោលជនបទទៅក្រៅប្រទេសរហូតដល់ប្រមាណ ១ ២៣៥ ៩៩៣ នាក់[4]។

បម្លាស់លំនៅពីជនបទ(ចំណោលជនបទ) ប្រមាណជា២លាននាក់ (មិនរាប់ពលករទៅក្រៅប្រទេស) បានបង្ហាញអំពីផលប៉ះពាល់ផ្នែកប្រជាសាស្ត្រ នៅតាមភូមិឃុំនៅតំបន់ជនបទទូទាំងប្រទេស ពោលគឺសំបូរទៅដោយមនុស្សចាស់ៗ ហើយកម្លាំងពលកម្មសម្រាប់ទ្រទ្រង់ផ្នែកផលិតកម្មស្រែចម្ការ ត្រូវបានកាត់បន្ថយ ព្រោះយុវវ័យបានចេញទៅធ្វើការឆ្ងាយៗ។ ផលប៉ះពាល់នៅតាមជនបទទាំងនោះ ដូចជា ការបោះបង់ចោលការចិញ្ចឹមគោក្របីឬជ្រូកតាមគ្រួសារ ដោយសារខ្វះអ្នកឃ្វាល អ្នករកស្មៅ ឬអ្នកថែទាំជាដើម។ ម្យ៉ាងទៀត ការងារផលិតកម្មនៅជនបទខ្វះ ត្រូវជួលពលកម្មអ្នកដទៃឬគ្រឿងយន្ត

[4] ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ "ពលករទៅធ្វើការនៅក្រៅប្រទេស" ឆ្នាំ២០១៨

ដូចជាក្ដួរពាស់ ច្រូតកាត់ជាដើម ប៉ុន្តែយន្តកម្ម(ការប្រើគ្រឿងយន្ត)មានការរីកចម្រើននៅជនបទ អាចជួយដោះស្រាយបញ្ហានេះ។

## ៥- បម្លាស់លំនៅនិងការអភិវឌ្ឍទីក្រុង

ការតាំងទីរបស់ពេងចក្រនៅកណ្ដាលក្រុងនិងជាយក្រុង (កន្លែងទាំងឡាយជាចំណែកនៃក្រុងដែលស្ថិតនៅជុំវិញ) ធ្វើឱ្យមានផលប៉ះពាល់មួយចំនួនដល់នគរូបនីយកម្ម ដូចការរៀបចំក្រុង ការកែលម្អ មានការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ការរៀបចំសណ្ដាប់ធ្នាប់សង្គម ដែលត្រូវធ្វើដើម្បីជានាការអភិវឌ្ឍប្រកបដោយសុខដុមភាពជាដើម។ បម្លាស់លំនៅចូលទីក្រុង ដោយសារលំហូរចូលនៃប្រជាជនចំណោលជនបទរាប់ពាន់ដល់រាប់ម៉ឺននាក់ទៅតាមកន្លែងនីមួយៗ បានធ្វើឱ្យមានកំណើនប្រជាជនរហ័ស ពិសេសអ្នកមកស្នាក់នៅផ្ទះជួល(រាប់ទាំងសំណង់ផ្ទះល្វែងផង)។ ការតាំងទីពេងចក្រមានការកំណត់ច្បាស់លាស់ក្នុងក្រមនគរូបនីយកម្ម តែកន្លែងផ្ទះជួល កន្លែងសេវាកម្ម ដែលផ្សារភ្ជាប់នឹងកម្មករនិយោជិតយ៉ាងកុះករ បានបង្កើតឡើងដោយវិស័យឯកជននៅកន្លែងចាស់ក៏មាន នៅកន្លែងថ្មីក៏មាន និងមជ្ឈដ្ឋាន ក្នុងការចាយដឹកជញ្ជូនកម្មករនិយោជិត និងចំណតរបស់វា ពុំទាន់ត្រូវបានរៀបចំឱ្យបានល្អនៅឡើយទេ។ ដោយឡែក សេវាលក់អាហារឆ្អិន និងផ្សារតូចៗ កើតមានឡើងនៅតាមតំបន់ជុំវិញពេងចក្រ ហើយនៅតាមចិញ្ចើមផ្លូវក៏មាន។ អ្វីទាំងអស់នេះ បង្កើតបាន "មុខមាត់ថ្មី" របស់ទីក្រុង ព្រមទាំងផ្ដល់ផលប៉ះពាល់ដែលត្រូវយកចិត្តទុកដាក់ ដូចជាការគ្រប់គ្រងស្ថិតិនិងសុវត្ថិភាពសង្គមនៅកន្លែងផ្ទះជួល សុវត្ថិភាពដឹកជញ្ជូន សុវត្ថិភាពចរាចរណ៍នៅមុខពេងចក្រ ការកកស្ទះចរាចរណ៍នៅក្នុងទីក្រុងជាដើម។

## ៦- បម្លាស់លំនៅនិងបញ្ហាដីធ្លី

លំនៅឋានភាគច្រើន គឺជាកន្លែងដែលជាទីតាំងនៃជីវភាពរស់នៅជាអចិន្ត្រៃយ៍របស់គ្រួសារឬបុគ្គលម្នាក់ៗ។ ប្រមាណជាបីទសវត្សចុងក្រោយនៅព្រះរាជាណាចក្រកម្ពុជា ពោលគឺក្រោយពីមានរាជរដ្ឋាភិបាលដែលកើតចេញពីការបោះឆ្នោត ឆ្នាំ១៩៩៣ វិស័យអចលនទ្រព្យនៅកម្ពុជាចាប់ផ្ដើមមានតម្លៃឡើងវិញ តាមរយៈការបង្កើតឱ្យមានភាពជាកម្មសិទ្ធិ និងជាអចលនទ្រព្យ ដែលអាចលក់ដូរបាន។ បម្លាស់លំនៅមួយចំនួន ត្រូវបានផ្លាស់ប្ដូរពីតំបន់ទីប្រជុំជននាកណ្ដាលក្រុងមកកើនឡើងនៅតាមតំបន់ជុំវិញ។ ជាក់ស្ដែង រាជធានីភ្នំពេញ បានពង្រីកនូវទំហំរបស់ខ្លួនជាបន្តបន្ទាប់ តាមរយៈកំណើនលំនៅដ្ឋានជាយក្រុង ដោយប្រែក្លាយពីតំបន់កសិកម្មមកជាតំបន់លំនៅដ្ឋាន។ នៅឆ្នាំ១៩៩៨ រាជធានីភ្នំពេញមានផ្ទៃក្រឡា ២៨៩,៩៧ គ.ម² និង ៣៨៥ គ.ម² នៅឆ្នាំ២០០៦ និងបន្តកើនឡើងរហូតដល់ ៦៩២,៤៦

គ.ម² នៅឆ្នាំ២០២១[5]។ តម្លៃដីថ្មី គឺជាបញ្ហាមួយដែលបង្កឱ្យមានការធ្វើបម្លាស់លំនៅ ព្រោះការវិនិយោគអាចជាកត្តាបង្ខំមួយចំពោះប្រជាជនដែលកំពុងរស់នៅតំបន់នៃគម្រោងវិនិយោគធ្វើបម្លាស់លំនៅចេញ ឬអាចបណ្ដាលមកពីសកម្មភាពរបស់ភាគីកាន់កាប់ថ្មី (កម្មសិទ្ធិ) ធ្វើឱ្យប៉ះពាល់ដល់ចំណែកណាមួយនៃដីផលិតកម្មកសិកម្ម ឬលំនៅឋាន ឬប៉ះពាល់ទាំងលំនៅឋាននិងដីកសិកម្ម ជាដើម។

## សេចក្ដីសន្និដ្ឋាន

ជារួម បម្លាស់លំនៅ គឺជាបទពិសោធន៍របស់មនុស្សក្នុងការទទួលបានអ្វីដែលថ្មី ជាពិសេស គឺរបៀបរស់រៀនមានជីវិត រាប់បញ្ចូលទាំងមុខរបរចិញ្ចឹមជិវិតផងដែរ។ ឆ្លងកាត់ដំណាក់កាលជាច្រើននៃព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ បម្លាស់លំនៅនៅក្នុងព្រះរាជាណាចក្រកម្ពុជា មានរបៀបច្រើនយ៉ាង រាប់ទាំងបម្លាស់លំនៅដោយបង្ខំចេញពីលំនៅដ្ឋានផ្ទាល់ខ្លួនទៅកាន់តំបន់ដែលមិនមែនជាគោលដៅរបស់ខ្លួន (ជម្លៀស) បម្លាស់លំនៅ ទៅកាន់តំបន់ផ្សេងៗដោយសារកត្តាសេដ្ឋកិច្ច និងដោយសារកត្តាប្រជាសាស្ត្រ ជាដើម។

រាជធានីភ្នំពេញ គឺជាតំបន់ប្រមូលផ្ដុំនូវចំនួនប្រជាជនច្រើនលើសគេ នៅក្នុងប្រទេស ពោលគឺជាតំបន់ដែលមានតង់ស៊ីតេខ្ពង់ជាងគេ និងជាបេះដូងរបស់ប្រទេស ដែលតម្រូវឱ្យរាជរដ្ឋាភិបាល យកចិត្តទុកដាក់អភិវឌ្ឍលើគ្រប់វិស័យ។ នៅក្នុងដំណាក់បច្ចុប្បន្ននេះ ឧស្សាហកម្មទី៤.០ គឺជាវិស័យដែលត្រូវបានផ្ដោតការយកចិត្តទុកដាក់អំពីថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់ ដែលក្នុងនោះយុវជន គឺជាមុខសញ្ញាដ៏ចាំបាច់សម្រាប់បញ្ជ្រាបនូវឱកាសនេះ និងដើម្បីដើរឱ្យទាន់សភាពការណ៍នៃសកលភាវូបនីយកម្ម។ ក្នុងន័យនេះ គួរពិនិត្យមើលកំណើននូវរោងចក្រកាត់ដេរសម្លៀកបំពាក់និងរោងចក្រផលិតស្បែកជើង នៅតាមតំបន់ទីប្រជុំជននានា ដែលជាមូលហេតុនៃចំណោលជនបទ។ របបសេដ្ឋកិច្ចទីផ្សារសេរី និងការលើកទឹកចិត្តវិនិយោគិន ឱ្យចូលបោះទុនជាច្រើន គឺបានស្រូបទាញយកភ្លាមៗនូវកម្លាំងពលកម្មពីជនបទ ដើម្បីបំពេញការងារ ដែលត្រូវការពលករច្រើន ហើយវាមានផលប៉ះពាល់ទៅដល់ការអភិវឌ្ឍទីក្រុងតាមរយៈកំណើនបម្លាស់លំនៅពីជនបទយ៉ាងគំហុក។ ដូច្នេះ ផែនការនាអនាគតមួយត្រូវតែគិតទុកឱ្យហើយ ព្រោះពេលដែលមានបម្លាស់លំនៅចូលទីប្រជុំជន តាមគ្រប់រូបភាព គឺពិតជាប៉ះពាល់ដល់បញ្ហាជាច្រើនសម្រាប់ជីវិតរស់នៅ ពោលគឺត្រូវមានផែនការច្បាស់លាស់ ដើម្បីរៀបចំប្រកបដោយនិរន្តរភាពយូរអង្វែង សម្រាប់ប្រសិទ្ធភាពទីប្រជុំជន ជា

[5] សុន្ទរកថា សម្ដេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា នៅក្នុងពិធីសម្ពោធអគារ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នៅថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២១

ពិសេសរាជធានីភ្នំពេញតែម្តង។ បម្លាស់លំនៅចូលទីក្រុង បានបង្កើតឱ្យមានការប្រមូលផ្តុំកម្មករនិយោជិត នៅតាមរោងចក្រសហគ្រាស និងបង្កើតបានជីវិតថ្មីមួយក្នុងសង្គម ទាំងផ្នែកស្មារតី (ការយល់ដឹង អំពីអង្គការសហជីព កូដកម្ម បាតុកម្ម នយោបាយនិងគណបក្ស) ទាំងផ្នែកវប្បធម៌ (ទំនាក់ទំនងយុវវ័យ ការស្លៀកពាក់ ការតុបតែង និងការប្រើប្រាស់សម្ភារៈទាន់សម័យ ម្ហូបអាហារ និងការកម្សាន្តនៅទីក្រុង ឬទីប្រជុំជន) ជាដើម។

# គន្ថនិទ្ទេស


- ក្រសួងផែនការ: ជំរឿនទូទៅនៃប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩ វិទ្យាស្ថានជាតិស្ថិតិ ឆ្នាំ២០២០
- ក្រុមប្រឹក្សាជាតិភាសាខ្មែរ: សទ្ទានុក្រមបច្ចេកសព្ទភូមិវិទ្យា និងប្រវត្តិវិទ្យា ឆ្នាំ២០១៨
- ឆយ អូន បម្លាស់លំនៅនៃប្រជាជនកម្ពុជាឆ្លងកាត់របបផ្សេងៗ ២០១៧
- ជា ចន្ថា: ការវិភាគអំពីកម្លាំងពលកម្មក្នុងប៉ូលសេដ្ឋកិច្ចភ្នំពេញ ព្រះសីហនុ និងសៀមរាប (២០០៨-២០១៨) និក្ខេបបទបណ្ឌិត ២០១៤
- សាគូ សាម៉ុត: ប្រវត្តិសាស្ត្រកម្ពុជា និងវរជនខ្មែរ ភ្នំពេញ ២០១៣
- រាជរដ្ឋាភិបាលកម្ពុជា: អត្ថបទគោលរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា សម្រាប់អធិប្បាយ ផ្តល់ការបំភ្លឺស្តីពីការងារបោះបង្គោលខណ្ឌសីមាព្រំដែនគោក និងការកំណត់ព្រំដែនសមុទ្រ រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណៈរដ្ឋសង្គមនិយមវៀតណាម សីហា ២០១២
- វ៉ាន់ឌី កាអុន: ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា ភាគទី២ បោះពុម្ពផ្សាយលើកទី២ ២០១០
- សាលាក្រុងភ្នំពេញ: ផែនការយុទ្ធសាស្ត្រអភិវឌ្ឍក្រុងឆ្នាំ២០០៥-២០១៥ ភ្នំពេញ ឆ្នាំ២០០៥
- អង្គការសហប្រជាជាតិ: កិច្ចព្រមព្រៀងនៅទីក្រុងប៉ារីសអំពីបញ្ហាកម្ពុជា(២៣-១០-១៩៩១)
- ហ៊ុន សែន: ១០ឆ្នាំនៃដំណើរការកម្ពុជា ១៩៧៩-១៩៨៩ រោងពុម្ព ណុប បូផាន់ ភ្នំពេញ ១៩៨៨
- សាធារណរដ្ឋប្រជាមានិតកម្ពុជា: បំភ្លឺមាគ៌ាបដិវត្តន៍ ក្រសួងឃោសនាអប់រំបដ្ឋិម លេខ២ ឆ្នាំ ១៩៨០

# សេដ្ឋកិច្ចវិទ្យានៃការបោះបង់ការសិក្សានៅវិទ្យាល័យ

(The Economics of High School Dropouts)

*ដោយៈ* **បណ្ឌិត សូ សុធីរ**

*មន្ត្រីស្រាវជ្រាវនាយកដ្ឋានវិទ្យាសាស្ត្រអប់រំ*

*នៃវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម រាជបណ្ឌិត្យសភាកម្ពុជា*

## ១-សេចក្តីផ្តើម

*បញ្ហាប្រឈមផ្នែកអប់រំដ៏សំខាន់មួយ នៅក្នុងស្ទើរតែគ្រប់ប្រទេសឧស្សាហកម្មទាំងអស់ កំពុងអះអាងថា សិស្សទាំងអស់ត្រូវតែបញ្ចប់វិ ទ្យាល័យ។ ទោះបីជាប្រទេសជាច្រើន អនុញ្ញាតឱ្យសិស្សឈប់រៀន មុនពេលបញ្ចប់មធ្យមសិក្សាទុតិយភូមិក៏ដោយ ក៏សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ត្រូវបានចាត់ទុកថា ជាតម្រូវការចាំបាច់បំផុតសម្រាប់ការចូលទៅក្នុងទីផ្សារការងារ និងសម្រាប់ការអប់រំក្រោយមធ្យមសិក្សា។ជាការពិតជាមួយសេដ្ឋកិច្ច ដែលបង្កើនបរិមាណការងារត ម្រូវឱ្យមានយ៉ាងហោចណាស់ ការសិក្សាក្រោយមធ្យមសិក្សាមួយចំនួន។ សិស្សដែលមិនទទួលបានសញ្ញាបត្រវិទ្យាល័យ ទំនងជានឹងធ្វើឱ្យទស្ស នវិស័យសេដ្ឋកិច្ចធ្លាក់ចុះ។*

*ទោះបីមានសារៈសំខាន់កាន់តែខ្លាំងឡើង នៃការបញ្ចប់វិទ្យាល័យក៏ដោយ ក៏ផ្នែកដ៏ធំមួយនៃចំនួននិស្សិត ក្នុងប្រទេសជាច្រើន ឈប់ឈប់រៀននៅវិទ្យាល័យ មុនពេលបញ្ចប់ការសិ ក្សា។ អត្ថបទនេះ ផ្តល់នូវការពិនិត្យឡើងវិញនូវសង្ខេបនៃការស្រាវជ្រាវអំពីអ្នកការបោះបង់ការសិក្សានៅវិទ្យាល័យ ផលវិបាកសេដ្ឋកិច្ច និងស ង្គមនៃការបោះបង់ការសិក្សា មូលហេតុការចាកចេញ និងអ្វីដែលអាចធ្វើបានធ្វើឱ្យប្រសើរឡើងនូវអត្រាបញ្ចប់ការសិក្សានៅវិទ្យាល័យសហរដ្ឋអាម៉េរិក។*

## ២-តើអ្នកណាបោះបង់ការសិក្សានៅវិទ្យាល័យ?

*សូចនាករមួយចំនួនត្រូវបានប្រើប្រាស់ ដោយភ្នាក់ងាររដ្ឋាភិបាល និងអ្នកស្រាវជ្រាវ ដើ ម្បីបញ្ជាក់ឱ្យប្រាកដថា ចំនួន និងអត្រាសិស្សបោះ បង់ការសិក្សានិងបញ្ចប់ការសិក្សានៅវិទ្យាល័យ។ សូចនាករ ខុសគ្នាទាក់ទងនឹងៈ*

*- និយមន័យនៃការបោះបង់ការសិក្សា ឬបញ្ចប់ការសិក្សា ដែលត្រូវបានប្រើ*

រួមទាំងការវាស់វែង និងពេលវេលា កំណត់អត្តសញ្ញាណ រយៈពេល។

- ចំនួនអ្នក ដែលត្រូវបានវាស់វែង។

- ប្រភពនៃទិន្នន័យ។

វិធានការមួយ គឺអត្រាបោះបង់ការសិ ក្សាប្រចាំឆ្នាំ ដែលវាស់សមាមាត្រសិស្ស ដែលឈប់រៀនជារៀងរាល់ឆ្នាំ។ នេះ បើតាមជំរឿនទិន្នន័យសិស្ស៥៣៥,000 នៅសហរដ្ឋអាម៉េរិក បានបោះបង់ការសិក្សានៃថ្នាក់ទី១0-១២ នៅក្នុងឆ្នាំ២0១៤-១៥ ឬប្រហែល៤.៩% នៃសិស្ស ដែលបានចុះឈ្មោះ (Snyder, de Brey, & Dillow, ឆ្នាំ២0១៨)។ នេះ មិនមែនជាការសង្ស័យទេ ព្រោះវាមិនរាប់បញ្ចូលសិស្ស ដែលបោះបង់ការសិក្សាមុនថ្នាក់ទី១0។ អត្រាបោះបង់ការសិក្សា គឺខ្ពស់ជាង សម្រាប់ក្រុមប្រជាសាស្ត្រមួយចំនួន៖

-បុរសមានអត្រាបោះបង់ការសិក្សាខ្ពស់ ជាងស្ត្រី។

-ជនជាតិស្បែកខ្មៅ និងពួកអេស្ប៉ាញ មានអត្រាបោះបង់ការសិក្សា ខ្ពស់ជាងជនជាតិអាស៊ី និងពួកស្បែកស។

-សិស្សមកពីគ្រួសារមានចំណូលទាប មានអត្រាបោះបង់ការសិក្សាខ្ពស់ជាងសិស្សពីគ្រួសារ ដែលមានប្រាក់ចំណូលខ្ពស់។

អត្រាបោះបង់ការសិក្សាប្រចាំឆ្នាំ នៅស ហរដ្ឋអាម៉េរិក ជាទូទៅ បានធ្លាក់ចុះ ដោយចាប់ផ្តើម នៅក្នុងទសវត្សឆ្នាំ១៩៧0 ឈានដល់កម្រិតទាបនៃ៣.0% ក្នុងឆ្នាំ២0១0 បន្ទាប់មកកាន់តែកើនឡើងនាពេលថ្មីៗនេះ ឈានដល់បច្ចុប្បន្នអត្រា៤.៩% ក្នុងឆ្នាំ២០១៥ (Snyder et al., ២0១៨)។

អត្រាបោះបង់ការសិក្សាប្រចាំឆ្នាំ បានបង្ហាញពីលទ្ធភាព ដែលសិស្សនឹងឈប់រៀន នៅក្នុងពេលណាមួយ នៅក្នុងអាជីពអប់រំរបស់គាត់។ វង្វាស់ល្អជាង គឺជាសមាមាត្រនៃការបោះបង់ការសិក្សា នៅក្នុងចំនួនប្រជាជន ដែលត្រូវបានគេហៅថា អត្រាបោះបង់ស្ថានភាព។ ជាថ្មីម្តងទៀត យោងតាមទិន្នន័យជំរឿននៅក្នុងឆ្នាំ២0១៥ នៅទីនោះ មានអ្នកបោះបង់ការសិក្សាចំនួន២.៣លាននាក់ ដែលមានអាយុ១៦ និង២៤ឆ្នាំ តំណាងឱ្យ ៥.៩%នៃចំនួនប្រជាជន (Snyderet al.,២0១៨)។ អត្រាទាំងនេះ ក៏មានខ្ពស់ជាង សម្រាប់ក្រុមប្រជាសាស្ត្រដូចគ្នាបានរៀបរាប់ខាងលើ។មិនដូចអត្រាបោះបង់ការសិក្សាប្រចាំឆ្នាំទេ ស្ថានភាពអត្រាបោះបង់ការសិក្សា បានធ្លាក់ចុះជាលំដាប់ក្នុងរយៈពេល២៥ឆ្នាំចុងក្រោយនេះ ពីកម្រិតខ្ពស់នៃ១៥.0% នៅក្នុង ១៩៧០ ដល់អត្រាបច្ចុប្បន្ន៥.៩% (Snyder et al.)។

ប៉ុន្តែ អត្រាបោះបង់ការសិក្សាតែម្យ៉ាង ប្រហែលជាមិនគ្រប់គ្រាន់ ដើម្បីបង្ហាញពីវិសាលភាពនៃបញ្ហា។ ទិន្នន័យជំរឿន ត្រូវបានគេរិះគន់ ព្រោះពួកគេពឹងផ្អែកលើស្ថានភាពអប់រំ ដែលបានរាយការណ៍ដោយខ្លួនឯងរបស់អ្នកឆ្លើយសំណួរ ដែលអ្នកឆ្លើយតប

ហួសហេតុ ហើយវា អាចនឹងផ្លាស់ប្ដូរនៅក្នុង ពេលណាមួយ ពីព្រោះយ៉ាងហោចណាស់ ការបោះបង់ការសិក្សាខ្លះ ផ្ដល់ផលចំណេញ ទៅសាលា។ ជាងនេះទៀត ដំរៀនចាត់ទុក បុគ្គល ដែលទទួលបានសញ្ញាបត្រមធ្យម សិក្សាទុតិយភូមិសមមូល តាមការប្រឡងការ អភិវឌ្ឍការអប់រំទូទៅ(General Education Development, GED) ជាការបញ្ចប់វិទ្យាល័យ ទោះបីភស្តុតាងទូលំទូលាយថា លិខិតសម្គាល់ ជំនួស មិនផ្ដល់អត្ថប្រយោជន៍សេដ្ឋកិច្ចដូចគ្នា នឹងសញ្ញាបត្រប្រពៃណីក៏ដោយ (Heckman, Hum- phries, & Mader, ២០១១)។

ដើម្បីផ្ដល់ជាទស្សនវិស័យតាមខ្សែ ប ណ្ដោយ ដែលយកការរីកចម្រើនរបស់ សិស្សវិទ្យាល័យឆ្ពោះទៅរកការបញ្ចប់ការ សិក្សា រដ្ឋាភិបាលក្នុងសហរដ្ឋអាម៉េរិក កំពុង ព្យាយាមវាស់ស្ទង់សមាមាត្រនៃសិស្សថ្នាក់ទី ៩ ដែលទទួលបានសញ្ញាបត្រទៀងទាត់ នៅ ក្នុងរយៈពេល៤ឆ្នាំ ដែលត្រូវបានគេស្គាល់ថា ជា អត្រាបញ្ចប់ការសិក្សាតាមក្រុមថ្នាក់ទីប្រាំ បួន។ អត្រាបែបនេះ ពិបាកវាស់វែង ជា ពិសេស ព្រោះវាទាមទារឱ្យមានការតាមដាន សិស្សច្រើនឆ្នាំ។ នេះ ជាបញ្ហាមួយផ្នែក ដោយសារតែសិស្ស តែងតែផ្ទេរពីកន្លែងអប់រំ មួយទៅកន្លែងមួយទៀត ក្នុងអំឡុងពេលនៅ វិទ្យាល័យរបស់ពួកគេ។ លើសពីនេះ សិស្ស មួយចំនួនត្រូវបានរក្សាទុកឱ្យនៅរៀន ជា ពិសេស នៅថ្នាក់ទី៩ នៅពេលដែលពួកគេ បរាជ័យ ក្នុងការទទួលបានក្រេឌីតគ្រប់គ្រាន់ ដើម្បីដំឡើងទៅថ្នាក់បន្ទាប់ទៀត។

វិធានការដាក់លាក់ចំនួនពីរ ត្រូវ បានប្រើ នាពេលបច្ចុប្បន្ន ប៉ាន់ប្រមាណអត្រា បញ្ចប់ការសិក្សាថ្នាក់ទីប្រាំបួននេះ។ អត្រា បញ្ចប់ការសិក្សាមធ្យមសិក្សាបឋមភូមិ ( Averaged Fresh- man Graduation Rate, AFGR) និងអត្រាបញ្ចប់ការសិក្សាតាមក្រុម ដែលបានកែសម្រួល (Ad justed Cohort Graduation Rate, ACGR)។ សូចនាករទាំង ពីរនេះ វាស់វែងអត្រាបញ្ចប់ការសិក្សា សម្រាប់សាលារដ្ឋ ដោយមិនអើពើប្រហែល ១០%នៃនិស្សិតវិទ្យាល័យ ដែលបានបញ្ចប់ ការសិ ក្សាពីសាលាឯកជន។ អត្រាបញ្ចប់ការ សិក្សាមធ្យមសិក្សាបឋមភូមិ ប៉ាន់ប្រមាណ អត្រាបញ្ចប់ការសិក្សាសម្រាប់ការចូលក្រុម សិ ស្ស ថ្នា ក់ ទី ៩ ដោ យ បែ ង ចែ ក ចំ នួ ន សញ្ញាបត្រសិស្សវិទ្យាល័យសាធារណៈ ដែល ទទួលបានក្នុងមួយឆ្នាំជា មួយនឹងការប៉ាន់ ប្រមាណចំនួនសិស្សថ្នាក់ទី៩ កាលពី៤ឆ្នាំ មុន (ជាមធ្យមនៃចំនួនសិស្សថ្នាក់ទី៨ កាល៥ ឆ្នាំមុន សិស្សថ្នាក់ទី៩ កាល៤ឆ្នាំមុន និង ចំនួនសិស្សថ្នាក់ទី១០ កាល៣ឆ្នាំមុន)។ អត្រា បញ្ចប់ការសិក្សាមធ្យមសិក្សាបឋមភូមិ គឺ ផ្អែកលើទិន្នន័យរដ្ឋបាលសរុប នៅលើការ រាប់ផ្នែកឆ្លងកាត់នៃសិស្ស ដែលបានរាយ ការណ៍ទៅរដ្ឋ ហើយដូច្នេះ មិនមែនជាអត្រា ក្រុមពិតប្រាកដទេ។ ផ្ទុយទៅវិញ អត្រាបញ្ចប់

ការសិក្សា តាមក្រុម ដែលបានកែសម្រួលជាអត្រាក្រុមពិតប្រាកដ ដោយផ្អែកលើកម្រិតបុគ្គលកំណត់ត្រាសិស្ស ចងក្រងដោយរដ្ឋ ទីភ្នាក់ងារអប់រំ និងរាយការណ៍ទៅរដ្ឋាភិបាល។ អត្រាបញ្ចប់ការសិក្សា តាមក្រុមដែលបានកែសម្រួលផ្លូវការ ដូចដែលបានកំណត់ដោយរដ្ឋាភិបាលសហព័ន្ធ ក្នុងឆ្នាំ២០០៩ តំណាងឱ្យអត្រាប ញ្ចប់ការសិក្សារយៈពេល៤ឆ្នាំ ឬ"ទាន់ពេល" ផ្អែកលើអំពីចំនួនសិស្សថ្នាក់ទីប្រាំបួន ដែលទទួលបាន សញ្ញាបត្រទៀងទាត់ក្នុងរយៈពេល៤ឆ្នាំ។ អត្រានេះ មិនបង្ហាញថា មានសិស្សថ្នាក់ទី៩ប៉ុន្មាននាក់ នៅទីបំផុតទទួលបានសញ្ញាបត្រ។

អង្គការសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច និងកិច្ចសហប្រតិបត្តិការ (The Organization for Economic and Cooperative Development, OECD) គណនាភាគរយនៃនិស្សិតបញ្ចប់ថ្នាក់មធ្យមសិក្សាទុតិយភូមិដំបូងដល់ប្រជាជន នៅអាយុធម្មតានៃការបញ្ចប់ការសិក្សា។ អត្រាបញ្ចប់ការសិក្សាជាមធ្យមសម្រាប់មនុស្ស ដែលមានអាយុក្រោម២៥ឆ្នាំក្នុងចំណោមប្រទេសអង្គការស ម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច និងកិច្ចសហប្រតិបត្តិការ ក្នុងឆ្នាំ២០១៦ គឺ៨១% ចាប់ពី៥៧% ក្នុងប្រទេសម៉ិកស៊ិក ដល់៩៤% នៅក្នុងប្រទេសកូរ៉េ ជាមួយនឹងអត្រាសហរដ្ឋអាម៉េរិកនៅ៨៤% (OECD, ២០១៨)។

**៣- តើមានផលវិបាកអ្វីខ្លះ?** (What are the consequences?)

ការបោះបង់ការសិក្សា មានផលវិបាកផ្នែកសេដ្ឋកិច្ច និងសង្គម ទាំងអ្នកបោះបង់ការសិ ក្សាខ្លួនឯង និងសម្រាប់ប្រទេសទាំងមូល។

-អ្នកបោះបង់ការសិក្សា មានការលំបាកក្នុងការស្វែងរកការងារ។ ទិន្នន័យរដ្ឋាភិបាល បានបង្ហាញថា មនុស្សច្រើនជាង៣៧% អាយុពី១៦ ទៅ២៤ឆ្នាំ នៅខែតុលា ឆ្នាំ២០១៥ ដែលបានបោះ បង់ការសិក្សាឆ្នាំមុន អត់មានការងារធ្វើ (Snyder et al.,ឆ្នាំ២០១៨)។ ក្នុងចំណោមមនុស្ស ដែលមានអាយុពី២០ ទៅ២៤ឆ្នាំទាំងអស់ក្នុងខែតុលា ឆ្នាំ២០១៥ អត្រាគ្មានការងារធ្វើស សម្រាប់ការបោះបង់ការសិក្សាគឺ២១.៤% ធៀបនឹង១៤.៥% សម្រាប់និស្សិតបញ្ចប់ការសិក្សា នៅវិ ទ្យាល័យ និង៦.០% សម្រាប់រយៈពេល៤ឆ្នាំ នៃនិស្សិតបញ្ចប់ការសិ ក្សា នៅមហាវិទ្យាល័យ (Snyder et al., ២០១៨)។

-ទោះជាពួកគេស្វែងរកការងារធ្វើក៏ដោយ សិស្សដែលបោះបង់ការសិក្សា រកប្រាក់បានតិចជាងសិស្សបញ្ចប់ការសិក្សា នៅថ្នាក់វិទ្យាល័យ។ ក្នុងឆ្នាំ២០០៥ ប្រាក់ចំណូលប្រចាំឆ្នាំជាមធ្យមរបស់អ្នកបោះបង់ការសិក្សានៅវិទ្យាល័យ មានចំនួនតិចជាង២៥%នៃប្រាក់ចំណូលរបស់សិស្សបញ្ចប់វិទ្យាល័យ

(Snyder et al., ២០១៨)។ ក្នុងជីវិតការងាររបស់ពួកគេ ការិយាល័យជំរឿន បានប៉ាន់ប្រមាណថា អ្នកបោះបង់ការសិក្សា នឹងរកបានប្រហែល$២00,000 តិចជាងសិស្សបញ្ចប់ការសិក្សានៅសាលា។

ហេតុផលមួយ សម្រាប់ការធ្លាក់ចុះសេដ្ឋកិច្ចក្រីក្ររបស់អ្នកបោះបង់ការសិក្សា គឺកម្រិតនៃការអប់រំទាបរបស់ពួកគេ។ ប៉ុន្តែ អ្នកបោះបង់ការសិក្សា អាចត្រឡប់ទៅសាលាវិញ។ សិស្សថ្នាក់ទីប្រាំបីស្ទើរតែពាក់កណ្តាលនៃឆ្នាំ១៩៨៨ ដែលបោះបង់ការសិក្សា បានបញ្ចប់ការសិក្សានៅវិទ្យាល័យ ដែលទទួលបានសញ្ញាប័ត្រ(១៦%) ឬវិញ្ញាបនបត្រសមមូល(២៩%) ក្នុងរយៈពេលពីរឆ្នាំនៃកាលបរិច្ឆេទបញ្ចប់ការសិក្សារបស់ពួកគេដែលបានគ្រោងទុកក្នុងឆ្នាំ១៩៩២ (Berktold, Geis, & Kaufman,ឆ្នាំ១៩៩៨)។ សិស្សបោះបង់ការសិក្សា ដែលបញ្ចប់វិទ្យាល័យ ទំនងជាចុះឈ្មោះចូលរៀន នៅក្រោយមធ្យមសិក្សាជាងសិស្ស ដែលមិនបានបញ្ចប់ការសិក្សាវិទ្យាល័យ (៤២% ទល់នឹង១៤%) (Berktoldet al., ១៩៩៨)។ យ៉ាងណាក៏ដោយ អ្នកបោះបង់ការសិក្សាដូចជាក្រុមមួយ ទំនងជាបានចុះឈ្មោះចូលរៀននៅនៅក្រោយមធ្យមសិក្សាតិចជាងអ្នកបញ្ចប់វិទ្យាល័យ ទោះបីជារដ្ឋភាគច្រើន អនុញ្ញាតឱ្យអ្នកបោះបង់ការសិក្សាចូលរៀន នៅមហាវិទ្យាល័យសហគមន៍ដោយគ្មានសញ្ញាបត្រវិទ្យាល័យក៏ដោយ។

អ្នកបោះបង់ការសិក្សា ជួបប្រទះលទ្ធផលអវិជ្ជមានផ្សេងទៀត (Belfield & Levin, ២00៧)។ អ្នកបោះបង់ការសិក្សា មានសុខភាពខ្សោយ និងអត្រាមរណភាពខ្ពស់ជាងនិស្សិតបញ្ចប់វិទ្យាល័យ។ ពួកគេទំនងជាមានអាកប្បកិរិយាព្រហ្មទណ្ឌ ហើយត្រូវជាប់គុកពេញមួយជីវិត បើប្រៀបធៀបទៅនឹងនិស្សិតបញ្ចប់ការសិក្សា។ ពួកគេក៏ទំនងជាត្រូវការជំនួយសាធារណៈ និងមិនសូវមានលទ្ធភាពបោះឆ្នោតដែរ។ ទោះបីជាទំនាក់ទំនង ដែលបានសង្កេតឃើញរវាងការបោះបង់ការសិក្សា និងលទ្ធផលសេដ្ឋកិច្ច និងសង្គមទាំងនេះ មិនចាំបាច់បញ្ជាក់ពីទំនាក់ទំនងបុព្វហេតុក៏ដោយ ជាក់ស្តែងភស្តុតាងស្រាវជ្រាវដែលកំពុងកើនឡើងបានបង្ហាញឱ្យឃើញមួយ។ នេះបានបង្ហាញថា ការខិតខំប្រឹងប្រែងកាត់បន្ថយអត្រាបោះបង់ការសិក្សាតាមពិតនឹងកាត់បន្ថយលទ្ធផលសេដ្ឋកិច្ច និងសង្គមអវិជ្ជមានទាំងនេះ។

លទ្ធផលអវិជ្ជមានពីអ្នកបោះបង់ការសិក្សា បង្កើតការចំណាយសង្គមដ៏ធំ។ រដ្ឋាភិបាលប្រមូលពន្ធតិចជាងមុនពីអ្នកបោះបង់ការសិក្សា។ រដ្ឋាភិបាលក៏ផ្តល់ប្រាក់ឧបត្ថម្ភដល់អ្នក ដែលមានសុខភាពមិនល្អ សកម្មភាពឧក្រិដ្ឋកម្មធ្ងន់ធ្ងរ និងកើនឡើងជំនួយសាធារណៈនៃអ្នកបោះបង់ការសិក្សា។ ការសិក្សាថ្មីមួយ ប៉ាន់ប្រមាណថា សិស្សវិទ្យាល័យថ្មីនីមួយៗ នឹងបង្កើតបានច្រើន

ជាង$២០០, ០០០ នៅក្នុងការសន្សំរបស់រដ្ឋាភិបាល ហើយថាកាត់បន្ថយពាក់កណ្តាលអត្រាបោះបង់ការសិក្សាពីក្រុមតែមួយនៃការបោះបង់ការសិក្សា នឹងបង្កើតប្រាក់សន្សំបានជាង៤៥ពាន់លានដុល្លារ(Belfield & Levin, ២០០៧)។

និន្នាការសេដ្ឋកិច្ច ប្រជាសាស្ត្រ និងការអប់រំមួយចំនួន អាចធ្វើឱ្យបញ្ហាទាំងនេះកាន់តែធ្ងន់ធ្ងរទៅៗនាពេលអនាគត។ ដោយសារតែសេដ្ឋកិច្ចរបស់សហរដ្ឋអាម៉េរិកផ្លោះទៅរកកម្លាំងពលកម្ម ដែលមានជំនាញកាន់តែខ្ពស់នោះ អ្នកបោះបង់ការសិក្សា នឹងមានពេលវេលាកាន់តែពិបាកក្នុងការរស់រានមានជីវិតទាក់ទងនឹងសេដ្ឋកិច្ច។ ចំនួនសិស្សដែលជាទូទៅ មានហានិភ័យខ្ពស់ ដែលសិស្សបរាជ័យនៃសាលារៀន និងគ្រួសារមានចំណូលទាបនិងពូជសាសន៍ ជាតិពន្ធុ និងភាសាជនជាតិភាគតិចកំពុងបង្កើនក្នុងសាលារៀនរបស់ជាតិ។ ជាចុងក្រោយ ការជំរុញឱ្យមានគណនេយ្យភាព នៅក្នុងសាលារដ្ឋរបស់ប្រទេសជាតិ ដែលបានបង្កើតគោលនយោបាយ ដើម្បីបញ្ចប់ការជួយសិស្សឱ្យឡើងថ្នាក់ (End social promotion) និងដើម្បីបង្កើតការប្រឡងចេញពីវិទ្យាល័យ អាចកើនឡើងចំនួនសិស្ស ដែលខកខានមិនបានបញ្ចប់វិទ្យាល័យ។

## ៤-ហេតុអ្វីបានជាសិស្សឈប់រៀន ?

( Why do students drop out? )

ការស្វែងយល់ពីមូលហេតុដែលសិស្ស បោះបង់ការសិក្សាពីសាលាជាគន្លឹះក្នុងការដោះ ស្រាយបញ្ហាអប់រំដ៏សំខាន់នេះ។ មកដល់ពេលនេះ ការកំណត់អត្តសញ្ញាណមូលហេតុនៃបោះ បង់ការសិក្សា ពិបាកខ្លាំងណាស់។ ដូចទម្រង់នៃសមិទ្ធផលអប់រំផ្សេងទៀត (ឧ. ពិន្ទុតេស្ត) មូលហេតុនៃការបោះបង់ការសិក្សា គឺបណ្តាលមកពីរបៀបនៃកត្តាជះឥទ្ធិពលផ្ទាល់ និងមិនផ្ទាល់ដល់សុខភាព (Proximal and distal factors) ពាក់ព័ន្ធទាំងសិស្សម្នាក់ៗ និងចំពោះសិស្ស កំណត់គ្រួសារ សាលារៀន និងសហគមន៍ ដែលសិស្សរស់នៅ។

សិស្សបោះបង់ការសិក្សា បានរាយការណ៍ពីហេតុផលផ្សេងៗសម្រាប់ការឈប់រៀន រួមទាំងទាក់ទងនឹងសាលារៀនផង រួមបញ្ចូលហេតុផលទាក់ទងនឹងសាលារៀន ហេតុផលទាក់ទងនឹងគ្រួសារ និងហេតុផលទាក់ទងនឹងការសិក្សា (Rotermund, ២០០៧)។ ហេតុផលជាក់លាក់បំផុត ដែលបានលើកឡើងដោយសិស្សថ្នាក់ទីដប់ឆ្នាំ២០០២ ដែលបានបោះបង់ការសិក្សាត្រូវបាន «គេចពីសាលាច្រើនថ្ងៃពេក" (៤៤%) "បានគិតថាវានឹងកាន់តែងាយស្រួលក្នុងការទទួលបាន ការអភិវឌ្ឍការអប់រំទូទៅ(General Education

**កត្តាបុគ្គល** (Individual factors)

កត្តាបុគ្គលផ្សេងៗគ្នា ត្រូវបានភ្ជាប់ជាមួយនឹងការបោះបង់ការសិក្សា (Rumberger, ២០១១) រួមទាំងកត្តាប្រជាសាស្ត្រជាច្រើន។ ជាទូទៅ អត្រាការបោះបង់ការសិក្សា មានកម្រិតខ្ពស់ជាងក្នុងចំណោមបុរស ជនជាតិស្បែកខ្មៅ និងពួកអេស្ប៉ាញ ជនអន្តោប្រវេសន៍ និងសិស្សប្រើភាសាជនជាតិភាគតិច។ ឥរិយាបថ ក៏ប៉ះពាល់ដល់អត្រាបោះបង់ការសិក្សាផងដែរ។ អត្រាបោះបង់ការសិក្សា ក៏ខ្ពស់ជាងក្នុងចំណោមសិស្ស ដែលមានការអប់រំទាប និងជីវភាពទាប។ សកម្មភាព និងអាកប្បកិរិយាជាច្រើន ក៏ព្យាករអត្រាបោះបង់ ការសិក្សា រួមទាំងអវត្តមានអាកប្បកិរិយាមិនល្អ នៅក្នុងសាលារៀន និងការមានផ្ទៃពោះ។ ទីបំផុតការសម្រេចបានការសិក្សាខ្សោយ គឺជាអ្នកព្យាករយ៉ាងខ្លាំងនៃបោះបង់ការសិក្សា។ ជារួម កត្តាទាំងនេះ គាំទ្រគំនិត ដែលថា ការបោះបង់ការសិក្សាត្រូវបានជះឥទ្ធិពលដោយបទពិសោធសង្គម និងការសិក្សារបស់សិស្ស។

បន្ថែមពីលើកត្តាសុខភាពផ្ទាល់ (Proximal factors) ទាំងនេះ កត្តាមិនផ្ទាល់មួយចំនួនត្រូវបានភ្ជាប់ជាមួយនឹងការបោះបង់ការសិក្សា ដូចជាចល័តភាពសិស្ស។ ទាំងការចល័តលំនៅដ្ឋាន (ផ្លាស់ប្តូរទីលំនៅ) និងការចល័តសាលារៀន (ការផ្លាស់ប្តូរសាលារៀន) បង្កើនហានិភ័យនៃការបោះបង់ Development, GED) (៤១%); "ទទួលបានចំណាត់ថ្នាក់ក្រីក្រ/ បរាជ័យសាលារៀន" (៣៨%); "មិនចូលចិត្តសាលារៀន" (៣៧%); និង "មិនអាចបន្តកិច្ចការសាលាបានទេ" (៣២%)។ ប៉ុន្តែ ហេតុផលទាំងនេះមិនបង្ហាញមូលហេតុជាមូលដ្ឋាន ដែលនាំឱ្យសិស្សឈប់រៀន ជាពិសេស មូលហេតុ ឬកត្តាទាំងនោះនៅក្នុងបឋមសិក្សា ឬអនុវិទ្យាល័យ ដែលអាចរួមចំណែកដល់ឥរិយាបថ អាកប្បកិរិយាសិស្ស និងស្នាដៃរបស់សាលា មុនការសម្រេចចិត្តចាកចេញរបស់ពួកគេពីសាលារៀន។ ជាងនេះទៅទៀត ប្រសិនបើកត្តាជាច្រើន រួមចំណែកដល់បាតុភូតនេះ ក្នុងរយៈពេលយូរនោះ វាស្ទើរតែមិនអាចទៅរួចទេ ក្នុងការបង្ហាញពីទំនាក់ទំនងមូលហេតុរវាងកត្តាតែមួយ និងការសម្រេចចិត្តឈប់រៀន។ ទោះបីមានការលំបាកនេះក៏ដោយ កត្តាពីរប្រភេទត្រូវបានគេកំណត់អត្តសញ្ញាណ ដែលរួមចំណែកដល់ ឬបង្កើនលទ្ធភាពដែលសិស្សបោះបង់ការសិក្សា៖

-កត្តាបុគ្គលដែលទាក់ទងនឹងលក្ខណៈឥរិយាបថ អាកប្បកិរិយា និងបទពិសោធរបស់សិស្ស។

-កត្តាបរិបទ ដែលទាក់ទងនឹងគ្រួសារ សាលារៀន សហគមន៍ និងមិត្តភ័ក្តិរបស់សិស្ស។

ការសិក្សានៅវិទ្យាល័យ (Rumberger, ២០១៥)។ ការចល័តរបស់សិស្សអាចតំណាងឱ្យភាពមិនសូវធ្ងន់ធ្ងរជាងទម្រង់នៃការមិនចូលរៀនរបស់សិស្សនៅសាលា។ កត្តាមិនផ្ទាល់មួយទៀត គឺការចូលរៀននៅក្នុងថ្នាក់។ ទោះបីជាចូលរៀននៅក្នុងថ្នាក់ អាចមានឥទ្ធិពលវិជ្ជមានលើសមិទ្ធផលសិក្សាក្នុងរយៈពេលខ្លីក៏ដោយ ការសិក្សាជាច្រើន បានរកឃើញថា វាបង្កើនលទ្ធភាពយ៉ាងខ្លាំងនូវភាពទំនង ដែលថាសិស្សនឹងបោះបង់ការសិក្សាពីសាលា។ ទីបំផុត ការសិក្សាចំនួនក្នុងរយៈពេលវែងបានរកឃើញថា កង្វះការសិក្សាសមិទ្ធផលដំបូង និងការចូលរួម (ឧ. វត្តមាន អាកប្បកិរិយាមិនល្អ) នៅសាលាបឋមសិក្សា និងមធ្យមបឋមភូមិ ព្យាករពីការដកខ្លួនចេញពីវិទ្យាល័យ។

**កត្តាស្ថាប័ន** (Institutional factors)

ខណៈពេលដែលកត្តាបុគ្គល បានរួមចំណែកយ៉ាងច្បាស់ ដល់ការសម្រេចចិត្តរបស់សិស្សក្នុងការបោះបង់ការសិក្សា ឥរិយាបថ និងអាកប្បកិរិយារបស់បុគ្គលម្នាក់ៗ ត្រូវបានបង្កើតឡើងដោយការកំណត់ឬបរិបទផ្សេងៗ ដែលសិស្សបានរស់នៅក្នុងគ្រួសារ សាលារៀន សហគមន៍ និងក្រុមមិត្តភ័ក្តិ។ សារៈសំខាន់នៃបរិបទក្នុងការផ្លាស់ប្តូរឥរិយាបថ រួមទាំងការបោះបង់ការសិក្សាត្រូវបានគេទទួលស្គាល់ នៅក្នុងរបាយការណ៍មួយ ដោយក្រុមប្រឹក្សាស្រាវជ្រាវជាតិស្តីពីយុវជន ដែលមានហានិភ័យខ្ពស់(១៩៩៣) ដែលបានអះអាងថា ការសង្កត់ធ្ងន់ខ្លាំងពេកលើយុវជន "ដែលមានហានិភ័យខ្ពស់" និងក្រុមគ្រួសាររបស់ពួកគេ និងមិនគ្រប់គ្រាន់ទេលើការកំណត់ហានិភ័យខ្ពស់ ដែលពួកគេរស់នៅ និងទៅសាលារៀន។ កត្តាមួយចំនួននៅក្នុងគ្រួសារ សាលារៀន និងសហគមន៍របស់សិស្ស (និងទំនាក់ទំនងមិត្តភ័ក្តិ) កំណត់ទុកជាមុនអំពីការបោះបង់ការសិក្សា។

**គ្រួសារ** (Families)

ប្រវត្តិគ្រួសារ ត្រូវបានគេទទួលស្គាល់យ៉ាងទូលំទូលាយថា ជាអ្នករួមចំណែកដ៏សំខាន់បំផុតតែមួយគត់ ចំពោះភាពជោគជ័យក្នុងសាលា។ ជាទូទៅ ស្ថានភាពសេដ្ឋកិច្ចសង្គម ត្រូវបានវាស់វែងសាមញ្ញបំផុតដោយការអប់រំឪពុកម្តាយ និងប្រាក់ចំណូលគ្រួសារ ជាអ្នកទស្សន៍ទាយដ៏មានឥទ្ធិពលនៃសមិទ្ធផលសាលា និងឥរិយាបថបោះបង់ការសិក្សា។ ការអប់រំមាតាបិតា មានឥទ្ធិពលលើសេចក្តីប្រាថ្នារបស់សិស្ស និងការគាំទ្រផ្នែកអប់រំ។ ខណៈពេលដែលប្រាក់ចំណូលគ្រួ សារ អនុញ្ញាតឱ្យឪពុកម្តាយ ផ្តល់ធនធានបន្ថែមទៀត ដើម្បីគាំទ្រដល់ការអប់រំរបស់កូនរបស់ពួកគេ រួមទាំងលទ្ធភាពទទួលបានសាលារៀន ដែលមានគុណភាពល្អជាង និងការគាំទ្របន្ថែមទៀតសម្រាប់ការរៀននៅក្នុងផ្ទះ។ លើសពីនេះទៀត សិស្សដែលមាន

ឪពុកម្តាយត្រួតពិនិត្យ និងគ្រប់គ្រងសកម្មភាពរបស់ពួកគេ បានផ្តល់ការគាំទ្រអារម្មណ៍ លើកទឹកចិត្តដល់ការសម្រេចចិត្តដោយឯករាជ្យ(ត្រូវគេស្គាល់ថាជាឪពុកម្តាយដែលផ្តល់សិទ្ធិអំណាចដល់កូន) ហើយជាទូទៅ ត្រូវបានចូលរួមកាន់តែច្រើន នៅក្នុងការសិក្សារបស់ពួកគេ ទំនងជាមិនសូវបោះបង់ការសិក្សាទេ។ លើសពីនេះ សិស្សដែលមានតែឪពុក ឬម្តាយ គ្រួសារមានឪពុក ឬម្តាយចុង ទំនងជាបោះបង់ចោលសាលារៀនជាងសិស្សក្នុងគ្រួសារ ដែលមានឪ ពុកម្តាយទាំងពីរនាក់។

**សាលារៀន** ( Schools )

គេបានទទួលស្គាល់យ៉ាងទូលំទូលាយថា សាលារៀនមានឥទ្ធិពលយ៉ាងខ្លាំង លើសមិទ្ធផលរបស់សិស្ស រួមទាំងអត្រាបោះបង់ការសិក្សា។ សាលាបួនប្រភេទ មានឥទ្ធិពលលើការអនុវត្តរបស់សិស្ស៖ សមាសភាពសង្គមនៃសាលារៀន លក្ខណៈពិសេសខាងរចនាសម្ព័ន្ធ ធនធានសាលា និងគោលនយោបាយសាលារៀន។

-សមាសភាពសង្គមនៃសាលារៀន ដែលជាលក្ខណៈរបស់សិស្ស ចូលរៀននៅសា លារៀន ជាពិសេស សមាសភាពសេដ្ឋកិច្ចសង្គមរបស់រាងកាយសិស្ស ព្យាករការបោះបង់ការសិក្សា សូម្បីបន្ទាប់ពីការគ្រប់គ្រងកត្តាបុគ្គល ដែលមានឥទ្ធិពលលើការបោះបង់ការសិក្សាក៏ដោយ។

-លក្ខណៈទីពីរ ទាក់ទងនឹងលក្ខណៈរចនាសម្ព័ន្ធនៃសាលារៀន ដូចជាទំហំ ទីតាំង និងការគ្រប់គ្រងសាលា (សាធារណៈទល់នឹងឯកជន)។ អត្រាបោះបង់ការសិក្សាពីសាលាកាតូលិក និងសាលាឯកជនផ្សេងទៀត ទាបជាងការបោះ បង់ការសិក្សាពីសាលារដ្ឋ សូម្បីតែបន្ទាប់ពីការគ្រប់គ្រងភាពខុសគ្នានៅក្នុងប្រវត្តិលក្ខណៈពិសេសរបស់សិស្ស។ មកដល់ពេលនេះ សិស្សមកពីសាលាឯកជន ជាធម្មតាផ្ទេរទៅសាធារណៈសាលារៀនជំនួសឱ្យ ឬមុនពេលបោះបង់ការសិ ក្សា ដើម្បីអត្រានៃការផ្លាស់ប្តូរសិស្សនៅក្នុងសាលាឯកជនខុសគ្នាខាងស្ថិតិជាងអត្រាក្នុងសាលារដ្ឋ។ សាលារៀនតូចៗ មានអត្រាបោះបង់ការសិក្សាទាបជាង។ អ្វីដែលមិនសូវច្បាស់ គឺថា តើលក្ខណៈរចនាសម្ព័ន្ធខ្លួនឯង ពន្យល់ភាពខុសគ្នាទាំងនេះ ឬថា តើពួកគេ ទាក់ទងនឹងភាពខុសគ្នានៃលក្ខណៈសិស្ស និងធនធានសាលា ជាញឹកញាប់ ទាក់ទងនឹងលក្ខណៈពិសេសនៃរចនាសម្ព័ ន្ធសាលារៀន។

-ប្រភេទទីបីនៃលក្ខណៈពិសេសទាក់ ទងនឹងធនធានសាលា។ ធនធាន ជាពិសេស សមាមាត្រសិស្ស/គ្រូ និងគុណភាពគ្រូបង្រៀន ហាក់ដូចជាមានឥទ្ធិពលលើអត្រាបោះបង់ការសិក្សា បន្ទាប់ពីការគ្រប់គ្រងបុគ្គល និងកត្តាបរិបទ ដែលអាចមានឥទ្ធិពលផងដែរ ដល់អត្រាបោះបង់ការសិក្សា។

-ប្រភេទចុងក្រោយ ទាក់ទងនឹងគោលនយោបាយសាលា និងការអនុវត្ត។ ជាពិសេស បរិយាកាសការសិក្សា និងសង្គម ត្រូវបានវាស់វែងដោយសាលាអត្រាចូលរៀននៅសាលា សិស្សដែលទទួលបានវគ្គសិក្សាជាន់ខ្ពស់ និងប្រ ត្យក្សារម្មណ៍របស់សិស្ស អំពីពិព័រណ៍មួយនៃគោលន យោបាយវិន័យត្រឹមត្រូវ ព្យាករពីការបោះបង់ការសិក្សា សូម្បីតែបន្ទាប់ពីការគ្រប់គ្រងលក្ខណៈប្រវ ត្តិរបស់សិស្ស ព្រមទាំងធនធាន និងលក្ខណៈពិសេសរចនាសម្ព័ន្ធនៃសាលារៀន។

កត្តាសាលា រួមចំណែកដល់ការបោះ បង់ការសិក្សារបស់សិស្សតាមពីរវិធី។ វិធីមួយ គឺដោយប្រយោល តាមការបង្កើតលក្ខខណ្ឌ ដែលមានឥទ្ធិពលលើសិស្សការចូលរួម និងការបោះ បង់ការសិក្សាដោយស្ម័គ្រចិត្តរបស់ពួកគេពីសាលា។ វិធីមួយទៀត គឺដោយផ្ទាល់ តាមរយៈគោលនយោបាយច្បាស់លាស់ និងការសម្រេចចិត្តតាមមនសិការ តាមបុគ្គលិកសាលា ដែលបណ្តាលឱ្យសិស្សបោះបង់ការសិក្សា ពីសាលាដោយអចេតនា។ ច្បាប់ទាំងនេះ និងសកម្មភាពអាចទាក់ទងនឹងកម្រិតពិន្ទុទាប ការចូលរៀនមិនល្អ អាកប្បកិរិយាមិនសមរម្យ (ដូចជាគោលការណ៍មិនអត់ឱន) ឬអាយុលើស ហើយអាចនាំឱ្យមានការព្យួរការសិក្សា ការបណ្តេញចេញ ឬការផ្ទេរដោយបង្ខំ។ ទម្រង់នៃការបោះ បង់ការសិក្សានេះ ធ្វើឡើងដោយសាលា និងផ្ទុយពីទម្រង់ដែលផ្តួចផ្តើមដោយសិស្សបានរៀបរាប់ខាងលើ។ ឧទាហរណ៍សាលាមួយចំនួន បានរួមចំណែកដល់ការបោះ បង់ការសិក្សា ដោយមិនស្ម័គ្រចិត្តរបស់សិស្សចេញពីសាលា ដោយមិនរាប់បញ្ចូល និងបណ្តេញចេញជាប្រព័ន្ធនូវ"អ្នកបង្កបញ្ហា" និងសិស្សដែលមានបញ្ហាផ្សេងទៀត។

## សហគមន៍ និងមិត្តរួមការងារ

(Community and peers)

បន្ថែមពីលើគ្រួសារ និងសាលារៀន សហគមន៍ និងក្រុមមិត្តភ័ក្តិ អាចមានឥទ្ធិពលលើសិស្សការបោះបង់ការសិក្សាពីសាលារៀន។ ភាពខុសប្លែកគ្នានៃលក្ខណៈសហគមន៍ អាចជួយពន្យល់ពីភាពខុសគ្នានៃអត្រាបោះបង់ការសិក្សាក្នុងចំណោមសហគមន៍ ក្រៅពីឥទ្ធិពលគ្រួសារ។ កស្តុតាងខ្លះ បង្ហាញថា មានកម្រិតកំណត់ លើគុណភាពនៃអ្នកជិតខាង ដែលនាំឱ្យអត្រាបោះបង់ការសិក្សាខ្ពស់នៅក្នុងសង្កាត់ ដែលជួបការលំបាកបំផុត។ សហគមន៍ក្រីក្រ អាចមានឥទ្ធិពលលើកុមារ និងការវិវត្តរបស់ក្មេងជំទង់ តាមរយៈកង្វះធនធាន (សួនកុមារ បន្ទាប់ពីចូលរៀនកម្មវិធី) ឬឥទ្ធិពលអវិជ្ជមានរបស់មិត្តភ័ក្តិ។ អ្នករស់ក្នុងស ហគមន៍ ក៏អាចជះឥទ្ធិពលលើការប្រតិបត្តិរបស់មាតាបិតា ហួសពីការអប់រំ និងប្រាក់ចំណូលរបស់មាតាបិតាផងដែរ។ សិស្ស ដែលរស់នៅក្នុងសហគមន៍ក្រីក្រ ទំនងជាបោះបង់ការសិក្សាច្រើនជាងមិត្តភ័ក្តិខ្លួន។ វិធីមួយ

ទៀត ដែលសហគមន៍ អាចជះឥទ្ធិពលលើអត្រាបោះបង់ការសិក្សា តាមរយៈការផ្តល់ឱកាសការងារទាំងអំឡុងពេល ឬក្រោយពេលសិក្សា។ ឱកាសការងារអំណោយផលសម្រាប់ការបោះបង់ការសិក្សានៅវិទ្យាល័យ ដូចដែលបានបង្ហាញដោយអត្រាអ្នកអត់ការងារធ្វើនៅក្នុងសង្កាត់ទាប ហាក់ដូចជាបង្កើនលទ្ធភាព ដែលសិស្សនឹងឈប់រៀន ខណៈពេលដែលផលចំណេញខាងសេដ្ឋកិច្ចដល់អ្នកបញ្ចប់ការសិក្សា ដូចដែលបានបង្ហាញដោយប្រាក់ខែខ្ពស់នៃនិស្សិតបញ្ចប់វិទ្យាល័យ បើធៀបនឹងការបោះ បង់ការសិក្សា ទំនងជាមានអត្រាបោះបង់ការសិក្សាទាប។ ការសិក្សាច្រើនម៉ោង នៅវិទ្យាល័យអាចបង្កើនលទ្ធភាពនៃការឈប់រៀន ផលប៉ះពាល់នៃការសិក្សានៅវិទ្យាល័យអាស្រ័យលើប្រភេទនៃការងារ និងតាមភេទរបស់សិស្ស។

## ៥-តើអាចមានដំណោះស្រាយអ្វីខ្លះ?
(What can be done?)

ចំណេះដឹង អំពីមូលហេតុដែលសិស្សបោះបង់ការប្រឡងផ្តល់ចំណុចជាច្រើនអំពីអ្វីដែលអាចធ្វើបាន រៀបចំយុទ្ធសាស្ត្រអន្តរាគមន៍ការបោះបង់ការសិក្សាប្រកបដោយប្រសិទ្ធភាព (Rumberger, ២០១១)។

ទី១ ដោយសារការបោះបង់ការសិក្សា បានជះឥទ្ធិពលទាំងបុគ្គល និងកត្តាស្ថាប័ន យុទ្ធសាស្ត្រអន្តរាគមន៍ អាចផ្តោតលើកត្តាណាមួយ ឬទាំងពីរ។ នោះ គឺអន្តរាគមន៍យុទ្ធសាស្ត្រ អាចផ្តោតលើការដោះស្រាយគុណតម្លៃបុគ្គល ឥរិយាបថ និងអាកប្បកិរិយា ដែលត្រូវបានផ្សារភ្ជាប់ជាមួយនឹងគ្រួសារ សាលារៀន និងសហគមន៍ ដែលអាចរួមចំណែកដល់កត្តាបុគ្គលទាំងនោះ។ ការការ ពារនៃការបោះបង់ការសិក្សាជាច្រើនដែលគាំទ្រការបន្តយុទ្ធសាស្ត្រ បន្ថែមធនធាន និងជំនួយ ដើម្បីជួយពួកគេស្នាក់នៅសាលា។ ជម្រើសយុទ្ធសាស្ត្រអន្តរាគមន៍ អាចផ្តោតលើការព្យាយាមកែលម្អបរិបទផ្លូវចិត្ត ជុំវិញនៃការបោះបង់ការសិក្សា ដែលមានសក្តានុពលផ្តល់ធនធាន និងការគាំទ្រ ដើម្បីពង្រឹង ឬរៀបចំរចនាសម្ព័ន្ធគ្រួសារ សាលារៀន និងសហគមន៍របស់ពួកគេ។ យុទ្ធសាស្ត្រជាប្រព័ន្ធបែបនេះ ច្រើនតែជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងធំជាងមុន ដើម្បីកែលម្អការអប់រំ និងលទ្ធផលសង្គមរបស់សិស្ស ដែលមានហានិភ័យកាន់តែច្រើនជាទូទៅ។

ទី២ ព្រោះការបោះបង់ចោល គឺជាប់ពាក់ព័ន្ធជាមួយនឹងបញ្ហាសិក្សា និងសង្គម យុទ្ធសាស្ត្របង្ការប្រកបដោយប្រសិទ្ធភាព ត្រូវតែផ្តោតលើបញ្ហាទាំងពីរ។ នោះគឺប្រសិនបើយុទ្ធសាស្ត្របង្ការការបោះបង់នឹងមានប្រសិទ្ធភាព ពួកគេត្រូវតែយល់ច្បាស់ដោយផ្តល់ធនធាន និងការគាំទ្រគ្រប់វិស័យនៃជីវិតរបស់សិស្ស។ព្រោះតែការបោះបង់ការសិក្សាពីសាលារៀនសម្រាប់ហេតុផលផ្សេងៗ

គ្នា សេវាកម្ម ត្រូវបានផ្តល់ជូនពួកគេ ត្រូវតែមានភាពបត់បែន និងសម្របតាមតម្រូវការផ្ទាល់ខ្លួនរបស់ពួកគេ។

ទី៣ ដោយសារបញ្ហាឥរិយាបថ និងអាកប្បកិរិយារបស់សិស្ស ដែលមានហានិភ័យនៃការបោះ បង់ការសិក្សា លេចឡើងនៅបឋមសិក្សា យុទ្ធសាស្ត្រការពារការបោះបង់ការសិក្សា អាចនិងគួរតែចាប់ផ្តើមដំបូង នៅក្នុងអាជីពអប់រំរបស់កុមារ។ កម្មវិធីទប់ស្កាត់ការបោះបង់ការសិក្សា ជារឿយៗ ផ្តោតលើសិស្សវិទ្យាល័យ ឬមធ្យមសិក្សា ដែលអាចជួបប្រទះការបរាជ័យផ្នែកអប់រំជាច្រើនឆ្នាំ ឬបញ្ហាដែលមិនអាចដោះស្រាយបាន។ កម្មវិធីស្តារការបោះបង់ការសិក្សា ក៏ត្រូវតែព្យាយាមជម្នះបញ្ហា ដែលមានរយៈពេលយូរផងដែរ ដើម្បីទទួលបានអ្នកបោះបង់ការសិក្សា ដើម្បីមកបញ្ចប់ការសិក្សា។ ប៉ុន្តែ កម្មវិធីបែបនេះ អាចមានតម្លៃថ្លៃ និងគ្មានប្រសិទ្ធភាព។ ផ្ទុយទៅវិញ អន្តរាគមន៍ដំបូង អាចជាវិធីសាស្ត្រដ៏មានឥទ្ធិពល និងមានប្រសិទ្ធភាពបំផុតក្នុងការទប់ស្កាត់ការបោះបង់ការសិក្សា។

ផលប្រយោជន៍យូរអង្វែង នៅក្នុងបញ្ហានៃការបោះបង់ការសិក្សា បានជំរុញឱ្យមានការខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងការអភិវឌ្ឍកម្មវិធី និងយុទ្ធសាស្ត្រ ធ្វើឱ្យប្រសើរឡើងនូវអត្រាបោះ បង់ការសិក្សា និងអត្រាបញ្ចប់ការសិក្សា។ ពួកគេ អាចត្រូវបានដាក់ជាក្រុមជាបីវិធីសាស្ត្រមូលដ្ឋានៈ គោលដៅការយល់ដឹង និងប្រព័ន្ធ។

**-គោលវិធីដែលមានគោលដៅ** (Targeted Approaches)

គោលវិធីសាមញ្ញបំផុត សម្រាប់កែលម្អការបោះបង់ការសិក្សា និងអត្រាបញ្ចប់ការសិក្សា គឺអភិវឌ្ឍកម្មវិធីពិសេស ផ្តោតលើសិស្ស ដែលមានហានិភ័យច្រើនបំផុត។ មានគោលវិធី២ ដែលបានកំណត់គោលដៅៈ

.ទីមួយ ផ្តល់សេវាកម្មបន្ថែមដល់សិស្សក្នុងកម្មវិធីសាលា ដែលមានស្រាប់។

.ទីពីរ ផ្តល់កម្មវិធីសាលាពិសេស នៅក្នុងសាលាដែលមានស្រាប់ ឬនៅក្នុងកន្លែងដាច់ដោយឡែកមួយ(ជម្រើសសាលា)។

គ្មានគោលវិធីណាមួយ ព្យាយាមផ្លាស់ប្តូរស្ថាប័ន ដែលមានស្រាប់ បម្រើសិស្សភាគច្រើនទេ ផ្ទុយទៅវិញ គោលវិធីបង្កើតបន្ថែម ឬកម្មវិធីជំនួស ដែលកំណត់គោលដៅសិស្ស ដែលត្រូវបានគេកំណត់ថា មានហានិភ័យបោះបង់ចោល ឬអ្នកដែលបានបោះបង់ការសិក្សារួចហើយ។

**- វិធីសាស្ត្រទូលំទូលាយ** (Comprehensive Approaches)

គោលវិធីទីពីរក្នុងការទប់ស្កាត់ការបោះបង់ការសិក្សា តាមរយៈកំណែទម្រង់ទូលំទូលាយ ឬទូទាំងសាលា។ គោលវិធីនេះ គឺផ្អែកលើជំនឿថា កម្មវិធីគោលដៅ មិនគ្រប់គ្រាន់ ដើម្បីកែលម្អអត្រាបោះបង់ការសិក្សា ឬ

បញ្ចប់ការសិក្សា ដោយសារគេមិនយល់គ្រប់គ្រាន់ ឬដោយសារតែពួកគេ មិនបានជួយសិស្សឱ្យបានគ្រប់គ្រាន់។ គោលវិធីកំណែទម្រង់សាលារៀន ពាក់ព័ន្ធនឹងការបង្កើតសំណុំការអនុវត្តទូលំទូលាយ និងកម្មវិធីនៅក្នុងមូលដ្ឋាន ឬដោយការទទួលយកគំរូកំណែទម្រង់សាលារៀនដ៏ទូលំទូលាយ ដែលបានអភិវឌ្ឍពីខាងក្រៅ។

## - គោលវិធីជាប្រព័ន្ធ

(Systemic Approaches)

គោលវិធីជាប្រព័ន្ធ ពាក់ព័ន្ធនឹងការធ្វើការផ្លាស់ប្តូរប្រព័ន្ធអប់រំទាំងមូល ក្រោមការសន្មតថា ការផ្លាស់ប្តូរបែបនេះ អាចផ្លាស់ប្តូររបៀប ដែលសាលារៀនទាំងអស់ មានមុខងារនៅក្នុងប្រ ព័ន្ធ អ្វីដែលអ្នកប្រាជ្ញខ្លះបានហៅថា "កំណែទ ម្រង់ប្រព័ន្ធសាលា"។ កំណែទម្រង់ប្រព័ន្ធ អាចកើតឡើងនៅថ្នាក់មូលដ្ឋាន ឬរដ្ឋាភិបាល។ ទោះ បីជាកំណែទម្រង់ប្រព័ន្ធទាំងអស់ អាចប៉ះពាល់ដល់អត្រាបោះបង់ការសិក្សា និងបញ្ចប់ការសិ ក្សា ដោយការកែលម្អសមត្ថភាពសាលានោះ កំណែទម្រង់ជាក់លាក់ចំនួនបី គឺភ្ជាប់ដោយផ្ទាល់ទៅនឹងការបោះបង់ការសិក្សា និងការបញ្ចប់ការសិក្សា អត្រា។

.មួយ គឺត្រូវបង្កើនអាយុសិក្សាជាកាតព្វកិច្ច ដែលសិស្សត្រូវតែចូលរៀនដល់អាយុ១៨ឆ្នាំដែលជាមធ្យោបាយមួយ ដើម្បីបង្ខំសិស្សឱ្យបន្តនៅសាលាបន្ថែមទៀត។

.មួយទៀត ផ្លាស់ប្តូរតម្រូវការការបញ្ចប់ថ្នាក់វិទ្យាល័យ ទាំងបរិមាណ និងវគ្គសិក្សាជាក់លាក់ ដែលសិស្សត្រូវតែឆ្លងកាត់ផ្តល់សញ្ញាប័ត្រ ក៏ដូចជាបញ្ជាក់ថា តើសិស្សត្រូវឆ្លងកាត់ការប្រ ឡងបញ្ចប់នៅវិទ្យាល័យដូចម្តេច ដើម្បីទទួលបានសញ្ញាបត្រ។

.កំណែទម្រង់ទីបី គឺបង្កើតផ្លូវជំនួស ឬ ជម្រើស សម្រាប់បញ្ចប់ការសិក្សានៅវិទ្យាល័យ និងទទួលបានសញ្ញាបត្រ។

ដោយផ្អែកលើការពិនិត្យឡើងវិញនៃអន្តរាគមន៍ការបោះបង់ការសិក្សាជាង៣០ ជា មួយនឹងការគាំទ្រការស្រាវជ្រាវយ៉ាងម៉ត់ចត់ ក្រុមប្រឹក្សាអ្នកជំនាញបានកំណត់នូវអនុសាសន៍ចំ នួន៤សម្រាប់ កាត់បន្ថយអត្រាបោះបង់ការសិក្សា និងការកែលម្អអត្រាបញ្ចប់ការសិក្សានៅសាលាមធ្យម និងវិទ្យាល័យ៖

.តាមដានវឌ្ឍនភាពរបស់សិស្សទាំងអស់ និងអន្តរាគមន៍យ៉ាងសកម្ម នៅពេលសិស្សបង្ហាញសញ្ញាដំបូងនៃបញ្ហាការចូលរៀន អាកប្បកិរិយា ឬការសិក្សា។

.ផ្តល់ការគាំទ្រជាលក្ខណៈបុគ្គលដល់សិស្សដែលបានប្រឡងធ្លាក់ និងប្រឈមសំខាន់ៗ ចំពោះភាពជោគជ័យ។

.ឱ្យសិស្សដោយការផ្តល់ជូននូវកម្មវិធីសិក្សា និងកម្មវិធី ដែលភ្ជាប់កិច្ចការសាលាជា មួយមហាវិទ្យាល័យ និងជោគជ័យក្នុងអាជីព និងកែលម្អសមត្ថភាពរបស់សិស្សក្នុង

ការគ្រប់គ្រងបញ្ហាប្រឈមនៅក្នុងនិងចេញពីសាលា។

.សម្រាប់សាលារៀន ដែលសិស្សមានហានិភ័យច្រើន សូមបង្កើតសហគមន៍តូចតាចផ្ទាល់ខ្លួន ដើម្បីជួយសម្រួលការត្រួតពិនិត្យ និងការគាំទ្រ។

ខណៈពេលដែលកម្មវិធីបង្ការការបោះ បង់ការសិក្សាភាគច្រើន ផ្ដោតលើអនុវិទ្យាល័យ និងវិទ្យាល័យ ការស្រាវជ្រាវ បានរកឃើញផងដែរនូវអន្តរាគមន៍ ដែលផ្ដោតលើការកែលម្អការសមត្ថភាពរបស់សិស្សនៅសាលាបឋមសិក្សា និងសូម្បីតែសាលាមត្តេយ្យ ក៏អាចប្រសើរឡើងនូវអត្រាបោះបង់ការសិក្សា និងបញ្ចប់ការសិក្សា។ អន្តរាគមន៍ដំបូងមួយបែបនេះ គឺនៅមត្តេយ្យ។ មិនត្រឹមតែមានការកើនឡើង នៃភស្តុតាងបានរកឃើញថា សាលាមត្តេយ្យ ដែលមានគុណភាពខ្ពស់អាចធ្វើឱ្យប្រសើរឡើងនូវការត្រៀមខ្លួនរបស់សាលា និងជោគជ័យនៅសាលាបឋមសិក្សា ប៉ុន្តែ ការសិក្សាតាមដានរយៈពេលវែង បានរកឃើញថា មត្តេយ្យក៏អាចធ្វើឱ្យប្រសើរនូវលទ្ធផលសិក្សាមនុស្សវ័យជំទង់ និងមនុស្សពេញវ័យ រួមទាំងការបញ្ចប់ការសិក្សានៅវិទ្យាល័យ (McCoy et al., 2017)។

ការស្រាវជ្រាវ មិនគ្រាន់តែរកឃើញថា បរិមាណអន្តរាគមន៍ អាចកាត់បន្ថយអត្រាបោះ បង់ការសិក្សា និងធ្វើឱ្យប្រសើរនូវអត្រាបញ្ចប់ការសិក្សា ប៉ុន្តែ យ៉ាងហោចណាស់ ពួកគេខ្លះ ផ្តល់ផលប្រយោជន៍សេដ្ឋកិច្ចលើសពីការចំណាយរបស់ពួកគេ។ ការសិក្សាថ្មីៗនេះបានប្រៀបធៀបការចំណាយ និងអត្ថប្រយោជន៍នៃអន្តរាគមន៍ចំ នួនប្រាំនោះ ដែលត្រូវបានគេបង្ហាញថាមានប្រសិទ្ធភាពក្នុងការលើកកម្ពស់អត្រាបញ្ចប់ការសិក្សានៅវិទ្យាល័យ ហើយបានរកឃើញថា ពួកគេទាំងអស់ សុទ្ធតែមានអត្ថប្រយោជន៍ លើសពីចំណាយរបស់ពួកគេ (Belfield & Levin, 2007)។

## សេចក្ដីសន្និដ្ឋាន

ការសង្កត់ធ្ងន់លើបញ្ហាបោះបង់ការសិក្សា នៅសហរដ្ឋអាម៉េរិក នឹងទាមទារទាំងសមត្ថភាព ទាំងឆន្ទៈ។ សមត្ថភាព ទាមទារជំនាញបច្ចេកទេស ដើម្បីអភិវឌ្ឍ និងអនុវត្តកម្មវិធីបង្ការ និងស្ដារការបោះបង់ការសិក្សាប្រកបដោយប្រ សិទ្ធភាព ព្រមទាំងកម្មវិធីជាច្រើនទៀត ព្រមទាំងកំណែទម្រង់សាលារៀនជាប្រព័ន្ធប្រកបដោយមហិច្ឆតា។ ខណៈពេលដែលមួយចំនួនសាលារៀន មានសមត្ថភាពបែបនេះ ភាគច្រើនត្រូវការធន ធានបន្ថែមជំនាញបច្ចេកទេស និងការលើកទឹកចិត្តក្នុងការរៀបចំរចនាសម្ព័ន្ធសាលា ដែលមានស្រាប់ឡើងវិញ។ ការអភិវឌ្ឍសមត្ថភាពបែបនេះ នឹងតម្រូវឱ្យមានឆន្ទៈនយោបាយ។ ប៉ុន្តែ ទោះបី ជាមានឆន្ទៈក្នុងការកែទម្រង់សាលារៀនក៏ដោយ វាមិនទំនងដែលថា សហរដ្ឋ

អាម៉េរិកនឹងលុបបំ បាត់ភាពខុសគ្នានៃអត្រា បោះបង់ការសិក្សាក្នុងចំណោមជាតិសាសន៍ និងក្រុមជនជាតិភាគតិច ដោយមិនលុប បំបាត់ភាពខុសគ្នា នៃធនធានគ្រួសារ សាលារៀន និងសហគមន៍។

# ឯកសារយោង

Almond, M. (2017). *Paper thin? Why all high school diplomas are not created equal.* Washington, D.C.: Alliance for Excellent Education.

Belfield, C., & Levin, H. M. (Eds.). (2007). *The price we pay: Economic and social consequences of inadequate education. Washington,* D.C.: Brookings Institution Press.

Berktold, J., Geis, S., & Kaufman, P. (1998). *Subsequent educational attainment of high school dropouts.* Washington, D.C.: U.S. Department of Education.

Day, J. C., & Newburger, E. C. (2002). *The big payoff: Educational attainment and synthetic estimates of work-life earnings.* Washington, D.C.: U.S. Census Bureau.

McCoy, D. C., Yoshikawa, H., Ziol-Guest, K. M., Duncan, G. J., Schindler, H. S., Magnuson, K., et al. (2017). *Impacts of early childhood education on mediumand long-term educational outcomes.* Educational Researcher, 46(8), 474e487. https://doi.org/10.3102/ 0013189X17737739.

National Research Council, Panel on High-Risk Youth. (1993). *Losing generations: Adolescents in high-risk settings.* Washington, D.C.: National Academies Press.

Organization for Economic Co-operation and Development (OECD). (2018). *Education at a glance:* OECD indicators 2018. Paris: OECD. https://doi.org/10.1787/eag-2018- en.

Rotermund, S. (2007). *Why students drop out of high school: Comparisons from three national surveys.* Santa Barbara: California Dropout Research Project, University.

U.S. Department of Education, Institute of Education Sciences. (2019). *What works clearinghouse.* Retrieved from: http://ies.ed.gov/ncee/wwc/

# សេដ្ឋកិច្ចវិទ្យានៃការបោះបង់ការសិក្សានៅមធ្យមសិក្សា

*ដោយៈ* **បណ្ឌិត សូ សុធីរ**

*មន្ត្រីស្រាវជ្រាវនាយកដ្ឋានវិទ្យាសាស្ត្រអប់រំ*

*នៃវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*

*រាជបណ្ឌិត្យសភាកម្ពុជា*

## ១-សេចក្តីផ្តើម

### សេដ្ឋកិច្ចវិទ្យា

*លោកសាស្ត្រាចារ្យ សាមុយអែលសាន់ ជាសេដ្ឋវិទូអាមេរិក បានឱ្យនិយមន័យថាៈ*

*"សេដ្ឋកិច្ចវិទ្យា ជាការសិក្សា អំពីវិធីដែលមនុស្ស និងសង្គមជ្រើសរើស ដោយប្រើ ឬមិនប្រើលុយកាក់ដើម្បីប្រើប្រាស់ធនធានផលិតផលកម្រ ទៅផលិតទំនិញផ្សេងៗក្នុងពេលមួយ ហើយចែកចាយទំនិញទាំងនោះ សម្រាប់យកទៅប្រើប្រាស់ក្នុងចំណោមមនុស្ស និងក្រុមមនុស្សផ្សេងគ្នាក្នុងសង្គម នៅពេលបច្ចុប្បន្ន និងអនាគត"។*

### ការបោះបង់ការសិក្សា

*តាមយូណេស្កូ ‹‹ការបោះបង់ការសិក្សា ជាការចាកចេញពីសាលា ការឈប់ចូលរៀន ការផ្លាស់ទៅសាលាផ្សេង ឬការស្លាប់។ ម្យ៉ាងទៀត និយាយយ៉ាងខ្លី គឺសិស្សដែលឈប់រៀន មុនពេលបញ្ចប់វគ្គសិក្សារបស់ខ្លួន។*

*បញ្ហាប្រឈមផ្នែកអប់រំដ៏សំខាន់មួយក្នុងគ្រប់ប្រទេសកំពុងអភិវឌ្ឍ ដូចជាកម្ពុជា និងប្រទេសឧស្សាហកម្មទាំងអស់ កំពុងអះអាងថា សិស្សទាំងអស់ គួរតែបញ្ចប់វិទ្យាល័យ។ ទោះបីជាប្រទេសជាច្រើន អនុញ្ញាតឱ្យសិស្សបានឈប់រៀន មុនពេលបញ្ចប់មធ្យមសិក្សាទុតិយភូមិក៏ដោយ ក៏សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ចាត់ទុកថាជាតម្រូវការចាំបាច់បំផុត សម្រាប់ ការចូលទៅក្នុងទីផ្សារការងារ និងសម្រាប់ការអប់រំក្រោយមធ្យមសិក្សា។ ជាការពិត ជាមួយសេដ្ឋកិច្ច ដែលបង្កើនបរិមាណការងារ តម្រូវឱ្យមានយ៉ាងហោចណាស់ការសិក្សា ក្រោយមធ្យមសិក្សាមួយចំនួន។ សិស្សដែលមិនទទួលបានសញ្ញាបត្រវិទ្យាល័យ ទំនងជានឹងធ្វើឱ្យទស្សនវិស័យសេដ្ឋកិច្ចធ្លាក់ចុះ។*

*ទោះបីមានសារៈសំខាន់កាន់តែខ្លាំងឡើង នៃការបញ្ចប់វិទ្យាល័យក៏ដោយ ក៏ផ្នែកដ៏ធំមួយនៃចំនួននិស្សិត ក្នុងប្រទេសជាច្រើន ឈប់*

ឈប់រៀននៅវិទ្យាល័យ មុនពេលបញ្ចប់ការសិក្សា។ អត្ថបទនេះ ផ្តល់នូវការពិនិត្យឡើងវិញនូវសង្ខេបនៃការស្រាវជ្រាវអំពីអ្នកការបោះបង់ការសិក្សានៅវិទ្យាល័យ ផលវិបាកសេដ្ឋកិច្ច និងសង្គមនៃការបោះបង់ការសិក្សា មូលហេតុការចាកចេញ និងអ្វីដែលអាចធ្វើបានធ្វើឱ្យប្រសើរឡើងនូវអត្រាបញ្ចប់ការសិក្សា។

## ២-តើអ្នកណា បោះបង់ការសិក្សា នៅមធ្យមសិក្សា?

សូចនាករមួយចំនួន ត្រូវបានបង្ហាញដោយរដ្ឋាភិបាល និងអ្នកស្រាវជ្រាវ ដើម្បីបញ្ជាក់ឱ្យប្រាកដថា ចំនួន និងអត្រាសិស្សបោះបង់ការសិក្សា និងបញ្ចប់ការសិក្សា នៅមធ្យមសិក្សា។ សូចនាករ ខុសគ្នាទាក់ទងនឹង៖

- និយមន័យនៃការបោះបង់ការសិក្សា ឬបញ្ចប់ការសិក្សា ដែលត្រូវបានប្រើ រួមទាំងការវាស់វែង និងពេលវេលា កំណត់អត្តសញ្ញាណរយៈពេល។

- ចំនួនអ្នក ដែលត្រូវបានវាស់វែង។

- ប្រភពនៃទិន្នន័យ។

វិធានការមួយ គឺអត្រាបោះបង់ការសិក្សាប្រចាំឆ្នាំ ដែលវាស់សមាមាត្រសិស្ស ដែលឈប់រៀនជារៀងរាល់ឆ្នាំ។ អត្រាបោះបង់ការសិក្សាខ្ពស់ជាងសម្រាប់ក្រុមប្រជាសាស្ត្រមួយចំនួន៖

-សិស្សស្រីមានអត្រាបោះបង់ការសិក្សាខ្ពស់ ជាងបុរស។

-ជនជាតិជាតិដើមភាគតិចនិងជនជាតិភាគតិច

-សិស្សមកពីគ្រួសារ ដែលមានចំណូលទាប មានអត្រាបោះបង់ការសិក្សា ខ្ពស់ជាងសិស្សពីគ្រួ សារ ដែលមានប្រាក់ចំណូលខ្ពស់។

អត្រាបោះបង់ការសិក្សាប្រចាំឆ្នាំ នៅកម្ពុជា ជាទូទៅ បានធ្លាក់ចុះនាពេលប៉ុន្មានឆ្នាំថ្មីៗនេះ តែចំនួនសរុបនៃការបោះបង់ការសិក្សាប្រចាំឆ្នាំនៅតែខ្ពស់ដដែល។ អត្រាធ្ងន់ធ្ងរភូមិសិក្សាស ម្រាប់សាលាចំ ណោះទូទៅរបស់រដ្ឋ និងឯកជន មានកម្រិតថយចុះខុសគ្នាជាខ្លាំងពីមធ្យមសិក្សាបឋមភូមិទៅមធ្យមសិក្សាទុតិយភូមិ ។

ជាឧទាហរណ៍ក្នុងឆ្នាំសិក្សា២០២១-២០២២ តាមស្ថិតិ និងសូចនាករអប់រំគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន បានឱ្យដឹងថា៖

-សិស្សនៅមត្តេយ្យសិក្សា មានចំនួន ៣៣ ៧៥៦នាក់ (ស្រី១៦៤ ៥២២នាក់)

-សិស្សនៅបឋមសិក្សា មានចំនួន២ ១៦៧ ១៥២នាក់ (ស្រី១ ០៦៣ ០៥៩នាក់)

-សិស្សនៅមធ្យមសិក្សាបឋមភូមិ មានចំនួន៧០៣ ០០៥នាក់ (ស្រី៣៦៩ ៣៥១នាក់)

-សិស្សនៅមធ្យមសិក្សាទុតិយភូមិ មានចំនួន៣៨៥ ៧៧៨នាក់ (ស្រី២០៩ ៥០៨នាក់)

ចំនួនសិស្ស ដែលកំពុងសិក្សាខាងលើ នៅមធ្យមសិក្សាបឋមភូមិ និងនៅមធ្យមសិក្សាទុតិយភូមិ មានកម្រិតខុសគ្នាខ្លាំងណាស់ មានន័យថា សិស្សចំនួន៣១៧ ២២៧នាក់ (ស្រី១៥៩ ៨២៣នាក់) បានបោះ បង់ការសិក្សា មិនបានចូលរៀននៅមធ្យមសិក្សាទុតិយភូមិ ហើយសិស្សស្រីមានកំណើនជាងសិស្សប្រុស។

អត្រាបោះបង់ការសិក្សាប្រចាំឆ្នាំ បានបង្ហាញពីលទ្ធភាព ដែលសិស្សនឹងឈប់រៀន នៅក្នុងពេលណាមួយ នៅក្នុងអាជីពអប់រំរបស់គាត់។ រង្វាស់ល្អជាង គឺជាសមាមាត្រនៃការបោះបង់ការសិក្សា នៅក្នុងចំនួនប្រជាជន ដែលត្រូវបានគេហៅថា អត្រាបោះបង់ស្ថានភាព។ អត្រាទាំងនេះក៏មានខ្ពស់ជាង សម្រាប់ក្រុមប្រជាសាស្ត្រដូចគ្នាបានរៀបរាប់ខាងលើ។

ប៉ុន្តែ អត្រាបោះបង់ការសិក្សាតែម្យ៉ាងប្រហែលជាមិនគ្រប់គ្រាន់ ដើម្បីបង្ហាញពីវិសាលភាពនៃបញ្ហា។ ទិន្នន័យជំរឿន ត្រូវបានគេរិះគន់ ព្រោះពួកគេពឹងផ្អែកលើស្ថានភាពអប់រំ ដែលបានរាយការណ៍ដោយខ្លួនឯងរបស់អ្នកឆ្លើយសំណួរ ដែលអ្នកឆ្លើយតបហួសហេតុ ហើយវាអាចនឹងផ្លាស់ប្តូរនៅក្នុងពេលណាមួយ។

ដើម្បីផ្តល់ជាទស្សនវិស័យតាមខ្សែប ណ្តោយ ដែលយកការរីកចម្រើនរបស់សិស្សវិទ្យាល័យឆ្ពោះទៅរកការបញ្ចប់ការសិក្សា កំពុងព្យាយាមវាស់ស្ទង់សមាមាត្រនៃសិស្ស ដែលទទួលបានសញ្ញាបត្រទៀងទាត់ ត្រូវបានគេស្គាល់ថាជា អត្រាបញ្ចប់ការសិក្សា តាមក្រុមថ្នាក់ទីប្រាំបួន។ អត្រាបែបនេះ ពិបាកវាស់វែង ជាពិសេស ព្រោះវាទាមទារឱ្យមានការតាមដានសិស្សច្រើនឆ្នាំ។ នេះជាបញ្ហាមួយផ្នែក ដោយសារតែសិស្ស តែងតែផ្ទេរពីកន្លែងអប់រំមួយទៅកន្លែងមួយទៀត ក្នុងអំ ឡុងពេលនៅវិទ្យាល័យរបស់ពួកគេ។

## ៣- **តើមានផលវិបាកអ្វីខ្លះ?**

ការបោះបង់ការសិក្សា មានផលវិបាកផ្នែកសេដ្ឋកិច្ច និងសង្គម ទាំងអ្នកបោះបង់ការសិ ក្សាខ្លួនឯង និងសម្រាប់ប្រទេសទាំងមូល។

-អ្នកបោះបង់ការសិក្សា មានការលំបាកក្នុងការស្វែងរកការងារ។

-ទោះជាពួកគេស្វែងរកការងារធ្វើក៏ដោយ សិស្សដែលបោះបង់ការសិក្សា រកប្រាក់បានតិចជាងសិស្សបញ្ចប់ការសិក្សា នៅថ្នាក់ម ធ្យមសិក្សា។ ក្នុងជីវិតការងាររបស់ពួកគេ អ្នកបោះបង់ការសិក្សាតិចជាងសិស្សបញ្ចប់ការសិក្សានៅសាលា។

ហេតុផលមួយ សម្រាប់ការធ្លាក់ចុះសេដ្ឋកិច្ចក្រីក្ររបស់អ្នកបោះបង់ការសិក្សា គឺកម្រិតនៃការអប់រំទាបរបស់ពួកគេ។ ប៉ុន្តែ អ្នកបោះបង់ការសិក្សា អាចត្រឡប់ទៅសាលាវិញ។ យ៉ាងណាក៏ដោយ អ្នកបោះបង់ការសិក្សាដូចជា

ក្រុមមួយ ទំនងជាបានចុះឈ្មោះចូលរៀននៅក្រោយមធ្យមសិក្សា តិចជាងអ្នកបញ្ចប់មធ្យមសិក្សាទុតិយភូមិ ទោះបីជារដ្ឋាភិបាលអនុញ្ញាតឱ្យអ្នកបោះបង់ការសិក្សាចូលរៀន នៅមហាវិទ្យាល័យសហគមន៍ដោយគ្មានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិក៏ដោយ។

អ្នកបោះបង់ការសិក្សាជួបប្រទះលទ្ធផលអវិជ្ជមានផ្សេងទៀត។ អ្នកបោះបង់ការសិក្សាមានសុខភាពខ្សោយ និងអត្រាមរណភាពខ្ពស់ជាងនិស្សិតបញ្ចប់វិទ្យាល័យ។ ពួកគេទំនងជាមានអាកប្បកិរិយាព្រហ្មទណ្ឌ ហើយត្រូវជាប់គុកពេញមួយជីវិត បើប្រៀបធៀបទៅនឹងនិស្សិតបញ្ចប់ការសិក្សា។ ពួកគេក៏ទំនងជាត្រូវការជំនួយសាធារណៈ និងមិនសូវមានលទ្ធភាពបោះឆ្នោតដែរ។ ទោះបីជាទំនាក់ទំនង ដែលបានសង្កេតឃើញរវាងការបោះបង់ការសិក្សា និងលទ្ធផលសេដ្ឋកិច្ច និងសង្គមទាំងនេះ មិនចាំបាច់បញ្ជាក់ពីទំនាក់ទំនងបុព្វហេតុក៏ដោយ ជាក់ស្តែងភស្តុតាងស្រាវជ្រាវ ដែលកំពុងកើនឡើងបានបង្ហាញឱ្យឃើញមួយ។ នេះ បានបង្ហាញថា ការខិតខំប្រឹងប្រែងកាត់បន្ថយអត្រាបោះបង់ការសិក្សាតាមពិត នឹងកាត់បន្ថយលទ្ធផលសេដ្ឋកិច្ច និងសង្គមអវិជ្ជមានទាំងនេះ។

លទ្ធផលអវិជ្ជមានពីអ្នកបោះបង់ការសិក្សាបង្កើតការចំណាយសង្គមដ៏ធំ។ រដ្ឋាភិបាលប្រមូលពន្ធតិចជាងមុនពីអ្នកបោះបង់ការសិក្សា។ រដ្ឋាភិបាល ក៏ផ្តល់ប្រាក់ឧបត្ថម្ភដល់អ្នកដែលមានសុខភាពមិនល្អ សកម្មភាពឧក្រិដ្ឋកម្មធ្ងន់ធ្ងរ និងកើនឡើងជំនួយសាធារណៈនៃអ្នកបោះបង់ការសិក្សា។

និន្នាការសេដ្ឋកិច្ច ប្រជាសាស្ត្រ និងការអប់រំមួយចំនួន អាចធ្វើឱ្យបញ្ហាទាំងនេះ កាន់តែធ្ងន់ធ្ងរទៅៗនាពេលអនាគត។ ដោយសារតែសេ ដ្ឋកិច្ចកម្ពុជា ផ្តោះទៅរកកម្លាំងព លកម្មដែលមានជំនាញកាន់តែខ្ពស់នោះ អ្នកបោះបង់ការសិក្សា នឹងមានពេលវេលាកាន់តែពិបាកក្នុងការរស់រានមានជីវិតទាក់ទងនឹងសេដ្ឋកិច្ច។ ចំនួនសិស្សទូទៅ មានហានិភ័យខ្ពស់ ជាសិស្សបរាជ័យនៅសាលារៀន និងគ្រួសារមានចំណូលទាប។

## ៤-ហេតុអ្វីបានជាសិស្សឈប់រៀន?

ការស្វែងយល់ពីមូលហេតុដែលសិស្សបោះបង់ការសិក្សាពីសាលាជាគន្លឹះក្នុងការដោះស្រាយបញ្ហាអប់រំដ៏សំខាន់នេះ។ មកដល់ពេលនេះ ការកំណត់អត្តសញ្ញាណមូលហេតុនៃបោះបង់ការសិក្សា ពិបាកខ្លាំងណាស់។ ដូចទម្រង់នៃសមិទ្ធផលអប់រំផ្សេងទៀត មូលហេតុនៃការបោះបង់ការសិក្សា គឺបណ្តាលមកពីរបៀបនៃកត្តាជះឥទ្ធិពលផ្ទាល់ និងមិនផ្ទាល់ដល់សុខភាពពាក់ព័ន្ធទាំងសិស្សម្នាក់ៗ និងចំពោះសិស្ស

កំណត់គ្រួសារ សាលារៀន និងសហគមន៍ ដែលសិស្សរស់នៅ។

សិស្សបោះបង់ការសិក្សា បានរាយការណ៍ពីហេតុផលផ្សេងៗសម្រាប់ការឈប់រៀន រួមទាំងទាក់ទងនឹងសាលារៀនផង រួមបញ្ចូលហេតុផលទាក់ទងនឹងសាលារៀន ហេតុផលទាក់ទងនឹងគ្រួសារ និងហេតុផលទាក់ទងនឹងការសិក្សា។ ហេតុផលជាក់លាក់បំផុត ដែលបានលើកឡើងដោយសិស្ស ដែលបានបោះបង់ការសិក្សាត្រូវបាន «គេចពីសាលាច្រើនថ្ងៃពេក»។ ប៉ុន្តែ ហេតុផលទាំងនេះ មិនបង្ហាញមូលហេតុជាមូលដ្ឋាន ដែលនាំឱ្យសិស្សឈប់រៀន ជាពិសេស មូលហេតុ ឬកត្តាទាំងនោះ នៅក្នុងបឋមសិក្សា ឬអនុវិទ្យាល័យ ដែលអាចរួមចំណែកដល់ឥរិយាបថ អាកប្បកិរិយាសិស្ស និងស្នាដៃរបស់សាលា មុនការសម្រេចចិត្តចាកចេញរបស់ពួកគេពីសាលារៀន។ ជាងនេះទៅទៀត ប្រសិនបើកត្តាជាច្រើន រួមចំណែកដល់បាតុភូតនេះ ក្នុងរយៈពេលយូរនោះ វាស្ទើរតែមិនអាចទៅរួចទេ ក្នុងការបង្ហាញពីទំ នាក់ទំនងមូលហេតុរវាងកត្តាតែមួយ និងការស ម្រេចចិត្តឈប់រៀន។ ទោះបីមានការលំបាកនេះក៏ដោយ កត្តាពីរប្រភេទ ត្រូវបានគេកំណត់អត្តសញ្ញាណ ដែលរួមចំ ណែកដល់ ឬបង្កើនលទ្ធភាពដែលសិស្សបោះបង់ការសិក្សា៖

-កត្តាបុគ្គលដែលទាក់ទងនឹងលក្ខណៈឥរិយាបថ អាកប្បកិរិយា និងបទពិសោធរបស់សិស្ស។

-កត្តាបរិបទ ដែលទាក់ទងនឹងគ្រួសារ សាលារៀន សហគមន៍ និងមិត្តភ័ក្តិរបស់សិស្ស។

**កត្តាបុគ្គល**

កត្តាបុគ្គលផ្សេងៗគ្នា ត្រូវបានភ្ជាប់ជាមួយនឹងការបោះបង់ការសិក្សា រួមទាំងកត្តាប្រជាសាស្ត្រជាច្រើន។ ជាទូទៅ អត្រាការបោះបង់ការសិក្សាមានកម្រិតខ្ពស់ក្នុងចំណោមសិស្សជាងសិស្សប្រុស។ ឥរិយាបថ ក៏ប៉ះពាល់ដល់អត្រាបោះបង់ការសិក្សាផងដែរ។ អត្រាបោះបង់ការសិក្សា ក៏ខ្ពស់ជាងក្នុងចំណោមសិស្ស ដែលមានការអប់រំទាប និងជីវភាពទាប។ សកម្មភាព និងអាកប្បកិរិយាជាច្រើន ក៏ព្យាករអត្រាបោះបង់ការសិក្សា រួមទាំងអវត្តមាន អាកប្បកិរិយាមិនល្អនៅក្នុងសាលារៀន និងការមានផ្ទៃពោះ។ ទីបំផុតការសម្រេចបានការសិក្សាខ្សោយ គឺជាអ្នកព្យាករយ៉ាងខ្លាំងនៃបោះបង់ការសិក្សា។ ជារួមកត្តាទាំងនេះ គាំទ្រគំនិត ដែលថា ការបោះបង់ការសិក្សា ត្រូវបានជះឥទ្ធិពលដោយបទពិសោធសង្គម និងការសិក្សារបស់សិស្ស។

បន្ថែមពីលើកត្តាសុខភាពផ្ទាល់ ទាំងនេះ កត្តាមិនផ្ទាល់មួយចំនួន ត្រូវបានភ្ជាប់ជាមួយនឹងការបោះបង់ការសិក្សា ដូចជាចល័តភាពសិស្ស។ ទាំងការចល័តលំនៅដ្ឋាន (ផ្លាស់ប្តូរ

ទីលំនៅ) និងការចល័តសាលារៀន (ការផ្លាស់ប្តូរសាលារៀន) បង្កើនហានិភ័យនៃការបោះបង់ការសិក្សានៅវិទ្យាល័យ។ ការចល័តរបស់សិស្សអាចតំណាងឱ្យភាពមិនសូវធ្ងន់ធ្ងរជាងទម្រង់នៃការមិនចូលរៀនរបស់សិស្សនៅសាលា។ កត្តាមិនផ្ទាល់មួយទៀត គឺការចូលរៀននៅក្នុងថ្នាក់។ ទោះបីជាចូលរៀននៅក្នុងថ្នាក់ អាចមានឥទ្ធិពលវិជ្ជមានលើសមិទ្ធផលសិក្សាក្នុងរយៈពេលខ្លីក៏ដោយ ការសិក្សាជាច្រើន បានរកឃើញថា វាបង្កើនលទ្ធភាពយ៉ាងខ្លាំងនូវភាពទំនង ដែលថាសិស្សនឹងបោះបង់ការសិក្សាពីសាលា។ ទីបំផុតការសិក្សាចំនួនក្នុងរយៈពេលវែងបានរកឃើញថា កង្វះការសិក្សាសមិទ្ធផលដំបូង និងការចូលរួម (ឧ. វត្តមាន អាកប្បកិរិយាមិនល្អ) នៅសាលាបឋមសិក្សា និងមធ្យមបឋមភូមិ ព្យាករពីការដកខ្លួនចេញពីវិទ្យាល័យ។

**កត្តាស្ថាប័ន**

ខណៈពេលដែលកត្តាបុគ្គល បានរួមចំណែកយ៉ាងច្បាស់ ដល់ការសម្រេចចិត្តរបស់សិស្សក្នុងការបោះបង់ការសិក្សា ឥរិយាបថ និងអាកប្បកិរិយារបស់បុគ្គលម្នាក់ៗ ត្រូវបានបង្កើតឡើងដោយការកំណត់ ឬបរិបទផ្សេងៗ ដែលសិស្សបានរស់នៅក្នុងគ្រួសារ សាលារៀន សហគមន៍ និងក្រុមមិត្តភ័ក្តិ។ សារៈសំខាន់នៃបរិបទក្នុងការផ្លាស់ប្តូរឥរិយាបថ រួមទាំងការបោះបង់ការសិក្សា ត្រូវបានគេទទួលស្គាល់ថាការសង្កត់ធ្ងន់ខ្លាំងពេក លើយុវជន "ដែលមានហានិភ័យខ្ពស់" និងក្រុមគ្រួសាររបស់ពួកគេ និងមិនគ្រប់គ្រាន់ទេ លើការកំណត់ហានិភ័យខ្ពស់ដែលពួកគេរស់នៅ និងទៅសាលារៀន។ កត្តាមួយចំនួននៅក្នុងគ្រួសារ សាលារៀន និងសហគមន៍របស់សិស្ស (និងទំនាក់ទំនងមិត្តភ័ក្តិ) កំណត់ទុកជាមុន អំពីការបោះបង់ការសិក្សា។

**គ្រួសារ**

ប្រវត្តិគ្រួសារ ត្រូវបានគេទទួលស្គាល់យ៉ាងទូលំទូលាយថា ជាអ្នករួមចំណែកដ៏សំខាន់បំផុតតែមួយគត់ ចំពោះភាពជោគជ័យក្នុងសាលា។ ជាទូទៅ ស្ថានភាពសេដ្ឋកិច្ចសង្គម ត្រូវបានវាស់វែងសាមញ្ញបំផុតដោយការអប់រំឪពុកម្តាយ និងប្រាក់ចំណូលគ្រួសារ ជាអ្នកទស្សន៍ទាយដ៏មានឥទ្ធិពលនៃសមិទ្ធផលសាលា និងឥរិយាបថបោះបង់ការសិក្សា។ ការអប់រំមាតាបិតា មានឥទ្ធិពលលើសេចក្តីប្រាថ្នារបស់សិស្ស និងការគាំទ្រផ្នែកអប់រំ។ ខណៈពេលដែលប្រាក់ចំណូលគ្រួ សារ អនុញ្ញាតឱ្យឪពុកម្តាយ ផ្តល់ធនធានបន្ថែមទៀត ដើម្បីគាំទ្រដល់ការអប់រំរបស់កូនរបស់ពួកគេ រួមទាំងលទ្ធភាពទទួលបានសាលារៀន ដែលមានគុណភាពល្អជាង និងការគាំទ្របន្ថែមទៀតសម្រាប់ការរៀននៅក្នុងផ្ទះ។ លើសពីនេះទៀត សិស្សដែលមានឪពុកម្តាយត្រួតពិនិត្យ និងគ្រប់ គ្រងសកម្មភាពរបស់ពួកគេបានផ្តល់ការគាំទ្រអារម្មណ៍ លើកទឹកចិត្ត

ដល់ការសម្រេចចិត្តដោយឯករាជ្យ (ត្រូវគេស្គាល់ថាជាឪពុកម្ដាយ ដែលផ្ដល់សិទ្ធិអំណាចដល់កូន) ហើយជាទូទៅ ត្រូវបានចូលរួមកាន់តែច្រើននៅក្នុងការសិក្សារបស់ពួកគេ ទំនងជាមិនសូវបោះបង់ការសិក្សាទេ។ លើសពីនេះ សិស្សដែលមានតែឪពុក ឬម្ដាយ គ្រួសារមានឪពុក ឬម្ដាយចុង ទំនងជាបោះបង់ចោលសាលារៀនជាងសិស្សក្នុងគ្រួសារ ដែលមានឪពុកម្ដាយទាំងពីរនាក់។

**សាលារៀន**

គេបានទទួលស្គាល់យ៉ាងទូលំទូលាយថា សាលារៀន មានឥទ្ធិពលយ៉ាងខ្លាំងលើសមិទ្ធផលរបស់សិស្ស រួមទាំងអត្រាបោះបង់ការសិក្សា។ សាលាបួនប្រភេទ មានឥទ្ធិពលលើការអនុវត្តរបស់សិស្ស៖ សមាសភាពសង្គមនៃសាលារៀន លក្ខណៈពិសេសខាងរចនាសម្ព័ន្ធ ធនធានសាលា និងគោលនយោបាយសាលារៀន។

-សមាសភាពសង្គមនៃសាលារៀន ដែលជាលក្ខណៈរបស់សិស្ស ចូលរៀននៅសាលារៀន ជាពិសេស សមាសភាពសេដ្ឋកិច្ចសង្គមរបស់រាងកាយសិស្ស ព្យាករការបោះបង់ការសិក្សា សូម្បីបន្ទាប់ពីការគ្រប់គ្រងកត្តាបុគ្គលដែល មានឥទ្ធិពលលើការបោះបង់ការសិក្សាក៏ដោយ។

-លក្ខណៈទីពីរ ទាក់ទងនឹងលក្ខណៈរចនាសម្ព័ន្ធនៃសាលារៀន ដូចជាទំហំ ទីតាំង និងការគ្រប់គ្រងសាលា (សាធារណៈទល់នឹងឯកជន)។ អត្រាបោះបង់ការសិក្សាពីសាលាកាតូលិក និងសាលាឯកជនផ្សេងទៀត ទាបជាងការបោះបង់ការសិក្សាពីសាលារដ្ឋ សូម្បីតែបន្ទាប់ពីការគ្រប់គ្រងភាពខុសគ្នា នៅក្នុងប្រវត្តិលក្ខណៈពិសេសរបស់សិស្ស។ មកដល់ពេលនេះ សិស្សមកពីសាលាឯកជន ជាធម្មតាផ្ទេរទៅសាធារណៈសាលារៀនជំនួសឱ្យ ឬមុនពេលបោះបង់ការសិក្សា ដើម្បីអត្រានៃការផ្លាស់ប្ដូរសិស្សនៅក្នុងសា លាឯកជន ខុសគ្នាខាងស្ថិតិជាងអត្រាក្នុងសាលារដ្ឋ។ សាលារៀនតូចៗ មានអត្រាបោះបង់ការសិក្សាទាបជាង។ អ្វីដែលមិនសូវច្បាស់ គឺថាតើលក្ខណៈរចនាសម្ព័ន្ធខ្លួនឯង ពន្យល់ភាពខុសគ្នាទាំងនេះ ឬថា តើពួកគេ ទាក់ទងនឹងភាពខុសគ្នានៃលក្ខណៈសិស្ស និងធនធានសាលា ជាញឹកញាប់ ទាក់ទងនឹងលក្ខណៈពិសេសនៃរចនាសម្ព័ន្ធសាលារៀន។

-ប្រភេទទីបីនៃលក្ខណៈពិសេស ទាក់ទងនឹងធនធានសាលា។ ធនធាន ជាពិសេសសមាមាត្រសិស្ស/គ្រូ និងគុណភាពគ្រូបង្រៀន ហាក់ដូចជាមានឥទ្ធិពលលើអត្រាបោះបង់ការសិក្សា បន្ទាប់ពីការគ្រប់ គ្រងបុគ្គល និងកត្តាបរិបទដែលអាចមានឥទ្ធិពលផងដែរ ដល់អត្រាបោះបង់ការសិក្សា។

-ប្រភេទចុងក្រោយ ទាក់ទងនឹងគោលនយោបាយសាលា និងការអនុវត្ត។ ជាពិសេស

បរិយាកាសការសិក្សា និងសង្គម ត្រូវបានវាស់វែងដោយសាលាអត្រាចូលរៀននៅសាលា សិស្សដែលទទួលបានវគ្គសិក្សាជាន់ខ្ពស់ និងប្រ ត្យក្សារម្មណ៍របស់សិស្សអំពីពិព័រណ៍មួយនៃគោលន យោបាយវិន័យត្រឹមត្រូវ ព្យាករពីការបោះបង់ការសិក្សា សូម្បីតែបន្ទាប់ពីការគ្រប់គ្រងលក្ខណៈប្រវត្តិរបស់សិស្ស ព្រមទាំងធនធាន និងលក្ខណៈពិសេសរចនាសម្ព័ន្ធនៃសាលារៀន។

កត្តាសាលា រួមចំណែកដល់ការបោះបង់ការសិក្សារបស់សិស្សតាមពីរវិធី។ វិធីមួយ គឺដោយប្រយោល តាមការបង្កើតលក្ខខណ្ឌ ដែលមានឥទ្ធិពលលើសិស្សការចូលរួម និងការបោះបង់ការសិក្សាដោយស្ម័គ្រចិត្តរបស់ពួកគេពីសាលា។ វិធីមួយទៀត គឺដោយផ្ទាល់ តាមរយៈគោលនយោបាយច្បាស់លាស់ និងការសម្រេចចិត្តតាមមនសិការ តាមបុគ្គលិកសាលា ដែលបណ្តាលឱ្យសិស្សបោះបង់ការសិក្សា ពីសាលាដោយអចេតនា។ ច្បាប់ទាំងនេះ និងសកម្មភាពអាចទាក់ទងនឹងកម្រិតពិន្ទុទាប ការចូលរៀនមិនល្អ អាកប្បកិរិយាមិនសមរម្យ (ដូចជាគោលការណ៍មិនអត់ឱន) ឬអាយុលើស ហើយអាចនាំឱ្យមានការព្យួរការសិក្សា ការបណ្តេញចេញ ឬការផ្ទេរដោយបង្ខំ។ ទម្រង់នៃការបោះ បង់ការសិក្សានេះ ផ្ញើឡើងដោយសាលា និងផ្ទុយពីទម្រង់ដែលផ្តួចផ្តើមដោយសិស្សបានរៀបរាប់ខាងលើ។ ឧទាហរណ៍ សាលាមួយចំនួន បានរួមចំណែកដល់ការបោះ បង់ការសិក្សា ដោយមិនស្ម័គ្រចិត្តរបស់សិស្សចេញពីសាលា ដោយមិនរាប់បញ្ចូល និងបណ្តេញចេញជាប្រព័ន្ធនូវ"អ្នកបង្កបញ្ហា" និងសិស្សដែលមានបញ្ហាផ្សេងទៀត។

**សហគមន៍ និងមិត្តរួមការងារ**

បន្ថែមពីលើគ្រួសារ និងសាលារៀន សហគមន៍ និងក្រុមមិត្តភ័ក្តិ អាចមានឥទ្ធិពលលើសិស្សការបោះបង់ការសិក្សាពីសាលារៀន។ ភាពខុសប្លែកគ្នានៃលក្ខណៈសហគមន៍ អាចជួយព ន្យល់ពីភាពខុសគ្នានៃអត្រាបោះបង់ការសិក្សាក្នុងចំណោមសហគមន៍ ក្រៅពីឥទ្ធិពលគ្រួសារ។ កស្តុតាងខ្លះ បង្ហាញថា មានកម្រិតកំណត់ លើគុណភាពនៃអ្នកជិតខាង ដែលនាំឱ្យអត្រាបោះ បង់ការសិក្សាខ្ពស់ នៅក្នុងសង្កាត់ដែលជួបការលំបាកបំផុត។ សហគមន៍ក្រីក្រ អាចមានឥទ្ធិពលលើកុមារ និងការវិវត្តរបស់ក្មេងជំទង់ តាមរយៈកង្វះធនធាន (សួនកុមារ បន្ទាប់ពីចូលរៀនកម្មវិធី) ឬឥទ្ធិពលអវិជ្ជមានរបស់មិត្តភ័ក្តិ។ អ្នករស់ក្នុងស ហគមន៍ ក៏អាចជះឥទ្ធិពលលើការប្រតិបត្តិរបស់មាតាបិតា ហួសពីការអប់រំ និងប្រាក់ចំណូលរបស់មាតាបិតាផងដែរ។ សិស្សដែលរស់នៅក្នុងសហគមន៍ក្រីក្រ ទំនងជាបោះបង់ការសិក្សាច្រើនជាងមិត្តភ័ក្តិខ្លួន។ វិធីមួយទៀត ដែលសហគមន៍ អាចជះឥទ្ធិពលលើអត្រាបោះបង់ការសិក្សា តាមរយៈការផ្តល់ឱកាសការងារទាំងអំឡុងពេល ឬក្រោយពេល

សិក្សា។ ឱកាសការងារអំណោយផល សម្រាប់ការបោះបង់ការសិក្សានៅវិទ្យាល័យ ដូចដែលបានបង្ហាញដោយអត្រាអ្នកអត់ការងារធ្វើនៅក្នុងសង្កាត់ទាប ហាក់ដូចជាបង្កើនលទ្ធភាពដែលសិស្សនឹងឈប់រៀន ខណៈពេលដែលផលចំណេញខាងសេដ្ឋកិច្ចដល់អ្នកបញ្ចប់ការសិក្សាដូចដែលបានបង្ហាញដោយប្រាក់ខែខ្ពស់នៃនិស្សិតបញ្ចប់វិទ្យាល័យ បើធៀបនឹងការបោះបង់ការសិក្សា ទំនងជាមានអត្រាបោះបង់ការសិក្សាទាប។ ការសិក្សាច្រើនម៉ោង នៅវិទ្យាល័យអាចបង្កើនលទ្ធភាពនៃការឈប់រៀន ផលប៉ះពាល់នៃការសិក្សានៅវិទ្យាល័យអាស្រ័យលើប្រភេទនៃការងារ និងតាមភេទរបស់សិស្ស។

## ៥-តើអាចមានដំណោះស្រាយអ្វីខ្លះ?

ចំណេះដឹង អំពីមូលហេតុដែលសិស្សបោះបង់ការប្រឡង ផ្តល់ចំណុចជាច្រើន អំពីអ្វីដែលអាចធ្វើបាន រៀបចំយុទ្ធសាស្ត្រអន្តរាគមន៍ការបោះបង់ការសិក្សាប្រកបដោយប្រសិទ្ធភាព។

ទី១៖ ដោយសារការបោះបង់ការសិក្សាបានជះឥទ្ធិពលទាំងបុគ្គល និងកត្តាស្ថាប័ន យុទ្ធសាស្ត្រអន្តរាគមន៍ អាចផ្តោតលើកត្តាណាមួយ ឬទាំងពីរ។ នោះ គឺអន្តរាគមន៍យុទ្ធសាស្ត្រអាចផ្តោតលើការដោះស្រាយគុណតម្លៃបុគ្គល ឥរិយាបថ និងអាកប្បកិរិយា ដែលត្រូវបានផ្សារភ្ជាប់ជាមួយនឹងគ្រួសារ សាលារៀន និងសហគមន៍ដែលអាចរួមចំណែកដល់កត្តាបុគ្គលទាំងនោះ។ ការការ ពារនៃការបោះបង់ការសិក្សាជាច្រើន ដែលគាំទ្រការបន្តយុទ្ធសាស្ត្រ បន្ថែមធនធាន និងជំនួយ ដើម្បីជួយពួកគេស្នាក់នៅសាលា។ ជម្រើសយុទ្ធសាស្ត្រអន្តរាគមន៍ អាចផ្តោតលើការព្យាយាមកែលម្អបរិបទផ្លូវចិត្ត ជុំវិញនៃការបោះបង់ការសិក្សា ដែលមានសក្តានុពលផ្តល់ធនធាន និងការគាំទ្រ ដើម្បីពង្រឹង ឬរៀបចំរចនាសម្ព័ន្ធគ្រួសារ សាលារៀន និងសហគមន៍របស់ពួកគេ។ យុទ្ធសាស្ត្រជាប្រព័ន្ធបែបនេះ ច្រើនតែជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងធំជាងមុន ដើម្បីកែលម្អការអប់រំ និងលទ្ធផលសង្គមរបស់សិស្ស ដែលមានហានិភ័យកាន់តែច្រើនជាទូទៅ។

ទី២៖ ព្រោះការបោះបង់ចោល គឺជាប់ពាក់ព័ន្ធជាមួយនឹងបញ្ហាសិក្សា និងសង្គម យុទ្ធសាស្ត្របង្ការប្រកបដោយប្រសិទ្ធភាព ត្រូវតែផ្តោតលើបញ្ហាទាំងពីរ។ នោះគឺប្រសិនបើយុទ្ធសាស្ត្របង្ការការបោះបង់នឹងមានប្រសិទ្ធភាព ពួកគេត្រូវតែយល់ច្បាស់ ដោយផ្តល់ធនធាន និងការគាំទ្រគ្រប់វិស័យនៃជីវិតរបស់សិស្ស។ព្រោះតែការបោះ បង់ការសិក្សាពីសាលារៀនសម្រាប់ហេតុផលផ្សេងៗគ្នា សេវាកម្ម ត្រូវបានផ្តល់ជូនពួកគេ ត្រូវតែមានភាពបត់បែន និងសម្របតាមតម្រូវការផ្ទាល់ខ្លួនរបស់ពួកគេ។

ទី៣៖ ដោយសារបញ្ហាឥរិយាបថ និងអាកប្បកិរិយារបស់សិស្ស ដែលមានហានិភ័យនៃការបោះ បង់ការសិក្សា លេចឡើងនៅបឋមសិក្សា យុទ្ធសាស្ត្រការពារការបោះបង់ការសិក្សាអាច និងគួរតែចាប់ផ្តើមដំបូង នៅក្នុងអាជីពអប់រំរបស់កុមារ។ កម្មវិធីទប់ស្កាត់ការបោះបង់ការសិក្សា ជារឿយៗ ផ្តោតលើសិស្សវិទ្យាល័យ ឬមធ្យមសិក្សា ដែលអាចជួបប្រទះការបរាជ័យផ្នែកអប់រំជាច្រើនឆ្នាំ ឬបញ្ហាដែលមិនអាចដោះស្រាយបាន។ កម្មវិធីស្តារការបោះបង់ការសិក្សាក៏ត្រូវតែព្យាយាមជម្នះបញ្ហា ដែលមានរយៈពេលយូរផងដែរ ដើម្បីទទួលបានអ្នកបោះបង់ការសិក្សា ដើម្បីមកបញ្ចប់ការសិក្សា។ ប៉ុន្តែកម្មវិធីបែបនេះ អាចមានតម្លៃថ្លៃ និងគ្មានប្រសិទ្ធភាព។ ផ្ទុយទៅវិញ អន្តរាគមន៍ដំបូង អាចជាវិធីសាស្ត្រដ៏មានឥទ្ធិពល និងមានប្រសិទ្ធភាពបំផុតក្នុងការទប់ស្កាត់ការបោះបង់ការសិក្សា។

ផលប្រយោជន៍យូរអង្វែង នៅក្នុងបញ្ហានៃការបោះបង់ការសិក្សា បានជំរុញឱ្យមានការខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងការអភិវឌ្ឍកម្មវិធី និងយុទ្ធសាស្ត្រ ធ្វើឱ្យប្រសើរឡើងនូវអត្រាបោះ បង់ការសិក្សា និងអត្រាបញ្ចប់ការសិក្សា។ ពួកគេ អាចត្រូវបានដាក់ជាក្រុមជាបីវិធីសាស្ត្រមូលដ្ឋាន៖ គោលដៅ ការយល់ដឹង និងប្រព័ន្ធ។

**-គោលវិធីដែលមានគោលដៅ**

គោលវិធីសាមញ្ញបំផុត សម្រាប់កែលម្អការបោះបង់ការសិក្សា និងអត្រាបញ្ចប់ការសិក្សា គឺអភិវឌ្ឍកម្មវិធីពិសេស ផ្តោតលើសិស្សដែលមានហានិភ័យច្រើនបំផុត។ មានគោលវិធី ២ ដែលបានកំណត់គោលដៅ៖

.ទីមួយ ផ្តល់សេវាកម្មបន្ថែមដល់សិស្សក្នុងកម្មវិធីសាលា ដែលមានស្រាប់។

.ទីពីរ ផ្តល់កម្មវិធីសាលាពិសេស នៅក្នុងសាលាដែលមានស្រាប់ ឬនៅក្នុងកន្លែងដាច់ដោយឡែកមួយ (ជម្រើសសាលា) ។

គ្មានគោលវិធីណាមួយ ព្យាយាមផ្លាស់ប្តូរស្ថាប័ន ដែលមានស្រាប់ បម្រើសិស្សភាគច្រើនទេ ផ្ទុយទៅវិញ គោលវិធីបង្កើតបន្ថែម ឬកម្មវិធីជំនួស ដែលកំណត់គោលដៅសិស្ស ដែលត្រូវបានគេកំណត់ថា មានហានិភ័យបោះបង់ចោលឬអ្នកដែលបានបោះបង់ការសិក្សារួចហើយ។

**-វិធីសាស្ត្រទូលំទូលាយ**

គោលវិធីទីពីរក្នុងការទប់ស្កាត់ការបោះបង់ការសិក្សា តាមរយៈកំណែទម្រង់ទូលំទូលាយ ឬទូទាំងសាលា។ គោលវិធីនេះ គឺផ្អែកលើជំនឿថា កម្មវិធីគោលដៅ មិនគ្រប់គ្រាន់ដើម្បីកែលម្អអត្រាបោះបង់ការសិក្សា ឬបញ្ចប់ការសិក្សា ដោយសារគេមិនយល់គ្រប់គ្រាន់

ឬដោយ សារតែពួកគេ មិនបានជួយសិស្សឱ្យបានគ្រប់គ្រាន់។ គោលវិធីកំណែទម្រង់សាលារៀន ពាក់ព័ន្ធនឹងការបង្កើតសំណុំការអនុវត្តទូលំទូលាយ និងកម្មវិធីនៅក្នុងមូលដ្ឋាន ឬដោយការទទួលយកគំរូកំណែទម្រង់សាលារៀនដ៏ទូលំទូលាយ ដែលបានអភិវឌ្ឍពីខាងក្រៅ។

**-គោលវិធីជាប្រព័ន្ធ**

គោលវិធីជាប្រព័ន្ធ ពាក់ព័ន្ធនឹងការធ្វើការផ្លាស់ប្តូរប្រព័ន្ធអប់រំទាំងមូល ក្រោមការសន្មតថា ការផ្លាស់ប្តូរបែបនេះ អាចផ្លាស់ប្តូររបៀប ដែលសាលារៀនទាំងអស់ មានមុខងារនៅក្នុងប្រ ព័ន្ធ អ្វីដែលអ្នកប្រាជ្ញខ្លះបានហៅថា "កំណែទ ម្រង់ប្រព័ន្ធសាលា"។ កំណែទម្រង់ប្រព័ន្ធ អាចកើតឡើងនៅថ្នាក់មូលដ្ឋាន ឬរដ្ឋាភិបាល។ ទោះ បីជាកំណែទម្រង់ប្រព័ន្ធទាំងអស់ អាចប៉ះពាល់ដល់អត្រាបោះបង់ការសិក្សា និងបញ្ចប់ការសិ ក្សាដោយការកែលម្អសមត្ថភាពសាលានោះ កំ ណែទម្រង់ជាក់លាក់ចំនួនបី គឺភ្ជាប់ដោយផ្ទាល់ទៅនឹងការបោះបង់ការសិក្សា និងការបញ្ចប់ការសិក្សាអត្រា។

.មួយ គឺត្រូវបង្កើនអាយុសិក្សាជាកាតព្វកិច្ច ដែលសិស្សត្រូវតែចូលរៀនដល់អាយុ ១៨ឆ្នាំដែលជាមធ្យោបាយមួយ ដើម្បីបង្ខំសិស្សឱ្យបន្តនៅសាលាបន្ថែមទៀត។

.មួយទៀត ផ្លាស់ប្តូរតម្រូវការការបញ្ចប់ថ្នាក់វិទ្យាល័យ ទាំងបរិមាណ និងវគ្គសិក្សាជាក់លាក់ ដែលសិស្សត្រូវតែឆ្លងកាត់ផ្តល់សញ្ញាប័ត្រ ក៏ដូចជាបញ្ជាក់ថា តើសិស្សត្រូវឆ្លងកាត់ការប្រ ឡងបញ្ចប់នៅវិទ្យាល័យដូចម្តេច ដើម្បីទទួលបានសញ្ញាបត្រ។

.កំណែទម្រង់ទីបី គឺបង្កើតផ្លូវជំនួស ឬជម្រើស សម្រាប់បញ្ចប់ការសិក្សានៅវិទ្យាល័យ និងទទួលបានសញ្ញាបត្រ។

ដោយផ្អែកលើការពិនិត្យឡើងវិញនៃអន្តរាគមន៍ការបោះបង់ការសិក្សាជាង៣០ជាមួយនឹងការគាំទ្រការស្រាវជ្រាវយ៉ាងម៉ត់ចត់ ក្រុមប្រឹក្សាអ្នកជំនាញបានកំណត់នូវអនុសាសន៍ចំ នួន៤សម្រាប់ កាត់បន្ថយអត្រាបោះបង់ការសិក្សា និងការកែលម្អអត្រាបញ្ចប់ការសិក្សានៅសាលាមធ្យម និងវិទ្យាល័យ៖

.តាមដានវឌ្ឍនភាពរបស់សិស្សទាំងអស់ និងអន្តរាគមន៍យ៉ាងសកម្ម នៅពេលសិស្សបង្ហាញសញ្ញាដំបូងនៃបញ្ហាការចូលរៀន អាកប្បកិរិយា ឬការសិក្សា។

.ផ្តល់ការគាំទ្រជាលក្ខណៈបុគ្គល ដល់សិស្សដែលបានប្រឡងធ្លាក់ និងប្រឈមសំខាន់ៗ ចំពោះភាពជោគជ័យ។

.ឱ្យសិស្សដោយការផ្តល់ជូននូវកម្មវិធីសិក្សា និងកម្មវិធី ដែលភ្ជាប់កិច្ចការសាលាជាមួយមហាវិទ្យាល័យ និងជោគជ័យក្នុងអាជីព

និងកែលម្អសមត្ថភាពរបស់សិស្សក្នុងការគ្រប់គ្រងបញ្ហាប្រឈមនៅក្នុងនិងចេញពីសាលា។

.សម្រាប់សាលារៀន ដែលសិស្សមានហានិភ័យច្រើន សូមបង្កើតសហគមន៍តូចតាចផ្ទាល់ខ្លួន ដើម្បីជួយសម្រួលការត្រួតពិនិត្យ និងការគាំទ្រ។

ខណៈពេលដែលកម្មវិធីបង្ការការបោះបង់ការសិក្សាភាគច្រើន ផ្តោតលើអនុវិទ្យាល័យ និងវិទ្យាល័យ ការស្រាវជ្រាវ បានរកឃើញផងដែរនូវអន្តរាគមន៍ ដែលផ្តោតលើការកែលម្អសមត្ថភាពរបស់សិស្សនៅសាលាបឋមសិក្សា និងសូម្បីតែសាលាមត្តេយ្យ ក៏អាចប្រសើរឡើងនូវអត្រាបោះបង់ការសិក្សា និងបញ្ចប់ការសិក្សា។ អន្ត រាគមន៍ដំបូងមួយបែបនេះ គឺនៅ ម ត្តេយ្យ។ មិនត្រឹមតែមានការកើនឡើងនៃ ក ស្តុតាងបានរកឃើញថា សាលាមត្តេយ្យ ដែលមានគុណភាពខ្ពស់អាចធ្វើឱ្យប្រសើរឡើងនូវការត្រៀមខ្លួនរបស់សាលា និងជោគជ័យនៅសាលាបឋមសិក្សា ប៉ុន្តែ ការសិក្សាតាមដានរយៈពេលវែង បានរកឃើញថា មត្តេយ្យក៏អាចធ្វើឱ្យប្រសើរនូវលទ្ធផលសិក្សាមនុស្សវ័យជំទង់ និងមនុស្សពេញវ័យ រួមទាំងការបញ្ចប់ការសិក្សានៅវិទ្យាល័យ។

ការស្រាវជ្រាវ មិនគ្រាន់តែរកឃើញថា បរិមាណអន្តរាគមន៍ អាចកាត់បន្ថយអត្រាបោះបង់ការសិក្សា និងធ្វើឱ្យប្រសើរនូវអត្រាបញ្ចប់ការសិក្សា ប៉ុន្តែ យ៉ាងហោចណាស់ ពួកគេខ្លះផ្តល់ផលប្រយោជន៍សេដ្ឋកិច្ចលើសពីការចំណាយរបស់ពួកគេ។ ការសិក្សាថ្មីៗនេះបានប្រៀបធៀបការចំណាយ និងអត្ថប្រយោជន៍នៃអន្តរាគមន៍ចំ នួនប្រាំនោះ ដែលត្រូវបានគេបង្ហាញថា មានប្រសិទ្ធភាពក្នុងការលើកកម្ពស់អត្រាបញ្ចប់ការសិក្សានៅវិទ្យាល័យ ហើយបានរកឃើញថា ពួកគេទាំងអស់ សុទ្ធតែមានអត្ថប្រយោជន៍ លើសពីចំណាយរបស់ពួកគេ។

## សេចក្តីសន្និដ្ឋាន

ការសង្កត់ធ្ងន់លើបញ្ហាបោះបង់ការសិក្សា នៅកម្ពុជា នឹងទាមទារទាំងសមត្ថភាពទាំងឆន្ទៈ។ សមត្ថភាព ទាមទារជំនាញបច្ចេកទេស ដើម្បីអភិវឌ្ឍ និងអនុវត្តកម្មវិធីបង្ការ និងស្តារការបោះបង់ការសិក្សាប្រកបដោយប្រសិទ្ធភាព ព្រមទាំងកម្មវិធីជាច្រើនទៀត ព្រមទាំងកំណែទម្រង់សាលារៀនជាប្រព័ន្ធប្រកបដោយមហិច្ឆតា។ ខណៈពេលដែលមួយចំនួនសាលារៀន មានសមត្ថភាពបែបនេះ ភាគច្រើនត្រូវការធន ធានបន្ថែម ជំនាញបច្ចេកទេស និងការលើកទឹកចិត្តក្នុងការរៀបចំរចនាសម្ព័ន្ធសាលា ដែលមានស្រាប់ឡើងវិញ។ ការអភិវឌ្ឍសមត្ថភាពបែបនេះ នឹងតម្រូវឱ្យមានឆន្ទៈនយោបាយ។ ប៉ុន្តែ ទោះបី ជាមានឆន្ទៈក្នុងការកែទម្រង់សាលារៀន

*ក៏ដោយ យើងនៅតែមិនទាន់បានលុបបំ បាត់ភាពខុសគ្នានៃអត្រាបោះបង់ការសិក្សារបស់សិស្សានុសិស្ស នៅតំបន់ទីក្រុង តំបន់ជនបទ និងតំបន់ដាច់ស្រយាល ដោយមិនលុបបំបាត់ភាពខុសគ្នា នៃធនធានគ្រួសារ សាលារៀន និងសហគមន៍។*

## ឯកសារយោង


*-ក្រសួងអប់រំ យុវជន និងកីឡា **ស្ថិតិ និងសូចនាករអប់រំ គ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន** នាយកដ្ឋានប្រព័ន្ធគ្រប់គ្រងព័ត៌មានអប់រំ* (EMIS), *២០១៨-២០២២។*

-Bradley (Steve)and Green (Colin), ***THE Economics Of Education, a Comprehensive Overview,*** *Academic Press, 2020.*

-Depover, Christian, and Francois Orivel, ***Developing Countries in the e-learning era, Fundamentals of Educational Planning 96,*** Paris: IIEP-UNESCO, 2012.

-Cohn (Elchanan), Geske (Terry G.), ***the Economics of Education,*** Pergamon Press, Oxford, 1990

# ប្រវត្តិឧត្តមសិក្សាកម្ពុជាពីឆ្នាំ១៩៤៦ ដល់ឆ្នាំ១៩៦៧

(History of Cambodian Higher Education From 1946 to 1967)

*ដោយ ៖* **បណ្ឌិត សុខ ស៊ីណា**

*មន្ត្រីស្រាវជ្រាវនៃនាយកដ្ឋានប្រវត្តិវិទ្យានិងវិទ្យាសាស្ត្រនយោបាយ*

*វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម នៃរាជបណ្ឌិត្យសភាកម្ពុជា*

## សេចក្តីផ្តើម

*ការអប់រំតាមបែបប្រពៃណីត្រូវបានធ្វើឡើងនៅតាមទីវត្តអារាម ដោយមានព្រះសង្ឃជាអ្នកបង្រៀន។ ការអប់រំនាសម័យកាលនោះ ការសិក្សាបានផ្តោតលើការសរសេរ ឬអធិប្បាយទាក់ទងទៅនឹងអត្ថបទសាសនាជាដើម។ តាមរយៈការសិក្សាបែបប្រពៃណីនេះអាចធ្វើឱ្យក្មេងខ្មែរចេះអាន និង សរសេរ។ តែទោះជាយ៉ាងនេះក៏ដោយការអប់រំនៅសម័យនោះក៏មានលក្ខណៈសមស្របទៅនឹងស្ថានភាពសង្គមនាពេលនោះផងដែរ។ផ្អែកតាមសភាពជាក់ស្តែងដូចបានរៀបរាប់ខាងលើនេះហើយ ទើបជនជាតិខ្មែរតែងតែផ្តល់តម្លៃថាទីវត្តអារាមជាបណ្តុំនៃការបណ្តុះបណ្តាលធនធានមនុស្ស ជាកន្លែងផ្ទុកនូវវប្បធម៌ ប្រពៃណី និង អរិយធម៌របស់ខ្មែរ។*

### ១. ប្រព័ន្ធអប់រំនៅប្រទេសកម្ពុជា

*នៅក្នុងប្រទេសនីមួយៗ គេបានចាត់ទុកការអប់រំ គឺជាមូលដ្ឋានគ្រឹះដ៏ចាំបាច់សម្រាប់ជាទុនក្នុងការពិចារណា និង យល់ដឹងអំពីសង្គមមនុស្ស។ ការអប់រំប្រកបដោយគុណភាពវានឹងនាំទៅរកការយល់ដឹងដែលមានគ្រឹះរឹងមាំ ព្រមទាំងមានគុណធម៌ និង សីលធម៌ផងដែរ។ នៅមុនពេលដែលបារាំងមកគ្រប់គ្រងនៅប្រទេសកម្ពុជានាស.វ.ទី១៩ ការអប់រំនៅកម្ពុជា គឺក្មេងប្រុសៗត្រូវទៅរៀននៅតាមទីវត្តអារាមនានាក្នុងទូទាំងប្រទេសកម្ពុជា។ នៅដើមស.វ.ទី២០ ការអប់រំនៅកម្ពុជាត្រូវបានបារាំងធ្វើកំណែទម្រង់ ដោយបានបង្កើតសាលាវត្តបែបថ្មី និង បង្កើតសាលាផ្លូវការ (សាលារាជការ)។ សាលាវត្តបែបថ្មី និង សាលាផ្លូវការ (សាលាបឋមសិក្សា អនុវិទ្យាល័យ វិទ្យាល័យរហូតដល់ការបង្កើត*

គ្រឹះស្ថានឧត្តមសិក្សា) បានដំណើរការបណ្តុះបណ្តាលធនធានមនុស្សជាបន្តបន្ទាប់។

យ៉ាងណាមិញបន្ទាប់ពីទទួលបានឯករាជ្យពីរបបអាណាព្យាបាលបារាំងនៅឆ្នាំ ១៩៥៣ គេសង្កេតឃើញថា កម្ពុជាបានយកចិត្តទុកដាក់លើវិស័យសំខាន់ៗដូចជាសេដ្ឋកិច្ច កសិកម្ម ការអប់រំ សុខាភិបាលជាដើម។ ជាពិសេសការអប់រំត្រូវបានរដ្ឋយកចិត្តទុកដាក់ជាវិស័យចម្បង ដែលជាហេតុនេះនាំទៅរកការបង្កើតគ្រឹះស្ថានសិក្សានានាបន្ថែមទៀត តាំងពីកម្រិតបឋមសិក្សារហូតថ្នាក់ឧត្តមសិក្សា ក្នុងបំណងឆ្លើយតបទៅនឹងការវិវត្តរីកចម្រើននៃប្រទេសជាតិ។

## ២. ការបង្កើតមហាវិទ្យាល័យ

ការបណ្តុះបណ្តាលធនធានកម្រិតឧត្តមសិក្សានៅប្រទេសកម្ពុជា បានចាប់ផ្តើមពីឆ្នាំ១៩៤៦។ មហាវិទ្យាល័យមួយចំនួន ដូចជា មហាវិទ្យាល័យច្បាប់ មហាវិទ្យាល័យពេទ្យ មហាវិទ្យាល័យគរុកោសល្យ និង មហាវិទ្យាល័យពាណិជ្ជកម្មជាដើមមុននឹងក្លាយទៅជាមហាវិទ្យាល័យគឺស្ថិតនៅក្នុងក្របខ័ណ្ឌជាសាលា ឬជាវិជ្ជាឋាននៅឡើយ។ បន្ទាប់ពីប្រទេសកម្ពុជាទទួលបានឯករាជ្យនៅឆ្នាំ១៩៥៣ ការអប់រំកាន់តែមានការអភិវឌ្ឍថែមទៀត ហេតុនេះ សាលា និង វិជ្ជាឋានទាំងនោះក៏បានផ្លាស់ប្តូរទៅជាមហាវិទ្យាល័យ។ ដូច្នេះចាប់ពីឆ្នាំ១៩៤៦មក នៅទីក្រុងភ្នំពេញគេសង្កេតឃើញមានការបង្កើតនូវគ្រឹះស្ថានឧត្តមសិក្សាជាបន្តបន្ទាប់។

### ២.១. ឧត្តមសិក្សាសុខាភិបាល (សាលាមន្ត្រីសុខាភិបាល)

ការបណ្តុះបណ្តាលធនធានមនុស្សក្នុងវិស័យសុខាភិបាលបានចេញដំណើរពីឆ្នាំ១៩៤៦ តាមរយៈការបង្កើតសាលាមន្ត្រីសុខាភិបាល។ សាលានេះបានបណ្តុះបណ្តាលនិស្សិតដើម្បីក្លាយជាគ្រូពេទ្យ។ លុះមកដល់ឆ្នាំ១៩៥៣ សាលាមន្ត្រីសុខាភិបាលបានប្តូរឈ្មោះទៅជាសាលាភូមិន្ទវិជ្ជាពេទ្យ។ ក្រោយពីការផ្លាស់ប្តូរឈ្មោះនេះមកយើងសង្កេតឃើញថា ការសិក្សានៅសាលានេះត្រូវបានបែងចែកជា២កម្រិត ៖

១-ការបណ្តុះបណ្តាលរយៈពេល៤ឆ្នាំដើម្បីឱ្យនិស្សិតក្លាយជាគ្រូពេទ្យ។

២-ការបណ្តុះបណ្តាលរយៈពេល៦ឆ្នាំដើម្បីឱ្យនិស្សិតក្លាយជាវេជ្ជបណ្ឌិត។

ជាការឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងក្នុងការពង្រឹង និង ពង្រីកវិស័យសុខាភិបាលសាលាភូមិន្ទវិជ្ជាពេទ្យបានប្រែក្លាយទៅជាមហាវិទ្យាល័យវេជ្ជបណ្ឌិត ឱសថកម្ម និង វិទ្យាសាស្ត្រឱសថកម្មក្នុងឆ្នាំ១៩៦២។

មួយវិញទៀត ចាប់ពីឆ្នាំ១៩៥៨ សម្រាប់អ្នកដែលមានសញ្ញាបត្រនៃវគ្គ

បណ្តុះបណ្តាលមន្ត្រីសុខាភិបាល និង មានក្របខ័ណ្ឌរដ្ឋអាចមកបន្តការសិក្សារបស់ខ្លួនដោយធ្វើនិក្ខេបបទថ្នាក់ឧត្តមផ្នែកវិជ្ជាពេទ្យនៅទីក្រុងភ្នំពេញ។ គួរបញ្ជាក់ថា នៅមុនឆ្នាំ ១៩៤៦ និស្សិតខ្មែរដែលមានបំណងចង់សិក្សាវិជ្ជាពេទ្យពួកគេត្រូវទៅបន្តការសិក្សានៅប្រទេសបារាំង វៀតណាម និង ទីក្រុងព្រៃនគរ។

## ២.២. ឧត្តមសិក្សានីតិសាស្ត្រ

ស្ថាប័នបណ្តុះបណ្តាលផ្នែកនីតិសាស្ត្រនៅប្រទេសកម្ពុជា ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៤៩ គឺវិជ្ជាឋានជាតិយុត្តិធម្មសាស្ត្រ និង សេដ្ឋសាស្ត្រ។ វិជ្ជាឋាននេះសម្រាប់បណ្តុះបណ្តាលនិស្សិតក្នុងការបង្កើតក្របខ័ណ្ឌផ្នែករដ្ឋបាល តុលាការ និង ហិរញ្ញវត្ថុនៃប្រទេសកម្ពុជា[1]។ ដំបូងឡើយ វិជ្ជាឋានជាតិយុត្តិធម្មសាស្ត្រ និង សេដ្ឋសាស្ត្រមានទីតាំងបណ្តោះអាសន្ននៅក្នុងវិទ្យាល័យព្រះស៊ីសុវត្ថិ និង នៅក្នុងសាលាគរុកោសល្យក្រុងភ្នំពេញ ហើយបានដំណើរការបណ្តុះបណ្តាលនិស្សិតរហូតដល់ឆ្នាំ ១៩៥៣ ក៏បានប្តូរឈ្មោះទៅជាវិជ្ជាឋានសិក្សាច្បាប់ នយោបាយ និង សេដ្ឋកិច្ចនៃប្រទេសកម្ពុជា។

បន្ទាប់ពីការផ្លាស់ប្តូរឈ្មោះនេះមក គេសង្កេតឃើញថា មានការវិវត្តនៃការបណ្តុះបណ្តាលធនធានមនុស្សផ្នែកច្បាប់ និង សេដ្ឋកិច្ចនៅប្រទេសកម្ពុជាមួយកម្រិតថែមទៀតគឺកម្មវិធីសិក្សាត្រូវបានកែលម្អដោយមានការបែងចែកការសិក្សាជាពីរគឺ៖

១-ផ្នែកការសិក្សាប្រតិបត្តិ។

២-ផ្នែកការសិក្សាជាន់ខ្ពស់។

នៅឆ្នាំ១៩៥៧ វិជ្ជាឋានសិក្សាច្បាប់ នយោបាយ និង សេដ្ឋកិច្ចបានក្លាយទៅជាមហាវិទ្យាល័យច្បាប់[2] ដែលមានកម្រិតបណ្តុះបណ្តាលចំនួនបី ៖

១-ថ្នាក់សមត្ថភាពច្បាប់

២-ថ្នាក់បរិញ្ញាបត្រច្បាប់

៣-ថ្នាក់បណ្ឌិតច្បាប់។

ការសិក្សាថ្នាក់បណ្ឌិតច្បាប់ចែកចេញជាពីរគឺ បណ្ឌិតច្បាប់ឯកជន និង បណ្ឌិតច្បាប់សាធារណៈ។

សូមរម្លឹកថា បន្ទាប់ពីមានការផ្តួចផ្តើមបង្កើតមហាវិទ្យាល័យច្បាប់តាំងពីឆ្នាំ ១៩៥៥ ដោយព្រះបាទនរោត្តម សីហនុ មកក្រសួងសិក្សាធិការជាតិ និង ក្រសួងសាធារណការបានសម្រេចជ្រើសរើសយកទីតាំងសាងសង់មហាវិទ្យាល័យច្បាប់ដែលស្ថិតនៅតាមបណ្តោយមហាវិថីព្រះមុនីវង្ស

[1] រាជកិច្ចពិសេស ចេញផ្សាយ ថ្ងៃទី៣១ ខែមីនា ឆ្នាំ ១៩៤៩ ទំព័រ ៨៩

[2] រាជកិច្ច ចេញផ្សាយ ថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៥៧ ទំព័រ ៣៧៩៦

(បច្ចុប្បន្នសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច)។ ការសាងសង់មហាវិទ្យាល័យច្បាប់បានចាប់ផ្តើមឡើងនៅឆ្នាំ១៩៥៩ហើយបានសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៅឆ្នាំ១៩៦១ ក្រោមការដឹកនាំសាងសង់ដោយលោក វណ្ណ ម៉ូលីវណ្ណ។

## ២.៣. គ្រឹះស្ថានឧត្តមសិក្សាព្រះពុទ្ធសាសនា

គ្រឹះស្ថានឧត្តមសិក្សាព្រះពុទ្ធសាសនា នៃប្រទេសកម្ពុជានាសម័យនោះ គឺពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ។ ការអប់រំតាមបែបសាសនានៅប្រទេសកម្ពុជាគឺមានការបង្កើតសាលាពុទ្ធិកបឋមសិក្សា សាលាពុទ្ធិកមធ្យមសិក្សា។ នៅឆ្នាំ១៩៥៤ ពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជត្រូវបានបង្កើតឡើងនៅភ្នំពេញតាមព្រះរាជក្រមលេខ៨៧៩ ន.ស.[3] ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ១៩៥៤[4]។ ការបង្កើតពុទ្ធិកមហាវិទ្យាល័យនេះគឺមានគោលបំណងលើកកម្ពស់វិស័យព្រះពុទ្ធសាសនា និង ពង្រឹងសមត្ថភាពរបស់ព្រះសង្ឃទាំងសមត្ថភាពផ្នែកពុទ្ធចក្រ និង ផ្នែកអាណាចក្រសំដៅចូលរួមចំណែកក្នុងការអភិរក្ស និង អភិវឌ្ឍន៍សង្គមកម្ពុជា។

ពុទ្ធិកមហាវិទ្យាល័យនេះបានចាប់ផ្តើមដំណើរការបណ្តុះបណ្តាលរបស់ខ្លួននៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៥៩។ នៅពេលនោះរាជរដ្ឋាភិបាលសង្គមរាស្ត្រនិយមបានជ្រើសរើសសម្តេចព្រះពោធិវង្ស ហួត តាត ដែលកំពុងកាន់ដំណែងជាចាងហ្វាងសាលាបាលីជាន់ខ្ពស់មករៀបចំកម្មវិធីសិក្សានៅពុទ្ធិកមហាវិទ្យាល័យនេះ។ ដើម្បីឱ្យពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជអាចដំណើរការទៅបានគេបានរៀបចំនូវយន្តការដូចខាងក្រោម ៖

-តែងតាំងលេខាធិការកាន់បញ្ជី

-ពិនិត្យមើលដំណើរការនៃការសាងសង់អគារ

-ធ្វើបញ្ជីសារពើភ័ណ្ឌ តុ ទូ និង សម្ភារៈផ្សេងៗ

-រៀបចំកម្មវិធីសិក្សា

-បង្កើតក្រុមប្រឹក្សាវិន័យ

-គាក់តែងបទបញ្ជាផ្ទៃក្នុង

-តែងតាំងសាស្ត្រាចារ្យបង្រៀន

-តែងតាំងគ្រូទទួលបន្ទុកថ្នាក់ គ្រូទទួលបន្ទុកការសិក្សា និង គ្រូទទួលបន្ទុករៀបចំសន្និសីទ

-ចុះឈ្មោះសមណនិស្សិតចូលសិក្សា។

[3] នរោត្តម សីហនុ

[4] រាជកិច្ច ចេញផ្សាយ ត្រីមាសទី២ ឆ្នាំ១៩៥៤ ទំព័រ ១៤៩៥

ចំពោះការជ្រើសរើសទីតាំងដើម្បីសាងសង់ពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ ថ្វីត្បិតតែផ្ទៃដីមានទំហំតូចក៏ពិតមែន ប៉ុន្តែ ជាការអនុគ្រោះដល់សមណនិស្សិតដែលចូលមកសិក្សា ព្រោះសមណនិស្សិតទាំងនោះភាគច្រើនគង់នៅវត្តឧណ្ណាលោម និង វត្តបទុម។

## ២.៤. មហាវិទ្យាល័យអក្សរសាស្ត្រ

នៅឆ្នាំ១៩៦១ មហាវិទ្យាល័យអក្សរសាស្ត្រត្រូវបានបង្កើតឡើង ក្នុងគោលបំណងដើម្បីបណ្តុះបណ្តាល និង ស្រាវជ្រាវលើវិស័យអក្សរសាស្ត្រជាតិក្នុងកម្រិតឧត្តមសិក្សា។ មួយវិញទៀតមហាវិទ្យាល័យនេះនឹងរៀបចំកិច្ចការស្រាវជ្រាវទាំងឡាយ ដែលទាក់ទងនឹងវិស័យវប្បធម៌ អរិយធម៌ ពិសេសការស្រាវជ្រាវក្នុងក្របខ័ណ្ឌអក្សរសាស្ត្រ សិល្បៈ និង មនុស្សសាស្ត្រ។ ទន្ទឹមនឹងនោះដែរ មហាវិទ្យាល័យអក្សរសាស្ត្រក៏បណ្តុះបណ្តាលនិស្សិតថ្នាក់បរិញ្ញាបត្រ ជាការឆ្លើយតបទៅនឹងសេចក្តីត្រូវការសាស្ត្រាចារ្យមធ្យមសិក្សាទុតិយភូមិដើម្បីទៅបង្រៀននៅតាមវិទ្យាល័យនានា នៃប្រទេសកម្ពុជាផងដែរ។ ក្នុងឆ្នាំសិក្សាដំបូង១៩៥៩-១៩៦០ មាននិស្សិតមកចុះឈ្មោះចូលរៀនបានត្រឹមតែ១៥ នាក់ប៉ុណ្ណោះ។ ប៉ុន្តែ ក្នុងរយៈពេលប៉ុន្មានឆ្នាំក្រោយមកចំនួននិស្សិតនៃមហាវិទ្យាល័យនេះបានកើនឡើងរហូតដល់១៣ ០០ នាក់។

## ២.៥. មហាវិទ្យាល័យវិទ្យាសាស្ត្រ និង បច្ចេកទេស

នៅឆ្នាំ១៩៦១ មហាវិទ្យាល័យវិទ្យាសាស្ត្រត្រូវបានបង្កើតឡើងក្នុងគោលបំណងដើម្បីបណ្តុះបណ្តាលនិស្សិតដោយផ្តោតទៅលើមុខវិជ្ជា គណិតវិទ្យា រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា ជាដើម។ ទន្ទឹមនឹងនោះ មហាវិទ្យាល័យនេះនឹងរៀបចំឱ្យមានការប្រឡងឧត្តមសិក្សាផ្នែកវិទ្យាសាស្ត្រ និង បច្ចេកទេសព្រមទាំងចេញសញ្ញាបត្រ ដែលស្របទៅនឹងផ្នែកផ្សេងៗតាមមុខវិជ្ជាសិក្សាផងដែរ[5]។ ការបណ្តុះបណ្តាលផ្នែកវិទ្យាសាស្ត្រ និង បច្ចេកទេស នៅមហាវិទ្យាល័យវិទ្យាសាស្ត្រ និង បច្ចេកទេសជាការផ្តល់នូវចំណេះដឹងផ្នែកវិទ្យាសាស្ត្រពិតទៅដល់ស្រទាប់នៃយុវវ័យខ្មែរ។

## ៣. ការបង្កើតសាកលវិទ្យាល័យ

ការបណ្តុះបណ្តាលធនធានមនុស្សកម្រិតឧត្តមសិក្សានៅកម្ពុជា ត្រូវបានធ្វើ

[5] រាជកិច្ច ចេញផ្សាយ ថ្ងៃទី៥ ខែមិថុនា ឆ្នាំ១៩៦១ ទំព័រ ៣៩៩៨

ឡើងក្រោយការបញ្ចប់នៃសង្គ្រាមលោកលើកទី២។ ក្នុងដំណាក់កាលនោះ មហាវិទ្យាល័យនានាត្រូវបានគេបង្កើតឡើងជាបន្តបន្ទាប់។ ដោយសារមានការបង្កើតមហាវិទ្យាល័យកាន់តែច្រើននោះ ទើបតម្រូវឱ្យមានការបង្កើតស្ថាប័នសាកលវិទ្យាល័យ។ មជ្ឈមណ្ឌលសាកលវិទ្យាល័យជាស្ថាប័នបណ្ដុះបណ្ដាលធនធានមនុស្សកម្រិតខ្ពស់ដល់និស្សិតឱ្យមានជំនាញ ដើម្បីចូលរួមក្នុងការអភិវឌ្ឍប្រទេសជាតិឱ្យមានការរីកចម្រើន។ ចាប់ពីឆ្នាំ១៩៦៥ សាកលវិទ្យាល័យជាច្រើននៅក្នុងប្រទេសកម្ពុជាត្រូវបានបង្កើតឡើងជាបន្តបន្ទាប់ លើកលែងតែសាកលវិទ្យាល័យខេមរភូមិន្ទ (សព្វថ្ងៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ) ជាសាកលវិទ្យាល័យដែលត្រូវបានបង្កើតឡើងដំបូងគេតាំងពីឆ្នាំ១៩៦០។

### ៣.១. សាកលវិទ្យាល័យខេមរភូមិន្ទ (បច្ចុប្បន្នសាកលវិទ្យាល័យភូមិន្ទភ្នំពេញ)

សាកលវិទ្យាល័យខេមរភូមិន្ទដែលសរសេរអក្សរកាត់ (ស.ខ.ភ.) ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៦០ ស្ថិតនៅក្រោមអាណាព្យាបាលរបស់ក្រសួងអប់រំជាតិ។

នៅឆ្នាំ១៩៦០ សាកលវិទ្យាល័យខេមរភូមិន្ទមានមហាវិទ្យាល័យដូចខាងក្រោម ៖

-មហាវិទ្យាល័យច្បាប់ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

-មហាវិទ្យាល័យវេជ្ជវិទ្យា ឱសថកម្ម និង វិទ្យាសាស្ត្រឈាបវេជ្ជវិទ្យា

-មហាវិទ្យាល័យវិទ្យាសាស្ត្រ និង បច្ចេកទេស

-មហាវិទ្យាល័យអក្សរសាស្ត្រ និង វិទ្យាសាស្ត្រមនុស្សជាតិ

-វិទ្យាស្ថានជាតិគរុកោសល្យ[6]។

នៅឆ្នាំ១៩៦៤ សាកលវិទ្យាល័យខេមរភូមិន្ទបានកែសម្រួលការគ្រប់គ្រងរបស់ខ្លួនដោយពង្រីកការគ្រប់គ្រងទៅលើមហាវិទ្យាល័យនានាបន្ថែមដូចតទៅ ៖

-មហាវិទ្យាល័យច្បាប់ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

-មហាវិទ្យាល័យវេជ្ជវិទ្យា និង វិទ្យាសាស្ត្រឈាបវេជ្ជវិទ្យា

-មហាវិទ្យាល័យវិទ្យាសាស្ត្រ និង បច្ចេកទេស

-មហាវិទ្យាល័យអក្សរសាស្ត្រ និង វិទ្យាសាស្ត្រមនុស្សជាតិ

-វិទ្យាស្ថានជាតិគរុកោសល្យ

---

[6] រាជកិច្ច ចេញផ្សាយ ថ្ងៃទី២១ ខែមករា ឆ្នាំ១៩៦០ ទំព័រ ១៩៦-១៩៧

-វិទ្យាស្ថានបច្ចេកទេសជាន់ខ្ពស់មិត្តភាពខ្មែរ-សូវៀត

-មហាវិទ្យាល័យឱសថកម្ម[7]។

នៅឆ្នាំ១៩៦៥ សាកលវិទ្យាល័យខេមរភូមិន្ទបានកែសម្រួលការគ្រប់គ្រងទៅលើមហាវិទ្យាល័យមួយចំនួនបន្ថែមទៀតដូចខាងក្រោម ៖

-មហាវិទ្យាល័យច្បាប់ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

-មហាវិទ្យាល័យវេជ្ជវិទ្យា និង វិទ្យាសាស្ត្រវណ្ណបវេជ្ជវិទ្យា

-មហាវិទ្យាល័យវិទ្យាសាស្ត្រ

-មហាវិទ្យាល័យអក្សរសាស្ត្រ និង វិទ្យាសាស្ត្រមនុស្សជាតិ

-មហាវិទ្យាល័យឱសថកម្ម

-មហាវិទ្យាល័យគរុកោសល្យ

-មហាវិទ្យាល័យវិទ្យាសាស្ត្រពាណិជ្ជកម្ម[8]។

### ៣.២. សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ

សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈដែលសរសេរអក្សរកាត់ (ស.ភ.វ.ស.) ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៦៥ ស្ថិតនៅក្រោមអាណាព្យាបាលរបស់ក្រសួងអប់រំជាតិ។

សាកលវិទ្យាល័យនេះមានមហាវិទ្យាល័យដូចតទៅ ៖

-មហាវិទ្យាល័យសិល្បៈនាដសាស្ត្រ

-មហាវិទ្យាល័យតន្ត្រី

-មហាវិទ្យាល័យសិល្បៈស្ទូនរូប

-មហាវិទ្យាល័យបុរាណវត្ថុវិទ្យា

-មហាវិទ្យាល័យស្ថាបត្យកម្ម និង នគរោបនីយវិទ្យា[9]។

### ៣.៣. សាកលវិទ្យាល័យភូមិន្ទបច្ចេកទេស

សាកលវិទ្យាល័យភូមិន្ទបច្ចេកទេសដែលមានអក្សរកាត់ (ស.ភ.ប.) ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៦៥ ស្ថិតនៅក្រោមអាណាព្យាបាលរបស់ក្រសួងអប់រំជាតិ។ សាកលវិទ្យាល័យនេះមានមហាវិទ្យាល័យ និង គ្រឹះស្ថានឧត្តមសិក្សាបច្ចេកទេសដូចខាងក្រោម ៖

-មហាវិទ្យាល័យ ទេពកោសល្យស៊ីវិល

[7] រាជកិច្ច ចេញផ្សាយ ថ្ងៃទី១០ ខែតុលា ឆ្នាំ១៩៦៤ ទំព័រ ៨៣៧៨-៨៣៧៩

[8] រាជកិច្ច ចេញផ្សាយ ថ្ងៃទី២០ ខែមករា ឆ្នាំ១៩៦៥ ទំព័រ ៥៤៩-៥៥០

[9] រាជកិច្ច ចេញផ្សាយ ថ្ងៃទី២០ ខែមករា ឆ្នាំ១៩៦៥ ទំព័រ ៥៥៣-៥៥៤

-មហាវិទ្យាល័យ ជលគតិវិជ្ជា និង នាវាចរណ៍

-មហាវិទ្យាល័យបច្ចេកទេសអគ្គិសនី

-មហាវិទ្យាល័យសិល្បៈ និង មុខរបរ

-សាលាជាន់ខ្ពស់គីមីអនុវត្តន៍

-សាលាជាន់ខ្ពស់អាកាសចរណ៍ស៊ីវិល

-សាលាជាន់ខ្ពស់កងនាវាជំនួញ។

-មជ្ឈមណ្ឌលសម្រាប់អប់រំបុគ្គលិកបច្ចេកទេស និង សម្រាប់បង្កើតផលិតភាព និង មហាវិទ្យាល័យបច្ចេកទេសទាំងឡាយ ដែលប្រមូលផ្តុំនៅក្នុងវិទ្យាស្ថានបច្ចេកទេសជាន់ខ្ពស់មិត្តភាពខ្មែរ-សូវៀតមាន ៖

-មហាវិទ្យាល័យសំណង់

-មហាវិទ្យាល័យអណ្តូងរ៉ែ

-មហាវិទ្យាល័យបច្ចេកទេសអគ្គិសនី

-មហាវិទ្យាល័យវាយនភ័ណ្ឌ[10]។

### ៣.៤. សាកលវិទ្យាល័យប្រជារាស្ត្រ

សាកលវិទ្យាល័យប្រជារាស្ត្រ ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៦៥ ស្ថិតនៅក្រោមអាណាព្យាបាលរបស់ក្រសួងអប់រំជាតិ។

សាកលវិទ្យាល័យនេះមានមជ្ឈមណ្ឌលបណ្តុះបណ្តាលចំនួន២ គឺ ៖

-មជ្ឈមណ្ឌលបណ្តុះបណ្តាលអ្នកបច្ចេកទេស

-មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ និង មុខរបរ។

### ៣.៥. សាកលវិទ្យាល័យភូមិន្ទកំពង់ចាម

សាកលវិទ្យាល័យភូមិន្ទកំពង់ចាម ដែលសរសេរអក្សរកាត់ (ស.ភ.ក.ច.) ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៦៥ ស្ថិតនៅក្រោមអាណាព្យាបាលរបស់ក្រសួងអប់រំជាតិ។

សាកលវិទ្យាល័យនេះមានមហាវិទ្យាល័យដូចតទៅ ៖

-មហាវិទ្យាល័យយន្តសាស្ត្រ

-មហាវិទ្យាល័យវប្បកម្មឧណ្ហប្រទេស

-មហាវិទ្យាល័យវិទ្យាសាស្ត្រ រូបនិយម គណិតសាស្ត្រ[11]។

### ៣.៦. សាកលវិទ្យាល័យភូមិន្ទវិទ្យាសាស្ត្រក្សេត្រវិទ្យា

សាកលវិទ្យាល័យភូមិន្ទវិទ្យាសាស្ត្រក្សេត្រវិទ្យាដែលសរសេរអក្សរកាត់ (ស.វ.ក.វ.ក្ស.) ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៦៥ ដែលមានមហាវិទ្យាល័យដូចតទៅ ៖

[10] រាជកិច្ច ចេញផ្សាយ ថ្ងៃទី២០ ខែមករា ឆ្នាំ១៩៦៥ ទំព័រ ៩៥០-៩៥២

[11] រាជកិច្ច ចេញផ្សាយ ថ្ងៃទី២០ ខែមករា ឆ្នាំ១៩៦៥ ទំព័រ ៩៥៤-៩៥៥

-មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម

-មហាវិទ្យាល័យវិទ្យាសាស្ត្រព្រៃឈើ

-មហាវិទ្យាល័យវិទ្យាសាស្ត្រចិញ្ចឹមត្រី (មច្ឆវប្បកម្ម)

-មហាវិទ្យាល័យវិទ្យាសាស្ត្រទេពកោសល្យជនបទ

-មហាវិទ្យាល័យវិទ្យាសាស្ត្រសង្គមវិទ្យា និង សេដ្ឋកិច្ចជនបទ[12]។

## ៣.៧. សាកលវិទ្យាល័យភូមិន្ទបាត់ដំបង

សាកលវិទ្យាល័យភូមិន្ទភូមិន្ទបាត់ដំបងត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៦៧ ស្ថិតនៅក្រោមអាណាព្យាបាលរបស់ក្រសួងអប់រំជាតិ។

សាកលវិទ្យាល័យនេះមានមហាវិទ្យាល័យដូចតទៅ ៖

-មហាវិទ្យាល័យឧស្សាហកម្មអាហារូបណីយ និង កសិកម្ម

-មហាវិទ្យាល័យភូគព្ភសាស្ត្រអនុវត្តន៍

-មហាវិទ្យាល័យស្ថាបនាគ្រឿងយន្ត និង បច្ចេកទេសជាន់ខ្ពស់[13]។

## ៣.៨. សាកលវិទ្យាល័យភូមិន្ទតាកែវ-កំពត

សាកលវិទ្យាល័យភូមិន្ទតាកែវ-កំពត ដែលសរសេរអក្សរកាត់ (ស.ភ.ត.ក) ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៦៥ ស្ថិតនៅក្រោមអាណាព្យាបាលរបស់ក្រសួងអប់រំជាតិ។ សាកលវិទ្យាល័យភូមិន្ទតាកែវ-កំពតត្រូវបានសាងសង់ឡើងនៅត្រង់ព្រំប្រទល់នៃខេត្តតាកែវ និង កំពត។

សាកលវិទ្យាល័យនេះមានមហាវិទ្យាល័យដូចតទៅ ៖

-មហាវិទ្យាល័យអគ្គិសនី

-មហាវិទ្យាល័យសាគរសាស្ត្រ[14]។

## ៤. ការគ្រប់គ្រងរដ្ឋបាលរបស់សាកលវិទ្យាល័យ

សាកលវិទ្យាល័យនីមួយៗត្រូវបានគ្រប់គ្រងដោយបុគ្គល ដែលមានចំណេះដឹងខ្ពង់ខ្ពស់ និង មានក្រុមប្រឹក្សាភិបាលសាកលវិទ្យាល័យផង។

---

[12] រាជកិច្ច ចេញផ្សាយ ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៦៥ ទំព័រ ១០៤៥៤

[13] រាជកិច្ច ចេញផ្សាយ ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ១៩៦៧ ទំព័រ ៤៥៣០-៤៥៣១

[14] រាជកិច្ច ចេញផ្សាយ ថ្ងៃទី២០ ខែមករា ឆ្នាំ១៩៦៥ ទំព័រ ៥៥៦-៥៥៧

## ៤.១. សាកលវិទ្យាធិការសាកលវិទ្យាល័យ និង ព្រឹទ្ធបុរសមហាវិទ្យាល័យ

### ៤.១.១. ការតែងតាំងសាកលវិទ្យាធិការ

*សាកលវិទ្យាធិការគឺជាអ្នកដឹកនាំសាកលវិទ្យាល័យ ដែលត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យ និង ត្រូវជ្រើសរើសពីក្នុងចំណោមសាស្ត្រាចារ្យដែលមានក្របខ័ណ្ឌនៃមហាវិទ្យាល័យ និង មានសញ្ជាតិខ្មែរ។ បើមិនមានសាស្ត្រាចារ្យក្របខ័ណ្ឌមហាវិទ្យាល័យទេ សាកលវិទ្យាល័យត្រូវបានដឹកនាំដោយវរជនខ្មែរម្នាក់ ដែលមានសញ្ញាបត្រមហាវិទ្យាល័យនៃឧត្តមសិក្សាតាមការស្នើសុំរបស់ក្រសួងអប់រំជាតិ។ នៅក្នុងព្រះរាជក្រឹត្យស្តីពីការប្រព្រឹត្តិទៅរបស់សាកលវិទ្យាល័យខេមរភូមិន្ទឆ្នាំ១៩៦០ ត្រង់ប្រការ៣ បានចែងថា សាកលវិទ្យាធិការត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យសម្រាប់រយៈពេល ៣ ឆ្នាំហើយសាកលវិទ្យាធិការរងត្រូវជ្រើសរើសក្នុងចំណោមសមាជិកនៃឧត្តមសិក្សា និង ត្រូវតែងតាំងដោយព្រះរាជក្រឹត្យផងដែរ។*

### ៤.១.២. ការតែងតាំងព្រឹទ្ធបុរសមហាវិទ្យាល័យ

*ព្រឹទ្ធបុរសមហាវិទ្យាល័យគឺជាអ្នកដឹកនាំមហាវិទ្យាល័យ ត្រូវជ្រើសរើសក្នុងចំណោមសាស្ត្រាចារ្យ ដែលមានក្របខ័ណ្ឌនៃមហាវិទ្យាល័យនោះហើយត្រូវមានសញ្ជាតិជាខ្មែរ។ តាមព្រះរាជក្រឹត្យលេខ ៣៨៦ ប.រ. ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ១៩៦០ ស្តីពីការប្រព្រឹត្តិទៅនៃសាកលវិទ្យាល័យខេមរភូមិន្ទ ត្រង់ប្រការ៨ បានចែងថា ព្រឹទ្ធបុរសមហាវិទ្យាល័យត្រូវតែងតាំងដោយព្រះរាជក្រឹត្យសម្រាប់រយៈពេល៣ ឆ្នាំ តាមសេចក្តីស្នើសុំពីរដ្ឋមន្ត្រីក្រសួងអប់រំជាតិ។ ព្រឹទ្ធបុរសរងត្រូវជ្រើសរើសពីក្នុងចំណោមបុគ្គលិកសិក្សាមហាវិទ្យាល័យ ដោយមានការស្នើសុំពីព្រឹទ្ធបុរសមហាវិទ្យាល័យនោះ ហើយត្រូវតែងតាំងដោយរដ្ឋមន្ត្រីក្រសួងអប់រំជាតិនៅរៀងរាល់ដើមឆ្នាំសិក្សា។*

### ៤.១.៣. តួនាទីរបស់សាកលវិទ្យាធិការ និង ព្រឹទ្ធបុរសមហាវិទ្យាល័យ

#### ក. តួនាទីរបស់សាកលវិទ្យាធិការ

*សាកលវិទ្យាធិការ គឺជាអ្នកទទួលខុសត្រូវរួមស្តីពីការប្រព្រឹត្តទៅរបស់សាកលវិទ្យាល័យដែលស្ថិតនៅក្រោមអាណាព្យាបាលរបស់ក្រសួងអប់រំជាតិ។ សាកលវិទ្យាធិការជាអ្នករៀបចំកិច្ចការរដ្ឋបាល និង ហិរញ្ញវត្ថុ និង ជាអ្នកសម្របសម្រួលជាមួយនឹងមហាវិទ្យាល័យនានាដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួន។ មួយវិញទៀត សាកលវិទ្យាធិការក៏មានមុខងារជាអ្នក*

រៀបចំថវិការបស់សាកលវិទ្យាល័យ ទាំងចំណូល និង ចំណាយប្រចាំឆ្នាំផងដែរ។

### ខ. តួនាទីរបស់ព្រឹទ្ធបុរសមហាវិទ្យាល័យ

ព្រឹទ្ធបុរសមហាវិទ្យាល័យមានការកិច្ចទទួលខុសត្រូវលើការរៀបចំ និង ការប្រព្រឹត្តទៅនៃមហាវិទ្យាល័យ។ ព្រឹទ្ធបុរសជាអ្នកទទួលបន្ទុករៀបចំបទបញ្ញាផ្ទៃក្នុងរៀបចំកិច្ចការបង្រៀនព្រមទាំងការប្រឡងរបស់និស្សិត និង ជាអ្នកដឹកនាំកិច្ចប្រជុំនៃក្រុមប្រឹក្សាវិន័យរបស់មហាវិទ្យាល័យ និង ជាអ្នករៀបចំថវិការបស់មហាវិទ្យាល័យ។

### គ. ក្រុមប្រឹក្សាភិបាល

នៅពេលនោះគ្រឹះស្ថានឧត្តមសិក្សាត្រូវមានក្រុមប្រឹក្សាភិបាល ដែលមានតួនាទីជាជំនួយដល់ដំណើរការប្រព្រឹត្តទៅរបស់សាកលវិទ្យាល័យ។ ក្រុមប្រឹក្សាភិបាលមានសមាសភាពមកពីបណ្ដាស្ថាប័នឧត្តមសិក្សាទាំងឡាយ ដែលជាប់ពាក់ព័ន្ធនឹងវិស័យឧត្តមសិក្សានៅប្រទេសកម្ពុជា។ ជាក់ស្ដែងសមាសភាពក្រុមប្រឹក្សាភិបាលនៃសាកលវិទ្យាល័យខេមរភូមិន្ទមានដូចតទៅ ៖

-ព្រះរាជតំណាងនៃព្រះករុណា ប្រធាន

-សាកលវិទ្យាធិការសាកលវិទ្យាល័យ អនុប្រធាន

-សាកលវិទ្យាធិការរង សមាជិក

-ព្រឹទ្ធបុរសមហាវិទ្យាល័យ សមាជិក

-នាយកគ្រឹះស្ថានឧត្តមសិក្សានានាក្នុងព្រះរាជាណាចក្រកម្ពុជា សមាជិក

-ព្រឹទ្ធបុរសរងនៃមហាវិទ្យាល័យ សមាជិក

-វរជនខ្មែរ២រូបដែលតែងតាំងដោយព្រះរាជក្រឹត្យតាមការស្នើសុំពីក្រសួងអប់រំជាតិជាសមាជិក។

ចំណែកឯគ្រឹះស្ថានឧត្តមសិក្សាពុទ្ធសាសនាគឺពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជមានសមាសភាពក្រុមប្រឹក្សាភិបាលដូចខាងក្រោម ៖

-រដ្ឋមន្ត្រីក្រសួងធម្មការ ឬ តំណាង ប្រធាន

-រដ្ឋមន្ត្រីក្រសួងអប់រំជាតិ ឬ តំណាង សមាជិក

-សម្ដេចសង្ឃគណៈធម្មយុត្តិ ឬ តំណាង សមាជិក

-សម្ដេចសង្ឃគណៈមហានិកាយ ឬ តំណាង សមាជិក

-សាកលវិទ្យាធិការពុទ្ធិកសាកលវិទ្យាល័យ សមាជិក

-សាស្ត្រាចារ្យ៣រូបមានក្របខ័ណ្ឌពុទ្ធិកសាកលវិទ្យាល័យតែង

តាំងដោយក្រសួងធម្មការតាមការស្នើសុំពីសាកលវិទ្យាធិការ ជាសមាជិក។

### ឃ. តួនាទីក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល ជាអ្នកចូលរួមធ្វើឱ្យសម្រេចនូវបញ្ហាទាំងឡាយ ដែលជាប្រយោជន៍ទាក់ទងនឹងសាកលវិទ្យាល័យ ដូចជា ផ្នែកហិរញ្ញវត្ថុ ចំណូល និង ចំណាយប្រចាំឆ្នាំជាដើម។ ក្រុមប្រឹក្សាភិបាលជាអ្នកជួយផ្តល់យោបល់ទាក់ទងនឹងការរៀបចំកម្មវិធីបង្រៀន និង ការតាក់តែងបទបញ្ជាសិក្សានៅក្នុងមហាវិទ្យាល័យ។

### ង. ក្រុមប្រឹក្សាវិន័យ

វិន័យជាកត្តាចាំបាច់ក្នុងការធានានូវសណ្តាប់ធ្នាប់ក្នុងគ្រឹះស្ថានសិក្សានានា។ ការពង្រឹង វិន័យជាចំណុចសំខាន់មួយក្នុងការធានាដល់ការបណ្តុះបណ្តាលប្រកបដោយគុណភាព និង សីលធម៌នៅក្នុងសង្គមជាតិ។ ក្រុមប្រឹក្សាវិន័យអាចដាក់ពិន័យទៅលើនិស្សិតទាំងឡាយណាដែលបានប្រព្រឹត្តខុសក្នុងពេលកំពុងសិក្សា និង ការប្រឡងជាដើម។

### ច. តួនាទីក្រុមប្រឹក្សាវិន័យ

នៅឆ្នាំ១៩៥៧ ក្នុងព្រះរាជក្រឹត្យស្តីពីការបង្កើតមហាវិទ្យាល័យច្បាប់ត្រង់ប្រការ ២៦ គេបានចែងថា ទណ្ឌកម្មខាងវិន័យមានដូចតទៅ ៖

-ការស្តីបន្ទោស

-មិនអនុញ្ញាតឱ្យចុះឈ្មោះ និង មិនឱ្យប្រឡងនៅមហាវិទ្យាល័យក្នុងរយៈពេល ១ឆ្នាំ ទៅ៥ឆ្នាំ

-បណ្តេញចេញជាស្ថាពរពីមហាវិទ្យាល័យ។

បើមានបញ្ហាមិនប្រក្រតីប៉ះពាល់ដល់ការប្រព្រឹត្តទៅរបស់មហាវិទ្យាល័យ ព្រឹទ្ធបុរសមហាវិទ្យាល័យ ដែលជាអ្នកដឹកនាំក្រុមប្រឹក្សាវិន័យនោះត្រូវធ្វើសំណើសុំទៅរដ្ឋមន្ត្រីក្រសួងអប់រំជាតិដើម្បីបិទមហាវិទ្យាល័យបណ្តោះអាសន្នមួយរយៈ ឬអាចបិទក្នុងរយៈពេល១ឆ្នាំ។

## ៥. គ្រូបខ័ណ្ឌសាស្ត្រាចារ្យសាកលវិទ្យាល័យ

នៅឆ្នាំ១៩៥៨ គេបានបង្កើតក្របខ័ណ្ឌសាស្ត្រាចារ្យឧត្តមសិក្សានៅមហាវិទ្យាល័យច្បាប់ដែលពេលនោះសាកលវិទ្យាល័យខេមរភូមិន្ទនៅមិនទាន់បង្កើតឡើងនៅឡើយ។ បន្ទាប់ពីការបង្កើតសាកលវិទ្យាល័យខេមរភូមិន្ទក្នុងឆ្នាំ១៩៦០មក គេបានបង្កើតក្របខ័ណ្ឌសាស្ត្រាចារ្យនៅសាកលវិទ្យាល័យខេមរភូមិន្ទដោយបែងចែកដូចខាងក្រោម ៖

-សាស្ត្រាចារ្យមានក្របខ័ណ្ឌ

-សាស្ត្រាចារ្យសមាគត

-ធារីបង្រៀន នាយពិនិត្យការអនុវត្ត

១-សាស្ត្រាចារ្យមានក្របខ័ណ្ឌត្រូវជ្រើសរើសក្នុងចំណោមបណ្ឌិតផ្នែកអក្សរសាស្ត្រ ឬ វិទ្យាសាស្ត្រ អ្នកមានមហាបរិញ្ញាច្បាប់ មហាបរិញ្ញាវិជ្ជាពេទ្យ ឱសថ និង ក្នុងចំណោមបណ្ឌិតសាកលវិទ្យាល័យ ជំនាញច្បាប់ អក្សរសាស្ត្រ វិទ្យាសាស្ត្រ វិជ្ជាពេទ្យ និង ឱសថ។

២-សាស្ត្រាចារ្យសមាគតត្រូវជ្រើសរើសក្នុងចំណោមសាស្ត្រាចារ្យមានក្របខ័ណ្ឌ ឬ អ្នកដែលមានសញ្ញាបត្រមហាបរិញ្ញានៃសាកលវិទ្យាល័យបរទេស។

៣-ធារីបង្រៀន និង នាយពិនិត្យការអនុវត្តត្រូវជ្រើសរើសក្នុងចំណោមអ្នកមានសញ្ញាបត្របរិញ្ញាបត្រ។

## ៥.១. ឋានន្តរស័ក្តិសាស្ត្រាចារ្យមហាវិទ្យាល័យ

ឋានន្តរស័ក្តិសាស្ត្រាចារ្យនៅមហាវិទ្យាល័យច្បាប់មានដូចខាងក្រោម ៖

-សាស្ត្រាចារ្យច្បាប់ ដើមខ្សែផុតលេខ

-សាស្ត្រាចារ្យច្បាប់ ថ្នាក់លេខ១

-សាស្ត្រាចារ្យច្បាប់ ថ្នាក់លេខ២

-សាស្ត្រាចារ្យច្បាប់ ថ្នាក់លេខ៣

-សាស្ត្រាចារ្យច្បាប់ ថ្នាក់លេខ៤

-សាស្ត្រាចារ្យច្បាប់ ថ្នាក់លេខ៥

ឋានន្តរស័ក្តិគ្រូបង្រៀនច្បាប់នៅមហាវិទ្យាល័យច្បាប់មានដូចតទៅ ៖

-គ្រូបង្រៀនច្បាប់ ដើមខ្សែផុតលេខ

-គ្រូបង្រៀនច្បាប់ ដើមខ្សែថ្នាក់លេខ១

-គ្រូបង្រៀនច្បាប់ ដើមខ្សែថ្នាក់លេខ២

-គ្រូបង្រៀនច្បាប់ ដើមខ្សែថ្នាក់លេខ៣

-គ្រូបង្រៀនច្បាប់ ថ្នាក់លេខ១

-គ្រូបង្រៀនច្បាប់ ថ្នាក់លេខ២

-គ្រូបង្រៀនច្បាប់ ថ្នាក់លេខ៣

-គ្រូបង្រៀនច្បាប់ បម្រុងរាជការ

ការបង្រួមក្របខ័ណ្ឌសាស្ត្រាចារ្យឧត្តមសិក្សានេះ គឺត្រូវបានធ្វើឡើងក្នុងគោលបំណងដើម្បី ៖

-លើកទឹកចិត្តដល់និស្សិតដែលខិតខំរៀនបានសញ្ញាបត្រខ្ពស់ឱ្យចូលមកបម្រើការងារក្នុងក្របខ័ណ្ឌនេះព្រោះសាស្ត្រាចារ្យឧត្តមសិក្សាមានចំនួនតិច។

-ក្របខ័ណ្ឌថ្មីនេះនឹងដាក់ឱ្យអនុវត្តន៍នៅគ្រប់មហាវិទ្យាល័យដែលស្ថិតនៅក្រោមការគ្រប់ គ្រងរបស់សាកលវិទ្យាល័យខេមរភូមិន្ទ។ សូមរម្លឹកថា នៅឆ្នាំ១៩៥៨ ការរៀបចំក្របខ័ណ្ឌសាស្ត្រាចារ្យឧត្តមសិក្សាត្រូវអនុវត្តន៍តែក្នុងមហាវិទ្យាល័យច្បាប់មួយប៉ុណ្ណោះ។

## ៦. ប្រភពថវិការបស់គ្រឹះស្ថានឧត្តមសិក្សាកម្ពុជា

ប្រភពថវិកាគ្រឹះស្ថានឧត្តមសិក្សាមានពីរ ៖

១-ប្រភពថវិកាជាតិ

២-និង ប្រភពថវិកាពីបរទេស

### ៦.១. ប្រភពថវិកាជាតិ

ក្រសួងហិរញ្ញវត្ថុបានផ្តល់ថវិកាជាតិសម្រាប់ដំណើរការគ្រឹះស្ថានឧត្តមសិក្សានានានៅក្នុងប្រទេសកម្ពុជា។ ការផ្តល់ថវិកាមកសាកលវិទ្យាល័យ និង មហាវិទ្យាល័យត្រូវបានធ្វើឡើងជារៀងរាល់ឆ្នាំសម្រាប់ថវិកាស្វយ័តរបស់សាកលវិទ្យាល័យ និងមហាវិទ្យាល័យនីមួយៗ។ ជាក់ស្តែង នៅពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ ក្នុងឆ្នាំ១៩៥៧ ក្រសួងហិរញ្ញវត្ថុបានផ្តល់ថវិកាចំនួន២២ ៦០០ រៀល តាមប្រកាសចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៥៧[15]។ ចំណែកឯមហាវិទ្យាល័យច្បាប់នៅឆ្នាំ១៩៥៨ ក្រសួងហិរញ្ញវត្ថុបានផ្តល់ថវិកាចំនួន១៧៣ ៨៩២ រៀល តាមប្រកាសចុះថ្ងៃទី២៧ ខែមករា ឆ្នាំ១៩៥៨[16]។

**ការផ្តល់ថវិកាជាតិសម្រាប់ក្រសួងអប់រំ ពីឆ្នាំ១៩៥៥ ដល់ឆ្នាំ១៩៦២**

| ល.រ | កាលបរិច្ឆេទ | ថវិកាគិតជាលានរៀល |
|---|---|---|
| ១ | ១៩៥៥ | ២៩៧ ៣០៩ រ |
| ២ | ១៩៥៦ | ៣៦៨ ៧៣៨ រ |
| ៣ | ១៩៥៧ | ៥០០ ៩៩៤ រ |
| ៤ | ១៩៥៨ | ៦៦០ ៩៨៨ រ |

[15] រាជកិច្ច ចេញផ្សាយ ថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៥៧ ទំព័រ ១៣៩៣

[16] រាជកិច្ច ចេញផ្សាយ ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ១៩៥៨ ទំព័រ ៨៦៨

| | | |
|---|---|---|
| ៥ | ១៩៥៩ | ៧៨០ ៩៤២ ៛ |
| ៦ | ១៩៦០ | ១ ០៨៤ ២២៦ ៛ |
| ៧ | ១៩៦១ | ១ ១២៥ ៤៩៩ ៛ |
| ៨ | ១៩៦២ | ១ ១៩៥ ៤៤៣ ៛ |

ប្រភព ៖ *ប្រទេសកម្ពុជាជួយដោយខ្លួនឯង* ឆ្នាំ១៩៦៣ ទំព័រ ១១

### ៦.២. ប្រភពថវិកាពីបរទេស

រដ្ឋាភិបាលកម្ពុជា ក្នុងសម័យសង្គមរាស្ត្រនិយមបានធ្វើទំនាក់ទំនងជាមួយបណ្តាប្រទេសធំៗនៅលើពិភពលោក ដូចជា ប្រទេសជប៉ុន បារាំង សហរដ្ឋអាម៉េរិក សហភាពសូវៀត ជាដើមហើយប្រទេសទាំងនេះបានផ្តល់ជំនួយថវិកាមកឱ្យប្រទេសកម្ពុជាជាបន្តបន្ទាប់។ ចំណែកមូលនិធិអាស៊ីក៏បានផ្តល់ជំនួយមកឱ្យប្រទេសកម្ពុជាដើម្បីទិញសៀវភៅ សម្ភារៈសិក្សា និង ការបញ្ជូននិស្សិតខ្មែរទៅសិក្សានៅបរទេសផងដែរ។

**តារាងបង្ហាញពីការផ្តល់ជំនួយសម្ភារអប់រំរបស់សហរដ្ឋអាម៉េរិក**

| ល.រ | កាលបរិច្ឆេទ | ចំនួនទឹកប្រាក់គិតជាដុល្លារ |
|---|---|---|
| ១ | ១៩៥៥ | ៦០០ ០០០ ដុល្លារ |
| ២ | ១៩៥៦ | ១ ៥០០ ០០០ ដុល្លារ |
| ៣ | ១៩៥៧ | ២ ៧០០ ០០០ ដុល្លារ |
| ៤ | ១៩៥៨ | ១ ៥០០ ០០០ ដុល្លារ |
| ៥ | ១៩៥៩ | ២ ៤០០ ០០០ ដុល្លារ |
| ៦ | ១៩៦០ | ៣ ៦០០ ០០០ ដុល្លារ |
| ៧ | ១៩៦១ | ៤ ៥០០ ០០០ ដុល្លារ |
| ៨ | ១៩៦២ | ៦ ៣០០ ០០០ ដុល្លារ |

ប្រភព ៖ *ប្រទេសកម្ពុជាជួយដោយខ្លួនឯង* ដ.ឯ.ម. ទំព័រ ១៥

សហភាពសូវៀតបានជួយស្ថាបនាវិទ្យាស្ថានបច្ចេកវិទ្យាមិត្តភាពខ្មែរ-សូវៀត ដែលបានសម្ពោធដាក់ឱ្យប្រើប្រាស់នៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ១៩៦៤។ ចំណែកឯរដ្ឋាភិបាលបារាំងក៏បានផ្តល់ប្រាក់បៀវត្សដល់សាស្ត្រាចារ្យជនជាតិបារាំង ដែលមកបង្រៀន

នៅមហាវិទ្យាល័យអក្សរសាស្ត្រ និង វិទ្យាសាស្ត្រមនុស្សជាតិនៅទីក្រុងភ្នំពេញដែរ។

**និស្សិតខ្មែរដែលទៅបន្តការសិក្សានៅបរទេស ក្នុងឆ្នាំសិក្សា១៩៥៧-១៩៥៨**

| ល.រ | ប្រទេស | ចំនួននិស្សិត | ផ្សេងៗ |
|---|---|---|---|
| ១ | បារាំង | ១៥២ នាក់ | |
| ២ | ស្វីស | ៣ នាក់ | |
| ៣ | បែលហ្ស៊ិក | ១ នាក់ | |
| ៤ | សហរដ្ឋអាម៉េរិក | ៩ នាក់ | |
| ៥ | អង់គ្លេស | ១៤ នាក់ | |
| ៦ | ជប៉ុន | ៦ នាក់ | |
| ៧ | ហុងកុង | ៤២ នាក់ | |
| ៨ | ថៃ | ១០ នាក់ | |
| ៩ | ឥណ្ឌា | ២ នាក់ | |
| ១០ | អូស្ត្រាលី | ១០ នាក់ | |

ប្រភព ៖ ***លទ្ធផលស្នាដៃសង្គមរាស្ត្រនិយមដែលធ្វើបានតាំងពីសសមាជជាតិលើកទី៦ ដល់ទី៧*** ឆ្នាំ ១៩៥៨ ទំព័រ ៦៧-៦៨

តាមការសិក្សាស្រាវជ្រាវនេះបាន បង្ហាញឱ្យយើងឃើញថា ការស្ថាបនាមូលដ្ឋានគ្រឹះឧត្តមសិក្សានៅប្រទេសកម្ពុជាពីឆ្នាំ ១៩៤៦ ដល់ឆ្នាំ១៩៦៧ គឺជាការយកចិត្តទុកដាក់ក្នុងបណ្តុះបណ្តាលនិស្សិតកម្រិតឧត្តមសិក្សាប្រកបដោយគុណភាព។ ប៉ុន្តែស្ថាប័នអប់រំវិជ្ជាជីវៈដំបូងគេនៅកម្ពុជាបានចាប់ផ្តើមដំណើរការនៅឆ្នាំ១៩៤៦ គឺការបង្កើតសាលាមន្ត្រីសុខាភិបាល និង នៅឆ្នាំ ១៩៤៩ បង្កើតវិជ្ជាឋានជាតិខាងវិជ្ជាច្បាប់ និងសេដ្ឋកិច្ច ។ល។

នៅចន្លោះពីឆ្នាំ១៩៥៤ ដល់ឆ្នាំ ១៩៦៧ សាកលវិទ្យាល័យចំនួន៩ត្រូវបានបង្កើតឡើងនៅទូទាំងប្រទេសកម្ពុជា។ ពេលនោះនៅទីក្រុងភ្នំពេញមានសាកលវិទ្យាល័យចំនួន៦ និង នៅតាមខេត្តមានសាកលវិទ្យាល័យចំនួន៣ ៖

ទី១. សាកលវិទ្យាល័យភូមិន្ទកំពង់ចាមសម្រាប់បណ្តុះបណ្តាលនិស្សិតដែលមកពីទឹកដីប៉ែកឦសាន។

ទី២. សាកលវិទ្យាល័យភូមិន្ទបាត់ដំបងសម្រាប់បណ្តុះបណ្តាលនិស្សិតដែលមកពីទឹកដីប៉ែកពាយ័ព្យ។

ទី៣. សាកលវិទ្យាល័យភូមិន្ទតាកែវ-កំពតសម្រាប់បណ្តុះបណ្តាលនិស្សិតដែលមកពីទឹកដីប៉ែកនិរតី។

មួយវិញទៀត យើងកត់សម្គាល់ឃើញថា ប្រព័ន្ធអប់រំឧត្តមសិក្សាកម្ពុជាត្រូវបានបំបែកជាច្រើនមុខជំនាញថែមទៀត ដើម្បីឆ្លើយតបទៅតាមតម្រូវការនៃទីផ្សារជាតិ និង សម្រាប់ទទួលសិស្សដែលមានសញ្ញាបត្រមធ្យមសិក្សា ហើយមិនចង់រៀននៅសាកលវិទ្យាល័យបែបប្រពៃណី ដូចជាសាកលវិទ្យាល័យប្រជារាស្ត្រជាដើម។ ទន្ទឹមនឹងនោះ យើងក៏កត់សម្គាល់ឃើញផងដែរថា និស្សិតមួយចំនួនបានចេញទៅបន្តការសិក្សានៅបរទេស ដែលភាគច្រើនបានទៅបន្តការសិក្សានៅប្រទេសបារាំង។

## សន្និដ្ឋាន

ការបណ្តុះបណ្តាលធនធានមនុស្សនៅកម្ពុជា បានផ្តើមចេញពីការអប់រំនៅតាមទីវត្តអារាមដែលមានព្រះសង្ឃជាអ្នកបង្រៀន។ ដំបូងមានតែកុមារប៉ុណ្ណោះដែលបានចូលរៀននៅតាមវត្តអារាមទាំងនោះ។ បន្ទាប់ពីបារាំងបានមកដាក់អាណាព្យាបាលនាស.វ. ទី១៩ វិស័យអប់រំកម្ពុជាត្រូវបានធ្វើការកែទម្រង់នៅដើមស.វ.ទី២០។ ការធ្វើកំណែទម្រង់នេះគេបានបង្កើតសាលាផ្លូវការដែលមានកម្រិតសិក្សាចាប់ពីសាលាបឋមសិក្សា មធ្យមសិក្សារហូតដល់ការអប់រំឧត្តម សិក្សា។

ពីមួយឆ្នាំទៅមួយឆ្នាំ សិស្សានុសិស្សដែលសិក្សានៅកម្រិតបឋមសិក្សាចេះតែកើនចំនួនច្រើនឡើងៗបានតម្រូវឱ្យរដ្ឋាភិបាលតាមរយៈក្រសួងអប់រំជាតិបង្កើតសាលាមធ្យមសិក្សា ដើម្បីទទួលយកសិស្សានុសិស្សដែលបញ្ចប់ថ្នាក់បឋមសិក្សានោះឱ្យចូលរៀនបន្តនៅថ្នាក់មធ្យមសិក្សា។ បន្ទាប់មកសិស្សដែលបានបញ្ចប់ការសិក្សានៅកម្រិតមធ្យមសិក្សាត្រូវបន្តការសិក្សារបស់ខ្លួននៅមហាវិទ្យាល័យ ហេតុនេះទើបមានការបង្កើតឱ្យមានការសិក្សានៅកម្រិតឧត្តម សិក្សា។ ក្រៅពីសិស្សដែលបន្តការសិក្សាកម្រិតឧត្តមសិក្សានៅក្នុងប្រទេស ក៏មានសិស្សខ្មែរទៅបន្តការសិក្សានៅបរទេសផងដែរ ជាពិសេសគឺពួកគេទៅបន្តការសិក្សានៅប្រទេសបារាំង។

ការអប់រំឧត្តមសិក្សាគឺជាការបណ្តុះបណ្តាលធនធានមនុស្សកម្រិតខ្ពស់ ដែលមានឯកទេស ឬ ជំនាញច្បាស់លាស់ និង មានសមត្ថភាពដើម្បីចូលរួមអភិវឌ្ឍប្រទេសជាតិឱ្យបានរីកចម្រើនថែមទៀត។ ការរៀបចំសង្គមមួយឱ្យមានភាពជឿនលឿន រឹងមាំ និង មាននិរន្តរភាពត្រូវពឹងផ្អែកទៅលើកត្តាធនធានមនុស្សប្រកបដោយសមត្ថភាព និង សីលធម៌តាំងពីកម្រិតបឋមរហូតដល់ឧត្តមសិក្សា។ ជានិច្ចកាលយើងទាំងអស់គ្នាត្រូវបន្តការគាំទ្រផ្នែកផ្លូវចិត្ត ព្រមទាំងជួយបង្កលក្ខណៈ និង ផ្តល់លទ្ធភាពដល់និស្សិតក្រីក្រ ដែលមិនមានឱកាសបន្តការសិក្សារបស់ពួកគេនៅកម្រិតឧត្តមសិក្សា។ ម្យ៉ាងទៀត ដើម្បីទទួលបាននូវចំណេះដឹងថ្មីៗមកជួយអភិវឌ្ឍប្រទេសជាតិនោះ យើងត្រូវបញ្ជូននិស្សិតឱ្យទៅសិក្សានៅបរទេស ជាពិសេសទៅសិក្សាចាប់យកជំនាញដែលឆ្លើយតបទៅនឹងតម្រូវការចំពោះមុខ និង ទៅថ្ងៃអនាគតរបស់កម្ពុជា ដូចជា ផ្នែកបច្ចេកវិទ្យា កសិកម្ម សំណង់ បរិស្ថាន ធនធានរ៉ែ ជាដើម។

## គន្ថនិទ្ទេស


### ឯកសារដើម

*១-រាជកិច្ចពិសេស ចេញផ្សាយ ថ្ងៃទី៣១ ខែមីនា ឆ្នាំ១៩៤៩*

*២-រាជកិច្ច ចេញផ្សាយ ថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៥៧*

*៣-រាជកិច្ច ចេញផ្សាយ ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ១៩៥៨*

*៤-រាជកិច្ច ចេញផ្សាយ ថ្ងៃទី១០ ខែតុលា ឆ្នាំ១៩៦៤*

*៥-រាជកិច្ច ចេញផ្សាយ ថ្ងៃទី២០ ខែមករា ឆ្នាំ១៩៦៥*

*៦-រាជកិច្ច ចេញផ្សាយ ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ១៩៦៧*

### ឯកសារស្នាដៃនិពន្ធ

*១-រាជបណ្ឌិតសភាកម្ពុជា **សន្និសីទជាតិស្តីពីការបណ្តុះបណ្តាលធនធានមនុស្សនៅកម្ពុជា តុល្យការ និង ចក្ខុវិស័យ*** ភ្នំពេញ ឆ្នាំ២០០០

២-មជ្ឈមណ្ឌលស្រាវជ្រាវអាស៊ី ***ប្រព័ន្ធអប់រំនៅក្នុងប្រទេសកម្ពុជា*** ឆ្នាំ២០១៨

៣-UNESCO, ***Policy Paper for Change and Development in Higher Education*** 1997.

៤-***Cambodia, a country study***, Federal Research Division Library of Congress, Edited by Russell R. Ross, December 1987, Third Edition, 1990.

# គុណតម្លៃនៃអំណាន

The Value of Reading

ដោយៈ **លោក ប៉ាន់ សំណាង**
*មន្ត្រីនាយកដ្ឋានវិទ្យាសាស្ត្រអប់រំ*
*វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*
*នៃរាជបណ្ឌិត្យសភាកម្ពុជា*

## ១.សេចក្តីផ្តើម

*បច្ចុប្បន្ន បច្ចេកវិទ្យាមានការរីកចម្រើនខ្លាំង សិស្សានុសិស្សមួយចំនួន មិនសូវមានការចាប់អារម្មណ៍ក្នុងការកាន់សៀវភៅទេ ដោយពួកគេចូលចិត្តកាន់ទូរសព្ទច្រើនជាង។ ការធ្វើអំណានសម្រាប់អ្នកសិក្សារៀនសូត្រ ជាការចាំបាច់បំផុត ដើម្បីទទួលបាននូវព័ត៌មានឬចំណេះដឹងថ្មីៗសម្រាប់ពួកគេ។ ការធ្វើអំណាន ជាដំណើរការយល់ដឹងដែលទាក់ទងនឹងនិមិត្តសញ្ញាចម្រុះមួយក្នុងការយល់ន័យសេចក្តីអ្វីមួយ ។ ការអាន ក៏ជាដំណើរការសកម្មនៃការបង្កើតអត្ថន័យនៃពាក្យ។ការអានដោយមានគោលបំណងជួយអ្នកអានឱ្យដឹកនាំព័ត៌មានឆ្ពោះទៅរកគោលដៅនិងផ្តោតការយកចិត្តទុកដាក់របស់ពួកគេ។[1] ទោះបីជាហេតុផលនៃការអានមានភាពខុសប្លែកគ្នាក៏ដោយ គោលបំណងចម្បង គឺដើម្បីយល់ពីអត្ថបទ។*

*ដើម្បីពង្រឹងនិងបណ្តុះទម្លាប់ការអាន ជំរុញនិងលើកកម្ពស់សមត្ថភាពអាន រាជរដ្ឋាភិបាលកម្ពុជាបានចេញអនុក្រឹត្យមួយស្តីអំពីទិវាជាតិអំណាន។នៅក្នុងអនុក្រឹត្យលេខ១៦០ អនក្រ.បករបស់រាជរដ្ឋាភិបាលចុះនៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៩ដោយត្រង់មាត្រា ១ចែង«ត្រូវកំណត់យកថ្ងៃទី១១ ខែមីនា រៀងរាល់ឆ្នាំជាទិវាជាតិអំណាននៃព្រះរាជាណាចក្រកម្ពុជា ដើម្បីបណ្តុះទម្លាប់អាន ជំរុញវប្បធម៌អាន លើកកម្ពស់សមត្ថភាពអាន និងការតែងនិពន្ធ រួមចំណែកការពារនិងពង្រឹងវប្បធម៌ខ្មែរ»។យោងតាមស្មារតីអនុក្រឹត្យនេះ ស្ថាប័នជាតិឬអង្គភាពនានា បានរួមគ្នាអនុវត្តយ៉ាងយកចិត្តទុកដាក់ ដូចជាថ្មីៗនេះ ក្រសួងវប្ប*

[1] https://study.com

ធម៌ និងវិចិត្រសិល្បៈ បានសហការជាមួយអង្គភាព អង្គការនានារួមគ្នាប្រារព្ធកម្មវិធីពិព័រណ៍សៀវភៅកម្ពុជា លើកទី៩ ឆ្នាំ២០២២ ក្រោមប្រធានបទ៖*មួយថ្ងៃអាន មួយថ្ងៃដឹង*ដែលប្រារព្ធនៅបណ្ណាល័យជាតិ ផ្តើមពីថ្ងៃទី៩ ដល់ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២២។

ការអាន គឺជាផ្នែកមួយនៃជីវិត។សង្គមមួយខ្លាំង គឺជាសង្គមដែលមានប្រជាជនអានច្រើន និងនិយម

ចូលចិត្តការសិក្សារៀនសូត្រជាប្រចាំ។[2]ការអានសៀវភៅដ៏អស្ចារ្យអាចផ្លាស់ប្តូរជីវិតរបស់អ្នក ជួយអ្នកដោះស្រាយបញ្ហា និងបង្កើនចំណេះដឹងរបស់អ្នក។ សៀវភៅ គឺជាកំណប់ទ្រព្យដ៏អស្ចារ្យ ដែលយើងអាចរៀន រីកចម្រើន បង្កើនជំនាញរបស់យើង អភិវឌ្ឍទេពកោសល្យថ្មីៗ និងសូម្បីតែការកម្សាន្តខ្លួនឯង។ តាមរយៈសៀវភៅ យើងអាចរៀនពីភាពបរាជ័យរបស់អ្នកដទៃ ដោយមិនចាំបាច់និយាយឡើងវិញនូវកំហុសរបស់គេ។ យើង អាចពង្រីកការយល់ដឹងរបស់យើង ពង្រីកគំនិតរបស់យើង អភិវឌ្ឍខ្លួនយើង និងក្លាយជាកំណែដ៏ល្អបំផុតសម្រាប់ខ្លួនយើងដែលអាចធ្វើទៅបាន។ដូច្នេះ យើងគ្រប់គ្នាត្រូវបណ្តុះទម្លាប់ស្រឡាញ់ការអាននិងខំធ្វើអំណានដើម្បីជាប្រយោជន៍នានាសម្រាប់ខ្លួនឯង គ្រួសារ និងសង្គមជាតិយើង។

# ២.ទិដ្ឋភាពទូទៅនៃការសិក្សា

## ២.១.ទិដ្ឋភាពទូទៅនៃអំណាន

ការអានសៀវភៅនីមួយៗ អ្នកត្រូវមានវត្ថុបំណងផ្ទាល់ខ្លួន មិនគួរអានដើម្បីតែអាន ឬចង់ឲ្យគេដឹងថាខ្លួនជាអ្នកចូលចិត្តអានសៀវភៅម្នាក់ដែរនោះទេ។មនុស្សមិនតិចទេដែលគ្មានវត្ថុបំណងច្បាស់

លាស់ក្នុងការអានសៀវភៅ ពួកគេឃើញគេអាន ក៏អាននឹងគេដែរទៅ ឃើញគេទិញសៀវភៅហ្នឹង ក៏ទិញតាមគេដែរទៅ ឬទិញដោយសារខ្លួនចូលចិត្តអ្នកនិពន្ធជាដើម។ ប្រសិទ្ធភាពនៃការអាន គឺត្រូវដឹងខ្លួនឯងថាតើអ្នកចង់ដឹងពីអ្វីខ្លះ? ចង់ដឹងពីសេដ្ឋកិច្ច? ឬហិរញ្ញវត្ថុ? ឬជាភូមិសាស្ត្រនយោបាយ? ឬមួយច្បាប់? ឬក៏ភាពជាអ្នកដឹកនាំ?... នៅពេលដែលអ្នកដឹងថាខ្លួនត្រូវការចង់ដឹងពីអ្វីហើយ ស៊ីមទិញសៀវភៅដែលនិយាយពីនោះយកមកអាន។

ចំពោះក្រសួងអប់រំដែលជាសេនាធិការរបស់រាជរដ្ឋាភិបាល បានខិតខំខ្លាំងក្លាណាស់ក្នុងការពង្រឹងគុណភាពអប់រំតាមរយៈការអាន ពិសេសតាំងពីឆ្នាំ២០១០ បានចាប់ផ្តើមកែលម្អសៀវភៅភាសាខ្មែរអានសរសេរថ្នាក់ទី១ដល់ទី៣ ។ សៀវភៅអាន-សរសេរថ្នាក់ទី១ដែលបាន អភិវឌ្ឍថ្មីត្រូវបានដាក់ឱ្យប្រើប្រាស់ជាទូទៅ នៅតាមសាលាចំណេះទូទៅក្នុងឆ្នាំ២០១១ ។[3]

[2] ដកស្រង់ពីសៀវភៅអំណាន ជាអំណាច របស់អ្នកនិពន្ធ ឡាំ លីម ២០២០

[3] ក្រសួងអប់រំ សៀវភៅស្តង់ដារអំណានថ្នាក់ទី១ ទំព័រ ឆ្នាំ២០១៤

ស្ថាប័ននេះ បានចងក្រងសៀវភៅស្តង់ដារអំណានសម្រាប់គ្រូបង្រៀនបង្ហាត់បង្ហាញសិស្សានុសិស្សជាហូរហែរ។

ទិដ្ឋភាពក្នុងដំណើរការអានមាន 5 យ៉ាង៖ សទ្ទវិទ្យា សូរវិទ្យា វាក្យសព្ទ ការយល់ដឹង និងភាពស្ទាត់ជំនាញ[4]។ ទិដ្ឋភាពទាំងប្រាំនេះធ្វើការរួមគ្នា ដើម្បីបង្កើតបទពិសោធន៍នៃការអាន។ នៅពេលដែលកុមាររៀនអាន ពួកគេត្រូវតែអភិវឌ្ឍជំនាញក្នុងផ្នែកទាំងប្រាំនេះ ដើម្បីក្លាយជាអ្នកអានដ៏ជោគជ័យ។[5] ការអានសៀវភៅ នឹងបង្រៀនអំពីប្រវត្តិសាស្ត្ររបស់មនុស្ស ទីកន្លែង និងព្រឹត្តិការណ៍។ បើអ្នកអាណាព្យាបាលឬឪពុកម្តាយ ចូលរួមជួយកូនៗពួកគាត់ដោយណែនាំកូនៗរៀនធ្វើអំណានតាមផ្ទះ នោះវាជាវិធីល្អមួយដែលបណ្តុះទម្លាប់កូនចូលចិត្តសៀវភៅនិងការអាន។

ដូចនេះ ដើម្បីកសាងទម្លាប់ល្អនិងមានប្រសិទ្ធិភាពក្នុងការធ្វើអំណាន មាតាបិតាឬអ្នកអាណាព្យាបាលត្រូវផ្តើមមុនគេ ពោលគឺជាបុព្វាចារ្យដំបូងបំផុតសម្រាប់កូនៗឬចៅៗនៅតាមផ្ទះ។

## ២.២.តើការសិក្សាជាអ្វី?

ការសិក្សា ត្រូវនឹងពាក្យជាភាសាអង់គ្លេស«learning និង study»ដែលមានន័យថា«ការលះបង់ពេលវេលា និងការយកចិត្តទុកដាក់ក្នុងការទទួលបានចំណេះដឹងអំពីមុខវិជ្ជាសិក្សា ជាពិសេសតាមរយៈសៀវភៅ (the devotion of time and attention to gaining knowledge of an academic subject, especially by means of books.)[6]។ ចំណេះដឹងដែលទទួលបានតាមរយៈការសិក្សា បទពិសោធន៍ ឬការបង្រៀន គឺមានភាពរឹងមាំ។ ការរៀនសូត្រ គឺជាដំណើរការបញ្ចូលព័ត៌មានតាមរយៈចំណេះដឹងបច្ចេកទេស ឬជំនាញថ្មីៗ។ ក្នុងន័យនេះការរៀនសូត្រមាន ទទួលបានដំណើរការយល់និងអនុវត្តព័ត៌មាន ដែលយើងត្រូវបានបង្រៀន ឬក៏ទទួលបានបទពិសោធន៍តាមរយៈស្ថានភាពជាក់ស្តែងនៅក្នុងជីវិតរបស់យើង។ ដូច្នេះការរៀនសូត្រ អាចត្រូវបានគេសង្កេតឃើញទាំងមនុស្ស និងសត្វ។ ទោះយ៉ាងណាក៏ដោយ នៅពេលយើងនិយាយជាពិសេសពីមនុស្ស ការរៀនសូត្រគឺជាលទ្ធផលនៃដំណើរការនៃការសិក្សា បទពិសោធន៍ការបង្រៀនហេតុផលនិងការសង្កេត។ នៅពេលដែលដំណើរការនេះកើតឡើងក្នុងជីវិតដំបូងអំឡុងពេលសិក្សាការរៀនសូត្រ មិនត្រឹមតែទាក់ទងនឹងការទទួលបានចំណេះដឹងថ្មីៗប៉ុណ្ណោះទេ ប៉ុន្តែវាក៏ពាក់ព័ន្ធនឹងបញ្ហានេះដែរ ការកែប្រែឥរិយាបថ និងគុណតម្លៃទាក់ទងនឹងសង្គមដែលយើងរស់នៅ។

[4] ស្រង់ពីគេហទំព័រ https://www.chesterufsd.org

[5] ស្រង់ពីគេហទំព័រ https://www.chesterufsd.org

[6] Definition from Oxford languages

## ២.៣.បំណិនសំខាន់ៗក្នុងការសិក្សា

*សិស្សានុសិស្សម្នាក់ៗ មានវិធីផ្សេងៗគ្នាក្នុងការសិក្សារៀនសូត្រ។ បំណិនសំខាន់ៗក្នុងការសិក្សាមានដូចខាងក្រោម៖*

- **ការនិយាយ៖** *សកម្មភាពនៃការបញ្ជូនព័ត៌មាន ឬការបង្ហាញពីអារម្មណ៍របស់មនុស្សម្នាក់នៅក្នុងសម្តី[7]មនុស្សយើងម្នាក់ៗ មុននឹងឈានទៅចេះដឹងពីបំណិនអ្វីមួយពីពិភពខាងក្រៅ ដំបូងគឺពួកគេត្រូវចេះនិយាយជាមុនដែលជាភាសាកំណើត ។នេះ ជាធម្មៈមួយទាក់ទងនឹងជីវិតដែលសិស្សានុសិស្សត្រូវទទួលស្គាល់ និងប្រើវាឱ្យមានប្រយោជន៍ក្នុងការសិក្សា និងជីវិតប្រចាំថ្ងៃ។ខាងក្រោមនេះជាគុណប្រយោជន៍សំខាន់ៗនៃការនិយាយ[8]៖*

1. ***ការនិយាយនាំមកនូវឱកាស***

   *តើអ្នកធ្លាប់មានបទពិសោធន៍នៃការស្តាប់វាគ្មិនដែលបំផុសគំនិតទេ? តើអ្នកបានស្តាប់នរណាម្នាក់ដែលធ្វើឱ្យអ្នកចង់ដើរតាមពួកគេដល់ចុងផែនដីទេ? គម្រោងដ៏អស្ចារ្យភាគច្រើនបានកើតឡើងដោយសារតែមាននរណាម្នាក់ នៅកន្លែងណាមួយជាអ្នកនិយាយបញ្ចុះបញ្ចូល។ សមិទ្ធិផលអាជីពភាគច្រើនទាមទារឱ្យយើងចងគ្នាជាក្រុម(Team)។*

2. ***ការនិយាយនាំមកនូវការយល់ចិត្ត***

   *ការនិយាយក៏អាចមានសារៈសំខាន់ជាមួយគ្រួសារផងដែរ។ តើអ្នកធ្លាប់មានក្មេងជំទង់ដែលមិនចេះនិយាយដែលសេពគប់ជាមួយហ្វូងមនុស្សខុសដែរឬទេ? ឬមានអ្នកណាម្នាក់ក្នុងគ្រួសារដែលធ្វើអ្វីដែលបំផ្លាញខ្លួនឯង? វាមានប្រយោជន៍ណាស់ក្នុងការប្រើជំនាញនិយាយរបស់អ្នក ដើម្បីដោះស្រាយស្ថានការណ៍ដោយយល់ចិត្ត។*

3. ***ការនិយាយធ្វើឱ្យយើងមានសុខភាពល្អ***

   *អសមត្ថភាពក្នុងការប្រាស្រ័យទាក់ទងជាមួយអារម្មណ៍របស់យើងគឺមានការខកចិត្ត និងតានតឹង។ ជារឿយៗ វាអាចបន្ថែមទៅលើស្ថានភាពតានតឹងរួចទៅហើយ។ ប្រសិនបើអ្នកអាចបញ្ចេញអារម្មណ៍*

[7] The action of conveying information or expressing one's feelings in speech.

[8] https://www.juliantreasure.com

របស់អ្នកបាន អ្នកអាចបញ្ចេញអារម្មណ៍របស់អ្នកតាមរបៀបសមហេតុផល។ តើអ្នកបានជួបប្រយោគថា « **ពេលដែលអ្នកធ្វើនោះ ខ្ញុំមានអារម្មណ៍នេះ**» ទេ? វាជាឧទាហរណ៍ដ៏ល្អដែលមានសុវត្ថិភាព ដែលជាវិធីបង្ហាញអារម្មណ៍ដោយមិនចាំបាច់ស្រែក។ យើងអាចបង្ហាញពីខ្លួនយើង ហើយបន្តទៅមុខទៀត។

4. **ការនិយាយធ្វើឱ្យយើងឮ**

ការនិទានរឿង គឺជារឿងមួយដែលជួយបានច្រើន។វា ជាមធ្យោបាយដ៏មានអានុភាពក្នុងការទទួលបានចំណុចល្អឬអាក្រក់របស់អ្នកនៅក្នុងវិធីណាមួយដែលចាប់អារម្មណ៍។ មនុស្សចូលចិត្តស្តាប់ បើអ្នកនិយាយប្រកបដោយសិល្បៈ សំឡេងឮច្បាស់ និងភាពប៉ិនប្រសប់។

ការនិយាយ មានលទ្ធផលអស្ចារ្យ។ វាគឺជាជំនាញបំប្លែង និងជាជំនាញមួយដែលអ្នកអាចរៀន។ ដូច្នេះ ហើយទើបតាមសាលា តាមវគ្គសិក្ខាសាលាឬវេទិកាណាមួយ មានការបណ្តុះបណ្តាលពីមេរៀននានាទាក់ទងនឹងការនិយាយ ទោះបីយើងកើតមកចេះនិយាយក៏ដោយ។

- **ការស្តាប់៖** ការយកចិត្តទុកដាក់ចំពោះសំឡេង ឬសកម្មភាព។ នៅពេលស្តាប់ មនុស្សម្នាក់បានឮនូវអ្វីដែលអ្នកដទៃកំពុងនិយាយ ហើយព្យាយាមយល់ពីអត្ថន័យរបស់វា។ សកម្មភាពនៃការស្តាប់ពាក់ព័ន្ធនឹងដំណើរការស្មុគ្រស្មាញ ការយល់ដឹង និងអាកប្បកិរិយាផ្សេងៗ។ម្យ៉ាងទៀត យើងក៏អាចនិយាយបានថា ការស្តាប់ ជាសមត្ថភាពមួយដែលជាការយកចិត្តទុកដាក់ទៅលើសំឡេងនិងបកស្រាយប្រកបដោយប្រសិទ្ធភាពនូវអ្វីដែលមនុស្សនិយាយ(Listening is the ability to pay attention to and effectively interpret what other people are saying.)[9]។ការស្តាប់ពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណសំឡេងនៃការនិយាយ និងដំណើរការវាទៅជាពាក្យ និងប្រយោគ។អត្ថប្រយោជន៍នៃការស្តាប់ គឺទូលំទូលាយ និងមានថាមពលខ្លាំង។ គឺមានតែការស្តាប់ប្រកបដោយប្រសិទ្ធភាពប៉ុណ្ណោះ ទើបអ្នកអាចយល់ពីអ្នកដទៃបាន បង្កើន

[9] Oxford Dictionary of English

ទំនាក់ទំនងល្អ បញ្ចុះបញ្ចូល ចែករំលែក មានភាពដឹកនាំនិងលើកទឹកចិត្តក្រុម ឬក៏រៀនពីអ្នកដទៃប្រកបដោយប្រសិទ្ធភាព ។ ការស្តាប់ គឺជាការចូលទៅកាន់លទ្ធផលដែលចង់បាន ហើយវាជាគន្លឹះសម្រាប់សុខុមាលភាពរបស់យើង។

- **ការអាន៖** ការបកស្រាយជាក់លាក់នៃអត្ថបទឬស្ថានភាព។ការអាន ជាសមត្ថភាពក្នុងការមើល និងយល់អត្ថន័យនៃបញ្ហាក្នុងអត្ថបទឬសៀវភៅ។អំណាន គឺជាការមើលឬការថាតាមអក្សរ [10]។ ម្យ៉ាងទៀត ក៏មានការលើកឡើងថា អំណានជាទម្រង់នៃការកសាងអត្ថន័យចេញពីអត្ថបទ ។ វាជាជំនាញស្មុគស្មាញមួយដែលទាមទារឲ្យមានការសម្របសម្រួលប្រភពទាក់ទងគ្នាទៅវិញទៅមកនៃព័ត៌មាន ។
- **ការសរសេរ៖** សកម្មភាពកត់ត្រាឬសរសេរអត្ថបទ។ការសរសេរ គឺជាដំណើរការនៃការប្រើប្រាស់និមិត្តសញ្ញា (អក្ខរក្រម វណ្ណយុត្តិ និងដំណកឃ្លា) ដើម្បីទំនាក់ទំនងគំនិត និងគំនិតក្នុងទម្រង់ដែលអាចអានបាន។( Writing" is the process of using symbols (letters of the alphabet, punctuation and spaces) to communicate thoughts and ideas in a readable form.)[11]។វា ក៏ជាសកម្មភាពនៃការសិក្សាពីផ្លូវចិត្ត សតិអារម្មណ៍ ផ្សារភ្ជាប់នឹងប្រព័ន្ធភ័យខ្លាចក្នុងការគិត ដែលពាក់ព័ន្ធនឹងដំណើរការនៃការយល់ដឹង និងរាងកាយ និងការប្រើប្រាស់ប្រព័ន្ធសរសេរ ដើម្បីកំណត់រចនាសម្ព័ន្ធ និងបកប្រែគំនិតរបស់មនុស្សទៅជាតំណាងជាប់លាប់នៃភាសាមនុស្ស។[12]

## ២.៤.ការសិក្សាទ្រឹស្តីផ្សារភ្ជាប់នឹងការអនុវត្ត

ការសិក្សាដោយលើកយកទ្រឹស្តីមកបង្ហាញដោយគ្មានការអនុវត្តជាក់ស្តែង នោះវាក៏គ្មានប្រសិទ្ធភាព និងប្រសិទ្ធផលទេ ពោលគឺទ្រឹស្តីត្រូវផ្សារភ្ជាប់នឹងការអនុវត្ត។ដូចគ្នានេះដែរ **ខុងជឺ**(Confucius)ក៏ធ្លាប់លើកឡើងថា«រៀនដោយគ្មានការគិតគឺគ្មានប្រយោជន៍»។ ចំពោះលោក**អាញស្តាញ**(Albert Einstein)ក៏យល់ស្រដៀងគ្នានេះដែរថា«មនុស្សណាដែលអានច្រើន ហើយប្រើខួរក្បាលតិច នឹងធ្លាក់ក្នុង

[10] សម្តេចព្រះសង្ឃរាជ ជួន ណាត វចនានុក្រមខ្មែរ ១៩៦៧

[11] https://www.englishclub.com

[12]Writing is a neuropsychological activity involving cognitive and physical processes and the use of writing systems to structure and translate human thoughts into persistent representations of human language

ទម្លាប់ខ្ជឹលគិត»។ដូច្នោះ អ្នកចេះ ធ្វើអំណានត្រូវយល់ពីវិធីអាននិងសៀវភៅដែលគួរអាន។ខាងក្រោម ជាកម្រងទ្រឹស្តីដែលទាមទារនូវការអនុវត្តៈ

**ក-តើអំណាន ជាអ្វី**?

អំណាន ជាបំណិនមួយក្នុងចំណោមជំនាញសំខាន់ៗដែលលើកឡើងមកខាងលើ។និយាយដល់ពាក្យ"អំណាន"អ្នកណាក៏តែងតែស្គាល់និងធ្លាប់ឮវាជារៀងរាល់ថ្ងៃ ។ ប៉ុន្តែ បើយើងក្រឡេកទៅរកការផ្តល់និយមន័យ គឺមិនសូវជាមានការបកស្រាយច្រើនទេ ។ ខាងក្រោមជានិយមន័យនៃអំណានៈ[13]

1. អំណាន ជាទម្រង់នៃការកសាងអត្ថន័យចេញពីអត្ថបទ ។ វាជាជំនាញស្មុគស្មាញមួយដែលទាមទារឲ្យមានការសម្របសម្រួលប្រកពទាក់ទងគ្នាទៅវិញទៅមកនៃព័ត៌មាន ។

2. អំណាន ជាទម្រង់ចំណេះដឹងនៃការទាញយកអត្ថន័យពីអត្ថបទដែលបានសរសេរឬបោះពុម្ពផ្សាយ ។

3. អំណានជាទម្រង់នៃការចងចាំនិងការយល់អត្ថន័យនៃគំនិតឬព័ត៌មានដែលបានរក្សាទុកមក ។

4. អំណាន គឺជាទម្រង់ទទួលដឹងឮដ៏ស្មុគស្មាញមួយដែលទាក់ទងដល់ការបកស្រាយអក្សរឬនិមិត្តសញ្ញាសម្ងាត់ក្នុង បំណងស្ថាបនា ទាញយកអត្ថន័យពីអក្សរ និមិត្តសញ្ញាទាំងនោះ ។ វាជាចំណែកដ៏សំខាន់មួយនៃជីវិតប្រចាំថ្ងៃរបស់មនុស្ស ហើយវាក៏មានសមត្ថភាពជួយយើងក្នុងការធ្វើអន្តរកម្ម និងការយល់ដឹងពីពិភពនានាដែលកំពុងនៅជុំវិញខ្លួន យើង ។ អ្នកអានទាំងឡាយអាចនឹងប្រើចំណែកដ៏ស្ទួចស្ទើងបំផុតនៃភាសាដែលមានអត្ថន័យដោយខ្លួនឯង ជាជាងពាក្យឬផ្នែករបស់ពាក្យ ការសិក្សាអត្ថន័យទាំងឡាយក្នុងភាសា និងលំដាប់ពាក្យក្នុងលំដាប់ណាមួយ ព្រមទាំងស្វាក ស្នាមបរិបទ (អត្ថបទទាំងមូលដែលនៅពីមុខឬពីក្រោយប្រយោគឬសំនួនសេចក្តីមួយ) ដើម្បីស្គាល់អត្ថន័យ ពាក្យទាំង ឡាយដែលមិនស្គាល់ ។ វិធីសាស្ត្រអំណានទាមទារឲ្យបន្តការអនុវត្ត ការអភិវឌ្ឍក៏ដូចជាការធ្វើកាន់ តែប្រសើរឡើងខាងការយល់ដឹង ។

5. អំណាន គឺជាជំនាញឬសកម្មភាពនៃការទទួលព័ត៌មានចេញពីសៀវភៅឬឯកសារនានា ។

6. អំណាន គឺជាឱកាសនៅពេលដែលអ្វីមួយដែលគេបានសរសេរជាពិសេសទាក់ទងនឹងកិច្ចការ

[13] ដកស្រង់ពីហ្វេសប៊ុកផេកៈSmaradey Khmer: Preserving Khmer Values and Pride.

*អក្សរសាស្ត្រដែលត្រូវបានគេនិយាយទៅកាន់អ្នកស្តាប់ ។*

7. *អំណាន គឺជារបៀបនៃការយល់ដឹងពីអ្វីមួយដែលគេបានសរសេរ ចង់ប្រាប់ ចង់បង្ហាញ ។*

8. *អំណាន គឺជាការមើលឬការថាតាមអក្សរ ។*

9. *អំណាន គឺជាការស្វែងយល់ ការដុះខាត់គំនិត ការយល់ដឹងពីគំនិតដែលគេបានសរសេរឬបានគូសវាសប្រាប់ឲ្យមានភាពភ្លឺថ្លានៅក្នុងខ្លួន(ខួរក្បាល-អារម្មណ៍)របស់អ្នកទទួល(អ្នកអាន)។*

**ខ-វិធីសាស្ត្រអានសៀវភៅប្រកបដោយប្រសិទ្ធភាព**

*នៅក្នុងបណ្តាប្រទេសជឿនលឿនសព្វថ្ងៃនេះ ចំណេះដឹង គឺជាស្នូលសំខាន់សម្រាប់បុគ្គលគ្រប់រូបក្នុងការយកទៅប្រើប្រាស់ ដើម្បីអភិវឌ្ឍខ្លួនឯង ក៏ដូចជាសង្គមជាតិទាំងមូល។ក្នុងនោះផងដែរ ចំណេះដឹងផ្សេងៗដែលយើងគ្រប់រូបសិក្សាអាចបានមកពីជីវិតនៃការរស់នៅប្រចាំថ្ងៃរបស់យើង សង្គមខាងក្រៅ មនុស្សដែលនៅជុំវិញខ្លួនយើង រួមទាំងការសិក្សានៅសាលារៀនផងដែរ ហើយអ្វីដែលសំខាន់បំផុតដែលយើងគ្រប់រូបមិនអាចមើលរំលងបាននោះ គឺការអានសៀវភៅ។ប៉ុន្តែទាក់ទងនឹងការអានសៀវភៅនោះ អ្នកសិក្សាខ្លះ បានត្អូញត្អែរដោយលើកឡើងថា មិនដឹងត្រូវអានសៀវភៅប្រភេទណាទេ ព្រោះរាល់ពេលអានសៀវភៅតែងតែងងុយគេង អានមិនចូលឬក៏អានមិនចាំជាដើម។តទៅនេះ ជាបែបបទនៃការអានសៀវភៅដោយមានគោលបំណងច្បាស់លាស់និងជាក់លាក់៖*

1. ***បែបបទទូទៅនៃការអានសៀវភៅ***
   - ***អានត្រួសៗ*** *(អានចំណង់ជើងរង និយមន័យ អានដើម្បីកំសាន្ត...)ការអានបែបនេះគឺមានគោលបំណងស្វែងយល់ពីប្រធានបទណាមួយដែលយើងបានរៀបចំទុកជាមុន (សម្រាប់សរសេររបាយការណ៍ឬសារណា)ដើម្បីបានឯកសារបន្ថែម គំនិតថ្មីៗបន្ថែមជាដើម...។*
   - ***អានទាំងអស់ តែមិនស៊ីជម្រៅ*** *(ប្រធានបទថ្មី សៀវភៅធ្លាប់អានហើយ...)ការអានបែបនេះ គឺមានគោលបំណងដើម្បីយល់ពីខ្លឹមសារទូទៅ អានមិនរំលងទំព័រទេ តែក៏មិនតម្រូវឱ្យអានយល់ទាំងអស់នោះដែរ ដោយមិនចាំបាច់វិភាគនោះទេ។*
   - ***អានស៊ីជម្រៅដោយត្រិះរិះ ពិចារណា និងវិភាគ*** *(សៀវភៅដែលសំខាន់ត្រូវនឹងជំនាញរបស់យើង)ការអាននេះមានសារៈសំខាន់ណាស់សម្រាប់ការរៀនដោយខ្លួនឯង។*

- **អានបែបអសកម្ម**(Passive)វាស្រដៀងគ្នានឹងអានទាំងអស់ តែមិនស៊ីជម្រៅដែរ។វា ជាការអានតាមការណែនាំរបស់អ្នកនិពន្ធ។
- **អានបែបសកម្ម**(Active) វាជាការអានផង វិភាគផងដោយពេលខ្លះស្វែងរកឯកសារមកផ្ទៀងផ្ទាត់ទៀតផង។[14]

2. **ចំណុចសំខាន់ៗដែលត្រូវយកចិត្តទុកដាក់ពេលធ្វើអំណាន**
   - អានតាមរយៈការប្រើភ្នែក និងខួរក្បាល មិនមែនអានតែមាត់ទេ
   - កុំអានដដែលៗច្រើនដងពេក
   - ធ្វើចលនាភ្នែកតាមទិសអំណាន
   - អានតាមស្ថានភាពជាក់ស្តែង
   - ពេលអានត្រូវស្វែងយល់ឃ្លានីមួយៗ មិនមែនតាមពាក្យទេ
   - អានរួចចេះសង្ខេប
   - អានរួចត្រូវចេះកត់ត្រា
   - អានរួចត្រូវចេះហាយឡាយចំណាំ
   - ចម្លងនូវអ្វីដែលអ្នកគិតថាមានលក្ខណៈវិទ្យាសាស្ត្រ

## ៣.គុណតម្លៃនៃអំណាន

យើង មិនដឹងពីវិធីសាស្ត្រនៃការអានទេនោះ វាប្រៀបដូចជាមនុស្សដែលចង់បានផលស្រូវពីការធ្វើស្រែ ប៉ុន្តែបែរជាមិនដឹងថាដីប្រភេទណាទើបអាចដាំដុះស្រូវបាននោះ ដូចជាទៅដាំលើដីចំការ ដីទួល គេនឹងខកចិត្តនិងខាតកម្លាំងព្រមទាំងពេលវេលាឥតអំពើទៅការចង់បាននោះ។ ការអានសៀវភៅក៏ដូចគ្នាដែរ ប្រសិនបើអ្នកចង់បានលទ្ធផលតែមួយមុខគឺមិនគ្រប់គ្រាន់នោះទេ អ្នកត្រូវដឹងវិធីសាស្ត្រនៃការអាន និងសៀវភៅដែលគួរអានផងដែរ ទើបអ្នកអាចទៅដល់គោលដៅដែលអ្នកចង់បានពីការអាននោះ។

នៅទំព័រខាងលើ យើងបានលើកយកវិធីអានប្រកបដោយប្រសិទ្ធភាពរួចមក តែយើងនៅមិនទាន់ដឹងថា សៀវភៅប្រភេទណាដែលជួយយើងចំគោលដៅដែលចង់បាន។ប៉ុន្តែយើងក៏ត្រូវសួរខ្លួនឯងដែរថា តើយើងចង់ដឹងពីអ្វី?ចង់ដឹងពីសេដ្ឋកិច្ច? ឬហិរញ្ញវត្ថុ? ឬថាភូមិសាស្ត្រនយោបាយ? ឬមួយច្បាប់? ឬក៏

[14] ដកស្រង់ពីហ្វេសប៊ុកផេក៖ Lima Angkor RCRC

ភាពជាអ្នកដឹកនាំ?... នៅពេលដែលយើងដឹងថាខ្លួនយើងត្រូវការចង់ដឹងពីអ្វីហើយ សឹមធ្វើអំណានសៀវភៅនោះៗចំណុចនេះ មានន័យថា យើងអានចំប្រភេទសៀវភៅដែលមានប្រយោជន៍សម្រាប់ខ្លួនឯងនិងចំគោលដៅដែលចង់បានៗប៉ុន្តែពេលខ្វះ យើងគិតថាការអានសៀវភៅធ្វើឱ្យធុញនិងឥតប្រយោជន៍ តែតាមការពិតការអានសៀវភៅជួយយើងនិងមានសារៈសំខាន់ជាច្រើនៗ ការធ្វើអំណាន

ច្រើន ក៏អាចមានជួយអ្នកមានគំនិតថ្មីៗដោះស្រាយបញ្ហា និងបង្កើនការយល់ដឹងឱ្យរូបអ្នកសម្រាប់បម្រើដល់ជីវភាពប្រចាំថ្ងៃដែរៗ

សៀវភៅគឺជាទ្រព្យដ៏មានសារៈសំខាន់ដែលមានអត្ថប្រយោជន៍ជាច្រើនដែលគ្រប់គ្នាអាចចូលប្រើប្រាស់បានៗ អត្ថប្រយោជន៍ទាំងនេះ រួមមានៈ[15]

**1. បង្កើនសមត្ថភាពក្នុងការផ្តោតអារម្មណ៍**

យើងនឹងយល់ស្របថាការអានសៀវភៅតម្រូវឱ្យមានការផ្តោតអារម្មណ៍ និងការយកចិត្តទុកដាក់ច្រើនៗ តាមរយៈការអានសៀវភៅជាប្រចាំ អ្នកនឹងចាប់ផ្តើមពង្រឹងសមត្ថភាពរបស់អ្នកក្នុងការផ្តោតអារម្មណ៍ និងយកចិត្តទុកដាក់ចំពោះព័ត៌មានលម្អិតៗ ការផ្តោតអារម្មណ៍និងការផ្តោតអារម្មណ៍បានអនុម័តពី អានសៀវភៅ អាចត្រូវបានបញ្ជូនចូលទៅក្នុងទិដ្ឋភាពផ្សេងទៀតនៃជីវិតរបស់យើងៗ

**2. ពង្រីក និងកែលម្អវាក្យសព្ទ**

វាក្យសព្ទ គឺជាគុណសម្បត្តិមួយក្នុងចំណោមគុណសម្បត្តិជាច្រើននៃការអានសៀវភៅៗ វាក្យសព្ទដ៏អស្ចារ្យធ្វើឱ្យការនិយាយរបស់អ្នកប្រសើរឡើង ការទំនាក់ទំនងជាលាយលក្ខណ៍អក្សរៗ

នេះគឺដោយសារតែអ្នកបង្កើនសមត្ថភាពរបស់អ្នកដើម្បីបង្ហាញខ្លួនអ្នកឱ្យកាន់តែច្បាស់នៅពេលអ្នកបង្កើតពាក្យសម្តីរបស់អ្នកៗ សៀវភៅល្អអាចបង្ហាញអ្នកនូវពាក្យថ្មី កន្សោមពាក្យថ្មី និងវិធីថ្មីនៃការប្រើប្រាស់ពាក្យចាស់ៗ ចំណុចនេះ ក៏មានឥទ្ធិពលក្នុងការបង្កើនវាក្យសព្ទរបស់អ្នកផងដែរៗ

**3. ធ្វើឱ្យអ្នកកាន់តែមានភាពច្នៃប្រឌិត**

---

[15]https://worldscholarshub.com

ការច្នៃប្រឌិតត្រូវបានកំណត់ថាជាសមត្ថភាពក្នុងការអភិវឌ្ឍអ្វីដែលថ្មី ឬបង្ហាញពីការស្រមើស្រមៃរបស់មនុស្សម្នាក់។ ជាមួយនឹងសៀវភៅត្រឹមត្រូវ បុគ្គលម្នាក់ៗអាចជ្រើសរើសវិធីគិតថ្មី គំនិតថ្មី និងវិធីដោះស្រាយបញ្ហាកាន់តែប្រសើរ។ វាត្រូវបានគេជឿថាចិត្តរបស់យើងឆ្លើយតបទៅនឹងអ្វីដែលយើងអនុញ្ញាតឱ្យចូលទៅក្នុងពួកគេ។ ដូច្នេះហើយ ប្រសិនបើយើងអនុញ្ញាតឱ្យគំនិតច្នៃប្រឌិតពីសៀវភៅចូលទៅក្នុងគំនិតរបស់យើង យើងកាន់តែមានភាពច្នៃប្រឌិត និងស្វែងរកវិធីថ្មីៗដើម្បីបង្ហាញ និងស្វែងយល់ពីការស្រមើស្រមៃរបស់យើង។

### 4. សៀវភៅផ្តល់ការបំផុសគំនិត

វាត្រូវបានគេស្គាល់យ៉ាងច្បាស់ថាការបំផុសគំនិតអាចត្រូវបានរកឃើញនៅកន្លែងដែលមិនទំនងបំផុត។ទីតាំងគួរឱ្យអស់សំណើចមួយគឺនៅក្នុងទំព័រសៀវភៅ។គឺមានសៀវភៅជាច្រើនដែលមានប្រធានបទ និងមុខវិជ្ជាជាច្រើនអាចផ្តល់ឱ្យអ្នកនូវការបំផុសគំនិតច្រើនជាងអ្វីដែលអ្នកអាចប្រើប្រាស់ ឬរំពឹងទុក។ ការអានសៀវភៅត្រឹមត្រូវអាចផ្តល់ឱ្យអ្នកនូវការបំផុសគំនិតដែលមិនអាចកាត់ថ្លៃបានសម្រាប់ស្ថានភាពណាមួយ។

### 5.ផ្លាស់ប្តូរទស្សនៈ

អ្នកអាចផ្លាស់ប្តូរទស្សនៈរបស់អ្នក និងផ្លាស់ប្តូរវិធីដែលអ្នកគិតដោយគ្រាន់តែអានសៀវភៅល្អ ដែលអាចបង្កើតអារម្មណ៍ត្រឹមត្រូវ។ ការមើលគំនិតរបស់អ្នកនិពន្ធអាចជួយបង្កើតទស្សនៈរបស់អ្នកលើគំនិតជាក់លាក់មួយៗបទពិសោធន៍អាចផ្លាស់ប្តូរជីវិត។

មនុស្សជាច្រើនបានផ្តល់ទីបន្ទាល់អំពីសៀវភៅជាច្រើនដែលបានផ្លាស់ប្តូរជីវិតរបស់ពួកគេ និងទស្សនៈរបស់ពួកគេចំពោះជីវិត។ ការអានសៀវភៅអាចផ្តល់ឱ្យអ្នកនូវពេលវេលាដែលផ្លាស់ប្តូរអ្វីគ្រប់យ៉ាងសម្រាប់អ្នក។

### 6. សៀវភៅអាចធ្វើឱ្យអ្នកក្លាយជាមិត្ត

វិធីដ៏អស្ចារ្យមួយក្នុងការបង្កើតមិត្តថ្មីគឺការសន្ទនាជាមួយអ្នកដែលមានចំណូលចិត្តសៀវភៅដូចគ្នានឹងអ្នកដែរ។ អ្នកនឹងចាប់ផ្តើមចែករំលែកគំនិតរបស់អ្នកនៅលើសៀវភៅហើយយូរៗទៅ អ្នកនឹងកត់សម្គាល់ពីភាពខុសគ្នា ភាពស្រដៀងគ្នា ឬភាពស្របគ្នានៅក្នុងទស្សនៈរបស់អ្នក។នៅពេលអ្នកចែករំលែក

ចំណាប់អារម្មណ៍រួម នោះវាកាន់តែងាយស្រួលសម្រាប់អ្នកក្នុងការភ្ជាប់ទំនាក់ទំនង និងក្លាយជាមិត្ត។

### 7. វិធីដ៏ល្អមួយដើម្បីសម្រាក

អ្នកអាចបន្ធូរអារម្មណ៍របស់អ្នកជាមួយនឹងសៀវភៅដ៏ល្អមួយ។ មនុស្សភាគច្រើនយកប្រលោមលោក ដើម្បីគេចចេញពីការពិត ឬបង្កឱ្យមានអារម្មណ៍មួយចំនួនដែលអាចជួយឱ្យពួកគេសម្រាក។ បន្ទាប់ពីថ្ងៃដែលមានភាពតានតឹង អ្នកខ្លះទៀតចូលចិត្តចំណាយពេលសល់ពេញមួយថ្ងៃលើសៀវភៅដើម្បីបំបាត់ភាពតានតឹង និងបន្ធូរអារម្មណ៍។

### 8. សៀវភៅអាចផ្តល់នូវភាពសប្បាយរីករាយ

មនុស្សផ្សេងគ្នាមានវិធីផ្សេងគ្នានៃការសប្បាយ។ អ្នកខ្លះមើលឃើញភាពសប្បាយរីករាយដូចជាការរាំក្នុងពិធីជប់លៀង ការទៅលេងកន្លែងថ្មី អានសៀវភៅ និងសូម្បីតែប្រថុយប្រថាន។សៀវភៅដែលសរសេរបានត្រឹមត្រូវមានឥទ្ធិពលញៀនដែលធ្វើឱ្យអ្នកចាប់អារម្មណ៍និងចង់ដឹងចង់ដឹងបន្ថែមទៀត។ អ្នកចាប់អារម្មណ៍នឹងគេយ៉ាងខ្លាំង ទើបអ្នកទទួលបានការរីករាយពីគេ។ សៀវភៅល្អៗអាចកំដរអ្នក ធ្វើឱ្យអ្នកសើច ហើយថែមទាំងយកការស្រមើស្រមៃរបស់អ្នកទៅកាន់កន្លែងដែលពួកគេមិនធ្លាប់ទៅពីមុនមក។ សៀវភៅមនោសញ្ចេតនាជាឧទាហរណ៍ អាចធ្វើឲ្យទំនាក់ទំនងរបស់អ្នកប្រសើរឡើងជាមួយដៃគូរបស់អ្នក បង្រៀនអ្នកពីវិធីថ្មីដើម្បីភ្ជាប់ទំនាក់ទំនងជាមួយពួកគេជាដើម។

### 9. ជួយអាជីពអ្នកឱ្យប្រសើរឡើង

ប្រសិនបើអ្នកចង់ជោគជ័យក្នុងវិស័យណាមួយ អ្នកអាចសម្រេចបានដោយស្វែងរកសៀវភៅដែលអាចជួយអ្នកបង្កើនជំនាញ និងចំណេះដឹងរបស់អ្នកក្នុងវិស័យនោះ ។ ការស្វែងរកសៀវភៅបែបនេះ ហើយចំណាយពេលវេលារបស់អ្នកដើម្បីអាន និងអនុវត្តវាអាចជួយអ្នកឱ្យបង្កើតអាជីពដែលអ្នកចង់បាន។

### 10. កសាងវិន័យនៅក្នុងតំបន់ផ្សេងទៀតនៃជីវិត

អ្នកដឹកនាំគំនិតល្បីៗ ជាច្រើនបានផ្តល់កស្តុតាងថាការប្រៀនប្រដៅក្នុងផ្នែកមួយនៃជីវិតរបស់យើងអាចនាំឱ្យមានការប្រៀនប្រដៅក្នុងវិស័យផ្សេងទៀត។ប្រសិនបើនេះជា

ការពិត នោះការអានសៀវភៅអាចជួយអ្នកឱ្យកាន់តែមានវិន័យនៅក្នុងផ្នែកផ្សេងទៀតនៃជីវិតរបស់អ្នក។នៅពេលអ្នកបង្កើតទម្លាប់អានដ៏អស្ចារ្យ អ្នកក៏អាចចាប់ផ្តើមកត់សម្គាល់ពីវិន័យកាន់តែប្រសើរឡើងនៅក្នុងផ្នែកផ្សេងទៀតនៃជីវិតរបស់អ្នកផងដែរ។

### 11. ក្លាយជាអ្នកនិពន្ធកាន់តែប្រសើរ

អ្នកអានកាន់តែច្រើន អ្នកកាន់តែពង្រីកវាក្យសព្ទរបស់អ្នក ហើយអ្នកអាចបញ្ចេញគំនិតរបស់អ្នកកាន់តែប្រសើរ។ ការសរសេរត្រូវទាក់ទងនឹងសមត្ថភាពរបស់អ្នកក្នុងការរៀបចំគំនិតរបស់អ្នកឱ្យបានត្រឹមត្រូវ ហើយដាក់វាទៅជាពាក្យដែលអ្នកដទៃអាចយល់បាន។ ការអានស្នាដៃរបស់អ្នកដទៃជួយអ្នកឱ្យឃើញវិធីថ្មីៗដើម្បីចូលទៅជិត ការសរសេរនិងជំនាញសរសេរថ្មី។.

### 12. បង្រៀនអ្នកពីរបៀបក្លាយជាអ្នកមាន

វាស្ថិតក្នុងចំណោមប្រធានបទពេញនិយមបំផុតនៅលើអ៊ីនធឺណិតនាពេលបច្ចុប្បន្ននេះ។ គ្មានឆ្ងល់ទេថាមានសៀវភៅជាច្រើននៅលើប្រធានបទ និងអ្នកនិពន្ធជាច្រើនដែលមានឯកទេសខាងផ្នែកនេះ។ យ៉ាងណាក៏ដោយ អ្នកមិនអាចទម្លាក់អំណាចនៃសៀវភៅដើម្បីធ្វើឱ្យមនុស្សមានទ្រព្យសម្បត្តិបានឡើយ។ នេះក៏ដោយសារតែអ្នកមានទ្រព្យសម្បត្តិជាច្រើនបានបញ្ជាក់ថាសៀវភៅជាផ្នែកដ៏សំខាន់នៃការរីកចម្រើនទៅជាទ្រព្យសម្បត្តិ។ ពួកគេក៏ណែនាំសៀវភៅមួយចំនួនដែលផ្លាស់ប្តូរជីវិតរបស់ពួកគេទៅអ្នកដទៃ។

### 13. ប្រភពនៃការលូតលាស់ និងការអភិវឌ្ឍផ្ទាល់ខ្លួន

ការអានកាន់តែច្រើន អ្នកកាន់តែអភិវឌ្ឍគំនិតរបស់អ្នក និងកាន់តែមានភាពប្រសើរឡើងក្នុងនាមជាមនុស្ស។ មានសៀវភៅមួយចំនួនដែលចាត់ទុកថាជាសៀវភៅអភិវឌ្ឍន៍ខ្លួនឯង ឬសៀវភៅជួយខ្លួនឯង។ ការបោះពុម្ពទាំងនេះត្រូវបានសរសេរដោយអ្នកនិពន្ធតាមរដូវកាលដើម្បីជួយអ្នកអានក្នុងការកែលម្អការអភិវឌ្ឍន៍ផ្ទាល់ខ្លួនរបស់ពួកគេ។

### 14. បង្រៀនអ្នកពីរបៀបដើម្បីឱ្យកាន់តែមានផលិតភាព

អ្នកអាចរៀនពីរបៀបធ្វើឱ្យកាន់តែមានផលិតភាពពីសៀវភៅ។ ដូច្នេះសៀវភៅជាច្រើនត្រូវបានសរសេរអំពីផលិតភាព ការគ្រប់គ្រង

ពេលវេលា និងប្រធានបទផ្សេងទៀតដែលអាចបង្កើនផលិតភាពទូទៅរបស់អ្នក។ការអានសៀវភៅប្រភេទនេះ ផ្ដល់អត្ថប្រយោជន៍ជាច្រើន និងបង្រៀនអ្នកពីរបៀបក្លាយជាបុគ្គលដែលមានផលិតភាពកាន់តែច្រើន។

### 15. ក្លាយជាមនុស្សល្អ

នៅពេលដែលអ្នកមានផ្នត់គំនិតល្អ និងវិធីគិតកាន់តែប្រសើរ វាចាប់ផ្ដើមកំណត់ថាអ្នកក្លាយជានរណា។សៀវភៅអាចធ្វើវាសម្រាប់អ្នក ដោយផ្លាស់ប្ដូរផ្នត់គំនិតរបស់អ្នក និងផ្ដល់ឱ្យអ្នកនូវសមត្ថភាពក្នុងការស្វែងរកទិដ្ឋភាពថ្មីៗនៃខ្លួនអ្នកដែលអ្នកមិនធ្លាប់ដឹង។ សៀវភៅល្អគឺជាសេចក្ដីរីករាយសម្រាប់ព្រលឹង ហើយអាចផ្លាស់ប្ដូរអ្នកទៅជាកំណែប្រសើរជាងមុនសម្រាប់ខ្លួនអ្នក។

### 16. ធ្វើឱ្យអ្នកស្ងប់ស្ងាត់និងសន្តិភាព

នៅពេលដែលអ្នកបានស្ទាត់ជំនាញសិល្បៈនៃការផ្ដោតអារម្មណ៍ និងការផ្ដោតអារម្មណ៍ពីការអានសៀវភៅរបស់អ្នក នោះអ្នកអាចស្ងប់ស្ងាត់ និងផ្ដោតលើរឿងណាមួយនៅពេលណាមួយ។សៀវភៅត្រូវបានសរសេរអំពីភាពស្ងប់ស្ងាត់ សន្តិភាព និងសុភមង្គលហើយពួកវា ជួយបុគ្គលដែលធ្វើអំណាន និងអនុវត្តគោលការណ៍ដែលគេសរសេរ ដើម្បីសម្រេចបាន។

### 17. កែលម្អការស្រមើលស្រមៃ

ការស្រមើស្រមៃរបស់យើងអាចពង្រីកលើសពីអ្វីដែលយើងអាចមើលឃើញ ឬមានអារម្មណ៍។ យើងអាចចូលទៅក្នុងទស្សនៈរបស់អ្នកដទៃតាមរយៈសៀវភៅរបស់ពួកគេ ហើយចាប់ផ្ដើមមើលឃើញវត្ថុពីមុំ និងទំហំខុសគ្នា។សៀវភៅដ៏អស្ចារ្យអាចបើកចិត្តរបស់អ្នក ពង្រីកការស្រមើស្រមៃរបស់អ្នក និងនាំអ្នកទៅមើលពីបរិយាកាសរបស់អ្នកនូវអ្វីដែលមិនធ្លាប់ស្គាល់។

### 18. បង្កើនចំណេះដឹង

ចំណេះដឹងគឺជាថាមពល ហើយសៀវភៅល្អផ្ដល់ឱ្យយើងនូវចំណេះដឹងលើប្រធានបទផ្សេងៗ និងសាលានៃការគិត។ អ្នកអាចបង្កើនចំណេះដឹងរបស់អ្នកអំពីវិស័យណាមួយដោយគ្រាន់តែអានសៀវភៅលើប្រធានបទនោះ។ សៀវភៅជួយយើងរីកចម្រើនក្នុងផ្នែកជាច្រើននៃជីវិតរបស់យើង រួមទាំងចំណេះដឹងរបស់យើង។

## 19. សៀវភៅផ្តល់ឱ្យអ្នកនូវគំនិតថ្មីៗ

ប្រសិនបើអ្នកកំពុងស្វែងរកវិធីថ្មីដើម្បីចូលទៅជិតស្ថានភាពមួយ សូមរកមើលសៀវភៅដែលទាក់ទងនឹងស្ថានភាពនោះ ហើយអានវា។ អ្នកនិពន្ធបានចែករំលែកបទពិសោធន៍របស់ពួកគេនៅក្នុងសៀវភៅរបស់ពួកគេ រួមទាំងបញ្ហាដែលពួកគេជួបប្រទះ និងរបៀបដែលពួកគេអាចយកឈ្នះលើពួកគេ។ រឿង និងវិធីសាស្ត្ររបស់ពួកគេអាចផ្តល់ឱ្យអ្នកនូវគំនិតថ្មីៗ និងណែនាំអ្នកឱ្យដោះស្រាយបញ្ហាផ្ទាល់ខ្លួនរបស់អ្នក។

## 20. ជួយឱ្យអ្នកចងចាំ និងរៀនបានកាន់តែប្រសើរ

ការអានសៀវភៅជួយឱ្យអ្នកចងចាំបានលឿន និងរៀនបានកាន់តែល្អ ពីព្រោះអ្នកមានឱកាសផ្អាក និងឆ្លុះបញ្ចាំងពីអ្វីដែលអ្នកកំពុងអាន។ អ្នកកាន់តែយល់ដឹងអំពីជម្រើសនៃពាក្យរបស់អ្នកនិពន្ធ ហើយអ្នកអាចមើលឃើញយ៉ាងច្បាស់ពីរបៀបដែលពួកគេប្រើវា។ អ្នកអាចរៀនពាក្យថ្មី កែលម្អអក្ខរាវិរុទ្ធរបស់អ្នក និងពង្រីកចំណេះដឹងរបស់អ្នកដោយការអានសៀវភៅ។

## 21. សៀវភៅអនុញ្ញាតឱ្យអ្នកធ្វើងកាត់កេរដំណែលរបស់អ្នក

មនុស្សអស្ចារ្យមួយចំនួន បានបង្កើតទម្លាប់បង្កើតបណ្ណាល័យសៀវភៅសម្រាប់ខ្លួនឯង។ ជាធម្មតា សៀវភៅមួយចំនួនដែលពួកគេបានអានដែលបានកែប្រែជីវិតរបស់ពួកគេ ឬបង្រៀនពួកគេនូវព័ត៌មានថ្មីៗគឺស្ថិតនៅក្នុងបណ្ណាល័យនេះ។ ជាមួយនឹងវិធីសាស្ត្រនេះ ពួកគេអាចផ្តល់ធនធានដ៏មានតម្លៃដល់កូនៗរបស់ពួកគេ និង បង្កើតចំណាប់អារម្មណ៍យូរអង្វែង។

## 22. ស្វែងយល់អំពីប្រវត្តិសាស្ត្រ

ការអានសៀវភៅ នឹងបង្រៀនអ្នកអំពីប្រវត្តិសាស្ត្ររបស់មនុស្ស ទឹកដី និងព្រឹត្តិការណ៍ ដូចជារទេះរុញវា ហើយនាំអ្នកចុះពីផ្លូវប្រវត្តិសាស្ត្រ។ វាជាបទពិសោធន៍ដ៏ស្រស់ស្អាត។នៅពេលអ្នកអាន អ្នកទទួលបានឱកាសដើម្បីយកព័ត៌មានលម្អិតសំខាន់ៗអំពីជីវិតរបស់មនុស្ស ទីតាំងភូមិសាស្ត្រ និងព្រឹត្តិការណ៍ប្រវត្តិសាស្ត្រសំខាន់ៗផ្សេងទៀត។

## 23. ធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងសង្គម

ការស្រាវជ្រាវមួយ បានបង្ហាញថាការអានអក្សរសិល្ប៍ប្រឌិតអាចកែលម្អទ្រឹស្ដីនៃចិត្តរបស់មនុស្ស។ ទិដ្ឋភាពនេះ អាចមកពីការពិតនៅពេលដែលអ្នកអាន អាចចាប់យកអារម្មណ៍ថ្មី ឬយល់បានច្បាស់លាស់។ ជំនាញថ្មីទាំងនេះដែលអ្នកនឹងទទួលបានដោយការអានសៀវភៅពីរបីក្បាលអាចជួយអ្នកឱ្យប្រសើរឡើងនូវទំនាក់ទំនងសង្គម និងទំនាក់ទំនងរបស់អ្នកជាមួយមនុស្ស។

## 24. ពង្រឹងខួរក្បាល

ការស្រាវជ្រាវជាច្រើនបានផ្ដល់សុពលភាពដល់ការពិតដែលថាការអានអាចធ្វើឱ្យគំនិតរបស់យើងប្រសើរឡើង និងផ្ដល់ថាមពលដល់ខួរក្បាលរបស់យើង។ ការស្រាវជ្រាវដែលបានចេញផ្សាយនោះ បានព្យាយាមទាក់ទងការអានជាមួយនឹងការអភិវឌ្ឍរចនាសម្ព័ន្ធនៃខួរក្បាលរបស់យើង។ របាយការណ៍បាននិយាយថា ការអានប្រកបដោយជំនាញនឹងតម្រូវឱ្យអ្នកប្រើប្រាស់តំបន់មួយចំនួននៃខួរក្បាលរបស់អ្នក ដែលនឹងពង្រឹងបន្តិចម្ដងៗនូវវិធីដែលតំបន់ខួរក្បាលទាំងនេះទាក់ទងគ្នាទៅវិញទៅមកតាមពេលវេលា។

## 25. ជួយអ្នកយកឈ្នះលើជំងឺធ្លាក់ទឹកចិត្ត

ការធ្លាក់ទឹកចិត្តអាចកើតឡើងពីអារម្មណ៍នៃភាពគ្មានតម្លៃ ឬភាពឯកោ។ការអានសៀវភៅអាចជួយអ្នកឱ្យយកឈ្នះលើអារម្មណ៍បែបនេះដោយបង្កើតអារម្មណ៍ថ្មីសម្រាប់អ្នក។ សៀវភៅល្អអាចផ្ដល់ឱ្យអ្នកនូវភាពជាដៃគូ ជួយអ្នកសើច បំផុសគំនិតអ្នក និងថែមទាំងជួយអ្នកឱ្យឆ្ងាយពីជំងឺធ្លាក់ទឹកចិត្តដោយការលើកទឹកចិត្តអ្នក។

## 26. អាយុយឺនយូរ

ការសិក្សាមួយ បានបង្ហាញពីរបៀបដែលការអានសៀវភៅអាចផ្ដល់អត្ថប្រយោជន៍ដល់ការរស់រានមានជីវិតរបស់យើងក្នុងនាមជាមនុស្ស។ការសិក្សានេះគឺជាការស្រាវជ្រាវរយៈពេលវែងដែលមានរយៈពេល 12 ឆ្នាំជាមួយនឹងអ្នកចូលរួមចំនួន 3635 នាក់ដែលនឹងផ្ដល់ព័ត៌មានអំពីពួកគេ ទម្លាប់អាន និងទំនោររបស់ខ្លួនផ្ទាល់។លទ្ធផលនៃការសិក្សាបានបង្ហាញថា ការអានសៀវភៅអាចផ្ដល់អាយុវែងជាផ្នែកនៃអត្ថប្រយោជន៍របស់វា។

## 27. អាចជួយឱ្យអ្នកគេងលក់ស្រួលពេលយប់

គ្និនិក Mayo បានផ្តល់យោបល់ថា ការអានសៀវភៅមុនពេលអ្នកចូលគេងអាចជួយឱ្យអ្នកគេងលក់ស្រួល។ព្យាយាមបន្ថែមការអានទៅក្នុងទម្លាប់នៃការគេងរបស់អ្នក ហើយរកមើលការផ្លាស់ប្តូរដែលអាចកើតឡើង។

## 28. ទទួលយកវិធីថ្មីនៃជីវិត

យើងអាចរៀនអំពីវប្បធម៌របស់ប្រជាជនដោយគ្រាន់តែអានសៀវភៅដែលបង្រៀនអំពីពួកគេ។ មិនថាអ្នកមានអាយុ 50 ឆ្នាំឬ អាយុ 12 ឆ្នាំ ការអានសៀវភៅ គឺជាវិធីដ៏ល្អមួយដើម្បីទទួលយកវិធីថ្មីនៃជីវិត និងភ្ជាប់ជាមួយវប្បធម៌របស់អ្នកដទៃនៅក្នុងការកៀសខ្លួន។

មនុស្សជាច្រើនបានរៀនយ៉ាងច្រើនអំពីអ្នកដទៃពីសៀវភៅដោយមិនធ្វេងព្រំដែន។

## 29. រៀនពីអ្នកដទៃ

ការអានអាចផ្តល់ឱ្យអ្នកនូវឱកាសដ៏កម្រមួយក្នុងការទទួលបានការបណ្តុះបណ្តាល ឬការណែនាំពីអ្នកជំនាញ ឬថៅហ្វាយនាយ។ អ្នកអាចរៀនតាមព្យញ្ជនៈវិធីដើម្បីចូលទៅជិតវិស័យណាមួយនៃជីវិត ឬជំនាញដោយអានសៀវភៅរបស់អ្នកជំនាញណាម្នាក់។ តាមរយៈសៀវភៅ អ្នកក៏អាចទទួលបានបទពិសោធន៍ដោយមិនចាំបាច់ឆ្លងកាត់ស្ថានភាពដូចគ្នាដោយខ្លួនឯងដែរ។ សៀវភៅកុមារ និងមនុស្សពេញវ័យ អាចរកបានសម្រាប់គោលបំណងសិក្សា និងអាយុផ្សេងៗគ្នា។

## 30.ការកំសាន្ត

សៀវភៅដែលសរសេរបានយ៉ាងល្អគឺជាវិធីដ៏ល្អបំផុតមួយក្នុងការកម្សាន្ត។ អារម្មណ៍របស់អ្នកអាចត្រូវបានលាតសន្ធឹង ហើយចិត្តរបស់អ្នកបានបញ្ជូនទៅកាន់ការពិតថ្មី ប្រឌិតវិទ្យាសាស្ត្រ សៀវភៅកំប្លែងការស្រមើស្រមៃដាក់ឈ្មោះឱ្យពួកគេ អាចផ្តល់ឱ្យអ្នកនូវវិធីមួយជាការកំសាន្ត និងទទួលបាននូវភាពរីករាយនៅពេលអ្នកធ្វើដូច្នេះ។

ជាការពិតណាស់ ការអានមានថាមពល និងមានគុណតម្លៃយ៉ាងច្រើន។ជាក់ស្តែងលោកម៉ូរ៉ាយស៍ រ៉ូជ័រស៍ ជរ (Maurice Rogers Jr.) បានសរសេរសៀវភៅមួយក្រោមចំណងជើងថា«ថាមពលនៃអំណាន»(The Power of Reading)បានលើកឡើងថា«សៀវភៅអាចត្រូវបានប្រើជាឧបករណ៍ជាក់ស្តែងដើម្បីផ្លាស់ប្តូរផ្នែកណាមួយនៃជីវិតរបស់អ្នក»។គាត់ក៏បានសរសេរទៀតថា«ខ្ញុំបានសរសេរសៀវភៅនេះដើម្បីចែករំលែកពីរបៀបដែលពួកវាបានផ្តល់

ផលប្រយោជន៍ដល់ជីវិតរបស់ខ្ញុំ និងដើម្បីលើកទឹកចិត្តអ្នកដទៃឱ្យចូលរួមជាមួយខ្ញុំក្នុងដំណើរនៃការរីកចម្រើនផ្ទាល់ខ្លួនជាយុទ្ធសាស្ត្រពេញមួយជីវិត»( I wrote this book to share how they have benefited my life and to inspire others to join me on the journey of lifelong strategic personal growth. )។តាមការលើកឡើងនេះ យើងអាចនិយាយបានថា សៀវភៅពិតជាមានតម្លៃណាស់សម្រាប់អ្នកសិក្សាស្រាវជ្រាវ ក៏ដូចជាមនុស្សទូទៅដែរ បើយើងចេះប្រើប្រាស់វា។

## ៤.អំណាននិងបច្ចេកវិទ្យាទំនើប

បច្ចេកវិទ្យា មានការរីកចម្រើនខ្លាំងនាពេលបច្ចុប្បន្ននេះ ពិសេសបច្ចេកវិទ្យាទូរសព្ទ។ដោយបច្ចេកវិទ្យាទូរសព្ទនេះ ក្មេងៗឬសិស្សានុសិស្សមួយចំនួន លែងចង់កាន់សៀវភៅអាន ហើយអ្នកអាណាព្យាបាលខ្លះកសាងទម្លាប់លេងទូរសព្ទឱ្យកូនចៅខ្លួនតាំងពីកូននៅតូចៗ ដោយរវល់នឹងការងារ។ទិដ្ឋភាពនេះ មានន័យថាអ្នកអាណាព្យាបាលកំពុងបង្កើតទម្លាប់មិនល្អដល់កូនចៅរបស់ខ្លួន ហើយក៏ជាចំណុចមួយនាំឱ្យកូនៗមិនសូវចូលចិត្តសៀវភៅ។ប៉ុន្តែបើអ្នកអាណាព្យាបាល ជាអ្នកចាប់ផ្តើមធ្វើជាគំរូក្នុងការអានសៀវភៅ ដូចជាការអានរឿងនិទានអប់រំកុមារជាដើម នោះកូនចៅនឹងមើលឃើញ ហើយអាចចូលចិត្តនិងអនុវត្តតាម។

ម្យ៉ាងទៀត បច្ចេកវិទ្យាក៏ជួយអភិវឌ្ឍការអានផងដែរ។ដោយកំណើននិងការវិវឌ្ឍឥតឈប់ឈរ បច្ចេកវិទ្យាបានជួយផ្លាស់ប្តូរទម្លាប់នៃការអានយើងយ៉ាងច្រើនក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។[16]វា ជួយបន្តការអានដើម្បីស្វែងរកវិធីផ្សេងៗគ្នាជាច្រើនដែលមានក្នុងបច្ចេកវិទ្យា ពិសេសបច្ចេកវិទ្យាទូរសព្ទដែលជាមធ្យោបាយសាមញ្ញជួយដល់កុមារឬសិស្សានុសិស្សតូចៗ ។ គឺគ្មានអ្វីអាក្រក់ជាងការដឹងថាការភ្លេចសៀវភៅដែលយើងចូលចិត្តក្នុងអំឡុងពេលធ្វើដំណើរផ្លូវឆ្ងាយនោះទេ។ ប៉ុន្តែជាមួយនឹងការកើនឡើងយ៉ាងឆាប់រហ័សនៃវេទិកាអានឌីជីថល នេះមិនមែនជាបញ្ហាទូទៅសម្រាប់ការភ្លេចសៀវភៅទៀតនោះទេ។ គេបានបង្កើតកម្មវិធីមួយចំនួនដែលត្រូវបានរចនាឡើងដើម្បីសម្រួលដំណើរការនៃការអាននៅពេលធ្វើដំណើរ។ យើង អាច

[16] https://www.readersdigest.co.uk

ជ្រើសរើសសៀវភៅ តាមដានវឌ្ឍនភាពរបស់យើង និងថែមទាំងដាក់បញ្ជូនការវាយតម្លៃផងដែរ។ ការចូលរួមក្នុងសហគមន៍នៃមនុស្សរាប់លាននាក់ដែលមានគំនិតដូចគ្នាអាចលើកទឹកចិត្តអ្នកឱ្យអានកាន់តែច្រើន និងយូរអង្វែង។ ដោយមិនចាំបាច់ដើរជុំវិញសៀវភៅទេ អ្នកអានទំនងជាចង់ទៅយកកន្លែងដែលពួកគេបានទុកចោលគ្រប់ពេលវេលា និងគ្រប់ទីកន្លែងទាក់ទងនឹងបច្ចេកវិទ្យានេះ។ សៀវភៅអាចត្រូវបានទាញយកនៅលើកុំព្យូទ័រយួរដៃ ស្មាតហ្វូន ឬឧបករណ៍ឆ្លាតវៃរបស់យើងដែលធ្វើឱ្យវាកាន់តែងាយស្រួលជាងមុនក្នុងការទទួលបានទំព័រពីរបីនៅលើផ្លូវទៅធ្វើការ។[17]

## ការសន្និដ្ឋាន

ការធ្វើអំណាន ត្រូវអនុវត្តគ្រប់មនុស្សម្នាក់ៗ ពីព្រោះយើងម្នាក់ត្រូវឆ្លងកាត់កម្រិតនិងភូមិសិក្សាគ្រប់ៗគ្នាដែលជាកាតព្វកិច្ចចាំបាច់។ ផ្អែកតាមលទ្ធផលសិក្សារបស់សិស្សប៉ុន្មានឆ្នាំកន្លងមកនេះ យើងឃើញថា សិស្សបឋមសិក្សាមាន មូលដ្ឋាននៃការអាន និងសរសេរនៅមានកម្រិតទាបគួរឱ្យបារម្ភ។[18] នេះជាភូមិសិក្សាដំបូងបន្ទាប់ពីមត្តេយ្យសិក្សាដែលទាមទារឱ្យកុមារធ្វើអំណានបានច្រើន ដើម្បីទទួលបាននូវចំណេះដឹងថ្មីៗ ក្នុងការទប់ទល់នឹងពិភពខាងក្រៅ។អំណាន គឺជាមូលដ្ឋានគ្រឹះក្នុងការ ពង្រឹងគុណភាពអប់រំ ក្នុងការបន្តការសិក្សាទៅមធ្យមសិក្សា និងឧត្តមសិក្សា។[19]

ដោយមើលឃើញថា អំណាន ជាមូលដ្ឋានគ្រឹះ ទើបវិធីសាស្ត្របង្រៀនអំណានដំបូងត្រូវបានរៀបចំឡើងដើម្បីជួយគ្រូដឹកនាំការបង្រៀន និងរៀនកាន់តែសកម្ម។

ការអានសៀវភៅ អាចផ្លាស់ប្តូរជីវិតរស់នៅប្រចាំថ្ងៃរបស់មនុស្សយើងម្នាក់ៗបាន។តាមរយៈសៀវភៅ សិស្ស និស្សិត អ្នកសិក្សាស្រាវជ្រាវ បានទទួលនូវគំនិតថ្មី បទពិសោធន៍ថ្មី ការងារថ្មី ។ទន្ទឹមនឹងការអភិវឌ្ឍសភាពខាងក្រៅ អំណានក៏ជួយដល់សកម្មភាពផ្លូវចិត្ត ផ្លូវអារម្មណ៍កាន់តែប្រសើរជាងអ្នកមិន

17 https://www.readersdigest.co.uk

18 ក្រសួងអប់រំ សៀវភៅភាសាខ្មែរថ្នាក់ទី១ ឆ្នាំ២០១៧

19 ប្រសាសន៍ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ថ្លែងក្នុងឱកាសអញ្ជើញជាអធិបតីក្នុងពិធីប្រកាសការអនុវត្តជាផ្លូវការ គម្រោងអប់រំបរិយាបន្ននៅបឋមសិក្សា (IPEA) ដែលត្រូវធ្វើ ឡើង កាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២។

អានសៀវភៅដែរ ដូចពាក្យគេថា«ការអាន
ជួយបង្កើនគុណភាពនៃជីវិត» (Reading
'improves quality of life')[20]។



**ឯកសារពិគ្រោះ**

-ក្រសួងអប់រំ ***សៀវភៅភាសាខ្មែរថ្នាក់ទី១*** ឆ្នាំ២០១៧

-ក្រសួងអប់រំ ***សៀវភៅស្តង់ដារអំណាន ថ្នាក់ទី១*** ២០១៤

-ជួន ណាត ***វចនានុក្រមខ្មែរ*** ការផ្សាយដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ១៩៦៧

-ឡាំ លីម ***អំណាន ជាអំណាច*** ការផ្សាយរបស់អ្នកនិពន្ធផ្ទាល់ ២០២០

-អនុក្រឹត្យលេខ១៤០ អនក្រ.បករបស់រាជរដ្ឋាភិបាល ***ស្តីអំពីទិវាជាតិអំណាន*** ចុះនៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៥

-ហ្វេសប៊ុកផេក៖ Lima Angkor RCRC

[20] https://www.khmertimeskh.com

- ហ្វេសប៊ុកផេក៖ Smaradey Khmer: Preserving Khmer Values and Pride.

-Maurice Rogers Jr. THE POWER OF READING 2018

- Oxford Dictionary of English App

- https://www.chesterufsd.org

- https://www.englishclub.com

- https://www.chesterufsd.org

- https://www.readersdigest.co.uk

- https://worldscholarshub.com

- https://study.com

- https://www.khmertimeskh.com

# ផលវិបាកនៃក្មេងទំនើងចំពោះសង្គម

(The Impact of Gangsters in Society)

*ដោយ៖* **លោក ប៉ាន់ សំណាង**

*មន្ត្រីនាយកដ្ឋានវិទ្យាសាស្ត្រអប់រំ*

*វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*

*នៃរាជបណ្ឌិត្យសភាកម្ពុជា*

## ១.សេចក្តីផ្តើម

*បច្ចុប្បន្ននេះ វិទ្យាសាស្ត្របច្ចេកវិទ្យា មានការរីកចម្រើនយ៉ាងខ្លាំងនៅលើពិភពលោក។ ប្រទេសទាំងអស់ មានវប្បធម៌ផ្សេងៗគ្នា តែហាក់ដូចជានៅជាមួយគ្នា ព្រោះតែបច្ចេកវិទ្យាទំនើបនេះឯង។ ដូច្នេះ ឥទ្ធិពលវប្បធម៌ មានចរន្តឆ្លងគ្នាទៅវិញទៅមកដោយគេចមិនផុតឡើយ មិនថាអតីតកាល ឬបច្ចុប្បន្នកាល។ កម្ពុជាជាប្រទេសដែលមានវ័យចំណាស់មួយនៅអាស៊ីអាគ្នេយ៍ដោយមានខឿនវប្បធម៌រឹងមាំសម្បូរបែប ហើយប្រទេសនានាក្នុងតំបន់ក៏ធ្លាប់ទទួលឥទ្ធិពលពីអរិយធម៌ដ៏ចំណាស់នៃប្រទេសនេះដែរ។ ជាទូទៅ ការទទួលឥទ្ធិពលវប្បធម៌ជាតិមួយពីជាតិមួយ គឺមានទៅមានមកជាធម្មតាទេ។ អ្វីដែលជាការលើកឡើងមកនេះ សុទ្ធតែឥទ្ធិពលវិជ្ជមាន ក៏ប៉ុន្តែអ្វីដែលយើងកំពុងព្រួយបារម្ភនោះ គឺឥទ្ធិពលអវិជ្ជមាន ដូចជាឥទ្ធិពលនៃគំរូអាក្រក់ពីសហគមន៍ និងសង្គម[1]។*

*ការកសាងគុណធម៌ជីវិត ជារឿងដែលកម្ពុជាបច្ចុប្បន្នគួរតែយកចិត្តទុកដាក់ខ្លាំង ព្រោះបញ្ហាបងតូច បងធំកកើតមានជាហូរហែរ។ ក្មេងទំនើង ជាក្តីកង្វល់មួយដែលជាតិទាំងមូលនិងប្រទេសនានា មិនត្រូវមើលរំលងឡើយ ពីព្រោះសូម្បីតែប្រទេសមហាអំណាចក៏មានបញ្ហានេះដែរ[2]។ សព្វថ្ងៃនេះ ពាក្យក្មេងទំនើង គឺ ត្រូវបានគេមើលឃើញ ស្តាប់ឮ តាមបណ្តាបណ្តាញ*

---

[1] *ឥទ្ធិពលសង្គម៖ មនុស្សពេញវ័យ មនុស្សចាស់ ឬបុគ្គលជាអាជ្ញាធរមួយចំនួនតូចដែលបានប្រើហិង្សាជាដំណោះស្រាយនិងបង្ហាញចរិតមិនល្អចំពោះយុវវ័យដែរ។*

[2] *នៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩២០ ក្រុមក្មេងទំនើងប្រហែលប្រមាណ១៣០០នាក់ បានរីករាលដាលដូចមេរោគដ៏សាហាវនៅទីក្រុងឈីកាហ្គោ*(Chicago)។

ព័ត៌មានផ្សេងៗនៅក្នុងប្រទេសកម្ពុជាដែលពាក្យមួយនេះ ត្រូវបានគេប្រើជំនួស ពាក្យបងធំបងធំបងតូច ពួកស្ទាវក្មេងស្ទាវ... ហើយសព្វថ្ងៃនេះ រាជរដ្ឋាភិបាលខ្មែរ កំពុងតែរៀបគម្រោងបកប្រែច្បាប់ពីបរទេសដើម្បីសិក្សា និងតាក់តែងច្បាប់ខ្មែរ ដើម្បីគ្រប់គ្រងពួកក្មេងទំនើងទាំងនោះ[3]បញ្ហានេះ បានក្លាយជាបញ្ហាសកលមួយ ព្រោះប្រទេសណាក៏មានមនុស្សទំនើងដែរ។

កន្លងមក រាជរដ្ឋាភិបាលកម្ពុជា បានចេញសារាចរលេខ០៨សរ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ ២០០៩ ស្តីពីវិធានការបង្ការទប់ស្កាត់ និងបង្ក្រាប «ក្មេងទំនើង» ចុះហត្ថលេខាដោយសម្តេចតេជោ អតីតនាយករដ្ឋមន្ត្រីនៃកម្ពុជា។[4] នៅក្នុងលិខិតនោះ រាជរដ្ឋាភិបាលបានពិនិត្យឃើញថា សកម្មភាពនៃ«ក្មេងទំនើង» បានបន្តរីករាលដាលក្រោមរូបភាពផ្សេងៗរហូតដល់ទីជនបទ។ ក្មេងទំនើងទាំងនេះ តែងបានប្រមូលផ្តុំគ្នាជាក្រុម ធ្វើសកម្មភាពអុកឡុកដល់សង្គម តាមតែអំពើចិត្តដោយមិនញញើត ឬគោរពកោតខ្លាចច្បាប់រដ្ឋ ឬក៏សមត្ថកិច្ចអ្វីឡើយ ដូចជាបង្កការអុកឡុករំខាននៅតាមទីកន្លែងសាធារណៈ នៅតាមសាលារៀន នៅតាមពិធីជប់លៀង រាំកំសាន្តនានាធ្វើការគំរាមកំហែងដល់សាធារណជន ជិះរថយន្ត ឬម៉ូតូប្រដេញគ្នាតាមផ្លូវសាធារណៈ ឬជិះម៉ូតូបង្ហោះ។ល។ (រូបទី១)



រូបទី១៖ក្មេងទំនើងបង្ហោះម៉ូតូ

ចំណុចទាំងនេះ គឺជាក្តីព្រួយបារម្ភដែលសង្គមទាំងមូលគួរតែចូលរួមទាំងអស់គ្នា។ តាមទ្រឹស្តីសង្គមវិទ្យាលើក្រុមទំនើង ក្រុមក្មេងទំនើងមានឥទ្ធិពលផ្ទាល់ទៅលើសង្គមមួយ ដូចជាការកើនឡើងនៃឧក្រិដ្ឋកម្ម អំពើហិង្សា និងឃាតកម្ម។ ក្រុមក្មេងទំនើង ក៏ទាមទារឱ្យមានការផ្តល់ការអប់រំ ឬ ដំបូន្មានក្នុងរយៈពេលវែងឬខ្លីដល់សមាជិកក្រុមក្មេងទំនើង ដោយពួកគេទំនងបានបោះបង់ការសិក្សានៅវិទ្យាល័យ រស់ក្នុង

[3] ដកស្រង់ពីគេហទំព័រ៖ https://isayon.wordpress.com

[4] បច្ចុប្បន្ន សម្តេចតេជោ ហ៊ុន សែន ជាប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើនាយករដ្ឋមន្ត្រី។

ភាពអត់ការងារធ្វើ ប្រើប្រាស់គ្រឿងញៀន និង គ្រឿងស្រវឹង ហើយចុងក្រោយគឺជាប់គុក (រូបទី ២)[5](Sociological Theories On Gangs: Gangs have direct effects on a society, such as increased levels of crime, violence and murder. Gangs also have long-term or late suggestions in that gang members are more likely to drop out of high school, struggle with unemployment, abuse drugs and alcohol or in end up in jail.)



រូបទី២៖ ក្មេងទំនើងជាប់ឃុំដែលប្រព្រឹត្តអំពើចោរកម្ម (រូបគំនូររបស់គេហទំព័រអោយស្តុកផូតូ istockphoto)

អំពើហឹង្សាជាក្រុម គឺជាបញ្ហាសំខាន់នៅទូទាំងពិភពលោក។ យុវជនជាច្រើនៗមានអារម្មណ៍ថាជាប់អន្ទាក់ដោយវប្បធម៌ក្រុមក្មេងទំនើង ហើយចូលរួម ពីព្រោះពួកគេមិនឃើញផ្លូវផ្សេងទៀតចេញពីកាលៈទេសៈបច្ចុប្បន្នរបស់ពួកគេ។ បញ្ហាគឺស្មុគ្រស្មាញ ហើយអាចមានអារម្មណ៍ថាមិនអាចចូលទៅក្នុងសហគមន៍។ យើង អាចជួយប្រយុទ្ធប្រឆាំងនឹងបញ្ហានេះ តាមរយៈការទាក់ទងទៅយុវជនដែលមានហានិភ័យ ដើម្បីការពារសមាជិកក្រុមក្មេងទំនើង ជាសមាជិកសហគមន៍សកម្ម និងការលើកកម្ពស់របៀបរស់នៅដែលគ្មានក្រុមក្មេងទំនើងនៅក្នុងសាលារៀន[6]សាលារៀននៅកម្ពុជា ឬសហគមន៍គំរូនានា អាចដើរតួនាទីសំខាន់ក្នុងការជួយលើកិច្ចការនេះដែរ ពោលគឺផ្តើមចេញពីគ្រួសារ ឬសាលាមត្តេយ្យតែម្តង។

## ២. ន័យរបស់ពាក្យគន្លឹះ

នៅក្នុងអត្ថបទខ្លីនេះ ពាក្យគន្លឹះសំខាន់ៗ គឺពាក្យ «សីលធម៌» និង «ក្មេងទំនើង»។

### ក. សីលធម៌

តាមវចនានុក្រមខ្មែរឆ្នាំ២០២២ផ្សាយដោយរាជបណ្ឌិត្យសភាកម្ពុជា បានកំណត់ន័យរបស់ពាក្យ«សីលធម៌» ជា២ចំណុច។ទី ១ មានន័យថា សីលដែលជាធម៌ (របស់សត្វលោក) ឬសីលនិងធម៌ កិរិយាមារយាទ សណ្តាប់ធ្នាប់ ដំបូន្មានដែលនាំឱ្យចៀសវាងអំពើអាក្រក់ ហើយឱ្យ

[5] ដកស្រង់ពីគេហទំព័រ៖ https://www.bartleby.com

[6] ដកស្រង់ពីគេហទំព័រ៖https://www.wikihow.com

ប្រព្រឹត្តតែអំពើល្អៈ ប្រកបដោយសីលធម៌ ប្រាកចាកសីលធម៌។ ទី២ (ទស្សនៈ) មានន័យថា គោលការណ៍និងជំនឿអំពីអាកប្បកិរិយាដែលត្រូវនិងខុស អាកប្បកិរិយាស្តង់ដារៈ ផ្នត់គំនិតនិងសីលធម៌លោកខាងលិច។បើតាមឯកសារមួយទៀតបង្ហាញថា សីលធម៌មកពីពាក្យ«សីល» +«ធម៌»។សីល មានន័យថា ការវៀរចាកអំពើអាក្រក់ សេចក្តីល្អ អំពើជាកុសល ហើយពាក្យ«ធម៌» មានន័យថា ដំបូន្មាន ជាតុ ទ្រឹស្តី សភាវៈទ្រទ្រង់[7]។ដូចនេះ សីលធម៌ គឺសម្គាល់នូវដំបូន្មានទាំងឡាយណាដែលនាំឱ្យប្រព្រឹត្តតែអំពើល្អ អំពើជាកុសល ឬដំបូន្មានទាំងឡាយណាដែលនាំឱ្យមនុស្សវៀរចាកអំពើអាក្រក់ឬអំពើជាអកុសល។ តែបើតាមវចនានុក្រមអក់ហ្វត (Oxford )អង់គ្លេស បានសរសេរថា«សីលធម៌ ជាគោលការណ៍ដែលទាក់ទងនឹងការបែងចែករវាងត្រូវ និងខុស ឬអាកប្បកិរិយាល្អ និងអាក្រក់។ បញ្ហានេះ ក៏ចោទលើសីលធម៌សាមញ្ញ៖ ឧទាហរណ៍៖ អ្នកទោសស្លូតត្រង់គួរតែត្រូវបានដោះលែង»។( Morality are principles concerning the distinction between right and wrong or good and bad behavior. "the matter boiled down to simple morality: innocent prisoners ought to be freed"

ជារួមទោះមានការលើកបែបណា ក៏វាផ្តោតលើន័យវិជ្ជមានដែលនាំឱ្យមានភាពចម្រើនលូតលាស់ប្រកបដោយគុណធម៌ដែរ។

**ខ. ក្មេងទំនើង**

ពាក្យ «ក្មេងទំនើង» មកពីពាក្យ«ក្មេង» និងពាក្យ «ទំនើង»។ ក្មេង មានន័យថា មនុស្សឬសត្វដែលមានអាយុតិចៈ មនុស្សក្មេង នៅក្មេង កាលពីក្មេង។ទំនើង មានន័យ២បែប៖ បែបទី១ មានន័យថា សេចក្តីទើង ដំណើរដែលធ្វើឥតទើសទាល់តាមតែអំណាចចិត្ត អំពើចិត្ត ចំណង់ៈ ធ្វើតាមទំនើងចិត្ត ប្រព្រឹត្តតាមទំនើង។ ទី២បានសេចក្តីដល់ ពាលដែលមិនស្គាល់ខុសត្រូវ ដែលមិនស្តាប់បង្គាប់ៈ ក្មេងទំនើង ពួកទំនើង។[8] ម្យ៉ាងទៀត យើងអាចយល់ឃើញថា «ក្មេងទំនើង» សម្តៅទៅលើក្មេងជំទង់ដែលមានអាយុចាប់ពី១៣ទៅ១៩ ឬក៏តិច ឬច្រើនជាងនេះបន្តិចបន្តួច។ លើសពីនេះ ពួកគេ គឺជាក្រុមក្មេងដែលមិនសូវស្តាប់ដំបូន្មានឪពុកម្តាយ អាណាព្យាបាល លោកគ្រូ អ្នកគ្រូ គណៈគ្រប់គ្រងសាលា និងអាជ្ញាធរជាដើម។ ក្រៅពីនេះ យើង

[7] ដកស្រង់ពីគេហទំព័រ៖ https://www.khsearch.com

[8] ដកស្រង់ពីវចនានុក្រមខ្មែរ ឆ្នាំ២០២២ ផ្សាយដោយ រាជបណ្ឌិត្យសភាកម្ពុជា

ក៏អាចហៅបានថា ជាក្រុមក្មេងដែលធ្វើអ្វីៗតាមចិត្តចង់ ឬទំនើងចិត្ត ដែលជាទូទៅមិនអនុលោមទៅតាមដំបូន្មាន សីលធម៌ គុណធម៌ វិន័យ និងច្បាប់ទម្លាប់ឡើយ[9]

ចំពោះន័យភាសាអង់គ្លេសវិញ ពាក្យ «ក្មេងទំនើង» ត្រូវនឹងពាក្យ«Gangster»។ វា មានន័យថា ឧក្រិដ្ឋជនដែលជាសមាជិកនៃក្រុមទំនើង (a criminal who is a member of gang.)[10]។ លើសពីនេះ គេក៏យល់ថា ក្មេងទំនើង ជាមនុស្សខូច (ដែលជម្មតាផ្តុំគ្នាជាក្រុម)។[11]

ដូច្នោះ តាមការលើកឡើងខាងលើ យើងអាចយល់ឃើញថា ពាក្យ «ក្មេងទំនើង» មានន័យច្រើន តែន័យរួមផ្តោតលើចំណុចអវិជ្ជមានដែលអាចបង្កចលាចលក្នុងសង្គមបាន។

## ៣. បុគ្គលិកលក្ខណៈរបស់ក្មេងទំនើង

ទំនើង ជាពាក្យមួយដែលសម្គាល់ដល់បុគ្គលមានគុណលក្ខណៈ«ពាល ដែលមិនស្គាល់ខុសត្រូវ ដែលមិនស្តាប់បង្គាប់[12]»។នេះ ជាលក្ខណ៍ន័យរបស់ពាក្យទំនើង។

បើយើងពិនិត្យជារួម ក្មេងទំនើងមានចរិតលក្ខណៈដូចខាងក្រោម៖

1. ខ្វះការអប់រំឬឱកាសអប់រំ
2. ខ្វះឱកាសការងារឬជំនាញ
3. ខ្វះភាពជាគំរូរបស់យុវជនល្អ
4. ខ្វះការគាំទ្ររបស់គ្រួសារ
5. ជំនឿជាក់លើខ្លួនឯងតិចតួច
6. ខ្វះអារម្មណ៍ថាខ្លួនមានអំណាច
7. ប្រើគ្រឿងញៀននិងគ្រឿងស្រវឹង
8. ខ្វះឱកាសទទួលបានសមភាពសង្គម[13]។

## ៤. មូលហេតុចម្បងៗដែលនាំឱ្យកើតក្មេងទំនើង

បើនិយាយពីសច្ចភាពប្រកបដោយលក្ខណៈសត្យានុម័ត សង្គមណាក៏ដូចសង្គមណាដែរ តែងតែមានចំណុចវិជ្ជមាន និងអវិជ្ជមាន ពោលគឺមានមនុស្សល្អ និងមនុស្សមិនល្អនេះឯង។

យុវជន ជាទំពាំងស្នងឫស្សី ជាឃ្លាមួយដែលបង្ហាញន័យបន្តវេនក្នុងការស្ថាបនា កសាង

[9] ស្រង់ពីកាសែតកម្ពុជាថ្មី ផ្សាយតាមគេហទំព័រនៅថ្ងៃទី ២១ កញ្ញា ២០២៣

[10] ស្រង់ពីវចនានុក្រមAdvanced English Dictionary

[11] ន័យក្នុងវចនានុក្រមអង់គ្លេស-ខ្មែរ

[12] ន័យរបស់ពាក្យ«ទំនើង»ស្រង់ពីវចនានុក្រមខ្មែរ ២០២២ផ្សាយដោយរាជបណ្ឌិត្យសភាកម្ពុជា

[13]ស្រង់ពីគេហទំព័រ៖https://www.16thcircuit.org

អភិវឌ្ឍ និងអភិវក្សាៗជាក់ស្ដែង បើទំពាំងនោះ ស្អុយរលួយហើយ ក៏មិនអាចក្លាយជាប្ញស្សីបាន ដែរ ហើយបើនិយាយដល់សង្គមជាតិ បើយុវជន ប្រុសស្រី មិនប្រកបដោយគុណធម៌ ក៏ពិបាក នឹងបន្តវេនវៀមច្បងឬអ្នកជំនាន់មុនផងដែរ។ ការធ្លាក់ចុះនូវសីលធម៌ ជាគ្រោះថ្នាក់មួយ សម្រាប់សង្គមជាតិទាំងមូល។តាមន័យទូទៅ សីលធម៌ដឹកនាំមនុស្សទៅរកផ្លូវល្អ ចៀសវាង ផ្លូវអាក្រក់នៅក្នុងជីវិតរស់នៅ។[14]ចំពោះការ កើតឡើងនូវក្មេងទំនើង ជាក្ដីកង្វល់រួមរបស់ យើងទាំងអស់គ្នា ព្រោះពួកគេបាត់បង់នូវគុណ ធម៌ សីលធម៌ដែលជានិយាមនាំសង្គមសុខសាន្ត។

ហេតុផលដែលនាំឱ្យកើតមានក្មេងទំនើង វា អាស្រ័យលើបរិបទ វប្បធម៌ ឬស្ថានភាពជាក់ ស្ដែងនៃសង្គមឬប្រទេសនីមួយៗ។ បើតាម**អ្នក និពន្ធស៊ី.អ័រ.ជេន** (C.R.Jahn) ដែលសរសេរអត្ថ បទមានចំណងជើងថា «ការពារខ្លួន» (Self Defense) បានលើកឡើងថា «នោះភាគច្រើន អាស្រ័យលើវប្បធម៌។ គ្រប់ជាតិសាសន៍នៅលើ ផែនដីហាក់ដូចជាមានថ្នាក់ឧក្រិដ្ឋកម្ម (Crime class) ដែលបានរៀបចំ។ ដើមហេតុនៃក្រុមក្មេង ទំនើង ច្រើនតែកើតឡើងដោយសារតែអំពើ ពុករលួយរីករាលដាល និងអារម្មណ៍នៃភាព អយុត្តិធម៌ និងគ្មានអំណាច។ ប្រសិនបើប៉ូលីស មិនការពារប្រជាជនទេ តុលាការមិនដាក់ទោស អ្នកធ្វើខុសទេ ហើយប្រជាជនមានអារម្មណ៍ថា មិនមានសុវត្ថិភាព គេបោកប្រាស់ និងអស់ សង្ឃឹមទៀត ពួកគេអាចនឹងប្រមូលផ្ដុំគ្នាតាម របៀបកុលសម្ព័ន្ធ ហើយប្រើអំពើហិង្សាដើម្បី ទទួលបានការការពារ សន្តិសុខ និងការគោរព ដោយខ្លួនពួកគេ។ នៅទីបំផុត ពួកគេអាច សម្រេចចិត្តរកប្រាក់ចំណេញពីឋានៈថ្មីរបស់ ពួកគេ តាមរយៈការចែកចាយគ្រឿងញៀន និង ឧបត្ថម្ភពេស្យាចារ ហើយនៅពេលដែលពួកគេ ទទួលបានទ្រព្យសម្បត្តិ ពួកគេទទួលបានឋានៈ និងមានគ្នាកាន់តែច្រើន ក្រោយមកក៏មាន ជម្លោះជាមួយក្រុមស្រដៀងគ្នាផ្សេងទៀត។ ទាំងនេះ ជារបៀបដែលក្រុមក្មេងទំនើងចាប់ ផ្តើម»[15]។ ប៉ុន្ដែយើងអាចរំលេចនូវមូលហេតុ សំខាន់ៗមួយចំនួនដែលយើងគួរពិចារណាដូច ខាងក្រោម៖

-**ទំនោរពីកំណើត**៖ ទោះបីជាមានភាគរយតិច តួចក៏ដោយ ក៏មិនអាចបដិសេធលទ្ធភាពនេះ ដែរ ពីព្រោះបើយោងតាមការសិក្សាបែបទស្សន

[14] ស្រង់ពីការផ្សាយរបស់RFI ចុះផ្សាយថ្ងៃទី២៧ មេសា ២០១៥

[15] ស្រង់ពីគេហទំព័រ៖https://www.quora.com

វិជ្ជា ធម្មជាតិរបស់ក្មេងម្នាក់ៗ អាចល្អ ឬអាក្រក់ពីកំណើត។ ប្រសិនបើវាអាក្រក់ ហើយពេលកើតមក និងរស់នៅក្នុងគ្រួសារ និងសង្គម វាទទួលឥទ្ធិពលអាក្រក់ទៀត នោះនាំឱ្យក្មេងនោះអាចនឹងក្លាយទៅជាក្មេងមិនល្អ។ធម្មជាតិរបស់យុវវ័យ គឺជាវ័យឈាមពាវ ឆេវឆាវ ចចេស ខ្វះការពិចារណា ចង់សាកល្បង ខ្វះបទពិសោធន៍ ងាយអូសទាញ និងងាយទទួលឥទ្ធិពលពីសង្គម ជាពិសេសឥទ្ធិពលមិនល្អ។

**-ឪពុកម្ដាយ ឬអ្នកអាណាព្យាបាល៖** សព្វថ្ងៃ ឪពុកម្ដាយជាច្រើនរវល់នឹងការងារ ហើយមិនខ្វល់ពីស្ថានភាពផ្លូវចិត្តរបស់កូន។ ក្មេងជំទង់ជាច្រើន គ្រាន់តែចង់បានការយកចិត្តទុកដាក់ និងសេចក្ដីស្រឡាញ់កាន់តែច្រើនពីឪពុកម្ដាយរបស់ពួកគេ ប៉ុន្តែឪពុកម្ដាយភាគច្រើនមិនអាចយល់ពីអារម្មណ៍កូនរបស់ពួកគេបានទេ។ ពួកគាត់ មិនបានតាមដាន និងស្វែងយល់អំពីការវិវឌ្ឍរបស់កូនទាំងរាងកាយ គំនិត ទាំងសកម្មភាពប្រចាំថ្ងៃរបស់កូន និងផ្ដល់សេរីភាពច្រើនពេកទៅឱ្យកូនៗជួនកាល ក្មេងទំនើង ពុំស្ដាប់បង្គាប់ឪពុកម្ដាយឬអ្នកអាណាព្យាបាលគឺបណ្ដាលមកពីក្មេងទាំងអស់នោះ មិនទទួលបានភាពកក់ក្ដៅពីសមាជិកគ្រួសារ ឬវង្សញាតិអ្វីមួយដោយអយុត្តិធម៌។[16] ឪពុកម្ដាយ អ្នកអាណាព្យាបាលខ្វះទំរើសកូនតាំងពីតូចរហូតដល់ជំទង់។

**-ការសេពគប់មិត្ត៖** ពាក្យខ្មែរយើងតែងលើកឡើងថា« **គប់ពាលពាលនាំទៅរកខុស គប់ប្រាជ្ញប្រាជ្ញនាំទៅរកប្រាជ្ញ**[17]...»ដែលជាឃ្លាបង្ហាញពីគុណតម្លៃនៃការចងមិត្តឬសេពគប់មិត្តភក្តិ។ មិត្តល្អ ដឹកនាំដើរលើផ្លូវល្អ តែមិត្តភក្តិមិនល្អ ឬការអូសទាញពីមិត្តភក្តិមិនល្អទទួលឥទ្ធិពលនៃគំរូអាក្រក់ពីសហគមន៍ និងសង្គម (មនុស្សពេញវ័យ មនុស្សចាស់ ឬបុគ្គល ជាអាជ្ញាធរមួយចំនួនតូច បានប្រើហិង្សាជាដំណោះស្រាយ និងបានបង្ហាញចរិតមិនល្អចំពោះយុវវ័យដែរ)។

**-ឥទ្ធិពលពីប្រព័ន្ធផ្សព្វផ្សាយ៖** ក្រៅពីឥទ្ធិពលខាងលើ ក្មេងជំទង់ក៏អាចនឹងទទួលឥទ្ធិពលពីប្រព័ន្ធផ្សព្វផ្សាយឲ្យក្លាយជាក្មេងទំនើងដែរ។ បច្ចុប្បន្ននេះ ពហុព័ត៌មានដូចជា អ៊ិនធឺណិត ទូរទស្សន៍ និងវិទ្យុ កំពុងពេញនិយម និងជារឿងធម្មតាក្នុងចំណោមយុវវ័យ។ ទោះជាយ៉ាងណា មានរឿងភាគ និងភាពយន្តជាច្រើនដែល

[16] ស្រង់ពីគេហទំព័រ៖ https://m.postkhmer.com

[17] ដកស្រង់ពីអត្ថបទកាព្យ«តម្លៃនៃការសេពគប់»ភាសាខ្មែរថ្នាក់ទី៨ ក្រសួងអប់រំ ឆ្នាំ២០២១

ផ្ទុះបញ្ចាំងពីសកម្មភាពក្រុមក្មេងទំនើង ហើយរឿងខ្លះថែមទាំងបានបង្កើតតួក្មេងទំនើងជាវីរបុរស។ យុវវ័យដែលនៅមិនទាន់ពេញវ័យគិតថាក្មេងទំនើងក្នុងឈុតទាំងនោះឡូយណាស់ ហើយក៏ក្លាយជាក្មេងទំនើង។ ពេលខ្លះ ក្មេងជំទង់ចូលរួមក្រុមក្មេងទំនើង ដោយសារពួកគេមិនសូវល្អក្នុងសកម្មភាពសង្គម ហើយចង់ទាក់ទាញការចាប់អារម្មណ៍ពីអ្នកដទៃ។[18]

-**ឥទ្ធិពលនៃគ្រឿងញៀន-គ្រឿងស្រវឹង៖** ទសវត្សឆ្នាំ១៩៨០ បានឃើញមានកំណើនឡើងនូវអំពើហិង្សានៃក្រុមយុវជនទំនើងនិងការកើនឡើងនៃការរីករាលដាលនៃកូកាអ៊ីន[19](The 1980's saw an increase in youth gang violence and the rise of the crack cocaine epidemic.)។ គ្រឿងញៀនគ្រឿងស្រវឹង និងក្មេងទំនើង គឺមានទំនាក់ទំនងនឹងគ្នាយ៉ាងជិតស្និទ្ធ ព្រោះគ្រឿងញៀនអាចបង្កកើតមានក្រុមទំនើង ហើយពួកទាំងនោះ ក៏អាចរកស៊ីចរាចរណ៍គ្រឿងញៀនដែរ (រូបទី៣)។ កន្លងមក យើងឃើញមានសមត្ថកិច្ច ចាប់ក្រុមក្មេងទំនើងប្រើប្រាស់ និងចែកចាយថ្នាំជាច្រើនករណី។[20]



រូបទី៣៖ ក្រុមក្មេងទំនើងជនជាតិចិនជុំគ្នាផឹកស៊ី
(រូបរបស់Quora)

-**អាជ្ញាធរ៖** ជួនកាល មានភាពខ្វះខាតក្នុងការអនុវត្តតួនាទីភារកិច្ចរបស់អាជ្ញាធរមូលដ្ឋាន ឬអាជ្ញាធរពាក់ព័ន្ធ ឬការគោរព និងការអនុវត្តច្បាប់នៅមានកម្រិត។ វាក៏អាចធ្វើឲ្យកើននូវក្រុមក្មេងទំនើងនេះដែរ។

-**អំពើពុករលួយ៖** ការអនុវត្តការងារខ្លះ ខុសពីច្បាប់ឬតួនាទីដែលបានចែងឬអនុវត្តលើស។ ជួនកាល មន្ត្រីបានបង្កើតអំពើពុករលួយថែមទៀត។នៅក្នុងគេហទំព័រមួយបានលើកឡើងថា ដើមហេតុនៃក្មេងទំនើង ច្រើនតែកើតឡើង

---

[18] ស្រង់ពីគេហទំព័រ៖ https://www.16thcircuit.org

[19] ការផ្សាយមួយក្នុងព្រឹត្តិបត្រ(Bulletin)របស់នាយកដ្ឋានយុត្តិធម៌សហរដ្ឋអាមេរិកតាមគេហទំព័រ https://www.justice.gov

[20] នគរបាល បង្ក្រាបបានក្មេងទំនើងសេពគ្រឿងញៀន នៅព្រំប្រទល់ស្រុកស្វាយចេក និងស្រុកថ្មពួក។នេះជាចំណងជើងអត្ថបទផ្សាយដោយកាសែតរស្មីកម្ពុជាចុះថ្ងៃ ៣១ កក្កដា ២០២២កន្លងមក។

ដោយសារតែអំពើពុករលួយរីករាលដាល និង អារម្មណ៍នៃភាពអយុត្តិធម៌ និងគ្មានអំណាច។ ប្រសិនបើប៉ូលីស មិនការពារប្រជាជនទេ តុលាការមិនដាក់ទោសអ្នកធ្វើខុសទេ នោះ ប្រជាជនមានអារម្មណ៍មិនមានសុវត្ថិភាព ចាញ់បោក និងអស់សង្ឃឹម ហើយពួកគេនឹង ប្រមូលផ្តុំគ្នាប្រើអំពើហឹង្សាដើម្បីទទួលបានការ ការពារ សន្តិសុខ និងការគោរព។[21]

-**ការអប់រំសីលធម៌មានការធ្លាក់ចុះ៖** បំណុច នេះរាប់ទាំងគ្រួសារ សាលារៀន និងសង្គម ទាំងមូលដែរ។ក្មេងកំព្រា ក្មេងអនាថា គ្មាន ការងារធ្វើ មានវិបត្តិ មានបញ្ហាផ្លូវចិត្ត អស់ សង្ឃឹម ក្នុងជីវិត ជាដើម។ក្រុមនេះ ជាអ្នកដែល ប្រឈមខ្លាំងក្នុងការក្លាយជាក្មេងទំនើង។ ជួនកាល មានការគិតថា ក្មេងទំនើង ជារឿងធម្ម តា។ជាក់ស្តែង នៅក្នុងអត្ថបទមួយបានលើក ឡើងថា ក្មេងទំនើង ជារឿងធម្មតានៅក្នុង ប្រទេសកំពុងអភិវឌ្ឍន៍ (developing nation) ដូច ជា ប្រទេសម៉ាឡេស៊ីដែលយើងបានដឹងច្រើន មកហើយថា វា កើតឡើងនៅតាមសាលារៀន។ គេបានរាយការណ៍បន្ថែមថា នៅក្នុងប្រទេស អភិវឌ្ឍន៍ (developed countries) កុមារសិស្ស សាលាត្រូវបានចូលរួមកាន់តែខ្លាំងឡើងនៅក្នុង ក្រុមក្មេងទំនើង។

-**ឥទ្ធិពលពីមជ្ឈដ្ឋានជុំវិញ៖** មនុស្សភាគ ច្រើនយល់ថា អំពើក្មេងទំនើង គឺបណ្តាលពី ក្មេងជំទង់ខ្លួនឯង។ប៉ុន្តែតាមពិត គឺជាបាតុភូត ដែលកើតឡើងដោយឥទ្ធិពលមជ្ឈដ្ឋានជុំវិញ យុវវ័យ ដូចជាករណីសិស្សសាលាដែលទទួល ឥទ្ធិពលមិត្តរួមសាលា ឬរួមថ្នាក់ជាដើម។

ជារួម យើងយល់ឃើញថា ការកកើតនិង ការកើនឡើងនៃពួកក្មេងៗដែលបង្កចលាចល ទាំងនោះ គឺទទួលឥទ្ធិពលពីកត្តាច្រើនរួមផ្សំគ្ នា។

## ៥. ផលវិបាកក្នុងសង្គមដោយក្មេង ទំនើង

ទោះបីអ្នកខ្លះយល់ថា ក្មេងទំនើង ជា បញ្ហាធម្មតា ក៏ដោយ ក៏វាជាក្តីកង្វល់សកលរួម មួយដែលយើងត្រូវបង្វែរឱ្យអ្នកទាំងនោះ ពិចារណាឡើងវិញដែរ។តាមពិត ប្រទេសណា ក៏មានបញ្ហារបស់វាដែរ ហើយក្មេងទំនើងនេះ គឺបានបង្កអសន្តិសុខដល់សង្គមជាតិគួរឱ្យព្រួយ បារម្ភ។អំពើហឹង្សាជាក្រុម គឺជាបញ្ហាសំខាន់នៅ ទូទាំងពិភពលោក។ ជាទូទៅគេសង្កេតឃើញ

[21] ស្រង់ពីគេហទំព័រ៖https://www.quora.com

ថា យុវជន មានអារម្មណ៍ថាជាប់អន្ទាក់ដោយវប្បធម៌ក្រុមក្មេងទំនើង ហើយចូលរួម ពីព្រោះពួកគេមិនឃើញផ្លូវផ្សេងទៀតចេញពីកាលៈទេសៈបច្ចុប្បន្នរបស់ពួកគេ។

លើសពីនេះ ក្រុមក្មេងទំនើងនេះ អាចបង្កបង្កើតនូវអំពើអបាយមុខផ្សេងៗដូចជា ចោរកម្ម ប្រើប្រាស់និងចរាចរណ៍គ្រឿងញៀន មនុស្សឃាត អំពើហិង្សាក្នុងគ្រួសារនិងក្នុងសង្គម ជាដើម។ ថ្មីៗនេះ យើងសង្កេតឃើញ ក្រុមក្មេងទំនើង មិនថាស្រីឬប្រុស បានវាយតប់គ្នា ប្ដីសម្លាប់ប្រពន្ធ ឬប្រពន្ធសម្លាប់ប្ដី ដែលបង្កដោយគ្រឿងញៀននេះឯង។

## ៦. វិធានការណ៍

ប្រទេសទាំងអស់ មិនគួរបណ្ដោតបណ្ដោយឱ្យក្រុមក្មេងទំនើង បងតូចបងធំ បន្តរីកពលដាលតទៅទៀតទេ។ សម្រាប់កម្ពុជាយើងរាជរដ្ឋាភិបាលបាននិងកំពុងខិតខំលើកិច្ចការនេះពិសេសកងកម្លាំងសមត្ថកិច្ចដែលជាសេនាធិការដឹកនាំចំពោះមុខៗកន្លងមក រាជរដ្ឋាភិបាលកម្ពុជា បានចេញសារាចរលេខ០៤សរ ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ២០០៩ ស្ដីពីវិធានការបង្ការទប់ស្កាត់ និងបង្ក្រាប «ក្មេងទំនើង» ចុះហត្ថលេខាដោយសម្ដេចតេជោ អតីតនាយករដ្ឋមន្ត្រីនៃកម្ពុជា។

ដើម្បីគ្រប់គ្រងស្ថានការណ៍នេះ និងចាត់វិធានការបង្ការទប់ស្កាត់និងបង្ក្រាបសកម្មភាពរបស់ក្មេងទំនើងល្មើសទាំងនេះ ឱ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាព ក្នុងគោលដៅធានារក្សាបរិយាកាសសង្គមល្អប្រសើរ ប្រកបដោយសន្តិសុខ សណ្ដាប់ធ្នាប់សាធារណៈភាពសុខសាន្ត និងសេចក្ដីថ្លៃថ្នូរ ក្នុងសារាចរនោះ រាជរដ្ឋាភិបាល សូមដាក់ចេញវិធានការដូចខាងក្រោម:

១-ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ ក្រសួងយុត្តិធម៌ ក្រសួងទេសចរណ៍ ក្រសួងអប់រំ យុវជន និងកីឡា រដ្ឋបាលរាជធានី-ខេត្ត និងក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀត ត្រូវបង្កើនការយកចិត្តទុកដាក់គ្រប់គ្រង ឬចាត់វិធានការគ្រប់គ្រងមុខសញ្ញា និងសកម្មភាពនៃក្រុមក្មេងទំនើង ដែលបង្កការអុកឡុករំខានដល់ប្រជាពលរដ្ឋ និង ធ្វើឱ្យប៉ះពាល់ដល់សន្តិសុខ សណ្ដាប់ធ្នាប់សាធារណៈ ត្រូវមានវិធានការអប់រំ វិធានការរដ្ឋបាល ឬវិធានការច្បាប់ ដែលចាំបាច់និងសមស្រប ដើម្បីបង្ការទប់ស្កាត់ និងបង្ក្រាបឱ្យមានប្រសិទ្ធភាព។

២-អគ្គស្នងការដ្ឋាននគរបាលជាតិ បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស គណៈបញ្ជាការឯកភាពរាជធានី-ខេត្ត និង ក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀតត្រូវចាត់វិធានការជាក់ស្តែងនានា នៅក្នុងសមត្ថកិច្ចរបស់ខ្លួន ធ្វើអន្តរាគមន៍បង្ការទប់ស្កាត់និងបង្ក្រាប ឱ្យបានទាន់ពេលវេលានូវរាល់សកម្មភាពអុកឡុកបង្កការប៉ះពាល់ដល់សន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងសកម្មភាពល្មើស របស់ក្រុមក្មេងទំនើងនៅតាមមូលដ្ឋាននីមួយៗ។ ក្នុងករណីចាំបាច់ មន្ត្រីនគរបាលយុត្តិធម៌ គណៈបញ្ជាការឯកភាពរាជធានី-ខេត្តអាចចាត់វិធានការអន្តរាគមន៍ផ្នែករដ្ឋបាល តាមស្ថានភាពជាក់ស្តែងនានា និងអាចធ្វើការនាំខ្លួនក្រុមក្មេងទំនើង ដែលបានធ្វើសកម្មភាពបង្កការអុកឡុកទាំងនោះ មកអង្គភាពរបស់ខ្លួន ដើម្បីធ្វើការអប់រំណែនាំដោយមានការចូលរួមទទួលខុសត្រូវពីឪពុក ម្តាយ ឬអាណាព្យាបាល។

៣-ក្នុងករណីសកម្មភាពអុកឡុករបស់ក្មេងទំនើង បង្កើតបានជាបទល្មើសព្រហ្មទណ្ឌ អាជ្ញាធរមានសមត្ថកិច្ច ត្រូវចាត់នីតិវិធីនិងប្រើអំណាចតាមផ្លូវច្បាប់ ធ្វើអន្តរាគមន៍ឱ្យបានទាន់ពេលវេលា ដើម្បីបង្ក្រាបនិងកសាងសំណុំរឿងបញ្ជូនទៅអយ្យការ ដើម្បីចាត់ការជាសមត្ថកិច្ចតាមនីតិវិធីនៃច្បាប់។

៤- ក្រសួងទេសចរណ៍ រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់លំដាប់ថ្នាក់ ក្រសួង ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធមានសមត្ថកិច្ចចេញអាជ្ញាប័ណ្ណ ត្រូវដាក់ចេញនូវវិធានការណែនាំ និងហាមឃាត់ចំពោះការប្រមូលផ្តុំគ្នារបស់ក្មេងទំនើងនៅតាមផ្ទះសំណាក់ សណ្ឋាគារ ឬក្លឹបកំសាន្ត ជាដើម ដើម្បីធ្វើសកម្មភាពល្មើសច្បាប់នានា។ អ្នកគ្រប់គ្រង ផ្ទះសំណាក់ សណ្ឋាគារ ឬក្លឹបកំសាន្ត ត្រូវសហការរាយការណ៍ជាបន្ទាន់ដល់អាជ្ញាធរមានសមត្ថកិច្ច អំពីសកម្មភាពនៃក្រុមក្មេងទំនើង នៅក្នុងទីកន្លែងរបស់ខ្លួនគ្រប់គ្រង។

៥- ដើម្បីធានារក្សាការពារសន្តិសុខសណ្តាប់ធ្នាប់របៀបរៀបរយសង្គម និងភាពសុខសាន្តរបស់ប្រជាពលរដ្ឋ នៅក្នុងមូលដ្ឋានរបស់ខ្លួន រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ត្រូវដាក់ចេញនូវវិធាន បញ្ញត្តិ ឬបទបញ្ជាផ្នែករដ្ឋបាលចាំបាច់នានា តាមស្ថានភាពជាក់ស្តែង ជាពិសេស ត្រូវកំណត់ធ្វើការហាមឃាត់ នូវសកម្មភាពដែលជាមុខសញ្ញានាំទៅដល់ការប្រមូលផ្តុំគ្នា បង្កើតជាក្រុមក្មេងទំនើង និងត្រូវលើកទឹកចិត្តដល់ប្រជាពលរដ្ឋ និងអង្គការមិន

មែនរដ្ឋាភិបាលនានា ឱ្យចូលរួម សហការ និង ពយការណ៍ផ្ដល់ព័ត៌មានទាក់ទងនឹង សកម្មភាពនៃក្មេងទំនើងទាំងនេះ។

៦- ក្រសួង ស្ថាប័ន និងអាជ្ញាធរមាន សមត្ថកិច្ចពាក់ព័ន្ធ ត្រូវធ្វើការផ្សព្វផ្សាយឱ្យបាន ទូលំទូលាយ និងបំផុសចលនាឱ្យមានការចូល រួមពីប្រជាពលរដ្ឋនៅតាមសហគមន៍ និង អង្គការមិនមែនរដ្ឋាភិបាលនានា ជាពិសេស លោកគ្រូ អ្នកគ្រូ ឪពុក ម្ដាយ និងអាណា ព្យាបាលក្នុងការអប់រំណែនាំដល់កូនចៅ បង ប្អូន សាច់ញាតិរបស់ខ្លួន សិស្សានុសិស្ស ឱ្យ យល់ដឹងអំពីគ្រោះថ្នាក់នៃសកម្មភាពក្រុមក្មេង ទំនើង ចៀសវាងការចូលរួម ឬប្រញាប់ដកខ្លួន ចេញពីក្រុមនេះ ព្រមទាំងពយការណ៍វែកមុខ អំពីមុខសញ្ញា និងសកម្មភាពរបស់ក្រុមក្មេង ទំនើង ដល់អាជ្ញាធរមានសមត្ថកិច្ចជាបន្ទាន់។

នៅក្នុងផ្លូវច្បាប់ វិធានការ មានទាំងវិធាន ការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភដូចខាងក្រោម(រូបទី៤)[22]៖

- ការប្រគល់អនីតិជនឱ្យទៅ ឪពុកម្ដាយ អាណាព្យាបាល បុគ្គលដែលថែរក្សា អនីតិជន នោះ ឬ បុគ្គលណាផ្សេងទៀត ប្រសិនបើបុគ្គលនោះ សក្តិសម នឹងទំនុកចិត្ត។




រូបទី៤ៈច្បាប់និងក្មេងទំនើងដែលជាអនីតិជន(រូបភាព គេហទំព័រCPC[23])

- ការប្រគល់អនីតិជនឱ្យទៅ សេវាសាធារណៈ ដែលសម្រាប់ ទទួលបន្ទុកអនីតិជន។
- ការប្រគល់អនីតិជនឱ្យទៅ អង្គការឯកជន ដែលមាននីតិ សម្បទាក្នុងការទទួលអនីតិជន។
- ការប្រគល់អនីតិជនឱ្យទៅមន្ទីរ ពេទ្យ ឬ ស្ថាប័នឯកទេស។
- ការដាក់អនីតិជនឱ្យស្ថិតនៅ ក្រោមការការពាររបស់ តុលាការ។

[22] មាត្រា៤០នៃជំពូក៣«ការទទួលខុសត្រូវព្រហ្មទណ្ឌ របស់អនីតិជន»នៃក្រមព្រហ្មទណ្ឌរបស់កម្ពុជា

[23] ស្រង់ពីគេហទំព័រhttps://www.cpc-news.com

ក្រៅពីសារាចរនិងវិធានការផ្លូវច្បាប់ចំពោះអនីតិជនខាងលើ យើងសង្កេតឃើញមានអង្គការ សង្គមស៊ីវិល ក៏ដូចជាអ្នកស្រាវជ្រាវ ផ្សេងៗ ក៏បានបញ្ចេញទស្សនៈជាច្រើនក្នុងការផ្តល់ជាដំណោះស្រាយទាក់ទិន នឹងក្មេងទំនើងនេះដែរ។ក្នុងនោះ យើងអាចសរុបមកមានដូចដូចតទៅ៖

- ពង្រឹងតួនាទីរបស់ឪពុកម្តាយ អ្នកអាណាព្យាបាល
- កាត់បន្ថយ ឬលុបបំបាត់គ្រឿងស្រវឹង និងគ្រឿងញៀន
- កាត់បន្ថយ ការបញ្ចាំងខ្សែភាពយន្តសាហាវៗនៅលើកញ្ចក់ទូរទស្សន៍ និងបណ្តាញសង្គម
- កាត់បន្ថយ ឬលុបបំបាត់មាតិកា ឬកម្មវិធីហ្គេមសាហាវៗ
- បង្កើតកន្លែង សម្រាប់កុមារ និងយុវជនកម្សាន្ត លេងកីឡា និងហាត់ប្រាណ ដើម្បីសុខភាពផង ដើម្បីកាត់បន្ថស្ត្រេសផង និងដើម្បីកាត់បន្ថយពេលសម្រាប់ទៅធ្វើសកម្មភាពមិនល្អផ្សេងទៀត។
- ប្រមូល យុវជនក្រីក្រ ដែលគ្មានការងារធ្វើ មានវិបត្តិ មានបញ្ហា ផ្លូវចិត្ត អស់សង្ឃឹម ក្នុងជីវិតជាដើម ឱ្យចូលរួមទទួលការពិគ្រោះយោបល់ ឬការព្យាបាលជំងឺផ្លូវចិត្ត ការអប់រំសីលធម៌ សិក្សាជំនាញវគ្គខ្លីៗ ឬចូលរួមសកម្មភាពស្ម័គ្រចិត្ត ជួយសង្គមផ្សេងៗ ។
- បង្កើនការបណ្តុះបណ្តាល វិជ្ជាជីវៈ និងផ្តល់ការងារដល់ យុវជន ដើម្បីបង្វែរពួកគេមករកផ្លូវត្រូវ និងកាត់បន្ថយឱកាសទៅប្រព្រឹត្តអំពើមិនល្អផ្សេងៗ។
- ពង្រឹងការអប់រំសីលធម៌នៅក្នុងគ្រួសារ សាលារៀន វត្តអារាម និងអង្គភាព
- ពង្រឹងតួនាទីនិងប្រតិបត្តិការរបស់អាជ្ញាធរមូលដ្ឋាន
- ពង្រឹងការអនុវត្តច្បាប់ លុបបំបាត់និទណ្ឌភាព កុំឱ្យអ្នកមានទោសរួចផុត ពី សំណាញ់ច្បាប់ លើសពីនេះទៀត មណ្ឌលអប់រំកែប្រែ ត្រូវតែអប់រំទណ្ឌិតឱ្យមានការកែប្រែពិតប្រាកដ កុំឱ្យពេលពួកគេចេញ

ពីពន្ធនាការមកកាន់តែសាហាវជាងមុន។

វិធានការដែលលើកឡើងមកខាងលើ ពិតជាចំណាត់ការដ៏ប្រសើរ។ ដើម្បីទទួលបានប្រសិទ្ធិភាពនិងប្រសិទ្ធិផលក្នុងកិច្ចការនេះ លុះត្រាតែមានការអនុវត្តនិងការចូលរួមពីគ្រប់ជ្រុងនៃសង្គមនិងពិភពលោកទាំងមូល ព្រោះវាជាបញ្ហាសកលដែលជះឥទ្ធិពលគ្នាទៅវិញទៅមកដោយគេចមិនផុតឡើយ។

## ៧. សន្និដ្ឋាន

សរុបមក ក្មេងទំនើងគឺបណ្តាលមកពីឥទ្ធិពលជាច្រើនរួមផ្សំគ្នា ដូចជាឥទ្ធិពលរបស់មនុស្សជុំវិញខ្លួនជាដើម។ ចេតនារបស់ក្មេងជំទង់ គឺដើម្បីទាក់ទាញអ្នកដទៃ និងដើម្បីការពារខ្លួន។ អំពើទំនើង ក៏នាំមកនូវផលអវិជ្ជមានជាច្រើនដល់សង្គម និងក្មេងជំទង់ខ្លួនឯងផ្ទាល់ផងដែរ។ មិនថាប្រទេសអ្នកមានឬអ្នកក្រ បញ្ហាក្មេងទំនើង បងតូចបងធំនេះ នៅតែជាកង្វល់ដល់សន្តិសុខ និងការអភិវឌ្ឍដូចៗគ្នា។

ដូច្នេះ ដើម្បីទប់ស្កាត់ជំងឺសង្គមទាំងនេះ មាតាបិតា អ្នកអាណាព្យាបាល អ្នកអប់រំ និងសង្គមទាំងមូល ក៏ដូចជាប្រទេសនានាលើលោក គួរតែយល់ដឹងអំពីអ្វីដែលកំពុងកើតឡើងក្នុងចំណោមយុវជន។ ទោះបីជាមានកត្តាចិត្តសាស្ត្រ និងរូបវន្តផ្សេងៗដែលបណ្តាលឱ្យបុគ្គលម្នាក់ជ្រើសរើសក្លាយជាសមាជិកក្រុមក្មេងទំនើងក៏ដោយ ក៏ឪពុក ម្តាយ ឬអ្នកអាណាព្យាបាលគួរជួយចិញ្ចឹមបីបាច់កូនដោយក្តីស្រឡាញ់ និងការគោរព ដើម្បីកាត់បន្ថយបញ្ហានេះ។ ក្មេងជំទង់ ក៏គួរគ្រប់គ្រងខ្លួនឯងដោយចូលរួមក្នុងសកម្មភាពសង្គមដែលមានសុខភាពល្អ ដូចជាកីឡា និងតន្ត្រី ដើម្បីឃ្លាតឆ្ងាយពីសកម្មភាពក្រុមក្មេងទំនើង។

ក្នុងវ័យជំទង់ យើងគួរតែបញ្ចេញកំហឹងរបស់យើងទៅជាអ្វីមួយផ្សេងទៀត ដូចជាចូលរួមក្លឹបប្រដាល់ តេក្វាន់ដូ ការច្រៀង ឬកីឡាជាដើម។ យើងត្រូវតែយល់ថា វាមិនត្រឹមត្រូវទេក្នុងការចូលរួមក្នុងក្រុមក្មេងទំនើង ដើម្បីបញ្ចេញសម្ពាធពីមិត្តភក្តិរបស់យើង។ យើងត្រូវតែនិយាយថា 'ទេ' ចំពោះអាកប្បកិរិយាអវិជ្ជមាន ដូច្នេះសកម្មភាពក្រុមក្មេងទំនើងនៅក្នុងសង្គមរបស់យើងនឹងថយចុះរហូតដល់កម្រិតសុវត្ថិភាពមួយ។

## គន្ថនិទ្ទេស

*១.កាសែតរស្មីកម្ពុជា ចុះផ្សាយនៅថ្ងៃទី៣១ កក្កដា ២០២២*

*២.កាសែតកម្ពុជាថ្មី ចុះផ្សាយនៅថ្ងៃទី២១ កញ្ញា ២០២៣*

*៣.ក្រសួងអប់រំ ភាសាខ្មែរថ្នាក់ទី៨  ២០២១*

*៤.ក្រមព្រហ្មទណ្ឌរបស់កម្ពុជា*

*៥. ក្រុមប្រឹក្សាជាតិភាសាខ្មែរ វចនានុក្រមខ្មែរ ផ្សាយដោយរាជបណ្ឌិត្យសភាកម្ពុជា ២០២២*

*៦.ជួន ណាត វចនានុក្រមខ្មែរ ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ១៩៦៧*

*៧.សារាចរលេខ០៤សរស្តីពីវិធានការបង្ការទប់ស្កាត់ និងបង្ក្រាប«ក្មេងទំនើង» ចុះថ្ងៃទី២៤ខែមិថុនាឆ្នាំ២០០៩*

*៨.*RFI *ផ្សាយនៅថ្ងៃទី២៧ មេសា ២០១៥*

*៩.*  Howell, 2006; Krohn, Ward, Thornberry, & Lizotte, 2011

*១០* .The approximated cost of gangs cannot be calculated since gang crimes are not routinely and systematically documented in most law enforcement agencies. (Hill et al., 1999)

## ប្រភពគេហទំព័រ

-http://www.fbi.gov>brief-history

- https://www.kampucheathmey.com

-https://www.cpc-news.com

-https://www.justice.gov

-https://www.khsearch.com

-https://isayon.wordpress.com

-https://www.bartleby.com

-https://www.wikihow.com

-http://www.16thcircuit.org

-http://www.quora.com

-http://www.ecosocc.gov.kh

-http://m.postkhmer.com

# វិន័យគ្រួសារ ជាគ្រឹះរឹងមាំ
# ជួយកុមារក្លាយជាមនុស្សធំជ៍ោគជ័យក្នុងសង្គម

ដោយៈ **ចាន់ សំណាង** មន្ត្រីនាយកដ្ឋានវិទ្យាសាស្ត្រអប់រំ
វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម
នៃរាជបណ្ឌិត្យសភាកម្ពុជា

## សេចក្តីផ្តើម

កាលដែលពួកយើងជាមនុស្សមានរបៀបរៀបរយ ត្រឹមត្រូវ ធ្វើអ្វីច្បាស់លាស់មានវិន័យ វាមិនមែនជារឿងងាយនោះទេ ហើយបើសិនជាពួកយើងមិនទម្លាប់រឿងនឹងទៀត វាកាន់តែពិបាក។

ប្រទេសមានច្បាប់ គ្រួសារមានវិន័យយ៉ាងណាមិញ ជីវិតនៅក្នុងគ្រួសារ ប្តីប្រពន្ធសុទ្ធតែមានតួនាទី និងភារកិច្ចដែលត្រូវរ៉ាប់រងទទួលខុសត្រូវផ្សេងៗគ្នា។ តែយ៉ាងណា ការបេះរួបរួមសាមគ្គីគ្នា វាគឺជារឿងដែលល្អបំផុត។[1]

ជាប្រពៃណី គ្រួសារ ជាអង្គភាពមូលដ្ឋានមួយនៅក្នុងសង្គម មានឪពុកម្តាយពីរនាក់ចិញ្ចឹមកូនៗរបស់ពួកគេ(Family is the basic unit in society traditionally consisting of two parents rearing their children)[2]។ ជនប្រុស ស្រីគ្រប់រូប តែងតែមានសេចក្តីប្រាថ្នាចង់បាន គ្រួសារមួយប្រកបដោយភាពកក់ក្តៅ និងមានសុភមង្គល ។ តែជាទូទៅការរៀបចំសុភមង្គលគ្រួសារ គឺជាចំណុចលំបាកសម្រាប់គ្រួសារមួយចំនួន ជាពិសេសគ្រួសារទើបតែរៀបការរួចថ្មីថ្មោង ហើយគ្រួសារខ្លះទៀតរហូតដល់បែកផ្លូវគ្នាក៏មាន។ សង្គមគ្រួសារ ជាប្រភពនៃសេចក្តីសុខ ទាំងផ្លូវចិត្តទាំងផ្លូវកាយ ហើយក៏អាចមានករណីខ្លះដែលផ្តល់ផលវិបាកផ្សេងៗដែរ ។ ឪពុកម្តាយ ខិតខំបីបាច់ថែរក្សា អប់រំទូន្មានប្រៀនប្រដៅកូនៗ ធ្វើយ៉ាងណាឱ្យកូនមានសុខភាពល្អ មានចំណេះដឹងមានអនាគតភ្លឺស្វាង និងក្លាយជាពលរដ្ឋល្អ

---

[1] ដកស្រង់ពីគេហទំព័រៈ https://www.knongsrok.com

[2] ដកស្រង់ពីគេហទំព័រៈ https//www.merrian-webster.com

ក្នុងសង្គម ។ ចំណែកកូនៗ ព្យាយាមត្រង់ត្រាប់ស្តាប់តាមដំបូន្មានចេះស្រឡាញ់គ្នា ធ្វើយ៉ាងណាដើម្បីសម្រេចតាមបំណងរបស់ឪពុកម្តាយ ។ ការចិញ្ចឹមបីបាច់ថែរក្សា ការស្រឡាញ់ ការសងគុណ ការបង្កើតបរិយាកាសរីករាយក្នុងរង្វង់គ្រួសារ ជាចំណងទាក់ទងមួយដ៏ប្រពៃសម្រាប់គ្រួសារដែលជំរុញឱ្យការរស់នៅប្រកបដោយភាពថ្លៃថ្នូរ សុខដុមរមនា ឯកភាពគ្នា ដើម្បីឈានទៅរកការឯកភាពគ្នាជាទូទៅក្នុងសង្គមទាំងមូល និងនៅលើសកលលោកក្នុងគោលបំណងបង្កើតវប្បធម៌សន្តិភាព ដែលជាសេចក្តីប៉ងប្រាថ្នារបស់មនុស្សទូទៅ ។[3]

ការវិវត្តនៃសង្គមមនុស្ស បានធ្វើឱ្យមានបម្រែបម្រួលអំពីចំនួននិងការរស់នៅរបស់មនុស្សខុសពីអតីតកាល។គ្រួសារបង្កើតទំនាក់ទំនងសង្គមមួយដែលផ្សារភ្ជាប់នឹងការបង្កើតជីវិតមនុស្សជាបន្តបន្ទាប់ ហើយមានសមាសភាពដូចជា ប្តី ប្រពន្ធ កូន ឬញាតិសន្តានដែលរស់នៅជាអចិន្ត្រៃយ៍ក្នុងផ្ទះតែមួយ។ គ្រួសារមានភាពចុះសម្រុងគ្នា និងរឹងមាំទៅបានមានកត្តាជាច្រើន។តើវា បង្កឡើងដោយកត្តាអ្វីខ្លះ? ដើម្បីឱ្យគ្រួសារនោះមានសេចក្តីសុខ មានសុភមង្គល និងមានវិន័យ ប្រកបដោយភាពថ្លៃថ្នូរ តើត្រូវធ្វើដូចម្តេច?

## ១.គ្រួសារ

មនុស្សម្នាក់ៗ មិនអាចរស់នៅដោយឯកោដាច់ដោយឡែក ម្នាក់ឯងបាននោះទេ គឺគេទាមទារការរស់នៅជាលក្ខណៈគ្រួសារ។ នៅក្នុងសៀវភៅសិក្សាសង្គមថ្នាក់ទី៨នៃក្រសួងអប់រំ បោះពុម្ពនៅឆ្នាំ២០១៥ ទំព័រ១៨៣ បានសរសេរ៖«គ្រួសារជាកោសិការនៃសង្គម និងជាក្រុមមនុស្សដែលរស់នៅក្រោមដំបូលតែមួយ»។ឯនៅក្នុងគេហទំព័រមើរៀន វេបស្ទើរ៍ (https//www.merrian-webster.com)សរសេរថា គ្រួសារជាក្រុមមនុស្សដែលរស់នៅក្រោមដំបូលតែមួយ ហើយជាធម្មតា វាស្ថិតក្រោមការដឹកនាំមួយ។[4]ចំណែកន័យមួយទៀត បានលើកឡើងថា គ្រួសារជាក្រុមដែលមានមនុស្សពីរនាក់ឬច្រើននាក់ដែលទាក់ទងនឹងកំណើតអាពាហ៍ពិពាហ៍ឬក៏ជាការសុំកូនមកចិញ្ចឹមដោយរស់នៅជាមួយគ្នា។ អ្នកពាក់ព័ន្ធទាំងអស់ត្រូវបានចាត់ទុកជាសមាជិកនៃគ្រួសារតែមួយ (A family is a group of two or more

[3] ក្រសួងអប់រំ សិក្សាសង្គម ថ្នាក់ទី៨ ទំព័រ១៨១ ឆ្នាំ ២០១៥

[4] Family is a group of individuals living under one roof and usually under one head.

persons related by birth, marriage, or adoption who live together; all such related persons are considered as members of one family. )[5](រូបទី១)។



រូបទី១៖ គ្រួសារខ្មែររីករាយ (រូបគេហទំព័រវេីតប្រែសដត់ខំ:wordprsess.com)

[5] https://www.hrsa.gov

## ២. ទំហំនៃគ្រួសារ

ជាទូទៅ យើងសង្កេតឃើញថា គ្រួសារខ្លះមានសមាជិកតិច គេកំណត់ថាជាគ្រួសារតូច រីឯគ្រួសារខ្លះទៀត មានសមាជិកច្រើន គេហៅថាគ្រួសារធំ។

គ្រួសារតូច ជាគ្រួសារដែលមានសមាជិកយ៉ាងច្រើនប្រាំនាក់រស់នៅជាមួយគ្នា មានដូចជា ឪពុកម្តាយ កូនប្រុស ស្រី និងអ្នកធ្វើការផ្ទះម្នាក់(រូបទី២)។



*រូបទី២៖សកម្មភាពឪពុកម្តាយបង្ហាត់បង្រៀន អប់រំនិងថែទាំកូនៗ*

*(រូបរបស់ក្រសួងអប់រំក្នុងសៀវភៅសិក្សាសង្គម)*

គ្រួសារធំ ជាគ្រួសារដែលមានសមាជិកលើសពីប្រាំនាក់ឬជាក្រុមមនុស្សដែលរស់នៅរួមគ្នាច្រើន ក្រោមដំបូលផ្ទះតែមួយ។គ្រួសារធំអាចមានសមាជិកដូចជា ជីដូន ជីតា ឪពុកម្តាយ  កូនប្រុស កូនស្រី មីង ពូ ក្មួយប្រុស ក្មួយស្រី។ល។[6](រូបទី៣)

[6] *ស្រង់ពីសៀវភៅសិក្សាសង្គមថ្នាក់ទី៨ របស់ក្រសួងអប់រំ ទំព័រ១៨៣-១៨៤ បោះពុម្ពឆ្នាំ២០១៥*



រូបទី៣៖រូបគ្រួសារធំដែលមានសមាជិកលើសពី៦នាក់ (រូបរបស់គេហទំព័រហ្វ្រីអុីមមិញជត់ខំ[7] )

## ៣.ប្រភេទនៃគ្រួសារ

ជាការពិតណាស់ គ្រួសារគឺជាអង្គការសង្គមសកល។ ប៉ុន្តែវាជាទម្រង់ រចនាសម្ព័ន្ធ ឬប្រភេទខុសគ្នាពីសង្គមមួយទៅសង្គម និងពីពេលមួយទៅពេលមួយ។ ដោយសារការប្រែប្រួលនៃស្ថានភាពជីវិត តម្លៃសង្គម វប្បធម៌ និងកត្តាមួយចំនួនទៀត ប្រភេទគ្រួសារផ្សេងៗគ្នាដែលបានរកឃើញថាមាន។

ដូច្នេះ វាពិតជាលំបាកណាស់ក្នុងការបែងចែកគ្រួសារ។ ប៉ុន្តែអ្នកសង្គមវិទូ និងនរវិទ្យាបានព្យាយាមចាត់ថ្នាក់គ្រួសារ។ ពួកគេចាត់ថ្នាក់គ្រួសារនៅលើមូលដ្ឋានផ្សេងគ្នា[8] នៅក្នុងសង្គម គ្រួសារនីមួយៗមានលក្ខណៈផ្សេងគ្នា។ ក្នុងន័យនេះ វាក៏មានន័យថា គ្រួសារក៏មានច្រើនប្រភេទដែរ។ ទោះយ៉ាងណាក៏ដោយផ្អែកលើសង្គមសាស្ត្រ ប្រភេទផ្សេងគ្នា ឬចំណាត់ថ្នាក់នៃគ្រួសារ គេបែកដូចតទៅ[9]៖

[7] https://www.freeimages.com

[8] ស្រង់ពីគេហទំព័រ៖https://www.yourarticlelibrary.com

[9] ស្រង់ពីគេហទំព័រ៖https://getuplearn.com

**ប្រភេទផ្សេងៗនៃគ្រួសារ**

(The different types of families)

| | |
|---|---|
| គ្រួសារតូច (Nuclear Family) | គ្រួសារដែលមានភាពឯករាជ្យដោយមានតែម្ដាយ ឪពុក និងកូនៗ។ (An independent family which just consists of a mum, dad and children.) |
| គ្រួសារធំ(Extended family) | គ្រួសារមួយដែលមានឪពុកម្ដាយ កូនប្រុសស្រី និងញាតិសន្ដាន ហើយរស់នៅជាមួយគ្នាឬផ្ដុំគ្នា។ (A family group that consists of parents, children, and other close relatives, often living in close proximity.) |
| គ្រួសារផ្សំផ្គុំ (Reconstituted families) | មនុស្សពីរនាក់រៀបការនឹងគ្នា ក៏ប៉ុន្ដែមានកូនពីចំណងទាក់ទងផ្សេងដែលមិនជាកូនខ្លួនបង្កើត។ (Two people who get married but also have children from another relationship.) |
| គ្រួសារមានតែឪពុកឬមានតែម្ដាយ (Lone parent families) | គ្រួសារមួយដែលកើតឡើងពីការរឹតចំណងនឹងគ្នាបន្ទាប់ពីការលែងលះឬបែកបាក់ថ្មីៗ (A family that is run by a single parent after a recent divorce or split.) |
| គ្រួសារខ្ពង់ខ្ពស់ (Beanpole families) | ប្រភេទនេះ ឆ្លុះពីបម្រើបម្រាស់យូរអង្វែងនៃពាក្យ«***ភាពជាសាច់ញាតិ***»ក្នុងមុខវិជ្ជានរវិទ្យាដែលសម្ដៅលើបណ្ដាញទំនាក់ទំនងសង្គមដែលបង្កើតជាផ្នែកសំខាន់នៃជីវិតមនុស្សភាគច្រើននៅក្នុងសង្គមនានា ទោះបីជាអត្ថន័យពិតនៃជីវិតដែលគេតែងលើកយកមកពិភាក្សាដេញដោលជាញឹកញាប់ក៏ដោយ ក៏វាត្រូវផ្សារភ្ជាប់នឹងវិន័យដែរ។ (This article reflects the long-standing use of the term kinship in anthropology, which refers to the web of social relationships that form an important part of the lives of most humans in most societies, |

| | |
|---|---|
| | although its exact meanings even within this discipline are often debated.) |
| គ្រួសារប៊ូមេរ៉ែង((Boomerang families) | មនុស្សវ័យជំទង់ដែលត្រឡប់ទៅរស់នៅជាមួយគ្រួសាររបស់គាត់វិញ ជាពិសេសសម្រាប់ហេតុផលហិរញ្ញវត្ថុ។ (a young adult who returns to live at his or her family home especially for financial reasons.) |
| គ្រួសារសមមាត្រឬស៊ីមេទ្រី (Symmetrical families) | គ្រួសារសមមាត្រឬស៊ីមេទ្រី គឺជាគ្រួសារដែលមានតួនាទីប្រុស និងស្រី។ឧទាហរណ៍៖ស្ត្រីនឹងទៅធ្វើការដូចបុរស ហើយបុរសមើលថែកូនៗ។ ស្ត្រីក៏ដូច្នោះដែរ វាជាមូលដ្ឋានចែករំលែកការងារគ្រួសារដោយស្មើភាព មិនថាអ្នកជាបុរសឬស្ត្រីនោះទេ។( A symmetrical family is a family that shares male and female roles. For example a woman will go to work just like the man will, a man will take care of these kids and so will the woman. It's basically sharing household jobs out fairly whether you are a male or female.) |

## ៤.វិន័យគ្រួសារ

វិន័យ មកពីពាក្យវិនយ (ន.)(សំ.បា.វិនយ)ការដឹកនាំទៅរកផ្លូវល្អ ច្បាប់ ច្បាប់បញ្ញត្តឬច្បាប់អនុញ្ញាត ច្បាប់ប្រដៅឱ្យប្រព្រឹត្តត្រឹមត្រូវ ច្បាប់ប្រដៅឱ្យសង្រួមកាយវាចាឱ្យត្រឹមត្រូវ ឱ្យចុះបែបបទឱ្យមានសណ្ដាប់ធ្នាប់ល្អ។[10] និយាយឱ្យខ្លីទៅ«វិន័យ»មានន័យថា ក្បួនប្រដៅមនុស្សឱ្យប្រព្រឹត្តិល្អ ទាំងកាយ ចិត្ត និងវាចា។ឧទាហរណ៍៖ ការមានវិន័យល្អ នាំឱ្យយើងជោគជ័យគ្រប់ភារកិច្ច។[11] គ្រួសារត្រូវមានវិន័យ ព្រោះគ្រួសារ ជាសង្គមតូចមួយដែលទាមទារឱ្យមានរបៀបរបបត្រឹមត្រូវមួយច្បាស់លាស់ ទើបគ្រួសារនោះមានភាពថ្កុំថ្កើង។

[10] វចនានុក្រមសម្ដេច ជួន ណាត

[11] https://thmeythmey.com

### ៤.១.សីលធម៌គ្រួសារ

គ្រួសារនីមួយៗ តែងចង់បានសុភមង្គល ពិតប្រាកដ រស់នៅមានការចុះសម្រុងនិងឯកភាពគ្នាក្នុងគ្រួសារទាំងមូល(រូបទី២)។ ម្ដាយឪពុកមួយចំនួន បានអប់រំលើលធម៌ដល់កូនរបស់ខ្លួនទៅតាមវិធីដែលគេធ្លាប់បានទទួលពីឪពុកម្ដាយរបស់គេដែរ។ខាងក្រោមនេះ ជាវិធីសាស្ត្រមួយចំនួនសម្រាប់បណ្ដុះបណ្ដាលនូវក្រមសីលធម៌ដល់កូនៗដូចជាម្ដាយឪពុកៈ

- ទទួលខុសត្រូវក្នុងការបង្កើតឱ្យមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយសមាជិកគ្រួសារទាំងអស់
- ស្រឡាញ់ថ្នាក់ថ្នម យោគយល់ មិនរើសអើង
- ឧបត្ថម្ភគាំទ្រចំពោះសមាជិកគ្រួសារទាំងអស់
- អត់ធ្មត់ ធ្វើពលិកម្ម ដើម្បីឱ្យកូនក្លាយជាមនុស្សល្អ
- ផ្ដល់ឱកាសឱ្យកូនស្វែងរកបទពិសោធន៍ក្នុងសង្គម។[12]



រូបទី២ៈ រូបគ្រួសារតូចរស់នៅប្រកបដោយសុភមង្គល
(រូបរបស់ក្រសួងអប់រំក្នុងសៀវភៅសិក្សាសង្គម ថ្នាក់ទី៨)

---

[12] ក្រសួងអប់រំ សិក្សាសង្គម ថ្នាក់ទី៨ ទំព័រ១៨៩ ឆ្នាំ ២០១៥

### ៤. ២. តម្លៃនៃគ្រួសារ

*ប្រទេសមានច្បាប់ គ្រួសារមានវិន័យ ជាពាក្យស្លោកមួយដែលគេតែងតែនិយាយ។ ទាក់ទងនឹងចំណុចនេះ* ***លោកលី ខ្វាន់យូ រដ្ឋបុរសនៃប្រទេសសិង្ហបុរី*** *បានដាក់ចេញនូវគោលការណ៍៣ក្នុងការរក្សារបៀបរៀបរយសង្គម ដោយផ្សារភ្ជាប់នឹងការប្រើគ្រឿងស្រវឹង។ គោលការណ៍៣នោះ រួមមានៈ*

1. *កំណត់អាយុអ្នកផឹកស្រា*
2. *ហាមលក់ស្រានៅទីសាធារណៈ*
3. *បើកបរក្នុងស្ថានភាពស្រវឹងត្រូវមានទោស*

*ផ្អែកលើគោលការណ៍៣ចំណុចរបស់មេដឹកនាំរូបនេះ បានធ្វើឱ្យប្រទេសសិង្ហបុរីទទួលបាននូវការសរសើរ ហើយប្រជាពលរដ្ឋឃ្លាតឆ្ងាយពីគ្រឿងស្រវឹងដោយពួកគេយល់ឃើញថា បើពិសារគ្រឿងស្រវឹងធ្វើឱ្យខាតទាំងលុយទាំងខុសច្បាប់ និងអាប់ឱនទាំងកិត្តិយស។*[13] *គ្រួសារ ក៏មិនខុសពីប្រទេសជាតិដែរ ពោលគឺច្បាប់ជាអ្នកកំណត់នូវភាពស្របច្បាប់នៃគ្រួសារនីមួយៗ។ ការឯកភាពគ្នាក្នុងគ្រួសារជាទង្វើមួយដែលផ្តល់តម្លៃជាពិសេសសម្រាប់គ្រួសារ។*

*ហេតុនេះ យើងត្រូវចេះថែរក្សាតម្លៃគ្រួសារដោយផ្អែកលើកត្តាមួយចំនួនដូចខាងក្រោមៈ*

- ***ភាពស្និទ្ធស្នាលក្នុងគ្រួសារៈ*** *ម្តាយឪពុក និងសមាជិកដទៃទៀតត្រូវចេះសហការគ្នាយ៉ាងជិតស្និទ្ធគ្រប់ពេលវេលា ដើម្បីនាំភាពថ្លៃថ្នូរដល់គ្រួសារទាំងមូល។ ម្តាយឪពុកគួរមានអាកប្បកាយសុភាពរាបសា និងត្រៀមខ្លួនជានិច្ចដើម្បីជួយកូន ។ ចំណែកកូនៗវិញ ត្រូវស្តាប់បង្គាប់ដឹងគុណ គោរពម្តាយឪពុក ។*
- ***ទំនាក់ទំនងល្អជាមួយអ្នកជិតខាងៈ*** *បំណងល្អអាចបង្ហាញតាមរយៈការជួយគ្នា ទាំងកម្លាំងកាយ ទាំងស្មារតី នៅពេលដែលអ្នកណាម្នាក់ជួបការលំបាក ឬគ្រោះថ្នាក់អ្វីមួយ ។ អ្នកមិនគួរនិយាយ មិនល្អ ឬជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងអ្នកជិតខាងឡើយ លើក*

[13] *ដកស្រង់ពីហ្វេសប៊ុកផេកៈ* K P Developer Land &House *ផ្សាយនៅថ្ងៃទី២៤ កក្កដា ២០២១*

*លែងតែមានសំណូមពរឱ្យជួយ ដូចពាក្យចាស់លោកបានពោលថា «**យកមនុស្សធ្វើរបង ប្រសើរជាងយកឈើធ្វើរបង**»។*

- ***ផែនការសេដ្ឋកិច្ចគ្រួសារ** : សមាជិកគ្រួសារម្នាក់ៗ ត្រូវចេះសហការគ្នាដើម្បីរកចំណូល សម្រាប់គ្រួសារ ចេនដោះស្រាយចំពោះការលំបាកក្នុងគ្រួសារ កូនមិនត្រូវបង្ខំឱ្យម្ដាយឪពុកទិញរបស់ណាដែលមិនចាំបាច់នោះឡើយ ត្រូវយកចិត្តទុកដាក់ចំពោះការងាររបស់ខ្លួន ថាតើ ត្រូវចិញ្ចឹមជីវិតបែបណា ធ្វើយ៉ាងណាដើម្បីឱ្យគ្រួសារមានជីវភាពធូរធារ ខិតខំស្វែងរកជំនាញ សម្រាប់អនាគត ។*
- ***រក្សាកេរ្តិ៍ឈ្មោះគ្រួសារ៖** កូនប្រុសស្រីមិនត្រូវប្រព្រឹត្តអំពើមិនល្អដូចជា លួចទ្រព្យគេប្រើថ្នាំ ញៀន ផឹកគ្រឿងស្រវឹង ចៀសវាងរាល់សកម្មភាពខុសច្បាប់សង្គម ផ្ទុយទៅវិញ ត្រូវថែរប្រកាន់អាកប្បកិរិយាថ្លៃថ្នូរទៅតាមទំនៀមទម្លាប់ ប្រពៃណីរបស់គ្រួសារ និង សហគមន៍ ។[14]*

## **៤. ៣. វិន័យគ្រួសារ**

*ឪពុក ម្ដាយ ជាគ្រូដើម(បុព្វាចារ្យ)របស់កូនប្រុសស្រី។ម្ដាយឪពុក ឬឪពុក ឬម្ដាយ មានតួនាទីជាអាណាព្យាបាលលើសមាជិកដទៃក្នុងគ្រួសារ។[15] ពេលឪពុកម្ដាយចេះកសាងវិន័យគ្រួសារ វានឹងនាំឱ្យគ្រួសារនោះរីកចម្រើននិងមានកេរ្តិ៍ឈ្មោះល្អ។ ការបង្កើតវិន័យ ចាំបាច់បំផុតសម្រាប់ក្មេងគ្រប់វ័យ កុំរង់ចាំទាល់តែកើតបញ្ហា ។ វិន័យ ត្រូវតែបង្កើតឲ្យក្មេងតាំងពីនៅតូច កាន់តែតូចប៉ុណ្ណា កាន់តែល្អ ព្រោះវិន័យល្អ ជាបែបបទមួយកើតជាមួយក្មេងហើយ និងនៅតាមខ្លួនគេរហូតដល់ធំ ហើយក្លាយជាចំណែកមួយរបស់ធម៌ប្រចាំចិត្តរបស់គេអស់មួយជីវិត។[16]តាមពិតទៅ ការបង្កើតវិន័យ វាជារឿងមិនពិបាកសោះ ពីព្រោះសូម្បីតែនៅផ្ទះក៏យើងអាចធ្វើវាបានដែរ ដូចជាការកំណត់ម៉ោងគេង ម៉ោងទទួលទាន*

---

[14] *ក្រសួងអប់រំ សិក្សាសង្គម ថ្នាក់ទី៨ ទំព័រ១៨៧ ឆ្នាំ ២០១៥*

[15] *ដកស្រង់៖ ឯកសារ ការអប់រំ ជាកិច្ចការទាំងអស់គ្នា ទំព័រ១៥ របស់លោកប៉ាន់ សំណាង ផ្សាយដោយវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គមនៃរាជបណ្ឌិត្យសភាកម្ពុជា*

[16] https://buyloy.com

អាហារ ពេលសម្រាកលំហែ ម៉ោងរំលឹកមេរៀន ជាដើម។

ក្រុមអ្នកសិក្សា ស្រាវជ្រាវអំពីវិធីសាស្ត្រប្រៀនប្រដៅកូនចៅបានឲ្យដឹងថា កុមារដែលមាន អាយុចាប់តាំងពីថ្ងៃចាប់កំណើតពីផ្ទៃម្តាយរហូតពេញវ័យ ត្រូវការថ្នាក់ថ្នមប្រាស្រ័យទាក់ទងតាមបែបសន្តិភាព ដើម្បីឲ្យខួរក្បាលរីកចម្រើន និងកាយសម្បទាមាំមួន។ ផ្ទុយទៅវិញបើគេប្រើហិង្សា ទៅលើកុមារ កុមារនោះនឹងភ្លេចភ្លាំង រៀនមិនឆ្លាត។ ប្រការនេះ មានសារសំខាន់ណាស់ចំពោះឪពុកម្តាយគ្រប់រូបដែលចង់អប់រំកូនចៅឲ្យឆ្លាតឈ្លាសវៃ។ការចិញ្ចឹមបីបាច់ថែរក្សាកូន គឺជាការងារលំបាក មួយរបស់ឪពុកម្តាយក្នុងចំណោមការងារ ចំពោះមុខផ្សេងៗទៀតក្នុងជីវិតគ្រួសារ និងក្នុងសង្គមជាតិ។ នៅពេលដែលកូនកើតមក ហើយឪពុកម្តាយមានកាតព្វកិច្ចចិញ្ចឹម និង អប់រំកូនឱ្យបានល្អ។[17]

គ្រួសារនីមួយៗ កុមារគ្រប់រូប និងគ្រប់ស្ថានភាពគឺខុសគ្នា។ ពេលខ្លះ ការផ្លាស់ប្តូររបៀបដែលយើងកំណត់តួនាទីនៃការចិញ្ចឹមបីបាច់កូនអាចផ្តល់ការបញ្ជាក់ឱ្យច្បាស់។ នៅគ្រប់ស្ថានការណ៍ អ្នកគប្បីចាំថាអ្នក គឺជាអ្នកដឹកនាំ មានសមត្ថភាពផ្តល់ការណែនាំ ការបណ្តុះបណ្តាល និងការលើកទឹកចិត្ត។

នៅក្នុងគ្រួសារអ្នកដឹកនាំភាគច្រើនច្រើនតែមានវិន័យរបស់គ្រួសាររបស់គេ។ ប្រសិនបើគ្រួសារមួយ ទទួលបាននូវការគ្រប់គ្រងល្អ ក៏ដូចជាមានវិន័យត្រឹមត្រូវ នោះសមាជិកក្នុងក្រុមគ្រួសារនោះ នឹងបន្តក្លាយជាកម្លាំងដ៏ខ្លាំងនៃសង្គម ពីព្រោះគ្រួសារជាផ្នែកមួយជួយក្នុងការអភិវឌ្ឍសង្គមមួយបានយ៉ាងល្អ។

ជាក់ស្តែងក្នុងសង្គមចិន គ្រួសារចិនតែងតែមានវិន័យសម្រាប់គ្រួសារនីមួយៗ ស្របតាមទស្សនៈដឹកនាំនានា តួយ៉ាងគ្រួសារ**លោក ម៉ៅ សេទុង**។ **លោក ម៉ៅ សេទុង** គឺជាអ្នកបដិវត្តកុម្មុយនីស្តដ៏លេចធ្លោរបស់ចិននិងជាបិតាស្ថាបនិកសាធារណរដ្ឋប្រជាមានិតចិន។ លោកបានចូលរួមជាមួយនឹងបញ្ញវន្តចិនដទៃទៀត បង្កើតបក្សកុម្មុយនីស្តចិន(CPC) ជាលើកដំបូងនៅឆ្នាំ១៩២៣ និង ក្លាយជាប្រធានគណបក្សកុម្មុយនីស្តពីឆ្នាំ១៩៤៩ដល់ឆ្នាំ១៩៧៦ ពោលគឺរហូតដល់លោកស្លាប់បាត់បង់ជីវិតតែម្តង។ **លោក ម៉ៅ** ក៏ធ្លាប់ជាប្រធានរដ្ឋាភិបាលកណ្តាលប្រជាជនចិន ជា

[17] https://www.rfa.org

ប្រធានគណៈកម្មការយោធាកណ្ដាលផងដែរ។ ប៉ុន្តែមុនទទួលបានជោគជ័យក្នុងបដិវត្តន៍ ម៉ៅ សេទុង បានឆ្លងកាត់នូវរឿងរ៉ាវជាច្រើន ។

**លោក ម៉ៅ សេទុង** ឬ ហៅម្យ៉ាងទៀតថា **ប្រធានម៉ៅ** កើតថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ១៨៩៣ នៅក្នុងគ្រួសារកសិករមួយ រស់នៅទីជនបទនៃស្រុកសាវសាន ខេត្តហ៊ូណានប្រទេសចិន។ ឪពុករបស់លោកឈ្មោះថា ម៉ៅ អ៊ីចាង (Mao Yichang) ជាមនុស្សមានវិន័យ តឹងរ៉ឹងបំផុត ហើយម្ដាយ មានឈ្មោះ វិន ឈីម៉ី (Wen Qimei) ។ នៅអាយុ ៨ឆ្នាំ **ម៉ៅ សេទុង** បានចូលរៀននៅសាលាបឋមសិក្សាក្នុងភូមិ និងត្រូវ ឪពុកបង្ខំឱ្យរៀនសូត្រតាមពាក្យប្រៀនប្រដៅរបស់**ខុងជឺ**យ៉ាងខ្ជាប់ខ្ជួនបំផុត ។ **ម៉ៅ** ក៏បានប្រឡងជាប់ចូលរៀននៅសាកលវិទ្យាល័យក្នុងខេត្តហ៊ូណានផងដែរ និងបានខិតខំប្រឹងប្រែងសិក្សារៀនសូត្រយ៉ាងខ្លាំង ។ បន្ទាប់ពីនោះ **ម៉ៅ សេទុង** បានបន្តរៀននៅសាកលវិទ្យាល័យក្នុងក្រុងប៉េកាំង ។ **ម៉ៅ** រៀនផង ធ្វើការជាជំនួយការបណ្ណារក្សក្នុងបណ្ណាល័យផង។ **ម៉ៅ** ជាមនុស្សចូលចិត្តអានសៀវភៅ និងអានមិនរើសថាជាមុខវិជ្ជាអ្វីឡើយ។ បណ្ណាល័យនេះឯងដែលជាឃ្លាំងនៃចំណេះដឹង និងជាប្រភពសន្ទុំបញ្ញារបស់**ម៉ៅ សេទុង** ។ មានការនិយាយតៗគ្នាថា ចំណេះដឹងដែលបានមកពីបណ្ណាល័យ ក្រុងប៉េកាំងនោះហើយ ជាដើមទុនសម្រាប់ឱ្យ**ម៉ៅ សេទុង** ធ្វើបដិវត្តន៍ផ្លាស់ប្ដូររបបគ្រប់គ្រង ប្រទេសចិនទាំងមូល ។[18]

## ៥គន្លឹះសំខាន់ៗក្នុងការជួយកុមារឱ្យក្លាយជាមនុស្សធំរឹងមាំ

ឪពុកម្ដាយមួយចំនួន ប្រហែលជាធ្លាប់ខ្មាសគេនៅទីសាធារណៈពេលកូនៗរបស់អ្នកមិនស្ដាប់បង្គាប់ និងបង្ករឿងផ្សេងៗ ហើយអ្នកប្រហែលជាគិតថា វាជាធម្មជាតិរបស់កុមារគ្រប់រូប។ ប៉ុន្តែ មាតាបិតាគ្រប់រូបតែងតែចង់ជួយកូនៗឲ្យមានអត្តចរិកល្អ និងមានជីវិតរស់នៅងាយស្រួល។

ហេតុនេះ «***ការមានវិន័យ***» ជាផ្នែកសំខាន់បំផុតអាចជួយពួកគេឱ្យក្លាយជាមនុស្សធំ ដែលមានភាពជោគជ័យទៅថ្ងៃអនាគត។ គន្លឹះមួយចំនួនខាងក្រោមនេះ អាចជាជំនួយ ដើម្បីជួយឱ្យកូនអ្នកមានវិន័យល្អក្នុងការរស់នៅៈ

### ក. ការកំណត់ទម្លាប់ក្នុងការរស់នៅ

- ***ប្រាប់ពួកគេពីហេតុផលច្បាស់លាស់***

[18] https://www.vayofm.com

មាតាបិតាមិនតម្រូវឱ្យពន្យល់កូនៗថាហេតុអ្វីអ្នកចង់ឱ្យពួកគេត្រូវតែមានវិន័យនោះទេ ប៉ុន្តែ ប្រសិនបើកូនរបស់អ្នកយល់ពីហេតុផលសាមញ្ញ ពីច្បាប់ទម្លាប់របស់អ្នកនោះ ពួកគេនឹងមិនរឹងទទឹង ហើយអនុវត្តតាមការប្រាប់របស់អ្នក។ ឧទាហរណ៍ អ្នកប្រាប់ពួកគេឱ្យចូលគេងនៅម៉ោង៨យប់ ពីព្រោះខួរក្បាលរបស់ពួកគេត្រូវការការគេងឱ្យបានច្រើន ដើម្បីសុខភាពល្អ និងរឹងមាំ ឬឱ្យពួកគេទុកដាក់របស់របរលេងឱ្យមានរបៀប ដើម្បីងាយស្រួលរក នៅពេលក្រោយ។

- **ផ្តល់ការសរសើរដល់ពួកគេ**

នៅពេលពួកគេជួយអ្នករៀបចំកន្លែងគេង តុញ៉ាំបាយ ឬឱ្យប្អូនរបស់គេលេងតុក្កតាជាមួយ អ្នកគួរតែសរសើរពីទឹកចិត្តរបស់ពួកគេ។ ឧទាហរណ៍ កូនពិតជាកូនល្អមែនដែលចង់ចាំពេលវេលារៀបចំកន្លែងគេង ឬម៉ាក់ប៉ាពិតជាសប្បាយចិត្តណាស់ដែលកូនមានអាកប្បកិរិយាដូចមនុស្សធំម្នាក់។

- **ដើរតួជាបុគ្គលគំរូ**

ការទុកដាក់របស់របរនៅពេលមកពីក្រៅ ដូចជាកាបូប ឬព្យួរខោអាវឱ្យមានរបៀប និងត្រូវកន្លែង ការមិនបញ្ចេញកំហឹង ឬនិយាយទាំងមួម៉ៅ នៅពេលធ្វើអ្វីមួយមិនបានសម្រេច...។ សកម្មភាពទាំងនេះនឹងបង្ហាញកូនៗអ្នក ពីគំរូដែលគេយកតម្រាប់តាម នៅពេលកូនៗឃើញទម្លាប់ល្អរបស់អ្នករាល់ថ្ងៃ ពួកគេនឹងចង់ធ្វើដូចអ្នកដែរ។

**ខ. ការដោះស្រាយបញ្ហា**

- **អនុញ្ញាតឱ្យកូនៗជាអ្នកធ្វើការសម្រេចចិត្ត**

ផ្តល់ឱកាសឱ្យកូនៗអ្នកក្នុងការសម្រេចចិត្តជ្រើសរើសអ្វីមួយដោយខ្លួនឯងនៅពេលពួកគេធំគ្រប់គ្រាន់។ ឧទាហរណ៍ ការជ្រើសរើសសម្លៀកបំពាក់ ឬបន្លែ ផ្លែឈើ ដែលពួកគេចង់ញ៉ាំ។ នៅពេលពួកគេអាចគ្រប់គ្រងលើចំណុចតូចៗបានពួកគេអាចឈានដល់ការសម្រេចចិត្តលើស្ថានភាពផ្សេងៗទៀតបាន។ ប្រសិនបើកូនៗអ្នក ឈ្លោះគ្នា ឬវាយគ្នា ជំនួសការគំរាមពួកគេ ឬស្រែកឲ្យពួកគេឈប់ អ្នកគួរតែសួរពួកគេថា "តើកូនអាចដោះស្រាយបញ្ហា តាមវិធីផ្សេងពីនេះឬទេ"។ អ្នកនឹងមានភាពភ្ញាក់ផ្អើលចំពោះដំណោះស្រាយរបស់ពួកគេ។

- **ផ្តល់ការលើកទឹកចិត្ត៖ «ព្យាយាម ព្យាយាមម្តងទៀត»**

ការងារមួយចំនួន អ្នកអាចធ្វើវាបានដោយខ្លួនឯង ប៉ុន្តែ រឿងសំខាន់ដែលគួរតែឱ្យកូនៗរបស់អ្នកសាកល្បងធ្វើវាដោយខ្លួនឯង

ដូចជា រៀបចំខ្លួនស្លៀកសម្លៀកបំពាក់ទៅសាលា ការបោកគក់ ខោអាវជាដើម។ ការចាប់ផ្តើមដំបូងអាចនឹងមិនមានភាពល្អឥតខ្ចោះ តែអ្នកអាចនិយាយទៅកាន់ពួកគេថា «កូនធ្វើបានល្អហើយ លើកក្រោយ កូននឹងធ្វើបានល្អជាងនេះទៀត»។

**• ជួយឱ្យពួកគេចេះរកដំណោះស្រាយ**

ដើម្បីពង្រឹងដល់ការគិតរបស់កូនៗ អ្នកគួរតែជំរុញឱ្យពួកគេត្រិះរិះពីចម្លើយនៃសំណួររបស់ពួកគេ។ ឧទាហរណ៍ នៅពេលកូនៗរបស់អ្នកសួរថា តើពួកគេត្រូវធ្វើដូចម្តេចចំពោះអ្វីមួយ អ្នកគួរតែឆ្លើយតប ដោយផ្តល់ទំនុកចិត្តទៅកាន់ពួកគេថា «តើកូនគិតថា គួរតែធ្វើយ៉ាងដូចម្តេច?»។

## គ. បង្រៀនកូនៗអ្នកឱ្យចេះអត់ធ្មត់

**• បង្ហាត់បង្រៀនកូនៗឱ្យចេះរង់ចាំ**

ចូរកុំផ្តល់ឱ្យរាល់ការទាមទាររបស់កូនៗអ្នកលឿនពេក អ្នកអាចឱ្យពួកគេធ្វើការរង់ចាំ ដោយផ្តល់ហេតុផលសមរម្យមួយ។ ឧទាហរណ៍ ពួកគេសុំឱ្យអ្នកធ្វើទឹកក្រូចប្រឡាក់ឱ្យគេញ៉ាំ ស្របពេលអ្នកកំពុងជាប់រវល់ការងារ អ្នកអាចឱ្យពួកគេរង់ចាំបន្ទាប់ពីអ្នកបញ្ចប់ការងារសិន។ ការធ្វើរបៀបនេះមានន័យថា អ្នកកំពុងបង្រៀនពួកគេឱ្យចេះគ្រប់គ្រងលើភាពអត់ធ្មត់ និងចេះផ្តល់អត្ថិភាពលើការងារ។

**• ប្រាប់ពីអារម្មណ៍របស់ពួកគេ**

កូនៗរបស់អ្នកប្រហែលជាពិបាកក្នុងការបកស្រាយអារម្មណ៍របស់ពួកគេនៅពេលត្រូវរង់ចាំអ្វីមួយ ហើយពួកគេមិនអាចអត់ធ្មត់បាន ប៉ុន្តែ អ្នកអាចជួយពួកគេកំណត់នូវអារម្មណ៍នោះបាន។ ឧទាហរណ៍ ពួកគេត្រូវតម្រង់ជួរយូរដើម្បីរង់ចាំដល់វេនពួកគេ អ្នកអាចប្រាប់ពួកគេថា «កូនពិតជាធ្វើវាបានល្អ ហើយកូនកំពុងរៀនអត់ធ្មត់ចំពោះរឿងដែលកូនកំពុងតែធ្វើ»។ ការវាយតម្លៃលើអារម្មណ៍ នៅពេលពួកគេប្រឹងប្រែងប្រឹងបែបនេះ វាអាចជួយពួកគេឱ្យព្យាយាមអត់ធ្មត់បន្ថែមទៀត។

**• ឱ្យពួកគេចូលរួមក្នុងសកម្មភាពដែលជួយពួកគេឱ្យចេះអត់ធ្មត់**

លើកទឹកចិត្តពួកគេឱ្យចូលរួមក្នុងសកម្មភាពដែលមិនបង្ហាញលទ្ធផលភ្លាមៗ ដូចជាការដាំដើមឈើ ហើយមើលថែវារហូតចេញជាផ្លែផ្កា ការលេងហ្គេមផាស្សល (Puzzle) តម្រៀបអក្សរ ឬគូររូបជាដើម។ បង្រៀនពួកគេឱ្យឃើញពីការវិវឌ្ឍជាដំណាក់រហូតបានជាលទ្ធផល គឺត្រូវតែរង់ចាំមើល

ថែទាំ និងយកចិត្តទុកដាក់ចំពោះសកម្មភាពរបស់ពួកគេ។[19]

## សន្និដ្ឋាន

ជារួម យើងអាចសន្និដ្ឋានបានថា វិន័យ គឺសំដៅលើការផ្លាស់ប្តូរអាកប្បកិរិយា មិនមែនអំពើការដាក់ទណ្ឌកម្មលើកុមារទេ។[20] វិន័យ អនុញ្ញាតឱ្យកុមារអភិវឌ្ឍការប្រៀនប្រដៅខ្លួនឯង និងជួយពួកគេឱ្យក្លាយជាមនុស្សពេញវ័យដែលមានភាពចាស់ទុំខាងផ្លូវចិត្ត ផ្លូវកាយនៅក្នុងសង្គមរស់នៅ។ ទោះមានបច្ចេកទេសដ៏មានប្រសិទ្ធភាពជាច្រើនដែលអាចជួយមាតាបិតាបង្រៀន និងណែនាំកូនរបស់ពួកគេ ហើយទម្រង់នៃការប្រៀនប្រដៅមួយចំនួននឹងនៅតែមានភាពចម្រូងចម្រាសខ្លះដែរ។ តួនាទីរបស់គ្រូបង្រៀនដែលជាឪពុកម្តាយគឺត្រូវចាត់វិធានការទុកជាមុនចំពោះវិន័យ ដែលពាក់ព័ន្ធនឹងបច្ចេកទេសដែលប្រើនៅក្នុងផ្ទះ។ ទិដ្ឋភាពដែលមានតុល្យភាពគួរតែត្រូវបានផ្តល់ជូនដល់ក្រុមគ្រួសារ។ ការយកចិត្តទុកដាក់ជាពិសេសគួរតែត្រូវបានផ្តល់ទៅឱ្យអាយុ កម្រិតនៃការអភិវឌ្ឍ និងនិស្ស័យរបស់កុមារនៅពេលផ្តល់ដំបូន្មានអំពីមធ្យោបាយនៃវិន័យប្រកបដោយប្រសិទ្ធភាព។ ការពិចារណាគួរតែត្រូវបានផ្តល់ទៅឱ្យភាពខុសគ្នានៃវប្បធម៌ ហើយការកែតម្រូវគួរតែត្រូវបានធ្វើឡើងសម្រាប់កុមារដែលមានបញ្ហាក្នុងការអភិវឌ្ឍ។ វាចាំបាច់ណាស់ក្នុងការបញ្ជាក់ដល់មាតាបិតាអំពីសារៈសំខាន់នៃភាពជាប់លាប់ ការធ្វើជាគំរូល្អ និងជៀសវាងការគំរាមកំហែង ពោលគឺមិនធ្វើតាមដោយរំពឹងលទ្ធផល។ វិន័យដែលមានប្រសិទ្ធភាពគួរតែផ្អែកលើអង្គហេតុសិក្សាជាជាងការយល់ឃើញតាមប្រធានបទ។ ដូច្នេះ វិន័យគ្រួសារនេះ គួរតែត្រូវបានចាត់ទុកជាកម្មវត្ថុនៃការពិនិត្យពិចារណាសម្រាប់ឪពុកម្តាយ ក៏ដូចជាអ្នកអាណាព្យាបាលដែរ ព្រោះការអនុវត្តជាក់ស្តែងប្រហែលជាមិនបង្ហាញលទ្ធផលភ្លាមៗនោះទេ តែឪពុកម្តាយគួរតែកត់សម្គាល់ពីបម្រែបម្រួលអត្តចរិករបស់កូនៗ ឱ្យតែមានភាពប្រសើរឡើងបន្តិច នោះមានន័យថា អ្នកទទួលបានជោគជ័យក្នុងការជួយពួកគេហើយ។ ថ្ងៃអនាគត កូនៗរបស់អ្នកនឹងដឹងពីបំណងល្អរបស់អ្នក ហើយនឹងធ្វើបែបនេះបន្តទៅកាន់កូនៗរបស់ពួកគេដែរ។

---
[19] https://healthtime.tips
[20] https://www.ncbi.nlm.nih.gov

## គន្ថនិទ្ទេស


-ក្រសួងអប់រំ *សៀវភៅសិក្សាសង្គម ថ្នាក់ទី៨* ២០១៥

-ប៉ាន់ សំណាង *ការអប់រំ ជាកិច្ចការទាំងអស់គ្នា* ផ្សាយរបស់រាជបណ្ឌិត្យសភាកម្ពុជា ២០២២

-ជួន ណាត *វចនានុក្រមខ្មែរ ផ្សាយដោយពុទ្ធសាសនបណ្ឌិត្យ* ១៩៦៧

-Facebook page: K P Developer Land & House ផ្សាយថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២១

-https://www.buyloy.com

-https://www.freeimages.com

-https://www.getuplearn.com

-https://www.knongsrok.com

-https://www.healthtime.tips

-https://www.hrsa.gov

-https://www.merian-webster.com

-https://www.ncbi.nlm.nih.gov

-https://www.rfa.org

-https://www.pinterest.com

-https://www.thmeythmey.com

-https://www.yourarticlelibrary.com

-https://www.vayofm.com

# ទស្សនវិជ្ជាសង្គម

*ដោយៈ លោក* **ឈុន ផារ៉េង**
*មន្ត្រីនាយកដ្ឋានទស្សនវិជ្ជា និង សង្គមវិទ្យា*
*នៃវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*

*មនុស្សជាតិទូទៅ ទោះចង់ឬមិនចង់ តែង បានអនុវត្តទ្រឹស្តីទស្សនវិជ្ជាសង្គម ដោយចៀស មិនរួច។ ទស្សនវិទូជាច្រើនបានកំណត់សកម្ម ភាពមួយចំនួនសម្រាប់ សម្គាល់ថាមនុស្សជាតិ ពិតជាបាននិងកំពុងរស់នៅដោយប្រើប្រាស់ ទស្សនវិជ្ជាសង្គម។ តើទស្សនវិជ្ជាសង្គមមាន ជាតុនិងខ្លឹមសារសំខាន់អ្វីខ្លះ សម្រាប់ជួយកែប្រែ មនុស្សក្នុងសង្គមឲ្យមានការរស់នៅកាន់តែ ប្រសើរឡើង?*

## ១-អត្ថន័យនៃពាក្យ ទស្សនវិជ្ជា

*តាមអត្ថន័យជាភាសាខ្មែរ ពាក្យ ទស្សន វិជ្ជា = ទស្សនៈ + វិជ្ជា ។ ទស្សនៈ គឺជាមតិ យោបល់ ការយល់ឃើញ សំណើ ញត្តិ គំនិត។ វិជ្ជា គឺជា ការសិក្សា ការរៀនសូត្រ ។*

*ទស្សនវិជ្ជា ន. (បា.) វិជ្ជាដែលកើតឡើង ដោយទស្សនៈ; វិទ្យាសាស្ត្រថែងអំពីគោល ការណ៍សំខាន់ៗ និងបុព្វហេតុផ្សេងៗ ឬអំពីជីវិត នៃមនុស្សនិងសត្វ : ទស្សនវិជ្ជា ជាគុណជាតិ វិសេសមួយចំណែក[1]។*

*ទស្សនវិជ្ជា គឺជាមុខវិជ្ជាមួយលើកយកមតិ យោបល់ ការយល់ឃើញ ទស្សនៈ សំណើ ញត្តិ គំនិត ទ្រឹស្តី សុភាសិត មនោគមវិជ្ជា លទ្ធិមកធ្វើ ជាកម្មវត្ថុសិក្សា។ យើងអាចនិយាយថា ទស្សន វិជ្ជា ជាមុខវិជ្ជាមួយសិក្សាពីទស្សនៈឬជាវិជ្ជា សម្រាប់ពិចារណារកការពិត និងភាពត្រឹមត្រូវ ដើម្បីស្វែងរកប្រយោជន៍ដល់មនុស្សទូទៅ។*

*យើងអាចកំណត់បានថា ទស្សនវិជ្ជា គឺ ជាវិស័យវប្បធម៌មួយដែលបង្កើតឡើងដើម្បី បម្រើសេចក្តីត្រូវការរបស់មនុស្ស ដោយការ ខិតខំស្រាវជ្រាវនិងត្រិះរិះពិចារណាលើបញ្ហា របស់មនុស្សប្រកបដោយវិចារណញ្ញាណ ពី ជំនាន់មួយទៅជំនាន់។*

## ២-អត្ថន័យនៃពាក្យ ទស្សនវិទូ

*ទស្សនវិទូ ន. (បា.) អ្នកប្រាជ្ញខាងទស្សន វិជ្ជា។ ឧទាហរណ៍ ព្រះពុទ្ធជាទស្សនវិទូឯកក្នុង លោក[2]។ ទស្សនវិទូ គឺជាអ្នកចូលចិត្តបំពេញ*

---

[1] *ជួន ណាត, វចនានុក្រមខ្មែរ, ការផ្សព្វផ្សាយដោយពុទ្ធសាសនបណ្ឌិត្យ, បោះពុម្ពគ្រាទី៥, ឆ្នាំ១៩៦៧ ទំព័រ ៤១៦*

[2] *ជួន ណាត, វចនានុក្រមខ្មែរ, ការផ្សព្វផ្សាយដោយពុទ្ធសាសនបណ្ឌិត្យ, បោះពុម្ពគ្រាទី៥, ឆ្នាំ១៩៦៧ ទំព័រ ៤១៦*

ការកិច្ចស្វែងរកពុទ្ធិនិងសច្ចភាពស្របតាមមនោគតិ និង លក្ខណៈវិទ្យាសាស្ត្ររបស់ខ្លួន ដើម្បីប្រយោជន៍មនុស្សជាតិក្នុងសង្គម និងសាកលលោក។ ជាទូទៅទស្សនវិទូទាំងឡាយតែងតែឯកភាពថា វិទ្យាសាស្ត្រ និង ទស្សនវិជ្ជា ត្រូវតែនៅជាមួយគ្នា។ មានតែចំណេះដឹងទូលំទូលាយពិតប្រាកដទេ ដែលអាចនាំសង្គមមនុស្សរស់នៅក្នុងជីវិតប្រកបដោយកុសល។ ទស្សនវិទូជាមនុស្សដែលយកចិត្តទុកដាក់លើ ការស្វែងយល់អំពីបញ្ហារបស់មនុស្ស និងផ្តល់នូវដំណោះស្រាយ។ យើងអាចកត់សម្គាល់បានខ្លះថា៖

*ក*- ផ្តើមពីការជឿងឆ្ងល់, ការសង្ស័យ, ភាពមិនច្បាស់លាស់នៅក្នុងវត្ថុឬបាតុភូតណាមួយ ទស្សនវិទូបង្កើតចំណោទបញ្ហា។

*ខ*-ផ្តើមពីចំណោទបញ្ហា ទស្សនវិទូវិភាគតាមបែបតក្កវិជ្ជាចំពោះ ភាសា ដោយបញ្ជាក់អត្ថន័យជា បញ្ញត្តិ វិនិច្ឆ័យ និង វិចារ ទាក់ទងនឹងកម្មវត្ថុដែលត្រូវពិចារណា និងពន្យល់បកស្រាយដល់មហាជន។

*គ*-ទស្សនវិទូ អាចប្រើវិធីទស្សនវិជ្ជាដើម្បីបកស្រាយចំណោទបញ្ហា ឬប្រធានបទ។

*ឃ*-ជាទូទៅ ទស្សនវិទូ ឆ្លើយតបនឹងចំណោទបញ្ហាតាមលក្ខខណ្ឌ ការគិតស្របនឹងតថភាព និង ការគិតស្របនឹងការគិត ហើយយកចំលើយនោះមករិះគន់ជាបន្តបន្ទាប់ដើម្បីបញ្ជាក់ពីសច្ចភាព។

*ង*-ទស្សនវិទូ តែងផ្តល់អនុសាសន៍ ដល់សាធារណជននូវការអនុវត្តគំនិតសាកលឱ្យទៅជាសកម្មភាពប្រតិបត្តិជាក់ស្តែង ក្នុងគោលបំណងកែប្រែឥរិយាបថមនុស្សនិងសង្គមឱ្យកាន់តែប្រសើរ។

ទស្សនវិទូជាអ្នកពិចារណា តាមហេតុផលតម្រង់ទៅរកសច្ចភាពនិងប្រយោជន៍ដែលជាគោលដៅខ្ពស់បំផុត ហើយសច្ចភាព និង ប្រយោជន៍ទាំងនោះទាក់ទងទៅនឹងតថភាពនិងសក្តានុពលនៃបទពិសោធន៍ មធ្យោបាយ និង លទ្ធភាពនានាដែលគេមាន។ សច្ចភាពគឺជាភាពពិតដែលទាក់ទងនឹងច្បាប់ធម្មជាតិ រីឯប្រយោជន៍ទាក់ទងនឹង សេចក្តីសុខចម្រើនសុភមង្គល នៃជីវិតមនុស្ស។ ទស្សនវិទូសង្គមយកចិត្តទុកដាក់និងចំណាយពេលវេលាលើប្រយោជន៍មនុស្សក្នុងសង្គមច្រើនជាងសច្ចភាពបពនុម័តិ។ ទស្សនវិទូសង្គម រួមមាន៖

*ក*.សម័យបុរាណមានលោកអារីស្តូតនិង ប្លាតុង

*ខ*.សម័យមជ្ឈិមមានលោកអូហ្គុស្ទីននិងអាខ្វៃណា

*គ*.សម័យទំនើបមានលោកម៉ាចាវិលី ហុប្បស៍ ឡុក្ខ រ៉ូស្សូ ស្មីត វិការដូ ម៉ាលធឹស មិល្ល បិនថឹម កុម្ព ម៉ាក្ស ឡេនីន

*ឃ*.សម័យក្រោយទំនើបមានលោក ម៉ារកឹស ហាប៊ឺរម៉ាស ហ្វូកាល្ទ ដេនិដា ជាដើម។

## ៣-អត្ថន័យនៃទស្សនវិជ្ជាសង្គម

ពាក្យទស្សនវិជ្ជាសង្គម មកពីទស្សនវិជ្ជា+សង្គម។ សង្គមគឺជាការប្រមូលផ្ដុំនៃរចនាសម្ព័ន្ធក្រុមមនុស្ស។ រចនាសម្ព័ន្ធក្រុមមនុស្សមាន ក្រុមគ្រួសារ ក្រុមញាតិមិត្ត និងក្រុមការងារ។ ទស្សនវិជ្ជាសង្គម គឺជាគោលគំនិតប្រកបដោយគតិបណ្ឌិតដែលពិចារណាជាចម្បងទៅដាក់លើបញ្ហា និង ឥរិយាបទសង្គម មនុស្ស ដោយពិនិត្យតាមដានមើល របៀបរបប គោលបំណងដំណើរការសង្គម និងផលប្រយោជន៍នៃរចនាសម្ព័ន្ធក្រុមមនុស្សដែលមាន ក្រុមគ្រួសារ ក្រុមញាតិមិត្ត និងក្រុមការងារ ជាដើម។ ទស្សនវិជ្ជាសង្គមមានវិសាលភាពគ្របដណ្ដប់គោលគំនិតសង្គមដែលក្នុងនោះមាន ទ្រឹស្ដីកិច្ចសន្យាសង្គម វប្បធម៌ អត្តសញ្ញាណជាតិ លក្ខខណ្ឌសេដ្ឋកិច្ចសង្គម ទំនាក់ទំនងរវាងបុគ្គលនិងសង្គមនិងជីវិតឯកជនជាដើម។

ទស្សនវិជ្ជាសង្គមពាក់ព័ន្ធនឹងវិស័យទស្សនវិជ្ជាផ្សេងទៀតដែលមានទស្សនវិជ្ជាពុទ្ធិ អស្តិរូបវិជ្ជា សីលវិជ្ជា ទស្សនវិជ្ជានយោបាយជាដើម។ លើសពីនេះទៀតទស្សនវិជ្ជាសង្គមតែងរួមបញ្ចូលសង្គមវិទ្យា នរវិទ្យា និងចិត្តសាស្ត្រ។ ទស្សនវិទូសង្គមទាមទារនូវពុទ្ធិវិទ្យាសាស្ត្រនិងការពិសោធន៍ដើម្បីសញ្ជឹងគិតលើវិស័យទាំងនេះ។ ការផ្ដល់ការពិភាក្សាឬទ្រឹស្ដី គឺជាធាតុចាំបាច់នៃទស្សនវិជ្ជាសង្គមនិងវិទ្យាសាស្ត្រសង្គមដែរ។ ទស្សនវិជ្ជាសង្គមទាក់ទងយ៉ាងជិតស្និទនឹងទស្សនវិជ្ជានយោបាយ ជាពិសេសលើបញ្ហា សិទ្ធិ អំណាច របៀបគ្រប់គ្រង បដិវត្តន៍កម្មសិទ្ធិទ្រព្យសម្បត្តិ សោភណវិជ្ជានិងសីលវិជ្ជាជាដើម។

## ៤-អត្ថន័យនៃសង្គមវិទ្យា

សង្គមវិទ្យាមាន និយមន័យផ្សេងៗគ្នាទៅតាមសង្គមវិទូម្នាក់ៗ។ យើងឃើញមាននិយមន័យសង្គមវិទ្យាដូចជា៖ ក)សង្គមវិទ្យាគឺជាប្រព័ន្ធនៃការសិក្សាសង្គម ខ)សង្គមវិទ្យាគឺជាការសិក្សាអន្តរកម្មទំនាក់ទំនងលក្ខណៈសម្បត្តិនិងផលវិបាករបស់មនុស្ស គ)សង្គមវិទ្យាគឺជាការសិក្សាអំពីអាកប្បកិរិយារបស់មនុស្សក្នុងក្រុម និង ឃ)កម្លាំងអន្តរកម្មដែលបានជះឥទ្ធិពលលើផ្នត់គំនិតបុគ្គលនិងការធ្វើចំណាត់ថ្នាក់សង្គម។[3]

## ៥-ទ្រឹស្ដីទស្សនវិជ្ជាសង្គម

ការជាមនុស្សមិនអាចរស់នៅឯកោដាច់ចេញពីគ្នាបានឡើយ។ គេត្រូវការរស់នៅក្នុងកិច្ចសហប្រតិបត្តិការនិងសំដែងសញ្ចេតនាក្នុងជីវភាពរស់នៅដល់គ្នាទៅវិញទៅមក ពោលគឺគេត្រូវរស់ក្នុងសង្គមដែលស្ថិតក្នុងរចនាសម្ព័ន្ធក្រុម

[3] យោងតាមលោក អេមីល ឌឺខេម (Durkheim Émile Durkheim, 1858 - 1917)។ ឌឺខេម ជាសង្គមវិទូ ជនជាតិបារាំងដែលបានបង្កើតវិធីសាស្ត្រសម្រាប់ការស្រាវជ្រាវជាក់ស្តែងទៅលើទ្រឹស្ដីសង្គមវិទ្យា។

មានក្រុមគ្រួសារ ក្រុមញាតិមិត្តនិងក្រុមការងារ។

## ៩.១-ធម្មជាតិមនុស្ស

ការស្គាល់ពីធម្មជាតិមនុស្ស ធ្វើឱ្យយល់ដឹងពីមូលហេតុនៃការគិត និងការប្រតិបត្តិក្នុងជីវិតរស់នៅរបស់មនុស្ស។ សារសំខាន់នៃការសិក្សាអំពីធម្មជាតិមនុស្ស គឺកំណត់ទ្រឹស្តីជាច្រើនអំពីមនុស្ស ដែលទ្រឹស្តីទាំងនោះមិនគ្រាន់តែជះឥទ្ធិពលលើទ្រឹស្តីសង្គម នយោបាយ និងប្រវត្តិសាស្ត្រប៉ុណ្ណោះទេ ប៉ុន្តែវាថែមទាំងជះឥទ្ធិពលទៅលើទ្រឹស្តីពុទ្ធិ តម្លៃ សីលធម៌ សិល្បៈ ភាសានិងសាសនាទៀតផង។ មានទស្សនៈបួនយ៉ាងស្តីពីធម្មជាតិរបស់មនុស្សៈ

ទស្សនៈទី១៖ អះអាងថាធម្មជាតិមនុស្សគឺអាក្រក់។ ទស្សនៈនេះគាំទ្រដោយសាវ័កគ្រិស្តសាសនា មានសន្តបុគ្គល អូហ្គូសស្ទីន ជាដើម។ ដោយសារតែភាពពោរពេញដោយអំពើបាបរបស់ពួកគេនោះ គ្រប់បុគ្គលទាំងអស់មានសារជាតិពុករលួយ ឬបាបពីកំណើតពីព្រោះមនុស្សបានទទួលមរតកគឺអំពើបាបពីបុព្វបុរសរបស់ពួកខ្លួន។

ទស្សនៈទី២៖ អះអាងថាធម្មជាតិមនុស្សគឺល្អ។ ទស្សនៈនេះបានគាំទ្រនិងការពារយ៉ាងខ្លាំងក្លាដោយលោករូស្សូ។ លោកជឿថាធម្មជាតិមនុស្សកើតមកល្អ ប៉ុន្តែអារ្យធម៌សង្គមទេដែលពុករលួយ អំពើពាលាអាវ៉ាសែ ហើយបានកែប្រែមនុស្សឱ្យទៅជាអាត្មានិយមក្រអឺតក្រទម មិនទុកចិត្តគ្នា និងប្រទូសរ៉ាយ។ លោកហឺប៊ឺតស្ប៊ិនស័រ(Herbert Spencer) បាននិយាយថាមាគ៌ានៃការវិវត្តគឺជាការប្រែប្រួលទៅរកភាពល្អប្រសើរជាង។ ដូច្នេះមនុស្សគួរតែឈរមកម្ខាងហើយទុកឱ្យធម្មជាតិអភិវឌ្ឍទៅរកគោលដៅរបស់វា ព្រោះបន្តិចម្តងៗ វានឹងនាំមកនូវការអភិវឌ្ឍទាំងស្រុងទៅលើសមត្ថភាពរបស់មនុស្ស និងការសម្របសម្រួលនឹងបរិស្ថានជុំវិញខ្លួនទៅរកសុខដុមរមនា។

ទស្សនៈទី៣៖ អះអាងថាធម្មជាតិរបស់មនុស្សគឺអព្យាក្រឹត គឺថាមិនល្អ ហើយក៏មិនអាក្រក់ដែរ ប៉ុន្តែប្រកបដោយសក្តានុភាពដ៏ធំធេងចំពោះអំពើល្អនិងអាក្រក់។ មិនដូចសត្វថ្នាក់ទាបផ្សេងៗនោះទេមនុស្សមានទំនោរបត់បែន ហើយមានសមត្ថភាពរៀនសូត្រថែមទៀត។ ការក្លាយទៅជាមនុស្សល្អ ឬអាក្រក់គឺជាលទ្ធផលនៃឥទ្ធិពលបរិស្ថានរស់នៅ និងដំណើរនៃគំនិតរបស់គេ។ គេជាភាវៈនៃការគិតជាភាវៈមានវិចារណញ្ញាណ។

ទស្សនៈទី៤៖ អះអាងថា ធម្មជាតិរបស់មនុស្សគឺល្អផងនិងអាក្រក់ផង។ ពុំមាននរណាម្នាក់មាន សុក្រឹតភាពទាំងស្រុងឡើយ ព្រោះមនុស្សមានលក្ខណៈសភាវគតិស្រេកឃ្លាននិងតម្រេកតណ្ហាដូចសត្វ លើសតែវិចារណញ្ញាណប៉ុណ្ណោះ។

## ៩.២-ទស្សនវិស័យស្តីពីមនុស្ស

### ៩.២.១-សមាសភាគរបស់មនុស្ស

មានទស្សនៈពីរ ដែលបានអះអាង ទាក់ទងទៅនឹងធាតុដែលផ្សំបង្កើតមនុស្សគឺ ទស្សនៈឯកនិយម(Monism) និងទស្សនៈទ្វិកនិយម(Dualism)។ ទស្សនៈឯកនិយមមាន២ប្រភេទ។ ឯកនិយមទី១យល់ថា មនុស្សមិនមានព្រលឹងទេ ដោយពន្យល់ថាអ្វីដែលគេស្មានថាវាជាព្រលឹងនោះគឺវាគ្រាន់តែជាធាតុកួតកើតពីរាងកាយប៉ុណ្ណោះ។ ទស្សនៈនេះយល់ថា កាលណារាងកាយស្លាប់ គ្មានបន្សល់ទុកព្រលឹងអ្វីឡើយ គឺស្លាប់ទៅសូន្យសុង គ្មានព្រលឹងអមតៈអ្វីឡើយ។ រីឯឯកនិយមទី២យល់ថា មនុស្សផ្សំឡើងដោយរាងកាយនិងព្រលឹង។ ព្រលឹងមានអត្ថិភាពអមតៈ។ កាលរាងកាយស្លាប់ ព្រលឹងមិនស្លាប់ទេ គឺព្រលឹងរង់ចាំចាប់បដិសន្ធិជាមួយរាងកាយថ្មី ហើយការកើតស្លាប់របៀបនេះវិលវល់ដដែលៗ គ្មានទីបញ្ចប់។ ចំណែកទស្សនៈទ្វិកនិយមយល់ថា មនុស្សមាន២ផ្នែក គឺទាំងរាងកាយនិងព្រលឹង។ គេជឿថា សមាសភាគមនុស្សគឺ រាងកាយព្រលឹង។ កាលរាងកាយស្លាប់ព្រលឹងក៏ស្លាប់ដែរ។

### ៥.២.២-ប្រភពកំណើតរបស់មនុស្ស

មានទ្រឹស្តីពីរ ស្តីអំពីប្រភពកំណើតមនុស្សគឺ៖ ទ្រឹស្តីវិវត្តន៍(Theory of Evolution) និងទ្រឹស្តីអាទិទេព។ ទ្រឹស្តីវិវត្តន៍ យល់ថា សរីរាង្គមានជីវិតបានអភិវឌ្ឍតាមក្រឹត្យក្រមនៃជម្រើសធម្មជាតិ។ ចំណែកទ្រឹស្តីទ្រឹស្តីអាទិទេព(សាសនាយូដា គ្រិស្ត អ៊ិស្លាម ហិណ្ឌូ ជាដើម) បញ្ជាក់ថា មនុស្សកើតឡើងពីព្រលឹងវិញ្ញាណរបស់ទិទេព។ ក្នុងសាសនា យូដា គ្រិស្ត អ៊ិស្លាម ជឿថា ព្រះបានបង្កើតមនុស្សពីធូលីដីហើយបានផ្លុំព្រលឹងវិញ្ញាណចូល រូបនេះក៏មានជីវិតរស់រវើកឡើង។ ហិណ្ឌូសាសនា ជឿថា មនុស្ស កើតពីអាត្មន់ដែលជាព្រលឹងតូចបែកចាកពីព្រហ្មន៍ដែលជាព្រលឹងធំ។ កាលណារាងកាយស្លាប់អាត្មន់មិនស្លាប់ទេ វានៅវិលវល់កើតស្លាប់ក្នុងវាលវដ្តសង្សារលុះត្រាទៅវាបានទៅជួបព្រហ្មន៍វិញ។

### ៥.២.៣-សារជាតិរបស់មនុស្ស

មានទស្សនៈបួនក្រុម ដែលនិយាយពីសារជាតិរបស់មនុស្ស គឺ៖

១.ទ្រឹស្តីវិចារណញ្ញាណនិយម យល់ថា សារជាតិមនុស្សស្ថិតលើសមត្ថភាពនៃការគិតពិចារណានិងយល់ដឹងរបស់មនុស្ស។ ផ្លាតូយល់ថា វិចារណញ្ញាណគឺជាផ្នែកមួយនៃព្រលឹង ព្រលឹងជាផ្នែកមួយខ្ពស់បំផុតដែលមានឯករាជ្យមិនចេះស្លាប់ ហើយវាគឺជាសតិតែមួយគត់ដែលវាអាចជួយឱ្យមនុស្សយល់ដឹងពីធម្មជាតិនៃភាវៈទាំងឡាយ។ អារីស្តូតអះអាងបន្ថែមថា វិចារណញ្ញាណជាទ្រព្យមានតម្លៃរបស់មនុស្ស ដែលបែងចែកមនុស្សខុសពីសត្វនានា។ លោករ៉ូប៊ីនស៊ុន (Robinson)យល់ថា គំនិតត្រូវគេចាត់ទុកថាជាកិត្តិយសដ៏សំខាន់និងជាឧបករណ៍របស់មនុស្សដែលអាចជួយមនុស្សឱ្យសម្រេចបាននូវអ្វីៗ ដែលអស្ចារ្យនៅក្នុងអារ្យធម៌របស់ខ្លួន។ មនុស្សអាចគិតពិចារណា តែសត្វដទៃមិនអាចពិចារណាបានទេ។ ដូច្នេះមនុស្សបានបង្កើត

សាសនា សិល្បៈ ស្ថាប័ន ប្រព័ន្ធទស្សនវិជ្ជា និងទេវវិទ្យាជាដើម។ មនុស្សទទួលបានពុទ្ធិ រួចស្វែងរកនិងច្នៃបង្កើតថ្មី ដើម្បីមានអាហារចិញ្ចឹមជីវិត ស្លៀកពាក់ការពារខ្លួន តុបតែងលម្អនិងដើម្បីរីករាយសប្បាយ។ ដូច្នេះដំណើរនៃគំនិតជាធាតុដ៏សំខាន់នៅក្នុងអារ្យធម៌ រីឯវិចារណញ្ញាណគឺជាមោទកភាពនិងភាពរុងរឿងរបស់មនុស្ស។

២-ទស្សនៈពាហិរសាសនាស្តីពីសារជាតិមនុស្ស យល់ថា មនុស្សគឺជាភាវៈពិសិដ្ឋដែលបង្កើតដោយអាទិទេព។ លក្ខណៈពិសិដ្ឋរបស់មនុស្សគឺព្រលឹងវិញ្ញាណ។ ព្រលឹងវិញ្ញាណមនុស្ស ផ្តល់ឱ្យមនុស្សនូវតម្លៃ និងលទ្ធភាពគ្មានព្រំដែន។

៣-ទស្សនៈពុទ្ធសាសនាស្តីពីសារជាតិមនុស្ស យល់ថា មនុស្សគឺជាភាវៈធម្មជាតិដែលផ្សំឡើងដោយទឹកដីភ្លើងខ្យល់ គ្មានអាទិទេពណាជាអ្នកបង្កើតឡើងទេ។ លក្ខណៈពិសេសរបស់មនុស្សគឺ បញ្ញា។ បញ្ញារបស់មនុស្សអាចនាំមនុស្សរំដោះខ្លួនទៅរកសុខស្ងប់ចាកទុក្ខបាន។

៤-ទស្សនៈវិទ្យាសាស្ត្របែកចេញជាពីរផ្នែកគឺៈ ទស្សនៈជីវសាស្ត្រ និងទស្សនៈអាកប្បកិរិយានិយម។ ទស្សនៈជីវសាស្ត្រ ចាត់ទុកមនុស្សថា មនុស្សជាផ្នែកមួយនៃលំដាប់រូបសាស្ត្រធម្មជាតិដូចវត្ថុផ្សេងៗទៀតដែរគឺមនុស្សមានទំហំទម្ងន់រាងរៅនិងពណ៌សម្បុរ។ មនុស្សរស់នៅក្នុងលំហនិងកាលហើយស្ថិតនៅក្រោមច្បាប់នៃរូបវិទ្យាដូចជាច្បាប់ទំនាញផែនដីជាដើម។ ចំណែកទស្សនៈអាកប្បកិរិយានិយម យល់ឃើញថា មនុស្សគឺជាភាវៈដែលអាចត្រូវបានគេប្រើប្រាស់ អាចត្រូវបានគេបង្កើត និងអាចត្រូវបានគេធ្វើឱ្យអភិវឌ្ឍជាច្រើនបែបដូចគ្នាទៅនឹងសត្វដទៃមួយចំនួនទៀតដែរ។ ពួកអាកប្បកិរិយានិយមអះអាងថា "ចូរឱ្យទារកម្នាក់មកខ្ញុំនិងពិភពរបស់ខ្ញុំដើម្បីចិញ្ចឹមទារកនេះហើយខ្ញុំនឹងបង្រៀនទារកនេះឱ្យចេះវារនិងចេះដើរចេះឡើងហើយនិងចេះប្រើប្រាស់ដៃទាំងទ្វេរបស់គេក្នុងការកសាងផ្ទះ ដែលធ្វើអំពីថ្មឬឈើ ហើយខ្ញុំនឹងធ្វើឱ្យគេក្លាយទៅជាចោរអ្នកកាន់កាំភ្លើងឬធ្វើឱ្យទៅជាអ្នកញៀនថ្នាំ។ លទ្ធភាពនៃការតម្រង់ទិសដៅគឺស្ទើរតែគ្មានទីបញ្ចប់"។

## ៩.២.២-លក្ខណៈពិសេសរបស់មនុស្ស

មនុស្សមានលក្ខណៈពិសេសខុសពីសត្វនិងភាវៈផ្សេងទៀត ដោយគេមានអំណាចក្នុងការគិតពិចារណាដែលធ្វើឱ្យខ្លួនខ្ពស់ជាងអម្បូរនៃសត្វដទៃទៀត។ លក្ខណៈផ្សេងទៀតដែលញែកមនុស្សឱ្យខ្ពស់ជាងទម្រង់នៃសត្វដទៃទៀតគឺមនុស្សមានបញ្ញាបង្កើតសង្គមនិងវប្បធម៌។ ខាងរាងកាយមនុស្ស មានរបៀបឈរឬអង្គុយរបស់មនុស្សគឺត្រង់ឆ្អឹងទៅលើដែលការឈរត្រង់ហ្នឹងអាចជួយគេឱ្យប្រើប្រាស់ដៃ និងប្រអប់ដៃដោយសេរីក្នុងការរកស៊ីនិងការប្រើប្រាស់។ មនុស្សមានម្រាមដៃដាច់ៗពីគ្នានិងមេដៃដែលចេះចាប់វត្ថុផ្សេងៗបាន។ មនុស្សមានម្រាមដៃដែលអាចប្រើបានច្រើនយ៉ាងផ្តល់ឱ្យគេនូវភាព

បត់បែនបានដោយសេរី។ អំណោយទានធម្មជាតិផ្ដល់ឱ្យនិងមានតម្លៃបំផុតសម្រាប់មនុស្ស គឺខួរក្បាលធំទូលាយនិងប្រព័ន្ធប្រសាទដែលមានភាពសាំញ៉ាំនិងដែលបានរៀបចំយ៉ាងខ្ពង់ខ្ពស់។ អំណោយទានធម្មជាតិផ្ដល់ឱ្យទាំងនេះ អនុញ្ញាតឱ្យមនុស្សមានអាកប្បកិរិយាប៉ិនប្រសប់ផ្សេងៗពីគ្នា។ លក្ខណៈពិសេសដោយឡែកទៀតរបស់មនុស្ស គឺជាលក្ខណៈពិសេសខាងសង្គម វប្បធម៌ និងបញ្ញា។ មនុស្សអាចមានសមត្ថភាពប្រើប្រាស់ភាសាដើម្បីនិយាយទាក់ទងគ្នាពន្យល់គ្នាជាឃ្លាប្រយោគ។ មនុស្សចេះច្នៃបង្កើតឧបករណ៍ប្រើប្រាស់និងបង្កើតម៉ាស៊ីនផ្សេងៗ។ មនុស្សរស់នៅជាក្រុម តាមលក្ខណៈសង្គមនិងនយោបាយ ដោយបង្កើតនិងអនុម័តច្បាប់នៃការប្រព្រឹត្តហើយមានកិច្ចសហប្រតិបត្តិការនៅក្នុងទិដ្ឋភាពសំខាន់ៗ។ មនុស្សអាចយល់ដឹងពីប្រវត្តិសាស្ត្រនិងមានការប្រមូលចងក្រងនូវប្រពៃណីវប្បធម៌។មនុស្សស្គាល់ពីសោភ័ណនិងបង្កើតសោភ័ណភាពហើយរីករាយនឹងសោភ័ណភាពនោះ។ មនុស្សចេះដឹងអំពីតម្លៃ ត្រូវនិងខុស ល្អ និងអាក្រក់ គឺជាសត្វមានសីលធម៌និងមានមនសិការសីលធម៌។ មនុស្សថែមទាំងចេះបង្កើតសាសនា និងគោរពប្រតិបត្តិពិធីទំនៀមទម្លាប់នានា។ល។

### ៩.២.៩-សមត្ថភាពរបស់មនុស្ស

មានទស្សនៈពីរស្ដីអំពីសមត្ថភាពមនុស្ស គឺទស្សនៈបុរាណ និងទស្សនៈទំនើប។ ទស្សនៈបុរាណស្ដីពីមនុស្ស យល់ថាមនុស្សមិនមានសមត្ថភាព ឬគំនិតដ៏ភ្លឺស្វាងឯករាជពីព្រហ្មលិខិតឬអាទិទេពឡើយ។ គំនិតមនុស្សជាធនធានដ៏សំខាន់របស់មនុស្សសុទ្ធតែជាអំណោយទានពីអាទិទេព។ ការច្នៃបង្កើត ការប្រើប្រាស់ភ្លើង ការកសាងជម្រក ការផ្សាំងសត្វ វិធីផលិតលោហៈធាតុ កសិកម្ម សុខាភិបាល នាវាចរណ៍ ភាសា គណិតវិទ្យា តារាវិទ្យា សិល្បៈ ទស្សន៍ទាយ ទាំងអស់នេះចាត់ទុកថាជាផលិតផលនៃបញ្ញាដែលអាទិទេពផ្ដល់ឱ្យ។

ចំណែកទស្សនៈទំនើបអំពីមនុស្ស (Modern Views of Man) យល់ថាមនុស្សជាភាវៈដែលបានសម្រេចនិងរីករាយចំពោះគោលជំហរអត្ថិភាពនៃអំណាចនិងឥទ្ធិពលបច្ចុប្បន្នរបស់ខ្លួន។ គោលជំហរបែបនេះគឺមិនមែនអាទិទេពផ្ដល់មនុស្សទេគឺ ដោយសមត្ថភាពពីធម្មជាតិរបស់មនុស្សផ្ទាល់តែម្ដង។ មនុស្សគឺជាភាវៈមានសញ្ញាខុសប្លែកគេនៅត្រង់មនុស្សមានសមត្ថភាព ជ្រើសរើសដោយសេរី។យោងតាមលោករូសូ គឺសមត្ថភាពក្នុងការជ្រើសរើសរបស់មនុស្សហ្នឹងហើយ ដែលកំណត់នូវប្រភេទនៃមនុស្សដែលនឹងក្លាយទៅជាមនុស្សបែបណា។ មនុស្សមានធម្មជាតិល្អពីកំណើត។ ប្រសិនបើគេក្លាយជាអាក្រក់គឺដោយសារការជ្រើសរើសឬអនុញ្ញាតឱ្យកម្លាំងណាមួយនៃបរិស្ថានជុំវិញ។ គេអាចមានសមត្ថភាពធ្វើឱ្យខ្លួនសុក្រឹតប៉ុន្តែវាទាមទារនូវអំណាចនៃ

ធន្ទៈនិងការជ្រើសរើសរបស់គេដើម្បីទទួលបាននូវសុក្រឹតភាពនោះ។

លោក កាល់ ម៉ាក្ស យល់ថា មនុស្សជា៖ "សត្វដែលមានសមត្ថភាពពិសេសសម្រាប់បង្កើត និងប្រើប្រាស់ឧបករណ៍"។ ពេលផ្ដោតដាក់ស្ដែងលើការច្នៃបង្កើតរបស់មនុស្ស ការច្នៃបង្កើតនេះតម្រង់តែមួយគត់ទៅលើផលិតកម្មសម្ភារៈ។ មនុស្សគឺជាសត្វផលិតកម្មជាចម្បង។ ចំពោះលោក កាល់ម៉ាក្ស ប្រព័ន្ធទូទៅនៃផលិតកម្មទំនិញគឺជាគន្លឹះចំពោះលក្ខណៈនៃស្ថាប័នសង្គមនយោបាយនិងតម្លៃវប្បធម៌។ ទស្សនៈលេចធ្លោស្ដីពីមនុស្ស គឺយកចិត្តទុកដាក់លើការច្នៃបង្កើតរបស់មនុស្ស។ ទស្សនៈនេះមើលឃើញអំណាចរបស់មនុស្សនៃការច្នៃបង្កើត និងប្រឌិតញាណ គឺជាកត្តារួមនៅក្នុងគ្រប់សកម្មភាពរបស់មនុស្ស។ នោះគឺការយល់ដឹងទង្វើនិងការបង្កើតរបស់ខ្លួននៅក្នុងគ្រប់ស្ថានភាព។ លោកពៀកស៍ (C.S. Pierce) និងចនដេវី (John Dewey) បង្ហាញពីសារសំខាន់នៃប្រឌិតញាណនេះថាជាអំណាចដែលប្រមើលមើលពីលទ្ធភាពក្នុងការច្នៃបង្កើតរបស់មនុស្សនិងការពង្រីកពុទ្ធិវិទ្យាសាស្ត្រ ។

## ៩.២.៦-ការប្រែប្រួលចរិតធម្មជាតិមនុស្ស

ចរិតធម្មជាតិរបស់មនុស្សអាចកែប្រែបាន។ ការផ្លាស់ប្ដូរឬការកែប្រែធម្មជាតិរបស់មនុស្សនេះអាចប្រដូចបានទៅនឹងសារធាតុដែលអាចសូនបានដូចជាថ្នាំស្និច ដែលអាចត្រូវបានគេកែច្នៃជាពងពៅផ្សេងៗតាមដែលគេចង់បាន។ សាស្ត្រាចារ្យហុកគីង (Hocking) យល់ថា ធម្មជាតិរបស់មនុស្ស គ្មានអ្វីដែលគួរឱ្យសង្ស័យទេ គឺជាជ័រថ្នាស្និចនៃពិភពមានជីវិតដែលអាចសម្របបាននិងអប់រំបាន។

## ៩.២.៧-មនុស្សជាភាវៈទំនាក់ទំនង

មនុស្សជាភាវៈទំនាក់ទំនងពីព្រោះគេមិនគ្រាន់តែទាក់ទងជាមួយមនុស្សដទៃទេ តែថែមទាំងទាក់ទងទៅនឹងភាវៈមានជីវិត ភាវៈគ្មានជីវិត ព្រឹត្តិការណ៍នានានិងទាក់ទងនឹងភាវៈខ្ពស់បំផុត (ឬព្រះអាទិទេព) ទៀតផង។ ជាភាវៈមានជីវិតមួយ មនុស្សខ្វល់ខ្វាយពីម្ហូបអាហារដើម្បីធំធាត់និងបន្តការរស់នៅ គេយកចិត្តទុកដាក់ពីសុខភាពនិងជម្រករបស់គេ។ ជាផ្នែកមួយនៃលំដាប់រូបសាស្ត្រធម្មជាតិមនុស្សត្រូវគោរពច្បាប់គីមីវិទ្យានិងរូបវិទ្យាជាដើម។ ក្នុងឋានៈជាភាវៈសង្គមជីវិតមនុស្សត្រូវគេរួមបញ្ចូលគ្នាជាមួយមនុស្សផ្សេងៗទៀតយ៉ាងជិតស្និទ្ធ។ ធម្មតាគេចំណាយជីវិតគេទាំងមូលផ្សារភ្ជាប់ជាមួយមនុស្សដទៃទៀតហើយគេជាសមាជិកសង្គមដែលត្រូវបានគេរៀបចំឡើងផ្សេងៗគ្នា។ ដើម្បីឱ្យការរស់នៅនិងសម្រាប់ជីវិតរបស់គេមានប្រយោជន៍មនុស្សត្រូវការអន្តរកម្មជាមួយមិត្តរបស់គេ។ គេត្រូវការមនុស្សផ្សេងទៀតដើម្បី ជួយគេ និងសរសើរពីសមិទ្ធផលរបស់គេ។ លោកទីទុសនិងស្មីតបញ្ជាក់ថា "ប្រសិនបើគេរស់នៅដាច់ដោយឡែកពីមនុស្សដទៃគឺគេគ្មានអភិវឌ្ឍអ្វីទាំងអស់ សូម្បី

តែកាសាក៏គ្មានដែរ។ គេមិនអាចរស់នៅដោយចាត់ទុកថាជីវិតល្អដោយផ្ដាច់ចេញទាំងស្រុងពីមិត្តរបស់គេនោះទេ។ សហគមន៍និងសង្គមធំធេងរបស់គេអាចដឹកនាំគេឱ្យសាងជីវិតប្រកបដោយខ្លឹមសារ ការឈឺចាប់និងសោកនាដកម្មផងដែរ៕ ពុទ្ធិស្ដីពីអតីតកលរបស់មនុស្សមានតម្លៃមិនគ្រាន់តែក្នុងការយល់ដឹងនិងក្នុងការរស់នៅនាពេលបច្ចុប្បន្នប៉ុណ្ណោះទេ តែថែមទាំងក្នុងការធ្វើគម្រោងផែនការនិងការបង្កើតសម្រាប់អនាគតផងដែរ។ យោងតាមលោក ដេវី មនុស្សខុសពីសត្វដែលស្ថិតក្នុងថ្នាក់ទាបជាង ពីព្រោះមនុស្សថែរក្សាទុកនូវបទពិសោធន៍អតីតកាលអ្វីដែលបានកើតមានឡើងនៅអតីតកាលត្រូវគេធ្វើឱ្យរស់រវើកឡើងវិញនៅក្នុងការចងចាំរបស់គេ។ អ្វីៗដែលបន្តអត្ថិភាពសព្វថ្ងៃគឺបានពីការចងក្រងភាពរសាត់អណ្ដែតនៃការគិតដែលទាក់ទងទៅនឹងវត្ថុស្រដៀងគ្នាដែលបានទទួលក្នុងពេលកន្លងទៅហើយ។[4]

### ៥.២.៨-ទំនោធម្មជាតិរបស់មនុស្ស

ទំនោរបង្កើតតម្រូវការ ចំណង់ចំណូលចិត្តឧត្ដមគតិ និងលោកទស្សនៈមានឥទ្ធិពលធំធេងដល់បុគ្គល គ្រួសារនិងសង្គមជាតិទាំងមូល។

ទំនោរ គឺជាចរិតលក្ខណៈនៃសភាវធម្មជាតិដែលធ្វើឱ្យមានចំណង់ក្នុងការគិតនិងប្រព្រឹត្តអ្វីមួយ។ វាជាប្រព័ន្ធនៃកម្លាំងចលករកំណត់អត្តចរិតសកម្មឬអំពើរបស់បុគ្គលនិងឥរិយាបថសង្គម។ ការព្យាយាមធ្វើគ្រប់មធ្យោបាយដើម្បីតម្រង់ទិសទៅរកវត្ថុបំណងណាមួយតែងតែជំរុញដោយកម្លាំងចលករផ្សេងៗនៃទំនោរ។ ឧទាហរណ៍៖ ការខិតខំព្យាយាមយកចិត្តទុកដាក់រៀនសូត្រ បណ្ដាលមកពីកម្លាំងចលករនៃការចង់ដឹងការពិត។ ចំណង់ចំណូលចិត្តក្នុងការងារគ្រូបង្រៀន ជំនឿចំពោះទង្វើល្អក្នុងវិស័យអប់រំ និងបំណងប្រាថ្នាផ្សេងៗទៀត ធ្វើឱ្យនិស្សិតសាស្ត្រាចារ្យ ខិតខំធ្វើឱ្យប្រសើរឡើងទៅតាមទស្សនៈនៃវិជ្ជាជីវៈរបស់ខ្លួន។ ក្នុងជីវភាពរស់នៅក្នុងសង្គម គេអាចចែកទំនោរជា៣ប្រភេទគឺ៖ ១) ទំនោរខាងសីលធម៌-នយោបាយ ២)ទំនោរខាងវិជ្ជាជីវៈ និង៣)ទំនោរបុគ្គល។

ទំនោរខាងសីលធម៌នយោបាយ ជាបាតុភូតចិត្តដែលស្ដែងឡើងជាចរិកពេញចិត្តប្រកាន់យកមនោគមវិជ្ជានយោបាយ ស្ថិរភាពនយោបាយ ភាពស្មោះត្រង់ចំពោះមាតុភូមិ និងកក្ដីភាពចំពោះស្នាដៃកសាងសង្គមថ្មី។ ទំនោរខាងវិជ្ជាជីវៈ ជាទំនោរដែលស្ដែងចេញឱ្យឃើញនូវភាពស្វាហាប់ក្នុងការដក់ចិត្តជាប់នឹងមុខរបរណាមួយ ដែលបុគ្គលប្រាថ្នាចង់ធ្វើនិងចង់បាន។ ទំនោរបុគ្គល(ឬទំនោរខាងជីវភាពរស់នៅរបស់បុគ្គល) ជាបាតុភូតចិត្ត ពេញដោយបំណងប្រាថ្នារបស់បុគ្គល ទៅលើឧបករណ៍សម្ភារៈ វប្បធម៌

---

[4] ក្រុមសាស្ត្រាចារ្យសាកលវិទ្យាល័យ បៀលប្រាយ ៖ មនុស្សនិងសង្គម ភ្នំពេញ ឆ្នាំ២០១៣, ទំព័រ ៣៣

និងសីលវិជ្ជា។ ទំនោរនេះអាចកើតមានព្រមគ្នានឹងទំនោរវិជ្ជាជីវៈ និងទំនោរសីលធម៌នយោបាយដែរ។

ទំនោរបុគ្គលគឺជាសភាពចិត្តមានលក្ខណៈស្មុគស្មាញ។វាមានធាតុផ្សេងៗគ្នាជាច្រើនផ្សារភ្ជាប់គ្នា។ ជាតុទាំងនោះរួមមាន បំណងប្រាថ្នា ការគិត ឬការស្រមៃ ចំណង់ចំណូលចិត្ត ការលំអៀង ឧត្តមគតិ ទស្សនៈ និងជំនឿ។ ធាតុទាំងនោះអភិវឌ្ឍពីកម្រិតទាបទៅកម្រិតខ្ពស់ ដោយយោងទៅតាមកម្លាំងនៃវត្ថុបំណង ទស្សនៈនៃសញ្ចេតនា ការជំរុញឱ្យមានទង្វើ និងការកំណត់បាននូវសច្ចភាពនៅក្នុងជីវភាពរបស់បុគ្គល។

ទំនោរបុគ្គលអាស្រ័យលើគុណសម្បត្តិទាំងឡាយដូចជាៈ ១.កម្រិតអាយុទំនោរ ២.ទំហំទំនោរ ៣.ឥទ្ធិពលទំនោរ ៤.ស្ថិរភាពសីលធម៌ទំនោរ និង ៦.ប្រសិទ្ធភាពទំនោរ។ កម្រិតអាយុទំនោរកំណត់នូវបំណងប្រាថ្នាដែលជាមូលដ្ឋានឧត្តមគតិនៃបុគ្គលម្នាក់ៗ ដែលទាក់ទងនឹងកម្រិតមនោគមវិជ្ជា និងទម្រង់សីលធម៌របស់បុគ្គលដែរ។ ទំហំទំនោរគឺជាលទ្ធភាពបង្កើតអ្វីមួយទៅតាមបំណងប្រាថ្នារបស់បុគ្គល។ ឥទ្ធិពលទំនោរ គឺជាកម្លាំងថាមពលធំធេងមួយដែលអាចកែប្រែបំណងប្រាថ្នាឱ្យក្លាយជាឆន្ទៈភ្ញាក់រលឹកសកម្មជ័និងផុបផុល។ ស្ថិរភាពសីលធម៌ទំនោរ គឺជាភាពគង់វង្សនៃមនោរគមវិជ្ជា ដែលទ្រទ្រង់បុគ្គលមិនឱ្យយឺងយោងនិងជៀសផុតពីទំនាស់ខាងសីលធម៌នៅក្នុងបុគ្គលខ្លួនឯង។ ចំណែកប្រសិទ្ធភាពទំនោរ គស្គុតាងដែលស្តែងឱ្យឃើញនៅក្នុងឥរិយាបថវិជ្ជមានរបស់បុគ្គលនៅពេលសម្រេចតាមបំណងប្រាថ្នា។ ប្រសិទ្ធភាពនៃទំនោរបែបនេះ មានបន្ទាស់ប្តូរមនោគមវិជ្ជារបស់បុគ្គល ឈានទៅរកភាពទាន់សម័យ។

ជាទូទៅ គុណសម្បត្តិនៃទំនោរបុគ្គលមានប្រយោជន៍ច្រើនក្នុងរចនាសម្ព័ន្ធនៃបុគ្គលិកលក្ខណៈរបស់មនុស្ស។ គុណសម្បត្តិនេះ អាចសម្គាល់តាមរយៈទឹកមុខ ឬកាយវិការ។ សកម្មភាព និងអំពើដែលប្រកបដោយសីលធម៌ និងតម្លៃសង្គមរបស់បុគ្គលម្នាក់ៗគឺជាគុណសម្បត្តិនៃទំនោរបុគ្គល។ ហេតុដូច្នេះ ការកិច្ចចម្បងចាំបាច់បំផុតនៅក្នុងវិស័យអប់រំគឺការបណ្តុះបណ្តាលធនធានមនុស្សឱ្យក្លាយជាពលរដ្ឋល្អដែលមានទំនោរវិជ្ជាជីវៈប្រកបដោយស្ថិរភាពរឹងមាំ កម្លាំងខ្លាំងក្លា និងប្រសិទ្ធភាពខ្ពស់។

ទំនោររបស់មនុស្ស ស្តែងឱ្យឃើញសារៈសំខាន់ក្រោមទិដ្ឋភាពនៃតម្រូវការ ចំណង់ចំណូលចិត្ត ឧត្តមគតិ និងលោកទស្សនៈរបស់បុគ្គល។ ទិដ្ឋភាពនៃតម្រូវការគឺជាកត្តាចាំបាច់ដើម្បីអត្ថិភាពនិងអភិវឌ្ឍជីវិតបុគ្គល។ ដើម្បីអត្ថិភាពគេប្រឹងប្រែងបំពេញតម្រូវការចាំបាច់មួយចំនួនដូចជា តម្រូវការម្ហូបអាហារ ទីជម្រកសម្លៀកបំពាក់ ការសិក្សា ទំនាក់ទំនង និងតម្រូវការផ្សេងៗទៀត។ ទិដ្ឋភាពនៃចំណង់ចំណូលចិត្តរបស់បុគ្គល គឺជាឥរិយាបថរបស់បុគ្គលនោះចំពោះវត្ថុដែលមានអត្ថន័យសំខាន់ក្នុងការផ្តល់

លទ្ធភាពធ្វើឱ្យសប្បាយរីករាយ និងពេញចិត្ត សម្រាប់ការរស់នៅរបស់ខ្លួន។ ទិដ្ឋភាពនៃឧត្តមគតិ គឺជាបំណងដ៏ថ្លៃថ្នូរ ដែលឆ្លុះបញ្ចាំងឱ្យឃើញនៅក្នុងមនសិការរបស់មនុស្សក្រោមទម្រង់នៃរូបតំណាងដ៏ល្អឥតខ្ចោះ និងជាគំរូដ៏ល្អប្រពៃ ដែលមានអានុភាពទាក់ទាញរាល់កម្លាំងទ្រទ្រង់ជីវិតបុគ្គលក្នុងការសម្រេចបានតាមបំណងក្នុងរយៈពេលមួយដ៏យូរ។ ចំណែកឯទិដ្ឋភាពនៃលោកទស្សនៈវិញគឺជាសំណុំនៃការយល់ដឹង ឬទស្សនៈរបស់បុគ្គលណាម្នាក់ ស្ដីពីបាតុភូតធម្មជាតិ បាតុភូតសង្គម និងអំពើនៃសកម្មភាពរបស់ខ្លួន។ ការបណ្ដុះបណ្ដាល និងការពង្រីកលោកទស្សនៈរបស់សិស្ស គឺជាភារៈដ៏សំខាន់របស់គ្រូ អាណាព្យាបាល និងសង្គម។ និន្នាការ ឬទំនោររបស់បុគ្គល គឺជាលក្ខណៈចិត្តដែលមានមូលដ្ឋានត្រឹមត្រូវ ហើយវាជាស្នូលនៃជីវិតផ្លូវចិត្តរបស់បុគ្គល។ និន្នាការនេះ បំពេញតួនាទីជាកម្លាំងចលករដាច់ខាត ដែលកំណត់បាននូវចរិតសកម្ម និងជម្រើសឥរិយាបថរបស់បុគ្គលចំពោះតថភាព។ ទំនោរនេះ ស្ដែងចេញឱ្យឃើញតាមរយៈតម្រូវការ ចំណង់ចំណូលចិត្ត ឧត្ដមគតិ និងលោកទស្សនៈរបស់បុគ្គលម្នាក់ៗ។ ការពង្រឹង និងការបណ្ដុះទំនោរតាមគ្រប់រូបភាពជាពិសេសស ឧត្ដមគតិ និងលោកទស្សនៈ គឺជាភារៈមួយយ៉ាងសំខាន់របស់ក្រសួងអប់រំជាពិសេស សាលារៀនមធ្យមសិក្សា ក្នុងការបណ្ដុះបណ្ដាលធនធានមនុស្សទៅតាមតម្រូវការរបស់សង្គម។

## ៦-រចនាសម្ព័ន្ធក្រុមមនុស្សក្នុងសង្គម

សង្គមវិទូអាមេរិក លោក ឆាល ហ៊រតុន ខូឡៃ (Charles Horton Cooley ១៨៦៤-១៩២៩) ដែលសិក្សាពីសង្គមមនុស្ស បានផ្ដល់ទស្សនៈថា បុគ្គលម្នាក់ៗមានទំនាក់ទំនងគ្នាជាអន្តរកម្មសង្គម ដែលលោកហៅថាក្រុម។ លោកបែងចែកមនុស្សក្នុងសង្គមមានបីក្រុម៖ ១.ក្រុមគ្រួសារ ២.ក្រុមញាតិមិត្ត ៣.ក្រុមការងារ។

## ៧-ដំណើរការសង្គម

ដំណើរការសង្គមគឺជាទម្រង់ឥរិយាបថនៃរចនាសម្ព័ន្ធក្រុមមនុស្ស ដែលកើតឡើងនៅក្នុងជីវភាពប្រចាំថ្ងៃរបស់សង្គម។ វាជា "គំរូនៃឥរិយាបថសង្គម ឬអន្តរកម្មសង្គមកើតមានជាប់លាប់ ហើយវាអាចក្លាយជាអត្តសញ្ញាណ របស់សង្គមមួយ"[5]។ ដំណើរការសង្គមចែកជាពីរផ្នែក គឺ៖ ១.ដំណើរការសង្គមឯកភាព និង ២.ដំណើរការសង្គមមិនឯកភាព។ ដំណើរការសង្គមឯកភាព គឺជាអំពើនិងសកម្មភាពដែលបង្កើតឱ្យមានការសហការ សមាហរណកម្ម ការយល់ចិត្តគ្នា និងមានឯកភាពគ្នា។ ទម្រង់នៃអន្តរកម្មសង្គមបែបនេះ នាំសមាជិក និងក្រុមក្នុងសង្គមឱ្យមានឯកភាពគ្នា យោគយល់គ្នា ការជួយគ្នាទៅវិញ

[5] Horton & Hunt, *Sociology and Society*, 1968, p. 53

ទៅមក ធ្វើឱ្យមានការចុះសម្រុងគ្នា និងការកាត់បន្ថយរាល់ការលំបាកទាំងឡាយ ហើយនាំមកនូវទំនាក់ទំនងសង្គមមួយដែលល្អប្រសើរ។

ចំណែក ដំណើរការសង្គមមិនឯកភាពគឺជាដំណើរការប្រកួតប្រជែងនិងទំនាស់។ ទម្រង់នៃអន្តរកម្មសង្គមបែបនេះ ត្រូវគេចាត់ទុកថាជាអន្តរកម្មបែបអវិជ្ជមានពីព្រោះវាបានបង្ការអ្នកដទៃមិនចូលរួមសម្រេចបំណងប្រាថ្នានៅទីបញ្ចប់។ ទម្រង់នៃអន្តរកម្មសង្គមបែបនេះបង្កើតឱ្យមានការបែកបាក់សាមគ្គី ឬទាស់ទែងគ្នាច្រើនជាងការចុះសម្រុង និងឯកភាពគ្នា។

**៨-គណបក្សនយោបាយក្នុងសង្គម**

មនុស្សដែលរស់នៅក្នុងសង្គមនិមួយៗតែងតែមានទស្សនៈផ្សេងៗគ្នា អំពីដំណើរការការពារ និងអភិវឌ្ឍន៍សង្គមរបស់ខ្លួន តាមរបៀបខុសៗគ្នា ដោយជៀសមិនរួច។ ទស្សនៈទាំងនេះអាចត្រូវបានប្រមូលផ្ដុំក្នុងអង្គការចាត់តាំងឬគណបក្សនយោបាយនានា ដែលត្រូវបង្កើតឡើងដើម្បីរួមកម្លាំងតស៊ូមតិតទល់នឹងគណបក្សមួយទៀតដើម្បីមានឥទ្ធិពលអនុវត្តន៍ទស្សនៈគំនិតរបស់ខ្លួន។

គោលបំណងនៃគណបក្សនយោបាយគឺដើម្បីដណ្ដើមយកតួនាទីដឹកនាំគ្រប់គ្រងរដ្ឋាភិបាល ដែលធម្មតាធ្វើឡើងតាមរយៈការបោះឆ្នោត។ គណបក្សនយោបាយ នីមួយៗមានមុខងារសំខាន់ក្នុងការជ្រើសរើសធនធានមនុស្សសម្រាប់តួនាទីក្នុងរចនាសម្ពន្ធនៃការដឹកនាំនិងការប្រព្រឹត្តិទៅនៃរដ្ឋាភិបាល។ ទោះបីជាប់បានឬមិនបានជាប់ឆ្នោត បានដឹកនាំរដ្ឋាភិបាលក៏ដោយ ក៏គណបក្សមានភារកិច្ច តាក់តែង និងអនុវត្តគោលនយោបាយរបស់ខ្លួនដើម្បីបម្រើប្រយោជន៍សាធារណជន និង ភ្ជាប់ទំនាក់ទំនងរវាងពលរដ្ឋទៅនឹងស្ថាប័នរដ្ឋ។

ជាទូទៅ គណបក្សនយោបាយមានអាយុកាលដូចប្រព័ន្ធនយោបាយដឹកនាំរដ្ឋដែរ។

គណបក្សនយោបាយមានទម្រង់ផ្សេងៗគ្នា។ គណបក្សខ្លះត្រូវបានរៀបចំឡើងដើម្បីគាំទ្រក្រុមឥស្សរជននយោបាយណាមួយ ក្នុងគោលបំណងជំរុញគោលនយោបាយដោយឡែកឬជំហរមនោគមន៍វិជ្ជាណាមួយ ផ្ដល់ជាជំនួយដល់ក្រុមឬផ្នែកនៃសង្គមដ៏ជាក់លាក់ណាមួយ។ គណបក្សនយោបាយ ត្រូវបានបង្កើតឡើងតាមវិធីជាច្រើនខុសៗគ្នា។ គណបក្សនយោបាយខ្លះ ប្រគល់អំណាចត្រួតត្រាឱ្យស្ថិតក្នុងកណ្ដាប់ដៃក្រុមឆ្នើមនៃគណៈកម្មការកណ្ដាលដែលត្រូវបានជ្រើសតាំងឱ្យ ស្ថិតនៅក្នុងតំណែងជារៀងរហូត ក្នុងខណៈពេលដែលគណបក្សនយោបាយខ្លះទៀត ធ្វើវិមជ្ឈការអំណាច ដើម្បីជ្រើសរើសបេក្ខជននិងធ្វើសេចក្ដីសំរេចចិត្តនៅអង្គភាពបក្សថ្នាក់មូលដ្ឋាន។

នាសតវត្សនេះ បណ្ដាសង្គមជាតិជាច្រើនក្នុងពិភពលោក មានគណបក្សនយោបាយជឿនលឿនជាច្រើនត្រូវបានបង្កើតឡើងប្រកបដោយ

ភាពចាស់ទុំនយោបាយ ដែលស្របនឹងសម្ទុះកើនឡើងនៃមនោគមវិជ្ជាប្រជាធិបតេយ្យ ។ ការយល់ដឹងនិងការឱ្យតម្លៃលើយន្តការនៃការបោះឆ្នោតជាសកល ដោយសេរី ស្មើភាព តម្លាភាព និងយុត្តិធម៌ដើម្បីផ្លាស់ប្ដូរ ឬរក្សាទុកនូវអង្គការចាត់តាំងឬក្បាលម៉ាស៊ីនដឹកនាំរដ្ឋ[6] គឺភាគច្រើនស្ថិតនៅលើឥទ្ធិពលនៃការឃោសនាអំពីការការពារអត្តសញ្ញាណជាតិស្របតាមវប្បធម៌និងការរីកចម្រើនជឿនលឿន ព្រមទាំងស្ថិតនៅលើឥទ្ធិពលនៃប្រសិទ្ធភាពនៃមធ្យោបាយផ្សព្វផ្សាយព័ត៌មាននិងសារគមនាគមន៍ដែលបាននិងកំពុងមានប្រជាប្រិយភាពកើនឡើងឥតឈប់ឈរៗ នៅក្នុងការប្រកួតប្រជែង អាចមានប្រព័ន្ធបក្សពីរ និងប្រព័ន្ធពហុបក្សៗ យុទ្ធសាស្ត្ររបស់គណបក្សនីមួយៗនៃប្រពន្ធ័បក្សពីរ ច្រើនមានភាពសម្របសម្រួល សំដៅធ្វើយ៉ាងណាឱ្យទទួលបានការគាំទ្រភាគច្រើនដាច់ខាត(៥០%បូក១)។ ចំណែកនៅក្នុងប្រព័ន្ធពហុបក្សលើសពីរ ភាពសម្របសម្រួលមានតិចជាង ហើយយុទ្ធសាស្ត្ររបស់គណបក្សគឺសង្កត់ធ្ងន់ទៅលើការរក្សាទុកឱ្យបាននូវការគាំទ្រនៃអ្នកបោះឆ្នោតគន្លឹះ ។

ដោយឡែកនៅក្នុងសង្គមឬប្រទេសដែលមានប្រព័ន្ធដឹកនាំដោយមានគណបក្សតែមួយ ឬប្រព័ន្ធមិនប្រកួតប្រជែង ជាធម្មតា គណបក្សតែងដើរតួនាទីជាឧបករណ៍របស់រដ្ឋ ក៏ដូចជារបស់រដ្ឋាភិបាល។ ក្នុងស្ថានភាពនេះ គណបក្សនយោបាយមានមុខនាទី ធ្វើយ៉ាងណារក្សាឱ្យបាននូវការគាំទ្រពីសាធារណជនចំពោះរបបដឹកនាំគ្រប់គ្រងរបស់ខ្លួន និងខំប្រឹងប្រែងលើកទឹកចិត្តប្រជាជនឱ្យចូលរួមក្នុងកម្មវិធីរដ្ឋាភិបាល និងផ្ដល់សញ្ញាឱ្យរដ្ឋាភិបាលដោយធ្វើការផ្លាស់ប្ដូរមតិជាសាធារណៈជារឿយៗតាមតែអាចធ្វើបាន ជាជាងការបំភិតបំភ័យនិងគាបសង្កត់ ដើម្បីបញ្ជៀសហានិភ័យទាំងឡាយនៃការតស៊ូបដិវត្តរបស់ប្រជាជនជាយថាហេតុ។

ជាទូទៅរចនាសម្ព័ន្ធ និងអាកប្បកិរិយានៃគណបក្សនយោបាយក្នុងប្រទេសនីមួយៗ មានលក្ខណៈផ្សេងគ្នា អាស្រ័យជាសំខាន់លើគោលនយោបាយ និងលក្ខណៈប្រវត្តិសាស្ត្រ វប្បធម៌របស់ប្រទេសឬសង្គមនីមួយៗ។

## ៩-សង្គមកិច្ច និង វប្បធម៌ នៃសង្គម

សង្គមកិច្ច និង វប្បធម៌ គឺជាកត្តាចាំបាច់សម្រាប់ទ្រទ្រង់សង្គមមួយឲ្យមានសុខុមាលភាព សន្តិសុខ សណ្ដាប់ ធ្នាប់ របៀបរៀបរយ និងចម្រើនរុងរឿង។ សង្គមកិច្ច គឺជាអន្តរកម្មនៃសញ្ចេតនានិងកាតព្វកិច្ចការងាររបស់មនុស្សក្នុងសង្គមដែលត្រូវជួយសង្គ្រោះគ្នាទៅវិញទៅមក។ អ្នកមានលទ្ធភាពមានកាតព្វកិច្ចជួយចិញ្ចឹមថែរក្សាការពារអ្នកដទៃទៀតដែលទន់ខ្សោយ។ ក្នុងន័យនេះ

[6] អង្គការចាត់តាំង ឬក្បាលម៉ាស៊ីនដឹកនាំរដ្ឋ ជាស្ថាប័នរដ្ឋាភិបាលដែលមាននាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ ការបរទេស មហាផ្ទៃ សេដ្ឋកិច្ច ហិរញ្ញវត្ថុ អប់រំនិងកីឡា យុត្តិធម៌ ជាដើម។

ឪពុកម្ដាយមានកាតព្វកិច្ចចិញ្ចឹមកូនដែលជាអនីតិជន លុះកូនធំ កូនមានករណីកិច្ចទទួលចិញ្ចឹមឪពុកម្ដាយ ដែលចាស់ជរាវិញ។ អ្នកមានជំនាញវិជ្ជាជីវៈត្រូវជួយយិតយោងដោយផ្ដត់ផ្គង់ចិញ្ចឹម សង្គ្រោះអ្នកក្រខ្សត់និងអ្នកសិក្សា និងជួយចូលរួមរក្សាថែរក្សាវិន័យសណ្ដាប់ធ្នាប់សង្គម។

សង្គមកិច្ច គឺកិច្ចការទាំងឡាយក្នុងសង្គមដែលមានគោលដៅបម្រើផលប្រយោជន៍រួម។ ការចែកដីធ្លី ផ្ទះសម្បែង ការលើកផ្លូវថ្នល់ ការសង់ស្ពាន សាលារៀន មន្ទីរពេទ្យ ការជួយសង្គ្រោះជនរងគ្រោះដោយសង្គ្រាមឬដោយហានិភ័យធម្មជាតិ ការបង្ក្រាបល្បែងស៊ីសង ការបង្ក្រាបនិងកម្ចាត់ជនទុច្ចរិតជាដើម សុទ្ធតែជា កិច្ចការសម្រាប់សម្រាលទុក្ខវេទនាមនុស្សក្នុងសង្គម និងផ្ដល់សេចក្ដីស្រណុកសុខស្រួលដល់ពលរដ្ឋនៃសង្គមនេះទៀតផង ។

ចំណែកវប្បធម៌វិញ ក៏ជាកត្តាមួយជះឥទ្ធិពលស្មើរតែទាំងស្រុងទៅលើសកម្មភាព និងវិបាកនានានៃសមាជិកសង្គម ។ វប្បធម៌ ពិតជាបានជះឥទ្ធិពលដល់ការគិត ការសំដែងមនោសញ្ចេតនា ការបញ្ចេញឥរិយបថ ការជ្រើសរើសរបៀបរស់នៅជាដើម ។ មរតកវប្បធម៌តែងមានឥទ្ធិគ្រប់ដណ្ដប់ទៅលើទំនៀមទម្លាប់ ប្រពៃណី ជំនឿ សាសនា ភាសា និងរបៀបរបបរស់នៅផ្ទាល់ខ្លួនក្នុងជីវភាពប្រចាំថ្ងៃ។ វប្បធម៌ គឺជាការសរុបរាល់អ្វីៗដែលយើងអាចរៀនសូត្រតាមរយៈការរស់នៅក្នុងក្រុម ឬសង្គមមួយជាមួយគ្នា។ លោក ប្រ៊ីនឃើសហ្វ (Brinkersoff) អះអាងថា វប្បធម៌ គឺជារបៀបរបបនៃការរស់នៅរួមរបស់មនុស្ស ដែលត្រូវបានសមាជិកសង្គមរួមគ្នាបង្កើតឡើង(វប្បធម៌រូបី) និងគំរូនៃការគិត ការមានអារម្មណ៍ និងទង្វើដដែលៗ (វប្បធម៌អរូបី)។ រីឯ លោកភឺសែល (Persell )បានពិពណ៌នាវប្បធម៌ថាជា "ឥរិយាបថទាំងឡាយដែលមនុស្សបានរៀនពីសង្គម ដូចជា ជំនឿ អារម្មណ៍ និងតម្លៃដែលជាបទពិសោធន៍របស់ក្រុម ឬសង្គមមួយផ្ដល់ឱ្យដល់សមាជិករបស់គេ។ ចំណែកលោក ហ៊របុន និង ហ័ន្ទ(Horton &Hunt) បានអះអាងថា វប្បធម៌ គឺជាប្រព័ន្ធមួយដែលបរិយាយយ៉ាងល្អិតល្អន់អំពី ស្តង់ដាដែលគេរំពឹងទុកទៅលើរបៀបរបបនៃការមានអារម្មណ៍ និងរបៀបនៃការប្រព្រឹត្តរបស់សមាជិកដែលសង្គមទទួលស្គាល់ និងត្រូវបានសមាជិករបស់សង្គមអនុវត្តតាមជាទូទៅ។

សង្គមដែលគ្មានវប្បធម៌ គឺជាសង្គមដែលគ្មានអត្តសញ្ញាណ ហើយជាសង្គមមួយដែលងាយនឹងបាត់បង់។ ក្នុងន័យនេះ ពលរដ្ឋខ្មែរតែងពោលថា វប្បធម៌រលត់ជាតិរលាយ វប្បធម៌ពណ្ណរាយជាតិថ្កើងថ្កាន។

## សេចក្ដីសន្និដ្ឋាន

ទស្សនវិជ្ជាសង្គមបានដោះបញ្ហារបស់មនុស្សប្រកបដោយវិចារណញ្ញាណ ពីជំនាន់

មួយទៅជំនាន់ៗ ទស្សនវិទូពិចារណាផ្អែកលើហេតុផលដើម្បីស្វែងរកសច្ចភាពនិងប្រយោជន៍សេចក្ដីសុខចម្រើន សុភមង្គល ដល់សង្គមមនុស្សៗ ទស្សនវិទូសង្គម យកចិត្តទុកដាក់ខ្លាំងលើប្រយោជន៍មនុស្សក្នុងសង្គមច្រើនជាងសច្ចភាពបរានុម័តិៗ

សង្គមមួយអាចផ្ដល់គុណភាពជីវិតដល់បុគ្គល, គូស្វាមីភរិយា, គ្រួសារ, ក្រុម, និងសហគមន៍បានលុះត្រាតែ រៀបចំសង្គមកិច្ចបានល្អដោយចេះរៀបចំធ្វើផែនការ គោលនយោបាយអភិវឌ្ឍសហគមន៍ដោយដោះស្រាយជីវភាពរស់នៅទាំងចំណីអាហារ សម្លៀកបំពាក់ ទីជម្រក និងអន្តរាគមន៍ដោះស្រាយវិបត្តិនានា ដើម្បីធានាសុខុមាលភាពសង្គមនិងសន្តិសុខប្រកបដោយយុត្តិធម៌ ដោយផ្ដោតលើវិស័យសំខាន់ៗ ដូចជារដ្ឋបាល សេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ អប់រំ សីលធម៌ ច្បាប់ សុខាភិបាល និង នយោបាយជាដើមៗ ម្យ៉ាងទៀត សង្គមមួយអាចដំណើរការបានល្អ លុះត្រាសមាជិកសង្គមទាំងអស់រួបរួមសាមគ្គីគ្នាប្រកបដោយគុណធម៌ គឺមានព្រហ្មវិហារធម៌ សុចរិតធម៌ និងចេះអធ្យាស្រ័យ សន្ដោសប្រោសប្រណី សមដូចពាក្យស្លោកខ្មែរថា ឈើកោងធ្វើកង់ ឈើត្រង់ធ្វើកាំ ជាដើម ។

**ឯកសារយោង/គន្ថនិទ្ទេស**

១-ជួន ណាត : *វចនានុក្រមខ្មែរ* ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ បោះពុម្ពលើកទី៥ ឆ្នាំ១៩៦៧

២-លី ដានី និងអ្នកផ្សេងទៀត : *ទស្សនវិជ្ជា* ភ្នំពេញ វិទ្យាស្ថានជាតិ ខេមរយានកម្ម ឆ្នាំ១៩៧៣

៣-សុង ស៊ីវ : *ចលនាអារ្យធម៌* ភ្នំពេញ ១៩៧១

៤- សាកលវិទ្យាល័យ បៀលប្រាយ : *មនុស្សនិងសង្គម* ភ្នំពេញ ឆ្នាំ២០១៣

# ទស្សនៈស្តីពីជីវិតរបស់ព្រះពុទ្ធសមណគោតម

*ដោយៈ លោក* **ឈុន ផារ៉េន**
*មន្ត្រីនាយកដ្ឋានទស្សនវិជ្ជា និង សង្គមវិទ្យា*
*នៃវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*

## ១. សេចក្តីផ្តើម

*ព្រះសិទ្ធត្ថកុមារ ដែលក្រោយមកមនុស្សជាច្រើនស្គាល់ថា ព្រះពុទ្ធ គឺជាបុត្រានៃមហាក្សត្រនៃប្រទេសឥណ្ឌាបុរាណ ដែលត្រូវស្នងរាជ្យសម្បត្តិបន្តពីព្រះវរបិតា។ ទោះបី បិតាខំប្រឹងប្រើប្រាស់មធ្យោបាយគ្រប់បែបយ៉ាងដើម្បីរៀបចំជីវិតបុត្រារូបនេះ ឲ្យពេញចិត្តនិងរាជសម្បត្តិដ៏ស្តុកស្តម្ភយ៉ាងណាក៏ដោយ ក៏ព្រះអង្គទទួលយកជីវិតបែបនេះឡើយ។ ព្រះអង្គចាកចោលរាជវាំង ប្រពន្ធកូន ស្រីស្នំ និងទ្រព្យទាំងឡាយ ទៅបួសជាសមណ ដើម្បីសិក្សាស្វែងរកការពិតនៃជីវិត។ ព្រះអង្គបានរកឃើញទស្សនៈស្តីពីជីវិតតាមរយៈ ចតុរារិយសច្ចៈ។ ធម៌ដែលព្រះពុទ្ធបានត្រាស់ដឹង អាចជួយមនុស្សទាំងឡាយអាចយកទៅប្រតិបត្តិក្នុងជីវិតប្រចាំថ្ងៃបានល្អប្រសើរយ៉ាងពិតប្រាកដ នៅគ្រប់សម័យកាល។*

## ២. ព្រះពុទ្ធពង្សាវលី[1]

*ព្រះពុទ្ធសមណគោតម[2] នាមដើមហៅថា សិទ្ធត្ថ[3] ជាបុត្រានៃ ព្រះបាទសុទ្ធោទន រាជ្យវង្សគោតម ព្រះរាជាបក្សសម្ព័ន្ធសាក្យៈ សោយរាជ្យសម្បត្តិនៅនគរកបិលពស្តុ[4]។ មាតា ព្រះនាមសិរិមហាមយា ជាបុត្រីព្រះរាជាបក្សសម្ព័ន្ធកោឡិយៈ នៅនគរទេវទហៈ[5]។ សិទ្ធត្ថប្រសូត នៅក្រោមសាលព្រឹក្ស នៃឧទ្យានលុម្ពិនី[6]ដែលជាព្រំដែននគរបិលពស្តុខាងបិតា និង នគរទេវទហៈខាងមាតា នៅថ្ងៃសុក្រ ១៥កើត ពេញបូរណមី ខែពិសាខឆ្នាំច ៨០ឆ្នាំមុនពុទ្ធសករាជ[7]។*

---

*[1] ព្រះពុទ្ធពង្សាវលី ពុតពង់សាវ៉ៈលី ( ន. ) ខ្សែញាតិវង្សរបស់ព្រះពុទ្ធ។*

*[2] អ្នកត្រាស់ដឹង នៃអ្នកបួស ត្រកូលគោតម។*

*[3] អ្នកសំរេចប្រយោជន៍គ្រប់យ៉ាង។*

*[4] កបិលពស្តុ ឬកបិលវត្ថុ ឬកបិលវស្តុ ជាឈ្មោះនៃទីក្រុងធំមួយក្នុងរដ្ឋសក្កៈដែលជារដ្ឋមានចំណាស់មួយ។ ទីក្រុងចំណាស់នេះ មានតាំងស្ថិតនៅក្នុងប្រទេសឥណ្ឌាភាគខាងត្បូងចម្ងាយ ១៥ គីឡូម៉ែត្រពីឧទ្យានលុម្ពិនី។ ព្រះសិទ្ធត្ថ(ព្រះពុទ្ធ)ទ្រង់បានចំណាយពេល២៩ឆ្នាំដំបូងនៃព្រះជន្មាយុព្រះអង្គរស់នៅក្នុងនគរកបិលវត្ថុនេះ។*

*[5] នគរទេវទហៈ បច្ចុប្បន្នស្ថិតក្នុងបូរណភាពរបស់ប្រទេសនេប៉ាល់។*

*[6] ឧទ្យានលុម្ពិនី បច្ចុប្បន្នស្ថិតនៅក្នុងប្រទេសនេប៉ាល់ ។*

*[7] ព្រះពុទ្ធអាយុ៨០ឆ្នាំ។ តាមពុទ្ធសាសនាកំណត់យកថ្ងៃទីមួយ ក្រោយពុទ្ធនិព្វានជាថ្ងៃផ្តើមពុទ្ធសករាជ ។ ក្នុងគ្រិស្ត*

សិទ្ធត្ថ ជាទារករឹងមាំ និងឆ្លាតបំផុត។ ពូជពង្សវង្សត្រកូលព្រះសិទ្ធត្ថ ជាអ្នក គោរពជឿព្រហ្មញ្ញសាសនា[8] យ៉ាងខ្ជាប់ខ្ជួនតាមទំនៀមទម្លាប់នៃត្រកូលក្សត្រច្រើនជំនាន់ និងជនជាតិឥណ្ឌាទូទៅ ដែរ។ គេបានធ្វើពិធីរៀបចំថ្វាយព្រះនាម ឱរស[9] ដោយថ្វាយព្រះនាមថា សិទ្ធត្ថ និងបានទស្សន៍ទាយពីជោគជតាអនាគតព្រះសិទ្ធត្ថ ដោយព្រាហ្មណ៍៨នាក់។ ព្រាហ្មណ៍[10] ប្រាំពីរនាក់ លើម្រាមពីរ ទាយថាបើព្រះរាជកុមារស្ថិតនៅជាក្សត្រព្រះអង្គនឹងបានជាស្តេចចក្រពត្តិ ប្រសិនបើព្រះអង្គចេញសាងផ្នួសនឹងបានត្រាស់ជាព្រះពុទ្ធ។ ព្រាហ្មណ៍ម្នាក់វ័យក្មេងជាងគេនាម កោណ្ឌញ្ញព្រាហ្មណ៍លើកម្រាមដៃតែមួយទាយថា ព្រះរាជកុមារ ប្រាកដជាបានត្រាស់ជាព្រះ[11] ពុទ្ធ។

សិទ្ធត្ថប្រសូត្របាន៧ថ្ងៃ ព្រះនាងសិរិមហាមយា ជាមាតាទ្រង់សោយទីវង្គត់ ព្រះរាជកុមារសិទ្ធត្ថត្រូវបានព្រះមាតុច្ឆា ព្រះនាងមហាបជាបតីគោតមីបីបាច់រក្សា។

កាលព្រះជន្មាយុគ្រប់ ៨ វស្សាព្រះរាជកុមារបានទទួលការសិក្សានូវវិជ្ជាផ្សេងៗដូចជាអក្សរសាស្ត្រ យុទ្ធសាស្ត្រ សិល្បៈក្នុងការគ្រប់គ្រង ។ល។ ទៅតាមលំនាំក្សត្រវង្សជំនាន់មុន។

---

សាសនាបានយកថ្ងៃកំណើតព្រះយេស៊ូ ជាថ្ងៃផ្ដើមគ្រិស្តសករាជ ។ ចំណែកឥស្លាមសាសនាកំណត់យកថ្ងៃព្រះមោហាម៉ាត់ត្រឡប់ចូលទៅកាន់ក្រុងយ៉ាត្រិបគឺ ម៉េឌីន (Medina=ក្រុងមេឌីណា) ថ្ងៃ ១៦ កក្កដា គ.ស. ៦២២ ថាជាមហាម័តសករាជ១ដំបូង។

[8] ចាប់ពីសតវត្សទី១០មក ព្រហ្មញ្ញសាសនា ត្រូវបានគេស្គាល់ថាជា ហិណ្ឌូសាសនា

[9] ឱរស គឺបុត្របង្កើត កូនប្រុសបង្កើត។ ខ្មែរប្រើពាក្យនេះចំពោះតែរាជសព្ទប៉ុណ្ណោះ។

[10] តាមលទ្ធិព្រាហ្មណ៍ ចែកពូជរបស់មនុស្សជា៤ថ្នាក់ ទី១- ព្រាហ្មណ៍ ថាដើមកំណើតដំបូងបំផុតកើតអំពីព្រះឱស្ឋរបស់ព្រហ្ម ដែលព្រហ្មតម្រូវឲ្យវណ្ណៈព្រាហ្មណ៍នេះ ជាម្ចាស់សាសនា មានមុខការខាងបង្រៀនប្រៀនប្រដៅវេទមន្តវិជ្ជាផ្សេងៗដល់វណ្ណៈផ្សេងទៀត; ទី២- ក្សត្រិយៈ ឬ ខត្តិយៈ កើតអំពីព្រះពាហា(ឬកំភួនដៃ តែឯកសារខ្លះថាកើតពីស្មា)របស់ព្រហ្ម មានមុខការខាងគ្រប់គ្រងរក្សាប្រទេស; ទី៣-វៃស្យៈ ឬ វេស្សៈ កើតអំពីព្រះឧរុ(ឯកសារខ្លះថាកើតពីដៃ)របស់ព្រហ្ម មានមុខការខាងធ្វើកិច្ចការខ្ពង់ខ្ពស់ចុះរងពីក្សត្រិយៈមក ឬកិច្ចការធម្មតា ; ទី៤-សូទ្រៈ ឬ សុទ្ទៈ កើតអំពីព្រះបាទរបស់ព្រហ្ម មានមុខការខាងស៊ីឈ្នួលឬការថយថោកផ្សេងៗ ។ បវេណីក្នុងកម្ពុជរដ្ឋលើកថ្នាក់វង្ស ក្សត្រិយ៍ ជាទី១, បារគូបុរោហិត (ដែលសន្មតថាព្រាហ្មណ៍ ) ជាទី២, វៃស្យៈ(ពូជព្រៃង៉ារ)ជាទី៣, សូទ្រៈ(ពូជអ្នកង៉ារ)ជាទី៤ (សម័យក្រោយមកពូជសូទ្រៈលើកលែងមិនឲ្យមាន ដោយរាប់បញ្ចូលជាប្រជាជនស្មើមុខគ្នាជាមួយនឹងវៃស្យៈទាំងអស់)។

[11] ពាក្យ ព្រះ នៅទីនេះមិនស្មើនឹងពាក្យ អាទិទេព(God) ដែលជាអ្នកបង្កើតពិភពលោកទេ។ ព្រះ ក្លាយមកពី វរ មានន័យថា ប្រសើរ, ខ្ពង់ខ្ពស់, លើសលន់; ជាចម្បង; ដែលគួរប្រាថ្នា, គួរចង់បាន ។ ព្រះ ឬ វរ សម្រាប់ប្រើនាំមុខនាមសព្ទឯទៀត បានច្រើនជាអនេកក្នុង រាជសព្ទ និងពុទ្ធសាសនា ។

លុះជន្មាយុគ្រប់ ១៦ ព្រះវស្សាព្រះរាជជនក[12] ជននី ក៏បានរៀបចំព្រះរាជពិធីអភិសេកវិវាហមង្គល ព្រះរាជកុមា សិទ្ធត្ថ ជាមួយព្រះនាងពិម្ពា យសោធរា ដែលត្រូវជាបងប្អូនជីដូនមួយក្នុងវ័យ ១៦វស្សាដូចគ្នា ជាបុត្រីរបស់ព្រះបាទសុប្បពុទ្ធ នៃនគរកោលិយៈ។

ដោយចង់បានឲ្យព្រះសិទ្ធត្ថស្នងរាជ្យសម្បត្តិ ព្រះបាទសុទ្ធោទនៈជាបិតា បានរៀបចំចាត់ចែងគ្រប់យ៉ាង ដើម្បីឲ្យព្រះសិទ្ធត្ថ អាចក្លាយជាស្តេច ។ ព្រះអង្គទ្រង់ចាត់ឲ្យគេសង់ប្រាសាទបី តម្រូវទៅតាមកាលរដូវទាំងបី គឺសម្រាប់រដូវក្តៅ រដូវរងារ រដូវរំហើយ, រៀបចំអ្នកបម្រើ ភីលៀងនៅក្នុងដំណាក់របស់ព្រះអង្គ មានសុទ្ធសឹងយុវវ័យ នារីស្អាតៗទាំងអស់។ ការគង់នៅក្នុងរាជវាំងព្រះសិទ្ធត្ថ ទ្រង់សោយសុខ ដោយកាមកិលេសលោកីយគ្រប់ប្រការ។ ព្រះអង្គទ្រង់ទតឃើញជារឿយៗ ភីលៀងអាមាត្យ ទាំងឡាយដេកលក់ ខ្លះហៀរទឹកមាត់ ខ្លះរបូតសំពត់អាវនៅស្ងួកស្តឹងហាក់គ្មានវិញ្ញាណដូចជាអង្គត់ឈើមួយដុំ។ ក្រោយមក នៅពេលដឹងថា ជីវិតពិតរបស់មនុស្សកើតមកត្រូវតែចាស់ ឈឺ ស្លាប់ទៅវិញ ធ្វើឲ្យព្រះសិទ្ធត្ថទ្រង់សង្វេគជាពន់ពេក ប៉ុន្តែនៅពេលបានជួបសមណ(អ្នកបួស) ព្រះអង្គទ្រង់មានសទ្ធាពេញហឫទ័យត្រេកអរជាក្រៃពេកចំពោះសមណភេទនេះ។

សិទ្ធត្ថគោតម មានការនឿយណាយនឹងរូបសង្ខារនិងលោកសន្និវាសនេះយ៉ាងខ្លាំង ព្រះអង្គសព្វព្រះហឫទ័យ ដោះស្រាយបញ្ហា ជិវិតដោយការចេញសាងព្រះផ្នួស ដើម្បីស្វែងរកនូវព្រះសម្មាសម្ពោធិញាណធម៌។

## ៣. ការចេញសាងផ្នួសព្រះអង្គ

កាល ព្រះសិទ្ធត្ថគោតម ព្រះជន្ម២៩ឆ្នាំថ្ងៃមួយ នាពេលថ្ងៃត្រង់ ព្រះនាមពិម្ពាយសោធរាប្រសូត្របានបុត្រាមួយអង្គ ដាក់ឈ្មោះថារាហុល[13]។ កណ្តាលរាត្រីស្ងាត់ នាថ្ងៃនោះ ព្រះសិទ្ធត្ថគោតម ចូលទៅបបោសអង្អែលរាហុលជាបុត្រាជាទីស្រលាញ់ និងងាកបែរសំលឹងទៅភរិយា ពិម្ពា ដែលកំពុងលង់លក់ក្នុងបន្ទំយ៉ាងស៊ប់ រួចហើយព្រះអង្គសម្រេចចិត្តយ៉ាងមុតមាំចាកចេញពីរាជវាំងដើម្បីសាងផ្នួស ។ ក្រោយពិធីសាងផ្នួស ព្រះសិទ្ធត្ថគោត្តម ទ្រង់ព្រះនាម(ត្រូវបានហៅ)ថា សមណគោតម តរៀងមក។ ចំណែកកោណ្ឌញ្ញព្រាហ្មណ៍ដែលជាព្រាហ្មមួយ

[12] ជនក ជៈនៈកៈ ឬ ជៈនក់ ( ន. ) (រាជសព្ទ) បិតា បុរសអ្នកបង្កើតកូន។

[13] រាហុល ជាឈ្មោះព្រះរាជឱរសនៃព្រះសក្យមុនីគោតម (កាលដែលព្រះសិទ្ធត្ថទ្រង់បានជ្រាប ដំណឹងថា "ព្រះរាជបុត្រប្រសូតហើយ", ទ្រង់លាន់ព្រះឱស្ឋថា "រាហូចាប់អញហើយតើ ! ចំណងកើតហើយតើ !" គឺទ្រង់ប្រៀបថាព្រះរាជបុត្រទុកដូចជារាហូនិងចំណងចាប់ចងព្រះអង្គ; ដោយហេតុនេះ បានជាព្រះបាទសិរីសុទ្ធោទនៈព្រះអង្គបានជ្រាបការណ៍នេះហើយ ទើបទ្រង់ព្រះរាជទាននាមព្រះរាជនត្តារបស់ព្រះអង្គថា រាហុល) ។

អង្គក្មេងជាងគេ ដែលកាលធ្វើពិធីថ្វាយព្រះនាមព្រះសិទ្ធត្ថ បានទាយថាព្រះសិទ្ធត្ថពិតជានឹងបានត្រាស់ដឹងជាព្រះពុទ្ធនោះ កាលបើដឹងថាព្រះសិទ្ធត្ថចេញសាងផ្នួសហើយ ក៏មានសទ្ធាជ្រះថ្លារួមជាមួយ សមណ ៤ អង្គទៀត ចេញទៅបួសតាមជួយថែរក្សាព្រះអង្គដែរ ។ អ្នកបួសទាំង៥នាក់នោះហៅថា បញ្ចវគ្គិយ៍ភិក្ខុ។

## ៤. **ទុក្ករកិរិយា ឬតបៈ**?

សមណ[14]គោតមបួសតាមប្រពៃណីសាសនាព្រាហ្មណ៍។ ព្រះអង្គបានសិក្សាពីសំណាក់គ្រូពីរនាក់ ដែលជាអ្នកប្រាជ្ញកំពូលខាងព្រាហ្មណ៍សាសនា គឺអាឡារតាបស និង ឧទកតាបស។ ក្រោយមក ដោយយល់ថា តាបស[15]ទាំងពីរអង្គពុំអាចឲ្យព្រះអង្គស្វែងរកសម្មាសម្ពោធិញ្ញាណនៃការត្រាស់ដឹងបាន ព្រះអង្គក៏សម្រេចព្រះហឫទ័យ សុំលាចាកចេញពីតាបសទាំងពីរ ហើយស្វែងរកសច្ចធម៌ ដោយព្រះអង្គឯង។ ព្រះអង្គទ្រង់ធ្វើទុក្ករកិរិយា[16] ដោយការប្រតិបត្តិធម៌យ៉ាងតឹងរឹង ដូចជាមានការអត់អាហាររហូតរូបរាងកាយស្គាំងស្គមជាខ្លាំង ធ្វើឲ្យមានការពិបាកដល់រូបកាយយ៉ាងក្រៃលែងបំផុត ដូចការប្រតិបត្តិតបៈ[17] ក្នុងព្រហ្មញ្ញសាសនាដែរ។

ការប្រព្រឹត្តទុក្ករកិរិយាអស់រយពេល៦ឆ្នាំ សមណគោតម មិនអាចរកឃើញសច្ចធម៌នៅឡើយ។ បន្ទាប់មក ព្រះអង្គទ្រង់ពិចារណាដោយប្រៀបធៀបការប្រព្រឹត្តប្រតិបត្តិតាមពិធីរឹតដេញខ្សែពិនជាគោល, ឃើញថាការធ្វើប្រតិបត្តិធូរលុងហួសពេក និងការប្រព្រឹត្តប្រតិបត្តិតឹងរ៉ឹងជ្រុលពេក ជាហេតុមិនអាចនាំមកនូវការត្រាស់ដឹងបានឡើយ។ លុះទ្រង់ពិចារណា ហេតុផលដូចនេះហើយ ទើបព្រះអង្គទ្រង់លះបង់ ការធ្វើទុក្ករកិរិយាចោល ហើយចាប់ផ្តើមប្រតិបត្តិជាកណ្តាល (របៀបមធ្យម ឬមជ្ឈិមាបដិប្បទា) គឺមិនធូរលុងពេកនិងមិនតឹងតែងពេក ដោយព្រះ

[14] សមណ  សៈម៉ៈណៈ ( ន. ) (សមណ; ស្រមណ) អ្នកមានព្យាយាមដុតកម្ដៅបាប, អ្នកខំប្រឹងប្រព្រឹត្តធម៌ធ្វើកាយវាចាចិត្តឲ្យស្ងប់ចាកបាប, អ្នកស្ងប់, អ្នករម្ងាប់បាប (អ្នកបួស) ។

[15] តាបស  (អានថា តាបស់)  បា. ( ន. ) ឥសី, អ្នកបួសខាងក្រៅពុទ្ធសាសនា កាន់ព្រហ្មណចរិយធម៌ វៀរចាកមេថុនធម្ម ប្រព្រឹត្តកាន់តបៈ ។

[16] ទុក្ករកិរិយា (ទុក-កៈរ៉ៈកិរិយ៉ា) ន.(បា.;សំ.ទុស្ករក្រិយា) អំពើយ៉ាងកម្រ, ដំណើរធ្វើកិច្ចដែលអ្នកទាំងពួងធ្វើបានដោយកម្រ។

[17] តបៈ  តៈប៉ៈ ឬ តៈបះ ( ន. ) (តបសិ > តបះ; តប) ការប្រព្រឹត្តកាន់វត្តយ៉ាងតឹងដើម្បីធ្វើកាយនិងចិត្តឲ្យស្ងប់ ។ ការប្រព្រឹត្តខំប្រឹងសិក្សាវេទមន្តព្រមទាំងកាន់វត្តប្រតិបត្តិតាមសណ្ដាប់របស់ពួកព្រាហ្មណ៍ តាបស, ឥសី; ។ ចំណែកតបះ របស់និគ្រន្ថតិរ្ថិយចំពួកខ្លះទៀត មានការប្រព្រឹត្តកាន់វត្តយ៉ាងតឹង ធ្វើខ្លួនឲ្យលំបាកហួសប្រមាណ ដូចជាការប្រព្រឹត្តតមមិនស្លៀកដណ្ដប់, មិនដេកលើគ្រឿងក្រាល ដេកផ្ទាល់តែលើផែនដីជាដើម។

អង្គទ្រង់ចាប់ផ្ដើមសោយអាហារខ្លះឡើងវិញ។ បញ្ចវគិយ៍ភិក្ខុ ឃើញដូចនោះ គិតយល់ថា ព្រះសិទ្ធត្ថសមណគោតម បាត់អស់សេចក្ដីព្យាយាមហើយ ដូច្នេះព្រះអង្គមិនអាចត្រាស់ដឹងជាព្រះពុទ្ធបានឡើយ ហើយក៏នាំគ្នាចាកចោលព្រះអង្គអស់ទៅ។

## ៥. ដំណើរនៃការត្រាស់ដឹង

ក្រោយពីលះបង់ចោលការធ្វើទុក្ករកិរិយា សមណគោតម ក៏ចាប់ផ្ដើមប្រព្រឹត្តប្រតិបត្តិតាមមជ្ឈិមបដិបទា វិញ។ ព្រះអង្គទ្រង់យាងទៅកាន់វដ្ឋមគធ[18] ក្នុងស្រុក ពោធិគយា ទ្រង់យាងទៅដល់មាត់ស្ទឹងនេរញ្ជរា ដ៏មានទឹកថ្លាគួរជាទីស្នាក់អាស្រ័យនៃសមណទាំងឡាយ ។ ទ្រង់គង់នៅក្រោមដើមពោធិព្រឹក្សមួយ ខាងលិចស្ទឹង បែរព្រះភក្ត្រទៅទិសបូព៌ ទ្រង់យកស្បូវភ្លាំង ដែលសាត្ថិយកុមារប្រគេននៅតាមផ្លូវ យកទៅក្រាលធ្វើជាកំរាលដើម្បីគង់ធ្វើសមាធិ។ ព្រះសមណគោតមទ្រង់គង់ភ្នែនពែនព្រះបាទលើបល្ល័ង្គដោយសុខស្រួល ហើយក៏តាំងប្រមូលអារម្មណ៍អធិដ្ឋានយ៉ាងមុតមាំជាទីបំផុតថាទោះបីមានឧបសគ្គដល់អាយុជីវិតក៏ដោយ ក៏ត្រូវរកការពិតគឺការត្រាស់ដឹងសច្ចធម៌ឲ្យខាងតែបាន។

ដំបូងព្រះអង្គទ្រង់ចាប់ផ្ដើមការនាចម្រើនអានាបាណសតិ[19] ធ្វើព្រះចិន្តា[20]ឲ្យស្ងប់ចាកនីវរណធម៌[21]ទាំងឡាយ បន្ទាប់មកទ្រង់ក៏បានសម្រេច ឈាន[22] ជាលំដាប់ រហូតបានត្រាស់ដឹង

---

[18] មគធ (ឬ មគធៈ) អានថា មៈគៈធៈ ( ន. ) ឈ្មោះដែនធំមួយក្នុងប្រទេសឥណ្ឌា ពីក្នុងពុទ្ធកាល, មានក្រុងរាជគ្រឹះជារាជធានី លុះបន្ទាប់មក មានក្រុងបាដលិបុត្រ ជារាជធានី; បច្ចុប្បន្នគឺ រដ្ឋប៊ិហារ (ពិហារ) នៃប្រទេសឥណ្ឌា។

[19] អានាបាណសតិ គឺស្មារតីនៃការដកដង្ហើម ដែលចាត់ ជាបែបនៃសមាធិមួយឲ្យដឹងនូវវេទនារម្មណ៍ក្នុងកាយ តាមសកម្មភាពនៃការដកដង្ហើមតាមវិធីចម្រើនសតិ ។ អានាបាណសតិ  អានថា អាន៉ាប៉ាណសតិ (< អាន "ខ្យល់ដង្ហើមចេញ" + អាបាណ "ខ្យល់ដង្ហើមចូល")។

[20] ចិន្តា  អានថា ចិន-ដា ( ន. ) ចិត្ត,  សេចក្ដីគិត(គំនិត) ។

[21] នីវរណធម៌  ( ន. )  សភាវៈរាំងរាំង ឃាត់ឃាំងទប់ចិត្តមិនឲ្យងាកទៅរកអំពើជាកុសល, មាន ៥ យ៉ាង គឺ ១-កាមច្ឆន្ទៈ សេចក្ដីប្រាថ្នាឬការពេញចិត្តចំពោះកាម; ២-ព្យាបាទៈ គំនុំឬសេចក្ដីគុំកួនធ្វើឲ្យអ្នកដទៃវិនាស; ៣-ថីនមិទ្ធៈ ការប្រអូសធុញទ្រាន់និងការងងុយដេក; ៤- ឧទ្ធច្ច-កុក្កុច្ចៈ សេចក្ដីរាយមាយនិងសេចក្ដីរសាប់រសល់ឬក្ដៅក្រហាយក្នុងចិត្ត; ៥-វិចិកិច្ឆា សេចក្ដីសន្ទិះសង្ស័យមិនដាច់ស្រេចក្នុងចិត្ត : នីវរណធម៌ជាទំនាស់នៃសមាធិ ។

[22]  ឈាន  ឬ ធ្យាន ( ន. )  ការសម្ងឹងអារម្មណ៍ ដែលជាអប្បនាសមាធិ។ អប្បនាសមាធិ គឺការតម្កល់ចិត្តស៊ប់មាំឬការទប់ចិត្តឲ្យតាំងនៅស្មើក្នុងអារម្មណ៍ដែលប្រកបដោយអង្គឈាន។ ឈានមាន ៤ ថ្នាក់ គឺថ្នាក់ទី១ ហៅ បឋមជ្ឈាន មានអង្គ៥ គឺ ១- វិតក្កៈ សេចក្ដីនឹកសំដៅឆ្ពោះទៅរកអារម្មណ៍ដែលកំពុងភាវនា; ២- វិចារៈ សេចក្ដីរំពឹងពិចារណាអារម្មណ៍ដែលកំពុងភាវនា; ៣- បីតិ សេចក្ដីឆ្អែតចិត្ត; ៤- សុខៈ សេចក្ដីសប្បាយក្នុងចិត្ត; ៥- ឯកគ្គតា ដំណើរមូលចិត្តស្ទុងទៅក្នុងអារម្មណ៍តែមួយ (អង្គទាំង ៥ នេះ សំដៅចំពោះអារម្មណ៍ ដែលស្ងប់ស្ងាត់ចាកកាមគុណ); ថ្នាក់ទី ២ ហៅ ទុតិយជ្ឈាន មានអង្គ ៣ គឺលះ វិតក្កៈ វិចារៈ ចេញ នៅសល់តែ បីតិ និង សុខៈ ដែលកើតមកជាប់មកអំពីសមាធិរបស់បឋមជ្ឈានជា៣ នឹង ឯកគ្គតា, ថ្នាក់ទី៣ហៅ តតិយជ្ឈាន មាន អង្គ ២ គឺលះ បីតិ

នូវពុទ្ធិ គឺត្រាស់ដឹងសម្មាសម្ពោធិញាណ ក្លាយជាព្រះពុទ្ធ។

ព្រះអង្គទ្រង់ដឹង(សោយ, ពាល់ត្រូវ) នូវវេទនាខន្ធ ដែលជាលំហូរទៅ(ដំណើរការ)នៃសង្ខារខន្ធនិងសញ្ញាខន្ធ នៅក្នុងរូបខន្ធនិងវិញ្ញាណខន្ធ។ ទ្រង់ឈ្វេងយល់[23] ឃើញថា សត្វលោកកំពុងជាប់ជំពាក់គ្មានទីបញ្ចប់នូវទុក្ខសោកទាំងឡាយក៏ព្រោះតែការភ័ន្តច្រឡំនៃសញ្ញាខន្ធ ដោយមានជំនឿថា អ្វីៗដែលជារបស់មិនទៀងទាត់ ថាជារបស់ទៀងទាត់ អ្វីៗដែលមិនមែនរបស់ខ្លួន(អនត្តា)ថាជារបស់ខ្លួន(អត្តា)។

ព្រះអង្គទ្រង់បានបង្ហាញឲ្យឃើញនូវការយល់ដឹងរបស់ព្រះអង្គ ចំពោះទ្រឹស្តីធម៌ ដោយច្បាស់ថា ភាវៈខាងគំនិត ប្រាជ្ញា (បញ្ញា) អាចប្រតិបត្តិដើម្បីរំដោះឲ្យរួចចាកពីពិភពនៃសេចក្តីទុក្ខទោមនស្ស ដែលមានជាអាទិ ការភ័យខ្លាច ខឹង ស្អប់ ក្រអឺតក្រអោង ច្រណែនឈ្នានីស ប្រច័ណ្ឌ លោភលន់ អំនួត អួតអាង ជំនឿ ស៊ីជោរ បញ្ឆើចបញ្ឆើ ដោយល្ងង់ខ្លៅ ។ល។ សេចក្តីទុក្ខទោមនស្សទាំងនេះ អាចមានដំណោះស្រាយប្រសិនបើមានការគិតពិចារណាយល់ដឹងត្រឹមត្រូវប្រកបដោយបញ្ញា។

ព្រះអង្គទ្រង់ឈ្វេងយល់យ៉ាងច្បាស់ថា ប្រភពនៃទុក្ខសោក(ទុក្ខទោមនស្ស)ទាំងឡាយគឺពិតជាកើតឡើងដោយសារតែធាតុអវិជ្ជា និងតណ្ហា ដែលជាបច្ច័យនៃការកើតស្លាប់ (ជាតិមរណៈ) និង ស្លាប់កើត(ចុតិ បដិសន្ធិ)។ ដើម្បីរំដោះសេចក្តីទុក្ខនេះបាន ត្រូវទំលុះផ្តាច់នូវអវិជ្ជា និងតណ្ហា ដោយរែករក បុព្វហេតុនៃសេចក្តីពិតក្នុងបញ្ចខន្ធ[24] ។

ព្រះពុទ្ធទ្រង់បានយល់ច្បាស់ថា ភាវៈនានា(នាមរូបំ)មិនអាចស្ថិតស្ថេរបានឡើយ គឺវាតែងតែប្រែប្រួលផ្លាស់ប្តូរ(អនិច្ចំ) ហើយវាមិនមែនជាកម្មសិទ្ធពិតប្រាកដរបស់ខ្លួនបុគ្គលដែលកំពុងអត្ថិភាពនោះឡើយ គឺវាជាអនត្តា(ខ្លួនមិនមែនជារបស់ខ្លួន)។ បើគ្មានធម៌អនិច្ចំនិងអនត្តាទេ គឺអ្វីៗមិនអាចកើតឡើងចំរើនលូតលាស់និងវិនាសទៅវិញនោះឡើយ។ អ្វីសុទ្ធតែប្រែប្រួល ហើយមានតែការប្រែប្រួលទេដែលពុំចេះប្រែប្រួល។

ចេញ នៅសល់តែ សុខៈ និង ឯកគ្គតា; ថ្នាក់ទី ៤ ហៅចតុត្ថជ្ឈាន មានអង្គ២ ដែរលះសុខៈ ចេញចិត្តក្លាយទៅជា ឧបេក្ខា គឺដើយព្រងើ យ ជា២ នឹង ឯកគ្គតា ។ ឈានទាំងបួនថ្នាក់នេះ ហៅថា រូបជ្ឈាន មានរូបធម៌ជាអារម្មណ៍រាប់បញ្ចូលក្នុងរូបាវចរភូមិ ។ បុគ្គលអ្នកចម្រើនភាវនា បានសម្រេចផ្លូវឈាន សូម្បីត្រឹមតែបឋមជ្ឈានប៉ុណ្ណោះ ក៏ជួបប្រទះសេចក្តីសុខសប្បាយធម្មតា ធ្ងាញ់ពិសាជាងរសជាតិអ្វីៗ ទាំងអស់។

[23] ឈ្វេងយល់ ( កិ. ) រំពឹងគិតយល់ដោយប្រាជ្ញាដ៏ភ្លឺថ្លា ។

[24] ខន្ធ ឬ (ស្កន្ធ) ( ន. ) ក; ដើម; គំនរ : ពួក, កង, ប្រជុំ; កំណាត់ ។ ខន្ធ៥ គឺរូបក្ខន្ធ, វេទនាខន្ធ, សញ្ញាខន្ធ, សង្ខារក្ខន្ធ, វិញ្ញាណក្ខន្ធ ។ ទម្លាយខន្ធ ឬ រំលាងខន្ធ គឺស្លាប់ ។ រំលត់ខន្ធ គឺបរិនិព្វាន លែងកើតស្លាប់ទៀត។

## ៦.ការផ្ចាញ់របស់មារ និងការឈ្នះកិលេសមារ

នាពេលព្រលប់ ព្រះពុទ្ធសមណគោតម ទ្រង់គង់លើរតនបល្ល័ង្ក ក្រោមពោធិព្រឹក្ស ។ មារាធិរាជ បានមកផ្ចាញ់ព្រះអង្គដោយឲ្យកូនស្រីក្រមុំស្រស់ល្អឯកទាំងបីនាក់គឺ នាងតណ្ហា១ នាងអរតី១ និង នាងរាគា១ មកអន្ទងចិត្តព្រះសមណគោតម ដើម្បីឲ្យព្រះអង្គលះបង់ការស្វែងរកការត្រាស់ដឹងចោល តែព្រះអង្គពុំមានការចាប់អារម្មណ៍ឡើយ ធ្វើ ឲ្យនាងទាំងបីវិនាសដោយចុះចាញ់យ៉ាងអាម៉ាស់។ ខ្លឹមសារសំខាន់គឺ ព្រះអង្គបានឈ្នះមារក្នុងខ្លួនគឺ រាគាទិក្កិលេស[25]។

បន្ទាប់ពីទទួលបរាជ័យតាមគម្រោងនេះ ក្រុងមារដែលមានចិត្តឫស្យាបានមកផ្ចាញ់ផ្ចាលព្រះអង្គទៀត ។ ខណៈព្រះសមណគោតម ដែលជាតួអង្គពោធិសត្វ[26]កំពុងគង់នៅលើរតនបល្ល័ង្កហៀបនឹងត្រាស់ដឹងជាព្រះពុទ្ធទៅហើយ គ្រានោះ វសវត្តីមារ ដែលជាអ្នកមានអំណាចលើសត្វលោកទាំងអស់បានប្រជុំពលមាររបស់ខ្លួនហើយបញ្ជាឲ្យបក្សពួកនិម្មិតខ្លួនជាភេទប្លែកៗគួរឲ្យខ្លាចកាន់អាវុធផ្សេងៗក្នុងដៃ ហើយនាំគ្នាចូលទៅរកព្រះសិទ្ធត្ថឲ្យដូច រលកហូរចូលទៅ។ ចំណែកវសវត្តីមារខ្លួនឯង ជិះដំរីមេខលា ដ៏ធំសម្បើម និមិត្តដៃមួយពាន់ កាន់អាវុធនានាហើយតម្រង់មករកព្រះពោធិសត្វ។ ចំណែកបរិស័ទរបស់ខ្លួនកាន់យកអាវុធផ្សេងៗគ្រប់ដៃមានដាវ កាំបិត ព្រួញ និងលំពែងជាដើម ពាក់ក្លងពស់ យកមាត់បៀមពិស ផ្ទុំភ្លើង ចេញពីមាត់មានកាយអាក្រាត សម្បុរកខ្វក់និម្មិតភេទផ្សេងៗដូចជា តិរច្ឆាន ប្រេត មានតែគ្រោងឆ្អឹងជាដើម ធ្វើរូបប្លែកៗគួរឲ្យខ្លាចទៅឡោមព័ទ្ធ ជុំវិញព្រះសមណកោតម ។ កាលវសវត្តីមារចូលទៅជិតព្រះបរមពោធិសត្វយ៉ាងនេះហើយ ទេវតាទាំងឡាយ មានសក្កទេវរាជ ព្រះព្រហ្មជាដើម សូម្បីត្រឹម១អង្គដែលអាចស្ថិតនៅទីនោះក៏មិនមានឡើយ គឺនាំគ្នារត់ចេញទៅទីដទៃៗយកតែប្រាសអាយុរៀងៗខ្លួន។ ក្នុងគ្រានោះ មារបានបណ្ដាលជាភ្លៀង៨ ប្រការ ដើម្បីញុំាងភ័យឲ្យកើតឡើងដល់ព្រះពោធិសត្វគឺ៖

១-បណ្ដាលឲ្យកើតខ្យល់ព្យុះដែលមានសន្ទុះយ៉ាងខ្លាំង អាចបក់បោកដើមឈើឲ្យរលំ បក់ថ្មឲ្យប៉ើង អាចបណ្ដាលឲ្យរបើកដំបូលផ្ទះដែលមានកំពូលបាន តែមិនអាចធ្វើសូម្បីត្រឹមតែជាយចីវរព្រះពោធិសត្វឲ្យកម្រើកបានឡើយ ។

---

[25] រាគាទិក្កិលេស (បា. < រាគ+អាទិ+កិលេស) កិលេសមានរាគៈជាដើម។ រាគៈ ( ន.) (រាគ) តម្រេក, សេចក្ដីរីករាយ, ត្រេកត្រអាលចំពោះកាម។

[26] ពោធិសត្វ (អានថា ពោធិស័ត ( ន. ) (ពោធិសត្ត) អ្នកដែលមានចិត្តឬមានសេចក្ដីប្រាថ្នាជាប់នៅក្នុងពោធិ គឺ អ្នកដែលកំពុងខំប្រឹងបំពេញបារមី បម្រុងនឹងបានត្រាស់ជាព្រះសម្មាសម្ពុទ្ធ។

២-បណ្ដាលឲ្យកើតធ្លាក់គ្រាប់ភ្លៀងធំៗ មកលើព្រះពោធិសត្វ តែមិនអាចធ្វើសូម្បីឲ្យទទឹកជាយចីវរ ព្រះពោធិសត្វបានឡើយ ។

៣-បណ្ដាលឲ្យកើតភ្លៀងរភ្លើងថ្ម ដែលមានកម្ដៅដ៏ក្ដៅរាប់ម៉ឺនអង្សាធ្លាក់ចុះមក ប៉ុន្តែសម្រាប់ព្រះពោធិសត្វ រងើកភ្លើងថ្មនោះ គឺជាកម្រងផ្កាទៅវិញ។

៤-បណ្ដាលឲ្យកើតភ្លៀងអាវុធមុខមួយ អាវុធមុខពីរ មានសរ លំពែង និងដាវជាដើម ធ្លាក់ចុះពីព្ធដ៏អាកាស ប៉ុន្តែសម្រាប់ព្រះពោធិសត្វ វាជាភួងផ្កាម្ទិះជាដើម រោយរាយធ្លាក់ចុះទៅវិញ។

៥-បណ្ដាលឲ្យកើតភ្លៀងអណ្ដាតភ្លើង ធ្លាក់ចុះពីអាកាស ប៉ុន្តែសម្រាប់ព្រះពោធិសត្វ វាជាលម្អិតខ្លឹមចន្ទន៍ធ្លាក់ចុះទៅវិញ ។

៦-បណ្ដាលឲ្យភ្លៀងខ្សាច់ក៏ក្ដៅគគុកធ្លាក់ចុះមក ប៉ុន្តែសម្រាប់ពោធិសត្វ វាជាកេសរផ្កាធ្លាក់ចុះទៅវិញ។

៧-បណ្ដាលឲ្យកើតភ្លៀងភក់ធ្លាក់ចុះមក ភ្លៀងភក់នោះមានកម្ដៅយ៉ាងខ្លាំង ប៉ុន្តែសម្រាប់ពោធិសត្វ វាក្លាយទៅជាភក់មានក្លិនក្រអូបទៅវិញ ។

៨-បណ្ដាលឲ្យកើតគប់ភ្លើងជាច្រើនធ្លាក់ចុះមកកម្ទេចភ្លើង និងផ្សែងភ្លើងពាសពេញអាកាសរន្ទះបាញ់លាន់ឮកក្រើករំពើក ញាប់ញ័រពេញអាកាសា សម្រាប់ពោធិសត្វ វាជាគ្រឿងសក្ការបូជាដ៏ប្រណីតទៅវិញ ។

ដោយមិនអាចធ្វើអ្វីចំពោះព្រះពោធិសត្វបាន មារាធិរាជក៏មានបំណងចូលទៅកាត់ព្រះសីសៈព្រះមហាបុរស ទើបចាប់ចក្រាវុធគប់សំដៅទៅរកព្រះអង្គ អាវុធនោះបានធ្លាក់ចុះជិតព្រះបាទព្រះអង្គ ប៉ុន្តែវាបែរជាក្លាយជាសំពត់ជូតព្រះបាទព្រះអង្គទៅវិញ។

ដោយទាល់គំនិត មិនដឹងនឹងរកអ្វីតទល់យកឈ្នះលើព្រះអង្គបាន មារស្រែកសម្លុតព្រះអង្គយ៉ាងកំរោល ឲ្យព្រះអង្គចាកចេញពីបល្ល័ង្គ។ ព្រះពោធិសត្វសម្លឹងមើលមារ និងសេនារបស់មារដោយមេត្តាចិត្ត ប្រៀបដូចបិតាសម្លឹងមើលមុខបុត្រ ។ គ្រានោះព្រះពោធិសត្វពោលចំពោះមារថា ម្នាលមារល្ងង់អ្នកឯងមិនដឹងខ្លួនឯងជាទោសៈរបស់យើងសោះៗ ព្រះសមណគោតមទ្រង់លើកព្រហស្តស្តាំ ចង្អុលព្រះធរណី និងអំពាវនាវប្រាប់ធរណី ឲ្យជួយធ្វើសាក្សី ទទួលដឹង លឺនូវអំពើកុសលរបស់ព្រះអង្គ។

ព្រះអង្គទ្រង់ត្រាស់ថា មហាប្រឹថពី(ដី)នេះហើយជាសាក្សីរបស់យើង។ ចំណែកនាងគង្គីងព្រះធរណីបានចេញមក ហើយយកដៃស្បូតសក់ហូរចេញជាទឹកក្លាយជាសមុទ្រ ពន្លិចរេហ៍ពលរបស់មហាមារអស់។

មហាមារឃើញដូច្នោះហើយក៏ក្រាបថ្វាយបង្គំព្រះអង្គដោយសរសើរថា «បពិតមហាបុរស អ្នកជាអ្នកមានញាណញេយ្យ ដ៏អស្ចារ្យមែន យើងខ្ញុំព្រះករុណា សូមនមស្សការដោយគោរព»។ ទីបំផុត ព្រះសមណគោតម បានឈ្នះ

ពល់ការខំប្រឹងប្រែងគំរាមកំហែងទាំងអស់របស់មារ ហើយបានធ្វើឲ្យមារព្រមចុះចាញ់។ ជារួម ព្រះអង្គបានឈ្នះមារ គឺ ទោសាទិក្កិលេស[27] ។

ចំណែកឯ ពួកទេវតាទាំងឡាយមាន សក្កទេវរាជ មហាព្រហ្ម ស្ដេចកាឡនាគរាជ ដ៏មានឫទ្ធានុភាព នៅពេលដែលមារកំពុងតាមផ្ចាញ់ព្រះសមណគោតម នាំគ្នាភ័យរន្ធត់ឥតឧបមា ហើយនៅពេលព្រះអង្គបានឈ្នះមារ ទេវតាទាំងឡាយនោះ បានចេញមកអបអរសាទរជ័យជំនះរបស់ព្រះពុទ្ធយ៉ាងកងរំពង។

## ៧. ការត្រាស់ដឹង សម្មាសម្ពោធិញ្ញាណ

ព្រះសមណគោតម ឈ្វេងយល់ថា ជីវិត (សង្ខារ)ទាំងឡាយមិនស្ថិតស្ថេរឡើយ និងប្រកបដោយទុក្ខវិលវល់ កើតស្លាប់ (ជាតិ មរណៈ) ស្លាប់កើត (ចុតិ បដិសន្ធិ) ក្នុងវាលវដ្តសង្សារ ដោយសារអវិជ្ជាជាបច្ច័យ។ ដោយសារ ញាណសម្បយុត្ត[28] ព្រះសមណគោតម បានចាកឆ្ងាយពីមារ គឺ មោហាទិក្កិលេស[29] និងកិលេសដទៃទៀត[30] ហើយបានត្រាស់ដឹងនូវសច្ចធម៌[31] គឺចតុរារិយសច្ចៈ[32]។ ព្រះអង្គមើលឃើញថា ការកើតជីវិត(ជាតិ)ទាំងឡាយ បណ្ដាលមកពីធាតុអវិជ្ជា គឺ សង្ខតធាតុ មានទឹកដីភ្លើងខ្យល់តាមច្បាប់ធម្មជាតិ ពុំមានព្រះអាទិទេពអង្គណាមួយ ជាអ្នកបង្កើតនោះឡើយ។ អ្វីៗទាំងអស់មិនមែនជារបស់ខ្លួនឡើយ វារងសម្ពាធជាទុក្ខនិងប្រែប្រួលជាដរាប(នាមរូបំ អនិច្ចំ ទុក្ខំ អនត្តា)។ វដ្តសង្សារនៃជីវិតក្នុងចក្រវាឡត្រូវស្ថិតនៅក្រោមទ្រឹស្ដីបដិច្ចសមុប្បាទ[33] ទាំងអស់។

---

[27] ទោសាទិក្កិលេស (បា. < ទោស+អាទិ+កិលេស) កិលេសមានទោសៈជាដើម។ ទោស បា. ( ន. ) ការប្រទូស្ត, កំហឹង; សម្អប់, កំហុស : មានទោសធ្ងន់ ។

[28] ញាណសម្បយុត្ត (ឬ សម្បយុត្តញាណ) គឺ ចិត្ត(ឬគំនិត) ប្រកបដោយបញ្ញា(ឬប្រាជ្ញា) ។

[29] មោហាទិក្កិលេស (បា. < មោហ+អាទិ+កិលេស) កិលេសមានមោហៈជាដើម។ មោហៈ ឬ មោហ ( ន. ) ភាពអវិជ្ជា, សេចក្ដីវង្វេង, សេចក្ដីល្ងង់ឬក័ន្តស្មារតីមិនយល់ការណ៍ពិត , មិនស្គាល់ខុសត្រូវ។

[30] កិលេស១០យ៉ាង៖ ១.លោភោ សភាពធ្វើចិត្តឲ្យជាប់ជំពាក់នៅក្នុងអារម្មណ៍ ។ ២.ទោសោ សភាពធ្វើចិត្តឲ្យប្រទុស្តក្នុងអារម្មណ៍ ។ ៣.មោហោ សភាពធ្វើចិត្តឲ្យវង្វេងក្នុងអារម្មណ៍ ។ ៤.មានោ សភាពលើកខ្លួន ឬដាក់ខ្លួនហួសការពិត ។ ៥.ទិដ្ឋិ ធម្មជាតិធ្វើចិត្តឲ្យឃើញខុស ឬយល់ខុស ។ ៦.វិចិកិច្ឆា ធម្មជាតិឲ្យសង្ស័យ ឬស្ទាក់ស្ទើរ ។ ៧.ថីនំធម្មជាតិឲ្យចិត្តឲ្យរួញរា ឬធុញទ្រាន់ក្នុងកុសលផ្សេងៗ ។ ៨.ឧទ្ធច្ចំ ធម្មជាតិធ្វើចិត្តឲ្យញាប់ញ័រ ឬឲ្យរាយមាយ ។ ៩.អហិរិកំ ធម្មជាតិមិនខ្មើមអំពើទុច្ចរិត ។ ១០.អនោតប្បំ ធម្មជាតិមិនខ្លាច ឬមិនតក់ស្លុតនូវអំពើទុច្ចរិត ។

[31] សច្ចធម៌ (ន.)សភាវៈឬធម្មជាតិពិតមិនក្លែងបន្លំបោកបញ្ឆោត។

[32] ចតុរារិយសច្ចៈ (ន.) ការពិតប្រាកដ៤យ៉ាង ដែលជាមូលដ្ឋានគ្រឹះនៃទស្សនវិជ្ជាពុទ្ធសាសនា គឺ៖ ១.ទុក្ខ ២.សមុទយ ៣.និរោធ ៤.មគ្គ។

[33] បដិច្ចសមុប្បាទ ប៉ៈដិច-ចៈ- សៈម៉ុប-បាត បា. ( ន. ) ធម៌ឬសភាវៈដែលកើតមានឡើងដោយសារបច្ច័យ គឺគ្រឿងអាស្រ័យទាក់ទងតៗគ្នា១២កងជាប់គ្នាគឺ៖ ១.អវិជ្ជាជាបច្ច័យឲ្យកើតសង្ខារ, ២.សង្ខារជាបច្ច័យឲ្យកើតវិញ្ញាណ,

លុះព្រលឹមអរុណរះ ព្រះនាងសុជាតា បានរៀបចំម្ហូបអាហារ ដើម្បីយកទៅ ថ្វាយបូជា ដល់ដើមពោធិព្រឹក្សដែលព្រះនាងបានធ្វើការបន់ស្រន់សុំរាជបុត្រនៅទីនោះ។ មកដល់ដើមពោធិព្រឹក្សនោះ ព្រះនាងទ្រង់ឃើញ យល់ព្រះសម្មាសម្ពុទ្ធ ហើយត្រេកអរប្រកបដោយសទ្ធាជ្រះថ្លាជាក្រៃពេក ទើបថ្វាយមធុបាយាស[34]ទ្រដោយភាជន៍មាសដល់ព្រះសម្មាសម្ពុទ្ធ។ នាគរាជដែលកំពុងដេកលក់អស់កាលដ៏យូរ បានភ្ញាក់ឡើងហើយប្រកាសថា មានព្រះពុទ្ធត្រាស់ដឹងមួយអង្គទៀតហើយ!។ ព្រះសមណគោតម បានត្រាស់ជាព្រះពុទ្ធ នៅថ្ងៃពុធ ១៥ កើត ពេញបូណ៌មី ខែពិសាខ ឆ្នាំរកា ក្នុងព្រះជន្ម ៣៥វស្សា ។ ខណៈនេះ សមណគោតមមានឈ្មោះ (ទ្រង់ព្រះនាម) ថា ព្រះពុទ្ធ[35]។

## ៨. បឋមទេសនា ប្រោសបញ្ចវគ្គិយភិក្ខុ

ដោយបានដឹងច្បាស់អំពីការត្រាស់ដឹងរបស់ព្រះពុទ្ធសមណគោតម សហម្បតីព្រហ្ម ជាឥសីលោកា ក៏បានចូលគាល់ ឱនសិរសា លើកដៃបង្គំអារាធនាព្រះអង្គទេសនាប្រោសជនទូទៅតាមឧបនិស្ស័យ។ ព្រះពុទ្ធក៏ទ្រង់អនុកូល[36] យល់ព្រមទទួលសំដែងនូវធម៌ទេសនា ជាបវេណីរហូតមក។

ដំបូងបំផុត ព្រះពុទ្ធទ្រង់និមន្តទៅកាន់ក្រុងពារាណសី ចូលទៅព្រៃឥសិបតនមិគទាយវ័នជាទីស្នាក់អាស្រ័យនៃបញ្ចវគិយ៍ភិក្ខុ[37]។ ភិក្ខុទាំង

---

៣.វិញ្ញាណជាបច្ច័យឲ្យកើតនាមរូប ៤.នាមរូបជាបច្ច័យឲ្យកើតអាយតនៈ ៥.អាយតនៈជាបច្ច័យឲ្យកើតផស្សៈ ៦.ផស្សៈជាបច្ច័យឲ្យកើតវេទនា, ៧.វេទនាជាបច្ច័យឲ្យកើតតណ្ហា ៨.តណ្ហាជាបច្ច័យឲ្យកើតឧបាទាន, ៩.ឧបាទានជាបច្ច័យឲ្យកើតភព ១០.ភពជាបច្ច័យឲ្យកើតជាតិ, ១១.ជាតិជាបច្ច័យឲ្យកើតមាន ១២.ជរា មរណៈ សោក ទុក្ខទោមនស្ស សេចក្ដីចង្អៀតចង្អល់ចិត្តជាច្រើនអនេក ។

[34] មធុបាយាស (ន.) បាយាសលាយទឹកឃ្មុំផ្សំផង។ បាយាស អានថា បាយ៉ាស ( ន. ) (បាយស ឬ បាយាស) ឈ្មោះបាយចម្អិនលាយនឹងទឹកដោះគោ ព្រមទាំងគ្រឿងផ្សំមានតម្លៃផ្សេងៗ; មាន២យ៉ាងគឺ សោទកបាយាស បាយាសមានទឹក (បាយាសទឹក), និរុទកបាយាស បាយាសឥតទឹក (បាយាសគោក) ប្រើនៅប្រទេសឥណ្ឌាសម័យបុរាណ។ មធុ មៈធុ បា. ( ន. ) ទឹកឃ្មុំ, ទឹកផ្អែម ។

[35] ពុទ្ធបរិស័ទ ហៅព្រះអង្គថា ព្រះពុទ្ធ, ព្រះពុទ្ធសមណគោតម, ព្រះសម្មាសម្ពុទ្ធ, ព្រះពុទ្ធជាបរមគ្រូ, ព្រះពុទ្ធជាម្ចាស់, ព្រះសាស្ដាចារ្យ ព្រះសព្វញ្ញុពុទ្ធ ។ល។ ពាក្យថា ពុទ្ធ សំដៅ អ្នកភ្ញាក់រឭក គឺមានសតិសម្បជញ្ញៈសព្វកាល និង អ្នកត្រាស់ដឹងធម៌ដែលកំបាំង គឺអរិយសច្ច៤ ។ ពុទ្ធសាសនិកយល់ថា នៅក្នុងភទ្ទកប្ប (កប្បចម្រើនរុងរឿង) នេះមានព្រះពុទ្ធ៥ អង្គត្រាស់ដឹង។ ព្រះពុទ្ធ៤អង្គដែលត្រាស់ដឹងហើយគឺ កុកសន្ធោ កោនាគមនោ កស្សបោ សមណៈគោតម ។ មិនទាន់ត្រាស់ដឹងគឺ ១អង្គគឺ ព្រះសិអារ្យមេត្រី (អរិយមេត្តេយ្យ) ដែលនឹងត្រាស់ដឹងនាអនាគតកាល ។

[36] អនុកូល (ន.)សេចក្ដីទំនុកបម្រុង, អនុគ្រោះ; ករុណា; សេចក្ដីពេញចិត្ត; ការបណ្ដោយតាម, ការព្រមតាម ។

[37] បញ្ចវគ្គិយភិក្ខុ គឺជាភិក្ខុ ៥ រូបដែលបានចេញសាងផ្នួសតាមរក្សា ហើយបន្ទាប់មកបោះបង់ព្រះសមណគោតម។ ភិក្ខុទាំង៥ (ឬបញ្ចវគ្គិយា) គឺ១.កោណ្ឌញ្ញ ឬអញ្ញកោណ្ឌញ្ញៈ, ២.ភទ្ទិយៈ, ៣.វប្បៈ, ៤.អស្សជិ និង ៥.មហានាម ។

៥ អង្គដែលធ្លាប់ចាកចោលព្រះអង្គក្រោយពេល ព្រះអង្គបញ្ចប់ទុក្ករកិរិយានោះ ពុំនឹកស្មានថា ព្រះសមណគោតម បានត្រាស់ជាព្រះពុទ្ធឡើយ បន្ទាប់ពីដឹងថាព្រះអង្គបានត្រាស់ដឹងហើយ ទាំងប្រាំអង្គក៏ក្រាបបង្គំនិមន្តព្រះពុទ្ធដោយជ្រះថ្លាក្រៃលែង។ ព្រះអង្គទ្រង់ទេសនាដំបូង ដើម្បីសន្តោសប្រោសដល់បញ្ចវគ្គីយ៍ ហើយភិក្ខុទាំង៥អង្គក៏បានសម្រេចជា សោតាបន្ន[38] ទាំងអស់ ដែលរាប់ថាជាអរិយបុគ្គលក្នុងគ្រានោះឯង។ បឋមទេសនានេះ ព្រះអង្គសម្ដែងអំពី ធម្មចក្កប្បវត្តនសូត្រ[39]

បន្ទាប់មកមានមនុស្សជាច្រើនបានចូលទៅបួសរៀន ក្នុងសំណាក់ព្រះអង្គ ហើយអ្នកទាំងនោះបានសម្រេចមគ្គផល ទៅតាមឧបនិស្ស័យ[40] តាមការគួរៀងៗខ្លួន។ បន្ទាប់មក ព្រះអង្គទ្រង់យាងទៅកាន់ក្រុងកបិលពស្តុ ចូលទៅកាន់សំណាក់ព្រះបាទសុទ្ធោទនបិតា និងព្រះនាងពិម្ពាជាព្រះជយា ។ ព្រះនាងពិម្ពាទ្រង់បង្គាប់ឲ្យរាហុលជាបុត្រា ចូលទៅសុំចែកទ្រព្យសម្បត្តិពីព្រះពុទ្ធជាបិតា ព្រះពុទ្ធក៏ទ្រង់បំបួស រាហុល ជាសាមណេរនៅពេលនោះឯង។

## ៩. ពុទ្ធកិច្ច

ចាប់ពីថ្ងៃបានត្រាស់ដឹងមក ព្រះសម្មាសម្ពុទ្ធទ្រង់បំពេញពុទ្ធកិច្ច ៥ប្រការជានិច្ចអស់រយៈពេល ៤៥វស្សាគឺ៖

១.នៅពេលព្រលឹម ទ្រង់និមន្តបិណ្ឌបាត
២.នៅពេលរសៀលទ្រង់សំដែងធម៌ទេសនា ប្រោសដល់សាធារណជន
៣.នៅពេលព្រលប់ទ្រង់ប្រទានឱវាទដល់ភិក្ខុសង្ឃទាំងឡាយ
៤.នៅពេលកណ្ដាលអធ្រាត ទ្រង់ដោះស្រាយប្រស្នាទេវតាទាំងឡាយ
៥.នៅពេលជិតភ្លឺ ទ្រង់ប្រមើលមើលសត្វដែលមាននិស្ស័យ និងឥតនិស្ស័យ។

---

[38] សោតាបន្ន គឺជាបុគ្គលដែលបានបើកភ្នែកព្រះធម៌ (ធម្មចក្ខុ) អាចក្ដាប់យកការយល់ត្រូវ(សម្មាទិដ្ឋិ ) បានលះដាច់នូវការប្រកាន់ថាបញ្ចក្ខន្ធជារបស់ផងខ្លួន(លះដាច់សកាយទិដ្ឋិ)។ ហើយនិងមានសទ្ធាពេញក្នុងត្រៃរតនៈ។ បុគ្គលនេះមិនយកកំណើតក្នុងភពជាតិរច្ឆាន ប្រេត នរកឡើយ ។

[39] ធម្មចក្កប្បវត្តនសូត្រ សំដែងអំពីការវៀរអន្តធម៌ពីរ ១, វៀរជំពាក់កាម ២.វៀរការធ្វើសេចក្ដីលំបាកដល់ខ្លួន, មកប្រតិបត្តិជាកណ្ដាល(អដ្ឋង្គិកមគ្គ)ដែលជាមាគ៌ាត្រាស់ដឹង ហើយជាសេចក្ដីប្រតិបត្តិធ្វើឲ្យកើតបញ្ញាចក្ខុ(ការឃើញដោយប្រាជ្ញា) ដើម្បីសេចក្ដីស្ងប់រម្ងាប់ រំលត់ទុក្ខ ។

[40] ឧបនិស្ស័យ អ៊ុប៉ៈនិស-សៃ ( ន.)(ឧបនិស្សយ) កុសលធម៌ដែលដេកឬអាស្រ័យនៅក្នុងខន្ធសន្តាន គឺកុសលដែលបានកសាងសន្សំអប់រំទុកមក។ ឧបនិស្ស័យមាន៣យ៉ាង គឺ៖១.ទានូបនិស្ស័យ សំណាងដែលបានសាងទុកមកដោយការបរិច្ចាគទ្រព្យធ្វើទាន; ២-សីលូបនិស្ស័យ សំណាងដែលបានសាងទុកមកដោយការរក្សាសីល ៣.ភាវនូបនិស្ស័យ សំណាងដែលបានសាងទុកមកដោយភាវនា ។

## ១០. ការប្រកាសដាក់អាយុសង្ខារ

ថ្វីត្បិតព្រះអង្គមានទុក្ខវេទនាផ្លូវកាយ ដោយសារតែព្រះអង្គស្ថិតនៅក្នុងស្ថានភាពជរា (ចាស់) ប្រឈួនព្រះកាយ[41] ពិសេសទ្រង់ប្រឈួនព្រះអង្គៈ(ឈឺចង្កេះ) ជាខ្លាំងយ៉ាងណាក៏ដោយ ក៏ព្រះហឫទ័យ(ចិត្ត) មិនមានទោមនស្សឡើយ ព្រោះមគ្គផលនិព្វាន[42]។ ព្រះអង្គមមិនមានការតក់ស្លុតចំពោះសេចក្តីស្លាប់ដែលស្ថិតនៅចំពោះមុខឡើយ។ មារបាននិមន្តព្រះអង្គបង្ខំឲ្យចូលបរិនិព្វាន[43]។

ព្រះពុទ្ធសមណគោតមអាចកំណត់ដឹងជាមុននូវពេលវេលាដែលត្រូវរំលត់ខន្ធ គឺចូលនិព្វាន។ ខណៈពេលមានព្រះជន្ម(ជីវិតរស់នៅ) ព្រះអង្គ យល់ច្បាស់ប្រាកដអំពីសច្ចធម៌ គឺមានសម្មាទិដ្ឋិអំពីបញ្ចខន្ធ ហើយ ព្រះហឫទ័យ គឺចិត្តមិនជាប់ជំពាក់ជាមួយនឹងខន្ធ៥ គឺរូបក្ខន្ធ, វេទនាខន្ធ, សញ្ញាខន្ធ, សង្ខារក្ខន្ធ, វិញ្ញាណក្ខន្ធទាំងនេះឡើយ ដូច្នេះមិនមានអ្វីជាបច្ច័យដើម្បីតាក់តែងបង្កើតឲ្យមានសង្ខារ[44]ជាថ្មីឡើយ។

ខណៈពេលចេញវស្សាទី៤៥ ក្នុងព្រះជន្មាយុ៨០ព្រះវស្សា នាថ្ងៃ១៥កើតពេញបូណ៌មី ខែមាឃ ឆ្នាំម្សាញ់ ព្រះពុទ្ធទ្រង់ប្រកាសអំពីការដាក់អាយុសង្ខារ ដោយប្រាប់មារថា ព្រះអង្គនឹងចូលបរិនិព្វាន ក្នុងរយពេល៣ខែទៀត។

ភិក្ខុសង្ឃទាំងឡាយជាសាវក ជាពិសេស គឺព្រះអានន្ទ ដែលជាអ្នកបំរើព្រះអង្គផ្ទាល់កាលបើដឹងថា ព្រះពុទ្ធបានកំណត់អាយុសង្ខារបែបនេះ ក៏មានការសោកស្តាយយ៉ាងខ្លាំង ព្រោះមិនទាន់ចង់ឲ្យព្រះអង្គចូលបរិនិព្វានឡើយ។

## ១១. ការបរិនិព្វាន

ក្រោយពីការកំណត់ពេលដាក់ព្រះជន្មរួចហើយ ព្រះអង្គទ្រង់និមន្តទៅបិណ្ឌបាតនៅគ្រប់ទិសទី។ ទីចុងក្រោយ ព្រះអង្គទ្រង់យាងទៅដល់នគរកុសិនារា ព្រះអង្គទ្រង់ប្រឈួនព្រះសិរ (ឈឺក្បាល)យ៉ាងខ្លាំង។ ទ្រង់យាងចូលទៅដល់ ព្រៃ

[41] កាយ បា.(ន.) រូបដែលជាទីប្រជុំអាការ ៣២ មាន សក់ , រោម, ក្រចក, ធ្មេញ, ស្បែក, សាច់, សរសៃ, ឆ្អឹង, ខួរក្នុងឆ្អឹង, តម្រងនោម, បេះដូង, ថ្លើម, វាវ, ក្រពះ, សួត, ពោះវៀនធំ, ពោះវៀនតូច, អាហារថ្មី, អាហារចាស់, ប្រមាត់, ស្លេស្ម, ខ្ទុះ, ឈាម, ញើស, ខ្លាញ់ខាប់, ទឹកភ្នែក, ខ្លាញ់រាវ, ទឹកមាត់, ទឹកសម្បោរ, ទឹករំអិល, ទឹកមូត្រ, ខួរក្នុងក្បាល ។

[42] និព្វាន និប-ពាន (ន.) ធម្មជាតិឬចិត្តដែលចេញផុតស្រឡះចាកពី វានៈ គឺឥតមានតណ្ហាដែលចាក់ស្រេះទាក់ទាក់រូបរឹត។

[43] បរិនិព្វាន ប៉ៈ-រ៉ុ-និប-ពាន (ន.) ដំណើរចេញផុតពីវដ្តសង្សារនៃការកើតស្លាប់ ។

[44] សង្ខារ សង់-ខា (ន.) (សំស្ការ) គ្រឿងប្រកបតាក់តែងប្រមូលផ្សំផ្គុំបង្កើតជាសព៌ាង្គកាយ ជីវិត គំនិត និង អ្វីៗទាំងពួងក្នុងលោក ។

សាលវន្ត ហើយទ្រង់ត្រាស់ឲ្យអានន្ទរៀបកន្ទេង ថ្វាយព្រះអង្គផ្ទុំ ព្រះអង្គទ្រង់ផ្ទុំផ្អៀងទៅខាងស្តាំ ។ ពេលបច្ចិមរាត្រី ព្រះអង្គទ្រង់ត្រាស់ប្រាប់ដល់ភិក្ខុទាំងឡាយថា «អ្វីៗដែលកើតមានហើយ ផ្តុំឡើងហើយ តែងមានសភាវធម៌ និងរលត់ទៅវិញជាធម្មតា អ្នកទាំងឡាយចូរញ៉ាំងប្រយោជន៍ឲ្យសំរេចដោយកិរិយាមិនប្រមាថចុះ»។ ព្រះពុទ្ធទ្រង់មានពុទ្ធដិកានេះហើយ ព្រះអង្គក៏ទ្រង់រលត់ខន្ធ[45]ក្នុងពេលនោះទៅ។

ព្រះពុទ្ធចូលបរិនិព្វាននៅ ថ្ងៃអង្គារ ១៥ កើតពេញបូណ៌មី ខែពិសាខ ឆ្នាំម្សាញ់ ៥៤៣ មុនគ.ស. ក្នុងព្រះជន្ម ៨០ឆ្នាំ។

## សេចក្តីសន្និដ្ឋាន

ព្រះពុទ្ធសមណគោតម ជាមនុស្សពិត មិនមែនជាព្រះអាទិទេពឡើយ។ ព្រះអង្គមិនព្រមទទួលការសោយរាជ្យសម្បត្តិ បែរមកជ្រើសរើសការស្វែងរកការត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណវិញ។ ទស្សនៈ(ធម៌ឬពុទ្ធិ)ដែលព្រះអង្គបានសំដែងធម្មទេសនាចែករំលែកនៅសម័យកាលព្រះអង្គ មានសារៈសំខាន់យ៉ាងក្រៃលែងសម្រាប់កែប្រែទស្សនៈខុសឆ្គង(មិច្ឆាទិដ្ឋិ) ស្តីអំពីវាលវដ្តសង្សារនៃការកើតស្លាប់នៃជីវិតសត្វលោក។ ទស្សនៈស្តីអំពីការកើតស្លាប់នៃជីវិតដែលព្រះពុទ្ធសមណគោតមបានត្រាស់ទេសនាអាចជួយមនុស្សគ្រប់វ័យ គ្រប់ជំនាន់ ឲ្យត្រិះរិះដើម្បីបានស្គាល់ជីវិតរបស់ខ្លួន និងការរៀបចំការរស់នៅឲ្យទទួលបានសេចក្តីសុខចម្រើន តាមឧបនិស្ស័យរៀងៗខ្លួន។

ការស្វែងយល់ដឹងទស្សនស្តីពីជីវិត និងប្រតិបត្តិតាមឱវាទរបស់ព្រះពុទ្ធសមណគោតមមានប្រយោជន៍បំផុតសម្រាប់សេចក្តីសុខចម្រើនក្នុងការរស់នៅរបស់មនុស្សជាតិទូទៅដោយគ្មានប្រកាន់ជាតិសាសន៍ ព៌ណសម្បុរ វណ្ណៈ ឋានៈ តួនាទី ភេទ ឬអ្វីឡើយ ព្រោះជាសច្ចធម៌ឬទ្រឹស្តីសាកល។

ពុទ្ធបរិស័ទដែលគោរពបូជាចំពោះព្រះពុទ្ធ មិនបួងសួងសុំអ្វីពីព្រះអង្គឡើយ ព្រោះព្រះអង្គបានបរិនិព្វាន រំលតខន្ធអស់ហើយ គ្មានអ្វីនៅសេសសល់ក្រៅពីព្រះធម៌ឡើយ។ ដូច្នេះមនុស្សជាតិត្រូវពិភាក្សាស្វែងយល់ និងប្រតិបត្តិធម៌ដោយខ្លួនឯង (អត្តាហិ អត្តនោនាថោ) តាមពុទ្ធោវាទ ជាព្រះធម៌ដែលព្រះអង្គបានត្រាស់ដឹង។

45 រលត់ខន្ធ គឺរលាយអស់ខន្ធមិនកើតទៀត (បរិនិព្វាន )

**ឯកសារយោង/គន្ថនិទ្ទេស**


១-កម្ពុជសុរិយា, *ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ*, ចេញរាល់ខែ ពីពុទ្ធសាសនបណ្ឌិត្យ ឆ្នាំទី ៣៧ លេខ១ ខែមករា ព. ស. ២៥០៧ គ. ស. ១៩៦៥

២- គណកម្មការធម្មវិន័យ, *ពុទ្ធប្បវត្តិ,(ទូរេនិទាន ភាគ១)សម្រាប់សាលាធម្មវិន័យថ្នាក់ត្រី*, បោះពុម្ពលើកទី៦ ព.ស ២៤៩៤ គ.ស ១៩៥១

៣-ជួន ណាត : *វចនានុក្រមខ្មែរ* ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ បោះពុម្ពលើកទី៥ ឆ្នាំ១៩៦៧

៤-ស្រុង ចាន់ណា, *គេហទំព័រ៥០០០ឆ្នាំ* (https://5000-years.org/kh/)

៥-សុន្ទរ សាមៀន(ភិក្ខុ ឥន្ទ្រិយសំវរោ), *អដ្ឋកថាព្រះអភិធម្មបិដក (ធម្មសង្គណី អដ្ឋសាលិនី)* ភាគ១ លេខ១,ការផ្សាយរបស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ពស.២៥៤៦ គស២០០២

៦- https://km.wikipedia.org/wiki/ព្រះពុទ្ធសាសនា

# ការអនុវត្តកិច្ចសន្យាពាណិជ្ជកម្មអន្តរជាតិ

ដោយៈ **បណ្ឌិត មិន ប្រុសបញ្ញារិទ្ធិ**

មន្ត្រីនាយកដ្ឋាននីតិសាស្ត្រ

នៃវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម

E-mail: prosepanharithmin@gmail.com

## សេចក្ដីផ្ដើម

ច្បាប់កិច្ចសន្យាត្រូវបានគេយកទៅអនុវត្តនៅគ្រប់ក្របខណ្ឌអភិវឌ្ឍន៍សហគ្រាសធុនតូច និង មធ្យមក្រុមហ៊ុនរូបវន្តបុគ្គល និង ក្រុមហ៊ុននីតិបុគ្គលជាតិ និង អន្តរជាតិ។ ដើម្បីដំណើរការប្រព្រឹត្តទៅបានល្អ កាត់បន្ថយនូវជម្លោះដែលអាចកើតឡើងជាយថាហេតុ។ ច្បាប់មានតួនាទីយ៉ាងសំខាន់ក្នុងការសម្របសម្រួល ដោះស្រាយ កាត់សេចក្ដី បញ្ចៀសជម្លោះ ក្នុងគោលបំណងបើកផ្លូវឆ្ពោះទៅរក កំណាប់ទ្រព្យនៃការធ្វើពាណិជ្ជកម្ម ទាំងក្របខណ្ឌជាតិ និង អន្តរជាតិ។ ក្នុងទិសដៅបង្ហាញដល់អ្នកអានអ្នកសិក្សាស្រាវ ឱ្យផ្ដោតការយកចិត្តទុកដាក់លើការធ្វើពាណិជ្ជកម្មអន្តរជាតិជាមុនសិនតាមរយៈការអនុវត្តច្បាប់ កិច្ចសន្យាពាណិជ្ជកម្មអន្តរជាតិ។

ផែនការយុទ្ធសាស្ត្រ អភិវឌ្ឍន៍ជាតិ ២០១៩- ២០២៣ មានខ្លឹមសារស្នូលសំខាន់ ***ដើម្បីកំណើន បង្កើតការងារ ជានាសមធម៌*** និង ***ប្រសិទ្ធភាព*** ឆ្ពោះទៅប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០នោះប្រទេសកម្ពុជាយើងបាន និង កំពុងខិតខំពង្រឹងនិងពង្រីកលើគ្រប់វិស័យ ក្នុងនោះ វិស័យច្បាប់ក៏ដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញការរីកលូតលាស់ ផ្នែកសេដ្ឋកិច្ចជាពិសេសការធ្វើពាណិជ្ជកម្មអន្តរជាតិ។ តើការអនុវត្តច្បាប់ពាណិជ្ជកម្មអន្តរជាតិ មានដំណើរប្រព្រឹត្តទៅយ៉ាងដូចម្ដេច?

## ១-ការធ្វើពាណិជ្ជកម្មអន្តរជាតិ

***ច្បាប់អន្តរជាតិ*** ជាទូទៅគ្រប់គ្រងវិធីដែលរដ្ឋ និង អន្តរជាតិ បុគ្គលដទៃទៀតប្រព្រឹត្តចំពោះគ្នាទៅវិញទៅមក។ ចូរចងចាំថា***សន្ធិសញ្ញា***ត្រូវបានធ្វើឡើងរវាងរដ្ឋនិងរដ្ឋ រវាងអង្គការអន្តរជាតិនានា ឬ រវាងរដ្ឋនិងអង្គការអន្តរជាតិ។ ក៏ប៉ុន្តែតើច្បាប់អ្វីដែលគ្រប់គ្រងវិធីដែលអង្គភាពពាណិជ្ជកម្ម និងបុគ្គលបរទេសធ្វើអាជីវកម្មជាមួយគ្នា? អង្គភាពពាណិជ្ជកម្ម និង បុគ្គលឯកជនមិនអាចចុះសន្ធិសញ្ញាបានទេ។

នៅពេលដែល**សាជីវកម្ម** និង បុគ្គលចង់ធ្វើអាជីវកម្មនៅក្នុងប្រជាជាតិដទៃទៀត ជាញឹកញាប់ ពួកគេធ្វើកិច្ចសន្យាពាណិជ្ជកម្ម។ ប្រភេទចម្បងនៃសកម្មភាពពាណិជ្ជកម្មអន្តរជាតិ ដែលកិច្ចសន្យាអាចកើតឡើងរួមមាន៖ (ក) ការលក់ដែលអាចទាក់ទិនទៅ នឹងកិច្ចសន្យាលក់ទំនិញ ឬ ផ្តល់សេវាកម្ម (ខ)កិច្ចសន្យាផ្តល់អាជ្ញាបណ្ណ៖ កិច្ចសន្យាដែលជាមូលដ្ឋាន ទាក់ទិនទៅនឹងកិច្ចសន្យាដែលភាគីមួយបានអនុញ្ញាតឱ្យភាគីមួយទៀត នូវសិទ្ធិផលិត ប្រើប្រាស់ ឬ លក់ផលិតផល ក្រោមលក្ខខណ្ឌជាក់លាក់ណាមួយ និង (គ)សកម្មភាពវិនិយោគ៖ សកម្មភាពដែលអាចទាក់ទិនទៅនឹងការបង្កើត និង ប្រតិបត្តិការនៃក្រុមហ៊ុនចម្រុះ ឬ សាខានៃក្រុមហ៊ុនបរទេស ឬ បុគ្គលសម្ព័ន្ធនៃក្រុមហ៊ុនមួយ។ តើនៅពេលណា ដែលកិច្ចសន្យាពាណិជ្ជកម្ម មួយក្លាយទៅជា កិច្ចសន្យាពាណិជ្ជកម្មអន្តរជាតិ?

## ២-កិច្ចសន្យាពាណិជ្ជកម្មអន្តរជាតិ

ចំណុចទីមួយ ដែលត្រូវបញ្ជាក់ឱ្យច្បាស់ថា តើកិច្ចសន្យារវាងភាគីចំនួនពីរ ពិតជាកិច្ចសន្យាអន្តរជាតិ ឬ យ៉ាងណា? ជាមូលដ្ឋាន ប្រសិនបើភាគីទាំងពីរមានកន្លែងអាជីវកម្មពាក់ព័ន្ធនៅក្នុង ប្រទេសតែមួយ ពេលនោះជាទូទៅ កិច្ចសន្យាគឺត្រូវគ្រប់គ្រងដោយប្រទេសនោះ ។ ម្យ៉ាងទៀតជម្លោះគឺត្រូវបានដោះស្រាយនៅតុលាការ ឬ នៅ**សាលាមជ្ឈត្តវិនិច្ឆ័យ**[1] នៃប្រទេសនោះ។ ប៉ុន្តែនៅពេលដែលភាគីទាំងពីរនៃកិច្ចសន្យា មានកន្លែងអាជីវកម្មពាក់ព័ន្ធនៅក្នុងប្រទេសផ្សេងគ្នាពេលនោះ កិច្ចសន្យារបស់ពួកគេមានលក្ខណៈជាអន្តរជាតិ ។ ដូច្នេះ វិធានច្បាប់អន្តរជាតិ នឹងអនុវត្តចំពោះកិច្ចសន្យានោះ។ កាលបើភាគីមួយមានកន្លែងអាជីវកម្មច្រើនជាងមួយ ជាទូទៅកន្លែងអាជីវកម្មដែលពាក់ព័ន្ធ គឺកន្លែងណាមួយដែលជាប់ទាក់ទងជិតបំផុតទៅនឹងកិច្ចសន្យា និង ការបំពេញ**កាតព្វកិច្ច**[2]នៃកិច្ចសន្យានោះ។ ចូរពិចារណាអំពីករណីរបស់ លោក ជ័យ ដែលជាអ្នកផលិតសម្រេចនៅប៉ោយប៉ែត។ ជ័យ លក់ផលិតផលម្រេចរបស់ខ្លួនឱ្យទៅក្រុមហ៊ុន Pennsylvania Pepper Company ដែលជាក្រុមហ៊ុនអាម៉េរិកាំងដែលមានទីស្នាក់ការនៅប៉ោយប៉ែត។ អ្នកតំណាងក្រុមហ៊ុន Pennsylvania Pepper Company ដែលស្ថិតនៅឯប៉ោយប៉ែត ចុះហត្ថលេខាលើកិច្ចសន្យាលក់មួយជាមួយ ជ័យ។ កិច្ចសន្យានោះដែលព្រាងដោយការិយាល័យច្បាប់មួយនៅប្រទេសថៃតម្រូវឱ្យ ជ័យ ប្រគល់

[1] សាលាមជ្ឈត្តវិនិច្ឆ័យ មានន័យថាសាលាជំនុំជម្រះក្តីដោយប្រើវិធីដោះស្រាយវិវាទដោយមជ្ឈត្តករ ហើយសេចក្តីសម្រេចរបស់មជ្ឈត្តករចងភាគីឱ្យអនុវត្តតាម។

[2] កាតព្វកិច្ច មានន័យថាចំណងតាមផ្លូវច្បាប់ដែលចងបុគ្គលពីរនាក់ ដោយឱ្យបុគ្គលម្នាក់ដែលបានកំណត់ហៅថា កូនបំណុលមានករណីយកិច្ចមួយចំនួនចំពោះបុគ្គលម្នាក់ទៀត ដែលបានកំណត់ហៅថា ម្ចាស់បំណុល។

ម្រេចដោយផ្ទាល់ទៅរថយន្តដឹកទំនិញ ដែលមកពីក្រុមហ៊ុនរបស់ថៃនៅឯចំការរបស់ ជ័យ ដែលស្ថិតនៅប្រទេសកម្ពុជា ហើយតម្រូវឱ្យក្រុមហ៊ុន Pennsylvania Pepper Company បង់ប្រាក់ឱ្យ ជ័យ នៅពេលប្រគល់ម្រេច។

ទាំង ជ័យ និង ក្រុមហ៊ុន Pennsylvania Pepper Company ចង់ដឹងថាតើច្បាប់របស់ប្រទេសណាដែលអនុវត្តលើកិច្ចសន្យានេះ គឺថាតើជាច្បាប់ប្រទេសកម្ពុជា ជាច្បាប់សហរដ្ឋអាម៉េរិក ឬក៏ជាច្បាប់ប្រទេស។ តើអស់លោកគិតថាជាច្បាប់របស់ប្រទេសណា ដែលអនុវត្តលើកិច្ចសន្យានេះ? ដោយហេតុថាភាគីទាំងពីរមានកន្លែងអាជីវកម្មពាក់ព័ន្ធនៅក្នុងប្រទេសកម្ពុជា។ កន្លែងអាជីវកម្ម ដែលពាក់ព័ន្ធជាងគេបំផុតទៅនឹងកិច្ចសន្យា និង ការបំពេញកាតព្វកិច្ចនៃកិច្ចសន្យា នោះច្បាប់ប្រទេស កម្ពុជានឹងអនុវត្តចំពោះកិច្ចសន្យានេះ។ និយាយយ៉ាងងាយគេមើលទៅហាក់ដូចជា ថាកិច្ចសន្យានេះ ត្រូវធ្វើឡើងដោយភាគីកម្ពុជាចំនួនពីរនាក់អញ្ចឹងដែរ។ ហើយជម្លោះណាមួយដែលកើតចេញពីកិច្ចសន្យានេះប្រហែលជាត្រូវដោះស្រាយនៅក្នុងប្រទេសកម្ពុជា លើកលែងតែភាគីមានការព្រមព្រៀង គ្នាមួយផ្សេងពីនេះទៀត។ ក៏ប៉ុន្តែចម្លើយនេះនឹងផ្សេងពីនេះដែរឬទេ? ប្រសិនបើអ្នកទិញដែលជាជនជាតិអាម៉េរិក នោះគ្រាន់តែផ្ញើលិខិតបញ្ជាទិញមកពីសហរដ្ឋអាមេរិក មកកាន់ទីភ្នាក់ងារថៃមួយ ហើយទីភ្នាក់ងារនោះបន្ទាប់មក ក៏ ទូរសព្ទមកលោក ជ័យ ហើយសុំឱ្យជ័យ ចាត់ចែងប្រគល់ម្រេចដោយខ្លួនឯងនៅអារញ្ញប្រទេសថៃ។ នៅក្នុងឧទាហរណ៍ថ្មីនេះ**សំណើ**[3]គឺ ធ្វើឡើងនៅក្នុងប្រទេសថៃ ការធ្វើ**ស្វីការ**[4]សំណើកើតឡើងនៅក្នុងប្រទេសកម្ពុជា ហើយការប្រគល់ទំនិញគឺត្រូវធ្វើឡើង ដោយឆ្លងកាត់ព្រំដែន នៃប្រទេសទាំងពីរ។ ថ្វីបើក្រុមហ៊ុនអាម៉េរិកមានទីស្នាក់ការនៅប៉ោយប៉ែតក៏ដោយក៏ទីស្នាក់ការនេះហាក់ដូចជា មិនមានការពាក់ព័ន្ធណាមួយឡើយនៅក្នុងកិច្ចសន្យា។ បើមានជម្លោះកើតឡើង តើច្បាប់របស់ប្រទេសណាដែលនឹងត្រូវអនុវត្តលើកិច្ចសន្យានេះ? ហើយតើនៅទីណាដែលជម្លោះត្រូវបានដោះស្រាយ? នៅក្នុងស្ថានភាពនេះចម្លើយ ហាក់ដូចជាមិនសូវច្បាស់លាស់សោះ។

ការសំខាន់ត្រូវដឹងថា ច្បាប់ណាត្រូវអនុវត្ត ពីព្រោះរឿងនេះអាចប៉ះពាល់ដល់សិទ្ធិនិងកាតព្វកិច្ចរបស់ភាគីនៃកិច្ចព្រមព្រៀង។

---

[3] សំណើមានន័យថាការសុំបង្កើតកិច្ចសន្យាដែលធ្វើឡើងដោយមានឆន្ទៈភ្ជាប់ខ្លួនជាមួយនឹងចំណងគតិយុត្តក្នុងករណី ដែលមានស្វីការរបស់ភាគីម្ខាងទៀតចំពោះសំណើនេះ។ និយាយយ៉ាងខ្លីគឺជាការស្នើបង្កើតកិច្ចសន្យា។ អ្នកស្នើហៅ (Offeror) ឯអ្នកទទួលសំណើហៅថា (Offeree)។

[4] ស្វីការមានន័យថាការសំដែងឆន្ទៈដែលបុគ្គលម្នាក់បានបញ្ចេញការយល់ព្រមរបស់ខ្លួនចំពោះសំណើដែលបុគ្គលដទៃ បានស្នើមកខ្លួនដើម្បីបង្កើតកិច្ចសន្យា។

ឧទាហរណ៍នៅក្នុង**យុត្តាធិការ**ជាច្រើនដែលប្រើច្បាប់ Common Law ជាទូទៅធ្វើការស្នើការសំណើមានអានុភាព នៅពេលដែលស្នើការនោះ ត្រូវបានផ្ញើយ៉ាងត្រឹមត្រូវដោយភាគីដែលធ្វើស្នើការសំណើ។ក៏ប៉ុន្តែនៅក្នុងយុត្តាធិការជាច្រើនដែលប្រើប្រព័ន្ធច្បាប់ស៊ីវិល Civil Law ជាទូទៅធ្វើស្នើការសំណើមានអានុភាព នៅពេលដែលភាគីធ្វើសំណើបានទទួលស្នើការសំណើ។ ការខុសគ្នានេះ អាចមិនមែនជារឿងតូចតាចទេ ប្រសិនបើភាគីដែលធ្វើសំណើព្យាយាមដកសំណើនោះវិញ ក្រោយពីភាគីម្ខាងទៀតបានផ្ញើស្នើការសំណើ ក៏ប៉ុន្តែមុនពេលដែលអ្នកធ្វើសំណើបានទទួលស្នើការ សំណើ។

សំណួរសួរថា តើច្បាប់ណាដែលអនុវត្តនោះ អាចធ្វើឱ្យប៉ះពាល់ដល់បញ្ហាសំខាន់ដទៃទៀតផងដែរ ដែលទាក់ទិនទៅនឹងកិច្ចការពាណិជ្ជកម្ម។ ឧទាហរណ៍តើអ្នកណាជាអ្នកទទួលខុសត្រូវបង់ពន្ធដារ នៅពេលដែលទំនិញត្រូវនាំចេញពីប្រទេសកម្ពុជា ឬ នាំចូលទៅក្នុងប្រទេសថៃ? តើអ្នកណាជាអ្នកទទួលខុសត្រូវចំពោះការខូចខាតដល់ទំនិញ ប្រសិនបើរថយន្តដែលដឹកទំនិញនោះធ្លាក់ចុះពីលើស្ពាន ដែលស្ថិតនៅចន្លោះប្រទេសទាំងពីរ ហើយគ្រាប់ម្រេចដែលផ្ទុកនៅក្នុងរថយន្តត្រូវខូចខ្ទេច? ចំពោះសំណួរដែលសួរថាតើត្រូវដោះស្រាយជម្លោះនៅទីណា ក៏រឹតតែសំខាន់ណាស់ដែរ។ភាគីនៃកិច្ចសន្យាមានអារម្មណ៍ថាជម្លោះអំពីកិច្ចសន្យាពាណិជ្ជកម្មអន្តរជាតិ ត្រូវបានដោះស្រាយយ៉ាងប្រសើរបំផុតនៅក្នុងប្រទេសអព្យាក្រឹត ឬ ដោយសាលាមជ្ឈត្តវិនិច្ឆ័យជាជាង ដោះស្រាយដោយប្រទេសសាមីភាគីដែលនៅទីនោះភាគីមួយអាចមានប្រៀបជាងភាគីមួយទៀតនោះ[5]។

## ៣-កិច្ចសន្យាពាណិជ្ជកម្មអន្តរជាតិមួយចំនួន

### ៣.១-កិច្ចសន្យាពាណិជ្ជកម្មទូទៅ

កិច្ចសន្យាអាចខ្លី ឬ វែង អាស្រ័យទៅលើខ ចែងលក្ខខណ្ឌទាំងឡាយដែលកិច្ចសន្យានោះមាន ។ គ្មានច្បាប់ស្តីពីប្រវែងនៃកិច្ចសន្យាឡើយ ប៉ុន្តែវាជាការឆ្លាតវាងវៃ ក្នុងការធ្វើឱ្យកិច្ចសន្យានោះ មានប្រសិទ្ធភាពដោយមិនលុបខ ចែងចាំបាច់ណាមួយឡើយ។ យ៉ាងហោចណាស់កិច្ចសន្យាទាំងឡាយ គួរតែវែងគ្រប់គ្រាន់ល្មម និង ប្រាប់យើងអំពីអ្វីដែលអ្នកត្រូវធ្វើ និង អ្វីដែលមិនត្រូវធ្វើ។ ខាងក្រោមនេះគឺជាចំណុចត្រួតពិនិត្យ នៃប្រការដែលត្រូវតែយកមកពិចារណានៅពេលព្រាងកិច្ចសន្យា[6]៖ **(១)**ធ្វើឱ្យប្រាកដថាភាគីទាំងពីរ ច្បាស់លាស់អំពី ខ ចែងនៃកិច្ចព្រមព្រៀងជាក់ស្តែងទាំង

[5] The Asia Foundation, *INTERNTIONAL CONTRACT LAW*, International Printing House, Phnom Penh, 2001, p.11-12.

[6] -ibid., p. 15.

អស់មុនអ្នកផ្តើមសរសេរកិច្ចសន្យា។ វាជាគំនិតល្អមួយក្នុងការរាយបញ្ជីនូវ ខចែងទាំងឡាយនៅក្នុងទម្រង់ព្រាង ហើយឱ្យភាគីទាំងអស់យល់ព្រមចំពោះ ខចែង ទាំងនោះជាដំបូងសិនមុន នឹងសម្រេចថាតើ ខចែង ទាំងនោះ នឹងត្រូវគេសរសេរបញ្ចូលទៅក្នុងកិច្ចសន្យាតាមរបៀបណា និង នៅកន្លែងណានោះ។ (២) ធ្វើកិច្ចព្រមព្រៀងលើអ្វីដែលនឹងត្រូវកើតឡើង ក្នុងករណីដែលមានការបំពានកិច្ចសន្យាដោយភាគីណាមួយនៃភាគីទាំងអស់នោះ។ (៣) ធ្វើកិច្ចព្រមព្រៀង ថាតើនរណា នឹងត្រូវហៅមកដោះស្រាយរាល់ទំនាស់ពាក់ព័ន្ធជាមួយអត្ថន័យ ខចែង នៃកិច្ចសន្យាទាំងនោះ។ (៤) ចូរពិចារណាអំពីឈ្មោះនៃកិច្ចសន្យា ដែលនឹងពិពណ៌នាឱ្យបានច្បាស់លាស់ អំពីគោលបំណងរបស់កិច្ចសន្យានោះតាមលក្ខណៈងាយៗ។

### ៣.២-កិច្ចសន្យាអាជីវកម្មអន្តរជាតិ

ច្បាប់អន្តរជាតិជាទូទៅ គ្រប់គ្រងវិធីដែលរដ្ឋ និង អន្តរជាតិ បុគ្គលដទៃទៀតប្រព្រឹត្តិចំពោះគ្នាទៅវិញទៅមក។ ចូរចងចាំថាសន្ធិសញ្ញាត្រូវបានធ្វើឡើងរវាងរដ្ឋនិងរដ្ឋ រវាងអង្គការអន្តរជាតិនានា ឬ រវាងរដ្ឋនិងអង្គការអន្តរជាតិ។ ក៏ប៉ុន្តែតើច្បាប់អ្វីដែលគ្រប់គ្រងវិធីអង្គភាពពាណិជ្ជកម្ម និងបុគ្គលបរទេសធ្វើជា ជីវកម្មជាមួយគ្នា? អង្គភាពពាណិជ្ជកម្ម និងបុគ្គលឯកជនមិនអាចចុះសន្ធិសញ្ញាបានទេ។ នៅពេលដែលសាជីវកម្ម និង បុគ្គលចង់ធ្វើជាជីវកម្ម នៅក្នុងប្រជាជាតិដទៃទៀត ជាញឹកញាប់ពួកគេធ្វើកិច្ចសន្យាពាណិជ្ជកម្ម។ ប្រភេទចំបងនៃសកម្មភាពពាណិជ្ជកម្មអន្តរជាតិ ដែលកិច្ចសន្យាអាចកើតមានរួមមាន៖ ការលក់ដែលអាចទាក់ទិនទៅនឹងកិច្ចសន្យាលក់ទំនិញ ឬផ្តល់សេវាកម្ម។

កិច្ចសន្យាផ្តល់សេវាកម្ម កិច្ចសន្យាផ្តល់អាជ្ញាប័ណ្ណ ដែលជាមូលដ្ឋានទាក់ទិនទៅនឹងកិច្ចសន្យា ដែលភាគីមួយបានអនុញ្ញាតឱ្យភាគីមួយទៀត នូវសិទ្ធិផលិតប្រើប្រាស់ ឬ លក់ផលិតផលក្រោមក្របខណ្ឌជាក់លាក់ណាមួយ និង សកម្មភាពវិនិយោគ ដែលអាចទាក់ទិនទៅនឹងការបង្កើត និង ប្រតិបត្តិការនៃក្រុមហ៊ុនចម្រុះ ឬ សាខានៃក្រុមហ៊ុនបរទេស ឬ បុគ្គលសម្ព័ន្ធនៃក្រុមហ៊ុនមួយ។ តើនៅពេលណាដែលកិច្ចសន្យាពាណិជ្ជកម្មមួយក្លាយទៅជាកិច្ចសន្យាពាណិជ្ជកម្មអន្តរជាតិ? តើកិច្ចសន្យារវាងភាគីចំនួនពីរពិតជាកិច្ចសន្យាអន្តរជាតិ ឬយ៉ាងណា? ជាមូលដ្ឋានប្រសិនបើភាគីទាំងពីរមានកន្លែងអាជីវកម្មពាក់ព័ន្ធ នៅក្នុងប្រទេសតែមួយពេលនោះកិច្ចសន្យា គឺ ត្រូវគ្រប់គ្រងដោយច្បាប់របស់ប្រទេសនោះ។

ប៉ុន្តែនៅពេលដែល ភាគីទាំងពីរនៃកិច្ចសន្យា មានកន្លែងអាជីវកម្មពាក់ព័ន្ធនៅក្នុងប្រទេសផ្សេងគ្នា ពេលនោះកិច្ចសន្យារបស់ពួកគេ មានលក្ខណៈជាអន្តរជាតិ ដូច្នេះវិធាន

ច្បាប់អន្តរជាតិនឹងអនុវត្តចំពោះកិច្ចសន្យានោះ។ កាលណាភាគីមួយមានកន្លែងអាជីវកម្មច្រើនជាងមួយ ជាទូទៅកន្លែងអាជីវកម្មដែលពាក់ព័ន្ធ គឺ កន្លែងណាមួយដែលជាប់ទាក់ទងជិតបំផុតទៅនឹងកិច្ចសន្យា និងការបំពេញកាតព្វកិច្ច នៃកិច្ចសន្យានោះ។ ជួនកាលភាគីទាំងសងខាងអាចធ្វើជាកិច្ចព្រមព្រៀង ដើម្បីជំរុញសេវា លក់ទំនិញ។

### ៣.៣-កិច្ចសន្យាទូទាត់ដោះដូរ

កិច្ចព្រមព្រៀងទូទាត់ដោះដូរ កើតឡើងនៅពេលដែលភាគីមួយនៃកិច្ចប្រគល់ទំនិញ សេវាកម្ម បច្ចេកវិទ្យា ឬ ក៏អ្វីដែលមានតម្លៃផ្សេងតទៀត ទៅឱ្យភាគីមួយទៀត ហើយជាថ្នូរ ភាគីមួយទៀតផ្តល់ទំនិញ សេវាកម្ម បច្ចេកវិទ្យា ឬក៏របស់មានតម្លៃទៅឱ្យភាគីទីមួយ។ ប្រទេសជាច្រើននៅតំបន់អាស៊ីភាគអាគ្នេយ៍ អឺរ៉ុបខាងកើត និង អាហ្វ្រិក ជាប្រពៃណីមានការពាក់ព័ន្ធទៅ នឹងកិច្ចព្រមព្រៀងទូទាត់ដោះដូរ។ នៅតំបន់អាស៊ីប្រទេសសឹង្ហបុរីជាមជ្ឈមណ្ឌលពាណិជ្ជកម្ម ទូទាត់ដោះដូរចំបងប្រចាំតំបន់នេះ មានកិច្ចព្រមព្រៀងទូទាត់ដោះដូរប្រភេទខុសគ្នា[7]។ ខាងក្រោមនេះ គឺ ជាការពិភាក្សាសង្ខេបអំពីប្រភេទសំខាន់ៗនៃកិច្ចព្រមព្រៀងទូទាត់ដោះដូរ ។ កិច្ចសន្យាដូរទំនិញនឹងទំនិញ គឺទាក់ទិនទៅនឹងកិច្ចសន្យា ដែលតម្រូវឱ្យភាគីមួយផ្តល់ទំនិញ ឬសេវាកម្មជាថ្នូរទៅនឹងទំនិញនឹងសេវាកម្មពីភាគីម្ខាងទៀត។ ដូចជាកាលបើឈ្មួញម្នាក់នៅកម្ពុជា យល់ព្រមផ្គត់ផ្គង់ខោអាវមួយចំនួន ទៅឱ្យឈ្មួញម្នាក់ទៀតនៅប្រទេសកូរ៉េខាងត្បូង ជាថ្នូរទៅនឹងទោចក្រយានយន្ត មួយចំនួនដល់ឈ្មួញនៅកម្ពុជា។

### ៣.៤-កិច្ចសន្យាទិញទៅវិញទៅមក

កិច្ចសន្យាអាជីវកម្ម ដែលទាក់ទងទៅនឹងការផ្គត់ផ្គង់ទៅវិញទៅមកនូវទំនិញ ឬសេវាកម្មរវាងភាគីទៅតាមកិច្ចសន្យា ពីរដាច់ដោយឡែកពីគ្នា ដែលភ្ជាប់ទំនាក់ទំនងនឹងគ្នាដោយកិច្ចព្រមព្រៀងទីបីមួយទៀត។ អាជីវកម្ម រថយន្តក្រុងបុមបៃ ប្រទេសឥណ្ឌា ព្រមព្រៀងទិញទៅវិញទៅមក នៅក្នុងកិច្ចសន្យាមួយជាមួយ នឹងរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា។ រាជរដ្ឋាភិបាលនៃប្រទេសកម្ពុជាយល់ព្រមទិញរថយន្តក្រុងមួយចំនួន ពីសាជីវកម្មរថយន្តក្រុងនៅបុមបៃ នៅក្នុងកិច្ចសន្យាទីពីរ ឱ្យតែសាជីវកម្មរថយន្តក្រុងនេះ យល់ព្រមទិញទំនិញផ្សេងៗ ដូចជាកៅស៊ូសំបកកង់មួយចំនួន ពីប្រទេសកម្ពុជា នៅក្នុងកិច្ចសន្យាទីបី។ តាមការពិតភាគីទាំងនេះដោះដូរគ្នា រវាងរថយន្តក្រុងជាមួយនឹងកៅស៊ូសំបកកង់។

### ៣.៥-កិច្ចសន្យាទិញមកវិញ

---

7 WTO, ***Opening Markets for Trade in Services,*** At the University Press, Cambridge, 2008, p.61-63.

*កិច្ចព្រមព្រៀង ដែលទាក់ទងទៅនឹងការលក់គ្រឿងបរិក្ខា ឬ បច្ចេកវិទ្យា ពីអ្នកផ្គត់ផ្គង់ម្នាក់ឱ្យទៅប្រទេស ដែលកំពុងអភិវឌ្ឍ ដោយអ្នកផ្គត់ផ្គង់ ទទួលយកការទូទាត់ជាទំនិញដែលផលិតដោយគ្រឿងបរិក្ខា ឬបច្ចេកវិទ្យានោះ។ ឧបមាថាក្រុមហ៊ុនបរទេសមួយយល់ព្រមមកសាងរោងចក្រ និងតម្លើងគ្រឿងបរិក្ខា ដើម្បីផលិតអំបោះធ្វើពីកប្បាស នៅក្នុងប្រទេសដែលកំពុងអភិវឌ្ឍ។ ផ្ទុយពីយល់ព្រមយកឈ្នួល ជាប្រាក់សម្រាប់ការតម្លើងរោងចក្រនោះ ក្រុមហ៊ុនបរទេសអាចយល់ព្រមទទួលយកអំបោះ ធ្វើពីកប្បាស ដែលផលិតនៅរោងចក្រនោះក្នុង រយៈពេលជាច្រើនឆ្នាំ។*

## ៣.៦-កិច្ចសន្យាទូទាត់ទ្វេភាគី

*កិច្ចព្រមព្រៀងរវាងពីរប្រទេស ដែលប្រទេសនីមួយៗ យល់ព្រមទិញទំនិញក្នុងចំនួនកំណត់ជាក់លាក់ ណាមួយនៅក្នុង កិច្ចសន្យាដាច់ដោយឡែកពីគ្នា ពីប្រទេសមួយទៀត។ កិច្ចព្រមព្រៀងនេះប្រហាក់ប្រហែលគ្នាទៅនឹងកិច្ចសម្រុះសម្រួលសម្រាប់កិច្ចព្រមព្រៀងទិញទៅវិញទៅមក ដែលបានពិភាក្សាខាងលើ។ ក៏ប៉ុន្តែនៅក្នុងកិច្ចព្រមព្រៀងទូទាត់ទ្វេភាគីប្រទេសនីមួយៗ រក្សាទុកគណនីទូទាត់ទ្វេភាគីនៅធនាគារនានា។ ប្រទេសនីមួយៗ ពិនិត្យមើលគណនីទូទាត់ទ្វេភាគីរបស់ប្រទេសមួយទៀត ដើម្បីឱ្យប្រាកដថាមានតុល្យភាព នៃជញ្ជីងពាណិជ្ជកម្មរវាងប្រទេសទាំងពីរនេះ។*

*ប្រសិនបើប្រទេស ក ទិញទំនិញពីប្រទេស ខ ច្រើនជាងប្រទេស ខ ទិញទំនិញពីប្រទេស ក ពេលនោះការទិញរបស់ប្រទេស ក ពីប្រទេស ខ ត្រូវផ្អាករហូតទាល់តែគណនីមានតុល្យភាពសាជាថ្មី។ ប្រសិនបើនៅទីបញ្ចប់នៃរយៈពេលដែលកំណត់ក្នុងកិច្ច ព្រមព្រៀងតុល្យភាព គណនី ត្រូវស្ថិតនៅខាងផ្នែកណាមួយពោលគឺ ប្រសិនបើប្រទេសណាមួយ បានទិញច្រើនជាងប្រទេសមួយទៀត ពេលនោះប្រទេសដែលបានទិញតិចជាងគេនោះ ជាធម្មតាត្រូវបេញសងចំពោះអតុល្យភាព គណនីនេះ[8]។ តើជម្លោះអំពីកិច្ចសន្យាពាណិជ្ជកម្មអន្តរជាតិត្រូវបានដោះស្រាយដោយវិធីណា?*

## ៤-ដំណោះស្រាយការអនុវត្តកិច្ចសន្យាពាណិជ្ជកម្មអន្តរជាតិ

*ដូចដែលបានពិភាក្សាខាងលើ កិច្ចសន្យាមួយរវាងភាគី ដែលមានកន្លែងអាជីវកម្មពាក់ព័ន្ធនៅក្នុងប្រទេសផ្សេងគ្នា មានលក្ខណៈជាអន្តរជាតិ ហើយជាទូទៅត្រូវស្ថិតនៅក្រោមច្បាប់ពាណិជ្ជកម្មអន្តរជាតិ។ ខាងក្រោមនេះគឺជាប្រភពច្បាប់ខ្លះៗ ដែលអាចអនុវត្តលើកិច្ចសន្យាពាណិជ្ជកម្មអន្តរជាតិ។ ការសំខាន់ភាគីត្រូវពិចារណាបញ្ហាទាំងនេះ មុននឹងធ្វើកិច្ច*

[8] The Asia Foundation, ***International Contract Law,*** op. cit., p.16.

*សន្យាពាណិជ្ជកម្មអន្តរជាតិ។ តាមតែអាចធ្វើទៅបាន ភាគីគប្បីព្យាយាមធ្វើឱ្យប្រាកដថា ពួកគេបានយល់និងយល់ព្រមលើច្បាប់ដែលនឹងអនុវត្តចំពោះកិច្ចសន្យារបស់ពួកគេ និងលើវិធីដោះស្រាយជម្លោះ។ការនេះសំខាន់ផងដែរ ក្នុងការបញ្ជាក់ថា នេះគឺជាវិស័យមួយដ៏លំបាក ហើយប្រហែលជាមិនមានចម្លើយច្បាស់លាស់ ចំពោះបញ្ហាជាចំណោទពិសេសណាមួយទេ។*

### ៤.១-ចំពោះកិច្ចសន្យា

*មិនថាឡើយកិច្ចសន្យាមួយ ត្រូវបានគេគិតថា ជាកិច្ចសន្យាអន្តរជាតិ ឬ មិនមែននោះទេ កិច្ចសន្យាដែលភាគីបានធ្វើ គឺជាប្រភពច្បាប់ទីមួយស្តីពី**សិទ្ធិ**[9] និង **កាតព្វកិច្ច**របស់ពួកគេនិង ស្តីពីដំណោះស្រាយជម្លោះទាក់ទិនទៅនឹងកិច្ចសន្យា។ មាត្រា២២នៃក្រឹត្យច្បាប់លេខ ៣៨ដែលជាច្បាប់កិច្ចសន្យាបច្ចុប្បន្នរបស់ប្រទេសកម្ពុជាឆ្នាំ ១៩៨៨ ចែងថា «កិច្ចសន្យាទុកជាច្បាប់រវាងភាគី»។ ផ្នែកខ្លះៗនៃកិច្ចសន្យាអាចមានសារសំខាន់ពិសេសក្នុងការជួយភាគីនិងតុលាការក្នុងការកំណត់ថា តើច្បាប់ណាដែលគ្រប់គ្រងកិច្ចសន្យា និង ថាតើជម្លោះត្រូវបានដោះស្រាយដោយវិធីណា។ ផ្នែកសំខាន់ពីរក្នុងចំណោមផ្នែកសំខាន់ទាំងនេះ នៃកិច្ចសន្យាគឺខចែងស្តីពីការជ្រើសរើសច្បាប់ និងការជ្រើសរើសសាលាជម្រះក្តី។ នៅក្នុង**យុត្តាធិការ**មួយចំនួនភាគីនៃកិច្ចសន្យាអាចជ្រើសរើសយកច្បាប់ដែលនឹងអនុវត្តលើកិច្ចសន្យារបស់គេ។ តាមធម្មតាច្បាប់ដែលបានជ្រើសរើសនោះត្រូវតែទាក់ទិនដល់កិច្ចការអាជីវកម្ម។*

*ឧទាហរណ៍ អ្នកទិញជនជាតិកម្ពុជាម្នាក់ យល់ព្រមទិញសូត្រពីអ្នកលក់ជនជាតិឥណ្ឌូនេស៊ីម្នាក់។ កិច្ចសន្យានេះចែងថា អ្នកលក់ត្រូវប្រគល់សូត្រទៅដល់អ្នកទិញនៅរាជធានីភ្នំពេញ។ ទំនិញនេះត្រូវដឹកតាមកប៉ាល់ពីឥណ្ឌូនេស៊ីមកសឹង្ហបុរី ដែលបន្ទាប់មកទៀតដឹកតាមរថភ្លើង ពីសឹង្ហបុរីមកបាងកក ហើយនៅទីបញ្ចប់ត្រូវដឹកតាមរថយន្តពីបាងកក មកកាន់រាជធានីភ្នំពេញ។ ដូច្នេះការប្រតិបត្តិកិច្ចសន្យានេះ ឆ្លងកាត់យុត្តាធិការជាច្រើនគឺ ឥណ្ឌូនេស៊ី សឹង្ហបុរី ម៉ាឡេស៊ី ថៃ និងកម្ពុជា។ ឧបមាថាភាគីនៃកិច្ចសន្យាជ្រើសរើសយកច្បាប់របស់សឹង្ហបុរី ដើម្បីដោះស្រាយជម្លោះណាមួយដែលកើតឡើង ប្រហែលដោយសារច្បាប់នេះ មានភាពងាយស្រួលនឹងអនុវត្ត ឬ ដោយសារហេតុផលណាមួយដទៃទៀត។ ដើម្បីឱ្យប្រាកដថា សេចក្តីប្រាថ្នារបស់គេត្រូវបានគោរព ភាគីអាចដាក់បញ្ចូលនូវសេចក្តីចែងមួយទៅក្នុងកិច្ចសន្យាដូចជាថា «អ្នកទិញនិងអ្នកលក់យល់ព្រមថា រាល់ជម្លោះ*

---

[9] *សិទ្ធិ មានន័យថាសេចក្តីសម្រេចតាមអំណាចច្បាប់។*

ដែលកើតឡើងពីកិច្ចសន្យា ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចច្បាប់សឹង្ហបុរី»។

ភាគីអាចជ្រើសរើសយក កិច្ចព្រមព្រៀងអន្តរជាតិ ឱ្យគ្រប់គ្រងកិច្ចសន្យារបស់គេបានផងដែរ ដូចជា **អនុសញ្ញា**អង្គការសហប្រជាតិ ស្តីពីកិច្ចសន្យាលក់ទំនិញអន្តរជាតិ ១៩៨០ (CISG) ឬ កម្រងវិធានដទៃទៀតដូចជាគោលការណ៍នៃ **កិច្ចសន្យាពាណិជ្ជកម្មអន្តរជាតិ** (UNIDROIT) ឆ្នាំ១៩៩៤។ គោលការណ៍ទាំងនេះនឹងមានពិភាក្សាបន្ថែមទៀត នៅក្នុងផ្នែកខាងក្រោមនេះ។ ម្យ៉ាងទៀតភាគីអាចជ្រើសរើសទីកន្លែងដែល ត្រូវជំនុំជម្រះជម្លោះកិច្ចសន្យា ឧទាហរណ៍ភាគីអាចបញ្ចូល ខ ចែងមួយទៅក្នុងកិច្ចសន្យាដែលចែងថា «ភាគីយល់ព្រមថា រាល់ជម្លោះដែលកើតចេញពីកិច្ចសន្យា ត្រូវតែវិនិច្ឆ័យនៅតុលាការរបស់ប្រទេសសឹង្ហបុរីតែប៉ុណ្ណោះ ដោយមិនគិតដល់តុលាការផ្សេងទៀត ដែលអាចមានសមត្ថកិច្ចដោយឡែកក្រៅពី ខ ចែងនេះ»។

ភាគីជាច្រើន នៃកិច្ចសន្យាពាណិជ្ជកម្មអន្តរជាតិ ជ្រើសរើសយកសាលាមជ្ឈត្តវិនិច្ឆ័យសន្ទានកម្មជាជាង ជ្រើសរើសយកតុលាការឱ្យដោះស្រាយជម្លោះ ឱ្យពួកគេដោយសារហេតុផលមួយចំនួន។ កិច្ចសន្យាពាណិជ្ជកម្ម អន្តរជាតិ អាចចែងសំអាងលើកម្រងស្តង់ដាអន្តរជាតិផងដែរ។ ឧទាហរណ៍កិច្ចសន្យាទាំងនេះអាចបញ្ចូលវាក្យសព្ទពាណិជ្ជកម្ម នៃសភាពាណិជ្ជកម្មអន្តរជាតិដែលគេហៅថា «វាក្យសព្ទពាណិជ្ជកម្មអន្តរជាតិ «INCOTERMS»។ វាក្យសព្ទពាណិជ្ជកម្មអន្តរជាតិ គឺជាវាក្យសព្ទស្តង់ដាដែលប្រើនៅក្នុងកិច្ចសន្យាលក់ទំនិញអន្តរជាតិ។ វាក្យសព្ទទាំងនេះបែងចែកសិទ្ធិនិងកាតព្វកិច្ច រវាងភាគីដែលទាក់ទិនទៅ នឹងបញ្ហាស្តីពី ការដឹកជញ្ជូន ការប្រគល់ទំនិញ ការធានារ៉ាប់រង និង ភយន្តរាយលើការបាត់បង់ទំនិញ។ ឧទាហរណ៍សេចក្តីចែងនៃកិច្ចសន្យាមួយអាចចែងថា «អ្នកលក់យល់ព្រមប្រគល់ក្រដាសចំនួន ១០០០០ រ៉ាម ក្នុងតម្លៃ ៥ ដុល្លាអាមេរិក ក្នុងមួយរ៉ាម CIF កំពង់សោម (វាក្យសព្ទពាណិជ្ជកម្មអន្តរជាតិ ១៩៩០)។ ពាក្យ CIF យោងដល់ពាក្យ «ថ្លៃដើម ថ្លៃធានារ៉ាប់រង និង ថ្លៃដឹកជញ្ជូន»។ នេះមានន័យថាតម្លៃដែលអ្នកទិញបង់ទៅតាមកិច្ចសន្យានោះ (៥ដុល្លា) ក្នុង១រ៉ាមរ៉ាប់បញ្ចូលទាំងថ្លៃក្រដាស ថ្លៃប្រគល់ក្រដាស ទៅដល់កំពង់សោម ហើយនិងថ្លៃធានារ៉ាប់រងចំពោះការបាត់បង់ ឬការខូចខាតដល់ក្រដាសក្នុងកំឡុងពេលដឹកជញ្ជូនទៅកាន់ផែកំពង់សោម។ការប្រើ «វាក្យសព្ទពាណិជ្ជកម្មអន្តរជាតិឆ្នាំ ១៩៩០» មានន័យថាជម្លោះណាមួយដែលកើតចេញពីកិច្ចសន្យាពាក្យ CIF ត្រូវតែបកស្រាយដោយយោង ទៅតាមការបកស្រាយ វាក្យសព្ទពាណិជ្ជកម្មអន្តរជាតិ១៩៩០។

### ៤.២-ចំពោះច្បាប់ពាណិជ្ជកម្មក្នុងស្រុករបស់រដ្ឋដែលទាក់ទិននៅនឹងកិច្ចការ អាជីវកម្ម

ច្បាប់ពាណិជ្ជកម្ម ក្នុងស្រុករបស់បណ្ដាប្រទេស ដែលពាក់ព័ន្ធនៅក្នុងកិច្ចការអាជីវកម្ម គឺជាប្រភពច្បាប់ដ៏សំខាន់មួយផ្សេងទៀត។ នៅក្នុងឧទាហរណ៍ខាងលើស្ដីពី ជ័យ រឿងនេះអាចរួមបញ្ចូលច្បាប់ពាណិជ្ជកម្មរបស់ប្រទេសកម្ពុជា ច្បាប់ថៃ ហើយនិង ច្បាប់សហរដ្ឋអាម៉េរិក។ ដូចដែលបានកត់សម្គាល់ខាងលើ ភាគីអាចចែងបញ្ជាក់នៅក្នុងកិច្ចសន្យារបស់គេ ថាតើច្បាប់ណាដែលនឹងត្រូវអនុវត្ត។ ក៏ប៉ុន្តែកាលបើមិនមាន ខ ចែងស្ដីពីការជ្រើសរើសច្បាប់ដែលអាចដាក់ឱ្យប្រតិបត្តិបាននោះទេ គេនឹងមិនដឹងច្បាស់លាស់ថា តើច្បាប់របស់ប្រទេសដទៃទៀតនឹងអនុវត្ត ឬយ៉ាងណា ហើយថា តើច្បាប់ប្រទេសទាំងនោះត្រូវអនុវត្តដោយរបៀបណាទេ។ រឿងនេះសំខាន់ដោយហេតុថា វាអាចមានភាពខុសគ្នារវាងច្បាប់របស់ប្រជាជាតិនានា ដែលពាក់ព័ន្ធទៅនឹងកិច្ចការអាជីវកម្មដែលជាវិស័យច្បាប់ នៃយុត្តាធិការផ្សេងៗគ្នាដែលមិនចុះសម្រុងនឹងគ្នា។ នៅក្នុងករណីនេះ ***វិធានច្បាប់អន្តរជាតិឯកជន*** ឬ ***ទំនាស់នៃការអនុវត្តច្បាប់***នឹងអនុវត្តលើប្រតិបត្តិការនោះ។

តុលាការអនុវត្តវិធានច្បាប់ អន្តរជាតិឯកជន ដើម្បីដោះស្រាយជម្លោះនៅពេលដែលច្បាប់ សមត្ថកិច្ច ឬ ***សាលក្រម*** របស់តុលាការនៃប្រទេសមួយផ្សេងទៀត មានការពាក់ព័ន្ធ។ ជាពិសេសវិធានទាំងនេះកំណត់ថាតើនៅពេលណា និង ដោយវិធីណាដែលតុលាការក្នុងស្រុកពិចារណាអំពី***អង្គហេតុ***នៃប្រព័ន្ធច្បាប់បរទេសនៅក្នុងរឿងក្ដីមួយ ដែលខ្លួនកំពុងសម្រេច។ វិស័យច្បាប់ដែលចែងអំពីវិធានទាំងនេះគេហៅថា «ច្បាប់អន្តរជាតិឯកជន» នៅក្នុងប្រជាជាតិដែលប្រើប្រព័ន្ធច្បាប់ស៊ីវិល ហើយគេហៅថាទំនាស់នៃការអនុវត្តច្បាប់នៅក្នុងប្រជាជាតិដទៃទៀត ដែលប្រើប្រព័ន្ធច្បាប់ Common Law។ វិធានទាំងនេះ គឺជាផ្នែកមួយនៃច្បាប់ក្នុងស្រុករបស់ប្រទេសនីមួយៗ ហើយវាប្រែប្រួលពីប្រជាជាតិមួយទៅប្រជាជាតិមួយទៀត។ ជួនកាលរដ្ឋខ្លះមានសន្ធិសញ្ញាជាមួយនឹងរដ្ឋខ្លះទៀតដែលទាក់ទិនទៅ នឹងវិធីដែលតុលាការ នឹងអនុវត្តច្បាប់បរទេសនៅក្នុងការដោះស្រាយជម្លោះ។ នៅក្នុងប្រជាជាតិដែលអនុវត្តច្បាប់ Common Law វិធានស្ដីពីភាពខុសគ្នា នៃច្បាប់ជាទូទៅទាក់ទិនទៅនឹងបញ្ហាសំខាន់៣យ៉ាងគឺ៖ (១)សាលាជម្រះដ៏សមស្រប៖ ថាតើតុលាការក្នុងស្រុកមានសមត្ថកិច្ចដោះស្រាយ រឿងក្ដីដែលទាក់ទិនទៅនឹងអង្គហេតុបរទេស ឬ យ៉ាងណា (២)អំពីសាច់ច្បាប់៖ ប្រសិនបើតុលាការក្នុងស្រុកពិតជាជំនុំជម្រះរឿងក្ដី ដែលទាក់ទិនទៅនឹងអង្គហេតុបរទេសនោះមែន ថាតើកម្រិតណា ដែលច្បាប់របស់មួយទៀតអនុវត្តបាន

ចំពោះរឿងក្តីនោះ (៣) អានុភាពនៃសាលក្រមៈ ប្រសិនបើតុលាការក្នុងស្រុកជំនុំជម្រះរឿងក្តីបែបនេះមែន ថាតើអានុភាពនៃសាលក្រមរបស់តុលាការ នៅក្នុងប្រទេសមួយទៀតនោះយ៉ាងណាដែរ។ នៅក្នុងប្រទេសដែលប្រើប្រព័ន្ធច្បាប់ស៊ីវិល វិធាននៃច្បាប់ឯកជនចែងជាពិសេស អំពីបញ្ហាថាតើច្បាប់ណាដែល នឹងអនុវត្តចំពោះប្រតិបត្តិការពាណិជ្ជកម្ម ដែលនៅក្នុងនោះ អង្គហេតុបរទេស។

## ៤.៣-ចំពោះច្បាប់ក្នុងស្រុកដទៃទៀត

ច្បាប់ជាតិដទៃទៀត អាចធ្វើឱ្យប៉ះពាល់ដល់ កិច្ចសន្យាពាណិជ្ជកម្មអន្តរជាតិផងដែរ។ ច្បាប់ទាំងនោះមិនអាចទាក់ទិនតែចំពោះការបង្កើតឬ ការបំពេញកាតព្វកិច្ចនៃកិច្ចសន្យាជាទូទៅប៉ុណ្ណោះទេ ក៏ប៉ុន្តែអាចធ្វើឱ្យប៉ះពាល់ដល់ បញ្ហានានាដូចជាតម្លៃទំនិញ ថាតើភាគីអាចទៅតាមច្បាប់ឬ យ៉ាងណានូវអ្វីដែលពួកគេស្នើឡើង ទាក់ទិនទៅនឹងកម្មវត្ថុនៃកិច្ចសន្យា។ ឧទាហរណ៍ ជារួមមានពន្ធគយលើទំនិញនាំចូល ការត្រួតពិនិត្យលើទំនិញនាំចូល និងនាំចេញច្បាប់ពន្ធដារផ្សេងៗ និងលក្ខខណ្ឌតម្រូវស្តីពីការរលាយសមាសភាគ ផលិតនិងការទិញ ដូចជាវិធានដែលចែងថា តើត្រូវមានសមាសភាគផលិតក្នុងស្រុកចំនួនប៉ុន្មានក្នុងការផលិតទំនិញនោះ។

## ៤.៤-ចំពោះការអនុវត្តច្បាប់អន្តរជាតិ

ច្បាប់អន្តរជាតិអាចអនុវត្ត បានផងដែរចំពោះកិច្ចសន្យាពាណិជ្ជកម្មអន្តរជាតិ។ ច្បាប់បែបនេះ អាចរាប់បញ្ចូល**សន្ធិសញ្ញា** និង ច្បាប់ប្រពៃណីអន្តរជាតិ ដែលបានពិភាក្សារួចមកហើយ។ កិច្ចការអាជីវកម្មអន្តរជាតិ អាចគ្រប់គ្រងដោយកិច្ចព្រមព្រៀងអន្តរជាតិ ដូចជាអនុសញ្ញាស្តីពីកិច្ចសន្យាលក់ទំនិញអន្តរជាតិ (CISG ) ឬ ដោយកម្រងវិធានដទៃទៀត ដូចជាគោលការណ៍នៃកិច្ចសន្យាពាណិជ្ជកម្មអន្តរជាតិ (UNIDROIT) ដូចដែលបានបញ្ជាក់នៅផ្នែកខាងលើ។ អនុសញ្ញាស្តីពីកិច្ចសន្យាលក់ទំនិញអន្តរជាតិមានសារៈសំខាន់ពិសេស។ ថ្វីបើសិង្ហបុរី ជាប្រទេសតែមួយនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ដែលសព្វថ្ងៃនេះអនុសញ្ញាស្តីពី ការលក់ទំនិញអន្តរជាតិមានអានុភាពលើប្រទេសនេះក៏ដោយ ក៏អនុសញ្ញានេះមានអានុភាព ទៅលើប្រទេសដទៃទៀតជាច្រើនដូចជា ប្រទេសអូស្ត្រាលី ចិន បារាំង និងសហរដ្ឋអាម៉េរិក។ អនុសញ្ញាស្តីពីការលក់ទំនិញអន្តរជាតិ ព្យាយាមរួមបញ្ចូល**អង្គហេតុ**នៃប្រព័ន្ធច្បាប់ផ្សេងៗ ហើយផ្តល់ឱ្យមានច្បាប់ជាសាកលមួយសម្រាប់ការលក់ទំនិញ ដែលឆ្លងកាត់ព្រំដែនជាតិ និង អន្តរជាតិ។ ដូច្នេះប្រសិនបើមានកិច្ចសន្យាលក់ទំនិញដែលធ្វើឡើងរវាងភាគីដែលស្ថិតនៅក្នុងប្រទេសផ្សេងគ្នា ដែលប្រទេសទាំងនោះ បានចុះហត្ថលេខាលើអនុសញ្ញាស្តីពីកិច្ចសន្យាលក់ទំនិញអន្តរជាតិ

ពេលនោះអនុសញ្ញានេះអាចអនុវត្ត ចំពោះកិច្ចសន្យានោះ។ ក៏ប៉ុន្តែចាំបាច់ត្រូវពិនិត្យមើលច្បាប់ក្នុងស្រុករបស់ប្រទេសនីមួយៗ ដើម្បីកំណត់ ថាតើអនុសញ្ញាស្តីពីកិច្ចសន្យាលក់ទំនិញអន្តរជាតិអនុវត្ត ឬ មិនអនុវត្ត ទោះបីប្រទេសនោះជាហត្ថលេខីក៏ដោយ។ ភាគីអាចជ្រើសរើសអនុសញ្ញាស្តីពីកិច្ចសន្យាលក់ទំនិញអន្តរជាតិផងដែរ សម្រាប់ធ្វើជាច្បាប់គ្រប់គ្រងកិច្ចសន្យារបស់ខ្លួន ដោយប្រើសេចក្តីថែងស្តីពី «ការជ្រើសរើសច្បាប់» ដូចការពិភាក្សានិងពន្យល់ខាងលើ។

អនុសញ្ញាស្តីពីការលក់ទំនិញអន្តរជាតិ (CISG ) អនុវត្តភាគច្រើនចំពោះការបង្កើត និងការបំពេញកាតព្វកិច្ចនៃកិច្ចសន្យា។ ដូចដែលឈ្មោះរបស់វាបានបង្ហាញឱ្យឃើញស្រាប់ អនុសញ្ញានេះអនុវត្តចំពោះតែកិច្ចសន្យាលក់ទំនិញតែប៉ុណ្ណោះ។ម្យ៉ាងទៀតអនុសញ្ញានេះមិនធ្វើឱ្យប៉ះពាល់ដល់ទិដ្ឋភាពខ្លះៗ ស្តីពី **សុពលភាព**នៃកិច្ចសន្យាដែលគ្រប់គ្រងដោយច្បាប់ក្នុងស្រុក ឬ ច្បាប់ជាតិនោះទេ។ ឧទាហរណ៍អនុសញ្ញា មិនធ្វើឱ្យប៉ះពាល់ដល់សមត្ថភាពរបស់ភាគីក្នុងការចុះកិច្ចសន្យា ឬធ្វើឱ្យប៉ះពាល់ដល់**នីត្យានុកូលភាព** នៃកិច្ចសន្យាដែលចំណុះច្បាប់ជាតិឡើយ។

កិច្ចសន្យាមួយរវាងភាគី ដែលមានកន្លែងអាជីវកម្មពាក់ព័ន្ធ នៅក្នុងប្រទេសផ្សេងគ្នាមានលក្ខណៈជាអន្តរជាតិ ហើយជាទូទៅត្រូវស្ថិតនៅក្រោមច្បាប់ពាណិជ្ជកម្មអន្តរជាតិ។ ខាងក្រមនេះគឺជាប្រភពច្បាប់ខ្លះៗដែលអាចអនុវត្ត លើកិច្ចសន្យាពាណិជ្ជកម្មអន្តរជាតិ។ ភាគីទាំងសងខាងគប្បីព្យាយាមធ្វើឱ្យប្រាកដថាពួកគេបានយល់ និងយល់ព្រមលើច្បាប់ដែលនឹងអនុវត្តចំពោះកិច្ចសន្យារបស់ពួកគេ និងលើវិធីដោះស្រាយជម្លោះ។ កិច្ចសន្យាមួយទោះបីវាជាកិច្ចសន្យាអន្តរជាតិឬមិនមែនក៏ដោយ ក៏វាគឺជាប្រភពច្បាប់ទីមួយ ស្តីពីសិទ្ធិ និងកាតព្វកិច្ចរបស់ពួកគេ និងស្តីពីដំណោះស្រាយជម្លោះទាក់ទិនទៅនឹងកិច្ចសន្យា។

ផ្នែកខ្លះៗ នៃកិច្ចសន្យាអាចមាន សារសំខាន់ពិសេសក្នុងការជួយភាគី និង តុលាការក្នុងការកំណត់ថា តើច្បាប់ណាដែលគ្រប់គ្រងកិច្ចសន្យានិង ថាតើជម្លោះត្រូវបានដោះស្រាយដោយវិធីណា។ ផ្នែកសំខាន់ពីរក្នុងចំណោម ផ្នែកសំខាន់ៗទាំងនេះនៃកិច្ចសន្យាគឺសេចក្តីថែងស្តីពីការជ្រើសរើសច្បាប់ និងការជ្រើសរើសសាលាជម្រះក្តី។ នៅក្នុងយុត្តាធិការមួយចំនួនភាគី នៃកិច្ចសន្យាអាចជ្រើសរើសយកច្បាប់ដែលនឹងអនុវត្តលើកិច្ចសន្យារបស់គេ។ តាមធម្មតាច្បាប់ ដែលជ្រើសរើសនោះត្រូវតែទាក់ទិនទៅនឹងកិច្ចការអាជីវកម្ម។ ឧបមាថាភាគីនៃកិច្ចសន្យាជ្រើសរើស យកច្បាប់សឹង្ហ បុរីដើម្បីដោះស្រាយជម្លោះណាមួយដែលកើតឡើងប្រហែលដោយសារតែច្បាប់នេះមាន

ភាពងាយស្រួលក្នុងការអនុវត្ត ឬ ដោយសារហេតុផលណាមួយដទៃទៀត។

ដើម្បីឱ្យប្រាកដថា សេចក្តីប្រាថ្នារបស់គេត្រូវបានគោរព ភាគីអាចដាក់បញ្ចូលនូវសេចក្តីចែងមួយទៅក្នុងកិច្ចសន្យា ដូចជាថា អ្នកទិញ និង អ្នកលក់យល់ព្រមថារាល់ជម្លោះដែលកើតមានឡើងពីកិច្ចសន្យាត្រូវស្ថិតនៅក្រោមសមត្ថកិច្ចនៃច្បាប់សឹង្ហបុរី។ ភាគីអាចជ្រើសរើសយកកិច្ចព្រមព្រៀងអន្តរជាតិឱ្យគ្រប់គ្រងកិច្ចសន្យារបស់គេបានផងដែរ ដូចជាអនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីការលក់ទំនិញអន្តរជាតិឆ្នាំ១៩៨០ ឬ កម្រងវិធានដទៃទៀតដូចជាគោលការណ៍នៃកិច្ចសន្យាពាណិជ្ជកម្មអន្តរជាតិ UNIDROIT ឆ្នាំ១៩៩៤។

នីតិវិធីដោះស្រាយវិវាទ[10] ដែលបានអនុវត្តដោយ អង្គការពាណិជ្ជកម្មពិភពលោក មានចែងពីយន្តការដោះស្រាយវិវាទ នៅពេលដែលប្រទេសមួយបានរកឃើញថា ប្រទេសមួយទៀតកំពុងបំពានលើវិធាន និង កិច្ចប្រឹងប្រែងរកដំណោះស្រាយសម្របសម្រួលក្នុងករណីពិគ្រោះយោបល់ទ្វេភាគីទទួលបរាជ័យ។ ជាទូទៅវិវាទដែលត្រូវបានដាក់ជូនអង្គការ WTO គឺកើតចេញពីព័ត៌មានដែលបានផ្តល់ដោយឧស្សាហកម្ម ឬ សាខារបស់គេជូនទៅ រដ្ឋាភិបាលអំពីការលំបាក ដែលគេប្រឈមក្នុងការរកទីផ្សារសម្រាប់ផលិតផលរបស់គេ នៅទីផ្សារខាងក្រៅ។ ការពិគ្រោះយោបល់ទ្វេភាគីការពិនិត្យដោយស្ថាប័នដោះស្រាយវិវាទ និងក្រោយមកការពិនិត្យ ដោយស្ថាប័នឧទ្ធរណ៍តំណាងរដ្ឋាភិបាលជាអ្នកចូលរួម ពួកគេត្រូវតែពឹងផ្អែកខ្លាំងទៅលើយោបល់និងការគាំទ្រដែលមាននិរន្តរភាពពីឧស្សាហកម្ម និងសមាគមន៍ទាំងឡាយ ដែលមានផលប្រយោជន៍ក្នុងកម្មវត្ថុនៃវិវាទនេះ។ លទ្ធភាពរបស់ រដ្ឋាភិបាលក្នុងការដោះស្រាយរឿងក្តីដោយមានប្រសិទ្ធភាព ឬ ដើម្បីការពារផលប្រយោជន៍ ដែលត្រូវបានប្តឹងប្រឆាំងនឹងខ្លួនពឹង ផ្អែកយ៉ាងខ្លាំងទៅលើជំនួយ និង ការគាំទ្រដែលក្រុមឧស្សាហកម្មពាក់ព័ន្ធបានផ្តល់ឱ្យ[11]។ ការទាញយកប្រយោជន៍ពីវិធានការសេរីភាវូបនីយកម្ម ក្រៅពីការជួយរដ្ឋាភិបាលរៀបចំកំហិតជិតគោលនយោបាយ ដែលគេត្រូវអនុម័តនៅក្នុងការភិភាក្សា ស្តីពីការអនុវត្តវិធាននៃកិច្ចព្រមព្រៀង និងនៅក្នុងការចរចាស្តីពីការបង្កើតវិធានសហគមពាណិជ្ជកម្មមានការទទួលខុសត្រូវជាបឋម ក្នុងការផ្លាស់ប្តូរការបន្ថយថ្លៃពន្ធនិងការសន្យាធ្វើសេរីភាវូបនីយកម្មទៅក្នុងកាលានុវត្តភាពពាណិជ្ជកម្មដោយការ

[10] សុក ស៊ីផាន់ណា, មគ្គុទ្ទេសក៍ពាណិជ្ជកម្មឆ្ពោះទៅរកប្រព័ន្ធពាណិជ្ជកម្មពិភពលោក មជ្ឈមណ្ឌលពាណិជ្ជកម្មអន្តរជាតិ ទីក្រុងហ្សឺណែវ ឆ្នាំ១៩៩៩ ទំព័រ ១៥។

[11] សុក ស៊ីផាន់ណា៖ មគ្គុទ្ទេសក៍ពាណិជ្ជកម្មឆ្ពោះទៅរកប្រព័ន្ធពាណិជ្ជកម្មពិភពលោក ដ. ឯ. ម. ទំព័រ ២៥។

អនុម័ត យុទ្ធសាស្ត្រអភិវឌ្ឍន៍និង ជំរុញការនាំចេញដ៏សមស្របមួយៗ

## ៥-នីតិសម្បទាឬសមត្ថភាព ( Capacity ) និង នីត្យានុកូលភាព ( Legality )

សមត្ថភាព គឺជាអំណាចផ្លូវច្បាប់របស់ភាគីនីមួយៗ ដែលជាធម្មតាមនុស្សពេញវ័យពល់រូបអាច ធ្វើបានដូចជាចុះកិច្ចសន្យាណាមួយៗ ជាទូទៅថាតើភាគីអាចមានសមត្ថភាពធ្វើកិច្ចសន្យាអន្តរជាតិ ឬយ៉ាងណានោះគឺអាស្រ័យលើច្បាប់របស់ប្រទេសនីមួយៗ ឬប្រទេសដទៃទៀតដែលមានយុត្តាធិការលើកិច្ចសន្យាៗ អនុសញ្ញាស្តីពីការលក់ទំនិញអន្តរជាតិ(CISG) មិនមានពិភាក្សាថាតើភាគី នៃកិច្ចសន្យាលក់ទំនិញអន្តរជាតិ មាន ឬ មិនមានសមត្ថភាពនឹងធ្វើកិច្ចសន្យានោះទេៗ ដូច្នេះប្រសិនបើមានសំណួរអំពីសមត្ថភាពរបស់ភាគី គំនិតដ៏ល្អ គឺត្រូវរកឱ្យបាននូវការជូនយោបល់ផ្នែកច្បាប់ទាក់ទិនទៅ នឹងច្បាប់របស់ប្រទេសមួយ ឬប្រទេសទាំងឡាយណាដែលពាក់ព័ន្ធនឹងកិច្ចសន្យាៗ

រីឯនីត្យានុកូលភាពនៃកិច្ចសន្យាអន្តរជាតិ គឺជាបញ្ហាដែលជាទូទៅអាស្រ័យលើច្បាប់ក្នុងស្រុក របស់ប្រទេសដែលមានយុត្តាធិការ លើកិច្ចសន្យាៗ ជាថ្មីម្តងទៀត គំនិតល្អ គឺ ត្រូវពិនិត្យមើលច្បាប់ក្នុងស្រុកទាំងនោះ ដើម្បីឱ្យប្រាកដថាកិច្ចសន្យាអាជីវកម្ម ដែលស្នើឡើងនោះមិនបំពានច្បាប់របស់ប្រទេស ដែលពាក់ព័ន្ធណាមួយឡើយ មានឧទាហរណ៍ជាច្រើនស្តីពីកិច្ចការអាជីវកម្ម ដែលខុសច្បាប់ៗ ប្រទេសនានាអាចមានការត្រួតពិនិត្យទៅលើការនាំទំនិញចូល ឬ នាំចេញពីប្រទេសនូវមុខទំនិញខ្លះៗដូចជា ក្អកដំរី....ៗលៗ ឬអាចថាជាអំពើខុសនឹងច្បាប់ក្នុងការនាំចូល ឬ សូម្បីតែការដឹកជញ្ជូនកាកសំណល់ជាតិគីមី ដែលនាំឱ្យមានគ្រោះថ្នាក់ៗ ម្យ៉ាងទៀតតាមច្បាប់របស់សហរដ្ឋអាមេរិក ការធ្វើពាណិជ្ជកម្មជាមួយប្រទេស «បច្ចាមិត្រ» គឺមិនស្របច្បាប់ទេៗ

## ៦-ការលំបាកក្នុងការបំពេញកាតព្វកិច្ចនៃកិច្ចសន្យានិងខចែងស្តីពីករណីប្រធានសក្តិ

ការធ្វើអាជីវកម្មអន្តរជាតិ ជាញឹកញាប់អាចបណ្តាលឱ្យភាគីទទួលរងនូវការប្រថុយច្រើនជាងធ្វើអាជីវកម្មនៅក្នុងប្រទេសរបស់សមីភាគីៗ ចំពោះហេតុផលនេះកិច្ចសន្យាអន្តរជាតិ ជាញឹកញាប់មានចែងអំពីអ្វីដែលគេហៅថាខចែងស្តីពី «ករណីប្រធានសក្តិ»ៗ ជាញឹកញាប់ខចែងបែបទាំងនេះចែងថាភាគីមិនបាច់បំពេញកាតព្វកិច្ចនៃកិច្ចសន្យាឡើយ ប្រសិនបើព្រឹត្តិការណ៍ដែលមិនអាចរំពឹងទុកជាមុនបាន ហើយហួសពីការគ្រប់គ្រងរបស់សាមីភាគី ធ្វើឱ្យការបំពេញកាតព្វកិច្ចតាមកិច្ចសន្យា មិនអាចធ្វើទៅកើត ឬមិនអាចប្រតិបត្តិតាមបានៗ ឧទាហរណ៍អំពីព្រឹត្តិការណ៍បែបនេះរួមមាន គ្រោះធម្មជាតិ និង ករណី

ប្រធានសក្តិដទៃទៀតដូចជា កូដកម្មរបស់កម្មករ សង្គ្រាម...។ល។ ខចែងអំពីករណីប្រធានសក្តិ អាចមានឈ្មោះផ្សេងៗ គ្នាទៅតាមយុត្តាធិការ នីមួយៗ។

ជាធម្មតា ខចែងអំពីករណីប្រធានសក្តិ ចែងថាភាគីនៃកិច្ចសន្យាអាចពន្យាពេលឬ បញ្ចប់កាតព្វកិច្ចរបស់ខ្លួនតាមកិច្ចសន្យា ប្រសិនបើការពិបាកដែលមិនអាចរំពឹងទុកជា មុនបែបនេះកើតឡើង។

ឧទាហរណ៍ ខចែងបែបនេះអាចចែង ថា «នៅក្នុងករណីប្រធានសក្តិភាគី ដែលទទួល ផលប៉ះពាល់ អាចបញ្ចប់កាតព្វកិច្ចរបស់ខ្លួន នៅក្រោមកិច្ចសន្យា»។ ខចែង នោះគប្បីចែង ថា តើព្រឹត្តិការណ៍នោះគ្រាន់តែអនុញ្ញាតឱ្យភា គី ដែលរងគ្រោះពន្យាពេលបំពេញកាតព្វកិច្ច នៃកិច្ចសន្យា ឬ មួយក៏បញ្ឈប់កាតព្វកិច្ច ហើយមិនបាច់ប្រតិបត្តិ សាជាថ្មីឡើងវិញ។ ខ ចែងនោះត្រូវចែងផងដែរថា តើនីតិវិធីណា ដែលភាគីត្រូវប្រតិបត្តិតាម ដើម្បីកាត់បន្ថយជា អប្បបរិមានូវការខាតបង់ ដែលកើតមកពី ព្រឹត្តិការណ៍ប្រធានសក្តិនោះ។

## ៧-ការធានារ៉ាប់រង

ការធានារ៉ាប់រង គឺជាកិច្ចសន្យារវាង ធានាការី (ក្រុមហ៊ុនធានារ៉ាប់រង) និង អ្នកកាន់ បណ្ណធានារ៉ាប់រង (ដែលគេហៅផងដែរថាអ្នក មានការធានារ៉ាប់រង)។ កិច្ចសន្យាធានារ៉ាប់រង ជាញឹកញាប់ គេហៅថាបណ្ណធានារ៉ាប់រង។ នៅក្នុងបណ្ណធានារ៉ាប់រង ធានាការីយល់ព្រម ថា នឹងផ្តល់ដល់អ្នកកាន់បណ្ណធានារ៉ាប់រងនូវ ទឹកប្រាក់មួយចំនួន ឬ អត្ថប្រយោជន៍ណាមួយ ផ្សេងទៀត ប្រសិនបើព្រឹត្តិការណ៍ជាក់លាក់ មួយដែលមិនប្រាកដថា នឹងកើតឡើងនៅក្នុង រយៈពេលធានារ៉ាប់រង ពិតជាកើតឡើងមែន នៅក្នុងរយៈពេលនោះ ហើយបង្កឱ្យមានការ ខូចខាត ឬ ការបាត់បង់ដល់ទ្រព្យសម្បត្តិ ឬ ផលប្រយោជន៍ដទៃទៀត របស់អ្នកកាន់បណ្ណ ធានារ៉ាប់រង។

ជាថ្នូរទៅ នឹងការបានទទួលនូវការ ធានារ៉ាប់រងទប់ទល់នូវគ្រោះថ្នាក់នេះ អ្នក កាន់បណ្ណធានារ៉ាប់រងយល់ព្រមបង់ឱ្យក្រុម ហ៊ុនធានារ៉ាប់រងនូវ ទឹកប្រាក់មួយចំនួន ដែល គេហៅថា **បុព្វលាភធានារ៉ាប់រង**។ អ្នកកាន់ប ណ្ណធានារ៉ាប់រង ត្រូវបង់បុព្វលាភធានារ៉ាប់រង ដោយមិនគិតថាព្រឹត្តិការណ៍ ដែលធានារ៉ាប់រង នោះកើតឡើង ឬ មិនកើតឡើងនោះទេ។ ឧទាហរណ៍ ម្ចាស់រថយន្តអាចធ្វើកិច្ចសន្យា ធានារ៉ាប់រងជាមួយនឹងក្រុមហ៊ុនធានារ៉ាប់រង។ ក្រុមហ៊ុនធានារ៉ាប់រងយល់ព្រមថា ប្រសិនបើ រថយន្តនោះមានគ្រោះថ្នាក់ចរាចរ នៅក្នុងឆ្នាំ ខាងមុខក្រុមហ៊ុននឹងចេញថ្លៃជួសជុលរថយន្ត ឱ្យទៅម្ចាស់រថយន្តនោះ។ ជាថ្នូរទៅនឹងការ សន្យារបស់ក្រុមហ៊ុនធានារ៉ាប់រង ដែលថានឹង ចេញប្រាក់សង ប្រសិនបើព្រឹត្តិការណ៍នោះ

កើតឡើង អ្នកកាន់បណ្ណធានារ៉ាប់រងសុខចិត្តបង់បុព្វលាភធានារ៉ាប់រង ដល់ក្រុមហ៊ុនធានារ៉ាប់រង។

នៅក្នុងការដឹកជញ្ជូនទំនិញសម័យទំនើប មានការប្រថុយផ្សងជាច្រើន ដែលភាគីអាចជ្រើសរើស ដើម្បីឱ្យបានការធានារ៉ាប់រង។ ទំនិញអាចបាត់បង់ ឬ ខូចខាតនៅពេលចាប់ផ្ដើមដំណើរ។ នាវាអាចលិចឬទទួលរងនូវការខូចខាតដោយសារធាតុអាកាសមិនល្អ ឬដោយសារតែការកាន់ច្រឡំរបស់មនុស្ស។ អំពើប្លន់តាមសមុទ្រ ក៏ជាព្រឹត្តិការណ៍អកុសលផងដែរ ហើយដែលនៅតែជាបញ្ហានៅឡើយនៅក្នុងផ្នែកខ្លះៗនៃពិភពលោក។ម្យ៉ាងទៀត សកម្មភាពមួយចំនួនរបស់រដ្ឋាភិបាល មិនអាចទស្សន៍ទាយបានឡើយ។ កាលពីប៉ុន្មានឆ្នាំកន្លងទៅពាណិជ្ជកម្មតាមនាវា រវាងប្រទេសពីរនៅតំបន់អាស៊ី មានភាពច្របូកច្របល់យ៉ាងខ្លាំងនៅពេលដែលកងកម្លាំងសន្តិសុខ មកពីប្រទេសទីបីបានឡើងកាន់កាប់នាវា ហើយបង្ខំឱ្យរើទំនិញចេញទៅក្នុងប្រទេសទីបីនោះ។ល។ ទំនិញក៏អាចខូចខាតដោយសារគ្រោះថ្នាក់ផ្លូវដែក ឬ គ្រោះថ្នាក់រថយន្តផងដែរ។ ភាគីនៃកិច្ចសន្យាទិញបណ្ណធានារ៉ាប់រងដោយសារភយន្តរាយបែបទាំងនេះ។

ភាគីនៃកិច្ចសន្យាលក់ទំនិញ គប្បីធានារ៉ាប់រងទប់ទល់នឹងភយន្តរាយចំពោះការបាត់បង់ ឬខូចខាតដល់ទំនិញនៅពេលចាប់ផ្ដើមដំណើរ។ ភាគីត្រូវចែងឱ្យបានច្បាស់លាស់នៅក្នុងកិច្ចសន្យាលក់ទំនិញ ថាតើនៅចំណុចណាដែល ភយន្តរាយចំពោះការខូចខាតត្រូវផ្ទេរពីអ្នកលក់ទៅអ្នកទិញ។ ការបែងចែកនូវភយន្តរាយកំណត់ថា តើអ្នកណាជាអ្នកទិញ បណ្ណធានារ៉ាប់រង សមស្របដើម្បីទប់ទល់នឹងភយន្តរាយ។ នៅក្នុងករណីខ្លះៗកិច្ចសន្យាលក់ទំនិញ អាចចែងយ៉ាងជាក់លាក់ថា ភាគីមួយមានកាតព្វកិច្ចត្រូវធានារ៉ាប់រង។ រឿងនេះកើតឡើងនៅក្នុងការប្រើវាក្យសព្ទពាណិជ្ជកម្មអន្តរជាតិជាក់លាក់ខ្លះៗ។ ឧទាហរណ៍ ពាក្យ CIF (ដែលមានន័យថា ថ្លៃទំនិញបូកថ្លៃធានារ៉ាប់រងបូកថ្លៃដឹកជញ្ជូន) តម្រូវឱ្យអ្នកលក់ធានារ៉ាប់រងទំនិញ រហូតទាល់តែទំនិញបានទៅដល់កំពង់ផែទិសដៅ ដែលកំណត់ឈ្មោះ។ ភាគីនៃកិច្ចសន្យាលក់ទំនិញអន្តរជាតិ ជាញឹកញាប់បានទទួលការធានារ៉ាប់រងតាមរយៈ ជើងសារធានារ៉ាប់រង។ជើងសារធានារ៉ាប់រង គប្បីជាមនុស្សមានកិត្តិសព្ទល្អហើយត្រូវរៀបចំធានារ៉ាប់រងជាមួយ នឹងក្រុមហ៊ុនធានារ៉ាប់រង ដែលមានសមត្ថភាពចេញសងនូវទឹកប្រាក់មួយចំនួនដែលបានព្រមព្រៀងគ្នានៅក្នុង កិច្ចសន្យាធានារ៉ាប់រង ប្រសិនបើមានការបាត់បង់ ឬការខូតខាតដល់ទំនិញ។

បណ្ណធានារ៉ាប់រង ត្រូវចែងឱ្យបានច្បាស់លាស់ថា តើភយន្តរាយប្រភេទណាខ្លះ ដែលបណ្ណនោះត្រូវចេញសង និង រយៈពេល

ដែលបណ្ណមានប្រសិទ្ធភាព (រយៈពេលនៃការធានារ៉ាប់រង)។ តាមការពិតតម្លៃនៃបុព្វលាភរ៉ាប់រង នឹងឆ្លុះបញ្ចាំងឱ្យឃើញ អំពីប្រភេទធានារ៉ាប់រងដែលត្រូវចេញសង។ ប្រសិនបើអ្នកលក់ ជាអ្នកទិញបណ្ណធានារ៉ាប់រង តម្លៃទំនិញ នឹងឆ្លុះបញ្ចាំឱ្យឃើញតម្លៃធានារ៉ាប់រងផងដែរ។ ចំពោះរយៈពេលនៃការធានារ៉ាប់រងវិញ ការធានារ៉ាប់រងអាចរៀបចំសម្រាប់ទំនិញតែមួយនាវាភណ្ឌ (ចំនួនមួយកប៉ាល់) ឬ នាវាភណ្ឌមួយចំនួន(ដែលអាចនឹងមានប្រយោជន៍កាលបើអាចផ្គត់ផ្គង់ទំនិញជាបន្តបន្ទាប់) ឬសម្រាប់រយៈពេលមួយដែលកំណត់ច្បាស់លាស់។ កត្តាសំខាន់មួយនៅក្នុងការសម្រេចថា តើភយន្តរាយប្រភេទណាដែលត្រូវធានារ៉ាប់រង គឺការកំណត់ដែលអនុសញ្ញាអន្តរជាតិ ដូចជាអនុសញ្ញាក្រុងវ៉ាសូវី ជាដើម ...ចែងអំពីការទទួលខុសត្រូវរបស់ក្រុមហ៊ុនដឹកជញ្ជូន។

ដើម្បីពន្យល់អំពី ប្រភេទធានារ៉ាប់រងដែលអាចមាន យើងនឹងពិភាក្សាយ៉ាងសង្ខេបអំពីការធានារ៉ាប់រងសម្រាប់ការដឹកជញ្ជូនទំនិញតាមសមុទ្រ។ ប្រភេទចំបងពីរយ៉ាងនៃភយន្តរាយដែលក្រុមហ៊ុនធានារ៉ាប់រង អាចចេញប្រាក់សង សម្រាប់ការដឹកជញ្ជូនទំនិញតាមសមុទ្រ គឺភយន្តរាយតាមផ្លូវសមុទ្រ។ ហើយនឹងភយន្តរាយបង្កដោយសង្គ្រាម។ ភយន្តរាយតាមផ្លូវសមុទ្ររួមមាន «គ្រោះថ្នាក់សមុទ្រ» អំពើប្លន់តាមសមុទ្រ អគ្គីភ័យ ចោរកម្ម និង ការប្រព្រឹត្តមិនល្អនៃក្រុមនាវិករបស់នាវានោះ។ គ្រោះថ្នាក់សមុទ្រ តាមធម្មតារួមមានគ្រោះថ្នាក់នានាដូចជា ការផ្ទុះ ការលិចនាវា ការបុកប្រាំងសមុទ្រ និងនាវាបុកគ្នា ក៏ប៉ុន្តែមិនរ៉ាប់បញ្ចូលការខូចខាត ដល់ទំនិញដែលបណ្តាលមកពីអំពើធម្មតានៃខ្យល់ និង រលកទឹកសមុទ្រនោះទេ។ ការធ្វេសប្រហែសរបស់នាយក ឬ ក្រុមនាវិកនៃនាវាតាមធម្មតាត្រូវរាប់បញ្ចូលទៅក្នុង «គ្រោះថ្នាក់សមុទ្រ»។ ភយន្តរាយបង្កដោយសង្គ្រាមរួមមានជម្លោះអន្តរជាតិ និង ជម្លោះស៊ីវិល ការបះបោរ ឬ កុបកម្ម ឬ ក៏ការរឹបអូសយកដោយរដ្ឋាភិបាល។

កិច្ចសន្យាធានារ៉ាប់រង ដែលបានដល់ភយន្តរាយចំពោះការបាត់បង់ទំនិញ ដែលកំពុងតែដឹកជញ្ជូនអាចរួមបញ្ចូលនូវ ខចែង ជាស្តង់ដាដែលគេហៅថា ខចែងនៃគ្រឹះស្ថានធានារ៉ាប់រងនាវាភណ្ឌ។ ខចែងទាំងនេះត្រូវបានបង្កើតឡើងដោយគ្រឹះស្ថានក្រុមហ៊ុនធានារ៉ាប់រងទីក្រុងឡុងដ៍ ដែលថ្មីៗនេះត្រូវបានរំលាយចូល ជាមួយសមាគមក្រុមហ៊ុនធានារ៉ាប់រងអន្តរជាតិទីក្រុងឡុងដ៍។ ខចែង នៃគ្រឹះស្ថានធានារ៉ាប់រងនាវាភណ្ឌ ត្រូវបានប្រើប្រាស់នៅក្នុងកិច្ចសន្យាស្តង់ដា ស្តីពីកិច្ចធានារ៉ាប់រងនាវាភណ្ឌនៅ ក្នុងប្រទេសភាគច្រើននៃពិភពលោក។ តាមខចែងស្តង់ដាបីនៃគ្រឹះស្ថានធានារ៉ាប់រងនាវាភណ្ឌ គឺ ខធានារ៉ាប់រង A ខធានារ៉ាប់រង B និង ខធានារ៉ាប់រង C។

ខធានារ៉ាប់រង A ចេញប្រាក់សងចំពោះភយន្តរាយប្រភេទទូលំទូលាយ ខ ធានារ៉ាប់រង B ចេញប្រាក់សងចំពោះភយន្តរាយមួយចំនួនតូច និង ខធានារ៉ាប់រង C ចេញប្រាក់សងចំពោះភយន្តរាយមួយចំនួនកាន់តែតូចថែមទៀត។ ខធានារ៉ាប់រង A ចេញប្រាក់សងដល់ភាគីដែលបានការធានារ៉ាប់រង លើគ្រប់ភយន្តរាយទាំងអស់ លើកលែងតែភយន្តរាយណាដែលគេបានចែងបញ្ជាក់យ៉ាងច្បាស់លាស់ថាមិនត្រូវសង។ ភយន្តរាយដែលគេមិនត្រូវសង ជារួមមាន ការខូចខាត ឬ ការបាត់បង់ដែលបណ្តាលមកពីការខ្ចប់ទំនិញ មិនត្រឹមត្រូវ ការសឹករេចតាមរយៈការប្រើប្រាស់ធម្មតា ការខាតបង់បណ្តាលមកពីការយឺតយ៉ាវ អសាធធនភាព (ភាពគ្មានប្រាក់សង) នៃក្រុមហ៊ុនធានារ៉ាប់រង ភាពដែលនាវាមិនអាចធ្វើនាវាចរណ៍បាន ប្រសិនបើអ្នកទិញ បណ្ណធានារ៉ាប់រងបានដឹង អំពីរឿងនេះសង្គ្រាម បដិវត្តន៍ កូដកម្មការងារ និង ការបិទពេងចក្របញ្ឈប់ការងារ។ ដោយសារតែភយន្តរាយដែលពាក់ព័ន្ធ នៅក្នុងកិច្ចសន្យាអន្តរជាតិ ជាការល្អ ភាគីនៃកិច្ចសន្យាគួរតែធ្វើយ៉ាងណាឱ្យបាននូវការធានារ៉ាប់រងចំពោះ «គ្រប់ភយន្តរាយទាំងអស់» ដូចជា បណ្ណធានារ៉ាប់រងដែលមានចែងនៅក្នុង ខធានារ៉ាប់រង A ជាដើម។

ខធានារ៉ាប់រង B ចេញប្រាក់សងដល់ភាគីដែលបានការ ធានារ៉ាប់រងតែលើភយន្តរាយជាក់លាក់ខ្លះៗប៉ុណ្ណោះ។ ភយន្តរាយទាំងនេះ ជារួមមានការខូចខាត ឬ ការបាត់បង់ដល់ទំនិញដែលបណ្តាលឡើងដោយអគ្គីភ័យ ឬ ការផ្ទុះការកឿងនាវា ការលិចនាវា ការក្រឡាប់នាវា ឬ ការកើលនាវា នាវាបុកគ្នា កម្លាំងធម្មជាតិដូចជាការរញ្ជួលដី ភ្នំភ្លើងផ្ទុះ ឬ កំផ្គររន្ទះ វិធានការដែលធ្វើឡើង ដើម្បីការពារនាវានិងនាវាកណ្តាលនោះ នៅក្នុងព្រឹត្តិការណ៍ដែលមានអាសន្ន ការទម្លាក់ទំនិញចោលដើម្បីសម្រាលនាវា ឬរលកសមុទ្របោកទំនិញធ្លាក់ចូលទៅក្នុងទឹក និងការខូចខាតដែលបណ្តាលមកពីទឹកសមុទ្រ។

ខធានារ៉ាប់រង C ចេញប្រាក់សងចំពោះភយន្តរាយមួយចំនួនតូច ។ ភយន្តរាយទាំងនេះជារួមមានការបាត់បង់ ឬ ការខូចខាតដល់ទំនិញដែលបណ្តាលមកពីអគ្គីភ័យ ឬ ការផ្ទុះ ការកឿងនាវា ការលិចនាវា ការកើលនាវា ឬ ការក្រឡាប់នាវា នាវាបុកគ្នា ការទម្លាក់ទំនិញចោលដើម្បីសម្រាលដល់នាវា និង ការដាក់ទំនិញចេញនៅឯកំពង់ផែដែលមានគ្រោះអាសន្ន។ ខធានារ៉ាប់រង A ខុសគ្នាពីខធានារ៉ាប់រង B និង ធានារ៉ាប់រង C តាមវិធីជាមូលដ្ឋានមួយ។ តាមសេចក្តីចែងនៃខធានារ៉ាប់រង A ប្រសិនបើទំនិញត្រូវខូចខាត ឬ បាត់បង់ដោយសារហេតុផលណាមួយ ដែលបណ្ណធានារ៉ាប់រងមិនបានចែង បញ្ជាក់យ៉ាងច្បាស់លាស់ថាមិនត្រូវបានប្រាក់ធានារ៉ាប់រង

ទេនោះ ពេលនោះក្រុមធានារ៉ាប់រង ត្រូវតែចេញប្រាក់សងទៅតាមការសន្យារបស់ខ្លួននៅក្នុងបណ្ណធានារ៉ាប់រង។ ក៏ប៉ុន្តែតាមសេចក្ដីចែងនៃខធានារ៉ាប់រង B និងខធានារ៉ាប់រង C ក្រុមហ៊ុនធានារ៉ាប់រងត្រូវចេញប្រាក់សងល្គឹកណាតែទំនិញត្រូវខូចខាតឬបាត់បង់ដោយសារគ្រោះថ្នាក់ (ភយន្តរាយ) ណាមួយ ដែលមានចែងបញ្ជាក់យ៉ាងច្បាស់លាស់នៅក្នុងកិច្ចសន្យាធានារ៉ាប់រងតែប៉ុណ្ណោះ។

ភាគីអាចទទួលបានផងដែរ នូវការធានារ៉ាប់រងលើភយន្តរាយដាច់ដោយឡែកៗពីគ្នា ដែលមិនមានចែងនៅក្នុងខធានារ៉ាប់រងជាស្តង់ដាទាំងនេះ។ ថ្វីបើខធានារ៉ាប់រងជាស្តង់ដាមិនបានចែងអំពីភយន្តរាយចំពោះការបាត់បង់ឬខូចខាតដល់ទំនិញដែលបង្កឡើងដោយសារសង្គ្រាម សង្គ្រាមស៊ីវិល ឬ ការប្រយុទ្ធគ្នារបស់ជនស៊ីវិលក៏ដោយ ក៏ភាគីអាចទទួលបាននូវការធានារ៉ាប់រងប្រភេទនេះ ប្រសិនបើភាគីមានបំណងបង់ថ្លៃឈ្នួលធានារ៉ាប់រងប្រភេទនេះ។ ឧទាហរណ៍ភាគីអាចប្រើបណ្ណសន្យាធានារ៉ាប់រងនៃគ្រឹះស្ថានធានារ៉ាប់រង សង្គ្រាមបានដែរ។ ភាគីក៏អាចទទួលបានផងដែរនូវការធានារ៉ាប់រងលើ ភយន្តរាយចំពោះការបាត់បង់ ឬ ខូចខាតដល់ទំនិញដែលបណ្ដាលមកពីជម្លោះការងារ ឬ អំពើភេរវកម្ម។

ក្រុមហ៊ុនធានារ៉ាប់រង គឺជាក្រុមហ៊ុនដែលផ្ដល់សេវាធានារ៉ាប់រងពោលគឺ ក្រុមហ៊ុននោះបានចុះកិច្ចសន្យា ទទួលប្រាក់កំរៃប្រចាំគ្រា ហៅថាបុព្វលាភរ៉ាប់រង ពីភាគីដែលសុំឱ្យមានការធានារ៉ាប់រង ដើម្បីសង ភាគីនេះនូវតម្លៃនៃគ្រោះខូចខាត ដែលកើតឡើងដោយថាហេតុ ចំពោះអ្វីដែលជាកម្មវត្ថុនៃការធានារ៉ាប់រង ដូចជា ទ្រព្យសម្បត្តិ, ជីវិត[12]។ល។

តាមការពិតការធានារ៉ាប់រងមានគ្រប់គ្រាន់ផងដែរសម្រាប់ទំនិញ ដែលត្រូវបានផ្ញើតាមមធ្យោបាយដឹកជញ្ជូនតាមសមុទ្រ។ មានទម្រង់ ខចែង ជាស្តង់ដាសម្រាប់ការដឹកជញ្ជូនទំនិញតាមផ្លូវអាកាសជារួមមាន ខធានារ៉ាប់រងមួយដែលប្រហាក់ប្រហែលគ្នា ទៅនឹងស្តង់ដាខធានារ៉ាប់រង A សម្រាប់ការដឹកជញ្ជូនទំនិញតាមសមុទ្រ។ ភាគីអាចទទួលបានផងដែរ នូវការធានារ៉ាប់រងលើការដឹកជញ្ជូនទំនិញ តាមផ្លូវថ្នល់ និង តាមផ្លូវដែក។

## ៨-គន្លឹះជាមូលដ្ឋានស្ដីពីការអនុវត្តកិច្ចសន្យាពាណិជ្ជកម្មអន្តរជាតិ

ជាសង្ខេបមុននឹងធ្វើកិច្ចសន្យាពាណិជ្ជកម្មអន្តរជាតិភាគីគប្បីស្វែងយល់ឱ្យបានប្រសើរ

[12] ហ៊ាន សាហ៊ីប និង ហ៊ីង ថូរ៉ាក់ស៊ីះ វចនានុក្រមបច្ចេកសព្ទសេដ្ឋកិច្ច បោះពុម្ពដោយរោងពុម្ពនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ភ្នំពេញ ឆ្នាំ២០០៣ ទំព័រ ៣៦៨-៣៦៩។

បំផុតអំពីអានុភាព**គតិយុត្ត**នៃកិច្ចសន្យា។ ភាគីគប្បីរកឱ្យបាននូវព័ត៌មានស្តីពីច្បាប់ ឬទីកន្លែងវិនិច្ឆ័យក្តីដែលពួកគេត្រូវទាក់ទិនជាមួយ ប៉ុន្តែមិនសូវដឹងច្បាស់អំពីច្បាប់នោះ។ ជាពិសេសភាគីគប្បីពិចារណាថា តើពួកគេចង់ជ្រើសរើសទីកន្លែងអព្យាក្រឹត្យដែរឬទេ ដើម្បីដោះស្រាយជម្លោះណាមួយ (ជ្រើសរើសទីកន្លែង) ហើយថាតើច្បាប់ណាដែលពួកគេចង់ ឱ្យចៅក្រមនៅកន្លែងនោះអនុវត្ត (ការជ្រើសរើសច្បាប់)។ ភាគីគប្បីធ្វើឱ្យប្រាកដផងដែរថា ពួកគេព្រមព្រៀងទៅលើអត្ថន័យ របស់វាក្យសព្ទពាណិជ្ជកម្មដែលប្រើក្នុងកិច្ចសន្យា ដូចជាប្រើវាក្យសព្ទពាណិជ្ជកម្មអន្តរជាតិ(INCOTERMS)។ ម្យ៉ាងទៀតភាគីគប្បីព្យាយាមធ្វើឱ្យប្រាកដថា ខចែងនៅក្នុងកិច្ចសន្យាមិនមានទំនាស់ជាមួយនឹងច្បាប់ក្នុងស្រុកនៃរដ្ឋ ដែលគេបំពេញកិច្ចការអាជីវកម្មនោះទេ។ ក្នុងករណីដែលមានមន្ទិលសង្ស័យចូរសុំយោបល់ផ្នែកច្បាប់។ បើយើងយល់ដឹងពីច្បាប់កិច្ចសន្យាពាណិជ្ជកម្មអន្តរជាតិច្បាស់លាស់ យើងហ៊ានពង្រីកពាណិជ្ជកម្មរបស់ពីលំដាប់ជាតិ ទៅជាអន្តរជាតិ និង ជួយបង្កើតការងារដល់មនុស្សមួយចំនួនធំ បង្កើនប្រាក់ចំណូលប្រចាំឆ្នាំរបស់ជាតិកាន់តែច្រើន។

ក្នុងនីតិកាលកន្លងទៅរាជរដ្ឋាភិបាលសម្រេចបាននូវសមិទ្ធផលធំៗ ជាច្រើនរួមមានៈ (១)ការធ្វើទំនើបកម្មក្របខណ្ឌច្បាប់ ពិសេសការអនុម័ត និង ការឱ្យប្រើនូវក្រមព្រហ្មទណ្ឌបន្ថែមលើក្រមសំខាន់ៗ ចំនួនបីផ្សេងទៀត គឺក្រមរដ្ឋប្បវេណី ក្រមនីតិវិធីរដ្ឋប្បវេណី និងក្រមនីតិវិធីព្រហ្មទណ្ឌ (២)ការបង្កើនការយល់ដឹង និងលើកកម្ពស់ការអនុវត្តច្បាប់តាមរយៈការអប់រំ ផ្សព្វផ្សាយនិងបណ្តុះបណ្តាលច្បាប់ដល់មន្ត្រីផ្តល់សេវាយុត្តិធម៌ និង មន្ត្រីអនុវត្តច្បាប់ពាក់ព័ន្ធផ្សេងទៀត (៣)ការកែលម្អប្រព័ន្ធតុលាការ តាមរយៈការពង្រឹងសមត្ថភាព និង ការទទួលខុសត្រូវវិជ្ជាជីវៈរបស់ចៅក្រម និងព្រះរាជអាជ្ញា (៤)ការផ្តល់មធ្យោបាយបន្ថែមទៀតដល់ស្ថាប័នតុលាការ តាមរយៈការបង្កើនថវិកាជាបណ្តើរៗ សម្រាប់វិស័យនេះ និង (៥)ការពង្រីក និង លើកកម្ពស់យន្តការនៃការដោះស្រាយវិវាទ ក្រៅប្រព័ន្ធតុលាការ តាមរយៈការដាក់ឱ្យដំណើរការមណ្ឌលសេវាកម្មយុត្តិធម៌ និង ការបង្កើតមជ្ឈមណ្ឌលជាតិនៃ មជ្ឈត្តការពាណិជ្ជកម្ម[13]។ ដើម្បីឱ្យកាន់តែច្បាស់លើកិច្ចការនេះ ខ្ញុំសូមបង្ហាញនូវក្រុមហ៊ុនធំៗនៅក្នុងពិភពលោក ដែលបាននឹង កំពុងធ្វើ

13 រាជរដ្ឋាភិបាលកម្ពុជា៖ យុទ្ធសាស្ត្រចតុកោណ ដើម្បី កំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព នៅកម្ពុជា ដំណាក់កាលទី៣ ភ្នំពេញ ឆ្នាំ២០១៣ ទំព័រ ៣៧-៣៨។

ពាណិជ្ជកម្មអន្តរជាតិអនុលោមទៅតាមច្បាប់កិច្ចសន្យាពាណិជ្ជកម្មអន្តរជាតិ។

## ៩-ក្រុមហ៊ុនធំដប់អនុវត្តច្បាប់កិច្ចសន្យាពាណិជ្ជកម្មអន្តរជាតិបានជោគជ័យ

ខាងក្រោមនេះគឺជា Top Ten នៃនាវាដឹកទំនិញធំៗ បំផុតនៅក្នុងពិភពលោក ដែលអាចផ្ទុកទំនិញបានចាប់ពីរាប់សែនតោន រហូតដល់រាប់លានតោន និង រកប្រាក់ចំណូលប្រចាំឆ្នាំបាន រហូតដល់ទៅខ្ទង់ពាន់លានដុល្លា[14]។

### ៩.១-ក្រុមហ៊ុន MAERSK AP Moller-MaersK Group របស់ប្រទេសហូឡង់




MAERSK គឺជាក្រុមហ៊ុនហូលឡង់ ដែលបានបង្កើតឡើងនៅក្នុងឆ្នាំ ១៩០៤ មានទីស្នាក់ការនៅក្នុងទីក្រុង កូផេនហាក (COPENHAGEN) ប្រទេសដាណឺម៉ាក។ ក្រុមហ៊ុននេះមាននាវាធំជាងគេបង្អស់ បាននិងកំពុងធ្វើប្រតិបត្តិការ ជាមួយប្រទេសចំនួន ១៣០ និង រកប្រាក់ចំណូលបានប្រមាណ ៦៧៩ ពាន់លានដុល្លាអាម៉េរិក ក្នុងមួយឆ្នាំ។ វាផ្តល់ការងារដល់មនុស្សចំនួន ៧៦ ០០០នាក់ និង អាចលើកដាក់ទំនិញបាន ៤ ១៧៦ ៥១៧ TEU។

### ៩.២-ក្រុមហ៊ុន Mediterranean Shipping Company S.A (MSC) របស់ប្រទេសស្វីស




ប្រតិបត្តិការពីទីក្រុងហ្សឺណែវ ប្រទេសស្វីស។ ក្រុមហ៊ុននេះប្រតិបត្តិការជាមួយកំពង់ផែចំនួន៥០០ លើផ្លូវពាណិជ្ជកម្មប្រមាណ២០០ នៅទូទាំងពិភពលោក។ វាបានផ្តល់ការងារជាង៧០ ០០០នាក់ និង រកប្រាក់ចំណូលបាន ២៨ ពាន់លានដុល្លាអាម៉េរិក ក្នុងមួយឆ្នាំ។

### ៩.៣-ក្រុមហ៊ុន China COSCO (COSCO Shipping) របស់ប្រទេសចិន




COSCO Shipping គឺជាក្រុមហ៊ុនរបស់ប្រទេសចិន ដែលមាននាវាជាង១០០០០ គ្រឿង ធ្វើប្រតិបត្តិការជាមួយកំពង់ផែជាង ១០០០ នៅទូទាំងពិភពលោក។ វាបានផ្តល់ការ

[14] http://www. ***top 10 biggest shipping companies in the world,***...// 12/2/2023

ចំនួន១៣០០០០ នាក់ និងរកប្រាក់ចំណូលបាន៧,២ ពាន់លានដុល្លាអាម៉េរិក ក្នុងមួយឆ្នាំ។

**៩.៤-ក្រុមហ៊ុន CMA CGM Group របស់ប្រទេសបារាំង**




CMA CGM Group គឺជាក្រុមហ៊ុនរបស់ប្រទេសបារាំង បានបង្កើតឡើងនៅក្នុងឆ្នាំ ១៩៧៨ មានទីស្នាក់ការនៅក្នុងទីក្រុង Marseille ប្រទេសបារាំង។ វាប្រតិបត្តិការតាមរយៈ១៦០ ក្រុមហ៊ុន៧៥៥ ភ្នាក់ងារ និង មានឃ្លាំងចំនួន៧៥០ វាបានផ្ដល់ការងារបានចំនួន ១១០ ០០០ នាក់ វាអាចលើកដាក់ទំនិញបាន ២ ៦៩៦ ៧១០ total TEU។

**៩.៥-ក្រុមហ៊ុន Hapag-Lloyd របស់ប្រទេសអាឡឺម៉ង់**




Hapag-Lloyd គឺជាក្រុមហ៊ុនរបស់ប្រទេសអាឡឺម៉ង់ ដែលធ្វើប្រតិបត្តិការពីទីក្រុង Hamburg។ ក្រុមហ៊ុននេះប្រតិបត្តិការជាមួយផែចំនួន៦០០ និង ជាមួយប្រទេសចំនួន១២៨ វាមានសមត្ថភាពផ្ទុកទំនិញបានចំនួន១ ៦៨៨ ៣៩៦ TEU និង ប្រើប្រាស់ផ្លូវពាណិជ្ជកម្មចំនួន១១៨ នៅទូទាំងពិភពលោក។ វាដឹកទំនិញឆ្លងកាត់ពីអាមេរិកខាងជើងអាម៉េរិកឡាទីន និង មជ្ឈឹមបូព៌ា។

**៩.៦-ក្រុមហ៊ុន** ONE (Ocean Network Express) **របស់ប្រទេសសឹង្ហបុរី**




ONE គឺជាក្រុមហ៊ុនមួយដែលបានបង្កើតឡើងនៅក្នុងឆ្នាំ២០១៨ មានទីស្នាក់ការនៅក្នុងប្រទេសសឹង្ហបុរី។ ក្រុមហ៊ុននេះមានសមត្ថភាពដឹកទំនិញបាន១ ៥៧៩ ៨៦៨ TEU និង ផ្ដល់ការងារ បានចំនួន១៤ ០០០ នាក់ វាគឺជាពាណិជ្ជកម្មរួមគ្នា (joint venture) រវាង ប្រទេសកូរ៉េខាងត្បូង (K-Line), (ប្រទេសជប៉ុន) ក្រុមហ៊ុន Nippon Yusen Kaisha, និងក្រុមហ៊ុន Mitsui OSK lines។ ហ៊ុននេះត្រូវបានគេចាត់ទុកថាជាក្រុមហ៊ុនវ័យក្មេងមួយ ដែលអាចរកប្រាក់ចំណូលប្រចាំឆ្នាំបានចំនួន២,៨៧ ពាន់លានដុល្លាអាម៉េរិក ។

**៩.៧-ក្រុមហ៊ុន EVERGREEN របស់ Taiwan**



EVERGREEN គឺជាក្រុមហ៊ុនមួយដែលបាននឹងកំពុងធ្វើជំនួញរវាង Far East និង ប្រទេសទាំងឡាយនៅក្នុងទ្វីបអាម៉េរិក ទ្វីបអឺរ៉ុបខាងជើង និង តំបន់មេឌីទែរ៉ានេខាងកើត។ ក្រុមហ៊ុន EVERGREEN មានទីស្នាក់ការធំនៅ Taiwan ក្រុមហ៊ុននេះមាននាវាដឹកទំនិញ( Container Ships) ជាង២០០ និងមានសមត្ថភាពផ្ទុក១ ៣០៣ ៤២០ TEU និង ធ្វើដំណើរទៅកាន់កំពង់ផែចំនួន២៤០ នៅទូទាំងពិភពលោក។

**៩.៨-ក្រុមហ៊ុន** YANG MING **របស់** Taiwan




YANG MING គឺជាក្រុមហ៊ុនមួយដែលបង្កើតឡើងនៅក្នុងឆ្នាំ១៩៧២ មានទីស្នាក់ការធំនៅ Taiwan។ ក្រុមហ៊ុននេះផ្តោតលើ International Logistics and Shipping Services វាធ្វើប្រតិបត្តិការជាមួយ៧០ ប្រទេស និង ចូលចតកំពង់ផែចំនួន១៧០ និងមានសមត្ថភាពផ្ទុកទំនិញបាន៧,៧៤ លានតោន។ ក្រុមហ៊ុននេះធ្វើប្រតិបត្តិការជាមួយប្រទេសហូឡង់ បែលហ្សិក សហរដ្ឋអាម៉េរិក និងតៃវ៉ាន់ ក្រុមហ៊ុននេះផ្តល់ការងារជាង៥០០០ នាក់ដល់មនុស្សម្នាទាំងឡាយ។

**៩.៩-ក្រុមហ៊ុន** Pacific International Lines (PIL) **របស់ប្រទេសសឹង្ហបុរី**




PIL គឺជាក្រុមហ៊ុនមួយដែលបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៦៧ និង មានទីស្នាក់ការនៅក្នុងប្រទេសសឹង្ហបុរី ក្រុមហ៊ុននេះមាននាវាដឹកទំនិញចំនួន១៥៣ ដែលបម្រើសេវានៅក្នុង៥០០ទីតាំងនៅក្នុងទ្វីបអាហ្វ្រិក ទ្វីបអាស៊ី មជ្ឈឹមបូព៌ា អូស្ត្រាលី ណូវែលហ្សេឡង់ ឥណ្ឌា អាម៉េរិកខាងជើង និង សមុទ្រខ្មៅ។ ក្រុមហ៊ុន PIL បានផ្តល់ការងារចំនួន១៨ ០០០នាក់ និង រកប្រាក់ចំណូលបាន៤,០៤ពាន់លានដុល្លាអាម៉េរិកក្នុងមួយឆ្នាំ។ វាមានសមត្ថភាពផ្ទុកទំនិញបាន៣៩៣ ៤៩៨ Total TEU។

**៩.១០-ក្រុមហ៊ុន** Hyundai Merchant Marine (HMM) **របស់ប្រទេសកូរ៉េខាងត្បូង**



HMM គឺជាក្រុមហ៊ុនមួយដែលបង្កើតឡើងនៅក្នុងឆ្នាំ១៩៧៦ មានទីស្នាក់ការនៅក្នុងទីក្រុងសេអ៊ូល ប្រទេសកូរ៉េខាងត្បូង។ ក្រុមហ៊ុននេះផ្តោតលើ International Shipping Solutions ដូចជាក្ញាស់សេទំនិញ, សម្ពួតទំនិញ ...។ល។ ក្រុមហ៊ុននេះបានរកប្រាក់ចំណូលបាន៤,៦ ពាន់លានដុល្លាអាមេរិកក្នុងមួយឆ្នាំ។ វាផ្តល់ការងារពី១២០០ នាក់ ដល់៥០០០ នាក់ និង អាចផ្ទុកទំនិញបាន៣៩២ ៣១៤ TEU ។

លោក ជាពិសេសការចេះ យល់ដឹងនូវច្បាប់ច្បាស់លាស់នោះវាគឺជាកូនសោរសម្រាប់ចាក់ចេញចូល ទៅក្នុងការធ្វើពាណិជ្ជកម្មអន្តរជាតិ ដើម្បីស្រូបយកប្រាក់ចំណេញ ដែលជាចំណូលប្រចាំឆ្នាំដ៏ក្រាស់ក្រែលបន្ថែមទៀតសម្រាប់ប្រទេសកម្ពុជា។

## សេចក្តីសន្និដ្ឋាន

សរុបសេចក្តីមកការអនុវត្តច្បាប់កិច្ចសន្យាពាណិជ្ជកម្មអន្តរជាតិ បានផ្តល់ឱ្យ ក្រុមហ៊ុនរូបវន្តបុគ្គល និង ក្រុមហ៊ុននីតិបុគ្គលជាតិ និងអន្តរជាតិមាននីតិសម្បទានិង នីត្យានុកូលភាព រឹងមាំតាមគតិយុត្ត ដែលកាន់តែជំរុញការធ្វើពាណិជ្ជកម្មអន្តរជាតិទាំងទ្វេភាគី និង ពហុភាគីឱ្យរីកចំរើនជាត់ពីមួយឆ្នាំទៅមួយឆ្នាំ ក្នុងនោះក្រុមហ៊ុននីមួយៗ អាចរកប្រាក់ចំណូលប្រចាំឆ្នាំ បានរាប់ពាន់លានដុល្លា និង បង្កើតការងារដល់មនុស្សជាតិរាប់ម៉ឺននាក់។ ទាំងនេះ គឺជាចក្ខុវិស័យសម្រាប់រៀបចំ អនុវត្ត និង ពង្រីកការធ្វើពាណិជ្ជកម្មអន្តរជាតិរបស់យើង ដោយឈរលើកត្តាសុខសន្តិភាព ស្ថិរភាពនយោបាយ ធនធានមនុស្ស ធនធានមូលធន ការចេះសមាហរណកម្មខ្លួន ចូលទៅក្នុងពិភព

**ឯកសារយោង**

១-ក្រសួងពាណិជ្ជកម្ម៖ ***ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម*** ធនាគារអភិវឌ្ឍន៍អាស៊ី ភ្នំពេញ ឆ្នាំ២០០៦។

២-សុក ស៊ីផាន់ណា, ***មគ្គុទេសក៍ពាណិជ្ជកម្មឆ្ពោះទៅរកប្រព័ន្ធពាណិជ្ជកម្មពិភពលោក*** បោះពុម្ពលើកទី២ មជ្ឈមណ្ឌលពាណិជ្ជកម្មអន្តរជាតិ ទីក្រុងហ្សឺណែវ ឆ្នាំ ១៩៩៩។

៣- ***វចនានុក្រមខ្មែរ ភាគទី១ និង ភាគីទី២*** ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ ឆ្នាំ ១៩៦៨។

៤-រាជរដ្ឋាភិបាលកម្ពុជា៖ ***ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣*** ភ្នំពេញ ឆ្នាំ ២០១៩។

៥-ទីស្តីការគណៈរដ្ឋមន្ត្រី៖ ***សទ្ទានុក្រមពាក្យច្បាប់ រដ្ឋប្បវេណី និង នីតិវិធីរដ្ឋប្បវេណី*** បោះពុម្ពលើកទី១ ភ្នំពេញ ឆ្នាំ ២០០៧។

៦-WTO, ***Trading into the Future***, World Trade Organizations, Geneva, 1995.

៧-WTO, ***Opening Markets for Trade in Services***, the University Press, Cambridge, 2008.

៨-The Asia Foundation, ***International Contract Law,*** International Printing House, Phnom Penh, 2001.

៩-Ministry of Commerce, http://www.moc.gov.kh 9 January,23.

១០-http://www.*top 10 biggest shipping companies in the world,*...// 12/2/2023

# ឧបសម្ព័ន្ធ

## ទី១




ផ្លូវដឹកជញ្ជូនតាមសមុទ្រ ដែលទាក់ទងទៅនឹងកំពង់ផែនៃប្រទេសសិង្ហបុរី

## ទី២




ផែនទីទិសដៅធ្វើដំណើររបស់នាវាតាមច្រកសមុទ្រសិង្ហបុរី

**ទី៣**




*កំពង់ផែរបស់ប្រទេសសឹង្ហបុរី*

**ទី៤**



*សកម្មភាពលើកដាក់ទំនិញ នៅកំពង់ផែក្រុងព្រះសីហនុ (១)*

**ទី៥**



*សកម្មភាពលើកដាក់ទំនិញ នៅកំពង់ផែក្រុងព្រះសីហនុ (២)*

**ទី៦**




*សកម្មភាពលើកដាក់ទំនិញ នៅកំពង់ផែក្រុងព្រះសីហនុ (៣)*

ទ្រឹស្តីផ្សារភ្ជាប់នឹងការអនុវត្ត ចងភ្ជាប់ដោយលទ្ធផល
ហើយត្រូវមានក្រមសីលធម៌វិជ្ជាជីវៈ